R E V

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃចិត្តសប្បុរស

O L U

ហ្គារី ឃីស៊ី

T I O N

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃចិត្តសប្បុរស

ហ្គារី ឃីស៊ី

R E V O L U T I O N

*បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃចិត្តសប្បុរស*

*រក្សាសិទ្ធិ © ២០២១ ដោយ ហ្គារី ឃីស៊ី (Gary Keesee)*

សម្រាប់សម្រង់ខគម្ពីរគឺបានដកស្រង់ចេញពីព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន ឆ្នាំ២០០៥ ដោយសមាគមព្រះគម្ពីរកម្ពុជា ©រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ២០០៥ - ដកស្រង់ដោយមានការអនុញ្ញាត។

សៀវភៅនេះត្រូវបានបោះពុម្ពនៅសហរដ្ឋអាមេរិក។ រក្សាសិទ្ធិគ្រប់យ៉ាងក្រោមច្បាប់ស្តីអំពីសិទ្ធិអ្នកនិពន្ធអន្តរជាតិ។ សម្រាប់មាតិកា និង/ឬក្របសៀវភៅនេះនឹងមិនត្រូវផលិតឡើងវិញទាំងស្រុង ឬតាមផ្នែកនៅក្នុងទម្រង់ណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគ្រឹះស្ថានបោះពុម្ពផ្សាយឡើយ។

លេខ ISBN: 978-1-945930-52-2

បោះពុម្ពផ្សាយដោយ Free Indeed Publishers ។

ធ្វើការចែកចាយដោយ Faith Life Now

Faith Life Now
P.O. Box 779
New Albany, OH 43054
1-(888)-391-LIFE

អ្នកអាចទំនាក់ទំនងទៅកាន់ព័ន្ធកិច្ច Faith Life Now តាមប្រព័ន្ធអ៊ីនធឺណិតតាមគេហទំព័រ www.faithlifenow.com

ប្រែសម្រួលជាភាសាខ្មែរដោយ៖ Anakot Translation & Consulting

# ការឧទ្ទិស

ខ្ញុំចង់ឧទ្ទិសសៀវភៅនេះជូនចំពោះឌ្រិនដា (Drenda) ជាភរិយារបស់ខ្ញុំ ដែលបានរៀបអាពាហ៍ពាហ៍ ៩០មកហើយ។ គាត់ជាមនុស្សដែលមានចិត្តសប្បុរសជាងគេដែលខ្ញុំធ្លាប់ស្គាល់។ គាត់តែងតែគិតពីអ្នកដទៃ ហើយបង្រៀនខ្ញុំជាច្រើនអំពីការស្រលាញ់ចំពោះមនុស្ស ជាអ្វីដែលខ្ញុំថ្លែងអំណរគុណចំពោះគាត់ជារៀងរហូត!

— ហ្គារី ឃីស៊ី

# បញ្ជីមាតិកា

សេចក្តីផ្តើម ........ 1

ជំពូក ១ អំណាចនៃចិត្តសប្បុរស ........ 11

ជំពូក ២ ចម្លើយ៖ ព្រះគុណ ........ 35

ជំពូក ៣  តើអ្នកមានលក្ខណសម្បត្តិ គ្រប់គ្រាន់ឬទេ? ........ 73

ជំពូក ៤ តើជាប្រាក់របស់នរណា? ........ 97

ជំពូក ៥ អ្នកត្រូវការដៃគូម្នាក់! ........ 119

ជំពូក ៦ អាថ៌កំបាំងនៃតង្វាយមួយភាគដប់ ........ 139

ជំពូក ៧ អ្នកត្រូវការកាបូបមួយ - ផ្នែកទីមួយ ........ 166

ជំពូក ៨ អ្នកត្រូវការកាបូបមួយ - ផ្នែកទី២ ........ 209

ជំពូក ៩ ច្បាប់អំពីរង្វាល់ ........ 225

ជំពូក ១០ ស្តេចដែលមានចិត្តសប្បុរស ........ 245

ជំពូក ១១ សេចក្តីសន្យាដល់អស់អ្នកដែលមានចិត្តសប្បុរស ........ 269

# សេចក្ដីផ្ដើម

ពេលព្រះជាម្ចាស់បានត្រាស់ហៅខ្រិនដា និងខ្ញុំឱ្យធ្វើកម្មវិធីទូរទស្សន៍ ខ្ញុំត្រូវតែទទួលស្គាល់ចេញពីចិត្តថា វាគឺជារឿងដ៏កំប្លែងបំផុត។ ខ្ញុំទើបតែត្រលប់មកពីប្រទេសអាល់បានី ដែលខ្ញុំបានបង្រៀនមេរៀនប្រាំវគ្គអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងប្រាប់ពួកគេថាខ្រិនដា និងខ្ញុំមានសេរីភាពពីបំណុល ដោយការអនុវត្តតាមច្បាប់នៃព្រះរាជ្យ។

ប្រសិនបើអ្នកបានអានសៀវភៅមុនៗរបស់ខ្ញុំ អ្នកមុខជាចាំរឿងអំពីអ័ព្ទពណិខៀវរបស់ព្រះជាម្ចាស់ អ្នកមុខជាចាំបានពីរបៀបដែលអ័ព្ទពណិខៀវនៃសិរីល្អរបស់ព្រះជាម្ចាស់គ្របដណ្ដប់បន្ទប់ទទួលភ្ញៀវរបស់បេសកជន នៅយប់ដែលយើងបង្រៀនវគ្គចុងក្រោយ។ នៅទីនោះហើយដែលព្រះជាម្ចាស់មានបន្ទូលមកខ្ញុំថា *«យើងត្រាស់ហៅអ្នកឱ្យចូលទៅកាន់ប្រជាជាតិជាច្រើន ដើម្បីបង្រៀនពីសម្ពន្ធមេត្រីរបស់យើង អំពីព្រះពរផ្នែកហិរញ្ញវត្ថុ ហើយគ្រប់កន្លែងដែលយើងបញ្ជូនអ្នកទៅ យើងគឺជាអ្នកចេញថ្លៃចំណាយ»*។

យប់នោះបានផ្លាស់ប្ដូរជីវិតខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនយល់ច្បាស់ទេនូវអ្វីដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំថា *«យើងត្រាស់ហៅអ្នកឱ្យចូលទៅកាន់ប្រជាជាតិជាច្រើន»*។

ពេលដែលខ្ញុំចាប់ផ្ដើមយល់ កម្មវិធីទូរទស្សន៍នេះហើយដែលព្រះអម្ចាស់បានគិតទុកក្នុងព្រះហឫទ័យទ្រង់។ ជាថ្មីម្ដងទៀត នោះមិនមែនជាអ្វីម្យ៉ាងដែលខ្ញុំគិតថានឹងធ្វើ ឬមានបំណងចង់ធ្វើទេ។ រឿងម្យ៉ាងដែលខ្ញុំដឹងច្បាស់គឺថា ខ្ញុំមានចំណង់ចំណូលចិត្តចង់ជួយមនុស្សឱ្យស្វែងរកអ្វីដែលខ្រិនដា និងខ្ញុំបានស្វែងរកឃើញនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

អស់រយៈពេល៨ឆ្នាំ ពួកយើងបានរស់នៅដោយជាប់បំណុលយ៉ាងធ្ងន់ធ្ងរ រស់នៅដោយសារការបញ្ចាំគ្រប់បែបយ៉ាង និងការតស៊ូយ៉ាងហត់នឿយជាមួយនឹងអាការៈស្លន់ស្លោ។ ថ្នាំបន្ធូរអារម្មណ៍ដែលគ្រូពេទ្យបានឱ្យខ្ញុំប្រើ មិនជួយអ្វីដល់ខ្ញុំសោះ។ ខ្ញុំឃើញថាខ្លួនខ្ញុំដកខ្លួនចេញពីជីវិត ហើយភាពងងឹតនៃភាពភ័យខ្លាច ហាក់ដូចជាជ្រៀតចូលគ្រប់ផ្នែកក្នុងគំនិតខ្ញុំ។ ភាពភ័យខ្លាចបានរួបរឹតខ្ញុំ ខ្ញុំធ្លាក់ខ្លួនដល់ថ្នាក់ភ័យខ្លាចរហូតមិនហ៊ានចេញពីផ្ទះ ហើយប្រាកដណាស់ថាខ្ញុំធ្វើការមិនបានល្អទេ នៅក្នុងអាជីវកម្មផ្នែកលក់របស់ខ្ញុំ។ យើងបានធ្លាក់ខ្លួនចូលក្នុងការក្ស័យធនយ៉ាងឆាប់រហ័ស ហើយខ្ញុំហាក់ដូចជាគ្មានអំណាចក្នុងការបញ្ឈប់វាទេ។ ជីវិតពេលនោះគឺរស់នៅក្នុងភាពអាម៉ាស់ ហើយខ្ញុំមានអារម្មណ៍ដូចមនុស្សបរាជ័យ។ អារម្មណ៍បរាជ័យដ៏ធំបំផុតគឺមានចំពោះភរិយាដ៏ល្អរបស់ខ្ញុំ និងកូនៗខ្ញុំ។ ក្រៅពីមិនបានផ្គត់ផ្គង់លុយដែលយើងត្រូវការហើយ ខ្ញុំក៏មិនមែនជាឪពុកដ៏ល្អម្នាក់ ឬជាស្វាមីដ៏ល្អម្នាក់បានទេក្នុងអំឡុងពេលនោះ។

យើងមានជីវិតរស់ ដោយរស់នៅក្នុងផ្ទះចម្ការចាស់ទ្រុឌទ្រោមសល់ពីខ្ទង់ឆ្នាំ១៨៥០ ជាកន្លែងដែលអ្វីៗគ្រប់យ៉ាងសុទ្ធតែបាក់បែក។ បង្អួចត្រូវបិទភ្ជាប់គ្នាដោយប្រើស្កុត។ កម្រាលព្រំក្នុងបន្ទប់គេងកូនប្រុសយើង គឺយើងរកបានពីគំនរសំរាមតាមផ្លូវ។ ឯតួយរបស់ពួកគេ គឺយកមកពីគំនររបស់របរដែលគេបោះចោល នៅផ្ទះថែទាំអ្នកជំងឺ។ ឡានដែលយើងបើក ជាឡានធ្វើឱ្យយើងអាប់មុខ ហើយជីវិតរបស់យើងពេញទៅដោយការទូរស័ព្ទចូលពីមេធាវី ក្រុមហ៊ុនកាតក្រេឌីត (Credit Card) និងក្រុមហ៊ុនផ្តល់ប្រាក់កម្ចីជាច្រើនដែលយើងជំពាក់លុយជាប់គ្នាហូរហែមិនដែលដាច់។

ខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង! មែនហើយ ខ្ញុំគឺជាគ្រិស្តបរិស័ទម្នាក់ដែលស្រលាញ់ព្រះជាម្ចាស់។ ខ្ញុំបានទៅក្រុមជំនុំ និងបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំមានបរិញ្ញាបត្រផ្នែកសម្ពន្ធមេត្រីចាស់ ហើយក៏មានបទពិសោធនៅសាលាព្រះគម្ពីរអស់រយៈពេលជាងមួយឆ្នាំដែរ ក៏ប៉ុន្តែមានអ្វីម្យ៉ាងខុស គឺខុសយ៉ាងខ្លាំង!

## សេចក្តីផ្តើម

ថ្ងៃមួយ ដោយភាពអស់សង្ឃឹម ខ្ញុំបានស្រែកអង្វររកព្រះជាម្ចាស់ ហើយភ្លាមៗនោះទ្រង់បានឆ្លើយតប។ មិនមែនមានន័យថា អំឡុងពេល៩ឆ្នាំនោះ ខ្ញុំមិនបានអធិស្ឋានទេ គឺខ្ញុំក៏បានអធិស្ឋានដែរ។ ប៉ុន្តែនៅលើកនេះ ខ្ញុំ*ដឹងថា*ខ្ញុំត្រូវការស្តាប់ឮទ្រង់។

ខ្ញុំអាចនិយាយបានថា រហូតមកទល់ពេលនោះ ខ្ញុំតែងតែគិតថាខ្ញុំអាចទាញខ្លួនឯងចេញពីរណ្តៅហិរញ្ញវត្ថុដែលខ្ញុំបានជីក ដោយការធ្វើអ្វីៗដោយកម្លាំងខ្លួនឯង។ ក៏ប៉ុន្តែនៅព្រឹកនោះខ្ញុំដឹងថា ខ្ញុំធ្វើលែងបានហើយ។ ខ្ញុំខ្ចីលុយពីមិត្តគ្រប់គ្នារបស់ខ្ញុំ ខ្ចីលុយរាប់ម៉ឺនដុល្លារពីក្រុមគ្រួសារខ្ញុំ ហើយខ្ញុំគ្មានផ្លូវណាអាចខ្ចីលុយបន្ថែមទៀតទេ។

ពេលដែលខ្ញុំអធិស្ឋាននៅព្រឹកនោះ ខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង ក៏ប៉ុន្តែខ្ញុំមានការភ្ញាក់ផ្អើលដែលខ្ញុំបានឮការឆ្លើយតបរបស់ទ្រង់យ៉ាងឆាប់រហ័ស។ ភ្លាមៗនោះនៅក្នុងវិញ្ញាណខ្ញុំ ខ្ញុំបានឮទ្រង់ដកស្រង់ខគម្ពីរ ភីលីព ៤:១៩ ប្រាប់ខ្ញុំថា ៖

> *ព្រះរបស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។*

ខ្ញុំបានប្រាប់ព្រះអម្ចាស់ថា «ព្រះអម្ចាស់ ខ្ញុំស្គាល់ខនោះ ក៏ប៉ុន្តែវាមិនកើតឡើងនៅក្នុងជីវិតខ្ញុំទេ»។ ទ្រង់មានបន្ទូលម្តងទៀត ហើយបានប្រាប់ខ្ញុំថា មូលហេតុដែលខ្ញុំស្ថិតក្នុងសភាពរញ៉េរញ៉ៃនោះ ដោយសារតែខ្ញុំមិនបានដឹងពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។ ខ្ញុំមិនយល់ពីអ្វីដែលទ្រង់មានបន្ទូលទេ ក៏ប៉ុន្តែគ្រិនដានិងខ្ញុំបានតាំងចិត្តថានឹងស្វែងយល់។

ខគម្ពីរមួយក្នុងចំណោមខគម្ពីរដែលព្រះជាម្ចាស់បានបង្ហាញយើងគឺនៅក្នុងគម្ពីរ លូកា ៦:២០ ៖

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

> *ព្រះយេស៊ូងើបព្រះភ័ក្ត្រទតមើលសិស្សរបស់ព្រះអង្គ ហើយមានព្រះបន្ទូលថា ៖ «អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ! អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់»។*

ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជាចម្លើយរបស់យើង?! ជាថ្មីម្តងទៀត យើងពិតជាមិនដឹងពីអ្វីដែលទ្រង់ចង់មានព្រះបន្ទូលទាល់តែសោះ ក៏ប៉ុន្តែយើងបានដឹងថាយើងត្រូវការធ្វើការស្វែងយល់។

យើងនឹងនិយាយបន្តទៀតពីព្រះរាជ្យក្នុងពេលបន្តិចទៀតនេះ ក៏ប៉ុន្តែខ្ញុំសូមប្រាប់អ្នករាល់គ្នាពីលទ្ធផលដែលបានកើតឡើង។

ព្រះវិញ្ញាណដ៏វិសុទ្ធចាប់ផ្តើមបង្ហាញយើងពីរឿងរ៉ាវនៅក្នុងព្រះគម្ពីរ ដែលយើងមិនធ្លាប់ឃើញពីមុនមក។ តាមរយៈការអនុវត្តអ្វីដែលព្រះអម្ចាស់បានបង្រៀនយើងពីព្រះរាជ្យ យើងអាចចាកចេញពីបំណុលទាំងស្រុង ក្នុងរយៈពេល២ឆ្នាំកន្លះ។ យើងចាប់ផ្តើមទិញឡានដោយលុយសុទ្ធ និងទិញដីទំហំជាង ២២ហិកតាដោយលុយសុទ្ធ និងដីដែលមានពេញទៅដោយដើមឈើស្រស់ស្អាត និងបឹងទំនាបដែលខ្ញុំអាចបរបាញ់បាន និងចិញ្ចឹមបីបាច់កូនៗខ្ញុំនៅក្នុងទីធ្លាដ៏ធំ។

ហើយអំណរដ៏ធំបំផុតនៅក្នុងជីវិតខ្ញុំ គឺការបានមើលឌ្រិនដា រចនា និងសាងសង់ផ្ទះក្នុងក្តីស្រមៃគាត់ ជាកម្មសិទ្ធិរបស់យើងដោយមិនជាប់បំណុលដូចគ្នាដែរ។

ក្រោយពីអ្វីដែលខ្ញុំធ្លាប់បានឆ្លងកាត់ និងក្រោយពីយើងបានឃើញរបៀបដែលព្រះរាជ្យមានដំណើរការ ដូចជាដំណើរការដែលប្រព្រឹត្តទៅក្នុងជីវិតយើង យើងរស់នៅក្នុងស្ថានភាពដែលមានការអបអរសាទរ*ជារៀងរាល់ថ្ងៃ* ។ ជាក់ស្តែង ពិធីជប់លៀងមិនទាន់បានបញ្ចប់ទេ។ យើងនៅតែអបអរសាទរចំពោះព្រះរាជ្យជារៀងរាល់ថ្ងៃ។ យើងបានចាកចេញពីការជីកកាយនៅក្រោមកម្រាលសាឡុង ដើម្បីរកមើលលុយពីរបីសេនទៅទិញអាហារដែលក្មេងៗចូលចិត្តសម្រាប់កូនៗយើង ចូលមកក្នុងការមានសេរី

ភាពពីបំណុល និងអាចមានលទ្ធភាពផ្ដល់លុយរាប់សែនដុល្លារដើម្បីជួយដល់ការផ្សាយដំណឹងល្អទៅជុំវិញពិភពលោក គឺពិតជាសមហេតុផលដែលយើងធ្វើការអបអរ។

ឌ្រិនដា និងខ្ញុំមានចិត្តឆេះឆួលយ៉ាងខ្លាំងអំពីការប្រាប់មនុស្សពីព្រះរាជ្យដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ នេះជាមូលហេតុដែលខ្ញុំទៅប្រទេសអាល់បានីតាំងពីដំបូង។

ដូចខ្ញុំបានរៀបរាប់មកហើយថា ពេលព្រះជាម្ចាស់មានបន្ទូលមកខ្ញុំនៅក្នុងប្រទេសអាល់បានីអំពីការធ្វើដំណើរទៅកាន់ប្រជាជាតិជាច្រើននោះ ខ្ញុំដូចជាមានភាពច្របូកច្របល់។ តើទ្រង់ចង់មានបន្ទូលពីអ្វី? ក្នុងពេលនោះខ្ញុំធ្វើការជាគ្រូគង្វាលនៅក្រុមជំនុំ ដែលឌ្រិនដា និងខ្ញុំបានចាប់ផ្ដើមឡើងកាលពី១០ឆ្នាំមុន។ តើមានន័យថាខ្ញុំត្រូវលាឈប់ពីក្រុមជំនុំ ហើយត្រូវធ្វើដំណើរវិញមែនឬទេ?

តាមរយៈសេចក្ដីណែនាំដែលព្រះជាម្ចាស់បានប្រទានមក ឌ្រិនដា និងខ្ញុំត្រូវបានគេណែនាំឱ្យស្គាល់មនុស្សដែលកំពុងធ្វើកម្មវិធីទូរទស្សន៍ និងក្រុមហ៊ុនជាច្រើនដែលធ្វើការងារផលិតកម្មវិធីទូរទស្សន៍។ មិនមែនមានន័យថាខ្ញុំទៅស្វែងរកពួកគេទេ ព្រះជាម្ចាស់គ្រាន់តែនាំពួកគេដើររួមផ្លូវជាមួយយើងតែប៉ុណ្ណោះ។ ខ្ញុំសូមប្រាប់ម្ដងទៀតថា ខ្ញុំមិនចាប់អារម្មណ៍ធ្វើកម្មវិធីទូរទស្សន៍ទាល់តែសោះ ក៏ប៉ុន្តែខ្ញុំបានចងចាំពីនិមិត្តរបស់ខ្ញុំកាលពីប៉ុន្មានឆ្នាំមុន។ ខ្ញុំកំពុងអធិស្ឋាននៅក្នុងវេនថ្វាយបង្គំមួយរបស់យើង ពេលនោះព្រះអម្ចាស់មានបន្ទូលប្រាប់ខ្ញុំភ្លាមៗថា ខ្ញុំនឹងធ្វើកម្មវិធីទូរទស្សន៍ និងកម្មវិធីវិទ្យុ។ ខ្ញុំមិនបានគិតអ្វីច្រើនពីវាទេ ដោយសារតែខ្ញុំពិតជាមិនចាប់អារម្មណ៍ក្នុងការធ្វើកម្មវិធីណាមួយទេក្នុងពេលនោះ ក៏ប៉ុន្តែវាធ្វើឱ្យខ្ញុំយកចិត្តទុកដាក់បន្តិច ហើយខ្ញុំបានប្រាប់ឌ្រិនដាពីរឿងនេះ។

និយាយដោយខ្លីទៅ ព្រះជាម្ចាស់បានបើកទ្វារដ៏អស្ចារ្យ និងបាននាំមនុស្សដ៏អស្ចារ្យមកដើររួមផ្លូវជាមួយយើង ដែលបានលើកទឹកចិត្តយើងឱ្យធ្វើកម្មវិធីទូរទស្សន៍ ក៏ប៉ុន្តែយើងមិនចេះអ្វីសោះទាក់ទងនឹងកម្មវិធីទូរទស្សន៍។ *ពេលដែលខ្ញុំប្រាប់ថាមិនចេះ*

*អ្វីសោះ ខ្ញុំចង់មានន័យថាគឺមិនចេះសោះមែន។* ក៏ប៉ុន្តែយើងមានអារម្មណ៍ថា យើងត្រូវការបន្តដើរតាមអ្វីដែលព្រះជាម្ចាស់បានបង្ហាញដល់យើង។

យើងគ្មានឧបករណ៍បរិក្ខារទេ ហើយមិនទាំងដឹងថាតើយើងត្រូវការបរិក្ខារអ្វីខ្លះ ដើម្បីធ្វើកម្មវិធីទូរទស្សន៍ទេ ក៏ប៉ុន្តែមនុស្សដែលព្រះជាម្ចាស់បាននាំមកជួយយើងដឹងពីរឿងនេះ។ ទីបំផុត យើងបានឈានចូលមកដល់ពេលដែលយើងត្រូវធ្វើការសម្រេចចិត្ត។ ក្រុមហ៊ុនផលិតកម្មវិធីទូរទស្សន៍មួយបានផ្ដល់កុងត្រាមួយដល់យើងឱ្យធ្វើកម្មវិធីទូរទស្សន៍ក្នុងអត្រាបញ្ចុះតម្លៃ។ ការរាប់បញ្ចូលទាំងពេលវេលាចាក់ផ្សាយ និងចំណាយទាំងអស់ដែលពាក់ព័ន្ធដើម្បីចាប់ផ្ដើមកម្មវិធីទូរទស្សន៍ យើងគិតឃើញថាវាអាចនឹងចំណាយខ្ទង់ ៣០០.០០០ដុល្លារ។ កាលនោះយើងគ្មានលុយដល់ទៅ ៣០០.០០០ដុល្លារទេ។ ក៏ប៉ុន្តែក្រោយពីយើងអធិស្ឋានអំពីកិច្ចការនេះ និងតវ៉ាជាមួយព្រះជាម្ចាស់អំពីរឿងនេះ នៅទីបំផុតខ្ញុំក៏យល់ព្រម។ (ជាការពិតណាស់អ្នកគ្មានថ្ងៃឈ្នះក្នុងការប្រកែកតវ៉ាជាមួយព្រះជាម្ចាស់ទេ)។

ដូច្នេះក្រុមហ៊ុនផលិតកម្មវិធីទូរទស្សន៍បានចូលមកទីក្រុង (ការិយាល័យពួកគេមានទីតាំងនៅរដ្ឋតិចសាស់ ហើយយើងចាប់ផ្ដើមថតកម្មវិធីទូរទស្សន៍ដំបូងរបស់យើង។ ដោយសារតែយើងគ្មានទីតាំងថត យើងគ្រាន់តែថតកម្មវិធីរបស់យើងមួយឆ្នាំពេញនៅក្នុងបន្ទប់ទទួលភ្ញៀវ ខាងមុខឡកម្ដៅ។ បើនិយាយថាខ្ញុំភ័យក្នុងពេលថតកម្មវិធីវគ្គដំបូង វាដូចជាមិនទាន់គ្រប់គ្រាន់ទេ។ ខ្ញុំមិនដឹងថាត្រូវរំពឹងចង់បានអ្វីទេ។ ហើយមិនមែនគ្រាន់តែការថតកម្មវិធីទូរទស្សន៍ជាក់ស្ដែងទេ ដែលធ្វើឱ្យខ្ញុំថប់បារម្ភ។ ខ្ញុំត្រូវការត្រៀមខ្លឹមសារទាំងអស់ ហើយនិយាយរួមទៅត្រូវដាក់កម្មវិធីទាំងមូលចូលគ្នា រួមជាមួយនឹងការចូលរួមគំនិតពីឌ្រិនដាផងដែរ។ ក្រុមអ្នកផលិតកម្មវិធីផ្ដល់យោបល់ដ៏ល្អដល់យើង និងបានបង្ហាត់បង្ហាញយើង ក៏ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍មិនស្រណុកចិត្ត។

## សេចក្ដីផ្ដើម

សូមយល់ថាធម្មជាតិរបស់ខ្ញុំ មិនមែនជាមនុស្សរួសរាយទេ ហេតុដូច្នេះហើយ សម្រាប់ខ្ញុំ ការធ្វើកម្មវិធីទូរទស្សន៍ គឺមិនស្ថិតនៅក្នុងលក្ខខណ្ឌស្រណុកចិត្តរបស់ខ្ញុំទាំងស្រុងតែម្ដង។ ក្រៅពីនេះ ក្រុមអ្នកផលិតកម្មវិធីមានទុក្ខព្រួយយ៉ាងខ្លាំងក្នុងថ្ងៃថតកម្មវិធីនោះ។ អ្នកដឹកនាំក្រុមបានចេញទៅទាំងយប់ ដោយសារតែកូនប្រុសតូចរបស់គាត់បានស្លាប់ ព្រោះតែត្រូវឡានអ្នកជិតខាងបុកនៅក្នុងផ្លូវបើកបរ។ ពួកគេបានប្រាប់ខ្ញុំពីរឿងនោះនៅពេលព្រឹកមុនពេលថតកម្មវិធី។ ខ្ញុំបានសម្រេចចិត្តថាមិនប្រាប់ឌ្រិនដារហូតដល់ពេលថតចប់។ ពិតជាពិបាកមែនក្នុងធ្វើបែបនោះ។

បន្ទាប់មក ភ្លាមៗក្រោយពីការថតកម្មវិធី បុគ្គលិកម្នាក់របស់យើងបានជិះម៉ូតូត្រៃរបស់កូនប្រុសខ្ញុំឈ្មោះ ធីម ហើយដួល។ ធីមបានរត់ចូលមកក្នុងផ្ទះ ទាំងស្រែកថា ដេវីឌស្លាប់ហើយ។ ការពិតគាត់មិនស្លាប់ទេ គ្រាន់តែសន្លប់ ប៉ុន្តែការចាប់ផ្ដើមដំបូងពិតជាពិបាកណាស់។

យើងបានឆ្លងផុតពេលវេលាថតកម្មវិធីមួយសប្ដាហ៍ ហើយកម្មវិធីទូរទស្សន៍បានចាក់បញ្ចាំងក្នុងស្ថានីយទូរទស្សន៍ក្នុងតំបន់មួយ។ យើងបានបន្តថតកម្មវិធីមួយសប្ដាហ៍ក្នុងមួយខែ ក៏ប៉ុន្តែនៅចុងបញ្ចប់នៃខែទីពីរ អ្វីៗហាក់ដូចជាមិនប្រសើរឡើងសោះ ហើយខ្ញុំបានជាប់គាំងនៅក្នុងអារម្មណ៍ថាមិនស័ក្តិសម និងភ័យស្លន់ស្លោក្នុងពេលតែមួយ។ ទីបំផុត ខ្ញុំក៏ប្រាប់ទៅម្ចាស់ក្រុមហ៊ុនផលិតកម្មវិធីថា ខ្ញុំមិនអាចធ្វើវាបានទៀតទេ។ គាត់សម្លឹងមុខខ្ញុំមួយស្របក់ ហើយនិយាយថា «ទេ! លោកត្រូវតែធ្វើកម្មវិធីទូរទស្សន៍!»

បន្ទាប់មកគាត់ប្រាប់ខ្ញុំឱ្យអង្គុយចុះ ដោយសារតែគាត់ចង់បង្ហាញអ្វីម្យ៉ាងដល់ខ្ញុំ។ គាត់បានបើកទូរទស្សន៍ និងប្ដូរទៅប្ដុកប៉ុស្តិ៍ទូរទស្សន៍គ្រិស្តបរិស័ទ។ និយាយដោយត្រង់ទៅ ខ្ញុំមិនដែលមើលកម្មវិធីទូរទស្សន៍គ្រិស្តបរិស័ទច្រើនទេ ក៏ប៉ុន្តែអ្វីដែលខ្ញុំ

ឃើញថ្ងៃនោះ ធ្វើឱ្យខ្ញុំធុញទ្រាន់ និងធ្វើឱ្យខ្ញុំគិតម្តងទៀត សូម្បីតែការចូលរួមជាមួយកម្មវិធីទូរទស្សន៍គ្រិស្តបរិស័ទក៏ដោយ។

នៅក្នុងកម្មវិធីមួយ ពួកគេកំពុងតែលក់ «ប្រេងអូលីវដ៏វិសុទ្ធ» ដែលពួកគេប្រកាសថានឹងនាំការចាក់ប្រេងតាំងកាន់តែអស្ចារ្យទៅកាន់ភាពចម្រុងចម្រើន។ នៅក្នុងកម្មវិធីមួយផ្សេងទៀត អ្នកអធិប្បាយកំពុងតែលក់ «នំផ្អែម (Wafer) ដែលបានចាក់ប្រេងតាំង» ដោយនិយាយថា អ្នកនឹងទទួលបានការបើកសម្តែងថ្មីនៅគ្រប់ម៉ាត់ដែលអ្នកទទួលទាន។ នៅក្នុងកម្មវិធីទូរទស្សន៍មួយទៀត ខ្ញុំបានឮថាប្រសិនបើអ្នកថ្វាយតង្វាយក្នុងពេលបីនាទីអ្នកនឹងទទួលបានការចាក់ប្រេងតាំងទៅរកភាពចម្រុងចម្រើនដល់ទៅបីដង។ នៅក្នុងកម្មវិធីមួយទៀត មានការផ្តល់អាហារសម្ងួតត្រជាក់។ នៅក្នុងកម្មវិធីទូរទស្សន៍នីមួយៗហាក់ដូចជាផ្តល់ឱ្យនូវអំណោយលើកទឹកចិត្តចម្លែកៗ ដើម្បីឱ្យមនុស្សថ្វាយតង្វាយ។

ក៏ប៉ុន្តែចំណុចដែលនៅខ្វះចន្លោះដែលខ្ញុំសម្គាល់ឃើញ គឺថាគ្មានកម្មវិធីណាមួយប្រាប់មនុស្សពីរបៀបទទួលបានអ្វីដែលពួកគេចង់បាន និងរបៀបដែលព្រះរាជ្យមានដំណើរការពិតប្រាកដទេ។ កម្មវិធីទាំងនោះប្រាប់ពួកគេ ថាពួកគេត្រូវដាំគ្រាប់ពូជ ក៏ប៉ុន្តែខ្ញុំដឹងថានរណាម្នាក់ត្រូវការប្រាប់មនុស្សពីរបៀប *ច្រូតផល* គ្រាប់ពូជនោះ!

មានរឿងជាច្រើនផ្នែកដែលមនុស្សត្រូវរៀន ប្រសិនបើពួកគេចង់ទៅរកភាពជោគជ័យ។ ដោយគ្រាន់តែបង្រៀនមនុស្សយ៉ាងសាមញ្ញពីរបៀបឱ្យ ហើយមិនដឹងពីការច្រូតផល ខ្ញុំដឹងថាមនុស្សនឹងប្រែជាខកបំណងនឹងព្រះជាម្ចាស់ ហើយគិតថាទ្រង់បានធ្វើឱ្យពួកគេខកចិត្ត ពេលដែលអ្វីមិនកើតឡើងតាមរបៀបដែលពួកគេរំពឹងទុក។

មនុស្សត្រូវការស្គាល់ពីច្បាប់របស់ព្រះរាជ្យ ហើយមូលហេតុដែលការឱ្យគឺជាផ្នែកមួយដ៏សំខាន់នៃការដើរនៅក្នុងភាពបរិបូរហូរហៀររបស់ព្រះរាជ្យ នៅក្នុងតពផែនដីនេះ។ ជាថ្មីម្តងទៀត អ្វីដែលកាន់តែសំខាន់ ពួកគេត្រូវការដឹងពីអ្វីដែលត្រូវធ្វើ *ក្រោយពី*

ពួកគេថ្វាយហើយ។ ពួកគេត្រូវការដឹងពីរបៀបច្រូតផលនូវអ្វីដែលពួកគេត្រូវការពីព្រះជាម្ចាស់។

ខ្ញុំស្វែងរកឃើញថា មានតួនាទីរបស់ខ្ញុំដែលត្រូវបំពេញនៅក្នុងការច្រូតផលជាដំបូងគឺត្រូវតែរៀនពីអ្វីទៅជាជំនឿ ហើយហេតុអ្វីត្រូវការមានជំនឿ។ ខ្ញុំត្រូវការរៀនពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំខ្ញុំទៅរកការច្រូតផល និងសារៈសំខាន់នៃពេលវេលាត្រឹមត្រូវ ហើយនិងរឿងលម្អិតរបស់ការច្រូតផលរបស់ខ្ញុំ។ ខ្ញុំស្វែងរកឃើញថាមានច្បាប់ខាងវិញ្ញាណដែលត្រូវការរៀន និងយកមកអនុវត្ត ក៏ដូចជាច្បាប់បញ្ញត្តិគ្រប់គ្រងក្នុងពិភពធម្មតាដែលនឹងប៉ះពាល់ដល់ការច្រូតផលដែរ។

កម្មវិធីទាំងអស់នេះធ្វើឱ្យយើងស្ដាប់ទៅដូចជាលុយនឹងគ្រាន់តែលេចមកក្នុងប្រអប់សំបុត្រអ្នកយ៉ាងដូច្នោះដែរ។

ខ្ញុំនឹងយល់ស្របថាជួនកាលវា*លេចមក*ក្នុងប្រអប់សំបុត្រមែន ប៉ុន្តែបើអ្នកពិនិត្យទៅករណីនោះឱ្យច្បាស់លាស់ អ្នកនឹងរកឃើញតម្រុយខាងវិញ្ញាណថាហេតុអ្វីហើយតើវាបង្ហាញខ្លួនឡើងមកដោយរបៀបណា។

បន្ទាប់ពីមើលកម្មវិធីពីរបីនេះមក ខ្ញុំខ្មាសអៀនណាស់ចំពោះអ្វីដែលខ្ញុំបានឃើញនោះ។ គ្មានអ្វីគួរឱ្យឆ្ងល់ទេថា ហេតុអ្វីបានជាមនុស្សមិនចាប់អារម្មណ៍ពីកម្មវិធីទាំងនោះ។ ក៏ប៉ុន្តែខ្ញុំក៏ខឹងដែរ។ ខ្ញុំដឹងក្នុងពេលនោះថា គេត្រូវការខ្ញុំ នឹងដឹងថាខ្ញុំមានរឿងត្រូវនិយាយ។

ខ្ញុំបានសម្រេចចិត្តបន្តធ្វើកម្មវិធីទូរទស្សន៍ ដោយសារតែខ្ញុំមានរឿងដែលខ្ញុំចង់និយាយប្រាប់។ ហើយខ្ញុំបានបន្តធ្វើកម្មវិធីទូរទស្សន៍មកទល់ពេលនេះគឺ ១៥ឆ្នាំហើយ ហើយខ្ញុំបានឃើញមនុស្សរាប់ម៉ឺននាក់បានស្វែងរកឃើញព្រះរាជ្យ ហើយពួកគេទទួលបានលទ្ធផលដូចគ្នា ដូចខ្រិនដា និងខ្ញុំបានទទួលដែរ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំដឹងថាអ្នកនឹងមានលទ្ធផលដូចគ្នាដែរ។

សៀវភៅ *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក ៖ អំណាចនៃចិត្តសប្បុរស* នេះគឺជាសៀវភៅទីប្រាំ និងជាសៀវភៅចុងក្រោយនៅក្នុងស៊េរីសៀវភៅ បដិវត្តន៍ហិរញ្ញវត្ថុ របស់ខ្ញុំ។ ខ្ញុំមានចិត្តរំភើបណាស់អំពីស៊េរីសៀវដែលបានបញ្ចប់នេះ ហើយខ្ញុំមានចិត្តរំភើបចំពោះសៀវភៅចុងក្រោយនេះដែរ។

—ហ្គារី ឃីស៊ី

# ជំពូក ១
# អំណាចនៃចិត្តសប្បុរស

គ្រួសាររបស់យើងកំពុងទទួលទានអាហារពេលល្ងាចនៅយប់មួយក្នុងភោជនីយដ្ឋានក្នុងតំបន់ដែលយើងចូលចិត្តជាងគេមួយ។ មានអ្នករត់តុជាស្ត្រីវ័យក្មេងម្នាក់ ដែលមានផ្ទៃពោះជិតសម្រាលកូន។ ពេលខ្ញុំរៀបចេញលុយ ខ្ញុំស្រាប់តែមានអារម្មណ៍ថាមានការដឹកនាំឱ្យខ្ញុំឱ្យធីបគាត់ច្រើនជាង ២២-២៥% ដែលខ្ញុំតែងតែឱ្យ ដូច្នេះខ្ញុំបានបន្ថែមលុយ ១០០ដុល្លារពីលើចំនួនលុយធីប។ គាត់បានទទួលយកវិក្កយបត្រកាតវីសា ដោយមិនមើលវាទេ ហើយក៏ដើរទៅផ្ទះបាយ។

មួយនាទីក្រោយមក គាត់ត្រលប់មកវិញ ទាំងទឹកភ្នែកស្រក់លើថ្ពាល់។ គាត់ត្រលប់មកវិញដើម្បីអរគុណយើង។ គាត់បានប្រាប់ពួកយើងពីស្ថានភាពតឹងតែងផ្នែកហិរញ្ញវត្ថុរបស់គាត់ ហើយកំពុងតែមិនដឹងត្រូវធ្វើដូចម្តេចដើម្បីអាចដោះស្រាយបាន។ យើងមានឱកាសក្នុងការចែករំលែកពីព្រះគ្រិស្តជាមួយគាត់ និងអធិស្ឋានឱ្យគាត់មុនពេលយើងចាកចេញ។

យើងមិនបានធ្វើអ្វីទេ គ្រាន់តែមានចិត្តសប្បុរស ដើម្បីបើកទ្វារនៃព័ន្ធកិច្ចចំហទៅកាន់ដួងចិត្តគាត់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

*ឬមួយអ្នកមើលងាយព្រះហឫទ័យសប្បុរស ព្រះហឫទ័យយោគយល់ និងព្រះហឫទ័យអត់ធ្មត់ដ៏ទូលំទូលាយរបស់ព្រះអង្គ! តើអ្នកមិនទទួលស្គាល់ថា ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសដូច្នេះ ដើម្បីជំរុញអ្នកឱ្យ**កែប្រែចិត្តគំនិតទេឬ**?*

—រ៉ូម ២:៤

ព្រះគម្ពីរបរិសុទ្ធ សម្រាប់គម្ពីររ៉ូម ២:៤ ចែងថា សេចក្តីសប្បុរសនៃព្រះទាញនាំឱ្យអ្នកបានប្រែចិត្តគំនិត។

## ការមានចិត្តសប្បុរស គឺជាការប្រព្រឹត្តដូចព្រះជាម្ចាស់

ព្រះគម្ពីរម៉ាថាយ ៥:៤៥ ចែងថា៖

*ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្ររបស់ព្រះបិតាដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គប្រទានឱ្យព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺ ទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយព្រះអង្គប្រទានទឹកភ្លៀងឱ្យទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ។*

ព្រះជាម្ចាស់ទ្រង់ល្អ ហើយទ្រង់សប្បុរស! យើងគឺជាបុត្ររស់ទ្រង់ ហើយលក្ខណៈថ្មីរបស់យើងនៅក្នុងព្រះគ្រិស្ត គឺលក្ខណៈមួយនៃការមានចិត្តសប្បុរសដូចគ្នាដែរ។ ដូចជានៅក្នុងរឿងខាងលើនេះ ការមានចិត្តសប្បុរស គឺការចែករំលែកដួងចិត្តរបស់ព្រះជាម្ចាស់ជាមួយមនុស្ស។ ដូចជាការក្រេបទឹកត្រជាក់នៅថ្ងៃដ៏ក្តៅដែរ ការមានចិត្តសប្បុរសនាំមកនូវភាពធូរស្បើយចិត្ត និងក្តីសង្ឃឹមទៅកាន់ពិភពលោកដែលកំពុងនៅក្នុងវាលរហោស្ថាននៃភាពក្រីក្រ។

ផលជះពីការឱ្យដោយឥតមានការហាមឃាត់ មានបង្ហាញយ៉ាងច្បាស់នៅក្នុងសេចក្តីណែនាំរបស់លោកប៉ូល ក្នុងគម្ពីរ ២ កូរិនថូស ៩:១០-១៥ ដែលបានសរសេរផ្ញើទៅក្រុមជំនុំក្នុងក្រុងកូរិនថូស ៖

*ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» ព្រះអង្គក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្ដីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ ដោយយើងជួយគេ ដ្បិតមុខងារប្រមូលប្រាក់នេះមិនត្រឹមតែជួយផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែមទាំងជួយគេឱ្យអរព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើងទៀតផង។ ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះបងប្អូនសម្ដែងឱ្យគេឃើញថា បងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អរបស់ព្រះគ្រិស្តដែលបងប្អូនប្រកាស ហើយបងប្អូនមានចិត្តទូលាយ ដោយយករបស់របរមកចែកជាមួយពួកគេ និងជាមួយមនុស្សទាំងអស់។ <u>គេទូលអង្វរព្រះជាម្ចាស់ឱ្យបងប្អូនដោយចិត្តស្រឡាញ់ ព្រោះតែព្រះគុណដ៏ច្រើនលើសលុបដែលព្រះជាម្ចាស់ប្រទានមកបងប្អូន។ សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គ រកថ្លែងពុំបាន!</u>*

ចិត្តសប្បុរសរបស់អ្នក ធ្វើឱ្យមនុស្សសរសើរតម្កើង និងអរព្រះគុណព្រះជាម្ចាស់!!! សូមចំណាំអ្វីដែលលោកប៉ូលនិយាយថា ការមានចិត្តសប្បុរសគឺជា *ការបម្រើ* ព្រះជាម្ចាស់របស់អ្នក។

និយមន័យនៃពាក្យថាបម្រើគឺ៖ *ការធ្វើកិច្ចការ ឬបំពេញភារកិច្ច ឱ្យអ្នកដែលមានអំណាចជាងម្នាក់ក្នុងនាមជាអ្នកបម្រើ។*[1]

[1] *វចនានុក្រមភាសាអង់គ្លេស* American Heritage *កំណែលើកទីប្រាំ*

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

វាគឺជាផ្នែកមួយនៃកាតព្វកិច្ចរបស់អ្នក ជាតំណាងព្រះជាម្ចាស់នៅក្នុងពិភពលោកនេះ ដើម្បីចែករំលែកដួងចិត្ត និងក្តីបារម្ភរបស់ទ្រង់ចំពោះមនុស្ស។ មានលទ្ធផលពិតប្រាកដ វាប៉ះពាល់ដល់ដួងចិត្តមនុស្ស និងបើចំហចិត្តពួកគេដើម្បីទទួលព្រះគ្រិស្ត។

ខ្ញុំគិតថាយើងទាំងអស់គ្នាអាចចងចាំបានពេលមាននរណាម្នាក់មកជួយយើងក្នុងគ្រាលំបាក និងចាំបានថាវាមានតម្លៃប៉ុណ្ណាសម្រាប់យើង។

ខ្ញុំនៅចាំបានថាខ្ញុំជំពាក់បំណុលពន្ធចំនួន ៥.០០០ ដុល្លារ ពេលទើបតែរៀបការរួចដំបូងៗ ហើយខ្ញុំមិនដឹងទេថាត្រូវទៅរកលុយមកពីណា។ ខ្ញុំគេងមិនលក់អស់ពេលជាច្រើនយប់ ដោយភ័យខ្លាចចំពោះស្ថានភាពដែលរបស់ខ្ញុំក្នុងពេលនោះ។ ពេលនោះយើងរស់នៅក្នុងទីក្រុងធុលសា និងមានគម្រោងទៅលេងនៅអូហៃយ៉ូ ក្នុងថ្ងៃវិស្សមកាល។

ពេលឪពុកខ្ញុំសួរថាខ្ញុំសុខសប្បាយទេ ខ្ញុំបានប្រាប់គាត់ពីការជំពាក់បំណុលពន្ធអាករ (IRS)។ គាត់បាននិយាយថា «បញ្ហានេះងាយស្រួលដោះស្រាយទេ» ហើយគាត់បានទាញមូលប្បទានបត្រមួយសន្លឹកមកសរសេរចំនួនលុយទាំងអស់នោះ ហើយហុចមកឱ្យខ្ញុំ។ ចិត្តសប្បុរសរបស់គាត់ចំពោះខ្ញុំក្នុងខណៈពេលនោះ បានធ្វើឱ្យខ្ញុំស្រលាញ់ឪពុកខ្ញុំកាន់តែខ្លាំងជាងមុន។ ដោយសារតែនៅពេលនោះខ្ញុំបានឃើញដួងចិត្តរបស់គាត់ចំពោះខ្ញុំ។

ជាទូទៅ ឪពុករបស់ខ្ញុំតែងតែលាក់មិនឱ្យខ្ញុំដឹងចិត្តទេ។ គាត់មិនដែលបង្ហាញអារម្មណ៍ពិតរបស់គាត់ដោយបើកចំហទៅកាន់អ្នកដទៃទេ សូម្បីតែទៅកាន់ម្តាយខ្ញុំក៏ដោយ។ មួយជីវិតនេះ ឪពុកខ្ញុំមិនដែលប្រាប់ខ្ញុំថាគាត់ស្រលាញ់ខ្ញុំទេ រហូតមកទល់ពេលមួយនោះតាមដែលខ្ញុំអាចចាំបាន។ មានតែម្តងគត់ដែលគាត់និយាយវា ដោយសារម្តាយខ្ញុំប្រាប់ឱ្យគាត់និយាយ ហើយគាត់មានប្រតិកម្មជ្រុលច្រើនណាស់ទម្រាំតែដាច់ចិត្តនិយាយ។ ខ្ញុំអាចចាំថ្ងៃនោះបាន វាហាក់ដូចជាទើបតែកើតឡើងពីម្សិលមិញ

នេះ។ ម្ដាយខ្ញុំបានជជែកវែកញែកជាមួយគាត់ថា «បងមិនអាចប្រាប់កូនខ្លួនឯងថាបងស្រលាញ់គាត់បានទេ មែនទេ?» ក៏ប៉ុន្តែគាត់នៅតែរក្សាភាពស្ងៀមស្ងាត់។

ចុងក្រោយពេលម្ដាយខ្ញុំស្រក់ទឹកភ្នែក ទើបគាត់និយាយថាគាត់ស្រលាញ់ខ្ញុំ។ ក៏ប៉ុន្តែខ្ញុំមិនដែលរាប់ថាពេលម្ដងនោះថាជាពេលដែលគាត់ប្រាប់ខ្ញុំថាគាត់ស្រលាញ់ខ្ញុំទេ ដោយសារតែគាត់និយាយទាំងបង្ខំ។

ជំនួសឱ្យការប្រាប់យើងតាមរយៈពាក្យសម្ដីថាគាត់ស្រលាញ់យើង មានពេលជាច្រើនដែលឪពុកខ្ញុំបានទិញអ្វីៗដែលពិសេសឱ្យយើង ហើយខ្ញុំគិតយើងជាកូនៗទាំងបួនដឹងថាគាត់ស្រលាញ់យើង។ ខ្ញុំមើលចិត្តឪពុកខ្ញុំធ្លុះ តាមតែទង្វើដែលគាត់ធ្វើតែប៉ុណ្ណោះ គឺសឹងតែមិនដែលមើលចិត្តគាត់ធ្លុះតាមពាក្យសម្ដីរបស់គាត់ទាល់តែសោះ។ ខ្ញុំរក្សាពេលវេលាទាំងនោះទុកជាប់ក្នុងចិត្ត ដោយសារតែវាលេចចេញមកប្រៀបដូចជាពន្លឺក្នុងពេលយប់ងងឹតសម្រាប់ខ្ញុំ។

ថ្ងៃដែលគាត់បានសរសេរមូលប្បទានបត្រឱ្យខ្ញុំសងបំណុលពន្ធអាករ ក្នុងដួងចិត្តខ្ញុំបានពេញហូរហៀរទៅដោយការដឹងគុណ។ ខ្ញុំឱបឪពុកខ្ញុំទាំងទឹកភ្នែក និងបានអរគុណគាត់។ អ្វីដែលគាត់ឆ្លើយតបមកខ្ញុំ ជាអ្វីដែលខ្ញុំនឹកស្មានមិនដល់។ គាត់បាននិយាយថា «ឱ្យតែប៉ាមាន ប៉ាចង់ជួយកូន»។

ខ្ញុំជឿជាក់ថាអ្នកក៏មានការចងចាំពីចិត្តសប្បុរសរបស់នរណាម្នាក់ ដូចជាខ្ញុំចាំបានដែរ ហើយវាជាពេលវេលាដែលដក់ក្នុងអារម្មណ៍អ្នក។ ហេតុដូច្នេះហើយសូមធ្វើកំណត់ត្រាដើម្បីទុកជាការចងចាំដូចខាងក្រោមនេះ ៖

**ចិត្តសប្បុរសបង្ហាញពីដួងចិត្តអ្នក និងព្រះហឫទ័យព្រះជាម្ចាស់ចំពោះពួកគេ។**

ចិត្តសប្បុរសមានអំណាចខ្លាំងណាស់។ វាជំនួសឱ្យពាក្យសម្ដី ហើយវាចាក់ចូលទៅក្នុងដួងចិត្តតែម្ដង។ វាពិតជាអស្ចារ្យណាស់ដែលយើងអាចចាំបានពីការសរសើរ ដែលនរណាម្នាក់សរសើរយើង ឬឱ្យកាដូមួយមកយើង។

ពេលដំបូងក្នុងជីវិតខ្ញុំដែលខ្ញុំដឹងចិត្តឪពុកខ្ញុំ គឺនៅពេលខ្ញុំរៀនថ្នាក់ទី៦។ ពេលនោះ ខ្ញុំ និងបងប្អូនជីដូនមួយខ្ញុំចូលចិត្តគ្រាប់រ៉ុកកែតក្មេងលេងយ៉ាងខ្លាំង ហើយខ្ញុំបានទិញក្បាលគ្រាប់ថ្លាដែលអាចយករបស់របរទៅដាក់នៅក្នុងវា ហើយអាចបាញ់វាចេញទៅលើមេឃបាន។

មានថ្ងៃមួយខ្ញុំ និងបងប្អូនជីដូនមួយខ្ញុំគិតថានឹងដាក់កង្កែបមួយចូលទៅក្នុងក្បាលគ្រាប់នោះ និងយកស្កុតមកបិទវាឱ្យជាប់ ដើម្បីឱ្យគ្រាប់រ៉ុកកែតលាន់ឮសូរផ្ទុះ តែមិនបើកវាឱ្យមានឆ័ត្រយោងចេញមកក្រៅ។ យើងមានចេតនាចង់ដឹងថានឹងមានអ្វីកើតឡើងចំពោះសត្វកង្កែបនោះ ខ្ញុំគិតថាអ្នកដឹងហើយថានឹងមានអ្វីកើតឡើង។

ពេលនោះយើងបានបង្ហោះគ្រាប់រ៉ុកកែត ហើយអ្វីដែលធ្វើឱ្យយើងភ័យខ្លាចនោះគឺឪពុកខ្ញុំបានចេញមកខាងក្រៅដើម្បីមើលយើង។ យើងដឹងថាគាត់មិនសប្បាយចិត្តទេដែលយើងនាំគ្នាសម្លាប់កង្កែបនោះ។

គ្រាប់រ៉ុកកែតក៏បានហោះឡើងទៅលើដូចជាធម្មតា ហើយវាក៏បត់ក្បាលចុះមកវិញដាំក្បាលគ្រាប់ចុះមកមុន បុកទៅនឹងដី។ ពេលខ្ញុំរត់ទៅរើសវាឡើង ខ្ញុំឃើញក្បាលគ្រាប់នោះបែកខ្ទេច ហើយកង្កែបនោះបានងាប់ដូចអ្វីដែលខ្ញុំបានរំពឹងទុក។

ពេលរើសគ្រាប់រ៉ុកកែតឡើង ខ្ញុំប្រញ៉ាប់រលាស់កង្កែបនោះចោល ដើម្បីលាក់ពីចេតនាពិតប្រាកដរបស់យើង កុំឱ្យឪពុកខ្ញុំដឹង។ គាត់បានដើរមករកយើងហើយសួររកគ្រាប់រ៉ុកកែតនោះ។ ខ្ញុំនៅចាំបានពីការបារម្ភរបស់គាត់ចំពោះគ្រាប់រ៉ុកកែតរបស់យើង។ ពេលគាត់កាន់វានៅនឹងដៃ គាត់បានចាប់ផ្ដើមប្រាប់ខ្ញុំពីរបៀបដែលខ្ញុំអាចជួសជុលវាបាន និងប្រាប់យើងថាគាត់សោកស្ដាយយ៉ាងណាចំពោះគ្រាប់រ៉ុកកែតដែលបានខូច

ខ្ទេចខ្ទីនោះ។ បន្ទាប់ពីនោះគាត់បានប្រាប់លម្អិតពីរបៀបដែលខ្ញុំអាចកសាងបំណែកបាក់បែកទាំងនោះឡើងវិញ។ ការយកចិត្តទុកដាក់នៅក្នុងសំឡេងរបស់គាត់ និងចិត្តដ៏ល្អរបស់គាត់បានបង្ហាញឱ្យខ្ញុំឃើញពីកំហុសរបស់ខ្លួនឯង។ គាត់មិនបានដឹងពីរឿងកង្កែបមួយក្បាលនោះទេ ក៏ប៉ុន្តែខ្ញុំមិនដែលភ្លេចពីការបារម្ភដ៏ទន់ភ្លន់របស់គាត់ពីខ្ញុំ និងគ្រាប់រ៉ុកកែតរបស់ខ្ញុំទេ។ ក្នុងពេលនោះហើយដែលវាបង្ហាញយ៉ាងច្បាស់ថា គាត់ពិតជាបានខ្វល់ខ្វាយពីខ្ញុំយ៉ាងពិតប្រាកដមែន។

បន្ទាប់មក មានពេលខ្លះព្រះជាម្ចាស់ប្រើប្រាស់មនុស្សដែលយើងមិនស្គាល់ដើម្បីមកលើកទឹកចិត្តយើង និងទាក់ទងយើង។

ពេលវេលាមួយដែលគួរឱ្យចងចាំ ជាពិសេសគឺជាពេលដែលឌ្រិនដា និងខ្ញុំបានទៅបរបាញ់សត្វស្លាបជាមួយមិត្តភក្តិមួយចំនួន។ ឌ្រិនដា និងខ្ញុំបានទើបតែរៀបការរួច ហើយរស់នៅទីក្រុងធុលសា។ មិត្តរួមបន្ទប់របស់ខ្ញុំម្នាក់រស់នៅក្នុងទីក្រុងខេនសាសបានអញ្ជើញយើងឱ្យចូលរួមជាមួយគាត់ ក្នុងថ្ងៃបើកការបរបាញ់សត្វស្លាបប្រចាំឆ្នាំនោះ។ ខ្ញុំពិតរំភើបលើសពីអ្វីដែលយកមកនិយាយនេះទៀត។

យើងបានបើកឡានរយៈពេលប្រាំម៉ោងទៅទីក្រុងខេនសាស ដោយបានមានថ្ងៃប្រមាញ់ដ៏សប្បាយរីករាយមួយ ហើយទទួលបានចំនួនបក្សីដែលយើងបានកំណត់។ ប៉ុន្តែនៅតាមផ្លូវត្រលប់ទៅក្រុងធុលសា ម៉ាស៊ីនឡានមិត្តរបស់យើងបានផ្ទុះ។ យើងនៅកណ្តាលផ្លូវ គ្មានកន្លែងណាមួយត្រូវទៅទេ ហើយនៅឆ្ងាយរាប់ម៉ោងពីផ្ទះ។ បើអ្នកធ្លាប់ទៅទីក្រុងខេនសាស នោះអ្នកនឹងដឹងថាវាដាច់ស្រយាលប៉ុណ្ណាហើយ។

វាដល់ពេលងងឹតហើយឥលូវនេះ យើងបានឃើញភ្លើងដែលបិទពីចម្ងាយតែមួយប៉ុណ្ណោះ។ យើងបានឡើងភ្នំទៅផ្ទះកសិករ ហើយប្រាប់គាត់ពីស្ថានភាពរបស់យើង។ ខ្ញុំចិត្តភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលគាត់និយាយថា « យប់នេះខ្ញុំនឹងដឹកអ្នកទៅផ្ទះ ខ្ញុំនឹងដាក់ឡានរបស់អ្នកនៅលើរថយន្តសណ្តោងរបស់ខ្ញុំ ហើយខ្ញុំនឹងជូនអ្នកទៅ

ផ្ទះឱ្យបានមុនពេលចូលធ្វើការនៅថ្ងៃចន្ទ»។ (ឌ្រិនដានឹងត្រូវចាប់ផ្តើមការងារថ្មីនៅពេលព្រឹក ដោយធ្វើការពាក់កណ្តាលពេលនៅភោជនីដ្ឋានមួយកន្លែង ហើយនាងមានការខកចិត្តយ៉ាងខ្លាំង នាងប្រហែលជាត្រូវសុំគេឱ្យជំនួស ហើយនិយាយថា នាងមិនអាចទៅធ្វើការបានទេ )។

ពិតជាអស្ចារ្យមែន បុរសម្នាក់ដែលយើងមិនធ្លាប់ជួបពីមុនមកសោះ បានជូនយើងប្រាំម៉ោងទៅផ្ទះនៅទីក្រុងធុលសា ហើយបន្ទាប់មកបើកឡានត្រលប់ទៅក្រុងខេនសាសវិញ មុនពេលព្រឹក។ គាត់បើកឡានពេញមួយយប់!

ខ្ញុំចងចាំមិនភ្លេចនូវទង្វើលះបង់ ដែលគ្មានភាពអាត្មានិយម និងចេញពីចិត្តសប្បុរសនេះឡើយ។ គាត់មិនយកប្រាក់សូម្បីតែមួយកាក់សម្រាប់ថ្លៃសាំង។ ខ្ញុំតែងតែដឹងគុណចំពោះបុរសម្នាក់នោះជានិច្ច។ នៅពេលណាខ្ញុំគិតដល់គាត់ ខ្ញុំតែងតែគិតពីអំណោយរបស់គាត់ ដោយមានការដឹងគុណ។

នៅពេលដែលមនុស្សគិតអំពីអ្នក ពួកគេនឹងអរព្រះគុណព្រះជាម្ចាស់ចំពោះចិត្តសប្បុរសរបស់អ្នក។

ខ្ញុំប្រាកដថាអ្នកអាចគិតពីស្ថានភាពបែបនេះ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នក។

**មនុស្សនឹងអរគុណព្រះជាម្ចាស់សម្រាប់ព្រះគុណដ៏ច្រើនលើសលប់របស់ទ្រង់បានផ្តល់ឱ្យអ្នកដែលមានចិត្តសប្បុរស!**

អ្នកនឹងចងចាំថាអ្នកមានចិត្តដឹងគុណយ៉ាងណាចំពោះការថែទាំ និងការព្រួយបារម្ភរបស់នរណាម្នាក់ដែលបានបង្ហាញចំពោះអ្នក។ មែនហើយ នេះជាអ្វីដែលលោកប៉ូលកំពុងព្យាយាមបង្ហាញចំពោះក្រុមជំនុំនេះដោយចិត្តសប្បុរសរបស់ពួកគេ គឺបានកំពុងតែឈោងចាប់មនុស្សជាមួយព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយធ្វើឱ្យមនុស្សសរសើរតម្កើងអរព្រះគុណដល់ទ្រង់សម្រាប់ការបម្រើរបស់ពួកគេទៅចំពោះទ្រង់។

## អំណាចនៃចិត្តសប្បុរស

នៅពេលដែលខ្ញុំបានចូលមកឯព្រះគ្រិស្ត ខ្ញុំបានឃើញថាចិត្តខ្ញុំបានបន្ទន់ចុះ ហើយខ្ញុំឃើញថា ខ្ញុំពិតជាយកចិត្តទុកដាក់ចំពោះមនុស្សយ៉ាងពិតប្រាកដ។ នៅពេលដែលខ្ញុំបានឃើញសេចក្ដីត្រូវការ ខ្ញុំតែងតែចង់ជួយ ប៉ុន្តែវាពិតជាមួរម៉ៅណាស់ ដែលជាធម្មតាខ្ញុំមិនអាចជួយបាន ដោយសារតែខ្ញុំមិនមានប្រាក់អាចចំណាយលើវាបាន។

ខ្ញុំដឹងថា នេះគឺដូចជាអ្វីដែលមនុស្សភាគច្រើនមានអារម្មណ៍អ៊ីចឹងដែរ។ បើគ្រាន់តែស្ទួររកទិសដៅណាមួយ នោះមិនខ្វះអ្នកចង់ជួយអ្នកស្វែងរកផ្លូវឱ្យអ្នកទេ។

ប៉ុន្តែដូចដែលខ្ញុំបានរកឃើញក្នុងព្រះគម្ពីរ ការមានចិត្តសប្បុរសគឺមានឥទ្ធិពលជាជាងអ្វីដែលខ្ញុំធ្លាប់ដឹង។ ការអានបទគម្ពីរនៅក្នុង ២កូរិនថូស ជំពូក៩ បានបើកសម្តែងច្បាប់មួយនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលផ្លាស់ប្ដូរអ្វីគ្រប់យ៉ាងនៅពេលដែលខ្ញុំគិតអំពីការផ្ដល់ឱ្យ៖

> *ដ្បិតមុខងារប្រមូលប្រាក់នេះមិនត្រឹមតែជួយផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែមទាំងជួយគេឱ្យអរព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើងទៀតផង។ ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះបងប្អូនសម្តែងឱ្យគេឃើញថាបងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អរបស់ព្រះគ្រិស្តដែលបងប្អូនប្រកាស ហើយបងប្អូនមានចិត្តទូលាយ ដោយយករបស់របរមកចែកជាមួយពួកគេ និងជាមួយមនុស្សទាំងអស់។ គេទូលអង្វរព្រះជាម្ចាស់ឱ្យបងប្អូនដោយចិត្តស្រលាញ់ ព្រោះតែ<u>ព្រះគុណដ៏ច្រើនលើសលុបដែលព្រះជាម្ចាស់ប្រទានមកបងប្អូន</u>។ សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គ រកថ្លែងពុំបាន!*
>
> — ២កូរិនថូស ៩:១២-១៥

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

មនុស្សនឹងអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះគុណដ៏ច្រើនលើសលុបដែលទ្រង់បានផ្តល់ឱ្យអ្នកដែលមានចិត្តសប្បុរស!

ដើម្បីពិតជាយល់អំពីអ្វីដែលប៉ូលកំពុងនិយាយនៅទីនេះ យើងត្រូវកំណត់ពាក្យគន្លឹះជាមុនសិន។

លើសលុប មានន័យថា ៖ ដែលមានបរិមាណច្រើន ឬកម្រិតខ្ពស់ ដែលច្រើនណាស់ លើស ឬធំធេង ៖ *<u>រចនាសម្ព័ន្ធនៃភាពរុងរឿងឆើតឆាយដ៏លើសលុប</u>*[2]

តើអ្វីនឹងក្លាយជាចំនួនដ៏ធំរបស់អ្នក? តើនឹងមានភាពធំធេង និងមានចិត្តសប្បុរសលើសលុបអ្វីក្នុងជីវិតរបស់អ្នក? គឺជាព្រះគុណរបស់ព្រះជាម្ចាស់!!!!!

មែនហើយ ឥលូវនេះ យើងត្រូវការនិយមន័យអំពីព្រះគុណ។

**ព្រះគុណ មានន័យថា** ការគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលមិនសមទទួលបាន។

នេះជានិយមន័យស្តង់ដានៃព្រះគុណ។ ប៉ុន្តែវាផ្តល់អត្ថន័យខ្លីអំពីអត្ថន័យពិតប្រាកដនៃពាក្យនេះ។ ខ្ញុំសូមផ្តល់ឱ្យអ្នកនូវនិយមន័យល្អជាងនេះ។

ខាងក្រោមនេះគឺជាសម្រង់ពីវិគីភីឌា អំពីព្រះគុណរបស់ព្រះជាម្ចាស់៖

*ការបង្រៀនរបស់គ្រិស្តបរិស័ទទូទៅគឺថា ព្រះគុណគឺជាក្តីមេត្តា (ការប្រណីសន្តោស) ដែលយើងមិនអាចធ្វើអ្វីមួយដើម្បីដូរឱ្យបាន ប៉ុន្តែដែលព្រះជាម្ចាស់បានប្រទានដល់មនុស្សជាតិដោយបញ្ជូនព្រះរាជបុត្រាទ្រង់ទៅសុគតនៅលើឈើឆ្កាង ដើម្បីប្រទានការសង្គ្រោះដ៏អស់កល្បជានិច្ច។ ទោះយ៉ាងណាក៏ដោយ និយមន័យតែមួយមិនអាចគ្របន័យក្នុងការប្រើប្រាស់ពាក្យទាំងអស់នៅក្នុង*

[2] Dictionary.com

*បទគម្ពីរបាននោះទេ។ ឧទាហរណ៍ លូកា ២៖៤០ "ព្រះកុមារមានវ័យចម្រើនឡើងជាលំដាប់ មានកម្លាំងកាន់តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញាញាណ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងព្រះកុមារនេះណាស់។" ក្នុងឧទាហរណ៍នេះ នៅពេលប្រើនិយមន័យនៃព្រះគុណមានន័យថា ការគាប់ព្រះឫទ័យដែលមិនសមទទួលបាន វាមិនច្បាស់ទេ ដែលយល់ថាព្រះគ្រិស្តដែលគ្មានបាបសោះនឹងត្រូវការចំណុចនេះ។*

*លោក James Ryle បានផ្ដល់យោបល់ថា "ព្រះគុណគឺជាវត្តមាននៃការផ្ដល់អំណាចរបស់ព្រះជាម្ចាស់ ដែលឱ្យអ្នកក្លាយជាអ្នកតាមដែលទ្រង់បានបង្កើតមក ហើយធ្វើអ្វីដែលទ្រង់បានហៅអ្នកឱ្យធ្វើ។" មួយវិញទៀតលោក Bill Gothard បានផ្ដល់យោបល់ថា "ព្រះគុណផ្ដល់ឱ្យយើងនូវបំណងចិត្ត និងអំណាចដែលព្រះជាម្ចាស់ប្រទានឱ្យយើងធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។" និយមន័យទាំងពីរនេះធ្វើឱ្យយល់ច្បាស់អំពីពាក្យព្រះគុណនៅក្នុងព្រះគម្ពីរទាំងមូល។*[3]

ដូច្នេះ យើងឃើញថាអ្វីដែលលោកប៉ូលកំពុងនិយាយនៅក្នុងបទគម្ពីរនេះគឺអំពីព្រះគុណ ឬ ការផ្ដល់អំណាច ដើម្បីចម្រុងចម្រើន។ អំណោយទាននេះ ជាអំណោយទាននៃព្រះគុណ ដោយត្រូវបានធ្វើឡើងព្រោះតែវាផ្ដល់សិទ្ធិអំណាចដល់មនុស្សឱ្យរីកចម្រើន។ ហើយឱ្យពួកគេមានចិត្តសប្បុរស បំពេញតម្រូវការរបស់មនុស្ស វានាំឱ្យពួកគេថ្វាយបង្គំព្រះជាម្ចាស់។

លោកប៉ូលបញ្ចប់ការពិភាក្សារបស់គាត់ដោយថា "**សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គ រកថ្លែងពុំបាន!**"

[3] https://en.wikipedia.org/wiki/Divine_grace

មែនហើយ មាននិយមន័យមួយទៀត។ ពាក្យថា រកថ្លៃងពុំបាន មានន័យដូចជាបញ្ជាក់យ៉ាងច្បាស់ថា គ្មានពាក្យណាដែលអាចពណ៌នាបានគ្រប់គ្រាន់នោះទេ។[4] ដោយហេតុនេះហើយ លោកប៉ូលបាននិយាយថាអំណោយទាននៃព្រះគុណគឺ *លើសពីអ្វីដែលអាចថ្លែងបាន* ហើយជាពិសេសចំពោះអ្នកដែលត្រូវបានបម្រើ ដោយលុយកាក់ដែលព្រះអំណោយទាននៃព្រះគុណនោះបានផ្ដល់មក។

នេះគឺជាអំណាចដែលអាចរំដោះអ្នកចេញពីចំណងហិរញ្ញវត្ថុ។ អំណាចនេះ ជាព្រះគុណរបស់ព្រះជាម្ចាស់ ដែលមានសម្រាប់អ្នកជឿគ្រប់រូប។

ប៉ុន្តែនេះជាបញ្ហា។ យើងអាចចំណាយពេលច្រើនក្នុងការនិយាយ អ្វីដែលប៉ូលបាននិយាយថាត្រូវធ្វើ—ដើម្បី*ផ្ដល់ឱ្យ*។ ប៉ុន្តែប្រសិនបើយើងមិនយល់អំពីព្រះគុណនៃការផ្ដល់អំណាច ដើម្បីចម្រុងចម្រើនដោយអំណាចរបស់ព្រះជាម្ចាស់នោះទេ យើងនឹងខកខានចម្រូតដែលព្រះជាម្ចាស់មានបំណងសម្រាប់យើង។ វានឹងដូចជាការដាំដុះសួនច្បាររបស់អ្នកនៅក្នុងព្រៃ នៅក្រោមម្លប់ដើមឈើធំ គ្មានពន្លឺថ្ងៃអ៊ីចឹង វាគ្មានថាមពលដើម្បីទទួលបានលទ្ធផលដែលយើងចង់បាននោះឡើយ។

ខ្រិនដា និងខ្ញុំបានអានរឿងនៅក្នុងព្រះគម្ពីរ ជាកន្លែងដែលបានបង្ហាញអំណាចរបស់ព្រះជាម្ចាស់ ហើយបានផ្លាស់ប្ដូរស្ថានភាពទាំងស្រុងសម្រាប់ការល្អ។ ខ្ញុំត្រូវតែទទួលស្គាល់ថា យើងបានឮរឿងបែបនេះតិចតួចណាស់ ដែលកើតឡើងនៅក្នុងក្រុមជំនុំរបស់យើងនៅពេលយើងធំឡើង។ ក្រៅពីការសង្គ្រោះ គ្មាននរណាម្នាក់ដែលធ្លាប់បាននិយាយអំពីរបៀបដើម្បីនាំយកព្រះគុណរបស់ព្រះជាម្ចាស់ចូលទៅក្នុងស្ថានភាពមួយនោះទេ។

[4] *វចនានុក្រមភាសាអង់គ្លេស* American Heritage *កំណែទីប្រាំ*

ឥលូវនេះ ខ្ញុំយល់ថាការសង្គ្រោះរបស់យើងគឺជារឿងសំខាន់បំផុត។ ប៉ុន្តែ ដូចដែលខ្ញុំទើបតែលើកឡើងអីចឹង ខ្ញុំត្រូវការព្រះគុណដដែល ដើម្បីឱ្យវាដំណើរការ *គ្រប់*ផ្នែកជីវិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាវាដំណើរការយ៉ាងដូចម្ដេចនោះទេ។ ហើយ ដោយសារតែព្រងើយកន្ដើយរបស់ខ្ញុំ យើងបានបែកបាក់ ឈឺ និងបាក់ទឹកចិត្ត។ យើង បានដឹងអំពីការសង្គ្រោះយើងថាមានផ្នែកនៃការសង្គ្រោះដ៏អស់កល្បជានិច្ច ប៉ុន្តែយើង មិនបានដឹង ឬយល់អំពីរបៀបដែលនាំស្ថានសួគ៌មកក្នុងជីវិតរបស់យើង និងបង្ហាញ អំណាចរបស់ព្រះជាម្ចាស់ទេ។ ដូចដែលខ្ញុំបានប្រាប់អ្នករាល់គ្នាអីចឹង យើងបានខូច ខាតផ្នែកហិរញ្ញវត្ថុមួយហើយ!

ប៉ុន្តែ នេះជាអ្វីដែលព្រះអម្ចាស់បានកំពុងតែមានបន្ទូលមកខ្ញុំ នៅថ្ងៃដែលទ្រង់ មានបន្ទូលមកកាន់ខ្ញុំទាក់ទងទៅនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ *"អ្នកនៅក្នុងភាពញ៉េរ ញ៉ៃនេះ ដោយសារតែអ្នកមិនដែលដឹងអំពីរបៀបដែលព្រះរាជ្យរបស់យើងដំណើរការ!"*

ម្យ៉ាងវិញទៀត ទ្រង់កំពុងតែមានបន្ទូលថា ខ្ញុំមិនចេះស្រាយនូវសិទ្ធិអំណាច របស់ស្ដេចនៅក្នុងអាណាចក្រផែនដីនេះឡើយ។ ខ្ញុំមិនដែលធ្លាប់រៀនអំពីរបៀបង្ហាញ អំពីសិទ្ធិអំណាច ឬទោះខ្ញុំធ្លាប់ក៏ដោយ ខ្ញុំមិនដឹងអំពីរបៀបដើម្បីចូលទៅក្នុងព្រះគុណ ជាអំណាចរបស់ព្រះជាម្ចាស់។

អូហ៎ និយាយអីចឹង មានការសន្ទនាជាច្រើននៅទៀតនៅថ្ងៃនោះ នៅពេល ដែលព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់បាន បន្តថា៖ *"ក្រុមជំនុំរបស់ខ្ញុំកំពុងតែរស់នៅដូចកូនចៅអ៊ីស្រាអែលបានប្រព្រឹត្តនៅពេល ដែលពួកគេជាទាសករ ធ្វើឥដ្ឋឱ្យស្ដេចផារ៉ោន។ ពួកគេជាទាសករ! ប្រជារាស្ត្ររបស់ យើងបានជាប់បំណុល យើងចង់ឱ្យពួកគេមានសេរីភាព!"*

ខ្ញុំសូមលើកយកចំណុចសំខាន់មួយមកនិយាយនៅត្រង់នេះ ៖ អ្នកនឹងមិន មានសេរីភាពឡើយ រហូតទាល់តែអ្នកមានសេរីភាពផ្នែកហិរញ្ញវត្ថុ។ ហើយដូចដែលខ្ញុំ

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នដា និងខ្ញុំបាននិយាយអស់រយៈពេល ៣០ ឆ្នាំចុងក្រោយនេះ អ្នកនឹងមិនអាចរកឃើញថាអ្នកជានរណាពិតប្រាកដ ហើយដើរក្នុងគោលបំណងខាងវិញ្ញាណសម្រាប់ជីវិតរបស់អ្នកទេ រហូតទាល់តែអ្នកដោះស្រាយរឿងរ៉ាវប្រាក់កាក់នេះជាមុនសិន។

ហើយខ្ញុំសូមលើកយកចំណុចសំខាន់មួយទៀតមកនិយាយនៅទីនេះដែរ៖

**អ្នកអាចមានសេរីភាព!**

ខ្ញុំបានបញ្ជាក់ពីរឿងនោះ ហើយមនុស្សរាប់ពាន់នាក់ផ្សេងទៀតក៏បានបញ្ជាក់ដូច្នេះដែរ។ ព្រះគុណរបស់ព្រះជាម្ចាស់គឺនៅទីនោះដើម្បីជួយអ្នក។ មានរឿងដែលអ្នកត្រូវបានត្រាស់ហៅឱ្យធ្វើ ហើយអ្នកមិនអាចសម្រេចវាដូចទាសករម្នាក់ឡើយ។ អ្នកត្រូវតែមានសេរីភាពផ្នែកហិរញ្ញវត្ថុ មិនត្រឹមតែសម្រាប់ខ្លួនអ្នក និងក្រុមគ្រួសាររបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីឱ្យមនុស្សអាចមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការក្នុងជីវិតរបស់អ្នកដែរ។ ហើយដូចជាដើមឈើហូបផ្លែ មានទៅដោយផ្លែឈើទុំ ហើយទាក់ទាញមនុស្សឱ្យចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់នោះ។

**មនុស្សកំពុងស្វែងរកចម្លើយ។ ពួកគេកំពុងរកមើលអំពីដំណោះស្រាយដ៏ពិតប្រាកដ។ ពួកគេត្រូវការមើលឃើញព្រះរាជ្យយ៉ាងខ្លាំង និងមិនមែនមើលសាសនាឡើយ។**

មនុស្សកំពុងស្វែងរកចម្លើយ។ ពួកគេកំពុងរកមើលអំពីដំណោះស្រាយដ៏ពិតប្រាកដ។ ពួកគេត្រូវការមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់យ៉ាងខ្លាំង មិនមែនមើលឃើញសាសនាឡើយ។

ខ្ញុំសូមប្រាប់អ្នកអំពីការសន្ទនានៅថ្ងៃមួយផ្សេងទៀតដែលខ្ញុំបានជួបជាមួយគិលានុបដ្ឋាយិកាម្នាក់។ មែនហើយ តាមពិតគិលានុបដ្ឋាយិកាពីរនាក់។

## អំណាចនៃចិត្តសប្បុរស

ម្ដាយរបស់ខ្ញុំមានអាយុ ៨៨ ឆ្នាំ ហើយមានសុខភាពល្អ ប៉ុន្តែគាត់ត្រូវការជំនួយក្នុងការប្ដូរទីកន្លែង ដូចដែលអ្នកអាចស្រមៃអ៊ីចឹង។ ដូច្នេះ នៅក្នុងថ្ងៃមួយនោះ ខ្ញុំត្រូវនាំគាត់ទៅជួបគ្រូពេទ្យតាមការណាត់បួនប្រាំដង។

នៅពេលខ្ញុំកំពុងនិយាយជាមួយគិលានុបដ្ឋាយិកានៅកន្លែងណាត់ជួបដំបូង នាងបានចាប់ផ្ដើមសួរខ្ញុំថា តើខ្ញុំធ្វើការអ្វីដើម្បីចិញ្ចឹមជីវិត។ ខ្ញុំបានប្រាប់នាងអំពីពួកជំនុំរបស់យើង អំពីក្រុមហ៊ុនហិរញ្ញវត្ថុរបស់ខ្ញុំ និងរបៀបដែលយើងជួយមនុស្សឱ្យរួចផុតអំពីបំណុល។ ជាការប្រសើរណាស់ដែលធ្វើឱ្យនាងចាប់អារម្មណ៍។ នាងបានបន្តប្រាប់ខ្ញុំថានាងមានបញ្ហាជំពាក់បំណុលគេច្រើន ហើយមិនដឹងសោះថាធ្វើយ៉ាងណាទើបអាចដោះស្រាយបំណុលនោះបាន។

នៅពេលខ្ញុំទៅជួបគ្រូពេទ្យទីពីរនៅថ្ងៃនោះ ខ្ញុំមានការសន្ទនាស្ទើរតែដូចគ្នាជាមួយគិលានុបដ្ឋាយិកានៅទីនោះដែរ។ តាមពិត នាងមានទឹកភ្នែករលីងរលោង ពេលកំពុងប្រាប់ខ្ញុំអំពីស្ថានភាពហិរញ្ញវត្ថុរបស់នាង។

មិត្តអើយ មិនមែនមានតែពួកគេទេដែលជួបស្ថានភាពនេះ។ នេះគឺជារបៀបដែលជនជាតិអាមេរិកកំពុងរស់នៅសព្វថ្ងៃ។

ខ្ញុំមានដួងចិត្ត និងភាពឆេះឆ្លលក្នុងការជួយមនុស្សឱ្យយល់ថាមានផ្លូវដែលប្រសើរជាងនេះក្នុងជីវិតរស់នៅ គឺជាផ្លូវនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។

នៅពេលដែលឌ្រិនដា និងខ្ញុំបានចាប់ផ្ដើមរៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយចាប់ផ្ដើមអនុវត្តអ្វីដែលព្រះអង្គកំពុងបង្រៀនយើងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ជីវិតរបស់យើងបានផ្លាស់ប្ដូរយ៉ាងខ្លាំង។ យើងចាប់ផ្ដើមឃើញអំពីព្រះគុណដែលលោកប៉ូលបានលើកឡើងនោះ បានបង្ហាញនៅក្នុងជីវិតរបស់យើង។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នៅយប់មួយ ខ្ញុំមានសុបិនចង់បើកអាជីវកម្មផ្ទាល់ខ្លួន ដើម្បីជួយមនុស្សឱ្យរួចផុតចេញពីបំណុល។ នោះឆ្កួតហើយមែនទេ? ខ្ញុំមានន័យថា ខ្ញុំខ្លួនឯងដែលមិនដែលមានលុយសោះ ឥលូវនេះបែរជារៀបចំដំណើរការក្រុមហ៊ុនបង្ហាញមនុស្សអំពីរបៀបរួចផុតពីបំណុល។ មានតែព្រះទេទើបអាចធ្វើបាន មែនទេ ?

អ្នកអាចនឹងសួរថា «តើវាកើតឡើងដោយរបៀបណា? តើអ្នកដឹងយ៉ាងដូចម្ដេចដើម្បីឱ្យរួចផុតពីបំណុល ដើម្បីឱ្យអ្នកពិតជាអាចនឹងជួយអ្នកផ្សេងទៀតឱ្យរួចផុតពីបំណុល?» នោះគឺជាសំណួរដ៏ល្អ!

ដើម្បីសង្ខេបនូវរឿងនេះ ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញខ្ញុំពីរបៀបដែលអាចធ្វើវាបានសម្រេច។

ជាការពិតណាស់ ខ្ញុំមានរឿងដែលត្រូវរៀននៅក្នុងធម្មជាតិពិតពលោក។ ហើយបន្ទាប់មក ខ្ញុំត្រូវការមនុស្សបង្វឹកខ្ញុំអំពីរបៀបបង្កើតក្រុមហ៊ុនរបស់ខ្ញុំ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធបានដឹកនាំវឌ្ឍនភាព និងយុទ្ធសាស្ត្រពិសេស ហើយនិងវិធីសាស្ត្រដែលយើងធ្លាប់ជួយមនុស្ស។ ក្រុមហ៊ុននោះបានចាប់ផ្ដើម ហើយនេះជាអ្វីដែលបានផ្ដល់ថវិកាដល់សេរីភាពហិរញ្ញវត្ថុរបស់យើង។

និយាយអីចឹង ខ្ញុំដឹងអំពីអ្វីដែលអ្នកកំពុងគិត៖ យើងត្រូវតែចំណាយប្រាក់ជាច្រើនសម្រាប់ជំនួយនោះ ប្រសិនបើវាផ្ដល់ប្រាក់ទាំងអស់ ដែលយើងត្រូវការដើម្បីមានសេរីភាព។

មិនដូច្នេះទេ។ ដូចជាខ្ញុំបាននិយាយអីចឹង ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ដល់គំរូអាជីវកម្មដែលពិសេស ហើយវាគឺជា៖

យើងធ្វើការជាមួយអតិថិជនរបស់យើងដោយ**ឥតគិតថ្លៃ**។

តើខ្ញុំអាចគិតថ្លៃសេវាចំពោះអ្នកដែលកំពុងជួបបញ្ហាបង់ថ្លៃការចំណាយរបស់ពួកគេដើម្បីជួយពួកគេឱ្យមានសេរីភាពយ៉ាងដូចម្តេចបានទៅ? អត់ទេ ខ្ញុំមិនអាចធ្វើអ្វីចឹងបានទេ។ ព្រះជាម្ចាស់បានប្រទានឱ្យខ្ញុំមានវិធីផ្សេងៗ ក្នុងការផ្តល់ថវិកាដល់ក្រុមហ៊ុនរបស់ខ្ញុំ។ កន្លងមក ក្រុមហ៊ុនខ្ញុំមិនធ្លាប់គិតប្រាក់ (ហើយពេលខាងមុខ ក៏នឹងមិនដែលគិតប្រាក់) ដល់អតិថិជន ដើម្បីបង្កើតផែនការផ្ទាល់ខ្លួនឱ្យអតិថិជនមានសេរីភាពពីបំណុលនោះទេ។ ក្រុមហ៊ុនរបស់ខ្ញុំមានជំនាញក្នុងការបង្ហាញអតិថិជនអំពីរបៀបធ្វើឱ្យមានសេរីភាពពីបំណុលក្នុងរយៈពេលតិចជាងប្រាំពីរឆ្នាំ រួមទាំងការបង់រំលស់ផ្ទះរបស់ពួកគេ ជាធម្មតាដោយគ្មានការផ្លាស់ប្តូរប្រាក់ចំណូលរបស់ពួកគេ។

យើងមិនបានការផ្គត់ផ្គង់ពីអតិថិជនរបស់យើងទេ ប៉ុន្តែដោយមានក្រុមហ៊ុនរាប់សិប អ្នកលក់ និងអ្នកជំនាញដែលយើងជ្រើសរើសដើម្បីផ្តល់ដំណោះស្រាយ និងជម្រើសរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនរបស់យើង។ ពួកគេជួយផ្គត់ផ្គង់យើងសម្រាប់ការប្រាប់អតិថិជនរបស់យើងអំពីពួកគេ។

ជាឧទាហរណ៍ នៅក្នុងដំណើរការរៀបចំឥណទានឡើងវិញរបស់យើង ប្រសិនបើខ្ញុំដឹងថាក្រុមហ៊ុន XYZ នោះ អាចកាត់បន្ថយថ្លៃចំណាយធានារ៉ាប់រងរបស់អតិថិជនខ្ញុំពាក់កណ្តាល ខ្ញុំនឹងប្រាប់ពួកគេឱ្យទៅពិគ្រោះជាមួយក្រុមហ៊ុន XYZ នោះ។ ឥលូវនេះ អតិថិជនរបស់ខ្ញុំអាចនិយាយជាមួយក្រុមហ៊ុន XYZ បានដោយផ្ទាល់បាន ហើយអាចគិតខ្លួនឯងឡើងវិញ និងធ្វើការសម្រេចចិត្តប្រសិនបើពួកគេចាប់អារម្មណ៍ ឬអត់ នៅលើអត្រាការប្រាក់ដែលទាបជាងរបស់ក្រុមហ៊ុន XYZ ដែលជាផ្នែកមួយចំពោះការរៀបចំឥណទានឡើងវិញ។

ដូច្នេះយើងមិនគិតកម្រៃអ្វីទាំងអស់ពីអតិថិជន។ ហើយខ្ញុំដឹងច្បាស់ថានេះគឺជាកត្តារួមចំណែកដ៏សំខាន់ នៅក្នុងការធ្វើឱ្យក្រុមហ៊ុនរបស់យើងរីកចម្រើនខ្លាំង។ សូមមើលគេហទំព័រ forwardfinancialgroup.com អំពីក្រុមហ៊ុនរបស់យើង។

យើងក៏ជួយមនុស្សឱ្យរកឃើញនូវអ្វីដែលខ្ញុំហៅថាការវិនិយោគប្រកបដោយសុវត្ថិភាពដែរ។ វាជាអ្វីដែលស្តាប់ទៅដូចជា ៖ ការវិនិយោគដោយគ្មានហានិភ័យនៃទីផ្សារធ្លាក់ចុះ លួចយកប្រាក់ចូលនិវត្តន៍ដ៏មានតម្លៃរបស់ពួកគេ។

ខ្ញុំបាននិយាយពីខាងដើមរួចហើយថា ជាង៣០ឆ្នាំកន្លងមកនេះ យើងបាននិយាយជាមួយមនុស្សរាប់សែននាក់ ហើយយើងបានឃើញអំពីភាពខ្សោយផ្នែកគ្រប់គ្រងហិរញ្ញវត្ថុភាគច្រើន ដែលជនជាតិអាមេរិកជួបប្រទះ។

មានឧទាហរណ៍មួយដែលខ្ញុំចងចាំ ហើយវាបង្ហាញអំពីស្ថានភាពរស់នៅជាច្រើនរបស់ជនជនជាតិអាមេរិក។

មានស្ត្រីម្នាក់បានហៅខ្ញុំឱ្យទៅលេងផ្ទះរបស់នាង ដោយសារនាងត្រូវការជំនួយក្នុងការដោះបំណុល។ ខ្ញុំ និងសហការីម្នាក់របស់ខ្ញុំបានទៅជួបជាមួយនាង ហើយខ្ញុំអង្គុយនៅទីនោះទាំងស្ទើរតែមិនជឿនូវអ្វីដែលនាងបានពន្យល់ពីស្ថានភាពរបស់នាង។ នាងមានកាតក្រេឌីតចំនួន ៣២ ផ្សេងៗគ្នា (មែនហើយ អ្វីអ្នកបានឮនោះត្រឹមត្រូវហើយ—នាងមានកាតក្រេឌីតចំនួន ៣២ ពិតមែន។)

នាងបានសង់គុកផ្ទាល់ខ្លួនយ៉ាងជោគជ័យ ហើយនាងកំពុងតែសុំកូនសោដើម្បីចេញក្រៅ។ នៅក្នុងគំនិតរបស់ខ្ញុំ ចម្លើយនោះគឺងាយស្រួលទេ ៖ ឈប់ប្រើកាតក្រេឌីតទៀតទៅ។ នោះជាការចាប់ផ្តើមដ៏ល្អហើយ។ ដូច្នេះខ្ញុំប្រាប់នាងឱ្យកាត់កាតទាំងនោះចោល ហើយបានទទួចថា នាងត្រូវចំណាយត្រឹមប្រាក់ចំណូលរបស់នាងបានហើយ។ បន្ទាប់មក ខ្ញុំបានឱ្យនាងធ្វើកិច្ចការមួយ ដោយធ្វើបញ្ជីនៃការចំណាយលើការរស់នៅរបស់នាងទាំងអស់ ដូច្នេះខ្ញុំនឹងដឹងកន្លែងដែលត្រូវចាប់ផ្តើមក្នុងធ្វើការប្រឹក្សាដល់នាង។ ខ្ញុំក៏បានស្នើឱ្យនាងចាប់ផ្តើមប្រើប័ណ្ណឥណពន្ធ (debit card) ជំនួសឱ្យកាតធនាគារ ដើម្បីចៀសវាងធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុរបស់នាងកាន់តែអាក្រក់ទៅ។

នៅពេលដែលខ្ញុំបានស្នើឱ្យកាត់កាតក្រេឌីត នាងក៏ហូរទឹកភ្នែកភ្លាមៗ ហើយសួរសំណួរដ៏ភ្ញាក់ផ្អើលថា «បើអ៊ីចឹង តើខ្ញុំធ្វើម៉េចអាចទិញស្បែកជើងបាន?»

តើខ្ញុំបានស្ដាប់ច្រឡំឬ? នាងមិនមានប្រាក់គ្រប់គ្រាន់សម្រាប់អាហារផង ប៉ុន្តែនាងចង់ទិញស្បែកជើង?

អ្នកប្រហែលជាគិតថា ស្ត្រីនោះច្បាស់ជាមានភាពខុសប្រក្រតីហើយ។ បើគិតពីចំនួនកាតក្រេឌីតដែលនាងមាន គឺនាងខុសប្រក្រតីមែន។ ប៉ុន្តែនៅក្នុងគុកហិរញ្ញវត្ថុ នាងមិនមែនខុសប្រក្រតីទេ។ សូមមើលស្ថិតិចុងក្រោយបំផុតនៅអាមេរិក ៖

- ៥៧% នៃប្រជាជនមិនមានប្រាក់ ១.០០០ ដុល្លា នៅក្នុងធនាគារទេ។[5]
- ៤៤% មិនអាចចំណាយប្រាក់ ៤០០ ដុល្លារ ដែលមិនបានរំពឹងទុក។[6]
- ២៣% នៃជនជាតិអាមេរិកមិនអាចបង់ថ្លៃចំណាយប្រចាំខែរបស់ពួកគេបានទេ ហើយកំពុងតែជំពាក់បំណុលកាន់តែច្រើនឡើងៗជារៀងរាល់ខែ។[7]

បងប្អូនទាំងអស់គ្នាអើយ ជនជាតិអាមេរិកគឺដូចជាអ្វីដែលព្រះបានប្រាប់ខ្ញុំអ៊ីចឹង ពួកគេជាទាសករ។

សូមគិតអំពីអ្វីដែលទាសករធ្វើ។

- គាត់មិនធ្វើការសម្រាប់ខ្លួនគាត់ទេ។ ទោះបីជាគាត់ (ឬនាង)ធ្វើការ ហើយបង្កើតប្រាក់ចំណេញក៏ដោយ ប្រាក់ចំណេញនោះត្រូវបានផ្ញើទៅអ្នកដែលបាន

---

[5] Ray Hanania “៥៧% នៃជនជាតិអាមេរិកមានប្រាក់សន្សំតិចជាង ១.០០០ ដុល្លារ ថ្ងៃទី ៣១ ខែមីនា ២០២១ SuburbanChicagoland.com

[6] Joseph Lawler “៤៤ ភាគរយនៃជនជាតិអាមេរិកមិនអាចចំណាយ ៤០០ ដុល្លារដែលមិនបានរំពឹងទុក” *Washington Examiner ថ្ងៃទី* ១៩ ខែឧសភា ឆ្នាំ ២០១៧។

[7] Megan Leonhardt "ចូរមានសេរីភាពពីបំណុល" ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៩

ឱ្យខ្ចីក្នុងមួយខែៗ ហើយគេសល់លុយល្មមសម្រាប់គ្រួសាររស់នៅខែមួយទៀតប៉ុណ្ណោះ។

- ទាសកររស់នៅក្នុងផ្ទះដែលមិនមែនជារបស់ពួកគេ (មានន័យថាពួកគេបានកម្ចីទិញផ្ទះ)។
- ពួកគេបើកឡានដែលមិនមែនជារបស់ពួកគេទៅធ្វើការ ដើម្បីបង់ប្រាក់លើផ្ទះដែលមិនមែនជារបស់ពួកគេ។
- ពួកគេស្លៀកសម្លៀកបំពាក់ដែលពួកគេទិញតាមកាតក្រេឌីត ដើម្បីទៅធ្វើការបង់ថ្លៃឡាន និងផ្ទះដែលមិនមែនជារបស់ពួកគេ។ រួមជាមួយនឹងប្រាក់កម្ចីនិស្សិតដែលពួកគេនៅតែត្រូវសង តាំងពី២០ឆ្នាំមុនមកម្ល៉េះ។

អ្នកយល់នូវគំនិតនេះហើយ។

*អ្នកមានតែងតែជិះជាន់អ្នកក្រ រីឯកូនបំណុលជាទាសកររបស់ម្ចាស់ប្រាក់។*
—សុភាសិត ២២:៧

តើអ្នកដឹងទេថាមនុស្សភាគច្រើនមិនចូលចិត្តការងាររបស់ពួកគេ? តាមពិតទៅការស្ទង់មតិរបស់ Gallup និយាយថា បុគ្គលិក ៨៥% ស្អប់ការងាររបស់ពួកគេ។[8]

ចុះហេតុអ្វីបានជាគេធ្វើការនៅកន្លែងការងាររបស់គេ? ព្រោះពួកគេជាទាសករ ហើយទាសករមិនមានជម្រើសផង!

ដូច្នេះ តើមានផ្លូវណាចេញពីភាពជាទាសករដែរឬទេ? មាន!

តើមិនជឿខ្ញុំទេឬ? តោះខ្ញុំនឹងបង្ហាញអ្នក។

---

[8] Sara Burrows "ការស្ទង់មតិរបស់ Gallup និយាយថា បុគ្គលិក ៨៥% ស្អប់ការងាររបស់ពួកគេ។" ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១៧ returntonow.net

*ដ្បិតមុខងារប្រមូលប្រាក់នេះមិនត្រឹមតែជួយផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែមទាំងជួយគេឱ្យអរព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើងទៀតផង។*

*ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះបងប្អូនសម្ដែងឱ្យគេឃើញថា បងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អ*របស់ព្រះគ្រិស្តដែលបងប្អូនប្រកាស ហើយបងប្អូនមានចិត្តទូលាយ ដោយយករបស់របរមកចែកជាមួយពួកគេនិងជាមួយមនុស្សទាំងអស់។ គេទូលអង្វរព្រះជាម្ចាស់ឱ្យបងប្អូនដោយចិត្តស្រលាញ់ ព្រោះតែ<u>ព្រះគុណដ៏ច្រើនលើសលុបដែលព្រះជាម្ចាស់ប្រទានមកបងប្អូន</u>។ សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គ រកថ្លែងពុំបាន!*

—២ កូរិនថូស ៩:១២-១៥

តោះសូមយើងបន្ដផ្ដោតលើចម្លើយ ជាព្រះគុណរបស់ព្រះជាម្ចាស់ ជាការផ្តល់អំណាចដើម្បីឱ្យយើងចម្រុងចម្រើន!

តោះសូមយើងដឹងផងដែរថា មារសត្រូវចង់ឱ្យអ្នកនៅជាប់ក្នុងបំណុល ហើយយើងមិនដែលរៀនរកផ្លូវចេញនោះទេ។ នោះហើយជាមូលហេតុដែលមានកាតក្រេឌីតសកម្ម ១.១ *ទ្រីលាន*នៅសហរដ្ឋអាមេរិក។[9] វាជាហេតុផលដែលមានបួន ទៅប្រាំបីពាន់ប៊ីលានកាតក្រេឌីត*ផ្តល់ជូន* ត្រូវបានផ្ញើចេញជារៀងរាល់ឆ្នាំ។[10]

---

[9] Raynor de Best "ចំនួនកាតក្រេឌីត និងបណ្ណឥណពន្ធនៅសហរដ្ឋអាមេរិក ២០១២-២០១៨។" ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០។ statisa.com/statistics

[10] Bob Bryan ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ businessinsider.com

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

មានម្នាក់ចង់ឱ្យអ្នករស់នៅក្នុងបំណុល វាមិនមែនគ្រាន់តែជាធនាគារ និងអ្នកលក់ដែលកំពុងសុំឱ្យអ្នកសាកល្បងកាតរបស់ពួកគេនោះទេ។

មារសាតាំងដឹងថា ប្រសិនបើវាអាចឱ្យអ្នកជាប់បំណុលបាន នោះអ្នកនឹងមិនអាចដើរតាមជោគវាសនាខាងវិញ្ញាណរបស់អ្នកបានឡើយ ដែលវាដឹងថាការធ្វើបែបនោះ នឹងធ្វើឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់មានការបំផ្លិចបំផ្លាញ។

ដូច្នេះ ខ្ញុំសូមរំឭកបន្តិចសិន។ តើសៀវភៅនេះនិយាយអំពីការមានចិត្តសប្បុរសមែនទេ? បាទ ត្រូវហើយ ហើយក៏មែនមែនដែរ។ ពិតមែន យើងនឹងនិយាយអំពីអត្ថប្រយោជន៍ទាំងអស់នៃការផ្តល់ឱ្យ និងចិត្តសប្បុរសបន្តិចទេ។ ប៉ុន្តែការឱ្យ ឬចែកទានតែម្យ៉ាងគឺមិនមែនជាចម្លើយទេ។ អ្នកត្រូវតែមានចំណេះដឹងពីរបៀបដើម្បីចូលទៅកាន់ព្រះគុណ ជាអំណាចរបស់ព្រះជាម្ចាស់។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ម្តងទៀត ៖ រូបមន្តនៃការផ្តល់ឱ្យ ឬធ្វើទានតែម្យ៉ាង វាគ្រាន់តែជារូបមន្ត ប៉ុន្តែមិនមែនជាគន្លឹះ (កូនសោ) ទេ។ ជាការពិត វាជាផ្នែកមួយនៃគន្លឹះ ប៉ុន្តែអ្នក និងខ្ញុំត្រូវការការផ្តល់អំណាចអធិធម្មជាតិដ៏អស្ចារ្យដើម្បីចម្រុងចម្រើន ជាអ្វីដែលយើងហៅថាព្រះគុណ។

ដាស្ទីន និងខេនដល បានយល់អំពីអ្វីដែលខ្ញុំកំពុងនិយាយ។ ពួកគេគឺជាគូស្វាមីភរិយាវ័យក្មេងមួយគូដែលមិនយល់ថាពួកគេត្រូវការព្រះគុណរបស់ព្រះជាម្ចាស់ នៅក្នុងហិរញ្ញវត្ថុរបស់ពួកគេទាល់តែសោះ រហូតដល់ពួកគេបានរកឃើញថាខ្លួនឯងមានបញ្ហារញ៉េរញ៉ៃផ្នែកហិរញ្ញវត្ថុ។ ពួកគេទើបតែបានមើលគំនិតអាជីវកម្មថ្មីមួយ ហើយសម្រេចចិត្តអនុវត្តវា។ តើវាមានតម្លៃប៉ុន្មាន? គឺ ១៥០.០០០ ដុល្លារ បូករួមទាំងបំណុលទាំងអស់នៃអាជីវកម្មនោះ។

នៅខែដដែល ដែលពួកគេបានទិញអាជីវកម្មនោះ ពួកគេត្រូវបានធ្វើសវនកម្មដោយ IRS ហើយគេឱ្យពួកគាត់បង់ ៥៣.០០០ ដុល្លារ ជាពន្ធដែលជំពាក់។ ដាស្ទីន

និយាយថាពួកគេបានដឹងខ្លួនឯងកំពុងនៅក្នុងបំណុលជាង ២០០.០០០ ដុល្លារ ដោយពិតជាមិនមានផ្លូវដោះចេញទេ ជាពិសេសដោយសារតែរឿងរ៉ាវផ្នែកហិរញ្ញវត្ថុមានភាពតឹងតែង មុននឹងពួកគេបានទិញអាជីវកម្មនោះទៅទៀត។

ពួកគេទើបតែខ្ចីប្រាក់យកទៅបង់ថ្លៃពេទ្យ សម្រាប់កូនរបស់ពួកគេដែលទើបតែកើតថ្មីៗនេះ ហើយកំពុងតែបង់សងទៅកម្ចីនោះ។ សវនកម្មបានជំរុញពួកគេមានដោះស្រាយលើសពីសមត្ថភាពរបស់ខ្លួន ហើយដាស្ទីនបានព្យាយាមស្វែងរកជម្រើសក្នុងការដោះស្រាយទាំងពិបាក។

បន្ទាប់ពីធ្វើការស្វែងរក ទីបំផុតគាត់បានទទួលការផ្តល់ជូនសម្រាប់កម្ចីបន្ថែមចំនួន៣០.០០០ដុល្លារដែលត្រូវបានអនុម័ត ហើយបានយកគំនិតនេះទៅប្រាប់ប្រពន្ធរបស់គាត់ ដើម្បីសួរយោបល់ពីនាង។ អ្វីដែលគាត់មិនបានដឹងនោះគឺថា ខេនដល បានសិក្សា និងជញ្ជឹងគិតលើសៀវភៅរបស់ខ្ញុំមានចំណងជើងថា *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃការសម្រាក* ដែលនិយាយអំពីការចូលទៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់ដែរ។

ដូច្នេះនៅពេលដែលដាស្ទីន បានយកគំនិតអំពីកម្ចីនេះមកនិយាយជាមួយប្រពន្ធ ខេនដល បានខកចិត្ត ដោយសង្ឃឹមថាប្តីនឹងបែរទៅរកព្រះជាម្ចាស់ជំនួសឱ្យការបែរទៅរកបំណុល។ នាងសម្រេចចិត្តនិយាយជាមួយគាត់អំពីការសម្រេចចិត្តរបស់ពួកគេ ហើយលើកទឹកចិត្តគាត់ឱ្យទុកចិត្តលើព្រះជាម្ចាស់។ ជាការប្រសើរ ដាស្ទីន បានទទួលប្រាជ្ញាពីភរិយារបស់គាត់។

នៅពេលពួកគេអធិស្ឋាន នោះពួកគេបានឮព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលឱ្យសាបព្រោះគ្រាប់ពូជមួយ។ ពិតណាស់នៅពេលនោះ ពួកគេមិនមានប្រាក់ក្នុងចំនួនដែលព្រះជាម្ចាស់បានបង្ហាញពួកគេ ដើម្បីផ្តល់ឱ្យនោះទេ ដូច្នេះពួកគេបានធ្វើការ ២៨

ថ្ងៃបន្តទៀត ដើម្បីរកប្រាក់ឱ្យគ្រប់ចំនួន ដើម្បីសាបព្រោះអ្វីដែលព្រះជាម្ចាស់បានបង្ហាញពួកគេ។

តើលទ្ធផលជាអ្វី? អាជីវកម្មរបស់ពួកគេបានដំណើរការ។

នៅឆ្នាំបន្ទាប់ ពួកគេអាចសងបំណុលចំនួន ១៧៥.០០០ ដុល្លារ។ ហើយ ដាស្ទីន បាននិយាយថាគាត់បានរកប្រាក់បានច្រើន ជាង**ដប់ពីរដង**នៅឆ្នាំនោះ ច្រើនជាងចំនួនដែលគាត់ធ្លាប់រកបានក្នុងពេញមួយជីវិត!

ខេនដល និង ដាស្ទីន បានដឹងថាព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការគ្រប់ពេលវេលា!

តើចម្លើយរបស់ពួកគេជាអ្វី? គឺព្រះរាជ្យរបស់ព្រះជាម្ចាស់ និងព្រះគុណរបស់ព្រះជាម្ចាស់!

តើចម្លើយរបស់អ្នកជាអ្វី? គឺព្រះរាជ្យរបស់ព្រះជាម្ចាស់ និងព្រះគុណរបស់ព្រះជាម្ចាស់!

# ជំពូក ២

# ចម្លើយ៖ ព្រះគុណ

នៅក្នុងជំពូកមុន យើងបាននិយាយអំពីរបៀបដែលចិត្តសប្បុរសមានឥទ្ធិពលចំពោះមនុស្សលើផ្នែកព្រលឹងវិញ្ញាណ របៀបដែលវាបន្ទន់ចិត្តពួកគេឱ្យមានការដឹងគុណចំពោះអ្នក និងព្រះជាម្ចាស់។ យើងក៏បានលើកយកនូវអ្វីដែលលោកប៉ូលបាននិយាយផងដែរ គឺថា សមត្ថភាពក្នុងការមានចិត្តសប្បុរស គឺជាលទ្ធផលនៃព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង។

> *គេក៏អធិស្ឋានឱ្យអ្នករាល់គ្នា ដោយស្រលាញ់ជាខ្លាំង ដោយព្រោះព្រះគុណនៃព្រះដ៏លើសលុប ដែលសណ្ឋិតលើអ្នករាល់គ្នា អរព្រះគុណដល់ព្រះអង្គ ដោយព្រោះអំណោយទានទ្រង់ដ៏រកថ្លែងពុំបាន។*
>
> —២ កូរិនថូស ៩:១៤-១៥

យើងបាននិយាយអំពីការសង្កត់ធ្ងន់ ដែលលោកប៉ូលបានដាក់ទៅលើពាក្យថា *លើសលុប* នៅពេលដែលគាត់បានពិពណ៌នាអំពីព្រះគុណដែលព្រះជាម្ចាស់ប្រទានឱ្យយើងដើម្បីឱ្យយើងចម្រុងចម្រើន។ យើងបានរកឃើញថា ព្រះគុណ គឺជាការផ្តល់អំណាចដ៏អស្ចារ្យដើម្បីសម្រេចអ្វីមួយ។ លោកប៉ូលហៅការផ្តល់អំណាចនៃព្រះគុណរបស់ព្រះជាម្ចាស់ ថាជាអំណោយដែលទានដែលមិនអាចពណ៌នាបាន! ខ្ញុំគិតថាគ្រប់គ្នានឹងត្រូវតែទទួលស្គាល់ថា ប្រសិនបើព្រះជាម្ចាស់ផ្ទាល់នឹងជួយពួកគេឱ្យចម្រុងចម្រើនក្នុងជីវិត នោះគឺជាអត្ថប្រយោជន៍ដ៏អស្ចារ្យណាស់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ដើម្បីជួយអ្នកឱ្យយល់អំពីទំហំនៃអ្វីដែលព្រះជាម្ចាស់ចង់ធ្វើលើជីវិតរបស់អ្នក និងអំណាចដ៏ធំសម្បើមដែលមានសម្រាប់អ្នក ចូរយើងមើលខយោងមួយចំនួន ហើយចាប់ផ្ដើមអានខប្រាំមួយ។

*ខ្ញុំចង់និយាយដូច្នេះ គឺថា អ្នកណាដែលព្រោះដោយកំណាញ់ នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះដោយសទ្ធា នោះនឹងច្រូតបានច្រើនវិញ ចូរឱ្យគ្រប់គ្នាធ្វើតាមដែលសម្រេចក្នុងចិត្តចុះ មិនមែនដោយស្ដាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រលាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ ហើយព្រះទ្រង់អាចនឹងធ្វើឱ្យគ្រប់ទាំងព្រះគុណ បានចម្រើនដល់អ្នករាល់គ្នា ប្រយោជន៍ឱ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច ដើម្បីឱ្យបានចម្រើនឡើង ខាងឯការល្អគ្រប់ជំពូក ដូចសេចក្ដីដែលចែងទុកមកថា «ទ្រង់បានចែកសុសសាយ ទ្រង់បានប្រទានទៅពួកទ័លក្រ សេចក្ដីសុចរិតទ្រង់នៅជាប់អស់កល្បជានិច្ច»*

*រីឯព្រះដែលទ្រង់ផ្គត់ផ្គង់ពូជ សម្រាប់អ្នកដែលព្រោះ នឹងអាហារ សម្រាប់បរិភោគផង នោះទ្រង់នឹងផ្គត់ផ្គង់ ហើយចម្រើនពូជដែលអ្នករាល់គ្នាព្រោះនោះដែរ ព្រមទាំងចម្រើនផលពីការសុចរិតរបស់អ្នករាល់គ្នាផង ដូច្នេះ អ្នករាល់គ្នានឹងបានចម្រើនកាន់តែច្រើនឡើងគ្រប់ជំពូក សម្រាប់ជាការសទ្ធាគ្រប់យ៉ាង ដែលនឹងបង្កើតសេចក្ដីអរព្រះគុណដល់ព្រះ ដោយសារយើងរាល់គ្នា។*

—២កូរិនថូស ៩:៦-១១

ឥលូវនេះ នេះជាអ្វីដែលគួរឱ្យរំភើប!

យើងឃើញពាក្យថា*ព្រះគុណ* ដដែល ដែលប្រើនៅទីនេះ លើកលែងតែក្នុងបទគម្ពីរនេះ លោកប៉ូលបន្ថែមគុណនាម*គ្រប់ទាំង* ដើម្បីជួយអ្នកអានឱ្យយល់ថាគ្រប់ទាំងអំណាចរបស់ព្រះជាម្ចាស់ គឺនៅពីក្រោយព្រះគុណ។ លោកប៉ូលកំពុងនិយាយ

យ៉ាងច្បាស់អំពីការឱ្យ និងការទទួលនៅត្រង់នេះ ហើយបញ្ជាក់ថា នៅពេលដែលអ្នកឱ្យ នោះគ្រប់ទាំងព្រះគុណរបស់ព្រះជាម្ចាស់គឺអាចនាំចម្រូតមកអ្នក។

គ្រប់ទាំងព្រះគុណរបស់ព្រះជាម្ចាស់បង្ហាញថា គ្រប់ទាំងអំណាច ប្រាជ្ញា ការសព្វព្រះហឫទ័យ និងការយល់ដឹងរបស់ទ្រង់ ឥលូវនេះមានសម្រាប់អ្នក ដើម្បីប្រមូលផលចំពោះគ្រាប់ពូជនោះ។ ខ្ញុំមិនដឹងអំពីអ្នកទេ ប៉ុន្តែវាធ្វើឱ្យខ្ញុំរំភើប!

ប៉ុន្តែនៅតែមិនមានន័យថា ការប្រមូលផលនឹងកើតដោយខ្លួនឯងគ្រប់យ៉ាងនោះទេ។

បើកសិករមានទ្រព្យសម្បត្តិច្រើនប្រាប់អ្នកថា គាត់នឹងឱ្យអ្នកខ្ចីឧបករណ៍កសិកម្មទាំងអស់របស់គាត់ មានតម្លៃរាប់លានដុល្លារដើម្បីដាំដុះ និងច្រូតកាត់ ប៉ុន្តែអ្នកមិនចេះអ្វីសោះអំពីការធ្វើកសិកម្ម នោះវាគ្មានប្រយោជន៍ឡើយ។

ព្រះជាម្ចាស់បានធ្វើឱ្យគ្រប់ទាំងអំណាចរបស់ទ្រង់ មានសម្រាប់យើង ប៉ុន្តែយើងនៅតែមានតួនាទីដែលត្រូវបំពេញ ដូចជាកសិករដែលដឹងថា ការធ្វើកសិម្មគឺលើសពីគ្រាន់តែសាបគ្រាប់ពូជទៅលើដី។

**បើអ្នកយកចិត្តទុកដាក់ចំពោះកិច្ចការរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងយកចិត្តទុកចំពោះកិច្ចការរបស់អ្នកវិញ។**

សម្រាប់ពេលនេះ អ្វីដែលខ្ញុំចង់ឱ្យអ្នកដឹងនោះគឺថា គ្រប់ទាំងសមត្ថភាពរបស់ព្រះជាម្ចាស់មិនត្រឹមចាំតែជួយអ្នកឱ្យប្រមូលផល បន្ទាប់ពីអ្នកបានសាបព្រោះប៉ុណ្ណោះទេ ប៉ុន្តែដើម្បីជួយអ្នកឱ្យដឹងពីពេលវេលា និងទីកន្លែងដើម្បីសាបព្រោះទៀតផង។ ហើយដោយសារតែហេតុនោះ អ្នកមានហិរញ្ញវត្ថុដែលគ្មានដែនកំណត់មួយនាពេលអនាគត!!!!

ឥលូវនេះយើងចូលដល់ជំហានមួយទៀត ហើយនិយាយអំពីការបើកសម្តែងពិតប្រាកដនៅក្នុងបទគម្ពីរនេះ ដែលដូចគោលបំណងនៃការមានប្រាក់នៅក្នុងជំពូកដំបូងដែរ។

*ព្រះទ្រង់អាចនឹងធ្វើឱ្យគ្រប់ទាំងព្រះគុណ បានចម្រើនដល់អ្នករាល់គ្នា ប្រយោជន៍ឱ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច ដើម្បីឱ្យបានចម្រើនឡើង ខាងឯការល្អគ្រប់ជំពូក។*

យើងបានយល់អំពីរឿងដំបូងដែលព្រះជាម្ចាស់មានបន្ទូល គឺចំពោះអ្វីដែលអ្នកត្រូវការ ឱ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច។ សូមកត់សម្គាល់ថា វាមិនមែនគិតតែពីរឿងប្រាក់មួយមុខនោះទេ។ តែទ្រង់មានបន្ទូលថា*គ្រប់របស់ទាំងអស់* និង*គ្រប់ពេលវេលាទាំងអស់*!

ខ្ញុំតែងតែនិយាយបែបនេះថា «បើអ្នកយកចិត្តទុកដាក់ចំពោះកិច្ចការរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងយកចិត្តទុកចំពោះកិច្ចការរបស់អ្នកវិញ។» ដូច្នេះ «នៅគ្រប់អ្វីៗ និងគ្រប់ពេលវេលាទាំងអស់» មានន័យចំពោះខ្ញុំគឺថា អ្នកនឹងមិនទៅដោយគ្មានអ្វីសោះនោះទេ ទោះជាមានបញ្ហាអ្វីកើតឡើងនៅក្នុងសេដ្ឋកិច្ចក៏ដោយ។ នៅពេលដែលព្រះជាម្ចាស់មានបន្ទូលថា តម្រូវការរបស់អ្នកនឹងត្រូវបានបំពេញ ទ្រង់ក៏មិនមែនកំពុងតែនិយាយអំពីការមានតែមួយរស់ៗនោះដែរ។

*អ្នកនឹងឱ្យទ្រព្យដល់ប្រជាជាតិជាច្រើនខ្ចី តែអ្នកមិនខ្ចីពីគេឡើយ។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងធ្វើឱ្យអ្នកបានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ អ្នកនឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច គឺមិនចុះខិនថយឡើយ។ ប៉ុន្តែអ្នកត្រូវស្តាប់បង្គាប់ ហើយកាន់ និងប្រតិបត្តិតាមបទបញ្ជារបស់ព្រះអង្គ ដែលខ្ញុំប្រគល់ឱ្យអ្នកនៅថ្ងៃនេះ។*

—ទុតិយកថា ២៨៖១២-១៣

នៅពេលដែលព្រះជាម្ចាស់កំពុងមានបន្ទូលអំពីតម្រូវការទាំងអស់របស់អ្នកដែលត្រូវបានបំពេញ ទ្រង់គឺមានបន្ទូលអំពីការដើរនៅកន្លែងដែលមានសេរីភាពហិរញ្ញវត្ថុទាំងស្រុង ដោយគ្មានជំពាក់បំណុលគេ ដើរក្នុងការចាត់តាំងរបស់អ្នកដោយចិត្តឆេះឆួល ហើយបរិភោគភោគផលពីដីដ៏មានជីវជាតិបំផុត។ វាក៏មានន័យថាអ្នកមានសុខភាពល្អ និងមានសន្តិភាពដ៏គ្រប់លក្ខណៈដែរ។

ទីពីរ បន្ទាប់ពីតម្រូវការរបស់អ្នកត្រូវបានបំពេញ អ្នកមិនត្រឹមតែរស់រានមានជីវិតប៉ុណ្ណោះទេ ប៉ុន្តែចម្រុងចម្រើនទៀតផង។

> *អ្នករាល់គ្នានឹងបានចម្រើនកាន់តែច្រើនឡើងគ្រប់ជំពូក* *<u>សម្រាប់ជាការសទ្ធាគ្រប់យ៉ាង។</u>*

លទ្ធផលចុងក្រោយ គឺអ្នកមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ មានចិត្តសប្បុរសដើម្បីធ្វើទាន (ឱ្យ) និងផ្គត់ផ្គង់មនុស្ស ហើយជួយគាំទ្រកិច្ចការរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។

គោលបំណងរបស់ព្រះជាម្ចាស់ គឺធ្វើឱ្យមនុស្សស្គាល់ព្រះហឫទ័យរបស់ទ្រង់ ហើយផ្លាស់ប្ដូរដួងចិត្តរបស់មនុស្សឱ្យត្រលប់ទៅកាន់ព្រះអង្គវិញ។

ដូចខ្ញុំតែងតែនិយាយថា «ព្រះជាម្ចាស់ធ្វើការនៅក្នុងកិច្ចការរបស់មនុស្ស។»

ខ្ញុំសូមចំណាយពេលបន្តិច ដើម្បីដោះស្រាយអំពីការយល់ខុសមួយដែលខ្ញុំបានឮជាញឹកញាប់។

មានពេលមួយខ្ញុំកំពុងនិយាយជាមួយអ្នកមានទ្រព្យស្ដុកស្ដម្ភម្នាក់ ហើយពួកគេបាន និយាយថា «ខ្ញុំមិនត្រូវការប្រាក់បន្ថែមទៀតទេ។ ខ្ញុំមានច្រើនហើយ»។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ឥលូវនេះ ខ្ញុំដឹងពីអ្វីដែលពួកគេកំពុងព្យាយាមនិយាយហើយ គឺថាពួកគេជាអ្នកមានខ្លាំងណាស់ ហើយពួកគេមិនត្រូវការប្រាក់បន្ថែមផ្ទាល់ខ្លួនទៀតទេ។ ប៉ុន្តែតាមការពិតទៅ ពួកគេត្រូវការប្រាក់បន្ថែម ហើយច្រើនទៀតផង។

ប្រសិនបើយើងមើលតែអ្វីដែលប្រាក់អាចធ្វើសម្រាប់យើង*ផ្ទាល់ខ្លួន*នោះ នោះខ្ញុំសន្មតថា មានចំណុចមួយដែលអ្នកនឹងលែងមានចិត្តចង់ទទួលបានប្រាក់បន្ថែមទៀត។ ប៉ុន្តែប្រសិនបើអ្នកយល់អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីឈោងចាប់មនុស្សរាប់លាននាក់ ដែលមិនទាន់បានរកឃើញជីវិតដ៏ល្អវិសេសនៅក្នុងព្រះរាជ្យរបស់ជាម្ចាស់ (ប៉ុន្តែនៅពេលនេះ ពួកគេកំពុងតែធ្វើដំណើរឆ្ពោះទៅស្ថាននរក) នោះអ្នកនឹងដឹងថាព្រះជាម្ចាស់ត្រូវការប្រាក់បន្ថែមទៀតយ៉ាងណា!!!!

សូមអនុញ្ញាតឱ្យខ្ញុំនិយាយម្តងទៀត «**ព្រះជាម្ចាស់ត្រូវការប្រាក់បន្ថែមទៀត!**»

មានកិច្ចការជាច្រើនទៀតដែលត្រូវសម្រេច។

> *ព្រះទ្រង់អាចនឹងធ្វើឱ្យគ្រប់ទាំងព្រះគុណ បានចម្រើនដល់អ្នករាល់គ្នា ប្រយោជន៍ឱ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច <u>ដើម្បីឱ្យបានចម្រើនឡើង ខាងឯការល្អគ្រប់ជំពូក។</u>*

អ្នកមានការងារល្អទាំងអស់ដើម្បីចូលរួមចំណែកធ្វើ។ គ្រប់ទាំងការងារគឺធ្វើតំណាងឱ្យស្តេច។ តាមពិតទៅ អ្នកមានការងារជាក់លាក់ណាស់ យោងតាមគម្ពីរ អេភេសូ ៤:៧, ១១-១២ក។

> *ព្រះអង្គបានផ្តល់ព្រះគុណមកឱ្យយើងម្នាក់ៗតាមកម្រិតព្រះអំណោយទានដែលព្រះគ្រិស្តប្រទានមកយើង។ គឺព្រះអង្គហើយដែលបានប្រទានឱ្យអ្នកខ្លះមានមុខងារជាសាវ័ក ឱ្យអ្នកខ្លះថ្លែងព្រះបន្ទូល អ្នកខ្លះផ្សាយដំណឹងល្អ អ្នកខ្លះ*

*ជាគង្វាល និងអ្នកខ្លះទៀតជាអ្នកបង្រៀន ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធឱ្យបំពេញមុខងារបម្រើ។*

— អេភេសូ ៤:៧, ១១-១២

អ្នកឃើញទេ មនុស្សភាគច្រើនមានបំណងចង់មានសេរីភាពផ្នែកហិរញ្ញវត្ថុ ដោយសារតែពួកគេធុញទ្រាន់នឹងទីប្រណាំងកណ្ដុរ។ ពួកគេកំពុងស្វែងរកសន្តិភាព។ ហើយដោយសារតែការងារភាគច្រើនជាកិច្ចការដែលពួកគេពិតជាមិនចូលចិត្ត ពួកគេកំពុងស្វែងរកសេរីភាពដែលការមានប្រាក់ អាចផ្ដល់ឱ្យពួកគេ។ ពួកគេកំពុងស្វែងរកសេរីភាព ធ្វើអ្វីដែលពួកគេ*ចង់*ធ្វើ ជំនួសឱ្យអ្វីដែលពួកគេ*ត្រូវតែ*ធ្វើ។ ពួកគេចង់ធ្វើតាមចិត្តឆេះឆួលរបស់ខ្លួន និងរកឃើញគោលបំណងនៃជីវិតរបស់ពួកគេ។

នេះជាការលើកឡើងដែលនាំអ្នកឱ្យកាន់សាសនាវង្វេង ៖

*អ្នករាល់គ្នានឹងបានចម្រើនកាន់តែច្រើនឡើងគ្រប់ជំពូក*

ត្រូវហើយ គឺនិយាយអីចឹងមែន។ អ្នកនឹងបានចម្រើនកាន់តែច្រើន!

ឥលូវនេះពាក្យថា ចម្រើនកាន់តែច្រើនឡើង ជាការពិតណាស់ គឺអាស្រ័យលើការយល់ឃើញរបស់មនុស្ស ហើយភាគច្រើនមានការយល់ច្រឡំនៅក្នុងវប្បធម៌របស់យើង។ យើងពិតជាមិនអាចនិយាយថានរណាម្នាក់ដែលមានប្រាក់មួយពាន់លានដុល្លារគឺសប្បាយចិត្តជាងអ្នកដែលមាន ១០០.០០០ ដុល្លារ នោះទេ។ មិនដូច្នេះទេ ការ «ចម្រើនឡើង» មានអត្ថន័យខុសគ្នាចំពោះមនុស្សផ្សេងៗគ្នា។ ប៉ុន្តែជាការពិត វាបង្ហាញថាតម្រូវការទាំងអស់របស់យើងត្រូវបានបំពេញ ឬយើងកំពុងរស់នៅការសងថ្លៃបំណុល ឬរីករាយជាមួយទឹកដីល្អបំផុត។

*ប្រសិនបើអ្នករាល់គ្នាស្ម័គ្រចិត្តស្ដាប់បង្គាប់យើង អ្នករាល់គ្នានឹងបរិភោគផលល្អៗនៅក្នុងស្រុកនេះ។*

—អេសាយ ១:១៩

ប៉ុន្តែការចម្រើនឡើង ឬក្លាយជាអ្នកមាន មិនមែនគ្រាន់តែមានប្រាក់នោះទេ។

**ដូច្នេះជាការបញ្ជាក់ម្តងទៀត គឺព្រះជាម្ចាស់ចង់ឱ្យអ្នកមានការផ្គត់ផ្គង់ហូរហៀរដើម្បីបន្តកិច្ចការរបស់ព្រះអង្គនៅក្នុងពិភពលោកនេះ។**

ពាក្យថាមាននោះក៏អាចនិយាយអំពីការលេងជាមួយចៅរបស់ខ្ញុំ ការកាន់ដៃជាមួយប្រពន្ធខ្ញុំ និងធ្វើរឿងដ៏អស្ចារ្យជាច្រើនទៀតនៅក្នុងជីវិត។ ឌ្រិនដា និងខ្ញុំមានកូនដ៏គួរឱ្យស្រលាញ់ប្រាំនាក់ សុទ្ធតែស្រលាញ់ព្រះជាម្ចាស់ ហើយខ្លះទៀតក៏មានការចូលរួមក្នុងព័ន្ធកិច្ចព្រះជាម្ចាស់។ យើងទាំងអស់គ្នារស់នៅក្បែរគ្នា ហើយនិយាយដោយត្រង់ទៅ យើងពិតជាចូលចិត្តដើរលេងជាមួយគ្នាណាស់។ រឿងទាំងនោះ ខ្ញុំហៅថាជាអ្នកមានហើយ!

អ្នកឃើញទេ អ្នកកាន់សាសនាគិតថា មានប្រាក់ច្រើនគឺលោភលន់។ ប៉ុន្តែប្រាក់ប៉ុណ្ណាក៏មិនច្រើនពេកដែរ ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមមនុស្សដែលធ្វើអាជីវកម្មជាមួយព្រះជាម្ចាស់។ តែងតែមានកិច្ចការថ្មីៗ និងទឹកដីថ្មីដែលត្រូវយក។

ដូច្នេះម្តងទៀត ព្រះជាម្ចាស់ចង់ឱ្យអ្នកមានការផ្គត់ផ្គង់ហូរហៀរ ដើម្បីបន្តកិច្ចការរបស់ព្រះអង្គនៅក្នុងពិភពលោកនេះ។

ព្រះជាម្ចាស់ចង់ឱ្យអ្នកមានចិត្តសប្បុរសសម្រាប់ទ្រង់ ជួយមនុស្ស និងផ្តល់ប្រាក់ដល់កិច្ចការរបស់ទ្រង់។ បើអ្នកនឹងអាចមានចិត្តសប្បុរសនៅគ្រប់ពេលវេលា អ្នកត្រូវតែមានប្រាក់មួយ ចំនួនផងដែរ។

ខ្ញុំចង់មានន័យថា គ្រប់ពេលវេលាអាចមានជា*រៀងរាល់ថ្ងៃ ឬច្រើនដងក្នុងមួយថ្ងៃ*។ ចូរនិយាយដោយត្រង់ ដើម្បីអាចធ្វើបានដូច្នេះបាន អ្នកនឹងមិនអាចរស់ពីមួយខែដើម្បីខែមួយខែនោះទេ អ្នកត្រូវមានប្រាក់ច្រើនជាងអ្វីដែលអ្នកត្រូវចំណាយ គឺមានច្រើនទៀត! ខ្ញុំគិតថាអ្នករាល់គ្នានឹងយល់ស្របចំពោះរឿងនេះ។

ប៉ុន្តែសូមមើលទៅកន្លែងដែលសំខាន់បំផុត នៅពេលយើងនិយាយអំពីការមានចិត្តសប្បុរស ឬការផ្តល់ឱ្យជាទូទៅ ៖

អ្នកត្រូវតែដោះស្រាយជាមួយនឹងការភ័យខ្លាចនៅពេលអ្នកផ្តល់ឱ្យ។

ខ្ញុំមិនបាននិយាយថា អ្នកត្រូវតែ*ទ្រាំទ្រនឹង*ភាពភ័យខ្លាចនោះទេ។ ខ្ញុំបាននិយាយថាអ្នកត្រូវតែ**ដោះស្រាយ**ជាមួយនឹងការភ័យខ្លាចនៅពេលអ្នកផ្តល់ឱ្យ។ ហើយវិធីល្អបំផុតដើម្បីដោះស្រាយជាមួយនឹងការភ័យខ្លាចគឺជាមួយសេចក្តីពិត!

ដូច្នេះតើអ្វីទៅជាការភ័យខ្លាចក្នុងការផ្តល់ឱ្យ? និយាយឱ្យចំទៅ គឺថាយើងនឹងមិនមានគ្រប់គ្រាន់សម្រាប់ខ្លួនយើងទេ ត្រូវឬអត់?

អ្នកប្រហែលជាគិតថា *ខ្ញុំត្រូវការប្រាក់នោះ* ហើយពិតណាស់ អ្នកត្រូវការវា។ ប៉ុន្តែ ព្រះជាម្ចាស់ក៏ត្រូវការវាដែរ។ ហើយព្រះជាម្ចាស់នឹងមិនសុំឱ្យអ្នកផ្តល់ឱ្យទ្រង់នូវប្រាក់របស់អ្នកដើម្បីប្រើដោយគ្មានការសន្យាថានឹងឱ្យត្រលប់មកអ្នកវិញនោះទេ ការត្រលប់មកវិញជាមួយការវិនិយោគរបស់អ្នក តើទ្រង់មានបន្ទូលដូច្នេះឬ? ខ្ញុំគិតថា ទ្រង់មានបន្ទូលយ៉ាងច្បាស់នៅក្នុងព្រះបន្ទូលទ្រង់ ៖

> *ចូរឱ្យទៅគេ នោះនឹងបានឱ្យមកអ្នកដែរ គេនឹងវាល់ឱ្យអ្នកយ៉ាងល្អ ទាំងញាត់ទាំងរលាក់ ហើយដាក់ឱ្យហៀរ នឹងយកមកដាក់បំពេញចិត្តអ្នកផង។*
>
> —លូកា ៦:៣០

ព្រះជាម្ចាស់ចំណាយពេលបន្ថែមទៀត ដើម្បីពន្យល់អ្នកអំពីអត្ថប្រយោជន៍នៃការផ្គត់ផ្គង់នៃព្រះរាជ្យរបស់ទ្រង់ បន្ទាប់មកទ្រង់បង្រៀនអ្នកអំពីអ្វីដែលត្រូវធ្វើ។ ទ្រង់មានបន្ទូលពាក្យមួយថា «ផ្តល់ឱ្យ» ប៉ុន្តែ ប្រើ២៣ពាក្យដើម្បីពន្យល់ពីអត្ថប្រយោជន៍ទៅកាន់អ្នក។ ខ្ញុំគិតថាខ្ញុំនឹងចុះកិច្ចសន្យាណាមួយដែលអាចបង្រៀនបែបនោះដែរ!

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ចូរដឹងថាព្រះជាម្ចាស់សព្វព្រះហឫទ័យចំពោះអ្វីដែលអ្នកធ្វើបានល្អ។ គិតអំពីវា៖ តើព្រះជាម្ចាស់នឹងទៅរកប្រាក់នៅឯណា តើទ្រង់ត្រូវការផ្ដល់ជំនួយ តាមដំណាក់កាលរបស់ទ្រង់មែនទេ? ប្រាក់នោះនឹងត្រូវមកតាមរយៈអ្នក តាមរយៈខ្ញុំ និងបងប្អូនរួមជំនឿផ្សេងទៀត។ ពិតណាស់ អ្នកដើរតាមសាតាំង នឹងមិនផ្ដល់ជំនួយចំពោះកិច្ចការរបស់ព្រះជាម្ចាស់នោះទេ។

រឿងដែលគួរឱ្យសោកស្ដាយគឺថាអ្នកជឿភាគច្រើននិយាយថាវាគឺជាកំហុសដែលថាព្រះជាម្ចាស់នឹងប្រទានត្រលប់មកវិញនូវអ្វីដែលពួកគេបានថ្វាយ។ ពួកគេជឿថាការថ្វាយតង្វាយ និងការរំពឹងចង់បានអ្វីត្រលប់មកវិញ នោះជាមូលដ្ឋាននៃភាពលោភលន់ និងមានការធ្លាក់ចុះនៃសកម្មភាពដ៏បរិសុទ្ធក្នុងការថ្វាយបង្គំព្រះជាម្ចាស់។

តើអ្នកជឿថាកសិករម្នាក់មានកំហុសដែរឬទេ ក្នុងការជឿថាការថ្វាយតង្វាយនោះនឹងបង្កើនផលចំណេញសម្រាប់គាត់ និងគ្រួសាររបស់គាត់? គាត់អាចប្រើពាក្យទូទៅថាព្រះជាម្ចាស់ជាអ្នកប្រទានពរដល់គាត់។

ព្រះជាម្ចាស់សព្វព្រះហឫទ័យឃើញយើងចម្រុងចម្រើន។ ទ្រង់បានប្រទានឱ្យយើងនូវច្បាប់នៃការសាបព្រោះ និងច្រូតផល សម្រាប់ប្រយោជន៍របស់យើង។ អារក្សបានកុហកក្រុមជំនុំអំពីការថ្វាយតង្វាយ និងប្រាក់ ចាប់តាំងពីដើមដំបូងមក។ និកាយខ្លះមានមោទនភាពចំពោះការគ្មានទ្រព្យសម្បត្តិរបស់ពួកគេ ដោយមិនដឹងថាពួកគេកំពុងធ្លាក់ចុះទៅក្នុងការកុហករបស់សាតាំងឡើយ។ ព្រះយេស៊ូបានដោះស្រាយចំពោះរឿងរ៉ាវបែបនោះជាច្រើនដងក្នុងព័ន្ធកិច្ចរបស់ទ្រង់។ តាមពិតទៅ ទ្រង់បានមានបន្ទូលប្រាប់ពីប្រស្នាដ៏ល្បីល្បាញមួយ ដែលទាក់ទងទៅនិងបញ្ហាគ្រប់យ៉ាង នោះគឺជាប្រស្នាអំពីសាសន៍សាម៉ារីចិត្តល្អ។

*ពេលនោះ មានបណ្ឌិតខាងវិន័យម្នាក់ក្រោកឈរទូលសួរព្រះយេស៊ូ ក្នុងគោលបំណងចង់ចាប់កំហុសព្រះអង្គថា៖ «លោកគ្រូ! តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យបាន*

*ទទួលជីវិតអស់កល្បជានិច្ច?»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «តើក្នុងក្រឹត្យវិន័យមានចែងអ្វីខ្លះ? ពេលលោកអាន តើលោកយល់យ៉ាងណា?»។ គាត់ទូលទៅព្រះយេស៊ូថា៖ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឱ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីកម្លាំង និងអស់ពីប្រាជ្ញា ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗឱ្យបានដូចស្រឡាញ់ខ្លួនឯងដែរ»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «លោកឆ្លើយត្រឹមត្រូវល្អណាស់ សុំធ្វើដូច្នេះទៅ នោះលោកនឹងមានជីវិតអស់កល្បជាមិនខាន»។ ប៉ុន្តែ អាចារ្យនោះចង់បង្ហាញថា សំណួររបស់គាត់ជាសំណួរត្រឹមត្រូវ គាត់ក៏សួរព្រះយេស៊ូទៀតថា៖ «តើនរណាជាបងប្អូនរបស់ខ្ញុំ?»។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានបុរសម្នាក់ធ្វើដំណើរចុះពីក្រុងយេរូសាឡឹម ឆ្ពោះទៅក្រុងយេរីខូ។ គាត់ធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកចោរ វាប្លន់គាត់ ថែមទាំងវាយដំគាត់ឱ្យរបួសជាទម្ងន់ រួចនាំគ្នារត់បាត់អស់ទៅ ទុកគាត់ចោលនៅស្ដូកស្ដឹងបាត់ស្មារតីមិនដឹងខ្លួន។ ពេលនោះ មានបូជាចារ្យ*មួយរូបធ្វើដំណើរចុះតាមផ្លូវនោះ។ គាត់ឃើញបុរសនោះ ក៏ដើរវាងហួសទៅ។ មានម្នាក់ពីក្រុមលេវី*ដើរមកដល់កន្លែងនោះដែរ។ គាត់ឃើញបុរសនោះ ក៏ដើរវាងហួសទៅ។ គាប់ជួនជាមានអ្នកស្រុកសាម៉ារីម្នាក់ ធ្វើដំណើរមកតាមផ្លូវនោះដែរ គាត់ឃើញបុរសនោះ គាត់មានចិត្តអាណិតអាសូរពន់ពេកណាស់។ គាត់ចូលទៅជិតអ្នករបួស យកប្រេង និងស្រា ចាក់ពីលើមុខរបួស រុំរបួសឱ្យ រួចគាត់លើកអ្នករបួសដាក់លើជំនិះរបស់គាត់ នាំទៅផ្ទះសំណាក់ ហើយថែទាំអ្នករបួសនោះ។ ស្អែកឡើង គាត់យកប្រាក់ប្រគល់ឱ្យម្ចាស់ផ្ទះសំណាក់ ទាំងផ្ដាំថា "សូមថែទាំបុរសនេះផង ប្រសិនបើអ្នកចំណាយលើសពីប្រាក់នេះ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងជូនបង្គ្រប់"។ ក្នុងចំណោមមនុស្សទាំងបីនាក់ តើលោកយល់ថា អ្នកណាចាត់ទុកខ្លួនជាបងប្អូននឹងបុរស ដែលធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកចោរប្លន់នោះ?»។ អាចារ្យឆ្លើយថា៖ «គឺអ្នកដែលមានចិត្តមេត្តា*

*ករុណាចំពោះគាត់»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំលោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឱ្យបានដូចអ្នកនោះទៅ»។*

—លូកា ១០:២៥-៣៧

ខ្ញុំគិតថាយើងទាំងអស់គ្នាបានឮអំពីប្រស្នានេះ ជាមួយនឹងមេរៀនទាំងនោះរួចហើយ ៖ តើព្រះជាម្ចាស់នឹងធ្វើយ៉ាងណា ប្រសិនបើទ្រង់កំពុងដើរតាមផ្លូវ ហើយបានឃើញបុរសម្នាក់នេះ? យើងដឹងថា ព្រះអម្ចាស់មិនទុកឱ្យបុរសដែលគេបានវាយដំនេះស្លាប់នៅតាមផ្លូវឡើយ។

មេរៀនដែលថ្នាក់រៀនថ្ងៃអាទិត្យភាគច្រើនតែងតែបង្រៀនពីប្រស្នានេះ គឺត្រូវធ្វើជាអ្នកជិតខាងដ៏ល្អ។ ត្រូវមើលថែមនុស្ស។ ការមើលថែមនុស្ស ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយខ្ញុំអាចនិយាយថា ខ្ញុំយល់ស្របមួយរយភាគរយជាមួយ ជាមួយការយល់បែបនោះ។ ទោះបីជា មានចន្លោះប្រហោងជាច្រើន ហើយជារឿយៗមិនអាចបំពេញចន្លោះបានក៏ដោយ។

ដើម្បីពិតជាយល់អំពីការស្តីបន្ទោសរបស់ព្រះយេស៊ូចំពោះគ្រូបង្រៀនក្រឹត្យវិន័យ អ្នកត្រូវយល់ពីបរិយាកាសសង្គមនៅសម័យនោះសិន។ ជនជាតិយូដាមើលងាយសាសន៍សាម៉ារី ហើយចាត់ទុកពួកគេថាជាដែលអ្នកមិនស្អាត មិនមានជីវិតខាងព្រលឹងវិញ្ញាណ។ ដូច្នេះ ជនជាតិយូដាបានចាត់ទុកខ្លួនឯងថាជាអ្នកវិសុទ្ធជាងគេ ហើយសុចរិតនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ជាងសាសន៍សាម៉ារី។ សូម្បីតែការតប់ប្រសព្វជាមួយគ្នាក៏គ្មានដែរ។ ដូច្នេះរឿងរបស់ព្រះយេស៊ូគឺដូចជាការទះកំផ្លៀងគ្រូក្រឹត្យវិន័យនេះ ដោយស្តីបន្ទោសចំពោះអាកប្បកិរិយាដ៏គួរឱ្យគោរពរបស់ពួកគេ។ ខ្ញុំគិតថាយើងទាំងអស់គ្នាយល់អំពីរឿងរ៉ាវទាំងនេះហើយ។

ប៉ុន្តែផ្នែកដែលខ្ញុំមិនធ្លាប់ឮ ហើយខ្ញុំចង់មានន័យថាជាផ្នែកមិនដែលឮបង្រៀនក្នុងថ្នាក់រៀនថ្ងៃអាទិត្យសោះ នោះគឺជាផ្នែកពាក់ព័ន្ធនឹងប្រាក់បួនកាក់។ ហេតុអ្វី

បានជាព្រះយេស៊ូនិយាយអំពីប្រាក់បួនកាក់នេះ? តើអ្វីដែលទ្រង់បានធ្វើនេះ វាទាក់ទងទៅនឹងកំហុសរបស់គ្រូក្រឹត្យវិន័យចំពោះសាសន៍សាម៉ារីដែរឬយ៉ាងណា? យើងនឹងស្វែងយល់ជាមួយគ្នា។

> *រួចលើកដាក់លើសត្វជាជំនិះរបស់ខ្លួន ដឹកនាំទៅឯផ្ទះសំណាក់ ថែទាំរក្សាគាត់ ស្អែកឡើង កាលគាត់រៀបនឹងចេញទៅ នោះក៏យកប្រាក់៤កាក់ ហុចដល់ម្ចាស់ផ្ទះនោះ ដោយប្រាប់ថា ចូរថែរក្សាអ្នកនេះផង បើចំនួនជាអ្នកចាយលើសពីនេះទៅ នោះដល់ខ្ញុំមកវិញ ខ្ញុំនឹងសងអ្នក"។*

—លូកា ១០៖៣៤-៣៥ (ព្រះគម្ពីរបរិសុទ្ធ)

ក្នុងរឿងនេះព្រះយេស៊ូកំពុងបង្រៀនយើង យើងក៏អាចឃើញនូវភាពស្រដៀងគ្នាចំពោះអ្វីដែលព្រះយេស៊ូនឹងធ្វើសម្រាប់យើងផងដែរ។ យើងអាចមើលឃើញមនុស្សជាតិត្រូវបានគេវាយឱ្យត្រូវរបួស ដោយអារក្សសាតាំង វាគឺជាចោរ។ យើងយល់ពីប្រេង និងស្រាគឺតំណាងឱ្យព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះលោហិត ជាសម្ពន្ធមេត្រីដែលព្រះយេស៊ូនឹងប្រទានដល់អស់អ្នកដែលមករកទ្រង់។ ហើយយើងឃើញក្នុងរឿងនេះថាបន្ទាប់ពីលាបប្រេង និងស្រារួចហើយ សាសន៍សាម៉ារីក៏ធ្វើមួយដំណាក់កាលទៀត ដោយបញ្ជូនបុរសរងគ្រោះនេះទៅផ្ទះសំណាក់មួយដើម្បីព្យាបាល។ សាសន៍សាម៉ារីដឹងថាបុរសនេះត្រូវការពេលវេលាដើម្បីព្យាបាល ហើយគាត់បាននាំបុរសនេះទៅកន្លែងមានសុវត្ថិភាពដើម្បីឱ្យជាសះស្បើយ។ ដោយគ្រប់ទាំងការចំណាយគឺសាសន៍សាម៉ារីជាអ្នកចេញថ្លៃ។

ខ្ញុំជឿថាផ្ទះសំណាក់តំណាងឱ្យក្រុមជំនុំក្នុងតំបន់។ នេះជាកន្លែងដែលព្រះយេស៊ូនាំមនុស្សដែលត្រូវបានគេវាយដំ និងមានរបួសជិតស្លាប់ដេកដួលនៅតាមផ្លូវនៃជីវិត។ ពួកគេបានកើតជាថ្មី ដោយត្រូវបានសម្អាតពីបាបដោយព្រះលោហិតនៃសម្ពន្ធមេត្រី ហើយបានធ្វើឱ្យរស់ឡើងវិញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែពួកគេនៅតែបន្ត

ជាមួយស្នាមប្រឡាក់ និងការឈឺចាប់របស់ពួកគេក្នុងប្រព័ន្ធនៃបណ្ដាសាលោកិយ។ ពួកគេត្រូវការពេលវេលាដើម្បីព្យាបាល និងរៀនពីរបៀបរស់នៅថ្មីទាំងស្រុង។ ព្រះយេស៊ូបានដាក់ពួកគេនៅក្នុងក្រុមជំនុំក្នុងតំបន់មួយ ហើយនៅក្រោមការមើលថែរបស់ម្ចាស់ផ្ទះសំណាក់មួយ ជាគ្រូគង្វាលក្នុងតំបន់ ដើម្បីពិនិត្យវឌ្ឍនភាពរបស់ពួកគេ។

ប៉ុន្តែគួរឱ្យសោកស្ដាយ យើងឃើញពីលក្ខណៈស្រដៀងគ្នានៅក្នុងក្រុមជំនុំដែលគ្រូខាងក្រឹត្យវិន័យបានធ្វើ។ មនុស្សមិនចង់រួមចំណែកជួយនៅផ្ទះសំណាក់ទេ។ ដូចអ្នកដែលដើរឆ្លងកាត់អ្នករបួសអឺចឹង ពួកគេបានចាត់ទុកបញ្ហារបស់គាត់ជាបញ្ហារបស់អ្នកដទៃ។ ហេតុអ្វីបានជាពួកគេគួររួមចំណែក? តើមានប្រយោជន៍អ្វីសម្រាប់ពួកគេក្នុងការជួយនោះ ផ្ទុយទៅវិញវាជាការខាតបង់ពេលវេលា និងប្រាក់របស់ពួកគេប៉ុណ្ណោះ?

ដោយសារតែបែបនេះហើយ ទើបគ្រូគង្វាលត្រូវចំណាយពេលជាច្រើនក្នុងការសុំឱ្យមនុស្សជួយថែទាំ ឬជួយដឹកនាំក្រុមតូចមួយ។ ប៉ុន្តែវាហាក់ដូចជាមនុស្សកំពុងរវល់ធ្វើរឿងផ្ទាល់ខ្លួនរបស់គេ ហើយពិបាកស្វែងរកអ្នកមានការប្ដេជ្ញាចិត្តឱ្យជួយណាស់។ សាសនាផ្ទាល់មិនមានការលើកទឹកចិត្តឱ្យជួយទេ មានតែកាតព្វកិច្ច និងច្បាប់ប៉ុណ្ណោះ។ សាសនាព្យាយាមដាក់ទោសទៅលើមនុស្សឱ្យជួយ ដោយនិយាយថា «អ្នកជំពាក់ព្រះជាម្ចាស់ ក្នុងការដោះស្រាយរឿងនេះ រឿងនោះ។ បន្ទាប់មកនិយាយថា សូមក្រឡេកមើលអ្វីដែលព្រះបានធ្វើសម្រាប់អ្នក»។ ហើយខ្ញុំយល់ស្រប យើងគួរតែមានឆន្ទៈ និងដឹងគុណជានិច្ចចំពោះព្រះជាម្ចាស់ ហើយមានបំណងចង់ជួយអ្នកដទៃ ប៉ុន្តែព្រះជាម្ចាស់មិនប្រើទម្រង់ដោយមានបន្ទូលថា «អ្នកជំពាក់យើង» នោះឡើយ។ ទ្រង់មានបន្ទូលថា «ខ្ញុំទុកប្រាក់បួនកាក់ដើម្បីទូទាត់ការចំណាយ ហើយនឹងសងអ្នកពេលខ្ញុំត្រលប់មកវិញ **ទោះជាត្រូវចំណាយប៉ុន្មាន**ក៏ដោយ»។

## ចម្លើយ៖ ព្រះគុណ

ជាថ្មីម្តងទៀត ផ្នត់គំនិតសាសនានឹងយកសេចក្តីថ្លែងការណ៍នោះ ជាអត្ថន័យ នៅពេលយើងឡើងទៅស្ថានសួគ៌ នោះព្រះយេស៊ូនឹងប្រទានរង្វាន់ដល់យើងសម្រាប់កិច្ចការដែលយើងបានធ្វើនៅលើផែនដីនេះ សម្រាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់។ មិនមែនទេ នៅពេលព្រះយេស៊ូនិទានរឿងនោះ ទ្រង់ចង់សំដៅដល់ពេលដែលអ្នកជំនួញនឹងត្រូវធ្វើដំណើរឆ្លងកាត់ត្រលប់ទៅទីក្រុងវិញ។ ព្រះយេស៊ូបាននិយាយអំពីជំនួយហិរញ្ញវត្ថុ តាមពេលវេលាជាក់ស្តែងសម្រាប់ម្ចាស់ផ្ទះសំណាក់នោះ។ ប៉ុន្តែមនុស្សឥលូវនេះនឹងនិយាយថា «អស្ចារ្យណាស់ ព្រះជាម្ចាស់នឹងរ៉ាប់រងការចំណាយរបស់ផ្ទះសំណាក់ ខណៈពេលដែលកំពុងមើលថែមនុស្សម្នាក់នេះ ប៉ុន្តែខ្ញុំក៏មានការចំណាយពិតប្រាកដនៅផ្ទះរបស់ខ្ញុំដែរ។ ខ្ញុំមិនអាចមានពេលវេលា ឬប្រាក់ដើម្បីរួមចំណែកជួយបានឡើយ»។ ផ្នត់គំនិតដែលគិតថា នឹងទទួលបានការសងវិញសម្រាប់ការចំណាយណាមួយក្នុងការចូលរួមនោះ គឺការមិនបានលើកទឹកចិត្តមនុស្សជាច្រើនឱ្យចេះជួយគ្នាទេ។ ពិតណាស់ យើងអាចធ្វើដូច្នេះបាន ប៉ុន្តែវាមិនបានបង្ហាញរឿងនៃសេចក្តីស្រលាញ់យ៉ាងពេញលេញរបស់ព្រះជាម្ចាស់ ចំពោះអ្នកដែលបានរួមចំណែកជួយនោះឡើយ។

ពិតមែនហើយ ខ្ញុំដឹងថាអ្នកនឹងនិយាយ ៖ «យើងគួរតែជួយចេញថ្លៃផ្ទះសំណាក់ទាំងអស់គ្នា ដើម្បីបង្ហាញសេចក្តីស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់»។ ពិតមែនហើយ អ្នកគួរតែធ្វើវាដោយចិត្តស្មោះត្រង់ទៅចំពោះគ្រូគង្វាលរបស់អ្នក មនុស្សជាទីស្រលាញ់របស់អ្នក និងកាតព្វកិច្ចចំពោះព្រះជាម្ចាស់ ហើយវាទាមទារនូវរឿងរ៉ាវមួយចំនួន... ប៉ុន្តែព្រះជាម្ចាស់ចង់ឱ្យអ្នកមានចិត្តរំភើបរីករាយចំពោះ «ការងារនៅឯផ្ទះសំណាក់» ជាមួយព្រះអង្គ។

នោះជាចំណុចសំខាន់ យើងមិនមែនធ្វើការ**សម្រាប់**ព្រះជាម្ចាស់នោះទេ ប៉ុន្តែធ្វើការ**ជាមួយ**ព្រះជាម្ចាស់ច្រើនជាង។ ព្រះអង្គផ្ទាល់មានបន្ទូលដូចខាងក្រោម តាមរយៈលោកប៉ូល៖

*មិនដែលមាននរណាបម្រើកងទ័ព ហើយចេញសោហ៊ុយខ្លួនឯងឡើយ មិនដែលមាននរណាដាំទំពាំងបាយជូរ ហើយមិនបរិភោគផ្លែនោះទេ ក៏មិនដែលមាននរណាចិញ្ចឹមហ្វូងសត្វ ហើយមិនពិសាទឹកដោះរបស់សត្វក្នុងហ្វូងនោះដែរ។ ខ្ញុំនិយាយដូច្នេះ មិនមែនត្រឹមតែតាមរបៀបរបស់មនុស្សទេ សូម្បីតែក្នុងក្រឹត្យវិន័យក៏មានចែងដូចគ្នាដែរ គឺក្នុងវិន័យរបស់លោកម៉ូសេមានចែងទុកថា៖ «កុំឃ្លុំមាត់គោ នៅពេលបញ្ជាន់ស្រូវនោះឡើយ»។ តាមពិត ព្រះជាម្ចាស់មិនខ្វល់ខ្វាយនឹងគោទេ ព្រះអង្គមានព្រះបន្ទូលដូច្នេះ មកពីព្រះអង្គគិតដល់យើង។ ពិតមែនហើយ ក្នុងគម្ពីរមានចែងទុកដូច្នេះសម្រាប់យើង។ អ្នកដែលភ្ជួររាស់ ត្រូវសង្ឃឹមថានឹងបានផល ហើយអ្នកបោកបែនក៏ត្រូវសង្ឃឹមថានឹងបានផលដែរ។*

—១កូរិនថូស ៩:៧-១០

ព្រះជាម្ចាស់មិនចង់ឱ្យអ្នកបម្រើទ្រង់ដោយសារភ័យខ្លាច ឬកាតព្វកិច្ចទេ។

សូមកត់សម្គាល់នូវអ្វីដែលទ្រង់មានបន្ទូល *«អ្នកដែលភ្ជួររាស់ ត្រូវសង្ឃឹមថានឹងបានផល ហើយអ្នកបោកបែនក៏ត្រូវសង្ឃឹមថានឹងបានផលដែរ»*។ ព្រះជាម្ចាស់មិនគ្រាន់តែខ្វល់ខ្វាយចំពោះការប្រមូលផល ជាលទ្ធផលនៃកិច្ចការដែលទ្រង់ឱ្យអ្នកធ្វើនោះទេ។ ទ្រង់ក៏យកចិត្តទុកដាក់ចំពោះអ្នកដែលកំពុងធ្វើការនៅទីនោះជាមួយនឹងទ្រង់ផងដែរ ទ្រង់ចង់ឱ្យពួកគេចូលរួមក្នុងអំណរនៃការប្រមូលផលដូចទ្រង់ដែរ។

ព្រះយេស៊ូបានជ្រើសរើសម្ចាស់ផ្ទះសំណាក់ម្នាក់នៅក្នុងរឿងនោះ គឺមានហេតុផលដ៏សំខាន់មួយ។ យើងដឹងថាម្ចាស់ផ្ទះសំណាក់បានកំពុងតែដំណើរការអាជីវកម្ម។ គាត់បានដាក់ចំណាយផ្សេងៗសម្រាប់អាជីវកម្ម និងប្រាក់ឈ្នួលបុគ្គលិក ទៅក្នុងអត្រាជួលប្រចាំថ្ងៃរបស់គាត់។ ប៉ុន្តែបន្ថែមពីលើចំណាយទាំងអស់ដើម្បីដំណើរការផ្ទះសំណាក់ គាត់បន្ថែមប្រាក់ចំណេញរបស់គាត់។ មែនហើយ គឺ*ប្រាក់ចំណេញ*។

គ្រប់ពេលដែលម្ចាស់ផ្ទះសំណាក់គិតប្រាក់ពីភ្ញៀវរបស់គាត់ ដែលមកស្នាក់នៅមួយយប់ គាត់គឺរកបានប្រាក់ចំណេញ។ ដោយសារតែហេតុនេះ ទើបម្ចាស់ផ្ទះសំណាក់គិតថាមានការលំបាកចំពោះអ្នករងរបួស ដែលបាននាំមកដាក់នៅមាត់ទ្វារផ្ទះរបស់គាត់។ វាមិនចំណាយប្រាក់មួយសេនសោះក្នុងការមើលថៃគាត់ ព្រោះអ្នកធ្វើដំណើរសន្យាថានឹងរ៉ាប់រងការចំណាយទាំងប៉ុន្មាន។ ប៉ុន្តែម្ចាស់ផ្ទះសំណាក់ដឹងការពិតដែលគាត់អាចជួយបុរសម្នាក់នេះដើម្បីកុំឱ្យមានការថ្នាំងថ្នាក់ចិត្ត។ តាមពិតម្ចាស់ផ្ទះស្ទើរតែហួសចិត្តទៅហើយ ចំពោះឱកាសដែលគាត់បានជួបប្រទេះនេះ។

អ្នកឃើញទេ ម្ចាស់ផ្ទះសំណាក់យល់ថារាល់យប់ ដែលបុរសនេះស្នាក់នៅនៅទីនេះ គាត់នឹងបានប្រាក់ចំណេញ ហើយជាមួយនឹងមូលប្បទានបត្រដែលផ្តល់ជូនដោយអ្នករកស៊ីដែលធ្វើដំណើរនោះ គាត់រីករាយណាស់។ ខ្ញុំអាចស្រមៃបាន។ ការសន្ទនារបស់ម្ចាស់ផ្ទះសំណាក់ជាមួយអ្នករកស៊ុ នៅពេលគាត់ដែលកំពុងធ្វើដំណើរចាកចេញ ៖ «អេ្ហ! បើអ្នកឃើញនរណាម្នាក់ផ្សេងទៀតដែលត្រូវការជំនួយនៅតាមផ្លូវ ត្រូវប្រាកដថានាំពួកគេមកទីនេះ។ ខ្ញុំនឹងទទួលអស់អ្នកណាដែលអ្នកនាំមកផ្ទះសំណាក់ខ្ញុំ បើខ្ញុំអស់បន្ទប់ ខ្ញុំនឹងធ្វើបន្ថែមទៀត!»

**គួរឱ្យសោកស្តាយ ពួកគេខកខានមិនបានយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលទ្រង់ស្ម័គ្រព្រះហឫទ័យក្នុងការបង់ថ្លៃ ដើម្បីឈោងចាប់មនុស្ស ទោះអស់តម្លៃប៉ុន្មានក៏ដោយ ហើយទ្រង់តែងតែប្រទាននូវអ្វីដែលមានច្រើនជាងការខំប្រឹងធ្វើរបស់យើងជានិច្ច។**

ដូចដែលអ្នកអាចឃើញអីចឹង មានរឿងជាច្រើនទៀត ជាជាងរឿងដែលអ្នកធ្លាប់ដឹងអំពីអ្វីដែលព្រះយេស៊ូធ្វើ។ ព្រះយេស៊ូព្យាយាមកែតម្រូវផ្នត់គំនិតបែបសាសនាដែលអ្នកប្រាជ្ញខាងវិន័យមានចំពោះព្រះជាម្ចាស់ និងសាសន៍សាម៉ារី។ ទ្រង់កំពុងតែធ្វើ

ឱ្យមានព្រឹត្តិការណ៍មួយកើតឡើងដើម្បីឱ្យអ្នកប្រាជ្ញខាងវិន័យដឹងថា ពួកគេកំពុងតែបាត់បងឱកាសដ៏អស្ចារ្យដែលសាសន៍សាម៉ារី ចាប់យក គឺ*ផលចំណេញ*!

ខ្ញុំតែងតែសោកស្តាយពេលឮគេនិយាយថា ព្រះជាម្ចាស់ធ្វើអាក្រក់ចំពោះមនុស្សល្អ ឬខ្ញុំឃើញមនុស្សបម្រើព្រះជាម្ចាស់ដោយសារតែកាតព្វកិច្ចសាសនា ជំនួសឱ្យជីវិតដ៏រំភើបរីករាយដែលពួកគេអាចមាន។ សាតាំងបានព្យាយាមលាក់សេចក្តីល្អរបស់ព្រះជាម្ចាស់ពីប្រជារាស្ត្រទ្រង់ ដើម្បីកុំឱ្យពួកគេស្ម័គ្រចិត្តបម្រើទ្រង់ដោយអស់ពីចិត្ត។

សម្រាប់មនុស្សភាគច្រើន ការទៅក្រុមជំនុំគ្រាន់តែជាព្រឹត្តិការណ៍មួយផ្សេងទៀតនៅលើប្រតិទិនប៉ុណ្ណោះ ជំនួសឱ្យការយល់ថាពួកគេថាជាក្រុមជំនុំ ជាផ្ទះសំណាក់ដែលព្រះជាម្ចាស់បញ្ជូនមនុស្សឱ្យទទួលបានភាពពេញលេញ។ គួរឱ្យសោកស្តាយ ពួកគេខកខានមិនបានយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលទ្រង់ស្ម័គ្រព្រះហឫទ័យក្នុងការបង់ថ្លៃ ដើម្បីឈោងចាប់មនុស្ស ទោះអស់តម្លៃប៉ុន្មានក៏ដោយ ហើយទ្រង់តែងតែប្រទាននូវអ្វីដែលមានច្រើនជាងការខំប្រឹងធ្វើរបស់យើងជានិច្ច។

ខ្ញុំអាចចាំបានពេលអង្គុយជាមួយបងប្រុសរបស់ឌ្រិនដាកាលពីប៉ុន្មានឆ្នាំមុន ដោយពិភាក្សាគ្នាអំពីចំណុចនេះថា ព្រះជាម្ចាស់គឺល្អ ជាអ្នកផ្តល់រង្វាន់ ហើយទ្រង់បានប្រទានឱ្យយើងនូវព្រះរាជ្យដែលបំពេញតម្រូវការទាំងអស់របស់យើង។ ការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់នេះគឺជារឿងថ្មីសម្រាប់ចននី និងប្រពន្ធរបស់គាត់ ខេនឌី ដែលពួកគេមកពីក្រុមជំនុំបែបបុរាណ ដែលបានបង្រៀនសេចក្តីពិតតិចតួចណាស់។

ចននី និងខេនឌីជាគ្រូបង្រៀននៅក្នុងប្រព័ន្ធសាលាមួយនៅក្នុងរដ្ឋចចជា នៅពេលនោះ។ អំឡុងពេលដែលចននីកំពុងបង្រៀន គាត់បានធ្វើការក្រៅម៉ោងជាមួយក្រុមហ៊ុនហិរញ្ញវត្ថុ Forward Financial Group របស់ខ្ញុំ។ វាហាក់ដូចជាចននីមានទេពកោសល្យផ្នែកអាជីវកម្មអ៊ីចឹង។ នៅឆ្នាំដំបូងរបស់គាត់ជាមួយក្រុមហ៊ុន គាត់រកចំណូល

បាននៅក្នុងពេលធ្វើការក្រៅម៉ោង ច្រើនជាងបង្រៀនមួយឆ្នាំពេញ ដូច្នេះគាត់បានសម្រេចចិត្តឈប់បង្រៀន ហើយទៅធ្វើការពេញពេលក្នុងអាជីវកម្មផ្នែកហិរញ្ញវត្ថុ។

ដំបូងចននីធ្វើបានល្អណាស់។ ប៉ុន្តែ នៅឆ្នាំក្រោយមក ខ្ញុំបានឃើញថាសកម្មភាពរបស់គាត់ចាប់ផ្តើមធ្លាក់ចុះ ហើយខ្ញុំដឹងថាគាត់មិនអាចបន្តឱ្យបានយូរទៀតទេ។

គ្រិនដា និងខ្ញុំមានគម្រោងធ្វើដំណើរកម្សាន្តទៅរដ្ឋចចជា សម្រាប់រដូវកាលបុណ្យណូអែល ហើយវាជាចេតនារបស់ខ្ញុំក្នុងការឈប់ និងចំណាយពេលខ្លះជាមួយចននី ដើម្បីមើលថាតើខ្ញុំអាចរកឃើញមូលហេតុមួយចំនួន ដែលចននីមិនអាចបង្កើតអាជីវកម្មដែលគាត់ត្រូវការ ដើម្បីបន្តនៅធ្វើការពេញពេល។ មុនពេលដែលខ្ញុំទូរសព្ទទៅចននី គាត់បានទូរសព្ទមកខ្ញុំ ហើយសួរថាតើខ្ញុំអាចមានពេលពិភាក្សារឿងអាជីវកម្មនេះសិនបានទេ? ជាការពិតណាស់ ខ្ញុំបានត្រៀមខ្លួនរួចហើយ ដើម្បីពិភាក្សាជាមួយគាត់។

ខ្ញុំអាចឃើញថាចននី និងខេនឌីបានភ័យខ្លាច។ ពួកគេត្រូវបង់ថ្លៃចំណាយ ៥.០០០ ដុល្លារ ហើយនៅខែនេះ ហើយពួកគេគ្មានប្រាក់ ៥.០០០ដុល្លារក្នុងខែក្រោយដែលពួកគេត្រូវការនោះទេ។ នៅពេលខ្ញុំអង្គុយជាមួយចននី ពាក្យដំបូងរបស់គាត់គឺ «វាមិនដើរទេ»។ ខ្ញុំដឹងថាការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជារឿងរ៉ាវមួយថ្មីសម្រាប់ចននី និងខេនឌី ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវបង្ហាញពួកគេពីរបៀបដោះស្រាយរឿងនេះខាងវិញ្ញាណ។ ព្រោះខ្ញុំដឹងថាព្រះរាជ្យរបស់ព្រះជាម្ចាស់តែងដំណើរការ! ដូច្នេះខ្ញុំចំណាយពេលប្រហែលជាពីរម៉ោងជាមួយពួកគេ ដើម្បីមើលអំពីច្បាប់ព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបស្រាយជំនឿរបស់ពួកគេ។ នៅពេលដែលខ្ញុំនិយាយ ខ្ញុំអាចមានអារម្មណ៍ពីភាពភ័យរសាត់បាត់ទៅ ហើយចាប់ផ្តើមកើតមានជំនឿឡើង។ ខ្ញុំដឹងថាចននីបានត្រៀមខ្លួនដើរទៅមួយជំហានទៀតហើយ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំបាននិយាយទៅ «ចននី» ថា «បងត្រូវដាំគ្រាប់ពូជមួយជាមួយព្រះជាម្ចាស់ ហើយជឿទុកចិត្តលើទ្រង់ចំពោះប្រាក់ដែលបងត្រូវការ»។

ចននី និងខេនឌីយល់ស្រប តែឥលូវពួកគេមិនមានប្រាក់ទេ។ ថៃដន្យអី ខ្ញុំបានយកប្រាក់ខែមកពីការិយាល័យចំនួន ១៦០ ដុល្លារសម្រាប់ចននីដែរ។ ខ្ញុំដឹងថាពួកគេអាចប្រើប្រាក់នោះបាន ប៉ុន្តែខ្ញុំបានលើកទឹកចិត្តពួកគេជំនួសវិញឱ្យសាបព្រោះជាគ្រាប់ពូជ ដូចដែលយើងទាំងពីរដឹងហើយថាលុយ ១៦០ ដុល្លារ វាមិនច្រើនទេ ក៏មិនអាចស្មើការចំណាយ ៥.០០០ ដុល្លារនោះដែរ។ ពួកគេត្រូវរកឱ្យបាន ៥.០០០ដុល្លារ ដើម្បីបង់ថ្លៃចំណាយដែលនឹងត្រូវមកដល់។ នោះពួកគេក៏យល់ព្រម។

នៅពេលដែលយើងអធិស្ឋាន និងស្រាយជំនឿជាមួយគ្នា ខ្ញុំបានសួរចននី « តើបងជឿថានឹងទទួលបានប្រាក់ប៉ុន្មានមកវិញតាមរយៈការសាបព្រោះប្រាក់នេះ?» ខ្ញុំទើបតែនិយាយរួចចេញពីមាត់ ស្រាប់តែព្រះវិញ្ញាណដ៏វិសុទ្ធបញ្ឈប់ខ្ញុំ ហើយឃាត់គាត់មិនឱ្យឆ្លើយ ហើយខ្ញុំក៏ដឹងអំពីមូលហេតុនោះ។ ចននីបាននិយាយថាគាត់ជឿក្នុងការទទួលបានប្រាក់ ៥.០០០ ដុល្លារនោះ ព្រោះជាក់ស្តែងវាស្ថិតនៅក្នុងភាពចាំបាច់។ ផ្ទុយទៅវិញ ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកខ្ញុំថា «សួរគាត់ទៅមើល ថាតើ ១២.០០០ ដុល្លារក្នុងរយៈពេល៣០ថ្ងៃគ្រប់ដែរឬទេ»។

ដូច្នេះខ្ញុំក៏បានសួរគាត់។ ខ្ញុំបានឃាត់គាត់មិនឱ្យឆ្លើយ ហើយសួរគាត់ថាតើ ១២.០០០ ដុល្លារក្នុងរយៈពេល៣០ថ្ងៃគ្រប់គ្រាន់ដែរឬទេ។ ខ្ញុំអាចមើលឃើញភ្នែករបស់គាត់បើកធំៗ នៅពេលដែលខ្ញុំបានប្រាប់ពីចំនួនដែលព្រះអម្ចាស់បានប្រាប់ខ្ញុំឱ្យសួរគាត់។ ខ្ញុំបានដឹងថាពេញមួយជីវិតរបស់គាត់ ចននីមិនដែលរកបាន ១២.០០០ ដុល្លារក្នុងរយៈពេល៣០ថ្ងៃនោះទេ។ គាត់បានអង្គុយនៅទីនោះមួយភ្លែត រួចឧទានថាពិតមែនហើយ គាត់ជឿថាវាគ្រប់គ្រាន់។ ខ្ញុំបានសួរខេនឌី នូវសំណួរដូចគ្នា ហើយនាង

ក៏ឆ្លើយថា ខ្ញុំក៏យល់ស្របដែរ។ យើងបានរួមគ្នាដាក់ដៃលើមូលប្បទានបត្រនោះ ហើយស្រាយជំនឿរបស់យើងសម្រាប់ប្រាក់ចំនួន ១២.០០០ ដុល្លារក្នុងរយៈពេល ៣០ថ្ងៃ។

បីសប្តាហ៍ក្រោយមក ខ្ញុំបានទទួលទូរសព្ទពីចននី។ គាត់ពិតជារំភើបណាស់។ គាត់បានសរសេរគម្រោងអាជីវកម្មបានសម្រេចក្នុងរយៈពេលបីសប្តាហ៍កន្លងមកនេះ ហើយបានទទួលប្រាក់មិនត្រឹមតែ ១២.០០០ ដុល្លារប៉ុណ្ណោះទេ ប៉ុន្តែរហូតដល់ ១៧.០០០ ដុល្លារ។ គាត់បាននិយាយថា គាត់គឺជាអ្នកជឿដ៏ពិតប្រាកដហើយឥលូវ។

គួរឱ្យស្តាយ ពីរខែក្រោយមក ចននីបានរេចង្កូតរថយន្តរបស់គាត់ នៅយប់មួយដែលមានភ្លៀងធ្លាក់ ពេលត្រលប់មកផ្ទះវិញក្រោយការណាត់ជួបមួយ។ រថយន្តខូចទាំងស្រុង ប៉ុន្តែចននី បានរួចជីវិតពីគ្រោះថ្នាក់រថយន្តនោះ ហើយការរួចជីវិតរបស់គាត់ជាការអស្ចារ្យមួយរបស់ព្រះជាម្ចាស់។ ទោះបីជាយ៉ាងណា ដោយសារតែគ្រោះថ្នាក់ ចននី មិនអាចធ្វើការដូចដើមបានទេ។ ក្នុងអំឡុងពេលនោះ ផ្ទះរបស់គាត់ត្រូវគេរឹបអូស ហើយត្រូវគេដាក់លក់ដេញថ្លៃ។ គាត់ត្រូវការប្រាក់ ១០.០០០ ដុល្លារ ដើម្បីលោះយកផ្ទះនោះមកវិញ។

អំឡុងពេលនេះ ទោះជាចននី និងខេនឌី បានសម្រេចចិត្តថា ពួកគេត្រូវផ្លាស់ទៅរដ្ឋអូហៃយ៉ូ ដើម្បីទៅជិតការបង្រៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលបានផ្លាស់ប្តូរជីវិតរបស់ពួកគេ។ ដូច្នេះពួកគេបានដាក់ផ្ទះលក់ ទោះបីពួកគេបានដឹងថា ពួកគេមានពេលប្រហែលមួយខែប៉ុណ្ណោះមុនដល់ថ្ងៃត្រូវគេដាក់លក់ដេញថ្លៃ។

នៅសល់ពេលកាន់តែខ្លី គ្មានអ្នកទិញពិតប្រាកដមកសោះ រហូតនៅពេលតែពីរបីថ្ងៃមុនដាក់ដេញថ្លៃ មានបុរសម្នាក់បានមកសុំទិញផ្ទះនោះ។ ប៉ុន្តែគាត់មានសំណើរមួយ។ គាត់ចង់ដឹងថាតើគាត់អាចឱ្យចននី ១០.០០០ ដុល្លារ ឥលូវនេះសិន ហើយចននីទុកផ្ទះនោះ ៣០ ថ្ងៃ រហូតដល់គាត់បង្ហើយការងារផ្សេងទៀត ដើម្បីយកប្រាក់មកទិញផ្ទះសរុប។

ចននីភ្ញាក់ផ្អើលជាខ្លាំង។ គាត់ដឹងថាប្រសិនបើគាត់នឹងយកផ្ទះពីការលក់ដេញថ្លៃមកវិញ គឺត្រូវតែមានគេទិញដោយឱ្យលុយសុទ្ធ ព្រោះការលក់ដេញថ្លៃនៅសល់តែពីរបីថ្ងៃទៀតប៉ុណ្ណោះ។ អ្នកទិញនេះចង់សរសេរមូលប្បទានបត្រ ១០.០០០ ដុល្លារឱ្យចននីនៅនឹងកន្លែង ហើយបិទបញ្ចប់ការលក់នៅពេលក្រោយ។ នេះជាចំនួនទឹកប្រាក់ដែលចននីត្រូវការ។ ចននី ដឹងថាព្រះជាម្ចាស់ជាអ្នកធ្វើការនេះ គាត់យកមូលប្បទានបត្រនោះ រួចបង់ប្រាក់ថ្លៃផ្ទះបច្ចុប្បន្ន។ អូហ៎ ហើយទឹកប្រាក់ ១០.០០០ ដុល្លារនោះ គឺ*បន្ថែមលើ*តម្លៃដែលដាក់លក់។

ដូច្នេះ ចននី និង ខេនឌី បានផ្លាស់ទៅរស់នៅរដ្ឋអូហៃយ៉ូ ហើយបានស្នាក់នៅផ្ទះជួល។ ពួកគេបានចូលរួមជាមួយក្រុមជំនុំ Faith Life ហើយចននីបានចូលក្នុងអាជីវកម្មហិរញ្ញវត្ថុជាមួយនឹងភាពរឹងមាំសាជាថ្មី។ ប៉ុន្តែ ពេលនេះពួកគេមានបញ្ហាមួយថ្មីទៀតហើយ។ ពួកគេមានឡានតែមួយ ហើយចននីត្រូវការវាដើម្បីទៅចូលរួមការណាត់ជួបជាច្រើនដែលគាត់មាន ដើម្បីប្រជុំជាមួយអតិថិជន។ ពិតណាស់ ពួកគេដឹងថាត្រូវធ្វើអ្វីមួយ។ ពួកគេបានសាបព្រោះគ្រាប់ពូជសម្រាប់ឡានថ្មី ហើយជឿថានឹងទទួលបាននៅពេលដែលពួកគេអធិស្ឋាន យោងតាម ម៉ាកុស ១១:២៤។

បន្ទាប់មកមានរឿងចម្លែកមួយបានកើតឡើង។ មិត្តភក្តិពីកុមារភាពរបស់ចននីបាន ទូរសព្ទមក...

គាត់សួរថា «ចននី តើខ្ញុំមានបានសងគុណឯង សម្រាប់កង់ដែលឯងបានឱ្យខ្ញុំកាលពីថ្នាក់ទីប្រាំមួយទេ?»។

ចននីឆ្លើយថា «មិនបានទេ»។

បន្ទាប់មក មិត្តភក្តិរបស់គាត់បាននិយាយថា «អ៊ីចឹង ខ្ញុំចង់សងគុណឯងវិញ។ ខ្ញុំនឹងទិញឡានម៉ាក BMW ឱ្យឯងមួយគ្រឿង»។

កាលពីក្មេង ពួកគេទាំងពីរនាក់នេះចូលចិត្តនិយាយអំពីឡាន ហើយគាត់ដឹងថា ចននីចង់បានឡានម៉ាក BMW ណាស់។ មិត្តម្នាក់នេះគោរពសម្ដីរបស់ខ្លួន ហើយបានផ្ញើរប្រាក់ឱ្យចននីទៅទិញឡាន BMW ដោយខ្លួនឯង។ ប៉ុន្តែនៅពេលដែលចននីបានទទួលប្រាក់នោះហើយ គាត់ដឹងថា ដោយសារតែសមាជិកគ្រួសារគាត់កាន់តែកើនឡើង ឡាន BMW គឺមិនមែនជាឡានដែលគាត់ត្រូវការទេ។ គាត់ និងខេនឌី បានសម្រេចចិត្តទិញឡាន SUV បែបគ្រួសារ ឱ្យខេនឌីវិញ ហើយទិញឡានមួយទៀតដែលតូចជាងនេះ សម្រាប់ប្រើប្រាស់ពេលចននីទៅធ្វើអាជីវកម្ម។ ដោយសារតែឡានរបស់ខេនឌីតូច ចាស់ និងឧស្សាហ៍ខូច ដូច្នេះទើបពួកគេសម្រេចចិត្តធ្វើបែបនេះ។

ខ្ញុំនៅតែចាំពេលយប់ដែលចននីបានទូរសព្ទមកខ្ញុំ។ គាត់កំពុងតែអង្គុយលើឡាន SUV ថ្មីរបស់គាត់ នៅលើផ្លូវខាងមុខផ្ទះ និងឡានថ្មីមួយទៀតរបស់គាត់ ដោយស្រក់ទឹកភ្នែកបណ្ដើរ ប្រាប់ខ្ញុំបណ្ដើរថាគាត់ពិតជាភ្ញាក់ផ្អើលដែលបានទិញឡានពីរគ្រឿង ជាលើកដំបូងក្នុងជីវិតរបស់គាត់។

ចននីជាមនុស្សថ្មី។ គាត់ដឹងថាព្រះជាម្ចាស់អាចធ្វើគ្រប់យ៉ាងបាន។

ថ្ងៃមួយគាត់បានមកការិយាល័យខ្ញុំ ហើយនិយាយថាគាត់ធុញទ្រាន់ក្នុងការជួលផ្ទះណាស់ ដូច្នេះគាត់និងខេនឌីចង់បានចម្ការមួយកន្លែងដែលមានដីទំនេរ ដូច្នេះពួកគេក៏កំពុងតែរកមើល។ ពិតណាស់ ខ្ញុំបានដឹងថាក្រេឌីតរបស់ចននីគឺមិនល្អទេ ដោយសារតែគ្រោះថ្នាក់រថយន្ត ហើយខ្ញុំលើកទឹកចិត្តគាត់ឱ្យនៅជួលផ្ទះយូរបន្តិចសិន និងសន្សំទុនបម្រុង ដើម្បីទុកពេលឱ្យពិន្ទុក្រេឌីតរបស់គាត់កើនឡើង។ ប៉ុន្តែចននីហាក់ដូចជាមិនសូវយកចិត្តទុកដាក់នឹងអ្វីដែលខ្ញុំបាននិយាយសោះ។

ពេលនោះគាត់ប្រាប់ខ្ញុំថា គាត់បានឃើញចម្ការមួយនៅរំលងមួយផ្លូវពីផ្ទះខ្ញុំដែលគេដាក់លក់ ហើយគាត់នឹងទៅនឹងពិនិត្យមើលដើម្បីទិញវា។ ពិតប្រាកដណាស់ ដោយហេតុថាខ្ញុំមានក្រុមហ៊ុនរំលោះនៅពេលនោះ ខ្ញុំដឹងថាមិនមានវិធីដែលចននីអាច

មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ទិញចម្ការនោះទេ។ ខ្ញុំក៏បានដឹងដែរថា គាត់មិនមានប្រាក់បង់មុន សម្រាប់ការទិញបែបនេះដែរ។

មួយសប្តាហ៍ក្រោយមក ខ្ញុំមានការភ្ញាក់ផ្អើល នៅពេលដែលគាត់បានដើរចូលមកការិយាល័យរបស់ខ្ញុំដោយញញឹម ហើយនិយាយថាគាត់ទិញបានចម្ការនោះហើយ។ ពេលគាត់ប្រាប់ខ្ញុំដូច្នេះ ខ្ញុំពិតជាចង់ដឹងដំណើររឿងនោះណាស់។ ជាការពិតណាស់ គាត់និងខេនឌីបានសាបព្រោះគ្រាប់ពូជហិរញ្ញវត្ថុចូលក្នុងកិច្ចការរបស់ព្រះជាម្ចាស់ ដូចដែលពួកគេត្រូវបានបង្រៀនឱ្យជឿថា ពួកគេនឹងទទួលបានមកវិញ នៅពេលពួកគេអធិស្ឋាន។ បន្ទាប់មក ចននីបានបន្ត ហើយពន្យល់ខ្ញុំអំពីអ្វីដែលបានកើតឡើង។

គាត់បានទៅពិគ្រោះជាមួយធនាគាររបស់គាត់អំពីការទិញដីចម្ការ ហើយអ្នកគ្រប់គ្រងទាញរបាយការណ៍ក្រេឌីតរបស់គាត់មកពិនិត្យ ហើយអង្គុយជាមួយគាត់ដោយប្រាប់គាត់ថា «ចននី លោកនិយាយត្រូវហើយអំពីក្រេឌីតរបស់លោក។ លោកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទិញអ្វីនោះទេ»។

ប៉ុន្តែបន្ទាប់មក អ្នកគ្រប់គ្រងបាននិយាយអ្វីដែលនឹកស្មានមិនដល់។ គាត់បានរុញ ឯកសារក្រេឌីតនោះទៅម្ខាង ហើយនិយាយថា «ប៉ុន្តែខ្ញុំចូលចិត្តលោក។ ខ្ញុំសូមពិនិត្យមើលសិនថាតើខ្ញុំអាចជួយអ្វីលោកបាន»។

និយាយឱ្យខ្លីទៅ ធនាគារបានផ្តល់ហិរញ្ញប្បទាន ១០០% សម្រាប់ការទិញនេះបានឱ្យពេលគាត់៩ខែ រហូតដល់ការជួលដែលគាត់មាននៅពេលនេះ ដល់កំណត់ប្តូរទីលំនៅ បានប្តូរហ្គាសឱ្យគាត់ពេញធុង បានបង់ពន្ធលើអចលនទ្រព្យដែលមិនទាន់បានបង់ ហើយបានមូលប្បទានបត្រចំនួន ៥.០០០ ដុល្លារដល់ចននី នៅពេលបញ្ចប់ការជួសជុលស្នាមប្រេះនៅក្នុងបេតុងនៅខាងមុខហោណ័ង។

ខ្ញុំអង្គុយនៅទីនោះទាំងស្រឡាំងកាំង ខណៈចននីនិយាយបន្តអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ខ្ញុំអាចត្រឹមតែនិយាយថា «អស្ចារ្យណាស់!»

មួយខែក្រោយមក ចននីបានប្រាប់ខ្ញុំថាគាត់បានសាបព្រោះគ្រាប់ពូជសម្រាប់ត្រាក់ទ័រ ហ្វដ។ គាត់បានប្រាប់ខ្ញុំថាគាត់សម្រេចចិត្តទិញត្រាក់ទ័រថ្មីមួយសម្រាប់ចម្ការរបស់គាត់ ហើយបានសាបព្រោះគ្រាប់ពូជដាក់លាក់មួយ សម្រាប់ត្រាក់ទ័រហ្វដម៉ាស៊ូតពណ៌ខៀវ។ ជាថ្មីម្តងទៀត ដោយសារគាត់ធ្វើការឱ្យខ្ញុំ និងការដឹងពីតម្លៃត្រាក់ទ័រផងនោះ ខ្ញុំដឹងថាគាត់មិនទាន់មានប្រាក់ទិញវាទេ។

ប៉ុន្តែប្រាកដណាស់ ពីរបីសប្តាហ៍ក្រោយមក នៅពេលដែលខ្ញុំមើលទៅផ្លូវ ខ្ញុំបានឃើញ ចននីបើកត្រាក់ទ័រម៉ាស៊ូតម៉ាក ហ្វដ ពណ៌ខៀវទៅផ្ទះរបស់គាត់។ ពេលខ្ញុំសួរគាត់ថា តើគាត់ យកត្រាក់ទ័រមកពីណា គាត់និយាយថា មានស្ត្រីម្នាក់បានដើរមកជួបគាត់នៅក្រុមជំនុំដោយចៃដន្យ ហើយសួរគាត់ថា តើគាត់មានស្គាល់នរណាម្នាក់ដែលត្រូវការត្រាក់ទ័រដែរឬទេ។ ពួកគេកំពុងលក់របស់របរពីចម្ការឪពុកម្តាយនាង ហើយពួកគេកំពុងលក់ត្រាក់ទ័រនេះចេញ។ ចននីបានប្រាប់នាងថាគាត់ចាប់អារម្មណ៍។

នាងក៏បានប្រាប់គាត់ថាកុំបារម្ភអំពីការទូទាត់ប្រាក់នាងអី គ្រាន់តែទូទាត់នៅពេលដែលគាត់មានទៅបានហើយ នាងមិនប្រញាប់ទេ។ ដូច្នេះ គាត់មានត្រាក់ទ័រផ្ទាល់ខ្លួនរបស់គាត់។

ភាពជោគជ័យរបស់គាត់នៅតែបន្ត។ នៅខែបន្ទាប់ គាត់រកបាន ៧២.០០០ ដុល្លារ ក្នុងពេលត្រឹមមួយខែប៉ុណ្ណោះ។ ប្រសិនបើអ្នកសួរទៅចននី ថាតើវាកើតឡើងបានយ៉ាងដូចម្តេច គាត់នឹងឆ្លើយថា វាបានកើតឡើងដោយការមានចិត្តសប្បុរសចំពោះព្រះជាម្ចាស់ ហើយមានការយល់ដឹងអំពីច្បាប់នៃព្រះរាជ្យរបស់ទ្រង់។

ជារឿងដ៏អស្ចារ្យ! ខ្ញុំនៅតែចាំពីការអង្គុយជាមួយចននីនិងខេនឌីនៅផ្ទះរបស់ពួកគេនៅរដ្ឋចចជាយប់នោះ ដោយបានចែករំលែកអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមួយពួកគេ។ ពួកគេមានអារម្មណ៍លើសលុប ដោយខ្វះលុយបង់ចំណាយវិក្កយបត្រ ៥.០០០ ដុល្លារ ហើយប្រឈមមុខនឹងការចំណាយសម្រាប់បុណ្យណូអែល និងមួយជុំ

ទៀតដែលស្មើនឹងទឹកប្រាក់ ៥.០០០ ដុល្លារនៅខែក្រោយ ដោយគ្មានប្រាក់សោះ។ ខ្ញុំគិតថាអ្នកប្រហែលជាចាប់អារម្មណ៍ចង់ដឹងអ្វី ដែលខ្ញុំនិយាយទៅកាន់ពួកគេនៅយប់នោះ។

ខ្ញុំបានដឹងថា ខ្ញុំគ្រាន់តែជួយពួកគេឱ្យឃើញព្រះជាម្ចាស់តាមរយៈស្ថានភាពដែលពួកគេប្រឈមមុខតែប៉ុណ្ណោះ។ ខ្ញុំចាប់ផ្ដើមដោយបង្ហាញពួកគេនូវអ្វីដែលយើងបាននិយាយនៅក្នុងព្រះគម្ពីរ ២ កូរិនថូស ៩:១០-១១ ៖

> *ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» ព្រះអង្គក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្តីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ ដោយយើងជួយគេ។*

ខ្ញុំបានលើកយកចំណុចដែលលោកប៉ូលនិយាយថា ព្រះជាម្ចាស់នឹងមិនត្រឹមតែផ្គត់ផ្គង់គ្រាប់ពូជដែលសាបព្រោះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ប្រទានអាហារសម្រាប់តម្រូវការរបស់អ្នកដែរ។ អាហារគឺចង់សំដៅទៅលើគ្រប់ទាំងសេចក្តីត្រូវការផ្ទាល់ខ្លួននៅក្នុងជីវិតរបស់អ្នក។ ពីចំណុចនោះ ទ្រង់នឹងបន្ថែមនូវសមត្ថភាពរបស់អ្នក ដើម្បីអាចផ្តល់ឱ្យកាន់តែច្រើន។ មានន័យថាអ្នកនឹងកាន់តែចម្រើនឡើង។

ជាថ្មីម្តងទៀត តើភាពភ័យខ្លាចនៅក្នុងការផ្តល់ឱ្យគឺជាអ្វី? គឺខ្លាចថា អ្នកនឹងខ្វះខាតនៅក្នុងការបំពេញតម្រូវការរបស់ខ្លួនឯង។

ប៉ុន្តែសូមយកចិត្តទុកដាក់នឹងអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ ទ្រង់ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងអាហារសម្រាប់បរិភោគ។ នេះជាសំណួរដ៏សំខាន់មួយហើយជាសំណួរដែលខ្ញុំបានសួរចននីដែរ។

## តើអ្វីដែលអ្នកមាននៅក្នុងដៃជាគ្រាប់ពូជ ឬជាអាហារ? វាជាជម្រើសរបស់អ្នក។

ឪពុករបស់ម្ដាយខ្ញុំ ជីតារបស់ខ្ញុំ គាត់ជាកសិករពេញមួយជីវិតរបស់គាត់។ ខ្ញុំចាំថា កាលពីក្មេងខ្ញុំលេងនៅក្នុងរទេះដឹកគ្រាប់ពូជរបស់គាត់។ អ្នកប្រហែលជាមិនធ្លាប់ឮអំពីរទេះដឹកគ្រាប់ពូជនេះទេ។ វាប្រហែលជាប្រើពាក្យមិនត្រូវផងក៏មិនដឹង ប៉ុន្តែរបស់នោះនៅជាមួយយើងតាំងពីខ្ញុំធំឡើងជាមួយជីតារបស់ខ្ញុំម្ល៉េះ។ អ្នកដឹងទេ ជារៀងរាល់ឆ្នាំនៅពេលរដូវចម្រូត ជីតាខ្ញុំតែងតែរក្សាទុកគ្រាប់ពូជឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញរទេះដែលគាត់មាន ហើយយកទុកក្នុងជង្រុក។ រទេះនោះមានពេញទៅដោយគ្រាប់ពូជដែលគាត់សន្សំដើម្បីទុកដាំនៅនិទាឃរដូវឆ្នាំក្រោយ។

ក្នុងរដូវរងា ជីតារបស់ខ្ញុំបានមើលទៅរទេះដាក់គ្រាប់សណ្ដែកសៀងដ៏ពេញនោះ ដោយដឹងថាគាត់មានជម្រើសលក់វាសម្រាប់តម្រូវការបន្ទាន់ ឬរក្សាទុកវាសម្រាប់ដាំនៅនិទាឃរដូវឆ្នាំក្រោយ ជាកន្លែងដែលគាត់បានដឹងថា វានឹងបង្កើតផលជាច្រើនដល់គាត់។ គាត់មានជម្រើសមួយ ប៉ុន្តែគាត់ជឿជាក់លើច្បាប់គ្រប់គ្រងពេលវេលាគ្រាប់ពូជ និងចម្រូត ហើយគាត់បានរក្សាទុកវាយ៉ាងមុតមាំ។

ចននី និងខេនឌី ត្រូវប្រឈមមុខនឹងការសម្រេចចិត្តដូចគ្នា នៅពេលកាន់មូលប្បទានបត្រ ១៦០ ដុល្លារនោះ។ ពួកគេប្រាកដជាអាចប្រើវា ដើម្បីទូទាត់តម្រូវការបន្ទាន់ ប៉ុន្តែផ្ទុយទៅវិញ ពួកគេដឹងថាការមានចិត្តសប្បុរសចំពោះព្រះជាម្ចាស់ នឹងឱ្យពួកគេប្រមូលផលបានកាន់តែច្រើននៅក្នុងរយៈពេលវែង។ ពួកគេបានធ្វើត្រូវហើយ។

*មនុស្សមានចិត្តទូលាយរឹតតែមានទ្រព្យច្រើន រីឯមនុស្សកំណាញ់ធ្វើឱ្យខ្លួនកាន់តែក្រទៅៗ។*

—សុភាសិត ១១:២៤

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

មុនពេលយើងបញ្ចប់ជំពូកនេះ មានរឿងប្រស្នាមួយទៀតដែលខ្ញុំចង់ពិនិត្យមើល គឺនៅ ម៉ាថាយ ២៥:១៤-៣០ ជាប្រស្នាអំពីប្រាក់ណែន។

*ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹងបុរសម្នាក់ ដែលហៀបចេញដំណើរទៅស្រុកឆ្ងាយ។ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឱ្យ។ គាត់ប្រគល់ប្រាក់ឱ្យអ្នកបម្រើម្នាក់ៗតាមសមត្ថភាពរៀងៗខ្លួន គឺឱ្យប្រាំណែន ទៅអ្នកទីមួយ ពីរណែនទៅអ្នកទីពីរ និងមួយណែនទៅអ្នកទីបី រួចគាត់ចេញដំណើរទៅ។ អ្នកបម្រើដែលបានទទួលប្រាក់ប្រាំណែន យកប្រាក់ចេញទៅរកស៊ីភ្លាម ហើយចំណេញបានប្រាំណែនទៀត។ អ្នកទីពីរក៏ដូច្នោះដែរ គាត់យកប្រាក់ពីរណែននោះទៅរកស៊ី ចំណេញបានពីរណែនទៀត។ រីឯអ្នកដែលទទួលប្រាក់មួយណែនបានចេញទៅជីកដីកប់ប្រាក់ម្ចាស់របស់ខ្លួនទុក។*

*លុះយូរក្រោយមក ម្ចាស់វិលត្រលប់មកវិញ ហើយគិតបញ្ជីជាមួយអ្នកទាំងបីនោះ។ អ្នកទទួលប្រាក់ប្រាំណែន យកប្រាក់ដែលចំណេញបានប្រាំណែន ចូលមកជូនម្ចាស់ ដោយពោលថា: «លោកម្ចាស់! លោកបានប្រគល់ប្រាក់ប្រាំណែនឱ្យខ្ញុំប្របាទ ឥលូវនេះ ខ្ញុំប្របាទចំណេញបានប្រាំណែនទៀត»។*

*ម្ចាស់ក៏ពោលទៅគាត់ថា: «ល្អហើយ! អ្នកបម្រើដ៏ប្រសើរមានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឱ្យមើលខុសត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ»។*

*អ្នកទទួលប្រាក់ពីរណែន ក៏យកប្រាក់ដែលចំណេញបានពីរណែនទៀតនោះចូលមកដែរ ហើយជម្រាបថា: «លោកម្ចាស់! លោកបានប្រគល់ប្រាក់ពីរណែនឱ្យខ្ញុំប្របាទ ឥលូវនេះ ខ្ញុំប្របាទចំណេញបានពីរណែនទៀត»។*

*ម្ចាស់ក៏ពោលទៅគាត់ថា: «ល្អហើយ! អ្នកបម្រើដ៏ប្រសើរមានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឱ្យមើលខុសត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ»។*

*បន្ទាប់មក អ្នកដែលបានទទួលប្រាក់មួយណែនក៏ចូលមក ហើយជម្រាបថា: « លោកម្ចាស់! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់។ លោកតែងច្រូតយកផលពីស្រែដែលលោកមិនបានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោកមិនបានដាំ។ ខ្ញុំប្របាទបានយកប្រាក់ដែលលោកប្រគល់ឱ្យទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យខ្លាចពេក។ ឥលូវនេះ សូមលោកម្ចាស់យកប្រាក់របស់លោកវិញចុះ»។*

*ម្ចាស់ក៏ពោលទៅអ្នកនោះថា: «នែ អ្នកបម្រើអាក្រក់ ខ្ជិលច្រអូសអើយ! អ្នកដឹងស្រាប់ហើយថា ខ្ញុំតែងច្រូតយកផលពីស្រែដែលខ្ញុំមិនបានសាបព្រោះ និងប្រមូលផលពីដំណាំដែលខ្ញុំមិនបានដាំ។ គួរតែអ្នកយកប្រាក់ខ្ញុំទៅចងការ កាលណាខ្ញុំត្រលប់មកវិញ ខ្ញុំនឹងទទួលប្រាក់ទាំងដើម ទាំងការ!។*

*ចូរយកប្រាក់ពីអ្នកនេះប្រគល់ឱ្យអ្នកដែលមានដប់ណែននោះទៅ ដ្បិតអ្នកណាមានហើយ អ្នកនោះនឹងទទួលបរិបូណ៌ហូរហៀរថែមទៀត។ រីឯអ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមានផង។ ចំណែកឯអ្នកបម្រើឥតបានការនេះ ចូរយកគាត់ទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោក ខឹងសង្កៀតធ្មេញនោះទៅ!»។*

—ម៉ាថាយ ២៥:១៤-៣០

នេះជារឿងដែលធ្លាប់ដឹងហើយ។ ម្ចាស់កំពុងចាកចេញទៅឆ្ងាយ ហើយទុកឱ្យអ្នកបម្រើបីនាក់គ្រប់គ្រង គឺឱ្យប្រាំណែនទៅអ្នកទីមួយ ពីរណែនទៅអ្នកទីពីរ និងមួយណែនទៅអ្នកទីបី។

ពីរនាក់ដំបូងយកប្រាក់ទៅធ្វើកិច្ចការភ្លាមៗ ហើយទទួលបានប្រាក់ទ្វេគុណ។ ម្ចាស់សប្បាយរីករាយចំពោះការងាររបស់ពួកគេ។ ប៉ុន្តែអ្នកបម្រើទីបី គឺជាអ្នកដែលខ្ញុំចង់ពិនិត្យមើល។ គាត់បានទទួលប្រាក់មួយណែន ប៉ុន្តែមិនបានធ្វើអ្វីជាមួយវាទេ។ តាមពិតគាត់គ្រាន់តែកប់វាចោលរហូតដល់ម្ចាស់ត្រលប់មកវិញ។

*បន្ទាប់មក អ្នកដែលបានទទួលប្រាក់មួយណែនក៏ចូលមក ហើយជម្រាបថាៈ «លោកម្ចាស់! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់។ លោកតែងច្រូតយកផលពីស្រែដែលលោកមិនបានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោកមិនបានដាំ។ ខ្ញុំប្របាទបានយកប្រាក់ដែលលោកប្រគល់ឱ្យទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យខ្លាចពេក។ ឥលូវនេះ សូមលោកម្ចាស់យកប្រាក់របស់លោកវិញចុះ»។*

សូមយកចិត្តទុកដាក់ចំពោះប្រយោគទីមួយ ៖ *«លោកម្ចាស់! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់។ លោកតែងច្រូតយកផលពីស្រែដែលលោកមិនបានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោកមិនបានដាំ»។*

តើគាត់កំពុងនិយាយអ្វី? ខ្ញុំនឹងប្រាប់អ្នកឱ្យច្បាស់នូវអ្វីដែលគាត់កំពុងនិយាយ។ គាត់កំពុងនិយាយថា «ហេតុអ្វីខ្ញុំគួរចូលរួម? ប្រសិនបើលោកប្រមូលផលនៅកន្លែងដែលមិនបានសាបព្រោះគ្រាប់ពូជទេ តើអ្នកណាជាអ្នកចេញថ្លៃគ្រាប់ពូជ ហើយអ្នកណាជាអ្នកសាបព្រោះ និងធ្វើការងារដើម្បីឱ្យវាដុះឡើង?»

ឥលូវយើងយល់ហើយថា ម្ចាស់ឱ្យប្រាក់គាត់ទិញគ្រាប់ពូជ ប៉ុន្តែគាត់មានចិត្តគំនិតបង្ហាញថា វាមិនសមនឹងឱ្យគាត់យកពេលទៅចូលរួមកិច្ចការនោះទេ។ វាមិនមានប្រយោជន៍សម្រាប់គាត់ទេ។ ប្រាក់ចំណេញទាំងអស់ លទ្ធផលការងាររបស់គាត់ទាំងឡាយ គឺនឹងបានទៅម្ចាស់ទាំងស្រុង។ ដោយសារតែគាត់មានទស្សនៈចំពោះម្ចាស់បែបនេះ ដែលគាត់មើលឃើញថាវាជាមេត្រួតការដ៏តឹងតែង គាត់បដិសេធមិនចូលរួម

នោះទេ។ គាត់បានព្យាយាមលាក់បាំងការមិនស្តាប់បង្គាប់ពិតប្រាកដចំពោះម្ចាស់ដោយបញ្ជាក់អំពីមូលហេតុដែលគាត់លាក់ប្រាក់នោះ គឺដោយសារគាត់ខ្លាចបាត់បង់វា។ ដូច្នេះហើយ គាត់បានលាក់ប្រាក់ដើម្បីរក្សាវាទុក។ ប៉ុន្តែ ម្ចាស់បានបន្ទោសចំពោះភាពល្ងីល្ងើរបស់គាត់ ហើយបាននិយាយថា ប្រសិនបើអ្នកពិតជាយកចិត្តទុកដាក់ចំពោះគាត់មែន យ៉ាងហោចណាស់គួរតែអ្នកយកប្រាក់ទៅផ្ញើធនាគារ ដើម្បីបានការប្រាក់ផង។

មិនមែនទេ អ្នកបម្រើមិនមែនខ្លាចបាត់បង់ប្រាក់នោះទេ។ គាត់ខ្លាចថាត្រូវឱ្យគាត់លះបង់ជាច្រើនដើម្បីចូលរួម។ គាត់មានគំនិតរឹងទទឹង និងគិតអាក្រក់ចំពោះម្ចាស់។ រឹងទទឹងព្រោះការពិតគឺផ្ទុយពីអ្វីដែលគាត់គិត។ ម្ចាស់មិនមែនជាមេត្រួតការដ៏តឹងតែងទេ។ អ្នកបម្រើពីរនាក់ទៀតទទួលបានរង្វាន់ជាមួយការដំឡើងតំណែង ហើយបានអញ្ជើញឱ្យមកអរសប្បាយជាមួយម្ចាស់ បន្ទាប់ពីពួកគេបានធ្វើការដោយជោគជ័យជាមួយនឹងប្រាក់របស់ម្ចាស់។ ចំណែកឯអ្នកបម្រើនេះ ដោយសារតែគិតខុសចំពោះម្ចាស់ ទើបជ្រើសរើសមិនចូលរួមកិច្ចការងារនោះ។ ហើយនេះពិតជាអ្វីដែលសាសនាបង្រៀនយើង ថាព្រះជាម្ចាស់គឺជាមេត្រួតការងារដ៏លំបាក និងមិនមានចំណេញក្នុងការធ្វើការជាមួយទ្រង់ទេ ដូច្នេះហេតុអ្វីបានជាចាំបាច់ត្រូវចូលរួមការងារទាំងនោះ?

ប៉ុន្តែការគិតអំពីព្រះជាម្ចាស់បែបនោះ គឺជាការរឹងទទឹង ហើយមិនត្រឹមត្រូវទាំងស្រុងតែម្តង។ និយាយថាព្រះជាម្ចាស់អយុត្តិធមិគឺជាការអាក្រក់ណាស់។ ព្រះជាម្ចាស់គឺពិតជាផ្ទុយស្រឡះពីការពិពណ៌នាទាំងនោះ។ ទ្រង់ល្អ ហើយជាព្រះដែលប្រទានរង្វាន់។

ប៉ុន្តែឥលូវនេះខ្ញុំចង់សង្កត់ធ្ងន់ទៅលើចំណុចសំខាន់ដែលមាននៅក្នុងសាច់រឿងនេះ។ សូមយកចិត្តទុកដាក់នូវអ្វីដែលម្ចាស់បានធ្វើជាមួយនឹងប្រាក់ដែលគាត់ដកយកចេញពីអ្នកបម្រើអាក្រក់នោះ។

*ចូរយកប្រាក់ពីអ្នកនេះប្រគល់ឱ្យអ្នកដែលមានដប់ណែននោះទៅ ដ្បិតអ្នកណាមានហើយ អ្នកនោះនឹងទទួលបរិបូណ៌ហូរហៀរថែមទៀត។ រីឯអ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមានផង។ ចំណែកឯអ្នកបម្រើឥតបានការនេះ ចូរយកគាត់ទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោក ខឹងសង្កៀតធ្មេញនោះទៅ។*

តើខ្ញុំបានអានត្រឹមត្រូវដែរឬទេ? ម្ចាស់យកប្រាក់មកពីអ្នកបម្រើគ្មានតម្លៃហើយប្រគល់ទៅអ្នកដែលមានប្រាក់ដប់ណែនវិញ ហើយមិនមែនជាម្នាក់ដែលមានប្រាក់បួនណែន? ខ្ញុំមិនប្រាកដថានេះជាគោលនយោបាយត្រឹមត្រូវនោះទេ ប៉ុន្តែនេះជាអ្វីដែលទ្រង់បានធ្វើ។ **សូមប្រយ័ត្នប្រយែង!!!!**

**ព្រះជាម្ចាស់នឹងប្រទានគំនិត និងកិច្ចការដ៏ល្អអស្ចារ្យរបស់ទ្រង់ទៅកូនរបស់ព្រះអង្គដែលគិតអំពីការរកផលចំណេញសម្រាប់ទ្រង់...**

ព្រះជាម្ចាស់នឹងប្រទានគំនិត និងកិច្ចការដ៏ល្អអស្ចារ្យរបស់ទ្រង់ទៅកូនរបស់ព្រះអង្គដែលគិតអំពីការរកផលចំណេញសម្រាប់ទ្រង់ ហើយបានបង្ហាញខ្លួនឯងថាមានភក្តីភាព និងស្មោះត្រង់នៅក្នុងការងារតូចៗជាមុនសិន។

ព្រះជាម្ចាស់មិនមែនល្ងង់ទេ។ ទ្រង់នឹងដាក់ប្រាក់របស់ទ្រង់នៅកន្លែងដែលវានឹងផ្តល់ផលចំណេញយ៉ាងអស្ចារ្យបំផុត។

សូមគិតអំពីអ្វីដែលខ្ញុំទើបតែបាននិយាយ ព្រះជាម្ចាស់នឹងដាក់ប្រាក់របស់ទ្រង់នៅកន្លែងដែលវានឹងផ្តល់ផលចំណេញយ៉ាងអស្ចារ្យបំផុត!

ឥលូវនេះ ពិតណាស់ ព្រះជាម្ចាស់មិនស្វែងរកការធ្វើអាជីវកម្មជាមួយនឹង *លុយ* ទេ ប៉ុន្តែទ្រង់ស្វែងរកការធ្វើអាជីវកម្មជាមួយព្រលឹង*មនុស្ស*។ ហើយពេលដែល

យើងស្មោះត្រង់នឹងធ្វើការដោយឧស្សាហ៍ព្យាយាម នោះទ្រង់នឹងលើកតម្កើងយើង ហើយសព្វព្រះហឫទ័យដោយប្រទានសេចក្ដីល្អរបស់ទ្រង់ដល់យើង។

ត្រូវហើយ ព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យជាមួយអ្នកដែលទ្រង់ទុកចិត្ត ដោយធ្វើកិច្ចការផ្សេងគ្នា។ ចំពោះអ្នកណាដែលបង្ហាញខ្លួនឯងថាស្មោះត្រង់ នោះនឹងទទួលបានការទុកចិត្តពីព្រះជាម្ចាស់ ដោយការចាត់ចែងកិច្ចការកាន់តែធំ និងមានរង្វាន់កាន់ច្រើនជាងសម្រាប់ពួកគេ។

សូមកត់សម្គាល់អាកប្បកិរិយារបស់អ្នកបម្រើពីរនាក់ដែលបានទទួលជោគជ័យ - ពួកគេបានចេញទៅ ហើយយកប្រាក់ម្ចាស់របស់ពួកគេឱ្យបង្កើតផល! ហេតុអ្វីត្រូវធ្វើភ្លាមៗដូច្នេះ? ដោយសារពួកគេដឹងថានេះជា*ឱកាស* មិនមែនជាសម្ពាធទាសករទេ។

មានប្រជារាស្ត្រជាច្រើនរបស់ព្រះជាម្ចាស់ចាត់ទុកការបម្រើព្រះជាម្ចាស់ជាការបង្ខិតបង្ខំ ជាកាតព្វកិច្ចដែលត្រូវបំពេញ ហើយគិតថាវាមិនមែនជាឱកាសដ៏ល្អទេ។

នៅពេលដែលឌ្រិនដា និងខ្ញុំកំពុងសាងសង់ទីតាំងថ្វាយបង្គំ Now Center យើងត្រូវធ្វើការសម្រេចចិត្ត។ យើងមានសមាជិកក្រុមជំនុំប្រមាណតែ ៣០០ នាក់ប៉ុណ្ណោះ។ យើងបានសម្រេចចិត្តថាយើងត្រូវសាងសង់កន្លែងអចិន្ត្រៃយ៍មួយ និងផ្ទះដ៏ធំជាងនេះ ដើម្បីឱ្យព្រះកាយដែលមានអ្នកជឿ (ក្រុមជំនុំ) របស់យើងលូតលាស់ឡើង។

យើងបានកំណត់ទឹកប្រាក់ដែលត្រូវរៃអង្គាសតាមដែលយើងអាចធ្វើបាន ដើម្បីចសម្រេចគម្រោងដែលមានទឹកប្រាក់៦លានដុល្លារ។ នេះគឺជាចំនួនទឹកប្រាក់ដ៏ច្រើនចំពោះយើងនៅពេលនោះ។ ផែនការនេះធ្វើឡើងគឺដើម្បីកសាងហេដ្ឋារចនាសម្ពន្ធមូលដ្ឋានប្រហែល ៤,២ លានដុល្លារ ហើយបន្ទាប់មកបន្ថែម ២លានដុល្លារដែលនៅសល់សម្រាប់គ្រឿងបរិក្ខារ និងសាងសង់តាមទឹកប្រាក់ដែលបន្តទទួលបាន។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នេះមិនមែនជាបទពិសោធដំបូងរបស់យើង ដែលមានចិត្តសប្បុរសសម្រាប់គម្រោងរបស់ព្រះជាម្ចាស់ទេ ប៉ុន្តែវាជាគម្រោងដ៏ធំបំផុតដែលយើងបានចូលរួមផ្នែកមកទល់ពេលនោះ។

ទោះជាយ៉ាងណាក៏ដោយ ដូចជាអ្នកបម្រើក្នុងរឿងនេះដែលស្គាល់អំពីសេចក្ដីល្អរបស់ព្រះជាម្ចាស់ យើងចង់ក្លាយជាផ្នែកមួយនៃការអែអង្គាសប្រាក់ភ្លាមៗ ហើយយើងចង់ផ្ដល់ឱ្យក្នុងកម្រិតមួយដែលទាមទារឱ្យមានជំនឿ និងការស្ដាប់បង្គាប់ចំពោះអ្វីដែលយើងជឿថាព្រះអង្គកំពុងប្រាប់យើង។

នៅថ្ងៃដែលក្រុមជំនុំទាំងមូលបានប្រកាសអំពីអ្វីដែលពួកគេយល់ស្របលើការសាបព្រោះនៅក្នុងគម្រោងសាងសង់នោះ ឌ្រិនដានិងខ្ញុំបាននិយាយថាយើងបានចំណាយអស់ ២០០.០០០ ដុល្លាររួចហើយ។ ឥលូវនេះ យើងមិនមានប្រាក់ ២០០.០០០ ដុល្លារទៀតទេ ប៉ុន្តែយើងមានគ្រាប់ពូជប្រហែល ២០.០០០ ដុល្លារដែលយើងនឹងសាបព្រោះសម្រាប់ប្រាក់ដែលនៅសល់។

យើងបានដឹង ដូចជាអ្វីដែលទ្រង់បានធ្វើកាលពីមុនរួចហើយ គឺព្រះជាម្ចាស់នឹងបង្ហាញយើងអំពីទីកន្លែង និងរបៀបប្រមូលប្រាក់ដែលនៅសេសសល់ជាច្រើនសម្រាប់យើង។

បន្ទាប់ពីបានសាបព្រោះអ្វីដែលយើងមានរួច យើងចាប់ផ្ដើមអធិស្ឋានដោយការណែនាំពីព្រះវិញ្ញាណ ដោយរង់ចាំសម្រាប់ទិសដៅ និងការណែនាំ ព្រមទាំងរបៀបចាប់យកចំនួនប្រាក់ដែលនៅសល់។ ដើម្បីបង្ហាញអ្នកឱ្យយល់អំពីររបៀបដែលព្រះជាម្ចាស់នាំទៅយកប្រាក់ទាំងនោះមក ខ្ញុំត្រូវតែប្រាប់អ្នកថា យើងបានកាន់កាប់ក្រុមហ៊ុនហិរញ្ញវត្ថុអស់រយៈពេល ៣៩ ឆ្នាំហើយ។ ក្រុមហ៊ុននោះធ្វើការជាមួយនឹងអ្នកលក់ និងអ្នកជំនាញផ្សេងៗ ដូចដែលខ្ញុំបាននិយាយប្រាប់អ្នកពីដំបូងអ៊ីចឹង។ ភាគច្រើននៃអ្នក

លក់ធំៗដែលយើងធ្វើការជាមួយ មានសន្និបាតប្រចាំឆ្នាំ និងការជួបជុំគ្នាសម្រាប់អតិថិជនរបស់ពួកគេ។

នៅក្នុងឆ្នាំនោះផ្ទាល់ អ្នកលក់របស់យើងម្នាក់បានអញ្ជើញឌ្រិនដា និងខ្ញុំទៅក្រុងឡុងដ៍ ប្រទេសអង់គ្លេសសម្រាប់សន្និបាតរបស់ពួកគេ។ យើងបានស្នាក់នៅសណ្ឋាគារដ៏ស្រស់ស្អាតមួយនៅកណ្ដាលទីក្រុងឡុងដ៍ ហើយវាជាកន្លែងគួរឱ្យស្រលាញ់ដូចជាគេនិយាយអីចឹង។

ក្រុមហ៊ុនបានរៀបចំព្រឹត្តិការណ៍មួយនៅម្ខាងទៀតនៃទីក្រុង ហើយអនុប្រធានក្រុមហ៊ុននោះបានអញ្ជើញឌ្រិនដា និងខ្ញុំឱ្យជិះឡានតាក់ស៊ីជាមួយនាង ដើម្បីចូលរួមព្រឹត្តិការណ៍នោះ ដែលយើងបានទទួលដោយការស្វាគមន៍យ៉ាងរីករាយ។ ក្នុងអំឡុងពេលជិះតាក់ស៊ី អនុប្រធានបានអរគុណយើងចំពោះរាល់អាជីវកម្មដែលយើងបានផ្ដល់ឱ្យពួកគេ។ ហើយបន្ទាប់មក ក៏ចាប់ផ្ដើមប្រាប់យើងអំពីកម្មវិធីប្រាក់រង្វាន់ថ្មីដែលពួកគេបានបើកដំណើរការនៅឆ្នាំនោះ។

នាងបានបន្តពន្យល់ពីរបៀបដែលវាដំណើរការ និងរចនាសម្ពន្ធប្រាក់រង្វាន់ថាពួកគេនឹងផ្ដល់នោះប្រាក់ទៅឱ្យសហការីណាដែលបានជួយណែនាំផលិតផលរបស់ពួកគេ។ ខ្ញុំរំភើបចិត្តណាស់ពេលឮនាងនិយាយដូច្នេះ ដោយធ្វើឱ្យខ្ញុំដឹងថាយើងបាននាំអតិថិជនឱ្យពួកគេគ្រប់គ្រាន់ សមនឹងទទួលរង្វាន់ដែលនាងកំពុងតែនិយាយនេះ។

បន្ទាប់មក ខ្ញុំក៏បានសួរលម្អិតបន្ថែមទៀត នាងបានបញ្ជាក់ភ្លាមៗថាក្រុមហ៊ុនរបស់យើងនឹងមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានកម្មវិធីប្រាក់រង្វាន់ទេ ដោយផ្អែកលើរចនាសម្ពន្ធនៃទំនាក់ទំនងរបស់យើងជាមួយក្រុមហ៊ុនរបស់នាង។

ខ្ញុំសឹងតែមិនជឿ។ ហេតុអ្វីបានជានាងនិយាយលម្អិតរឿងប្រាក់រង្វាន់ទាំងអស់នេះឱ្យខ្ញុំសប្បាយចិត្តរួចហើយ បែរជាដកយកភាពសប្បាយនោះចេញវិញមួយរំពេចដូច្នេះ? ខ្ញុំក៏មិនយល់ពីទំនាក់ទំនងរបស់ខ្ញុំជាមួយក្រុមហ៊ុននាង ថាត្រូវបានរៀបចំ

រចនាសម្ពន្ធឡើងយ៉ាងដូចម្ដេច ទើបបានជាមិនឱ្យខ្ញុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់រង្វាន់នោះ។

ទោះបីជាខ្ញុំបានសួរសំណួរបន្ថែមទៀតយ៉ាងណាក៏ដោយ នាងមិនបានផ្ដល់ចម្លើយឱ្យខ្ញុំច្បាស់លាស់ទេ។ រឿងតែមួយគត់ដែលខ្ញុំដឹងច្បាស់គឺថា ខ្ញុំមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ប្រាក់រង្វាន់នោះទេ គឺនាងបាននិយាយដូច្នេះយ៉ាងច្បាស់។

មួយឆ្នាំកន្លងផុតទៅ ហើយផលិតកម្មរបស់យើងមានភាពល្អប្រសើរសម្រាប់ឆ្នាំនោះ ដូច្នេះខ្ញុំមានគំនិតចង់ទូរសព្ទទៅនាង ហើយសួរម្ដងទៀតអំពីការទទួលប្រាក់រង្វាន់។ ទោះបីជាយ៉ាងណា លើកនេះពេលខ្ញុំទូរសព្ទទៅ ខ្ញុំមិនអាចទាក់ទងនាងបានទេ ទើបខ្ញុំផ្ញើសារទៅជំនួយការរបស់នាង ដោយភ្ជាប់នូវសំណួររបស់ខ្ញុំ។

**អ្នកឃើញទេ ព្រះជាម្ចាស់ជាព្រះដែលប្រទានរង្វាន់! ហើយមានផលចំណេញក្នុងការមានចិត្តសប្បុរសចំពោះកិច្ចការរបស់ទ្រង់។**

នៅថ្ងៃបន្ទាប់ ជំនួយការរបស់នាងបានទូរសព្ទត្រលប់មកខ្ញុំវិញ ហើយបានបញ្ជាក់ដោយសំឡេងយ៉ាងម៉ឺងម៉ាត់ថា អនុប្រធានបានប្រាប់ខ្ញុំរួចហើយ កាលពីមួយឆ្នាំមុនគឺថា ខ្ញុំមិនមានលក្ខណៈគ្រប់គ្រាន់ ហើយគ្មានអ្វីដែលអាចឱ្យនាងផ្ដល់រង្វាន់នោះបានទេ។

*ពិតណាស់ មិនអីទេ។* ខ្ញុំបានគិតថា *យ៉ាងហោចណាស់ក៏ខ្ញុំបានព្យាយាមដែរ។*

ឥលូវនេះ នៅពេលដែលខ្ញុំកំពុងអធិស្ឋានអំពីកន្លែងដែលអាចរកប្រាក់ ១៨០.០០០ ដុល្លារ ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធប្រាប់ខ្ញុំឱ្យទូរសព្ទទៅអនុប្រធាននោះ ហើយសួរដំណឹងអំពីប្រាក់រង្វាន់ម្ដងទៀត។ ខ្ញុំនឹងប្រាប់អ្នកថា ខ្ញុំមិនរំភើបចិត្តពេលបានឮដូច្នេះទេ។ បន្ទាប់ពីខ្ញុំមានបទពិសោធសុំនាងកាលពីពីរឆ្នាំមុន ខ្ញុំបានដឹងថានាងជាមនុស្សមានលក្ខណៈបែបណា។ នាងបានបញ្ជាក់យ៉ាងច្បាស់អំពីរឿងប្រាក់រង្វាន់នោះ។

ដូច្នេះខ្ញុំគិតថា ខ្ញុំគ្រាន់តែផ្ញើអ៊ីមែលទៅនាង ដើម្បីគ្រាន់តែចង់សាកល្បងប៉ុណ្ណោះ ដើម្បីរកវិធីនិយាយជាមួយនាង។

ប្រហែលប្រាំពីរថ្ងៃក្រោយមកខ្ញុំបានទទួលការឆ្លើយតបរបស់នាង ដែលធ្វើឱ្យខ្ញុំមានអំណរដោយនាងបានគិតអំពីរង្វាន់នោះ ហើយបានសម្រេចចិត្តផ្តល់រង្វាន់ដល់ក្រុមហ៊ុនរបស់ខ្ញុំ ជាចំនួនទឹកប្រាក់រង្វាន់ ២០០.០០០ ដុល្លារ! ត្រង់នេះជាផ្នែកដ៏អស្ចារ្យ។ កុងត្រានោះត្រូវបានផ្លាស់ប្តូរស្ថិតនៅក្នុងកិច្ចព្រមព្រៀងថ្មីរហូតមកទល់បច្ចុប្បន្ននេះក្នុងពេល ១៩ **ឆ្នាំ**មកហើយ។ ហើយយើងបានទទួលប្រាក់រង្វាន់ ២០០.០០០ ដុល្លារជារៀងរាល់ឆ្នាំចាប់តាំងពីពេលនោះមក។

អ្នកឃើញទេ ព្រះជាម្ចាស់គឺជាអ្នកផ្តល់រង្វាន់! ហើយមានផលចំណេញក្នុងការមានចិត្តសប្បុរសចំពោះកិច្ចការរបស់ទ្រង់។

តើវាមានតម្លៃប៉ុណ្ណា ដែលឌ្រិនដានិងខ្ញុំបានសាបព្រោះចំនួន ២០០.០០០ ដុល្លារ?

ប្រហែលជាប្រាំឆ្នាំកន្លងផុតទៅ យើងបានសម្រេចចិត្តនៅក្នុងក្រុមជំនុំថារៃអង្គាសប្រាក់បន្ថែមទៀតដើម្បីធ្វើរឿងមួយចំនួនទៀតសម្រាប់ក្រុងជំនុំ ហើយទិញគ្រឿងបរិក្ខារមួយចំនួនទៀត។ ជាថ្មីម្តងទៀត ឌ្រិនដានិងខ្ញុំបានសម្រេចថា តើយើងចង់បានប្រាក់ប៉ុន្មានទៀត ដើម្បីសាបព្រោះសម្រាប់គម្រោងនោះ។ ហើយយើងបានសម្រេចចិត្តថាត្រូវការ ៥០០.០០០ ដុល្លារបន្ថែមទៀត។

វ៉ោ៎ នោះជាចំនួនទឹកប្រាក់ដ៏ច្រើន។ ប៉ុន្តែយើងមានអារម្មណ៍ថា យើងអាចទុកចិត្តព្រះជាម្ចាស់ជាមួយនឹងចំនួនទឹកប្រាក់នោះ បន្ទាប់ពីបានឃើញអ្វីដែលទ្រង់បានធ្វើជាមួយនឹងទឹកប្រាក់ចំនួន ២០០.០០០ ដុល្លាររួចមក។ ជាថ្មីម្តងទៀត យើងបានសាបព្រោះ អ្វីដែលយើងអាចធ្វើបាន ដែលខ្ញុំគិតថាប្រាកដជាទទួលបានទឹកប្រាក់ ៥០.០០០

ដុល្លារ ហើយយើងជឿព្រះវិញ្ញាណដ៏វិសុទ្ធកំពុងបង្ហាញយើងពីទីកន្លែង និងរបៀបដើម្បីរកប្រាក់ដែលនៅខ្វះចំនួន ៩៥០.០០០ ដុល្លារទៀត។

ខ្ញុំគិតថាប្រហែលជាប្រាំមួយសប្ដាហ៍កន្លងផុតទៅ ខ្ញុំបានទទួលការជូនដំណឹងមួយថា នឹងមានការផ្លាស់ប្ដូរកិច្ចសន្យាមួយចំនួនអំពីរបៀបដែលគេនឹងបង់ប្រាក់ឱ្យក្រុមហ៊ុនរបស់យើង។ បន្ទាប់ពីយើងគណនាការផ្លាស់ប្ដូរដែលនឹងកើតឡើង យើងអាចរកបានប្រហែល ៦៣០.០០០ ដុល្លារបន្ថែមទៀតក្នុងរយៈពេលជាងបីឆ្នាំខាងមុខ ច្រើនជាងប្រាក់ដែលយើងរកបាន។ ពិតជាឡូយណាស់ មែនទេ? ការផ្លាស់ប្ដូរកិច្ចសន្យានោះបានស្ថិតនៅក្នុងកិច្ចព្រមព្រៀងមកទល់តលូវនេះគឺ១១ឆ្នាំហើយ យើងនៅតែទទួលបានអត្រាកើនឡើងក្នុងកិច្ចសន្យានោះជារៀងរាល់ឆ្នាំ។

ជាថ្មីម្ដងទៀត តើវាមានតម្លៃប៉ុន្មានដែលខ្ជិនជា និងខ្ញុំបានសាបព្រោះ និងការមានចិត្តសប្បុរសចំពោះគម្រោងរបស់ព្រះជាម្ចាស់?

ដូច្នេះសូមចងចាំថា ព្រះជាម្ចាស់ជាព្រះនៃផលចំណេញ។ ទ្រង់ល្អ និងជាព្រះដែលប្រទានរង្វាន់។

# ជំពូក ៣
# តើអ្នកមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ឬទេ?

ខ្ញុំគិតថា អ្នករាល់គ្នាបានឮរឿងបុណ្យណូអែល និងស្ដេចបីអង្គដែលនាំយកមាស គ្រឿងក្រអូប និងជ័រល្វីងទេសមកថ្វាយព្រះយេស៊ូ។ តើអ្នកធ្លាប់ឆ្ងល់ទេថារបស់ទាំងនោះមានតម្លៃប៉ុនណាទេ? សំណួរងាយយល់ជាងនេះគឺថា «ហេតុអ្វីបានជាស្ដេចទាំងបីអង្គនាំយករបស់ទាំងនោះ មកថ្វាយទ្រង់ដល់ទីកន្លែងដែលទ្រង់ប្រសូត?»

មែនហើយ ដោយមានការស៊ើបអង្កេតមួយចំនួនខ្ញុំបានរកឃើញថា វាជារឿងសាមញ្ញ នៅសម័យនោះ ក្នុងការផ្ដល់កិត្តិយសដល់ស្ដេចដោយថ្វាយអំណោយប្រភេទនេះ ដូចដែលគេមើលឃើញថាទ្រង់ជាស្ដេចនាពេលអនាគត។

ការប៉ាន់ប្រមាណដ៏ល្អបំផុតគឺថាអំណោយទាំងនេះប្រហែលជាមានតម្លៃចន្លោះពី១០០.០០០ដុល្លារ ដល់រាប់រយពាន់ដុល្លារ។

អ្នកប្រាជ្ញទាំងនោះប្រាកដជាបានសិក្សាបទគម្ពីរ និងទំនាយអំពីព្រះមេស្ស៊ីដែលនឹងយាងមក ហើយនៅពេលដែលបានឃើញផ្កាយនោះ បានសន្និដ្ឋានថាទ្រង់នៅទីនោះ បន្ទាប់មកបានធ្វើដំណើរដ៏ឆ្ងាយដើម្បីនាំយកអំណោយថ្វាយទ្រង់។

គោលគំនិតដែលថា ស្ដេចទាំងបីអង្គនោះបានជួបព្រះយេស៊ូនៅក្នុងស្នូក មិនមែនជាអ្វីដែលបានកើតឡើងនោះទេ ទោះបីជាវាត្រូវបានបង្ហាញតាមរបៀបនោះនៅក្នុង

រឿងបុណ្យណូអែលរបស់យើងក៏ដោយ។ យើងដឹងរឿងនេះដោយសារគម្ពីរម៉ាថាយចែងដូចខាងក្រោម។

> *គេចូល<u>ទៅក្នុងផ្ទះ</u> ឃើញព្រះឱរសគង់នៅជាមួយនាងម៉ារីជាមាតា គេក៏នាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ រួចបើកហិបយកទ្រព្យរបស់ខ្លួន គឺមាស គ្រឿងក្រអូប និងជ័រល្វីងទេស មកថ្វាយព្រះអង្គ។*
>
> —ម៉ាថាយ ២:១១

ស្ដេចទាំងបីអង្គនោះបានជួបព្រះយេស៊ូនៅឯផ្ទះរបស់ទ្រង់ មិនមែននៅក្នុងស្នូកនោះទេ។ អត្ថបទគម្ពីរនេះបញ្ជាក់ថា ទ្រង់ជាកុមារតូច មិនមែនជាទារកទេឡើយ។ ដូច្នេះ អ្នកប្រាជ្ញត្រូវចំណាយពេលមួយរយៈដើម្បីទៅដល់ទីនោះ។

ទីពីរ គ្មាននរណាម្នាក់ដឹងថាមានអ្នកប្រាជ្ញប៉ុន្មាននាក់នោះទេ។ ព្រះគម្ពីរមិនបាននិយាយថាមានអ្នកប្រាជ្ញប៉ុន្មាននាក់មកនោះទេ ប៉ុន្តែបានកត់ត្រាអំពីអ្វីដែលអ្នកប្រាជ្ញទាំងនោះ បាននាំយកមកថ្វាយទ្រង់។ នៅពេលនោះ គ្រឿងក្រអូប និងជ័រល្វីងទេសពិតជាមានតម្លៃជាងមាសទៅទៀត ដូច្នេះហើយ អំណោយដែលអ្នកប្រាជ្ញបាននាំយកមកថ្វាយទ្រង់មានតម្លៃខ្លាំងណាស់។

ដូច្នេះ ហេតុអ្វីបានជាខ្ញុំលើកយករឿងនេះមកនិយាយ? ខ្ញុំសូមសួរអ្នកថា «តើអ្នកគិតថា ហេតុអ្វីបានជាហោរាទាំងនេះនាំយកអំណោយទាំងនេះមកថ្វាយទ្រង់?»

ខ្ញុំអាចប្រាប់អ្នកពីមូលហេតុ—លោកយ៉ូសែបត្រូវការការផ្គត់ផ្គង់សម្រាប់កិច្ចការរបស់គាត់។

ចូរចងចាំថា...

ព្រះជាម្ចាស់តែងតែផ្ដល់ថវិកាដល់កិច្ចការរបស់ទ្រង់ជានិច្ច!

## តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ?

ក្រុមជំនុំ Faith Life Church មានមនុស្សចូលរួមយ៉ាងកកកុញ។ វាមានមនុស្សចូលរួមយ៉ាងកកកុញនៅថ្ងៃចុងសប្តាហ៍ និងកកកុញនៅក្នុងអំឡុងសប្តាហ៍ ដែលយើងបានអប់រំកុមារជាង ២០០នាក់ ហើយមានពេញដោយក្រុមតូច និងបុគ្គលិកជាច្រើន។ យើងត្រូវការបន្ទប់បន្ថែមទៀត។ យើងបានចាប់ផ្តើមពិភាក្សាថាតើយើងគួរតែបើកទីតាំងថ្វាយបង្គំទីពីរ ឬបើកក្នុងអគារ បច្ចុប្បន្នរបស់យើង។ យើងបានសម្រេចចិត្តធ្វើរឿងទាំងពីរនេះក្នុងពេលតែមួយ។

ដូច្នេះ យើងបានបង្កើតជាក្រុមមួយដើម្បីចាប់ផ្តើមស្វែងរកទីកន្លែងសាងសង់អគារហើយយើងបានដឹកនាំពួកគេទៅកាន់តំបន់ទីប្រជុំជនដែលយើងមានអារម្មណ៍ថាយើងគួរតែមើលមុនគេ។

ក្នុងពេលជាមួយគ្នានេះ យើងបានចាប់ផ្តើមជំហានដំបូងក្នុងការរចនាអគារ ការសិក្សាផ្នែកវិស្វកម្ម និងផ្សេងៗទៀតដើម្បីពង្រីក។ យើងបានឱ្យស្ថាបត្យករ និងអ្នកសាងសង់ចូលរួម ហើយបង្កើតជាក្រុមប្រឹក្សាយោបល់រួមគ្នាមួយ ដែលសុទ្ធតែមានបទពិសោធក្នុងការម៉ៅការ។

យើងបានរកឃើញថាមានបញ្ហាធ្ងន់ធ្ងរមួយចំនួនបន្ថែមទៀត។ អ្វីដែលសំខាន់បំផុតនោះគឺថាយើងមិនមានប្រព័ន្ធលូ និងមិនមានទឹកប្រើប្រាស់នៅក្នុងអគារបច្ចុប្បន្នរបស់យើងឡើយ។ យើងបានប្រើប្រាស់ទឹកអណ្តូង និងប្រព័ន្ធគ្រប់គ្រងកាកសំណល់ដោយខ្លួនឯងសម្រាប់ប្រព័ន្ធលូរបស់យើង។

រដ្ឋាភិបាលក្នុងតំបន់បានប្រាប់យើងថា យើងមិនអាចសាងសង់នៅលើ ឬបន្ថែមអគារនៅលើបរិវេណទំហំ ១៥ ហិចតារបស់យើងបានទេ លុះត្រាតែយើងមានទឹករដ្ឋ និងមានប្រព័ន្ធលូរដ្ឋតភ្ជាប់ទៅអគារ ព្រោះយើងបានពង្រីកសមត្ថភាពពេញតាមកម្រិតដែលពួកគេអាចអនុញ្ញាតហើយ។ យើងបានដឹងពីស្ថានភាពនោះ ប៉ុន្តែមានអគារ

ថ្មីជាច្រើនដែលកំពុងត្រូវបានសាងសង់នៅជុំវិញយើង ដែលខ្ញុំប្រាកដថា នឹងមានការតភ្ជាប់ទឹក និងប្រព័ន្ធលូគ្រប់គ្រាន់មកដល់។

ប៉ុន្តែយើងបានរកឃើញថា បណ្តាញទឹក និងប្រព័ន្ធលូមិនទាន់មាននៅតាមផ្លូវរបស់យើងនៅឡើយ ដូច្នេះវាមិនមែនជាបញ្ហាក្នុងការគ្រាន់តែទទួលបានសេវាទាំងនោះទេ ប៉ុន្តែគឺមិនមានសេវាទាំងនេះនៅទីនោះទេ។

យើងចាប់ផ្តើមទទួលបានការដេញថ្លៃលើការតបណ្តាញទឹក និងបណ្តាញលូមកក្នុងអគាររបស់យើង ដោយយើងជាអ្នកទទួលខុសត្រូវលើការបង់ថ្លៃសេវា ហើយបន្ទាប់មកទទួលបានមកវិញនូវថ្លៃចំណាយជាច្រើន ដោយសារការអភិវឌ្ឍថ្មីៗដែលត្រូវទូទាត់មកយើងនូវថ្លៃភ្ជាប់សេវាតបណ្តាញទឹក និងប្រព័ន្ធលូ។ អ្នកប្រហែលជាមិនចង់ដឹងទេថា តើការតភ្ជាប់ទាំងអស់នោះនឹងត្រូវចំណាយអស់ប៉ុន្មាន។

**ព្រះជាម្ចាស់តែងតែផ្តល់ថវិកាដល់កិច្ចការរបស់ទ្រង់!**

ដូច្នេះ យើងបានត្រលប់ទៅទីក្រុងវិញ ហើយពិនិត្យមើលផែនការ និងពេលកំណត់របស់ពួកគេថាតើសេវាទាំងនេះនឹងមាននៅពេលណា ហើយយើងសង្ឃឹមថាគេនឹងពិចារណាក្នុងការលើកពេលបន្តិច ដោយសារតែតំបន់នេះកំពុងរីកចម្រើន ហើយសេវាទាំងនោះនឹងមានសារៈសំខាន់បំផុត។ ប៉ុន្តែពួកគេមិនបានផ្លាស់ប្តូរឡើយ។ ដូច្នេះតើពួកគេបាននិយាយថាចំណាយពេលយូរប៉ុនណា ទម្រាំមានសេវាទាំងនោះ? មិនមែនឆាប់ៗនេះទេ។

យើងដឹងថាយើងមិនអាចរង់ចាំទឹក និងបណ្តាញលូជាច្រើនឆ្នាំនោះទេ ដើម្បីឱ្យមាននៅក្នុងតំបន់របស់យើង ដូច្នេះយើងបានសម្រេចចិត្តក្នុងការផ្អាកការសាងសង់បន្ថែមរបស់យើងសិន ហើយដាក់គោលបំណងចម្បងដោយចាប់ផ្តើមស្វែងរកទីតាំងថ្វាយបង្គំមួយវិញ។ (មានរយៈពេលបួនឆ្នាំហើយ ចាប់តាំងពីការប្រជុំនោះរហូតដល់

ពេលនៃការសរសេរជំពូកនេះ ហើយរដ្ឋាភិបាលក្នុងទីក្រុងនៅតែមិនទាន់និយាយថានៅពេលណាមានបណ្ដាញលូ។)

ក្រុមការងាររបស់យើងបានស្វែងរកទីតាំងថ្វាយបង្គំដែលល្អបំផុតអស់រយៈពេល០៦ខែ តែមិនទទួលបានជោគជ័យឡើយ។ វាហាក់ដូចជាមិនមានអគារណាដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យរបស់យើងដែលអាចជួល ឬទិញបានទេ។ ដូច្នេះយើងបានពិចារណាជួលមជ្ឈមណ្ឌលរៀបចំព្រឹត្តិការណ៍មួយនៅក្នុងតំបន់នោះ ហើយសម្រាប់រៀបចំតែថ្ងៃចុងសប្ដាហ៍ប៉ុណ្ណោះ ដែលនឹងត្រូវចំណាយអស់ ៣០.០០០ដុល្លារក្នុងមួយខែ។ លើសពីថ្លៃចំណាយនេះ យើងនឹងត្រូវរៀបចំ និងរុះរើរាល់សប្ដាហ៍។ ខ្ញុំពិតជាមិនចង់ឱ្យសមាជិករបស់យើងនៅក្នុងស្ថានភាពនោះទេ។ ខ្ញុំចង់បានកន្លែងជាអចិន្ត្រៃយ៍ដែលយើងអាចគ្រប់គ្រងបាន។ យើងមិនមានសេចក្ដីសុខសាន្តក្នុងចិត្តអំពីមជ្ឈមណ្ឌលរៀបចំព្រឹត្តិការណ៍នេះទេ។

បន្ទាប់មក យើងស្វែងរកជួលកន្លែងនៅក្នុងផ្សារទំនើបចាស់មួយក្នុងទីប្រជុំជន។ ប៉ុន្តែបន្ទាប់ពីបានពិចារណាលើការជួសជុល និងការផ្លាស់ប្ដូរទាំងអស់ដែលចាំបាច់ យើងបានសម្រេចចិត្តថា វាមិនមែនជាកន្លែងដែលយើងត្រូវទៅទេ។

តម្លៃស្នូលមួយក្នុងចំណោមតម្លៃស្នូលទាំងឡាយរបស់យើងក្នុងការស្វែងរកអគារ គឺថាអគារនោះត្រូវតែអាចបម្រើដល់ការអប់រំរបស់កុមារក្នុងអំឡុងពេលសប្ដាហ៍។ មានគ្រួសាររាប់រយដែលមានកូនរៀននៅក្នុងក្រុមជំនុំរបស់យើង ហើយយើងបានសហការ និងរៀបចំថ្នាក់រៀនរៀងរាល់សប្ដាហ៍។ យើងបាននិយាយជាច្រើនដងអំពីថ្ងៃណាមួយដែលអាចមានសាលារៀន មានមណ្ឌលថៃទាំ កម្មវិធីបន្ទាប់ពីម៉ោងសិក្សា និងកម្មវិធីជាច្រើនទៀតដើម្បីបម្រើដល់សហគមន៍មូលដ្ឋានរបស់យើង។ យើងចង់រកកន្លែងដែលយើងអាចធ្វើកិច្ចការនោះ។ យើងបានផ្សព្វផ្សាយក្នុងការទទួលបានអគារ

នោះ ដោយអះអាងថា យើងនឹងស្វែងរកអគារដ៏ល្អឥតខ្ចោះសម្រាប់តម្រូវការរបស់យើង ប៉ុន្តែយើងរកអគារមិនបានឡើយ។

ឌ្រិនដា និងខ្ញុំមានគម្រោងនឹងចូលរួមកិចប្រជុំមួយនៅទីក្រុង Fort Worth រដ្ឋតិចសាស ក្នុងការគាំទ្រប៉ុស្តិ៍ទូរទស្សន៍ជ័យជម្នះថ្មី។ ពេលដែលខ្ញុំស្ថិតនៅក្នុងកិច្ចប្រជុំនោះ ព្រះជាម្ចាស់បានមានព្រះបន្ទូលមកខ្ញុំថា *«យើងចង់ឱ្យអ្នកសាបព្រោះប្រាក់ចំនួន ១០០.០០០ដុល្លារទៅក្នុងប៉ុស្តិ៍ទូរទស្សន៍នេះ។ សូមត្រលប់ទៅផ្ទះវិញចុះ ទៅក្រុមជំនុំរបស់អ្នក ចេញមូលប្បទានបត្រ និងកាន់វានៅក្នុងវេនប្រជុំថ្វាយបង្គំនីមួយៗ ហើយប្រកាសអំពីគ្រាប់ពូជនោះថា អ្នកនឹងរកឃើញអគារដ៏ល្អឥតខ្ចោះ។ ម្យ៉ាងវិញទៀត ចូរបន្ទោសសាតាំង ហើយប្រាប់វាឱ្យឈប់រារាំងកិច្ចការរបស់យើង។ ចូរហៅកិច្ចការនោះថាបានសម្រេច ដូចដែលអ្នកបានសាបព្រោះ»។*

ដូច្នេះ នោះជាអ្វីដែលយើងបានធ្វើ។ យើងបានទៅផ្ទះវិញ ហើយខ្ញុំបានទូរសព្ទទៅហិរញ្ញិករបស់ខ្ញុំ ហើយប្រាប់គាត់ឱ្យចេញមូលប្បទានបត្រតម្លៃ ១០០.០០០ ដុល្លារឱ្យប៉ុស្តិ៍ទូរទស្សន៍ជ័យជម្នះ។ បន្ទាប់មក ខ្ញុំបានយកមូលប្បទានបត្រនោះទៅក្នុងវេនថ្វាយបង្គំនីមួយ ហើយក្រុមជំនុំទាំងមូលបានយល់ព្រមជាមួយខ្ញុំ ពេលយើងសាបព្រោះគ្រាប់ពូជនោះដើម្បីបានអគារដ៏ល្អឥតខ្ចោះ។ យើងបានស្តីបន្ទោសសាតាំង ហើយប្រាប់វាឱ្យឈប់រារាំង និងបង្អាក់ដល់ការផ្គត់ផ្គង់របស់យើង។

នៅថ្ងៃបន្ទាប់ គឺព្រឹកថ្ងៃចន្ទ យើងបានទទួលការហៅទូរសព្ទពីកូនស្រីរបស់យើង ដែលបាននិយាយថា ខណៈពេលដែលយើងនៅឯកិច្ចប្រជុំនៅរដ្ឋតិចសាស់ ភ្នាក់ងារអចលនទ្រព្យបានបង្ហាញគាត់អំពីអចលនទ្រព្យដ៏គួរឱ្យចាប់អារម្មណ៍មួយ។ វាមិនមែនសម្រាប់ជួលទេ ហើយវាមានតម្លៃលើសពីខ្ទង់ថវិការបស់យើង ដោយសារតែគេលក់ក្នុងតម្លៃ ៧,៩លានដុល្លារ។ ប៉ុន្តែវាមានតម្លៃថ្លៃជាងនោះទៅទៀត ព្រោះអគារនោះជាការរឹបអូសរបស់ធនាគារ។ គាត់បាននិយាយថា វានឹងជាអគារដ៏ល្អឥតខ្ចោះ ប៉ុន្ត

គាត់ដឹងថា វាមិនមែនជាជម្រើសផ្នែកហិរញ្ញវត្ថុនោះទេ។ ប៉ុន្តែគាត់ចង់ដឹងថាតើយើងចង់ទៅមើលឬទេ? យើងបាននិយាយថា ប្រាកដណាស់យើងចង់ទៅមើល។

ដូច្នេះ នៅព្រឹកថ្ងៃអង្គារ យើងបានទៅមើលអចលនទ្រព្យ។ អចលទ្រព្យនោះស្ថិតនៅលើផ្ទៃដីទំហំបីហិចតា និងធ្លាប់ជាទីតាំងវិទ្យាល័យឯកជនលំដាប់ខ្ពស់មួយ។ អចលនទ្រព្យនោះមានអគារវិទ្យាល័យបីជាន់ និងអគារធំៗចំនួនពីរទៀត ថែមទាំងមានផ្ទះមួយនៅលើអចលនទ្រព្យផងដែរ។ មានទីលានរត់ប្រណាំង ទីលានវាយកូនបាល់ចំនួនបួន បន្ទប់ហាត់ប្រាណ អគារសិល្បៈមួយដែលមានបន្ទប់ថតរូប ឡដុតចំនួនពីរសម្រាប់ធ្វើគ្រឿងស្មូន បន្ទប់ដែលមានពេញដោយឧបករណ៍សម្រាប់ដេរ និងសម្ភារៈសិល្បៈ ឧបករណ៍តន្ត្រីរាប់សិបគ្រឿងនៅក្នុងបន្ទប់តន្ត្រី និងមានអ្វីៗជាច្រើនទៀត។ អចលទ្រព្យទាំងមូលត្រូវបានបំពាក់ដោយគ្រឿងសង្ហារិម និងមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់។

យើងបានដើរមើលជុំវិញអចលនទ្រព្យនោះ យើញថាល្អណាស់។ ប៉ុន្តែនៅពេលជាមួយគ្នានោះ យើងដឹងថាយើងមិនអាចជំពាក់បំណុលគេដើម្បីទិញអចលទ្រព្យនោះទេ។ យើងមានប្រាក់សន្សំប្រហែល៣លានដុល្លារនៅក្នុងមូលនិធិសាងសង់អគាររបស់យើង ប៉ុន្តែដើម្បីទិញអចលនទ្រព្យនោះ យើងនៅតែត្រូវខ្ចីប្រាក់គេជិត៥លានដុល្លារ។

នៅយប់នោះ យើងគ្រោងពិសាអាហារពេលល្ងាចជាមួយដៃគូព័ន្ធកិច្ចម្នាក់ក្នុងចំណោមដៃគូព័ន្ធកិច្ចទាំងអស់របស់យើង។ ឥលូវនេះ អាហារពេលល្ងាចដែលបានគ្រោងទុក ហើយបានលើកពេលប្រហែលជាបួនដងនៅរដូវស្លឹកឈើជ្រុះ ដោយសារយើងទាំងពីរមមាញឹកខ្លាំង ប៉ុន្តែយប់នោះ យើងបានពិសាអាហារពេលល្ងាចជុំគ្នា។

នៅពេលយើងនិយាយគ្នា បុរសនោះបានចាប់ផ្តើមសួរខ្ញុំអំពីគម្រោងសាងសង់អគារ ហើយខ្ញុំបានប្រាប់គាត់អំពីការពន្យារពេលទាំងអស់ដែលយើងបានជួប

ប្រទះ។ គាត់មើលមកខ្ញុំ ហើយនិយាយថា «លោកដឹងទេ ខ្ញុំមិនមានអារម្មណ៍សាងសង់អគារទេ។ ខ្ញុំពិតជាគិតថា លោកគួរតែពិចារណាបើកសាលារៀនជំនួសវិញ»។ ខ្ញុំបានប្រាប់គាត់ថា យើងយល់ស្របតាមគំនិតនេះ ហើយតាមពិតទៅ យើងបានស្វែងរកអគារអស់រយៈពេលប្រាំមួយខែមកហើយ ដោយមិនទទួលបានជោគជ័យឡើយ។ ទោះយ៉ាងណាក៏ដោយ យើងបានប្រាប់គាត់ថា យើងទើបតែបានទៅមើលទីតាំងអគារដ៏ល្អមួយនៅថ្ងៃនោះ ប៉ុន្តែអគារនោះមិនមែនសម្រាប់ជួលទេ ហើយលើសពីខ្ទង់ថវិការបស់យើង។

គាត់បានសួរសំណួរមួយចំនួនអំពីរឿងនេះ បន្ទាប់មកគាត់មើលទៅគ្រិនដា ហើយនិយាយថា «ចុះប្រសិនបើគេឱ្យដោយមិនគិតថ្លៃ យ៉ាងម៉េចដែរ?» គ្រិនដាមិនបានឆ្លើយអ្វីឡើយ ដោយនាងគិតថាគាត់និយាយលេង។ គាត់និយាយម្តងទៀតថា «គ្រិនដា ខ្ញុំនិយាយថា ចុះប្រសិនបើគេឱ្យដោយមិនគិតថ្លៃ យ៉ាងម៉េចដែរ?»

គ្រិនដាបានសួរថា «តើលោកចង់មានន័យថាម៉េច?»

គាត់បាននិយាយថា «ខ្ញុំនឹងសរសេរសែកសម្រាប់ទិញអគារនោះ!»។

គ្រិនដា និងខ្ញុំអង្គុយនៅទីនោះទាំងស្រឡាំងកាំង។

និយាយឱ្យខ្លីទៅ គាត់ជាអ្នកចេញថ្លៃទិញអគារ។ យើងត្រូវចំណាយប្រាក់ខ្លះលើការជួសជុលកែលម្អ និងផ្លាស់ប្តូរអគារឱ្យត្រូវនឹងការប្រើប្រាស់ដែលយើងចង់បាន។ លទ្ធផលគឺជាអគារដ៏ល្អឥតខ្ចោះ។ ហើយមានគេចេញថ្លៃទិញអគារជំនួសយើង!

ខ្ញុំមិនអាចរៀបចំគម្រោងអគារដ៏ល្អឥតខ្ចោះជាងនេះសម្រាប់តម្រូវការរបស់យើងឡើយ។ អ្វីគ្រប់យ៉ាងអំពីអគារនេះគឺល្អឥតខ្ចោះ។ យើងមានការវាយតម្លៃដែលបានធ្វើឡើងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់យើង ហើយគេវាយតម្លៃថា អគារនេះមានតម្លៃ១១លានដុល្លារ រួមទាំងសម្ភារៈទាំងឡាយដែលមាននៅក្នុងអគារនេះ។

សូមពិចារណាអំពីនេះ ៖ ឥលូវនេះយើងមានអគារដែលមានតម្លៃ១១លានដុល្លារដែលមានទីធ្លាទំហំ ៨.២៧០ ម៉ែត្រការ៉េ ដែលមានគេចេញថ្លៃជំនួសយើង! តើអ្នកចូលចិត្តរឿងនោះទេ?

ដូចដែលខ្ញុំបាននិយាយថា ព្រះជាម្ចាស់តែងតែផ្តល់ថវិកាដល់កិច្ចការរបស់ទ្រង់។ កិច្ចការនេះជាព័ន្ធកិច្ចរបស់ទ្រង់ មិនមែនជាព័ន្ធកិច្ចរបស់យើងឡើយ។ យើងគ្រាន់តែធ្វើការជាមួយទ្រង់នៅក្នុងកិច្ចការលក្ខណៈគ្រួសារ។

ឥលូវនេះ ខ្ញុំសូមប្រាប់អ្នកពីអ្វីដែលបានកើតឡើងចំពោះប្តីប្រពន្ធដែលបានផ្តល់ថវិកាសាងសង់អគារមកយើង។ ដំបូងបង្អស់ ដោយសារការជម្រះសៃក ពួកគេអាចយកអគារនោះជាថ្នូរនឹងការបរិច្ចាគរបស់ពួកគេ ហើយប្រាក់ពន្ធដែលត្រូវបង់របស់ពួកគេត្រូវបានកាត់បន្ថយច្រើនជាងអ្វីដែលពួកគេបានបង់សម្រាប់អគារ។ តើរឿងនេះអាចកើតឡើងដោយរបៀបណា? អគារនេះត្រូវដាក់ឈ្មោះរបស់ពួកគេរយៈពេលពីរឆ្នាំសិន។ បន្ទាប់មកពួកគេបានបរិច្ចាគអគារនេះសម្រាប់ព័ន្ធកិច្ចតាមតម្លៃដែលបានវាយតម្លៃបច្ចុប្បន្ន។

នេះជាយុទ្ធសាស្រ្តដែលអ្នកគួរយល់ដឹង ប្រសិនបើអ្នកជាគ្រូគង្វាល ហើយត្រូវការអគារ។ ដូច្នេះ អគារនោះបានមកយើងទាំងពីរដោយយើងមិនបានចំណាយប្រាក់ទាល់តែសោះ ដោយគាត់មានផែនការបង់ពន្ធដ៏ឆ្លាតវៃ។ ប៉ុន្តែនោះមិនមែនជាផ្នែកដ៏អស្ចារ្យនៃរឿងនេះនោះទេ។

ដៃគូនេះកំពុងព្យាយាមទិញអាជីវកម្មផ្សេងទៀតនៅក្នុងទីប្រជុំជនដែលគេដាក់លក់ នៅពេលដែលយើងមើលអចលនទ្រព្យ។ ទោះបីជាគាត់កំពុងធ្វើការផ្តល់ជូនសាច់ប្រាក់ក៏ដោយ ក៏ការដេញថ្លៃរបស់គាត់ត្រូវមានការឯកភាពពីម្ចាស់ហ្វ្រែនឆាយដែលមានបំណងទិញ តែជាអកុសល ពួកគេបានត្រលប់មកវិញ ហើយនិយាយថាពួកគេបានផ្តល់ជូនអ្នកផ្សេងហើយ។ គាត់មានការខកចិត្តយ៉ាងខ្លាំងចំពោះការសម្រេចចិត្ត

របស់ពួកគេ។ គាត់បានប្រាប់ខ្ញុំថា គាត់មិនចង់ឱ្យវាបានទៅគេទេ។ គាត់គ្រាន់តែមានអារម្មណ៍ថា វាមិនទាន់ហួសពេលទេ។

ដូច្នេះ នៅពេលដែលគាត់បានបរិច្ចាគប្រាក់នោះសម្រាប់អគាររបស់យើង គាត់បានប្រាប់ខ្ញុំថាគាត់បានបរិច្ចាគដោយជឿថាម្ចាស់ហ្វ្រេនឆាយនឹងដូរចិត្ត ដោយសារគាត់មានស្ថានភាពហិរញ្ញវត្ថុល្អបំផុត បើធៀបនឹងការសុំទិញផ្សេងទៀត ហើយគាត់ទូទាត់ជាសាច់ប្រាក់ទៀត។

ជាការពិតណាស់ បន្ទាប់ពីមានប្រតិបត្តិការលើអចលនទ្រព្យរបស់យើង គាត់បានទទួលការហៅទូរសព្ទពីម្ចាស់ដោយបញ្ជាក់ថាកិច្ចព្រមព្រៀងពីមុនត្រូវបានចាត់ទុកជាមោឃៈ ហើយតលូវនេះអគារនេះជាកម្មសិទ្ធិរបស់គាត់ប្រសិនបើគាត់ចង់បាន។ គាត់បាននិយាយថា បាទ ប្រាកដណាស់ គាត់ចង់បាន។

ក្រោយមក ពីរបីសប្តាហ៍មុនពេលដែលគាត់នឹងត្រូវទិញអចលនទ្រព្យអាជីវកម្មថ្មីនេះ គាត់មានកិច្ចព្រមព្រៀងដែលមិនបានរំពឹងទុកទាល់តែសោះ ដែលទទួលបានប្រាក់ទាំងអស់ដែលត្រូវការដើម្បីទូទាត់ជាសាច់ប្រាក់សម្រាប់អាជីវកម្ម។ គាត់មិនចាំបាច់ប៉ះសាច់ប្រាក់ដោយផ្ទាល់ដែលគាត់បានបម្រុងទុកពីមុនដើម្បីទិញអគារទាល់តែសោះ។ គាត់បានប្រាប់ខ្ញុំថា វាដូចការទទួលបានអាជីវកម្មមួយដោយមិនចំណាយប្រាក់ទាល់តែសោះ។

អូហ៎! ដោយវិធីនេះ នៅពេលដែលគាត់បានទិញអាជីវកម្មនោះ ដែលត្រូវបានវាយតម្លៃថា មានតម្លៃច្រើនជាងទ្វេដងនូវអ្វីដែលគាត់បានចំណាយសម្រាប់អគារនោះ។ ពេលគាត់ទូរសព្ទមកខ្ញុំនៅថ្ងៃដែលគាត់បានទិញអចលនទ្រព្យនោះ គាត់រំភើបចិត្តណាស់។

ព្រះរាជ្យនៃព្រះជាម្ចាស់ធ្វើការរាល់ពេល!

ដៃគូនេះមានចិត្តសប្បុរសចំពោះកិច្ចការរបស់ព្រះជាម្ចាស់ និងស្តាប់បង្គាប់ក្នុងការដើរតាម និងមើលពីអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើងទាំងពីរ។ យើងបានសាបព្រោះទៅក្នុងស្ថានីយទូរទស្សន៍ថ្មីមួយទៀតដែលជាការចាត់តាំងរបស់ព្រះជាម្ចាស់ ហើយមើលអ្វីដែលបានកើតឡើងសម្រាប់យើង។

ការមានចិត្តសប្បុរសចំពោះព្រះជាម្ចាស់ និងរាស្ត្ររបស់ទ្រង់នឹងបើកទ្វារដែលអ្នកមិនធ្លាប់គិតថាមានទ្វារនោះ។

មនុស្សតែងតែសួរខ្ញុំគ្រប់ពេលថា «ហ្គារី ប្រសិនបើអ្នកអាចផ្តល់ឱ្យខ្ញុំនូវគន្លឹះដ៏សំខាន់មួយនៅថ្ងៃនេះ ទាក់ទងនឹងហិរញ្ញវត្ថុរបស់ព្រះរាជ្យនៃព្រះជាម្ចាស់ តើគន្លឹះនោះនឹងមានលក្ខណៈយ៉ាងដូចម្តេច?»

មានរឿងជាច្រើនដែលខ្ញុំពិតជាចង់ប្រាប់អ្នក។ ប៉ុន្តែដំបូន្មានបន្តិចបន្តួចខាងក្រោមនឹងសំខាន់សម្រាប់អ្នកដែលមិនអាចកាត់ថ្លៃបាន។ ដូច្នេះសូមប្រាកដថា អ្នកកត់សម្គាល់អំពីគោលការណ៍ព្រះរាជ្យនៃព្រះដូចខាងក្រោម។

**<u>ប្រសិនបើអ្នកមិនយល់អំពីអ្វីដែលមាននៅក្នុងសៀវភៅនេះទេ៖ សូមកត់សម្គាល់ដូចខាងក្រោម!</u>**

ខ្ញុំចង់ឱ្យអ្នកមើលព្រះគម្ពីរលូកាជំពូក៩ នៅពេលខ្ញុំចាប់ផ្តើមបកស្រាយក្រឹត្យវិន័យអំពីព្រះចេស្តានៃព្រះរាជ្យរបស់ព្រះជាម្ចាស់សម្រាប់អ្នក។ ខ្ញុំដឹងថាអត្ថបទខាងក្រោមគឺវែងជាងអត្ថបទដែលខ្ញុំបានដកស្រង់ជាទូទៅបន្តិច ប៉ុន្តែការអានអត្ថបទទាំងមូល អ្នកនឹងបានគ្ពក្បរសជាតិនៃអ្វីដែលកំពុងកើតឡើង និងមូលហេតុដែលព្រះយេស៊ូបានឆ្លើយតបតាមរបៀបដែលទ្រង់បានធ្វើ។

*ព្រះយេស៊ូយាងទៅភូមិណាសារ៉ែត ជាភូមិដែលព្រះអង្គគង់នៅកាលពីកុមារ។ នៅថ្ងៃសប្ប័ទ ព្រះអង្គយាងទៅសាលាប្រជុំ*តាមទម្លាប់របស់ព្រះអង្គ។ ព្រះអង្គក្រោកឈរឡើង ដើម្បីអានគម្ពីរ។ គេបានយកគម្ពីររបស់ព្យាការីអេសាយមកថ្វាយព្រះអង្គ ព្រះអង្គបើកគម្ពីរត្រង់អត្ថបទមួយ ដែលមានចែងថា៖*

*«ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតលើខ្ញុំ។ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំឱ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំឱ្យមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឱ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា»។*

*លុះអានចប់ហើយ ព្រះយេស៊ូបិទគម្ពីរ ប្រគល់ទៅអ្នកថែរក្សា រួចព្រះអង្គគង់ចុះវិញ។ មនុស្សគ្រប់ៗរូបនៅក្នុងសាលាប្រជុំសម្លឹងមើលព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្ដាប់អម្បាញ់មិញ បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»។*

*ឮដូច្នេះ គេស្ងើចសរសើរព្រះយេស៊ូគ្រប់ៗគ្នា ទាំងនឹកឆ្ងល់អំពីព្រះបន្ទូលប្រកបដោយព្រះហឫទ័យប្រណីសន្ដោស ដែលហូរចេញពីព្រះឱស្ឋរបស់ព្រះអង្គ។ គេពោលថា៖ «អ្នកនេះមិនមែនជាកូនរបស់ជាងយ៉ូសែបទេឬ?»។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាប្រហែលជាចង់យកសុភាសិតដែលចែងថា "គ្រូពេទ្យអើយ ចូរមើលជំងឺរបស់ខ្លួនឱ្យជាសិនទៅ" មកផ្ចាញ់ផ្ចាលខ្ញុំទេដឹង! ឬមួយអ្នករាល់គ្នាចង់និយាយមកខ្ញុំទៀតថា "យើងឮគេនិយាយអំពីកិច្ចការទាំងអស់ ដែលអ្នកធ្វើនៅក្រុងកាពើណិម ចូរធ្វើការដដែលនៅទីនេះ ជាស្រុកកំណើតរបស់អ្នក ឱ្យយើងឃើញផង!"»។*

*ព្រះអង្គមានព្រះបន្ទូលទៀតថាៈ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា មិនដែលមានព្យាការីណាម្នាក់ត្រូវគេគោរព នៅក្នុងស្រុកកំណើតរបស់ខ្លួនឡើយ។ ខ្ញុំសុំបញ្ជាក់ថា នៅជំនាន់លោកអេលីយ៉ា មេឃរាំងអស់រយៈពេលបីឆ្នាំកន្លះ បណ្តាលឱ្យមានទុរ្ភិក្សយ៉ាងខ្លាំងពេញទាំងស្រុក។ នៅស្រុកអ៊ីស្រាអែល មានស្ត្រីមេម៉ាយជាច្រើន។ ក៏ប៉ុន្តែ ព្រះជាម្ចាស់ពុំបានចាត់ព្យាការីអេលីយ៉ាឱ្យទៅជួយស្ត្រីមេម៉ាយណាម្នាក់ នៅស្រុកអ៊ីស្រាអែលឡើយ គឺព្រះអង្គបានចាត់លោកឱ្យទៅជួយស្ត្រីមេម៉ាយម្នាក់ ដែលរស់នៅភូមិសារិបតា ក្នុងក្រុងស៊ីដូនវិញ។*

—លូកា ៤:១៦-២៦

អត្ថបទនេះកើតឡើងបន្ទាប់ពីព្រះយេស៊ូត្រូវបានល្បួងនៅទីរហោស្ថាន ហើយបន្ទាប់មកត្រលប់ទៅស្រុកកំណើតរបស់ទ្រង់ ជាកន្លែងដែលយើងលើកយករឿងនោះមកសរសេរ។

ដោយសារព្រះយេស៊ូត្រូវបានចិញ្ចឹមបីបាច់នៅភូមិណាសារ៉ែត ពួកគេបានស្គាល់ទ្រង់ និងក្រុមគ្រួសាររបស់ទ្រង់យ៉ាងជិតស្និទ្ធ ហើយយើងអាចសន្មតថាទ្រង់បានអានបទគម្ពីរជាច្រើនដងនៅឯសាលាប្រជុំក្នុងតំបន់។ ឥលូវនេះ មានអ្វីមួយដែលអ្នកត្រូវដឹងអំពីអត្ថបទដែលព្រះយេស៊ូបានជ្រើសរើសដើម្បីអានឱ្យពួកគេស្តាប់។ ទ្រង់បានអានពីព្រះគម្ពីរអេសាយ ៦១:១-២ហើយទ្រង់បានអានដល់កន្លែងមួយដែលចែងថា «***ប្រកាសពីឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា***» ទ្រង់ក៏ឈប់អាន។

ឥលូវនេះ អ្វីដែលគួរឱ្យចាប់អារម្មណ៍អំពីកន្លែងដែលទ្រង់ឈប់អាន គឺនៅកណ្តាលប្រយោគ ដូច្នេះយើងដឹងថាទ្រង់បានឈប់អាននៅកន្លែងនោះដោយមានហេតុផលរបស់ទ្រង់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ឆ្នាំដែលព្រះជាម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណាគឺឆ្នាំមេត្តាករុណា ហើយវាតំណាងឱ្យការស្តារឡើងវិញនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងអាណាចក្រផែនដី។ វាជាស្រមោលនៃអ្វីដែលព្រះមេស្ស៊ីនឹងស្តារឡើងវិញ នៅពេលទ្រង់យាងមក។ ដូច្នេះនៅពេលដែលព្រះយេស៊ូឈប់អាននៅត្រង់ឃ្លានោះ ហើយទ្រង់មានបន្ទូលថា ***«ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្តាប់អម្បាញ់មិញ បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»*** ។ទ្រង់កំពុងតែប្រកាសថាទ្រង់គឺជាព្រះមេស្ស៊ី!

ទ្រង់មានព្រះបន្ទូលបន្ត ហើយបានទាយពីអ្វីដែលពួកគេនឹងនិយាយទៅកាន់ទ្រង់នៅពេលអនាគត ថា «យើងមិនជឿអ្នកទេ ចូរបញ្ជាក់ប្រាប់យើងមក» ដោយសារពួកគេមិនជឿទ្រង់។

> *ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាប្រហែលជាចង់យកសុភាសិតដែលចែងថា "គ្រូពេទ្យអើយ ចូរមើលជំងឺរបស់ខ្លួនឱ្យជាសិនទៅ" មកផ្ចាញ់ផ្ចាលខ្ញុំទេដឹង! ឬមួយអ្នករាល់គ្នាចង់និយាយមកខ្ញុំទៀតថា "យើងឮគេនិយាយអំពីកិច្ចការទាំងអស់ ដែលអ្នកធ្វើនៅក្រុងកាពើណិម ចូរធ្វើការដដែលនៅទីនេះ ជាស្រុកកំណើតរបស់អ្នក ឱ្យយើងឃើញផង!"»។*

ក្រុងកាពើណិមជាកន្លែងដែលព្រះយេស៊ូបានចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់ និងជាកន្លែងដែលការអស្ចារ្យជាច្រើនរបស់ទ្រង់បានកើតឡើង។ ទ្រង់បានទាយប្រាប់ពួកគេថា ពួកគេនឹងឮពីការអស្ចារ្យដែលនឹងកើតឡើងនៅក្រុងកាពើណិម ហើយនៅពេលដែលពួកគេបានឮអំពីរឿងទាំងនេះ ពួកគេនឹងនិយាយថា មកទីនេះ ហើយធ្វើកិច្ចការដូចគ្នានៅទីនេះនៅភូមិណាសារ៉ែត ដើម្បីឱ្យយើងអាចជឿអ្នក។ ការពិតគឺថា ទ្រង់កំពុងកាត់ទោសពួកគេ ដោយពួកគេមានចិត្តរឹង និងមិនជឿទ្រង់។ ទ្រង់ជ្រាបថាពួកគេមិនជឿទ្រង់ ហើយទ្រង់ជ្រាបថាពួកគេនឹងមិនជឿទ្រង់ឡើយ ។ យើងដឹងអំពីការណ៍នោះដោយសារទ្រង់បានមានបន្ទូលបន្ថែមថា ពួកគេក៏នឹងនិយាយថា *«គ្រូពេទ្យអើយ ចូរ*

*មើលជំងឺរបស់ខ្លួនឱ្យជាសិនទៅ»* យោងទៅលើអ្វីដែលនឹងត្រូវបាននិយាយអំពីការឆ្កាងទ្រង់។

*មនុស្សម្នាដើរកាត់តាមនោះ ប្រមាថមើលងាយព្រះអង្គ គ្រវីក្បាលដាក់ព្រះអង្គទាំងពោលថា៖ «អ្នករុះព្រះវិហារ ហើយសង់ឡើងវិញតែបីថ្ងៃអើយ! ចូរសង្គ្រោះខ្លួនឯងទៅ! បើអ្នកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន អញ្ជើញចុះពីឈើឆ្កាងមក!»។ រីឯពួកនាយកបូជាចារ្យ ពួកអាចារ្យ និងពួកព្រឹទ្ធាចារ្យក៏នាំគ្នាចំអកដាក់ព្រះអង្គដូចគេដែរ ដោយពោលថា៖ «គាត់បានសង្គ្រោះអ្នកឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯងទេ! គាត់ជាស្ដេចអ៊ីស្រាអែល ឱ្យគាត់ចុះពីឈើឆ្កាងឥលូវនេះមក ដើម្បីយើងជឿផង!*

—ម៉ាថាយ ២៧:៣៩-៤២

តាំងពីចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់រហូតដល់ចប់ ទ្រង់មានបន្ទូលថា ទោះបីជាពួកគេនឹងឮយ៉ាងណាក៏ដោយ ក៏គេមិនទទួលយកសាររបស់ទ្រង់ដែរ។ បន្ទាប់មក ទ្រង់បានបន្តមានបន្ទូលទៅគេកាន់តែច្បាស់ ដោយប្រាប់ពីដំណើររឿងរបស់លោកអេលីយ៉ា និងស្ត្រីមេម៉ាយ ដែលព្រះជាម្ចាស់ត្រូវបញ្ជូនលោកអេលីយ៉ាទៅក្រៅស្រុកអ៊ីស្រាអែល ដោយសារប្រជាជនអ៊ីស្រាអែលមានចិត្តរឹង និងមិនជឿទ្រង់។ នេះបានធ្វើឱ្យពួកអ្នកច្បាប់ខឹងសម្បារហូតដល់ចាប់យកព្រះយេស៊ូទៅខាងក្រៅ ដើម្បីសម្លាប់ទ្រង់ ប៉ុន្តែព្រះគម្ពីរចែងថា ទ្រង់បានយាងចេញបាត់។

ឥលូវនេះខ្ញុំចង់ឱ្យអ្នកសរសេរពាក្យមួយសម្រាប់ខ្ញុំ ហើយដាក់ពាក្យនោះនៅកន្លែងណាមួយដែលអ្នកអាចចងចាំពាក្យនោះបាន ព្រោះវាជាគន្លឹះចំពោះអនាគតហិរញ្ញវត្ថុរបស់អ្នក។ សូមសរសេរពាក្យថា «បានបញ្ជូន»។ ពាក្យនេះសំខាន់ណាស់!

## <u>បានបញ្ជូន</u>

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំចង់អានព្រះគម្ពីរ ១ពង្សាវតារក្សត្រ ១៧:៧-១៦ ដែលយើងនឹងរកឃើញអាថ៌កំបាំងដ៏មានឥទ្ធិពល ដែលនឹងផ្លាស់ប្ដូរជីវិតរបស់អ្នកទាំងស្រុង។

*បន្តិចក្រោយមក ទឹកជ្រោះក៏រីង ព្រោះគ្មានភ្លៀងធ្លាក់នៅស្រុកនោះទេ។ ពេលនោះ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកអេលីយ៉ាថា៖ «ចូរក្រោកឡើងធ្វើដំណើរទៅសារិបតា ជាក្រុងរបស់ជនជាតិស៊ីដូន ហើយស្នាក់អាស្រ័យនៅទីនោះចុះ យើងនឹងបង្គាប់ឱ្យស្ត្រីមេម៉ាយម្នាក់ផ្គត់ផ្គង់អ្នក»។ លោកក្រោកឡើងធ្វើដំណើរទៅកាន់ក្រុងសារិបតា។ លុះដល់មាត់ទ្វារក្រុង លោកឃើញស្ត្រីមេម៉ាយម្នាក់កំពុងតែរើសអុស។ លោកហៅស្ត្រីនោះមក ហើយនិយាយទៅកាន់នាងថា៖ «សូមទៅយកទឹកឱ្យខ្ញុំទទួលទានបន្តិច!»។ នាងក៏ទៅយកទឹក ប៉ុន្តែលោកស្រែកប្រាប់នាងទៀតថា៖ «សូមយកនំបុ័ងឱ្យខ្ញុំមួយដុំផង!»។ នាងតបថា៖ «នាងខ្ញុំសូមជម្រាបលោក ក្នុងនាមព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ជាព្រះរបស់លោកថា នាងខ្ញុំគ្មាននំបុ័ងទេ នាងខ្ញុំនៅសល់តែម្សៅមួយក្ដាប់ក្នុងខាប់ និងប្រេងបន្តិចនៅក្នុងដបប៉ុណ្ណោះ។ នាងខ្ញុំកំពុងតែរើសអុសពីរអង្កត់នេះយកទៅដុតនំបុ័ង សម្រាប់នាងខ្ញុំ និងកូន ទទួលទាន។ ពេលទទួលទានរួចហើយ យើងខ្ញុំទាំងពីរនាក់ម្ដាយកូននឹងស្លាប់ទាំងអស់គ្នា»។ លោកអេលីយ៉ាមានប្រសាសន៍ទៅកាន់នាងថា៖ «កុំខ្លាចអ្វីឡើយ! សូមចូលទៅធ្វើតាមពាក្យនាងចុះ! តែសូមដុតនំបុ័ងមួយដុំតូចយកមកឱ្យខ្ញុំជាមុនសិន រួចសឹមដុតសម្រាប់នាង និងកូនរបស់នាង ដ្បិតព្រះជាម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា ម្សៅក្នុងខាប់នឹងមិនចេះអស់ទេ ហើយប្រេងនៅក្នុងដបក៏មិនចេះអស់ដែរ រហូតដល់ថ្ងៃព្រះជាម្ចាស់បង្អុរភ្លៀងមកលើផែនដី»។*

*នាងក៏ចេញទៅធ្វើតាមពាក្យដែលលោកអេលីយ៉ាបានប្រាប់។ ពួកគេមានអាហារបរិភោគជាយូរថ្ងៃ ទាំងនាងទាំងកូននាង និងលោកអេលីយ៉ា គឺម្សៅ*

*មិនចេះរលស់ពីខាប់ ប្រេងក៏មិនចេះរលស់ពីដប ស្របតាមព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង តាមរយៈលោកអេលីយ៉ា។*

—១ ពង្សាវតារក្សត្រ ១៧:៧-១៦

សូមអនុញ្ញាតឱ្យខ្ញុំរៀបរាប់ពីដំណើរដើមទង។ មានគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរបានកើតឡើង ហើយទឹកជ្រោះជាកន្លែងដែលអេលីយ៉ាស្នាក់នៅក៏រីងស្ងួត។ ឥលូវនេះគាត់ត្រូវផ្លាស់ទៅកន្លែងថ្មីដើម្បីរកអាហារ និងទឹក។ ព្រះជាម្ចាស់មានបន្ទូលទៅគាត់ ហើយបង្គាប់គាត់ថា ***«ចូរក្រោកឡើងធ្វើដំណើរទៅសារិបតា ជាក្រុងរបស់ជនជាតិស៊ីដូន ហើយស្នាក់អាស្រ័យនៅទីនោះចុះ យើងនឹងបង្គាប់ឱ្យស្ត្រីមេម៉ាយម្នាក់ផ្គត់ផ្គង់អ្នក»។*** គួរកត់សម្គាល់ថា សារិបតាជាក្រុងរបស់ជនជាតិកាណាន ហើយមិនមែនជាផ្នែកនៃប្រទេសអ៊ីស្រាអែលនៅពេលនោះទេ។

នៅពេលដែលលោកអេលីយ៉ាចូលទៅជិតទីក្រុង គាត់ឃើញស្ត្រីមេម៉ាយម្នាក់កំពុងប្រមូលអុស គាត់ស្រែកប្រាប់នាងឱ្យយកទឹកឱ្យគាត់ទទួលទានបន្តិច។ ***«នាងក៏ទៅយកទឹក ប៉ុន្តែ លោកស្រែកប្រាប់នាងទៀតថា៖ «សូមយកនំប៉័ងឱ្យខ្ញុំមួយដុំផង!»។*** នាងឆ្លើយថា នាងអស់អាហារហើយ មានគ្រប់តែមួយពេលទៀតប៉ុណ្ណោះសម្រាប់កូនប្រុសរបស់នាង និងខ្លួននាងផ្ទាល់។

ប៉ុន្តែ នៅពេលនោះព្យាការីបានធ្វើរឿងដ៏ចម្លែកមួយ ជាអ្វីមួយដែលអ្នកប្រហែលជានឹកស្មានមិនដល់ថានឹងកើតឡើង។ គាត់ប្រាប់នាងឱ្យទៅផ្ទះធ្វើនំប៉័ង ហើយយកទៅឱ្យគាត់ទទួលទានមុននឹងធ្វើសម្រាប់គ្រួសាររបស់នាង។ ដោយមិនសួរពីអ្វីដែលគាត់និយាយ គាត់បានបញ្ជាក់ប្រាប់នាងថា *«កុំខ្លាចអី»*។ គាត់ប្រកាសប្រាប់នាងដូចខាងក្រោម៖

*ដ្បិតព្រះជាម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែលមានព្រះបន្ទូលថា «ម្សៅក្នុងខាប់នឹងមិនចេះអស់ទេ ហើយប្រេងនៅក្នុងដបក៏មិនចេះអស់ដែរ រហូតដល់ថ្ងៃព្រះជាម្ចាស់បង្អុរភ្លៀងមកលើផែនដី»។*

វ៉ោ! តើនាងនឹងធ្វើអ្វី? តើនាងនឹងជឿគាត់ និងឱ្យអាហារគាត់បរិភោគដែរឬទេ ដែលគាត់មានតែមួយពេលទៀតប៉ុណ្ណោះសម្រាប់កូនប្រុសរបស់គាត់?

*<u>នាងក៏ចេញទៅធ្វើតាមពាក្យដែលលោកអេលីយ៉ាបានប្រាប់។</u> ពួកគេមានអាហារបរិភោគជាយូរថ្ងៃ ទាំងនាងទាំងកូននាង និងលោកអេលីយ៉ា គឺម្សៅមិនចេះរលស់ពីខាប់ ប្រេងក៏មិនចេះរលស់ពីដប ស្របតាមព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែង តាមរយៈលោកអេលីយ៉ា។*

នាងបានជឿគាត់ ហើយយកចិត្តទុកដាក់ចំពោះលទ្ធផលដែលថាមានអាហារជារៀងរាល់ថ្ងៃសម្រាប់លោកអេលីយ៉ា និងសម្រាប់ស្ត្រីនោះ និងគ្រួសាររបស់នាង។ សូមអនុញ្ញាតឱ្យខ្ញុំផ្លាស់ប្តូរពាក្យមួយហើយនិយាយម្តងទៀតថា «មានអាហារជារៀងរាល់ថ្ងៃសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ និងអាហារសម្រាប់ស្ត្រី និងគ្រួសាររបស់នាង»។

យើងបាននិយាយនៅក្នុងជំពូកចុងក្រោយអំពីការភ័យខ្លាចក្នុងការថ្វាយតង្វាយ ថាវានឹងមិនមានគ្រប់គ្រាន់សម្រាប់តម្រូវការរបស់អ្នកទេ ប្រសិនបើអ្នកបានថ្វាយសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។ ដូចដែលអ្នកបានឃើញ ហើយនឹងឃើញជានិច្ច នោះនឹងមិនកើតឡើងទេ!

ដូច្នេះ ខ្ញុំសូមសួរអ្នកនូវសំណួរមួយថា «តើស្ត្រីមេម៉ាយនោះខាតបង់អ្វីដែរឬទេក្នុងការផ្តល់អាហារចុងក្រោយរបស់នាងទៅឱ្យលោកអេលីយ៉ា?» ទេ នាងមិនខាតបង់អ្វីឡើយ ប៉ុន្តែវាបានជួយសង្គ្រោះជីវិតរបស់នាង។

## តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ?

ឥលូវនេះ មុនពេលយើងពិភាក្សាអំពីពាក្យ បានបញ្ជូន ខ្ញុំចង់សួរសំណួរមួយទៀត។ ហេតុអ្វីបានជាព្យាការីសុំនាងឱ្យធ្វើនំសម្រាប់គាត់ជា*មុន*សិន? មិនមែនធ្វើនំ*ជាមួយនឹង*អាហាររបស់នាងទេ ប៉ុន្តែធ្វើ*ផ្សេងពីគ្នា*។ គាត់ថែមទាំងបានសុំឱ្យនាងយកនំមកឱ្យគាត់*មុនពេល*នាងចាប់ផ្តើមធ្វើនំសម្រាប់ខ្លួនឯង។ (សូមចងចាំថា ប្រសិនអ្នកចង់ក្លាយជាអ្នកវិទ្យាសាស្រ្តខាងវិញ្ញាណម្នាក់ អ្នកត្រូវចោទជាសំណួរ។)

រឿងទាំងអស់នេះបង្ហាញអ្នកនូវការយល់ដឹងសំខាន់ៗអំពីក្រឹត្យវិន័យ និងប្រតិបត្តិការរបស់ព្រះរាជ្យនៃព្រះជាម្ចាស់។ តើលោកអេលីយ៉ាឃ្លានខ្លាំងដល់ម្ល៉េះបានជាគាត់មិនចង់រង់ចាំពេលនាងធ្វើម្ហូបសម្រាប់គ្រួសារទាំងមូលឬ? ទេ មានហេតុផលសំខាន់ណាស់ដែលគាត់ធ្វើដូច្នេះ។ ព្យាការីបានដឹងថា នៅពេលដែលនាងបានឱ្យនំដំបូងជូនគាត់ មុនពេលដែលនាងធ្វើសម្រាប់ខ្លួនឯង នោះសកម្មភាពរបស់នាងបាននាំម្សៅ និងប្រេងទាំងអស់របស់នាងមកដាក់នៅក្រោមការគ្រប់គ្រងដោយស្របច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ និងកិច្ចការរបស់ទ្រង់។ ខ្ញុំសូមនិយាយម្តងទៀត។

នៅពេលដែលនាងឱ្យព្យាការី (កិច្ចការរបស់ព្រះជាម្ចាស់) នូវនំដំបូងរបស់នាង ប្រេង និងម្សៅរបស់នាងបានផ្លាស់ប្តូរព្រះរាជ្យរបស់ព្រះជាម្ចាស់។ ឥលូវនេះ ពួកគេបានចូលមកក្រោមការគ្រប់គ្រងនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ មានតែពេលនោះទេ ដែលព្រះជាម្ចាស់អាចធ្វើឱ្យម្សៅ និងប្រេងកើនឡើងដោយស្របច្បាប់។

អ្នកនឹងឃើញគោលការណ៍ដូចគ្នានេះដំណើរការនៅពេលក្រោយក្នុងព័ន្ធកិច្ចរបស់ព្រះយេស៊ូ នៅពេលទ្រង់ប្រទានអាហារដល់មនុស្ស ៥.០០០ នាក់ជាមួយនឹងនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ។

ប្រសិនបើអ្នកនៅចាំរឿងនោះ ព្រះយេស៊ូមានបន្ទូលប្រាប់ពួកសិស្សឱ្យទៅមើលអ្វីដែលពួកគេមាន។ ពួកគេត្រលប់មកវិញ ហើយនិយាយថា ពួកគេមាននំប៉័ងតែប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ។ ព្រះយេស៊ូបានប្រាប់សិស្សរបស់ទ្រង់ឱ្យយកនំប៉័ង និង

ត្រីមកឱ្យទ្រង់។ ព្រះគម្ពីរបានកត់ត្រាថា ទ្រង់បានយកនំបុ័ង និងត្រី ហើយប្រទានពរ បន្ទាប់មកបានប្រគល់ឱ្យសិស្សវិញ។ ខ្ញុំដឹងថាព្រះយេស៊ូមិនបានធ្វើអ្វីខាងសាសនាទេ ដូច្នេះហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ?

ទ្រង់ត្រូវធ្វើដូច្នេះ បើមិនដូច្នេះទេនំបុ័ង និងត្រីមិនមានគ្រប់គ្រាន់ឡើយ។ អ្នកឃើញទេ នំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយ ស្ថិតនៅក្រោមការគ្រប់គ្រងដោយស្របច្បាប់របស់មនុស្សនៅពេលនោះ។ ព្រះជាម្ចាស់មិនអាចធ្វើអ្វីដោយស្របច្បាប់ជាមួយនឹងនំបុ័ង និងត្រីទាំងនោះទេ។ ប៉ុន្តែនៅពេលដែលសិស្សយកនំបុ័ង និងត្រីទាំងនោះមកថ្វាយទ្រង់ ហើយទ្រង់បានប្រទានពរ នោះនំបុ័ង និងត្រីទាំងនោះមកស្ថិតនៅក្រោមការគ្រប់គ្រងដោយស្របច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ មានតែពេលនោះប៉ុណ្ណោះដែលនំបុ័ង និងត្រីមានចំនួនកើនឡើងដ៏ច្រើន។

យើងអាចមើលគោលការណ៍ដូចគ្នានេះ នៅក្នុងលូកាជំពូកទី៥ ដែលលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហានបាននេសាទពេញមួយយប់ តែមិនបានត្រីសោះ។ ដោយខ្ចីទូករបស់លោកពេត្រុស ព្រះយេស៊ូបានចេញពីច្រាំងបន្តិច និងបង្រៀនដល់ហ្វូងមនុស្ស បន្ទាប់មកទ្រង់ប្រាប់លោកពេត្រុសឱ្យទម្លាក់អួនទៅក្នុងទឹកជ្រៅ ដើម្បីចាប់ត្រី។

ដូចដែលអ្នកដឹងហើយថា ពួកគេបានចាប់ត្រីពេញទូកចំនួនពីរ ហើយទូកចាប់ផ្ដើមលិច។ ពេលដែលព្រះយេស៊ូខ្ចីទូករបស់ពួកគេ ទ្រង់ក៏បានខ្ចីមុខរបរនេសាទពីពួកគេ ដើម្បីបង្រៀនមនុស្សនៅថ្ងៃនោះ។ នៅពេលដែលទ្រង់បានកាន់កាប់ទូក និងមុខរបរនេសាទរបស់ពួកគេ មុខរបរទាំងមូលបានស្ថិតនៅក្រោមការគ្រប់គ្រងដោយស្របច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ នេះបានធ្វើឱ្យស្ថានសួគ៌បានប្រាប់ទៅព្រះយេស៊ូឱ្យដឹងដោយស្របច្បាប់អំពីកន្លែងដែលមានត្រី ដែលទ្រង់អាចចាប់បានត្រីក្នុងចំនួនដ៏ច្រើន។ (ខ្ញុំតែងតែនិយាយថា អ្នកណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើព្រះយេស៊ូប្រាប់

ពួកគេថាត្រីនៅកន្លែងណា និងរបៀបចាប់ត្រី។ នេះគឺជាគោលការណ៍ដូចគ្នាដែលអ្នកនឹងប្រើដែរ នៅពេលដែលអ្នកថ្វាយសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។)

ឥលូវនេះ យើងត្រលប់ទៅមើលរឿងអំពីលោកអេលីយ៉ាវិញ ស្ត្រីមេម៉ាយម្នាក់នេះពិតជាបានសហការជាមួយលោកអេលីយ៉ា និងកិច្ចការរបស់គាត់ ដូច្នេះនាងទទួលបានរង្វាន់ដូចគ្នានឹងលោកអេលីយ៉ាដែរ។ ពេលនោះ មានការផ្គត់ផ្គង់ដល់លោកអេលីយ៉ា និងស្ត្រីមេម៉ាយ និងគ្រួសាររបស់នាង។ តើអ្នកឃើញទេ?

ខ្ញុំនឹងនិយាយបន្ថែមអំពីគោលការណ៍នេះនៅក្នុងសៀវភៅនេះ ដូចខាងក្រោម ប៉ុន្តែ ខ្ញុំចង់បន្តនិយាយអំពីគន្លឹះសំខាន់ៗនៅក្នុងរឿងនេះ គឺពាក្យ បានបញ្ជូន។

តោះ! ទៅមើលទាំងអស់គ្នា។ ព្រះជាម្ចាស់បានបង្គាប់ឱ្យលោកអេលីយ៉ាធ្វើកិច្ចការរបស់ទ្រង់។ លោកអេលីយ៉ាត្រូវការការផ្គត់ផ្គង់ដើម្បីបំពេញកិច្ចការរបស់ទ្រង់។ យើងដឹងថាលោកអេលីយ៉ាជាព្យាការី ដូច្នេះគាត់បានស្តាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅគ្រប់ទីកន្លែងដែលព្រះចាត់ឱ្យគាត់ទៅ។ ប៉ុន្តែព្រះជាម្ចាស់ត្រូវការឱ្យមានការផ្តល់ថវិកាសម្រាប់កិច្ចការរបស់ទ្រង់ ហើយនោះតែងតែពាក់ព័ន្ធនឹង*មនុស្ស*។

ក្នុងករណីនេះ ព្រះជាម្ចាស់មិនអាចរកឃើញស្ត្រីមេម៉ាយនៅប្រទេសអ៊ីស្រាអែលដែលមានជំនឿស្តាប់បង្គាប់ទ្រង់ឡើយ។ ព្រះអង្គជ្រាបពីអ្វីដែលទ្រង់ចង់ធ្វើ ប៉ុន្តែទ្រង់ត្រូវការនរណាម្នាក់ឱ្យចុះចូលនឹងនគរស្ថានសួគ៌ ដើម្បីឱ្យទ្រង់ផ្គត់ផ្គង់លោកអេលីយ៉ានូវអ្វីដែលគាត់ត្រូវការតាមក្រឹត្យវិន័យ។

ចាំទេ! មិនមានអាហារនៅគ្រប់កន្លែង។ មានមនុស្សស្លាប់គ្រប់កន្លែង។ វាមិនមែនជាបញ្ហាក្នុងការរកម្ហូបអាហារ ឬទៅផ្សារនោះទេ ព្រោះមិនមានអាហារ។ ការផ្គត់ផ្គង់លោកអេលីយ៉ាត្រូវផ្គត់ផ្គង់ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។

**បង្វិលត្រូវហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ដោយសារមិនមាននរណាម្នាក់ក្នុងប្រទេសអ៊ីស្រាអែលដែលមានជំនឿលើទ្រង់ នោះព្រះជាម្ចាស់ត្រូវចេញទៅក្រៅប្រទេសអ៊ីស្រាអែលទៅកាន់ប្រទេសផ្សេងទៀតដែលទ្រង់បានរកឃើញស្ត្រីមេម៉ាយដែលមានចិត្តជឿលើទ្រង់។ ហើយដូចដែលយើងបាននិយាយមុននេះ លោកអេលីយ៉ាត្រូវបានចាត់ឱ្យទៅកាន់ស្ត្រីមេម៉ាយនេះ ដោយសារព្រះជាម្ចាស់ដឹងថានាងនឹងជឿទ្រង់។

ដោយសារតែនាងបានដាក់ព្រះជាម្ចាស់ជាទីមួយ ហើយគោរពតាមព្រះបន្ទូលរបស់ទ្រង់ ព្រះបានផ្គត់ផ្គង់កិច្ចការរបស់ទ្រង់ និងលោកអេលីយ៉ា ក៏ដូចជាគ្រួសាររបស់នាងនៅក្នុងអំឡុងពេលមានទុរ្ភិក្ស។

ដូច្នេះ នេះជាចំណុចសំខាន់នៃផ្ទៃរឿង...

នៅពេលដែលព្រះជាម្ចាស់ឱ្យគេធ្វើកិច្ចការរបស់ទ្រង់ ទ្រង់ទតមើលមកផែនដីដើម្បីស្វែងរកនរណាម្នាក់ដែលទ្រង់អាចទុកចិត្តបាន នរណាម្នាក់ដែលនឹងស្តាប់បង្គាប់ទ្រង់ និងអនុវត្តតាមផែនការរបស់ទ្រង់។ ទ្រង់ក៏ត្រូវការមនុស្សដែលនឹងផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់កិច្ចការរបស់ទ្រង់ផងដែរ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ឱ្យច្បាស់៖ ប្រសិនបើអ្នកចង់មានចំណេះដឹងជ្រៅជះ ប្រសិនបើអ្នកចង់ឱ្យព្រះជាម្ចាស់បង្ហាញផ្លូវអ្នកនូវកិច្ចការដ៏អស្ចារ្យ អ្នកត្រូវតែមានលក្ខណៈគ្រប់គ្រាន់សម្រាប់កិច្ចការទាំងនោះ! ព្រះអង្គជ្រាបពីចិត្តគំនិតរបស់អ្នក ហើយទ្រង់កំពុងទតមកផែនដី រកមើលអ្នកដែលទ្រង់អាចទុកចិត្តបានចំពោះកិច្ចការរបស់ទ្រង់។ ទ្រង់កំពុងរកមើលអ្នកណាដែលទ្រង់អាចទុកចិត្តបាន ដើម្បីផ្គត់ផ្គង់កិច្ចការរបស់ទ្រង់។ បន្ទាប់មក ទ្រង់នឹងចាត់ម្នាក់នោះតាមផែនការរបស់ទ្រង់សម្រាប់ប្រមូលប្រាក់ដែលត្រូវការ។ តើអ្នកឃើញទេ?

ចាំទេ! ព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានបញ្ជូនទៅកាន់ស្ត្រីមេម៉ាយម្នាក់នេះ ហើយព្រះបន្ទូលបានសង្គ្រោះជីវិតរបស់នាង!

## តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ?

ខ្ញុំចាំថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទ្រង់មានបន្ទូលមកខ្ញុំឱ្យចេញទៅធ្វើកិច្ចការរបស់ខ្ញុំ ជាមួយនឹងអាទិភាព និងការចាត់តាំងថ្មី។ ខ្ញុំបានធ្វើតាមទ្រង់ ហើយបានសង្គ្រោះជីវិតខ្ញុំ។

ព្រះជាម្ចាស់ស្វែងរកអ្នកដែលមានចិត្តស្តាប់បង្គាប់ទ្រង់ ដើម្បីផ្តល់មូលនិធិដល់កិច្ចការរបស់ទ្រង់!

សូមពិនិត្យមើលគោលការណ៍ដែលយើងឃើញនៅក្នុងរឿងនេះ។

១. ព្រះជាម្ចាស់មានភារកិច្ចនៅក្នុងអាណាចក្រផែនដី ដែលទ្រង់ចង់សម្រេច។

២. រាល់កិច្ចការទាំងអស់ត្រូវការមនុស្ស។

៣. រាល់កិច្ចការទាំងអស់ត្រូវការការផ្តល់ថវិកា។

៤. ព្រះជាម្ចាស់កំពុងទតមកផែនដីដើម្បីស្វែងរកមនុស្សដែលនឹងបំពេញកិច្ចការរបស់ទ្រង់។

៥. ហើយព្រះជាម្ចាស់កំពុងទតមើលមកផែនដី ស្វែងរកអ្នកដែលនឹងផ្តល់មូលនិធិសម្រាប់កិច្ចការរបស់ទ្រង់។

៦. នៅពេលដែលយើងផ្តល់ថវិកាដល់កិច្ចការរបស់ព្រះ នោះយើងកំពុងផ្តល់ការគ្រប់គ្រងដោយស្របច្បាប់ដល់នគរស្ថានសួគ៌ ទ្រង់មិនត្រឹមតែប្រើប្រាស់យើងដើម្បីផ្តល់ថវិកាដល់កិច្ចការរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ទ្រង់ក៏ផ្តល់ថវិកាដ៏ហូរហៀរដល់ជីវិតរបស់យើងផងដែរ។

អ្នកមិនចាំបាច់ចំណាយអ្វីឡើយដើម្បីឱ្យមានចិត្តសប្បុរស! ខ្ញុំប្រាប់ក្រុមជំនុំរបស់ខ្ញុំថា «តែងតែនិយាយថា បាទ/ចាស ជានិច្ច»។

# ជំពូក ៩
# តើជាប្រាក់របស់នរណា?

តើអ្នកធ្លាប់យល់ថាប្រាក់មួយចំនួនដែលអ្នកមានឥលូវនេះ មិនមែនជាប្រាក់របស់អ្នកទេ?

ខ្ញុំដឹងថា ស្តាប់ទៅដូចជាប្លែកបន្តិច ប៉ុន្តែតើអ្នកធ្លាប់ដឹងទេថា ព្រះប្រហែលជាដាក់ប្រាក់នោះក្នុងដៃរបស់អ្នកដើម្បីយកទៅឱ្យអ្នកផ្សេង?

ខ្ញុំដឹងថាអ្នកប្រហែលជាមិនបានគិតអំពីជីវិតពីទស្សនៈនោះទេ ប៉ុន្តែអ្នកគួរតែគិតបែបនោះ ព្រោះវាជាគន្លឹះមួយទៀតដើម្បីធ្វើឱ្យជីវិតរបស់អ្នករីកចម្រើន។

សូមគិតអំពីអ្វីដែលខ្ញុំកំពុងនិយាយ។ យើងបាននិយាយអំពីការផ្តល់ថវិកាសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់ មែនទេ? ហើយយើងបាននិយាយថា ព្រះជាម្ចាស់កំពុងទតមកផែនដី ដើម្បីស្វែងរកមនុស្សដែលមានដួងចិត្តចំពោះព្រះរាជ្យនៃព្រះ ហើយនឹងផ្តល់ថវិកាដល់កិច្ចការរបស់ទ្រង់។ យើងដឹងថាប្រាក់គឺនៅក្នុងដៃរបស់មនុស្ស ហើយប្រសិនបើព្រះជាម្ចាស់នឹងផ្តល់ថវិកាដល់កិច្ចការរបស់ទ្រង់ នោះទ្រង់ត្រូវតែយកប្រាក់ទៅដាក់ក្នុងដៃរបស់មនុស្សដែលសុខចិត្តលះបង់ប្រាក់នោះ ហើយមានចិត្តសប្បុរសចំពោះទ្រង់ និងប្រជារាស្ត្ររបស់ទ្រង់។

ដូច្នេះ តើមានអ្វីនៅក្នុងដៃរបស់អ្នក? ពេលដែលសម្លឹងមើលអ្វីដែលអ្នកមាន តើអ្នកដឹងទេថាប្រហែលជាព្រះជាម្ចាស់ដាក់របស់នោះនៅក្នុងដៃរបស់អ្នកសម្រាប់អ្នក

ផ្សេង? ឬថាទ្រង់ប្រហែលជាយកមកឱ្យអ្នក ដើម្បីផ្តល់ថវិកាដល់គម្រោងដែលទ្រង់ចង់សម្រេច?

ជាការពិតណាស់ តាមផ្លូវច្បាប់ អ្វីដែលអ្នកមានគឺជារបស់អ្នក និងជាសិទ្ធិរបស់អ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ធ្វើអ្វីជាមួយនឹងរបស់នោះ។ ប៉ុន្តែប្រសិនបើព្រះជាម្ចាស់នឹងដាក់ប្រាក់នៅក្នុងដៃរបស់ម្នាក់ ខ្ញុំចង់នៅក្នុងបញ្ជីដែលទ្រង់បានអនុម័ត ។ ចុះអ្នកវិញ?

> *ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» ព្រះអង្គក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្ដីសុចរិតរបស់បងប្អូនបង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ជំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ ដោយយើងជួយគេ។*
>
> —២ កូរិនថូស ៩:១០-១១

យើងបានមើលអត្ថបទនេះរួចហើយ ប៉ុន្តែប្រហែលជាមានអ្វីមួយដែលអ្នកមិនបានចាប់អារម្មណ៍។ ខ១០ ចែងថា ព្រះជាម្ចាស់*ផ្គត់ផ្គង់*គ្រាប់ពូជដល់អ្នកសាបព្រោះ និងអាហារសម្រាប់បរិភោគ។

សូមគិតអំពីអ្វីដែលកំពុងនិយាយ៖ ព្រះជាម្ចាស់ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងអាហារសម្រាប់បរិភោគ។ អាហារសម្រាប់បរិភោគតំណាងឱ្យអ្វីៗទាំងអស់ដែលអ្នកត្រូវការនៅក្នុងគ្រួសាររបស់អ្នក ដើម្បីរស់នៅក្នុងជីវិតពេញបរិបូរដែលព្រះជាម្ចាស់ប្រទានដល់អ្នក។ ប៉ុន្តែ ទ្រង់ប្រទាន*គ្រាប់ពូជដល់អ្នកសាបព្រោះ*។

តើអ្នកធ្លាប់សាបព្រោះគ្រាប់ពូជក្នុងសួនច្បារ ឬសាបព្រោះគ្រាប់ស្មៅក្នុងទីធ្លារបស់អ្នកដែរឬទេ? អ្នកចាប់ផ្ដើមដាក់គ្រាប់ពូជទៅក្នុងដី ហើយពេលដែលអ្នកកំពុងសាបព្រោះ នោះអ្នកបន្ដយកគ្រាប់ពូជមួយក្ដាប់ទៀត ខណៈពេលដែលអ្នកកំពុងសាបព្រោះគ្រាប់ពូជដែលមានក្នុងដៃស្រាប់។ មានលំហូរយ៉ាងជាក់លាក់អំពីការសាបព្រោះនេះ។ ខណៈពេលដែលកំពុងសាបព្រោះគ្រាប់ពូជដែលមានក្នុងដៃរបស់អ្នក ដៃរបស់អ្នកក៏ពេញដោយគ្រាប់ពូជថ្មីៗ ដែលអ្នកក៏នឹងសាបព្រោះផងដែរ។ ឃ្លានេះ *ព្រះជាម្ចាស់ទ្រង់ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ* មានអត្ថន័យដូចគ្នា មានន័យថា ព្រះជាម្ចាស់ប្រទានគ្រាប់ពូជដល់អ្នកដែលកំពុងសាបព្រោះ។

## ព្រះជាម្ចាស់ប្រទានគ្រាប់ពូជដល់អ្នកដែលកំពុងសាបព្រោះ

សាវ័កប៉ូលបន្ដនិយាយថា ព្រះជាម្ចាស់ក៏ប្រទានឱ្យយើងនូវនំប៉័ងដែលយើងត្រូវការដែរ ប៉ុន្ដែខ្លឹមសារនៅក្នុងអត្ថបទគម្ពីរនេះគឺនិយាយអំពីការសាបព្រោះ និងឥទ្ធិពលនៃអត្ថបទគម្ពីរនេះមកលើជីវិតរបស់យើង ព្រមទាំងលើអ្នកដែលយើងមានចិត្តសប្បុរសជាមួយ។ ដូចដែលយើងបាននិយាយរួចហើយថា ខគម្ពីរនេះទាញដួងចិត្តមនុស្សឱ្យទៅរកព្រះជាម្ចាស់។

ដោយចងចាំពីសេចក្ដីនេះ ខ្ញុំគិតថាយើងទាំងអស់គ្នាអាចយល់ស្របថា ព្រះជាម្ចាស់សព្វព្រះហឫទ័យសាបព្រោះគ្រាប់ពូជឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ដើម្បីឱ្យទ្រង់អាចប្រមូលកាត់បានផលដ៏ច្រើន។ ដូច្នេះបើអ្នកជាព្រះជាម្ចាស់ តើអ្នកនឹងផ្ដល់គ្រាប់ពូជដល់អ្នកណា? ម្នាក់ដែលខ្ជិល និងមិនដែលចេញទៅសាបព្រោះ ឬម្នាក់ដែលកំពុងសាបព្រោះយ៉ាងសកម្ម? ខ្ញុំគិតថាអ្នកដឹងចម្លើយយ៉ាងច្បាស់ហើយ។

នៅពេលដែលយើងស្មោះត្រង់នឹងអ្វីដែលយើងមាន នោះព្រះជាម្ចាស់មានបន្ទូលថាទ្រង់នឹងបង្កើនឃ្លាំងគ្រាប់ពូជរបស់យើង ដើម្បីយើងអាចសាបព្រោះបានកាន់តែច្រើន និងមានឥទ្ធិពលកាន់តែខ្លាំងនៅលើផែនដីនេះសម្រាប់ព្រះរាជ្យទ្រង់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

តើអ្នកបានកត់សម្គាល់ទេថា សាវ័កប៉ូលបាននិយាយថា ពេលអ្នកកំពុងសាបព្រោះ និងច្រូតកាត់ ឃ្លាំងគ្រាប់ពូជរបស់អ្នកនឹងកើនឡើង ដែលអាចឱ្យអ្នកមានចិត្តសប្បុរសនៅគ្រប់កាលៈទេសៈ? ប្រសិនបើនេះជាការពិត នោះឃ្លាំងគ្រាប់ពូជរបស់អ្នកគឺជាប្រាក់ដែលអ្នកកំពុងកាន់ឥលូវនេះសម្រាប់ឱកាសនោះដើម្បីបង្ហាញភាពសប្បុរស។ អ្នកត្រូវមានឃ្លាំងគ្រាប់ពូជ មុនពេលអ្នកអាចមានចិត្តសប្បុរស។

ជាថ្មីម្តងទៀត តាមគំនិតរបស់ខ្ញុំគឺថា ប្រាក់ដែលអ្នកកំពុងកាន់មិនមែនជារបស់អ្នកទាំងអស់នោះទេ។ ប្រាក់មួយចំនួន ព្រះជាម្ចាស់បានប្រទានមកអ្នក ដើម្បីធ្វើជាគ្រាប់ពូជ។ វដ្តនៃការសាបព្រោះ និងការច្រូតកាត់នេះគឺជាលំហូរមួយ។ យើងសាបព្រោះ បន្ទាប់មកយើងច្រូតកាត់។ ហើយនៅពេលដែលយើងបន្តធ្វើដូច្នេះ ដរាបណាយើងមិនបរិភោគគ្រាប់ពូជរបស់យើង ចម្រូតរបស់យើងនឹងបន្តកើនឡើង ហើយយើងមានចិត្តសប្បុរសកាន់តែច្រើនឡើង។

ជាការពិតណាស់ នៅពេលអ្នកឃ្លាន និងត្រូវការអាហារ អ្នកក៏ទាញយកពីអាជីវកម្មគ្រាប់ពូជនូវអ្វីដែលអ្នកត្រូវការ។ នៅពេលដែលអាជីវកម្មគ្រាប់ពូជរបស់អ្នកកើនឡើង សមត្ថភាពរបស់អ្នកក្នុងការយកនំប៉័ងពីគ្រាប់ពូជនោះក៏កើនឡើងដែរ។

ប៉ុន្តែ ខ្ញុំចង់និយាយឱ្យស៊ីជម្រៅបន្តិចអំពីផ្នត់គំនិតនេះ។

ខ្ញុំសូមលើកយកចំណុចដែលព្រះជាម្ចាស់ប្រទានគ្រាប់ពូជរបស់ទ្រង់ដល់អ្នកដែលមានចិត្តចង់សាបព្រោះ មិនមែនដល់អ្នកដែលនឹងពិចារណាសាបព្រោះនៅថ្ងៃណាមួយ។ ទ្រង់ប្រទានដល់អ្នកសាបព្រោះ។

ដូច្នេះ នេះជាសំណួរ៖ តើអ្នកចង់រស់នៅដោយគ្រាន់តែគ្រប់គ្រងប្រាក់*របស់អ្នក* ឬតើអ្នកចង់រស់នៅក្នុងជីវិតដែលគ្រប់គ្រងប្រាក់របស់អ្នក និងប្រាក់របស់ព្រះជាម្ចាស់?

យ៉ាកុប និងអេលឡា បានមកក្រុមជំនុំរបស់យើង ដោយសារពួកគេបានឮរឿងដែលពួកគេមិនធ្លាប់ឮនៅក្នុងសហគមន៍អាមីស ជាកន្លែងដែលពួកគេទាំងពីរធំធាត់ឡើង។

**តើអ្នកចង់រស់នៅដោយគ្រាន់តែគ្រប់គ្រងប្រាក់របស់អ្នក ឬគ្រប់គ្រងប្រាក់របស់អ្នក និងប្រាក់របស់ព្រះជាម្ចាស់?**

គោលគំនិតអំពីព្រះរាជ្យនៃព្រះគឺថ្មីសម្រាប់ពួកគេ ហើយពួកគេគឺជាសិស្សដ៏អស្ចារ្យនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពួកគេយកចិត្តទុកដាក់ស្តាប់សារដែលយើងបានបង្រៀនអំពីការរស់នៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់នៅក្រុមជំនុំ Faith Life Church។

ថ្ងៃមួយ យ៉ាកុបបានប្រាប់ព្រះជាម្ចាស់ថា គាត់បានឮរឿងទាំងអស់នេះពីអ្នកដទៃអំពីរបៀបដែលព្រះរាជ្យនៃព្រះជាម្ចាស់បានធ្វើរឿងដ៏អស្ចារ្យនៅក្នុងជីវិតរបស់ពួកគេ ហើយគាត់ចង់មានទីបន្ទាល់ដូចគ្នា។ គាត់បានសម្រេចចិត្តថាគាត់នឹងសាកល្បងច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលគាត់បានឮ។ ពួកគេកំពុងឈប់សម្រាក ហើយបានចំណាយពេលច្រើនស្តាប់សារដែលទាក់ទងនឹងចំណែកទ្វេគុណ ដែលខ្ញុំបានបង្រៀននៅពេលនោះ។ សៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា *បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃការសម្រាក* ទើបតែចេញផ្សាយ ហើយខ្ញុំបានបង្រៀនពីសៀវភៅនោះ។ ដូច្នេះ ពួកគេបានសម្រេចចិត្តថា ពួកគេគ្រាន់តែយល់ដឹងជ្រៅជ្រះអំពីព្រះបន្ទូល មុនពេលដែលពួកគេសាបព្រោះគ្រាប់ពូជណាមួយ។

ពួកគេសម្រេចចិត្តថានឹងសាបព្រោះចំពោះចម្រូតដែលមានតម្លៃ១០.០០០ ដុល្លារ ដែលពួកគេត្រូវការសម្រាប់ការជួសជុលមួយចំនួន និងតម្រូវការផ្សេងទៀតដែលគ្រួសារទាំងអស់ដែលមានកូនតូចៗ។ ពួកគេមិនដឹងថាប្រាក់នោះបានមកពីណា

ទេ ប៉ុន្តែពួកគេបានសិក្សាអំពីព្រះរាជ្យនៃព្រះជាម្ចាស់យូរល្មមនៅពេលនោះ ទើបពួកគេមានអារម្មណ៍ថាពួកគេមានជំនឿលើព្រះរាជ្យនៃព្រះជាម្ចាស់។

នៅពេលនោះ យ៉ាកុបជាម្ចាស់អាជីវកម្មជួសជុលរថយន្តផ្ទាល់ខ្លួនរបស់គាត់។ នៅពេលគាត់ចេញទៅធ្វើការ មិនយូរប៉ុន្មានបន្ទាប់ពីពួកគេបានសាបព្រោះទឹកប្រាក់ក្នុងតម្លៃ ១០.០០០ដុល្លារ នោះគាត់បានសារភាពប្រាប់អេលឡាថាបន្ទាប់ពីសិក្សាអំពីចំណែកទ្វេគុណ គាត់ពិតជាមានអារម្មណ៍ថាពួកគេគួរតែជឿជាក់សម្រាប់ចំណែកទ្វេគុណលើគ្រាប់ពូជរបស់ពួកគេ។ គាត់បាននិយាយថា គាត់ជឿថានឹងទទួលបានប្រាក់ចំនួន២០.០០០ដុល្លារមកវិញ។ អេលឡាបាននិយាយថា នាងមានការតក់ស្លុតបន្តិច ប៉ុន្តែនាងបានទៅជាមួយប្តីរបស់នាង។ ខណៈគាត់កំពុងដើរចេញតាមទ្វារ នាងបាននិយាយថា «ហ្នឹងហើយ ២០.០០០ដុល្លារ»។

ថ្ងៃមួយ នៅហាង ម៉ូយម្នាក់របស់យ៉ាកុប បានចូលមកសុំឱ្យមានការជួសជុល ហើយនៅពេលដែលគាត់សរសេរការបញ្ជាទិញរួច អតិថិជនរបស់គាត់បានអង្គុយនៅក្នុងការិយាល័យរបស់យ៉ាកុប ហើយប្រាប់គាត់ថា ថ្មីៗនេះគាត់មួរម៉ៅនឹងគោរបស់គាត់យ៉ាងខ្លាំង។ ជាក់ស្តែង គោរបស់គាត់បានបុកបំបាក់របងទាំងអស់របស់គាត់ ហើយបានផ្លោះចេញទៅក្រៅ។ ដីរបស់គាត់មានព្រំប្រទល់ជាប់នឹងព្រៃឈើជាតិ ដូច្នេះសត្វគោទាំងនេះដើរពាសវាលពាសកាល។ អតិថិជនរបស់យ៉ាកុប គឺជាបុរសចំណាស់ម្នាក់ដែលក្រោយមកបាននិយាយថា គាត់ចាស់ណាស់ហើយមិនអាចតាមដេញគោទាំងនោះបានឡើយ ហើយគាត់ក៏ឆ្អែតចិត្តនឹងគោទាំងនោះដែរ។ ពាក្យបន្ទាប់របស់គាត់បានធ្វើឱ្យយ៉ាកុបភ្ញាក់ផ្អើលរហូតដល់គាត់ត្រូវសួរខ្លួនឯងថា តើមិត្តភក្តិរបស់គាត់កំពុងតែនិយាយមកគាត់ឬ?

មិត្តរបស់គាត់បាននិយាយថា «ខ្ញុំអស់និស្ស័យជាមួយគោទាំងនេះហើយ ដូច្នេះហើយបានជាខ្ញុំយកគោទាំងអស់នេះមកឱ្យអ្នកនៅថ្ងៃនេះ។ ចាប់ពីថ្ងៃនេះតទៅ

គោទាំងនេះជារបស់អ្នក»។ យ៉ាកុបមិនដឹងថាត្រូវនិយាយយ៉ាងណាឡើយ។ គាត់មិនមានដី។ គាត់រស់នៅជាយក្រុង ហើយគាត់ជាជាងជួសជុលរថយន្ត។ មែនហើយ គាត់ធំធាត់នៅក្នុងអម្បូរអាមីស ហើយតាំងពីកើតមក គាត់នៅជាមួយនឹងសត្វគោ ប៉ុន្តែនោះមានរយៈពេលច្រើនឆ្នាំមុន។ គាត់ហៀបនឹងនិយាយថាទេ អរគុណពេលគាត់នឹកឃើញពូជពង្សរបស់ពួកគេ។ ប្រហែលជាមានអ្វីមួយនៅទីនេះដែលគាត់ត្រូវពិនិត្យ។

បន្ទាប់ពីសាកសួរមិត្តភក្តិរបស់គាត់បន្ថែមទៀត គាត់បានរកឃើញថា មានគោប្រភេទ Black Angus ចំនួន ២៣ ក្បាល និងសេះ ៣ ក្បាលនៅក្នុងកិច្ចព្រមព្រៀងនេះ។ យ៉ាកុបនឹកឃើញថា ធ្លាប់មានគេនិយាយប្រាប់គាត់ថា ពួកគេកំពុងរកទិញហ្វូងគោ។ ពួកគេមិនចង់ទិញតែម្តងពីរបីក្បាលនោះទេ ប៉ុន្តែចាប់អារម្មណ៍ទិញយកទាំងហ្វូង។ យ៉ាកុបបានទូរសព្ទទៅគេ ហើយបុរសនោះបាននិយាយថា គាត់ចាប់អារម្មណ៍។ ពេលនោះ យ៉ាកុបបានសួរគាត់ថា តើគាត់ចង់ឱ្យតម្លៃទិញគោក្នុងតម្លៃប៉ុន្មាន? ហើយបុរសនោះគិតមួយភ្លែត រួចនិយាយថា «អូ! ប្រហែលជា ២០.០០០ដុល្លារ»។

យ៉ាកុបមិនជឿនូវអ្វីដែលគាត់បានឮ។ រឿងនេះបានកើតឡើងបន្ទាប់ពីគាត់បានចាកចេញពីផ្ទះនៅថ្ងៃនោះ ហើយបានប្រាប់អេលឡាអំពីចំណែកទ្វេគុណពីព្រះវិញ្ញាណដ៏វិសុទ្ធ។ គាត់ប្រាប់ខ្ញុំថា វាពិតជាការងារមួយក្នុងការប្រមូលសត្វគោ រួចដឹកទៅកន្លែងថ្មី ប៉ុន្តែគាត់បានធ្វើកិច្ចការនោះ។ ពេលនោះ យ៉ាកុបបានប្រាប់ខ្ញុំថា គាត់ពិតជាជឿជាក់ថា ព្រះរាជ្យនៃព្រះជាម្ចាស់អាចធ្វើបានគ្រប់រឿងទាំងអស់ ហើយថាសក្តានុពលរបស់គាត់លែងមានកម្រិតទៀតហើយ។

នៅពេលដែលគាត់ទៅផ្ទះនៅថ្ងៃដំបូង ហើយប្រាប់អេលឡាអំពីសត្វគោនោះ គាត់បាននិយាយថា នាងតក់ស្លុត។ ប្រសិនបើអ្នកនឹងសួរយ៉ាកុប និងអេលឡា អំពីព្រះគុណរបស់ព្រះជាម្ចាស់ អ្នកគួរតែមានរយៈពេលពីរបីម៉ោងដើម្បីសម្រាក ព្រោះពួកគេនឹងមានអ្វីៗត្រូវនិយាយច្រើន។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នេះជាគំរូដ៏អស្ចារ្យមួយនៃព្រះវិញ្ញាណបរិសុទ្ធ ដែលបង្ហាញបុគ្គលណាម្នាក់ពីកន្លែងដែលត្រូវច្រូតកាត់ដោយចិត្តសប្បុរសចំពោះព្រះជាម្ចាស់។ នៅពេលដែលយើងសាបព្រោះ យើងប្រហែលជាត្រូវចាំថា អ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញដល់យើងប្រហែលជា *ប្លែកបន្តិច*! ខ្ញុំចង់និយាយថា គ្មានវិធីណាដែលយ៉ាកុបនឹងបង្កើតគំនិតនោះដោយប្រើខ្មៅដៃ និងក្រដាសរបស់គាត់ដែលធ្វើការតាមរយៈ T-bar របស់គាត់ ហើយសម្លឹងមើលជម្រើសផ្សេងៗ។

ឧទាហរណ៍ លើកយកពេត្រុសមកនិយាយ។ ខ្ញុំប្រាកដក្នុងចិត្តថា គាត់មិនដែលគិតចង់រកមើលក្នុងមាត់ត្រី ដើម្បីរកកាក់បង់ពន្ធរបស់គាត់ទេ ឬថាព្រះគ្រូដែលដើរតាមមាត់សមុទ្រនឹងអាចប្រាប់គាត់ឱ្យច្បាស់ពីកន្លែងដែលត្រូវទម្លាក់អួនរបស់គាត់ដើម្បីចាប់ត្រីដើម្បីចិញ្ចឹមជីវិត។

សូមក្រឡេកមើលឌ្រិនដា និងខ្ញុំជំពាក់បំណុលគេរយៈពេលប្រាំបួនឆ្នាំប្រកបដោយភាពតានតឹង និងភាពចលាចល។ គំនិតដែលថាថ្ងៃណាមួយយើងនឹងធ្វើជាម្ចាស់ក្រុមហ៊ុនដែលជួយមនុស្សឱ្យរួចផុតពីបំណុល ឬកាន់តែតក់ស្លុតនោះ មានការចាក់ផ្សាយតាមទូរទស្សន៍ដែលចាក់ផ្សាយនៅគ្រប់តំបន់ពេលវេលាក្នុងពិភពលោកដែលមានចំណងជើងថា *ការដោះស្រាយបញ្ហាអំពីប្រាក់* គឺមិនអាចទៅរួចនោះទេ។

អ្នកប្រហែលជាមិនចង់ដាក់កម្រិតចំពោះព្រះជាម្ចាស់នោះទេ។

ដូច្នេះសូមយើងពិនិត្យមើល ហើយចាំថាព្រះជាម្ចាស់ទ្រង់ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ—អ្នកដែលនឹងសាបព្រោះ ហើយចង់សាបព្រោះ!

តោះ! យើងបន្តទៀត។ ឥលូវនេះ ខ្ញុំចង់មើលពីអ្វីដែលខ្ញុំចាត់ទុកថាជារឿងប្រៀបប្រដូចដ៏អស្ចារ្យមួយដែលព្រះយេស៊ូធ្លាប់បានបង្រៀនអំពីព្រះដែលធ្វើការជាមួយមនុស្ស និងរបៀបដែលពួកគេត្រូវតែមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីឱ្យទ្រង់អាចប្រើប្រាស់ពួកគេបាន។ រឿងមួយនេះច្បាស់ជាធ្វើឱ្យអ្នកជញ្ជឹងគិតមួយភ្លែត។

*ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សិស្សថា៖ «មានសេដ្ឋីមួយរូបបានប្រគល់មុខងារឱ្យអ្នកបម្រើម្នាក់មើលខុសត្រូវលើទ្រព្យសម្បត្តិរបស់លោក។ មានគេមកជម្រាបលោកថា អ្នកនោះបានចាយវាយទ្រព្យសម្បត្តិលោកយ៉ាងខ្ជះខ្ជាយ។ សេដ្ឋីក៏ហៅអ្នកមើលខុសត្រូវមកប្រាប់ថា "ចូរគិតបញ្ជីយកមកឱ្យខ្ញុំ អ្នកមិនអាចមើលខុសត្រូវលើទ្រព្យសម្បត្តិខ្ញុំតទៅទៀតឡើយ ព្រោះសេចក្ដីដែលខ្ញុំបានឮគេនិយាយអំពីអ្នកមិនល្អសោះ"។*

*អ្នកបម្រើនោះរិះគិតក្នុងចិត្តថា "ចៅហ្វាយលែងឱ្យអញទទួលខុសត្រូវលើទ្រព្យសម្បត្តិលោកទៀតហើយ។ តើអញគិតទៅធ្វើការអ្វីវិញហ្ន៎? អញគ្មានកម្លាំងនឹងកាប់គាស់ដីទេ បើដើរសុំទានខ្មាសគេ។ អ៊ុំ! នឹកឃើញហើយ គួរធ្វើយ៉ាងនេះ ដើម្បីអ្នកស្រុកទទួលអញឱ្យស្នាក់នៅផ្ទះគេ នៅពេលអញឈប់កាន់កាប់ការងារនេះ"។*

*គាត់ក៏ហៅកូនបំណុលរបស់ចៅហ្វាយឱ្យចូលមកម្នាក់ម្ដងៗ គាត់សួរអ្នកទីមួយថា "តើអ្នកជំពាក់ចៅហ្វាយខ្ញុំប៉ុន្មាន?"។*

*កូនបំណុលនោះឆ្លើយថា "ប្រេងមួយរយប៉ោត"។*

*អ្នកបម្រើប្រាប់ថា "នេះនែ៎! យកបញ្ជីរបស់អ្នក ហើយអង្គុយចុះ សរសេរយ៉ាងប្រញាប់ដាក់ថា ជំពាក់ហាសិបប៉ោត"។*

*បន្ទាប់មក គាត់សួរម្នាក់ទៀតថា "តើអ្នកជំពាក់ចៅហ្វាយខ្ញុំប៉ុន្មានដែរ?"។*

*កូនបំណុលនោះឆ្លើយថា "ស្រូវប្រាំរយថាំង"។*

*អ្នកបម្រើប្រាប់ថា "នែ៎! យកបញ្ជីរបស់អ្នក ហើយសរសេរដាក់ថា ជំពាក់បួនរយថាំង"។*

*ម្ចាស់ក៏សរសើរអ្នកបម្រើដែលប៉ិនប្រសប់បោកបញ្ឆោត។ មនុស្សក្នុងលោកនេះតែងតែប៉ិនប្រសប់រកស៊ីជាមួយគ្នា ជាងអស់អ្នកដែលស្គាល់ពន្លឺរបស់ព្រះជាម្ចាស់ទៅទៀត»។ «ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ចូរយកទ្រព្យសម្បត្តិលោកីយ៍ដែលបញ្ឆោតចិត្តនេះទៅធ្វើទាន ដើម្បីឱ្យមានមិត្តភក្តិច្រើន។ ពេលណាទ្រព្យនេះរលាយសូន្យទៅមិត្តភក្តិទាំងនោះនឹងទទួលអ្នករាល់គ្នា នៅក្នុងដំណាក់របស់ព្រះជាម្ចាស់។*

*អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ។ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់ក្នុងរបៀបប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍ ដែលបញ្ឆោតចិត្តនេះទេ ព្រះជាម្ចាស់ក៏ពុំអាចប្រគល់ទ្រព្យសម្បត្តិដ៏ពិតប្រាកដមកអ្នករាល់គ្នាដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងទ្រព្យសម្បត្តិអ្នកដទៃផង ធ្វើម្ដេចឱ្យព្រះជាម្ចាស់ប្រទានទ្រព្យសម្បត្តិដែលព្រះអង្គបម្រុងទុកសម្រាប់អ្នករាល់គ្នា មកអ្នករាល់គ្នាបាន!*

*គ្មានអ្នកណាអាចបម្រើម្ចាស់ពីរនាក់បានទេ ព្រោះអ្នកនោះនឹងស្អប់ម្នាក់ស្រឡាញ់ម្នាក់ ស្មោះត្រង់នឹងម្នាក់ មើលងាយម្នាក់ទៀតពុំខាន។ អ្នករាល់គ្នាពុំអាចគោរពបម្រើព្រះជាម្ចាស់ផង គោរពបម្រើទ្រព្យសម្បត្តិលោកីយ៍ផងឡើយ»។*

*កាលពួកខាងគណៈផារីស៊ីឮដូច្នោះ គេក៏ចំអកឱ្យព្រះយេស៊ូ ដ្បិតពួកគេស្រឡាញ់ប្រាក់ណាស់។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាតែងតែសម្ដែងឫកពាឱ្យមនុស្សលោកឃើញថា អ្នករាល់គ្នាជាជនសុចរិត ប៉ុន្តែ ព្រះជាម្ចាស់ឈ្វេងយល់ចិត្តអ្នករាល់គ្នា។ អ្វីៗដែលមនុស្សលោកយល់ឃើញថាល្អប្រសើរ ព្រះជាម្ចាស់ចាត់ទុកថាជាការគួរឱ្យស្អប់ខ្ពើម។*

—លូកា ១៦:១-១៥

មានចំណុចជាច្រើននៅក្នុងរឿងប្រៀបប្រដូចនេះដែលយើងត្រូវពិនិត្យមើល។ ទីមួយ យើងឃើញថា ម្ចាស់ដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភបានឱ្យអ្នកបម្រើទទួលខុសត្រូវលើប្រតិបត្តិការរបស់គាត់ ហើយជាក់ស្ដែង អ្នកបម្រើខ្ជះខ្ជាយទ្រព្យសម្បត្តិរបស់ម្ចាស់ ហើយម្ចាស់បានដកសិទ្ធិពីគាត់មិនឱ្យគ្រប់គ្រងបន្ថែមទៀត។ ដោយដឹងថាគាត់បាត់បង់ការងារ គាត់ក៏ប្រញាប់ហៅអ្នកណាដែលជំពាក់ប្រាក់ថៅកែរបស់គាត់ ហើយប្រាប់ពួកគេថា ពួកគេអាចគិតបញ្ជីដើម្បីទទួលបានការបញ្ចុះតម្លៃដ៏ច្រើន។ ជួនកាលទទួលបានការបញ្ចុះតម្លៃពាក់កណ្ដាល ប្រសិនបើពួកគេគិតបញ្ជីបានលឿន។

ជាការពិតណាស់ ម្ចាស់មិនបានដឹងទាំងស្រុងពីអ្វីដែលអ្នកបម្រើកំពុងធ្វើនោះទេ។ ប៉ុន្តែអ្នកបម្រើដែលមិនស្មោះត្រង់គិតថា ប្រសិនបើគាត់ឱ្យប្រាក់ទាំងនេះទៅអ្នកដទៃ ពួកគេនឹងចូលចិត្តគាត់នៅពេលដែលគាត់ចាកចេញពីម្ចាស់ ហើយគាត់សង្ឃឹមថាពួកគេអាចផ្ដល់ការងារឱ្យគាត់ក្នុងប្រតិបត្តិការរបស់ពួកគេ។ នៅពេលម្ចាស់ឮរឿងដែលអ្នកបម្រើមិនស្មោះត្រង់បានធ្វើ ម្ចាស់ក៏ហៅគាត់ទៅជួប ហើយ៖

*ម្ចាស់ក៏សរសើរអ្នកបម្រើដែលប៉ិនប្រសប់បោកបញ្ឆោត។*

និយមន័យនៃភាពប៉ិនប្រសប់បោកបញ្ឆោតគឺ៖ មាន ឬបង្ហាញការយល់ដឹងដ៏ឆ្លាតវៃ ឬធនធាន ជាពិសេសក្នុងកិច្ចការជាក់ស្ដែង។ គ្រប់គ្រង ឬសម្គាល់ដោយការអនុវត្តប្រកបដោយភាពប៉ិនប្រសប់ និងកលល្បិច; ការបោកបញ្ឆោត[11]។

ម្ចាស់បានឃើញថាអ្នកបម្រើមានសមត្ថភាពក្នុងការបង្កើត និងអនុវត្តផែនការដែលនឹងបង្កើតប្រាក់ចំណេញ ក្នុងករណីនេះ មិនមែនសម្រាប់ម្ចាស់ទេ ប៉ុន្តែសម្រាប់ខ្លួនគាត់ - ជាអ្វីមួយដែលគាត់មិនបានឃើញពីអ្នកបម្រើនេះជំនួសគាត់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលប្រាក់នោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ គាត់បានគ្រប់គ្រងដោយឆ្លាតវៃ និងច្បាស់លាស់។ គាត់បានបង្ហាញគំនិតផ្ដួចផ្ដើមទាក់ទងនឹង

---

[11] *វចនានុក្រមភាសាអង់គ្លេស* American Heritage *កំណែទីប្រាំ*

កិច្ចការរបស់គាត់ និងសុខុមាលភាពរបស់គាត់ ប៉ុន្តែគាត់មិនបានបង្ហាញចំណុចទាំងនោះតាងនាមឱ្យម្ចាស់គាត់ទេ។ ខ្ញុំសូមនិយាយត្រង់នេះបន្តិច - គាត់ជាអ្នកស៊ីឈ្នួល!

ឥលូវនេះ ខ្ញុំសូមសួរសំណួរដ៏ពិបាក៖ តើអ្នកជាគ្រិស្តបរិស័ទស៊ីឈ្នួលដែរឬទេ?

តើអ្នកខ្វល់ខ្វាយអំពីសុខុមាលភាពរបស់អ្នកជាងកិច្ចការរបស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកខ្វល់ខ្វាយពីការយកចិត្តទុកដាក់ និងការព្រួយបារម្ភរបស់អ្នកច្រើនជាងការយកចិត្តទុកដាក់ និងការព្រួយបារម្ភរបស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកកំពុងខ្ជះខ្ជាយទ្រព្យសម្បត្តិរបស់ព្រះដែរឬទេ?

ខ្ញុំដឹងថាសំណួរទាំងនេះពិបាកឆ្លើយ។ ហេតុនេះហើយបានជាខ្ញុំនិយាយថា ការប្រៀបប្រដូចនេះមានអត្ថន័យជ្រាលជ្រៅណាស់ ព្រោះវាចាក់ចំបេះដូង ហើយបង្ហាញពីអាកប្បកិរិយាខុសឆ្គងដែលអាចលាក់ទុក។

ព្រះយេស៊ូបានបង្ហាញដល់យើង និងកំណត់និយមន័យអំពីអ្នកស៊ីឈ្នួលនៅក្នុងព្រះគម្ពីរយ៉ូហាន ១០:១១-១៣។

> *«ខ្ញុំហ្នឹងហើយជាគង្វាលដ៏ល្អ គង្វាលដ៏ល្អតែងតែស៊ូប្តូរជីវិត ដើម្បីចៀមរបស់ខ្លួន។ រីឯអ្នកស៊ីឈ្នួលវិញ កាលគេឃើញចចកមកដល់ គេរត់ចោលចៀម ទុកឱ្យចចកខាំអូសយកទៅ ហើយដេញកម្ចាត់កម្ចាយជាមិនខាន ពីព្រោះអ្នកនោះមិនមែនជាគង្វាល ហើយក៏មិនមែនជាម្ចាស់របស់ចៀមផង។ អ្នកនោះមិនខ្វល់ខ្វាយនឹងចៀមឡើយ ព្រោះគេគ្រាន់តែស៊ីឈ្នួលប៉ុណ្ណោះ។*
>
> —យ៉ូហាន ១០:១១-១៣

ព្រះគម្ពីរខ្មែរបច្ចុប្បន្ន (ខ១៣) ចែងថា

*អ្នកនោះមិនខ្វល់ខ្វាយនឹងចៀមឡើយ ព្រោះគេគ្រាន់តែស៊ីឈ្នួលប៉ុណ្ណោះ*

ចំពោះអ្នកបម្រើមិនស្មោះត្រង់ គាត់ត្រូវបានដកសិទ្ធិមិនឱ្យគ្រប់គ្រងប្រាក់របស់ម្ចាស់ទេ ដោយសារគាត់ពិតជាមិនខ្វល់ពីសុខុមាលភាពរបស់ម្ចាស់។ គាត់គិតតែពីខ្លួនឯងប៉ុណ្ណោះ។ ឥលូវនេះ គាត់នៅតែមានលទ្ធភាពចេញក្រៅ និងរកប្រាក់ដោយខ្លួនឯង ប៉ុន្តែគាត់នឹងលែងមានឱកាសគ្រប់គ្រងប្រាក់របស់គាត់ និងប្រាក់របស់ម្ចាស់ទៀតហើយ។

ខ្ញុំជឿថា យើងកំពុងរស់នៅក្នុងពេលដែលមានការធ្វើបាបផ្លូវចិត្តចំពោះអ្នកស៊ីឈ្នួលនៅអាមេរិក និងក្នុងពិភពលោក។

ខ្ញុំប្រាកដថាអ្នកធ្លាប់នៅក្នុងភោជនីយដ្ឋាន ហើយបានឃើញតុ និងកម្រាលកខ្វក់ ហើយនៅខាងក្រោយអ្នកឃើញបុគ្គលិកពីរបីនាក់ខ្ជិលធ្វើការ។ ឬអ្នកចូលទៅភោជនីយដ្ឋានអាហាររហ័សប្រហែលជា ៣០ នាទីមុនពេលបិទ ហើយអ្នកភ្ញាក់ផ្អើលពេលឃើញកៅអីទាំងអស់នៅលើតុ ហើយបុគ្គលិកតម្រង់ជួរតាមម៉ោងរង់ចាំចាកចេញ។ ដោយមិនចាំបាច់សួរ អ្នកប្រាកដជាដឹងថាម្ចាស់មិននៅទីនោះទេ។ ទាំងនេះសុទ្ធតែជាអ្នកស៊ីឈ្នួល។ ពួកគេមិនខ្វល់ពីប្រាក់ចំណេញរបស់អាជីវកម្មនោះទេ។ ពួកគេនៅទីនោះដើម្បីទទួលបានប្រាក់ខែតែប៉ុណ្ណោះ។

ដូច្នេះនិយោជកជាច្រើនប្រាប់ខ្ញុំថា វាមិនល្អឡើយ ប្រសិនបើនិយោជិតគ្រាន់តែបង្ហាញខ្លួននៅម៉ោងធ្វើការ គាត់ចង់ឱ្យតែមនុស្សមើលឃើញគាត់។ និយោជកកំពុងស្រែករកម្ចាស់ មិនមែនអ្នកយកទេ។ ពួកគេចង់បាននិយោជិតដែលនឹងធ្វើការ និងយកចិត្តទុកដាក់ចំពោះការងារផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគេប្រាប់ខ្ញុំថា បុគ្គលិកដែលមានអាកប្បកិរិយាល្អនឹងត្រូវបានដំឡើងតួនាទី ហើយគេត្រូវការបុគ្គលិកប្រភេទនោះ។

ព្រះជាម្ចាស់ក៏មិនខុសគ្នាដែរ។ ទ្រង់កំពុងស្វែងរកមនុស្សដែលខ្វល់ខ្វាយនូវអ្វីដែលទ្រង់ខ្វល់ខ្វាយ និងស្អប់នូវអ្វីដែលទ្រង់ស្អប់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នៅក្នុង១សាំយូអែលជំពូក១៥ ព្រះជាម្ចាស់បានប្រាប់ស្ដេចសូលឱ្យវាយប្រហារជនជាតិអាម៉ាលេកចំពោះអ្វីដែលពួកគេបានធ្វើមកលើប្រទេសអ៊ីស្រាអែលនៅពេលពួកគេចេញពីប្រទេសអេស៊ីប។ ស្ដេចសូលត្រូវបានគេប្រាប់កុំឱ្យចុះចេញពីអំណាច ហើយមនុស្សទាំងឡាយនៅមានជីវិត។ ពួកគេមិនត្រូវនាំសត្វទាំងនោះមកជាមួយទេ ប៉ុន្តែសូលបានធ្វើដូច្នេះ ៖

> *តែព្រះបាទសូល និងកងទ័ពបានទុកជីវិតឱ្យស្ដេចអកាក់ ព្រមទាំងសត្វដ៏ល្អៗជាងគេ មានគោ ចៀម សត្វធាត់ៗ កូនចៀម និងអ្វីៗដែលល្អបំផុត ពួកគេមិនព្រមបំផ្លាញថ្វាយផ្ដាច់ដល់ព្រះជាម្ចាស់ទេ។ ពួកគេបំផ្លាញតែអ្វីៗដែលគ្មានតម្លៃ និងគ្មានប្រយោជន៍ប៉ុណ្ណោះ។*
>
> —១ សាំយ៉ូអែល ១៥:៩

ចូរទៅមើលអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលនៅក្នុងខ១០-១១៖

> *ពេលនោះ ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសាំយូអែលថា «យើងសោកស្ដាយណាស់ដោយបានតែងតាំងសូលជាស្ដេច ព្រោះគេងាកចេញពីយើង ហើយពុំបានប្រតិបត្តិតាមបទបញ្ជារបស់យើងទេ»។*

បន្ទាប់មកយើងឃើញព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកសាំយូអែលអំពីស្ដេចសូលនៅក្នុង ១ សាំយូអែល ១៦:១។

> *ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកសាំយូអែលថា៖ «តើអ្នកនៅតែយំសោកស្ដាយសូលដល់ណាទៀត? យើងបោះបង់គេចោល លែងឱ្យធ្វើជាស្ដេចលើជនជាតិអ៊ីស្រាអែលទៀតហើយ។ ចូរយកស្នែងមកចាក់ប្រេងឱ្យពេញ រួចធ្វើដំណើរទៅ។ យើងចាត់អ្នកឱ្យទៅផ្ទះលោកអ៊ីសាយ នៅភូមិបេថ្លេហិម ដ្បិត*

*ក្នុងចំណោមកូនប្រុសរបស់គាត់ យើងជ្រើសរើសយកម្នាក់ឱ្យធ្វើជាស្ដេច ដែលត្រូវចិត្តយើង»។*

ដូចជាអ្នកបម្រើមិនស្មោះត្រង់ត្រូវបានដកសិទ្ធិក្នុងការគ្រប់គ្រងកិច្ចការរបស់ម្ចាស់ ដូច្នេះ សូលត្រូវបានដកសិទ្ធិ។ ហើយទាយមើលថានឹងមានអ្វីកើតឡើង? អ្នក និងខ្ញុំអាចត្រូវបានដកសិទ្ធិផងដែរ។

តើព្រះជាម្ចាស់កំពុងស្វែងរកអ្វី? តើទ្រង់នឹងទុកចិត្តអ្នកណា?

*ក្រោយពីបានដករាជ្យពីព្រះបាទសូល ព្រះជាម្ចាស់ប្រទានឱ្យព្រះបាទដាវីឌឡើងគ្រងរាជ្យ។ ព្រះអង្គប្រទានសក្ខីភាពអំពីព្រះបាទដាវីឌនេះថាៈ “យើងរកបានមនុស្សម្នាក់ ជាទីគាប់ចិត្តយើងណាស់ គឺដាវីឌជាបុត្ររបស់អ៊ីសាយ ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង”។*

—កិច្ចការ ១៣:២២

បើយើងអាចបាត់បង់សិទ្ធិ យើងក៏អាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែរ។ អ្នកអាចនឹងនិយាយថា «មែនហើយ ហ្គារី តើខ្ញុំធ្វើរឿងនោះដោយរបៀបណា?» រឿងប្រៀបប្រដូចនេះឆ្លើយសំណួរនោះសម្រាប់អ្នក។

*អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ។ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់ក្នុងរបៀបប្រើប្រាស់ទ្រព្យសម្បត្តិលោកីយ៍ដែលបញ្ឆោតចិត្តនេះទេ ព្រះជាម្ចាស់ក៏ពុំអាចប្រគល់ទ្រព្យសម្បត្តិដ៏ពិតប្រាកដមកអ្នករាល់គ្នាបានដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងទ្រព្យសម្បត្តិអ្នកដទៃផង ធ្វើម្ដេចឱ្យព្រះជាម្ចាស់ប្រទានទ្រព្យសម្បត្តិដែលព្រះអង្គបម្រុងទុកសម្រាប់អ្នករាល់គ្នា មកអ្នករាល់គ្នាបាន!*

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

*គ្មានអ្នកណាអាចបំរើម្ចាស់ពីរនាក់បានទេ ព្រោះអ្នកនោះនឹងស្អប់ម្នាក់ ស្រឡាញ់ម្នាក់ ស្មោះត្រង់នឹងម្នាក់ មើលងាយម្នាក់ទៀតពុំខាន។ អ្នករាល់គ្នាពុំអាចគោរពបំរើព្រះជាម្ចាស់ផង គោរពបំរើទ្រព្យសម្បត្តិលោកីយ៍ផងបានឡើយ»។*

— លូកា ១៦:១០-១៣

ខ្ញុំសូមពន្យល់ឱ្យច្បាស់៖ អ្នកត្រូវតែឆ្លងកាត់ការសាកល្បងភាពស្មោះត្រង់។ បើគេអាចទុកចិត្តអ្នកចំពោះកិច្ចការតូចបំផុត នោះគេក៏អាចទុកចិត្តអ្នកចំពោះកិច្ចការដ៏ធំដែរ។ ការធ្វើតេស្តតែងតែចាប់ផ្តើមជាមួយនឹងធម្មជាតិ រហូតដល់ព្រលឹងវិញ្ញាណ។ គេអាចទុកចិត្តអ្នកក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិលោកិយ មុនពេលព្រះជាម្ចាស់អាចទុកចិត្តអ្នកចំពោះទ្រព្យសម្បត្តិរបស់ទ្រង់។ ប្រសិនបើគេមិនទុកចិត្តអ្នកចំពោះទ្រព្យអ្នកដទៃ តើអ្នកណានឹងប្រគល់ទ្រព្យសម្បត្តិដល់អ្នក? ប្រាកដណាស់មិនមែនព្រះជាម្ចាស់ទេ។

ខាងក្រោមនេះជាការអនុវត្តនៃរឿងប្រៀបប្រដូចទៅនឹងជីវិតរបស់យើងផ្ទាល់។

## គ្រិស្តបរិស័ទភាគច្រើនថ្វាយព្រះជាម្ចាស់នូវអ្វីដែលនៅសល់

គ្រិស្តបរិស័ទភាគច្រើនមើលថវិការបស់ពួកគេ ហើយសម្រេចចិត្តថា «ខ្ញុំអាចថ្វាយបានតែប៉ុណ្ណឹងទេ» ប៉ុន្តែពួកគេមិនមានបញ្ហាក្នុងការចេញទៅក្រៅក្នុងថ្ងៃដដែល និងទិញទូកថ្មីនោះទេ។

ឥលូវនេះ ខ្ញុំមិនព្យាយាមធ្វើឱ្យអ្នកណាម្នាក់មានអារម្មណ៍ថាមានកំហុសនោះទេ ហើយព្រះជាម្ចាស់ពិតជាមិនខ្វល់ថាអ្នកមានទូកដ៏ស្រស់ស្អាតនោះទេ។ ខ្ញុំគ្រាន់តែសួរអ្នកថា តើអ្នកចង់គ្រប់គ្រងប្រាក់របស់អ្នក ឬរបស់ព្រះជាម្ចាស់?

ប្រសិនបើអ្នកស្រាវជ្រាវនៅលើ Google នូវអ្វីដែលគ្រិស្តបរិស័ទថ្វាយជាមធ្យម អ្នកប្រហែលជាភ្ញាក់ផ្អើល។ ខ្ញុំបានឃើញស្ថិតិមួយដែលនិយាយថា គ្រិស្តបរិស័ទដែលមានជីវភាពមធ្យមថ្វាយតង្វាយតែជាង១៣ដុល្លារក្នុងមួយសប្តាហ៍ដល់ក្រុមជំនុំ។[12]

ខ្ញុំបានមើលស្ថិតិជាច្រើនទាក់ទងនឹងការថ្វាយតង្វាយ ហើយពួកគេទាំងអស់មានការខកចិត្ត។ ដូចដែលខ្ញុំបាននិយាយ គ្រិស្តបរិស័ទភាគច្រើនថ្វាយដល់ព្រះជាម្ចាស់នូវអ្វីដែលនៅសល់ពីពួកគេ។ ជាថ្មីម្តងទៀត សូមយល់ថា ខ្ញុំមិនព្យាយាមថ្កោលទោស ឬរកចាប់កំហុសនោះទេ។ ខ្ញុំគ្រាន់តែលើកយកចំណុចមួយមកនិយាយប៉ុណ្ណោះ—ហើយខ្ញុំគិតថាព្រះបន្ទូលរបស់ព្រះជាម្ចាស់គាំទ្រទស្សនៈរបស់ខ្ញុំ—ថាព្រះជាម្ចាស់មិនស្វែងរកអ្នកស៊ីឈ្នួលទេ។ ទ្រង់កំពុងស្វែងរកម្ចាស់។

ទីពីរ ព្រះជាម្ចាស់មិនស្វែងរកមនុស្សដែលមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យលះបង់កំហុសនោះទេ។ ព្រះជាម្ចាស់ស្រឡាញ់អ្នកថ្វាយតង្វាយដោយរីករាយ យោងតាម ២កូរិនថូស ៩:៧។

ស្តេចសូលត្រូវបានដកសិទ្ធិដោយសារមិនធ្វើអ្វីដែលព្រះជាម្ចាស់បានឱ្យគាត់ធ្វើ ប៉ុន្តែដាវីឌត្រូវបានជ្រើសរើសដោយសារតែគាត់ស្តាប់បង្គាប់ និងធ្វើតាមអ្វីដែលព្រះជាម្ចាស់ប្រាប់ឱ្យគាត់ធ្វើ។

ដូច្នេះ ខ្ញុំសូមលើកឡើងនូវទស្សនៈថ្មីមួយ។ ចុះបើយើងផ្លាស់ប្តូរជីវិតរបស់យើងទាំងស្រុង និងសម្រេចចិត្តរស់នៅថ្វាយព្រះជាម្ចាស់ជាមុន ហើយយើងនឹងក្លាយជាមនុស្សដែលរស់នៅសេសសល់លើផែនដី? ខ្ញុំគ្រាន់តែអាចសន្និដ្ឋានថា កិច្ចការដែលនៅសេសសល់នឹងធ្លាក់មកលើអ្នកក្នុងពេលវេលាដ៏ឆាប់ ហើយអ្នកនឹងរស់នៅក្នុងជីវិតដែលពេញដោយព្រះពរ។

---

[12] https://www.pastorrickypowell.com/life_matters_with_pastor_/2009/10/ startling-statistics

ទស្សនៈនេះមានប្រសិទ្ធភាពនៅ R.G. LeTourneau។ ចាប់ពីការបន្ទាបខ្លួន និងកម្រិតវប្បធម៌ត្រឹមថ្នាក់ទី៧ប៉ុណ្ណោះ គាត់បានបង្រៀនខ្លួនឯង ហើយនៅទីបំផុតគាត់បានកសាងចក្រភពផលិតកម្មមួយ។ គ្រឿងចក្រឈូសឆាយដីរបស់គាត់បានជួយឱ្យឈ្នះសង្គ្រាមលោកលើកទី២ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវហាយវេនៃប្រទេសអាមេរិកទំនើប។ ក្នុងជីវិតចុងក្រោយរបស់គាត់គាត់មានប្រកាសនីយបត្រតក្កកម្ម (ប៉ាតង់) ចំនួន៣០០។[13]

តើអ្វីជាអាថិកំបាំងរបស់គាត់? គាត់បានថ្វាយព្រះជាម្ចាស់ ៩០% នៃប្រាក់ដែលគាត់រកបាន។[14]

ឥលូវនេះ ខ្ញុំមិនប្រាប់អ្នកឱ្យធ្វើដូចគ្នាទេ។ នេះជាកិច្ចព្រមព្រៀងមួយដែលគាត់និងព្រះជាម្ចាស់បានធ្វើនៅពេលគាត់មានអាយុ ៣០ ឆ្នាំ ហើយជំពាក់បំណុលគេវ័ណ្ឌក ។ គាត់យកព្រះជាម្ចាស់ធ្វើជាដៃគូអាជីវកម្មរបស់គាត់ (ដូចដែលគាត់បានអំពាវនាវរកទ្រង់) ហើយការណ៍ដែលគាត់ធ្វើនោះបានទទួលផល។

នៅពេលដែលព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឱ្យបង្កើតក្រុមជំនុំតាំងពីដំបូង ខ្ញុំបានបើកក្រុមហ៊ុនរបស់ខ្ញុំរួចហើយគឺ Forward Financial Group។ ក្រុមហ៊ុននោះបានទទួលជោគជ័យយ៉ាងខ្លាំង ហើយបានជាប់ចំណាត់ថ្នាក់លេខ១ក្នុងចំណោមការិយាល័យចំនួន៥.០០០ទូទាំងពិភពលោក ជាមួយនឹងអាជីករចម្បងរបស់យើង។ នៅពេលដែលព្រះជាម្ចាស់ត្រាស់ហៅខ្ញុំឱ្យធ្វើជាគ្រូគង្វាល ខ្ញុំបានសួរទ្រង់ថា «តើខ្ញុំគួរធ្វើយ៉ាងណាចំពោះក្រុមហ៊ុន Forward Financial Group ? តើខ្ញុំគួរបិទ ហើយផ្តោតលើការដឹកនាំក្រុមជំនុំរបស់ខ្ញុំឬ?»

---

[13] http://centerforfaithandwork.com/article/who-was-rg-letourneau
[14] https://centerforfaithandwork.com/article/why-rg-letourneau-gave-90-percent

ព្រះជាម្ចាស់ឆ្លើយតបមកខ្ញុំ និងមានបន្ទូលថា *«ទេ កុំបិទ បើកបន្តទៀតចុះ ព្រោះក្រុមហ៊ុននេះជួយដល់មនុស្សជាច្រើន»។* ដូច្នេះ ខ្ញុំបានធ្វើតាមទ្រង់។

ខ្ញុំនឹងទទួលស្គាល់ថា ពេលខ្លះពិបាកក្នុងការធ្វើរឿងទាំងពីរនេះ ប៉ុន្តែវាបានជួយមនុស្សរាប់ពាន់នាក់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅពេលដែលខ្ញុំធ្វើជាគ្រូគង្វាលនៅក្រុមជំនុំរបស់យើង ខ្ញុំបានសន្មតថាផលិតផលក្រុមហ៊ុននឹងធ្លាក់ចុះដោយត្រូវកាត់បន្ថយការចូលរួមរបស់ខ្ញុំច្រើន។ ប៉ុន្តែនៅពេលដែលឌ្រិនដា និងខ្ញុំបានថ្វាយជីវិតរបស់យើងដើម្បីសម្រេចបាននូវអាណត្តិរបស់ព្រះជាម្ចាស់។ ខ្ញុំមានគំនិតផ្ទុយពីនេះ។ ទោះបីជាខ្ញុំធ្វើការតែពេលទំនេរជាមួយក្រុមហ៊ុនក៏ដោយ ក៏វានៅតែដំណើរការក្នុងកម្រិតខ្ពស់។

ក្នុងចំណោមការិយាល័យរាប់រយ យើងស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ៥ដល់លេខ១០នៃការិយាល័យទូទាំងប្រទេស ហើយត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិ។ ប៉ុន្តែខ្ញុំត្រូវតែញញឹម ដោយដឹងថាខ្ញុំធ្វើកិច្ចការនេះក្រៅម៉ោង ហើយខ្ញុំធ្វើជាគ្រូគង្វាលច្រើនម៉ោង។ ព្រះជាម្ចាស់បានលើកតម្កើងខ្ញុំដោយទ្រង់ផ្តល់ជំនួយ និងប្រាជ្ញាដើម្បីឱ្យមនុស្សនៅក្នុងលោកិយនេះដែលខំដេញតាមប្រាក់ ត្រូវឈប់ ហើយឆ្ងល់ថា ខ្ញុំបានធ្វើរឿងនោះដោយរបៀបណា។

ខ្ញុំចាំបានថាខ្ញុំអង្គុយនៅតុមួយនៅឯសន្និបាតមួយ ហើយបុរសដែលអង្គុយក្បែរខ្ញុំសួរខ្ញុំថាតើខ្ញុំធ្វើទីផ្សារបានច្រើនប៉ុនណា? ខ្ញុំញញឹម រួចនិយាយថា «គ្មានទេ»។ បន្ទាប់មកគាត់ក៏សួរថា «ចុះហេតុអ្វីបានជាអាជីវកម្មរបស់អ្នករីកចម្រើនម្ល៉េះ?» ខ្ញុំបានប្រាប់គាត់ថា យើងគ្រាន់តែផ្សព្វផ្សាយឱ្យអតិថិជននិយាយតៗគ្នា ហើយថាព្រះជាម្ចាស់បានប្រទានពរដល់យើង។ គាត់គ្រាន់តែងក់ក្បាល ព្រោះគាត់មិនអាចយល់ពីខ្ញុំ។

មានពេលមួយ ប្រធានក្រុមហ៊ុនផ្គត់ផ្គង់មួយរបស់យើងបានទូរសព្ទមកខ្ញុំ និងចង់ដឹងថាតើខ្ញុំនឹងនិយាយទៅកាន់អ្នកចូលរួមសន្និបាតអំពីរបៀបដែលខ្ញុំអាចផលិ

តបានច្រើន ឬទេ។ ខ្ញុំបាននិយាយថា ខ្ញុំរីករាយក្នុងការចែករំលែក។ ពេលនោះ គាត់ចាប់ផ្តើមសួរខ្ញុំអំពីរបៀបដែលប្រតិបត្តិការរបស់យើងដំណើរការ និងរបៀបដែលយើងធ្វើអាជីវកម្ម។

**ព្រះជាម្ចាស់ទតឃើញទាំងអស់។ ក្នុងគ្រប់កិច្ចការទាំងអស់ អ្នកកំពុងហ្វឹកហាត់សម្រាប់កិច្ចការបន្ទាប់ ដូច្នេះ កុំមើលងាយក្នុងពេលនៃកិច្ចការបន្តិចបន្តួច។**

ជាការពិតណាស់ ខ្ញុំត្រូវប្រាប់គាត់ពីរបៀបដែលយើងទុកចិត្តព្រះជាម្ចាស់ និងរបៀបដែលទ្រង់ប្រទានពរយើងដោយទ្រង់ផ្តល់ជំនួយដល់យើង។ បន្ទាប់ពីខ្ញុំប្រាប់គាត់ថា ខ្ញុំធ្វើការតែពីរបីម៉ោងក្នុងមួយសប្តាហ៍ ហើយជាគ្រូគង្វាលពេញម៉ោង គាត់បាននិយាយថា «មែនហើយ ខ្ញុំគិតថា អ្នកត្រូវតែមានយុទ្ធសាស្រ្តទីផ្សារច្បាស់លាស់ ហើយអ្នកនឹងចែករំលែកពីរបៀបដែលយុទ្ធសាស្រ្តនោះដំណើរការ។ ខ្ញុំមិនគិតថានេះជាអ្វីដែលខ្ញុំមានក្នុងចិត្តនោះទេ ប៉ុន្តែ ខ្ញុំរីករាយចំពោះឆន្ទៈរបស់អ្នកក្នុងការចែករំលែក»។ អូហ៎! មែនហើយ នោះគឺជាការខាតបង់របស់ពួកគេ។ ខ្ញុំអាចជួយមនុស្សជាច្រើននៅទីនោះ។

ខ្ញុំបាននិយាយនៅក្នុងសៀវភៅនេះទាំងមូលថា ប្រសិនបើអ្នកយកចិត្តទុកដាក់ចំពោះកិច្ចការរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងយកចិត្តទុកដាក់ចំពោះអ្នកដែរ!

ដូច្នេះ ខ្ញុំសូមសួរអ្នកនូវសំណួរមួយថា «តើជាប្រាក់របស់នរណា?»

តើអ្នកគ្រាន់តែគ្រប់គ្រងប្រាក់របស់ខ្លួនឯង ដូចជាអ្នកបម្រើមិនស្មោះត្រង់ ឬក៏អ្នកចង់គ្រប់គ្រងប្រាក់របស់ព្រះជាម្ចាស់ដែរ? នៅពេលដែលអ្នកគ្រប់គ្រងប្រាក់របស់ព្រះជាម្ចាស់ អាជីវកម្មគ្រាប់ពូជរបស់អ្នកនឹងចម្រើនឡើងដោយមានប្រាជ្ញា និងព្រះគុណរបស់ព្រះជាម្ចាស់ ដែលអនុញ្ញាតឱ្យមានការប្រមូលផលនំប៉័ងផ្ទាល់ខ្លួនរបស់អ្នក ដែលត្រូវធ្វើឡើងជាមួយនឹងការកើនឡើងនោះ។

ខ្ញុំជឿថា ព្រះជាម្ចាស់មិនខ្វល់ថាអ្នកមានប្រាក់រាប់លាននោះទេ ដរាបណាទ្រង់មានដួងចិត្តរបស់អ្នក!

សូមចាំថា វាចាប់ផ្តើមជាមួយនឹងកិច្ចការតូចៗ ដែលគ្មាននរណាម្នាក់ស្គាល់ឈ្មោះរបស់អ្នក។ ទោះជាអ្នកប្រហែលជាគិតថាគ្មាននរណាខ្វល់ពីអ្វីដែលអ្នកកំពុងធ្វើក្នុងការងារក្រៅម៉ោងនោះទេ ព្រះជាម្ចាស់ទតឃើញ។ ក្នុងគ្រប់កិច្ចការទាំងអស់ អ្នកកំពុងហ្វឹកហាត់សម្រាប់កិច្ចការបន្ទាប់ ដូច្នេះកុំមើលងាយក្នុងពេលនៃកិច្ចការបន្តិចបន្តួច។

ចូរធ្វើកិច្ចការនោះ ដូចជាអ្នកកំពុងធ្វើកិច្ចការផ្ទាល់ខ្លួន និងធ្វើឱ្យអស់ពីសមត្ថភាព។ ខ្ញុំធានាថាអ្នកនឹងភ្លឺស្វាងដូចផ្កាយពេលរាត្រី និងត្រៀមខ្លួនសម្រាប់ការដំឡើងតួនាទី និងទទួលបានជំនួយ។

-

# ជំពូក ៥

# អ្នកត្រូវការដៃគូម្នាក់!

ដូចដែលអ្នកបានដឹងហើយថា ខ្ញុំបានធ្វើការខាងផ្នែកអាជីវកម្មហិរញ្ញវត្ថុអស់រយៈពេលជិត៥០ឆ្នាំហើយរហូតដល់ពេលឥលូវនេះ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំត្រូវបានមនុស្សជាច្រើនសួរខ្ញុំអំពីរបៀបធ្វើ និងរបៀបចាប់ផ្តើមអាជីវកម្ម ព្រមទាំងអ្វីដែលធ្វើឱ្យអាជីវកម្មមានភាពរីកលូតលាស់ទៅមុខ។

ជាការពិតណាស់ មានរឿងជាច្រើនដែលមនុស្សត្រូវដឹង ប៉ុន្តែអ្វីដែលសំខាន់បំផុតដែលខ្ញុំអាចប្រាប់ពួកគេបានគឺ ពួកគេត្រូវការ*ដៃគូម្នាក់*។

ឥលូវនេះក្នុងនាមខ្ញុំជាគ្រូគង្វាលអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានឃើញមនុស្សជាច្រើនបង្រៀនថា វាជាការដ៏អស្ចារ្យក្នុងការចូលរួមអាជីវកម្មជាមួយមិត្តភក្តិក្នុងក្រុមជំនុំរបស់ពួកគេ។ ហើយបន្ទាប់ពីអាជីវកម្មទាំងមូលបានដួលរលំ មិត្តភក្តិទាំងនោះបានអាក់អន់ស្រពោនចិត្តនឹងគ្នា ហើយថែមទាំងឈប់និយាយរកគ្នាទៀតផង។ ទំនាក់ទំនងត្រូវបានបំផ្លាញ ហើយខ្ញុំក៏ធ្លាប់បានឃើញរឿងនេះកើតឡើងច្រើនដងមកហើយដែរ។ ខ្ញុំកម្រណែនាំអ្នកណាម្នាក់ឱ្យទៅរកស៊ីជាមួយមិត្តភក្តិរបស់ពួកគេណាស់ លុះត្រាតែអ្នកនោះបានដាក់ដែនកំណត់ ហើយសរសេរក្រដាសស្នាមឱ្យបានច្បាស់លាស់ជាមុនសិន។

ទោះជាយ៉ាងណាក៏ដោយ មានដៃគូម្នាក់ដែលខ្ញុំតែងតែទទូចឱ្យអ្នកទទួលយកធ្វើជាដៃគូ ហើយដៃគូម្នាក់នោះ គឺជាព្រះជាម្ចាស់។

នៅក្នុងជំពូកមុន យើងបាននិយាយអំពីស្ត្រីម្នាក់ដែលបានទទួលព្យាការីអេលីយ៉ា នាងបានផ្តល់អាហារចុងក្រោយរបស់នាងទៅឱ្យគាត់។ យើងបានឃើញអំពីទង្វើនៃសេចក្តីជំនឿបានបង្កើតឱ្យមានអាហារជារៀងរាល់ថ្ងៃសម្រាប់ព្យាការីម្នាក់នោះ។ នេះជាកិច្ចការរបស់ព្រះជាម្ចាស់ និងគ្រួសាររបស់ស្ត្រីម្នាក់នោះ។ នាងបានចាប់ដៃគូជាមួយគាត់ក្នុងកិច្ចការរបស់គាត់ ហើយពេលដែលនាងបានធ្វើដូច្នេះ ការចាក់ប្រេងតាំង និងការផ្គត់ផ្គង់ដែលមាននៅក្នុងកិច្ចការរបស់គាត់ បានក្លាយជាកិច្ចការរបស់នាងដែរ។ ពួកគេបានក្លាយជាដៃគូនឹងគ្នា។

នៅក្នុងសៀវភៅនេះ យើងបាននិយាយអំពីការមានចិត្តសប្បុរសចំពោះព្រះជាម្ចាស់ ហើយសាបព្រោះទៅក្នុងកិច្ចការរបស់ទ្រង់។ ខ្ញុំក៏បានប្រាប់អ្នកផងដែរ អំពីរបៀបដែលចិត្តសប្បុរសជួយបើកចិត្តមនុស្សចំពោះអ្នក និងចំពោះព្រះជាម្ចាស់ផងដែរ។

នៅក្នុងជំពូកនេះ ខ្ញុំចង់ចែករំលែកជាមួយអ្នកអំពីគោលការណ៍ដ៏មានឥទ្ធិពលមួយនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលនឹងជំរុញហិរញ្ញវត្ថុរបស់អ្នកទៅកាន់កម្រិតថ្មីមួយទៀតទាំងស្រុង វាគឺជាគោលការណ៍នៃភាពជាដៃគូ។

> *ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្តាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចព្រះអង្គសុំឱ្យគាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្តាជនពីក្នុងទូកនោះ។*
>
> *លុះព្រះអង្គបង្រៀនគេចប់ហើយ ព្រះអង្គមានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។ លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់*

*បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

—លូកា ៥:១-៧

ខ្ញុំដឹងថា ខ្ញុំបាននិយាយរឿងនេះពីមុនរួចមកហើយ ពេលដែលខ្ញុំនិយាយអំពីទូក និងអាជីវកម្មនេសាទ ដែលទទួលបានការផ្លាស់ប្ដូរដោយសារព្រះរាជ្យរបស់ព្រះជាម្ចាស់ (ឬការគ្រប់គ្រងរបស់ព្រះជាម្ចាស់) នៅពេលដែលលោកពេត្រុស (ស៊ីម៉ូន) បានឱ្យទូករបស់គាត់ទៅព្រះយេស៊ូខ្ចីដើម្បីបង្រៀនមហាជន។ ខ្ញុំក៏បានលើកឡើងដែរ អំពីការចាប់ត្រីដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានកើតឡើងដ៏មិនគួរឱ្យជឿ ហើយបានធ្វើឱ្យទូកទាំងពីររបស់ពួកគេស្ទើរតែលិច។ លោកពេត្រុសបាននិយាយថា គាត់បាននេសាទត្រីពេញមួយយប់ហើយ ហើយចាប់មិនបានអ្វីសោះ។ ឥលូវនេះ ប៉ុន្មានម៉ោងក្រោយមកគាត់ក៏ចាប់បានត្រីយ៉ាងច្រើនសន្ធឹកសន្ធាប់ គាត់សឹងតែមិនអាចទាញអួនឱ្យលឿនបានទេ។ តើមានអ្វីពិសេសកើតឡើងនៅទីនេះ?

ជាការពិតណាស់ គឺជាព្រះរាជ្យរបស់ព្រះជាម្ចាស់ ប៉ុន្តែក៏ជាដៃគូផងដែរ។ សូមអនុញ្ញាតឱ្យខ្ញុំពន្យល់អ្នកពីចំណុចនេះ។

*ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចព្រះអង្គសុំឱ្យគាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។*

សូមយល់ឱ្យច្បាស់អំពីកាលៈទេសៈនៅទីនេះ។ តើពួកគេនៅឯណា? ហើយតើពួកគេកំពុងធ្វើអ្វីពេលព្រះយេស៊ូយាងមក? ពួកគេមិនមែនកំពុងតែនេសាទទេ។ ពួកគេ

នៅលើច្រាំងកំពុងលាងអួន បន្ទាប់ពីធ្វើការនេសាទពេញមួយយប់មក ហើយចាប់អ្វីមិនបានសោះ។

ព្រះយេស៊ូបានជ្រាបថា មានទូកទំនេរពីរនៅទីនោះ ហើយទ្រង់បានសួរលោកពេត្រុសថា តើគាត់អាចថយទូកចេញពីច្រាំងបន្តិចបានដែរឬទេ? ដើម្បីឱ្យទ្រង់អាចបង្រៀនហ្វូងមនុស្សពីទូករបស់គាត់។ និយាយដូច្នេះ តើលោកយ៉ាកុប និងលោកយ៉ូហានដែលជាដៃគូរបស់គាត់នៅឯណាដែរ ពេលលោកពេត្រុសឃាងព្រះយេស៊ូឱ្យគង់នៅក្នុងទូករបស់គាត់? មែនហើយ ពួកគេនៅលើច្រាំងជាមួយនឹងអួន ព្រមទាំងទូករបស់អ្នកនេសាទផ្សេងទៀតក៏នៅទីនោះដែរ។

បន្ទាប់ពីបង្រៀនចប់ ព្រះយេស៊ូបានប្រាប់ពេត្រុសឱ្យទម្លាក់អួននៅទឹកជ្រៅ។ ហើយអ្នកដឹងអំពីរឿងនេះហើយ។ គាត់ចាប់ផ្ដើមចាប់បានត្រីជាច្រើន ដែលអួនរបស់គាត់ស្ទើរតែធ្លាយទៅហើយ។ ដូច្នេះ គាត់បានហៅដៃគូរបស់គាត់មកជួយអូសត្រី ហើយព្រះគម្ពីរចែងថាទូកទាំងពីរក៏ស្ទើរតែលិចផងដែរ ដោយសារពួកគេចាប់ត្រីបានយ៉ាងច្រើនសន្ធឹកសន្ធាប់។

> *គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

ឥលូវនេះ ដល់ពេលសួរសំណួរដ៏សំខាន់មួយទៀត៖ តើលោកយ៉ាកុប និងលោកយ៉ូហានមានជំនឿប៉ុណ្ណា ដើម្បីធ្វើឱ្យទូករបស់ពួកគេបានត្រីពេញស្ទើរតែលិចទូកដូច្នេះនោះ?

សូមគិតអំពីការនេះ ពួកគេបាននៅលើច្រាំងជាមួយនឹងអួន។

គឺលោកពេត្រុសទេ ដែលជាអ្នកយល់ព្រមជាមួយព្រះយេស៊ូ។ គាត់គឺជាអ្នកដែលនិយាយថា «*តែខ្ញុំនឹងទម្លាក់អួន តាមពាក្យលោកមើល*» ដូច្នេះចម្លើយដែលត្រឹមត្រូវ គឺគ្មានទេ! យ៉ាកុប និងយ៉ូហាន មិនបានទទួលផលដែលជាត្រីនៅក្នុងទូករបស់ពួកគេ ដោយសារជំនឿរបស់ពួកគេទេ តែដោយសារជំនឿរបស់លោកពេត្រុសវិញ។ លោកពេត្រុសបានហៅដៃគូរបស់គាត់ ដែលនៅមាត់ច្រាំងមកជួយយកត្រី។ អស្ចារ្យណាស់ទូករបស់ពួកគេក៏បានពេញហូរហៀរទៅដោយត្រីយ៉ាងពិតប្រាកដដូចជាទូករបស់លោកពេត្រុសដែរ។

> *លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែបើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។*

ដូច្នេះ ប្រសិនបើជំនឿរបស់ពេត្រុសធ្វើឱ្យពួកគេទទួលបានត្រី ហើយបានត្រីពេញហូរហៀរក្នុងទូករបស់ពួកគេទៅទៀតនោះ តើហេតុអ្វីបានជាទូករបស់លោកយ៉ាកុប និងលោកយ៉ូហានបានត្រីច្រើនដូចជាទូករបស់លោកពេត្រុសដែរ?

អត្ថបទនេះឆ្លើយសំណួរមួយនេះ៖ អត្ថបទនេះប្រាប់យើងថាពួកគេជា*ដៃគូ*គ្នានឹងគ្នា។

និយមន័យនៃពាក្យដៃគូនៅក្នុងវចនានុក្រមអង់គ្លេស Collins គឺ៖

**បុគ្គលដែលមានភាគហ៊ុន ឬមានទំនាក់ទំនងជាមួយអ្នកផ្សេងនៅក្នុងសកម្មភាព ឬការខិតខំប្រឹងប្រែងណាមួយ ជាធម្មតាគឺចូលរួមខាត និងចំណេញជាមួយគ្នានៅក្នុងអាជីវកម្មមួយ។**

ក្រុមហ៊ុនដៃគូគឺជានីតិបុគ្គល ហើយចែករំលែកទាំងនៅក្នុងការខាតបង់ ការចំណាយ និងប្រាក់ចំណេញនៃអាជីវកម្ម។ ដូច្នេះ ពេលលោកពេត្រុសឱ្យទូកទៅព្រះ

យេសូខ្ញី គាត់ពិតជាកំពុងតែផ្ដល់កម្ចីដល់ព្រះយេស៊ូ ធ្វើ*អាជីវកម្ម* ក្នុងន័យផ្លូវច្បាប់ មិនមែនគ្រាន់តែទូករបស់គាត់តែប៉ុណ្ណោះទេ។ តាមច្បាប់អាជីវកម្ម លោកយ៉ាកុប និងយ៉ូហានក៏ជាម្ចាស់ភាគហ៊ុននៃទូកនោះដែរ។ លោកពេត្រុសអនុញ្ញាតឱ្យព្រះយេស៊ូប្រើប្រាស់ទូកគាត់ ហើយដោយសារភាពជាដៃគូរបស់ពួកគេ ទូកទាំងពីរក៏ត្រូវបានបំពេញស្មើៗគ្នា។ លោកយ៉ាកុប និងលោកយ៉ូហាន បាន<u>ប្រមូលផលយ៉ាងពិតប្រាដ</u>ដូចលោកពេត្រុសដែរ។ ទោះបីជាពួកគេមិនមានជំនឿលើស្ថានភាពនោះសោះក៏ដោយ ខ្ញុំហ៊ានភ្នាល់ថាពួកគេក៏រីករាយជាមួយពេត្រុសដែលជាដៃគូរបស់ពួកគេនៅថ្ងៃនោះដែរ។ តើអ្នកគិតយ៉ាងដូចម្ដេចដែរ? ខ្ញុំក៏គិតអ៊ីចឹងដែរ។ ខ្ញុំនឹងផ្ដល់ឧទាហរណ៍ផ្ទាល់ខ្លួនបន្ថែមទៀតដល់អ្នកអំពីគោលការណ៍មួយនេះ។

ឌ្រិនដា និងខ្ញុំ ជាម្ចាស់ដីដ៏ស្រស់ស្អាតចំនួន២៨ហិចតា ដែលមានព្រៃឈើចម្រុះ វាលតក់ និងវាលស្មៅ។ វាជាកន្លែងដ៏ល្អឥតខ្ចោះសម្រាប់បរបាញ់សត្វក្ដាន់។ មានដំណាំដែលបានដាំនៅជុំវិញដីរបស់យើង ហើយព្រៃឈើ និងវាលតក់ ជាមេដៃកធម្មជាតិសម្រាប់ទាក់ទាញសត្វក្ដាន់។

ខ្ញុំបានសាងសង់ការិយាល័យរបស់ខ្ញុំ នៅលើយានដ្ឋានរបស់ពួកយើង ហើយវាមានធ្នើរសៀវភៅធ្វើអំពីឈើ និងឡដុតកម្ដៅមួយផងដែរ។ វាជាកន្លែងស្ងប់ស្ងាត់ កក់ក្ដៅ ជាកន្លែងបែបមនុស្សប្រុស ដែលខ្ញុំចូលចិត្តធ្វើការនៅទីនោះ។ រឿងតែមួយគត់ដែលខ្ញុំតែងតែនឹកដល់ គឺតាំងរូបសត្វក្ដាន់ដែលខ្ញុំបាញ់បាននៅលើតុការិយាល័យរបស់ខ្ញុំ។ និយាយឱ្យត្រង់ទៅ ខ្ញុំមិនដែលចាប់អារម្មណ៍បាញ់សត្វក្ដាន់ដែលមានទំហំធំបែបនេះទេ ក្នុងនាមខ្ញុំជាអ្នកប្រមាញ់យកសាច់ ខ្ញុំមិនដែលបរបាញ់សត្វក្ដាន់ឈ្មោលដែលធំខ្លាំង ដើម្បីបរិភោគឡើយ។

យើងបានរស់នៅទីកន្លែងនោះអស់រយៈពេលប្រាំឆ្នាំមកហើយ មានពេលមួយឌ្រិនដាបានទទូចឱ្យខ្ញុំបាញ់ក្ដាន់ឈ្មោលដ៏ធំមួយសម្រាប់ដាក់តាំងនៅការិយាល័យ

របស់ខ្ញុំ។ រហូតមកដល់ពេលនោះ ខ្ញុំមិនធ្លាប់ឃើញសត្វក្តាន់ឈ្មោលដែលមានទំហំធំនៅដីខ្ញុំសោះ។ ខ្ញុំបានចេញទៅបរបាញ់សត្វក្តាន់គ្រប់រដូវកាល ហើយព្យាយាមបាញ់សត្វក្តាន់ដើម្បីឱ្យបានស្នែងដែលបែកខ្នែងច្រើន ប៉ុន្តែមិនដែលបាញ់បានសត្វក្តាន់ធំណាមួយសោះ។ ខ្ញុំបានគិតថាខ្ញុំគួរតែទៅរៀនបរបាញ់ហើយមើលទៅ។

ប៉ុន្តែនៅឆ្នាំនោះ ដោយសារខ្ញុំកាន់តែគិតអំពីវា ខ្ញុំក៏យល់ស្របជាមួយគ្រិនដា។ ខ្ញុំបានប្រាប់គ្រិនដាថា ខ្ញុំចង់ទៅរកសត្វក្តាន់ឈ្មោលដ៏ធំដើម្បីទទួលបានជ័យជម្នះក្នុងកម្មវិធីការប្រមាញ់សត្វក្តាន់នៅពេលនោះ។ ជាថ្មីម្តងទៀត ខ្ញុំមិនដែលឃើញសត្វក្តាន់ឈ្មោលដ៏ធំនៅក្នុងព្រៃនេះទេ។ បង្អួចផ្ទះបាយរបស់យើងបែរមុខទៅព្រៃ និងទីវាល ប៉ុន្តែខ្ញុំមិនដែលបានឃើញ សូម្បីតែស្រមោលសត្វក្តាន់ឈ្មោលដ៏ធំមួយក៏មិនដែលបានឃើញផង។

ដូច្នេះគ្រិនដា និងខ្ញុំ បានសាបព្រោះសម្រាប់សត្វក្តាន់ឈ្មោលដ៏ធំមួយ។ ខ្ញុំបានសរសេរនៅលើមូលប្បទានបត្រគ្រាប់ពូជរបស់ខ្ញុំ ខ្ញុំបានសាបព្រោះវាសម្រាប់សត្វក្តាន់ដែលមានស្នែងបែកដប់ខ្នែង ឬច្រើនជាងនេះ។ យើងបានអធិស្ឋានសម្រាប់គ្រាប់ពូជនោះរួចហើយ ហើយខ្ញុំបានដាក់វានៅលើតុរបស់ខ្ញុំដើម្បីផ្ញើវាចេញតាមប្រៃសណីយ៍។ ស្រោមសំបុត្រនោះនៅជាមួយខ្ញុំបីថ្ងៃហើយ តែខ្ញុំនៅតែមិនអាចផ្ញើវាចេញបានទេ។ ខ្ញុំបានដឹងថាខ្ញុំមិនមានជំនឿសម្រាប់សត្វក្តាន់ដែលមានស្នែងបែកដប់ខ្នែងទេ។ ខ្ញុំមានជំនឿសម្រាប់តែសត្វក្តាន់ដែលមានស្នែងបែកប្រាំបីខ្នែង ប្រាំមួយខ្នែង ឬបួនខ្នែងនៅថ្ងៃនោះប៉ុណ្ណោះ។ សម្រាប់ខ្ញុំ ខ្ញុំយល់ឃើញថាខ្ញុំមានបញ្ហាក្នុងការមើលឃើញសត្វក្តាន់ឈ្មោលដ៏ធំមួយ និងការអះអាងដោយជំនឿដែលនិយាយថា «ខ្ញុំដឹងថា ខ្ញុំជឿថា ខ្ញុំនឹងបាញ់បានសត្វក្តាន់ឈ្មោលមួយដែលមានស្នែងបែកដប់ខ្នែង ឬច្រើជាងនេះ ពេលខ្ញុំចេញទៅក្រៅ។»

ខ្ញុំមានបទពិសោធគ្រប់គ្រាន់ជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលខ្ញុំអាចដឹងថាខ្ញុំមិនមានជំនឿទេ។ ដូច្នេះ ខ្ញុំបានហែកមូលប្បទានបត្រនោះចោល ហើយជំនួសវាដោយមូលប្បទានបត្រថ្មីមួយទៀត ដែលបានសរសេរថា «សម្រាប់សត្វក្តាន់សត្វក្តាន់ដែលមានស្នែងបែកបួនខ្នែង ឬច្រើនជាងនេះវិញ» ហើយខ្ញុំក៏បានផ្ញើវាតាមប្រៃសណីយ៍ចេញទៅ។

នៅពេលយប់ មុនពេលខ្ញុំចេញទៅក្រៅ ខ្ញុំបានប្រាប់គ្រីនដាអំពីអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំបានប្រាប់នាងថា៖ «ខ្ញុំមិនមានជំនឿថាទទួលបានសត្វក្តាន់ដ៏ធំបែបនេះទេ។» នាងបានមើលមកខ្ញុំ ហើយបាននិយាយថា «*បង*មានជំនឿថានឹងទទួលបានសត្វក្តាន់ ហើយ*ខ្ញុំ*មានជំនឿថាបងនឹងទទួលបានពានរង្វាន់អ្នកប្រមាញ់។ ព្រះជាម្ចាស់ទ្រង់អាចធ្វើលើសពីអ្វីដែលបងសុំ ឬគិតទៅទៀត!»

ពេលព្រឹកព្រលឹមបានចាប់ផ្តើមដោយមានសំឡេងសត្វកំប្រុក និងសត្វស្លាបនៅក្នុងព្រៃប្រទ្បែងគ្នា ហើយក្លិនស្លឹកឈើជ្រុះបានទាក់ទាញអារម្មណ៍ខ្ញុំក្នុងការប្រមាញ់សត្វក្តាន់។ ខ្ញុំបានអង្គុយនៅទីនោះមិនយូរទេ ប្រហែលជា២០នាទី ពេលដែលខ្ញុំបានឮសំឡេងក្តាន់ឈ្មោលកំពុងរត់ចូលក្នុងព្រៃ។ សត្វក្តាន់ឈ្មោលបានកំពុងរត់ឆ្ពោះទៅរកដើមឈើរបស់ខ្ញុំ ហើយខ្ញុំបានត្រៀមខ្លួនដើម្បីបាញ់វា។

ពេលដែលសត្វក្តាន់ឈ្មោលនោះចូលមកកាន់តែជិត ខ្ញុំឃើញថាសត្វក្តាន់ឈ្មោលនោះមានស្នែងបែកបួនខ្នែង។ ជាចំនួនខ្នែងដែលខ្ញុំចង់បាន វាជាសត្វក្តាន់ឈ្មោលដែលមានសាច់ឆ្ងាញ់ពិសា។ សត្វក្តាន់ឈ្មោលនោះឈរក្នុងចំងាយប្រហែល ២៣ ម៉ែត្រ ហើយខ្ញុំក៏បាញ់ព្រួញទៅ។ ខ្ញុំបានឃើញគ្រាប់ព្រួញហោះទៅចំកន្លែងសំខាន់របស់វា ហើយខ្ញុំដឹងថាខ្ញុំបានបាញ់ត្រូវវាហើយ។

សត្វក្តាន់ឈ្មោលនោះបានលោតចូលទៅក្នុងព្រៃ រួចលោតចូលទៅក្នុងចម្ការពោតដែលជាប់នឹងព្រៃនោះ ហើយបាត់ដានវារកមិនឃើញ។ ខ្ញុំនៅតែអាចឮសំឡេងវា

រត់កាត់ចម្ការពោត ខ្ញុំក៏ដឹងថាវានៅមានកម្លាំងនៅឡើយទេ ខ្ញុំអាចត្រូវចំណាយពេលយូរក្នុងការតាមរកវា។ ខ្ញុំបានសម្ងំចាំនៅលើដើមឈើប្រហែល២០នាទី ហើយបន្ទាប់មកក៏សម្រេចចិត្តចុះក្រោម ដើម្បីដើរពិនិត្យរកមើលគ្រាប់ព្រួញ។ ខ្ញុំអាចនិយាបានថាខ្ញុំពិតជាបានបាញ់ត្រូវសត្វក្តាន់ឈ្មោលនោះមែន ព្រោះខ្ញុំបានឃើញដានឈាមរបស់វា។

ពេលខ្ញុំដើរតាមដានឈាមនោះ ខ្ញុំសប្បាយចិត្តព្រោះបានឃើញដានឈាមនោះយ៉ាងច្បាស់។ ប៉ុន្តែ បន្ទាប់ពីបានប្រហែល ៩០ ម៉ែត្រ ដានឈាមនោះបានស្ងួតអស់រលីង។ ខ្ញុំបានព្យាយាមមើលហើយមើលទៀត ប៉ុន្តែរកមិនឃើញសូម្បីតែមួយដំណក់។ បន្ទាប់ពីព្យាយាមរកអស់រយៈពេលពីរម៉ោងរួចមក ខ្ញុំដឹងថាសត្វក្តាន់ឈ្មោលនោះបានទៅបាត់ហើយ។ ខ្ញុំពិតជាអន់ចិត្តជាខ្លាំង។ ទីមួយអារម្មណ៍របស់ខ្ញុំ គឺមិនចង់ឱ្យសត្វក្តាន់ឈ្មោលនោះមានរបួស ហើយរត់បាត់អីចឹងទេ។ ទីពីរ ខ្ញុំអន់ចិត្តជាមួយទឹកដៃនៃការបរបាញ់របស់ខ្ញុំ។

ពេលដែលខ្ញុំឈរក្នុងចម្ការពោត ខ្ញុំក៏សម្រេចចិត្តចាប់ផ្តើមដើរត្រលប់មកផ្ទះវិញ ដោយមានគំនិតមួយថា *ខ្ញុំនៅតែមានឱកាសនៅឡើយទេ ប្រហែលខ្ញុំអាចបាញ់សត្វក្តាន់នៅពេលធ្វើដំណើរមកផ្ទះវិញពេលដើរកាត់តាមចម្ការពោត និងតំបន់វាលភក់។*

ខ្ញុំបានកាន់ស្នារបស់ខ្ញុំ។ ហើយពេលដែលខ្ញុំកំពុងដើរយឺតៗនៅតាមស្មៅមាត់ជ្រោះ ស្រាប់តែមានសត្វក្តាន់មួយក្បាលលោតចេញមកក្រៅនៅចំពីមុខខ្ញុំ។ ខ្ញុំមិនដឹងថាត្រូវធ្វើដូចម្តេចទេ សត្វក្តាន់នោះក៏ឈប់ ហើយមើលមកក្រោយ។ សត្វក្តាន់ដែលខ្ញុំបានឃើញនោះជាសត្វក្តាន់ឈ្មោល។ ខ្ញុំមានអារម្មណ៍ស្ទាក់ស្ទើរបន្តិច ដោយសារខ្ញុំកំពុងពួន ហើយមិនអាចចេញពីកន្លែងពួននោះមកក្រៅបានទេ គឺបានតែអើតមើលសត្វក្តាន់នោះតែបន្តិចប៉ុណ្ណោះ។ ខ្ញុំបានឃើញត្រឹមតែស្នែងរបស់វាតែប៉ុណ្ណោះទេ ខ្ញុំមិនបានដឹងថាវាធំប៉ុនណា ហើយមានស្នែងបែកខ្នែងច្រើនប៉ុណ្ណាទេ។

ខ្ញុំបានដឹងថា ខ្ញុំមានពេលតែមួយភ្លែតទេ ដើម្បីបាញ់សត្វក្ដាន់ឈ្មោលមួយនោះ។ វាហួសពីកម្លាំងចម្ងាយស្នាធម្មតារបស់ខ្ញុំហើយ ដែលមានចម្ងាយប្រហែល៥០ ម៉ែត្រ ហើយវាឈរនៅចំហៀងខ្ញុំ។ ខ្ញុំក៏យឹតស្នាយ៉ាងរលឿន ហើយតម្រង់ចំស្មាមុខរបស់វា ហើយបានបាញ់វា។

សត្វក្ដាន់ឈ្មោលនោះបានដួលចុះភ្លាមៗ ពេលដែលគ្រាប់ព្រួញបានបាញ់ចំត្រូវវា។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើល។ តើវាពិតជាបានកើតឡើងមែនឬ?

ពេលខ្ញុំដើរទៅរកសត្វក្ដាន់ឈ្មោលនោះ ពាក្យដំបូងដែលខ្ញុំបាននិយាយគឺ « ជាជំនឿរបស់ឌ្រិនដា!» សត្វក្ដាន់ឈ្មោលនោះធំណាស់! ខ្ញុំបានរាប់ទៅគឺមានស្នែងបែក ២៦ខ្នែង ហើយវាមានដុះខ្នែងជើងទៀតផង។ ខ្ញុំមិនដែលឃើញសត្វក្ដាន់ឈ្មោលណាដែលធំដូចសត្វក្ដាន់មួយនេះទេ! ខ្ញុំសប្បាយចិត្តរកអ្វីនឹងថ្លែងពុំបាន។

ដូចដែលអ្នកបានគិតអីចឹង ឥលូវនេះសត្វក្ដាន់ឈ្មោលនោះ គឺនៅលើតុនៅក្នុងការិយាល័យរបស់ខ្ញុំហើយ។

ប៉ុន្តែ ខ្ញុំចង់និយាយអំពីសត្វក្ដាន់នេះមួយភ្លែតសិន។ តើហេតុអ្វីបានជាខ្ញុំលើករឿងសត្វក្ដាន់នេះយកមកនិយាយ?

សម្រាប់សត្វក្ដាន់ដែលមានស្នែងបែកបួនខ្នែង វាបានបង្ហាញខ្លួនតាមពេលវេលាដ៏ត្រឹមត្រូវ ទោះបីខ្ញុំបាញ់វាខុសក៏ដោយ។ ប៉ុន្តែឌ្រិនដាបាននិយាថា នាងជឿជាក់ថានឹងបានទទួលពានប្រមាញ់សត្វក្ដាន់។

ឥលូវនេះ នាងមានប្រៀបជាងខ្ញុំហើយ។ នាងមិនធ្លាប់ទៅបរបាញ់សត្វក្ដាន់ទេ ដូច្នេះចំពោះនាង ពានរង្វាន់គួរតែងាយស្រួលទទួលបានទេ ងាយស្រួលដូចសត្វក្ដាន់ដែលមានស្នែងបែកបួនខ្នែងអីចឹងដែរ ដោយសារតែពួកវាគ្រាន់តែជាសត្វក្ដាន់តែប៉ុណ្ណោះចំពោះនាង។ ដោយសារនាងមិនបានចេញទៅបរបាញ់ នាងមិនមានរូបភាពដែលមិនអាចទៅរួចនៅក្នុងគំនិតរបស់នាងទេ។ ខ្ញុំមិនដែលឃើញសត្វក្ដាន់ធំៗដែល

មានដែលមានស្នែងបែកប្រាំបីខ្នែងនៅលើដីរបស់ខ្ញុំទេ ប៉ុន្តែជំនឿរបស់នាងមិនបានផ្អែកទៅលើអ្វីដែលមាន ឬមិនមាននៅក្នុងដីរបស់យើងទេ។ នាងមានជំនឿថាព្រះជាម្ចាស់អាចនាំក្តាន់ដែលមានស្នែងបែកបួនខ្នែងទាំងនោះមកបាន។

ការរបរបាញ់នេះបានកើតឡើងក្នុងរដូវបន្តពូជក្តាន់ ដែលជាពេលដែលសត្វក្តាន់ស្វែងរកដៃគូបន្តពូជ ហើយក្តាន់ឈ្មោលអាចធ្វើដំណើរមកពីចម្ងាយដើម្បីបង្កាត់ពូជ។ ដូច្នេះនៅទីនោះតែងតែជាឱកាសដ៏ល្អដែលយើងអាចឃើញក្តាន់ដែលយើងមិនធ្លាប់បានឃើញពេលដល់រដូវដែលវាបង្កាត់ពូជគ្នា។ អ្នកនឹងអាចឃើញក្តាន់ឈ្មោលដែលជាធម្មតាអ្នកមិនដែលធ្លាប់បានឃើញវានៅក្នុងចម្ការរបស់អ្នកទេ។

ជំនឿរបស់ឌ្រិនដាបាននាំឱ្យខ្ញុំទទួលបានក្តាន់ឈ្មោលមួយនេះ ទោះបីខ្ញុំគ្មានជំនឿសម្រាប់ពានរង្វាន់ក៏ដោយ។

ខ្ញុំចង់ឱ្យអ្នកអានវាម្តងទៀត ខ្ញុំគ្មានជំនឿថានឹងទទួលបានក្តាន់ឈ្មោលពានរង្វាន់បែបនេះទេ។

ខ្ញុំដឹងថាអ្នកកំពុងតែគិតពីអ្វី — *ចាំបន្តិចសិន លោកគ្រូហ្គារី។ ខ្ញុំរៀងច្រឡំបន្តិចហើយ ប្រសិនបើលោកគ្រូគ្មានជំនឿថានឹងទទួលបានក្តាន់ឈ្មោលនោះទេ ចុះហេតុអ្វីបានជាលោកគ្រូបានទទួលវាទៅវិញ?*

ដូចគ្នានឹងទូករបស់លោកយ៉ាកុប និងលោកយ៉ូហានដែរ ដែលទូកពួកគេត្រូវបានបំពេញដោយត្រីដ៏ច្រើនសន្ធឹកសន្ធាប់គឺដោយសារតែជំនឿរបស់លោកពេត្រុស។

នោះគឺជាអំណាចនៃភាពជាដៃគូ។

ខ្ញុំសូមលើកឧទាហរណ៍មួយទៀត ហើយបន្ទាប់មកយើងអាចនិយាយអំពីវាបន្ថែមទៀត។

*ពេលណាខ្ញុំនឹកគិតដល់បងប្អូន ខ្ញុំតែងតែអរព្រះគុណព្រះជាម្ចាស់របស់ខ្ញុំជានិច្ច គឺគ្រប់ពេល ខ្ញុំទូលអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនទាំងអស់គ្នា ខ្ញុំទូលអង្វរដោយចិត្តរីករាយជាដរាប ព្រោះបងប្អូនរួមចំណែកក្នុងការផ្សាយដំណឹងល្អ តាំងពីថ្ងៃដំបូង រហូតមកទល់សព្វថ្ងៃ។ ខ្ញុំជឿជាក់ថា ព្រះអង្គដែលបានចាប់ផ្ដើមធ្វើការល្អនៅក្នុងបងប្អូន ទ្រង់ក៏នឹងបង្ហើយការនេះរហូតដល់ថ្ងៃព្រះគ្រិស្តយេស៊ូយាងមក។*

*ខ្ញុំមានចិត្តគំនិតបែបនេះចំពោះបងប្អូនទាំងអស់គ្នាពិតជាត្រឹមត្រូវមែន ព្រោះចិត្តខ្ញុំនៅជាប់ជំពាក់នឹងបងប្អូនជានិច្ច ហើយទោះបីខ្ញុំនៅជាប់ឃុំឃាំងក្ដី ឬពេលខ្ញុំនិយាយ និងពង្រឹងដំណឹងល្អក្ដី បងប្អូនទាំងអស់គ្នា <u>ក៏បានរួមចំណែកជាមួយខ្ញុំក្នុងកិច្ចការដែលព្រះជាម្ចាស់ប្រណីសន្ដោស ឱ្យខ្ញុំបំពេញនេះដែរ។</u>*

—ភីលីព ១:៣-៧

លោកប៉ូលនិយាយថា គាត់នឹកចាំអំពីក្រុមជំនុំនៅក្រុងភីលីព ដោយអំណរ ដោយសារពួកគេនៅតែបន្តភាពជាដៃគូព័ន្ធកិច្ចជាមួយគាត់។ គាត់បន្តដោយនិយាយថា ដោយសារភាពជាដៃគូរបស់ពួកគេ ឥលូវនេះ ពួកគេបានរួមចំណែកក្នុងព្រះគុណរបស់ព្រះជាម្ចាស់ គឺក្នុងព័ន្ធកិច្ចរបស់គាត់ដែរ។

សូមចាំថា ពេលយើងនិយាយពីព្រះគុណ គឺមានន័យថាវាជាការទទួលអំណាចមកពីព្រះជាម្ចាស់ ឬទទួលបានសមត្ថភាពមកពីព្រះអង្គ។ ប្រសិនបើលោកប៉ូលមិនទទួលបានអំណាច ឬសមត្ថភាពមកពីព្រះជាម្ចាស់ទេ តើគាត់អាចបំពេញកិច្ចការរបស់គាត់បានដែរឬទេ? ក្រុមជំនុំនៅក្រុងភីលីពកំពុងចែករំលែកការចំណាយលើកិច្ចការនេះ ដូចជាលោកយ៉ាកុប និងលោកយ៉ូហានដែរ។ ពួកគេបានចូលរួមនៅក្នុងការចាក់ប្រេងតាំង និងព្រះគុណដែលមាននៅក្នុងកិច្ចការបម្រើរបស់លោកប៉ូល។

ឥលូវនេះ សូមមើលទៅជំពូកទីបួន ហើយអ្នកនឹងឃើញលទ្ធផលដ៏អស្ចារ្យនៃភាពជាដៃគូបានបង្កើតឡើង។

*ទោះជាយ៉ាងណាក្ដី បងប្អូនរួមជាមួយខ្ញុំក្នុងពេលខ្ញុំមានទុក្ខវេទនាដូច្នេះ ជាការប្រសើរណាស់។បងប្អូននៅក្រុងភីលីពអើយ បងប្អូនជ្រាបស្រាប់ហើយថា តាំងពីខ្ញុំបានចាប់ផ្ដើមផ្សព្វផ្សាយដំណឹងល្អគឺតាំងពីខ្ញុំបានចាកចេញពីស្រុកម៉ាសេដូនមកនោះ ក្រៅពីបងប្អូន គ្មានក្រុមជំនុំ*ណាបានជួយខ្ញុំ ក្នុងការចំណាយឬចំណូលឡើយ។ កាលខ្ញុំនៅក្រុងថេស្សាឡូនិក បងប្អូនបានផ្ញើប្រាក់ទៅជួយ តាមសេចក្ដីត្រូវការរបស់ខ្ញុំដល់ទៅពីរបីលើក។ ត្រង់ណេះ មិនមែនមានន័យថា ខ្ញុំប្រាថ្នាចង់បានជំនួយពីបងប្អូនទេ តែខ្ញុំចង់ឱ្យបងប្អូនបានទទួលព្រះពរដ៏បរិបូណ៌។ ខ្ញុំបានទទួលសព្វគ្រប់ទាំងអស់ហើយ ហើយខ្ញុំមានបរិបូណ៌ថែមទៀត ឥលូវនេះខ្ញុំមានរឹតតែច្រើន ដោយបានទទួលអំណោយពីបងប្អូនតាមរយៈលោកអេប៉ាប្រូឌីត។ អំណោយទាំងនេះប្រៀបបីដូចជាក្លិនក្រអូបឈ្ងុយឈ្ងប់ ជាយញ្ញបូជាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ និងយល់ព្រមទទួល។ <u>ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូនស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។</u>*

—ភីលីព ៤:១៤-១៩

លោកប៉ូលទើបតែបានទទួលការផ្គត់ផ្គង់ពីក្រុមជំនុំក្រុងភីលីព។ សូមស្ដាប់អ្វីដែលលោកប៉ូលបាននិយាយត្រលប់ទៅកាន់ពួកគេវិញ *«ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន។»*

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

សូមកត់សម្គាល់ថាលោកប៉ូលមិនបាននិយាយថា «ព្រះ*របស់អ្នក*នឹងបំពេញសេចក្តីត្រូវការរបស់អ្នក ព្រោះអ្នកមានចិត្តសប្បុរសចំពោះខ្ញុំ។» **មិនមែនទេ**! គាត់បាននិយាយថា «ព្រះ*របស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន!*»

អ្នកឃើញទេ អ្នកជឿនៅក្រុងភីលីពជាដៃគូជាមួយលោកប៉ូល ហើយភាពជាដៃគូនេះឯង បានធ្វើឱ្យពួកគេអាចចែករំលែកនៅក្នុងព្រះគុណព្រះជាម្ចាស់ នៅក្នុងកិច្ចការរបស់លោកប៉ូល។ ឥលូវនេះ ដូចដែលលោកយ៉ាកុប និងលោកយ៉ូហានបានចាប់ត្រីទាំងអស់នោះ គឺដោយសារជំនឿរបស់លោកពេត្រុស ហើយលោកប៉ូលកំពុងតែប្រកាសថាសេចក្តីត្រូវការរបស់ពួកគេនឹងត្រូវបានបំពេញដោយសារតែជំនឿរបស់*គាត់*!

ខ្ញុំសង្ឃឹមថាអ្នកអាចឃើញពីអត្ថប្រយោជន៍នៃគោលការណ៍មួយនេះ។

ឧទាហរណ៍ថា អ្នកត្រូវការឡានមួយគ្រឿង ហើយអ្នកគឺជាដៃគូព័ន្ធកិច្ចជាមួយយើង។ ឧទាហរណ៍ទៀតថា ឡាននោះមានតម្លៃ៣០.០០០ដុល្លារ។ ឥលូវនេះ ពេលអ្នកសាបព្រោះចូលទៅក្នុង GaryKeesee.com អ្នកប្រាកដជាដឹងអំពីអត្ថន័យនៃភាពជាដៃគូក្នុងការចូលរួមនៅក្នុងការចាក់ប្រេងតាំង និងព្រះគុណ នៅក្នុងព័ន្ធកិច្ចរបស់យើងហើយ។

ក្នុងនាមជាអ្នកធ្វើព័ន្ធកិច្ច យើងអាចយល់ព្រមបានយ៉ាងងាយក្នុងតម្លៃ៣០.០០០ដុល្លារនេះ ព្រោះថាយើងធ្លាប់មានលុយ៣០.០០០ដុល្លារនេះយូរមកហើយ។ យើងងាយក្នុងការជឿជាក់ថាមានលុយ៣០.០០០ដុល្លារទៀត ព្រោះឥលូវនេះ យើងចំណាយរាប់លានដុល្លារក្នុងមួយឆ្នាំៗ។ ប៉ុន្តែបើកាលពីមុនវិញ ខ្ញុំអាចចាំបានថា ខ្ញុំត្រូវការជំនឿលើព្រះជាម្ចាស់ សម្រាប់ចំនួនទឹកប្រាក់៣០.០០០ដុល្លារ ព្រោះនៅពេលនោះចំនួនលុយប៉ុននេះប្រៀបបីដូចជាភ្នំមួយសម្រាប់ពួកយើងអីចឹងដែរ។

ដូច្នេះ បើអ្នកសួរខ្ញុំថា តើខ្ញុំអាចជឿព្រះជាម្ចាស់ថានឹងរកបានលុយ៣០.០០០ដុល្លារដែរឬទេ? ចម្លើយរបស់ខ្ញុំគឺ ច្បាស់ណាស់ ប្រាកដជាអាចរកបាន។ ដូច្នេះ ដូច

លោកប៉ូលដែរ ពេលយើងមានការព្រមព្រៀងគ្នា ហើយធ្វើជាដៃគូជាមួយគ្នា ខ្ញុំអាចនិយាយបានថា តម្រូវការរបស់អ្នកនឹងត្រូវបានបំពេញ មិនមែនដោយសារជំនឿ*របស់អ្នក*ទេ តែដោយសារ*ជំនឿរបស់ខ្ញុំ*វិញ។

ឥលូវនេះ ច្បាស់ណាស់អ្នកត្រូវមានជំនឿ នៅពេលអ្នកសាបព្រោះគ្រាប់ពូជនោះ ដើម្បីឱ្យបានប្រាក់៣០.០០០ដុល្លារ ហើយអ្នកត្រូវតែមានទំនុកចិត្ត មិនត្រឹមតែនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងខ្លួនអ្នកផងដែរ។ អ្នកគួរតែមានជំនឿលើខ្ញុំ មានទំនុកចិត្តថាខ្ញុំត្រូវបានចាក់ប្រេងតាំង និងការត្រាស់ហៅពីព្រះជាម្ចាស់ ដោយសារខ្ញុំដើរតាមសេចក្តីសុចរិត ហើយអ្នកគួរតែអាចឃើញ*លទ្ធផលដែលបានបង្ហាញ*នៅក្នុងជីវិតរបស់ខ្ញុំ និងនៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំដែរ។ ប្រសិនបើអ្នកក្រឡេកមើលអ្វីដែលយើងកំពុងធ្វើ ហើយដឹងថាយើងបានមកដល់ចំណុចនេះដោយរបៀបណា នោះអ្នកប្រាកដជាដឹងថា ខ្ញុំមានជំនឿសម្រាប់លុយ៣០.០០០ដុល្លារនោះហើយ។

អ្នកប្រហែលជាមិនមានជំនឿសម្រាប់លុយ៣០.០០០ដុល្លារនោះទេ ប៉ុន្តែយើងអាចធ្វើជាដៃគូជាមួយគ្នាបាន ហើយអ្នកនឹងអាចឃើញលទ្ធផលដ៏អស្ចារ្យ។ វាក៏ដូចគ្នាជាមួយការទទួលបានពានរង្វាន់ក្នុងការប្រមាញ់សត្វក្តាន់ឈ្មោលដែរ។ ឌ្រិនដាបាននិយាយនៅយប់មុនពេលខ្ញុំបានចេញទៅបរបាញ់ថា «អ្នកជឿថានឹងបានសត្វក្តាន់ ហើយខ្ញុំជឿថានឹងទទួលបានពាន់រង្វាន់ប្រមាញ់ក្តាន់ឈ្មោល» នេះគឺជាអ្វីដែលដៃគូធ្វើការជាមួយគ្នា។

ដូច្នេះ ខ្ញុំកំណត់ច្បាប់មូលដ្ឋានមួយចំនួននៅទីនេះ ដោយសួរអ្នកនូវសំណួរមួយ៖ បើអ្នកចង់បើកក្រុមហ៊ុនកុំព្យូទ័រមួយ តើអ្នកចង់បានមនុស្សម្នាក់ ដែលគ្មានប្រាក់ ហើយកំពុងសិក្សានៅឆមាសទីមួយផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រមកធ្វើជាដៃគូរបស់អ្នកដែរ

ឬទេ? ឬក៏អ្នកទៅរកមនុស្សម្នាក់ដែលមានលុយរាប់លានដុល្លារ បានកំពុងធ្វើអាជីវកម្មកុំព្យូទ័រ ហើយមានហិរញ្ញវត្ថុដើម្បីជួយអ្នកក្នុងការចាប់ផ្តើមក្រុមហ៊ុនរបស់អ្នក?

ពិតណាស់ មានរឿងជាច្រើននៅទីនេះ ហើយខ្ញុំកំពុងបង្កើតរូបភាពមួយអំពីវាដើម្បីបង្ហាញដល់អ្នក ដើម្បីឱ្យអ្នកកាន់តែយល់ច្បាស់ជាងនេះ។

ប៉ុន្តែខ្ញុំគិតថា វាអាចស្រពិចស្រពិលបន្តិចដែរ តែជម្រើសដ៏ជាក់ស្តែងមួយ គឺអ្នកនឹងជ្រើសរើសនរណាម្នាក់ដែលមានបទពិសោធ និងមានសមទ្ធិផលក្នុងកំណត់ត្រា ហើយម្នាក់នោះមិនមែនជាអ្នកដែលគ្មានលុយនោះទេ! វាដូចគ្នាដែរ ពេលអ្នកចង់សាបព្រោះជាមួយដៃគូព័ន្ធកិច្ច។

សូមកុំយល់ច្រឡំនូវអ្វីដែលខ្ញុំកំពុងនិយាយ ដែលទាក់ទងជាមួយការដឹកនាំរបស់ព្រះជាម្ចាស់ដោយផ្ទាល់ដើម្បីចាប់ដៃគូជាមួយនរណាម្នាក់ឱ្យសោះ។ ការដឹកនាំបែបនេះវាលើសពីអ្វីដែលខ្ញុំកំពុងនិយាយនៅពេលនេះ។ មានពេលជាច្រើនដែលព្រះជាម្ចាស់អាចដឹកនាំអ្នកឱ្យធ្វើជាដៃគូក្នុងកិច្ចការរបស់ទ្រង់ ប៉ុន្តែពេលខ្លះទៀត អ្នកក៏ត្រូវតែជ្រើសរើសដៃគូដោយខ្លួនឯងផងដែរ។ ពេលនេះ ខ្ញុំកំពុងតែនិយាយជាពិសេសអំពីការសាបព្រោះដែលជា*ជម្រើស*របស់អ្នក ដែលអ្នកចង់សាបព្រោះ ព្រោះអ្នកត្រូវការការប្រមូលផល និងមានបំណងប្រាថ្នាចង់ឈានទៅកាន់កម្រិតបន្ទាប់ទៀត។

ខ្ញុំបានសាបព្រោះទៅក្នុងកិច្ចការដែលខ្ញុំជឿជាក់ ក្នុងគោលបំណងពន្លឿនការទទួលថវិកាដែលជាតម្រូវការសម្រាប់ជីវិតខ្ញុំ។ មានច្បាប់មួយដែលខ្ញុំមិនដែលរំលងទេ គឺខ្ញុំតែងតែសាបព្រោះទៅក្នុងកិច្ចការដែលយល់អំពីសេចក្តីជំនឿ និងយល់ព្រមជាមួយខ្ញុំពេលខ្ញុំចង់ពន្លឿនការប្រមូលផលរបស់ខ្ញុំ។ ការសាបព្រោះប្រភេទនេះមានលក្ខណៈ*ជាក់លាក់* ហើយមិនត្រូវច្រឡំវាជាមួយការសាបព្រោះដល់ជនក្រីក្រនោះទេ។ ការសាបព្រោះ ឬការផ្តល់ឱ្យដល់អ្នកខ្វះខាត ឬជនក្រីក្រ គឺជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយនឹងមានការតបស្នងមកវិញ ប៉ុន្តែខ្ញុំកំពុងតែនិយាយអំពីភាពជាដៃគូជាមួយកិច្ច

ការដែលមានភស្តុតាងអំពីជំនឿ ដែលខ្ញុំដឹងថាពួកគេមានសមត្ថភាពអាចធ្វើកិច្ចការនោះបានជាមួយខ្ញុំ។

សូមគិតបែបនេះវិញម្តង៖ ប្រសិនបើខ្ញុំជួបនរណាម្នាក់ដែលបានធ្វើការដោយទទួលបានប្រាក់កម្រៃចំនួន៣ដុល្លារក្នុងមួយម៉ោង ហើយគាត់បានឈប់ធ្វើការងារនោះបន្ទាប់មកគាត់បានយល់ព្រមមកធ្វើការជាមួយខ្ញុំរយៈពេលជាច្រើនឆ្នាំ ដើម្បីទទួលបានប្រាក់កម្រៃចំនួន១០លានដុល្លារក្នុងមួយម៉ោងវិញ តើឱកាសនៃកិច្ចព្រមព្រៀងដ៏ពិសេសនេះអាចកើតឡើងដែរឬទេ? ដោយរបៀបណាដែរ?

ឥលូវនេះ ខ្ញុំអាចធ្វើការបម្រើដល់នរណាម្នាក់បាន ហើយខ្ញុំទទួលបានការត្រាស់ហៅឱ្យធ្វើដូច្នេះ ប៉ុន្តែនៅពេលមានការព្រមព្រៀងគ្នាដើម្បីធ្វើកិច្ចបម្រើ នោះវាត្រូវតែមានកិច្ចព្រមព្រៀងច្បាស់លាស់។ កសិករម្នាក់មិនចេះតែសាបព្រោះលើដីស្រែចម្ការណាក៏បាននោះទេ គាត់ត្រូវស្វែងរកដីដែលត្រឹមត្រូវ ដើម្បីប្រមូលផលតាមអ្វីដែលគាត់ចង់បាន។ ការដែលខ្ញុំកំពុងតែនិយាយនៅពេលនេះ គឺទាក់ទងជាមួយការចាប់ដៃគូធ្វើកិច្ចការនៅលើផែនដីនេះ ជាមួយជំនឿរបស់នរណាម្នាក់ផ្សេងទៀត ឬការចាក់ប្រេងតាំងរបស់នរណាម្នាក់ផ្សេងទៀត។

រឿងមួយទៀតដែលខ្ញុំនឹងគិត ពេលខ្ញុំសាបព្រោះក្នុងកិច្ចការរបស់ព្រះជាម្ចាស់ គឺខ្ញុំពិនិត្យមើលផលផ្លែរបស់វា ខ្ញុំមើលថាតើកិច្ចការនោះមានផលផ្លែដូចជាអ្វីដែលខ្ញុំចង់បានដែរឬទេ។

ជាឧទាហរណ៍ ក្រុមហ៊ុនរបស់ខ្ញុំមានយន្តហោះពីរគ្រឿង។ មុនពេលខ្ញុំទិញយន្តហោះមួយគ្រឿងណាក៏ដោយ ខ្ញុំបានសាបព្រោះនៅក្នុងកិច្ចការរបស់ព្រះជាម្ចាស់ដែលជាព័ន្ធកិច្ចដែលខ្ញុំបានដឹងថាបានចំណាយប្រាក់លើយន្តហោះរាប់សិបលានដុល្លារកាលពីមុន។ ពេលខ្ញុំនិយាយថាចំណាយប្រាក់ច្រើន នោះខ្ញុំមានន័យថាពិតជា*ច្រើន*ពិតមែន ហើយយន្តហោះទាំងនោះត្រូវបានបង់ជាសាច់ប្រាក់សុទ្ធតែម្តង។ ព័ន្ធ

កិច្ចនោះបានបង្ហាញផលផ្លែ ដែលជាយន្តហោះជាច្រើន។ ខ្ញុំដឹងថាពួកគេអាចយល់ព្រមជាមួយខ្ញុំយ៉ាងងាយស្រួលសម្រាប់យន្តហោះមួយគ្រឿង ដោយមានជំនឿថានឹងទទួលបានវា នោះខ្ញុំនឹងបានទទួលវាពិតមែន។ ខ្ញុំនឹងមិនរកដៃគូជាមួយព័ន្ធកិច្ចណាដែលនិយាយថា យន្តហោះនោះថ្លៃណាស់ ឬយើងមិនសមជាម្ចាស់យន្តហោះនោះទេ ឬការមានយន្តហោះគឺមិនល្អទេ។ ការនិយាយបែបនោះ មិនបានបង្ហាញពីកិច្ចព្រមព្រៀងជាមួយគ្នាទេ។ ខ្ញុំមិនចុះកិច្ចព្រមព្រៀងជាមួយព័ន្ធកិច្ចដែលនិយាយបែបនោះទេ ខ្ញុំចុះកិច្ចព្រមព្រៀងជាមួយព័ន្ធកិច្ចណាដែលដឹងថាខ្ញុំកំពុងស្ថិតនៅចំណុចណា ហើយជឿព្រះជាម្ចាស់ជាមួយខ្ញុំសម្រាប់ការមានយន្តហោះមួយគ្រឿង ហើយពួកគេក៏មានផលផ្លែដើម្បីបញ្ជាក់អំពីវាផងដែរ។

ខ្ញុំបានក្លាយជាអ្នកបើកយន្តហោះតាំងពីខ្ញុំមានអាយុ១៩ឆ្នាំមកម្ល៉េះ ហើយធ្លាប់បានរៀនបើកបរនៅលើផ្លូវយន្តហោះចម្ងាយ ៩០០ ម៉ែត្រ មុនពេលហោះឡើង។ ខ្ញុំបានជួលយន្តហោះគេជិះស្ទើរតែពេញមួយជីវិតខ្ញុំទៅហើយ តែថ្ងៃមួយខ្ញុំបានគិតថា ហេ ចុះវាយ៉ាងម៉េចដែរ? *ប្រសិនបើខ្ញុំគ្រាន់តែសាបព្រោះគ្រាប់ពូជមួយ ហើយជឿទុកចិត្តលើព្រះជាម្ចាស់សម្រាប់ការទទួលបានយន្តហោះផ្ទាល់ខ្លួនមួយគ្រឿងវិញនោះ។*

នោះជាអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំដឹងពីយន្តហោះដែលខ្ញុំចង់បានយ៉ាងច្បាស់ ហើយខ្ញុំបានសាបព្រោះសម្រាប់វា ខ្ញុំបានសរសេរចំនួនលុយនៅលើមូលប្បទានបត្រដើម្បីបានយន្តហោះនោះយ៉ាងពិតប្រាកដ ហើយឌ្រិនដា និងខ្ញុំបានយល់ព្រមចំពោះរឿងនេះ។ បន្ទាប់មកយើងបានផ្ញើមូលប្បទានបត្រនោះទៅព័ន្ធកិច្ចមួយដែលខ្ញុំទើបតែលើកឡើង។

ប្រហែលមួយខែកន្លងផុតទៅ ខ្ញុំបានទៅជួបគ្រូពេទ្យប្រចាំខ្លួនរបស់ខ្ញុំ។ ខ្ញុំកំពុងតែនិយាយជាមួយគ្រូពេទ្យរបស់ខ្ញុំនៅថ្ងៃនោះ ហើយគាត់បាននិយាយធម្មតាថា «តើអ្នកមានស្គាល់អ្នកណាម្នាក់ដែលចង់ទិញយន្តហោះដែរឬទេ?»

ខ្ញុំមានការភ្ញាក់ផ្អើលបន្តិចចំពោះសំណួរមួយនេះ ព្រោះខ្ញុំមិនដែលធ្លាប់ឮនរណាម្នាក់សួរខ្ញុំសំណួរមួយនេះទាល់តែសោះ។ ពេលគាត់សួរខ្ញុំថា តើអ្នកមានស្គាល់អ្នកណាម្នាក់ចង់ទិញយន្តហោះដែរឬទេ? ខ្ញុំក៏សួរគាត់វិញថា តើយន្តហោះនោះប្រភេទអ្វីដែរ? វាជាយន្តហោះដែលត្រូវគ្នាជាមួយយន្តហោះដែលខ្ញុំបានសាបព្រោះគ្រាប់ពូជនោះតែម្តង។

ពិតណាស់ រឿងយន្តនោះបានធ្វើឱ្យខ្ញុំចាប់អារម្មណ៍។ ខ្ញុំចង់ទៅមើលយន្តហោះនោះ ដូច្នេះខ្ញុំក៏ទាក់ទងទៅម្ចាស់យន្តហោះនោះ ហើយគាត់បាននាំខ្ញុំឡើងជិះយន្តហោះនោះ។ យន្តហោះនោះគឺល្អខ្លាំងណាស់។ បញ្ហាតែមួយគត់របស់ខ្ញុំនៅពេលនោះ គឺខ្ញុំមិនមានប្រាក់សម្រាប់ទិញវាទេ។

ប៉ុន្តែ ព្រះជាម្ចាស់មានផែនការសម្រាប់យន្តហោះរបស់ខ្ញុំ។ នៅរដូវស្លឹកឈើជ្រុះមុននេះ (ឥលូវនេះគឺខែមីនាហើយ) ខ្ញុំបានទទួលផ្ទះមួយពីឪពុកខ្ញុំ ដែលខ្ញុំនឹងកែផ្ទះនោះឱ្យក្លាយទៅជាការិយាល័យរបស់ខ្ញុំនៅនិទាឃរដូវ។ ឪពុកខ្ញុំបានប្រាប់ខ្ញុំថា គាត់បានបិទទឹកមុនរដូវរងារួចហើយ ហើយខ្ញុំក៏មិនបាច់ទៅពិនិត្យមើលវាទេ។

ប៉ុន្មានថ្ងៃបន្ទាប់ពីខ្ញុំបានទៅមើលយន្តហោះនោះរួចមក បងប្រុសរបស់ខ្ញុំបានទូរសព្ទប្រាប់ខ្ញុំថា ផ្ទះរបស់ខ្ញុំត្រូវបានខូចខាតអស់ហើយ គាត់បានបន្តប្រាប់ខ្ញុំថាពិដានក្នុងផ្ទះទាំងអស់ត្រូវបានបំផ្លាញ ហើយជញ្ជាំងភាគច្រើនបានដួលរលំអស់។

តាមពិតទៅ ទឹកនៅក្នុងផ្ទះនោះមិនបានបិទទេ ហើយបំពង់ទុយោបានកកក្នុងរដូវរងា។ ឥលូវនេះវាជាខែមីនាហើយ ហើយវាឡើងកម្តៅជាងមុន ដូច្នេះទឹកក្នុងទុយោបានហូរចេញមកពេញផ្ទះ មិនដឹងថាតាំងពីពេលណាមកទេ យ៉ាងហោចណាស់ក៏បានហូរពីរបីសប្តាហ៍ហើយដែរ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

អ្វីដែលបងប្រុសខ្ញុំមិនបានដឹងនោះគឺថា ខ្ញុំបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ដើម្បីរុះរើផ្ទះទាំងមូល ទាំងជញ្ជាំង និងផ្នែកខាងក្រៅ ដើម្បីសាងសង់វាឡើងវិញ ដោយច្នៃវាពីផ្ទះទៅជាការិយាល័យថ្មីរបស់ខ្ញុំ។

ឥលូវនេះ ដល់ពេលដែលរឿងល្អបានកើតឡើងហើយ៖ ក្រុមហ៊ុនធានារ៉ាប់រងបានសងសម្រាប់ការខូចខាតដោយសារទឹក ហើយនោះជាសាច់ប្រាក់ដែលខ្ញុំបានយកទៅទិញយន្តហោះរបស់ខ្ញុំ។

យន្តហោះនោះត្រូវបានទិញជាសាច់ប្រាក់សុទ្ធ!

ដូច្នេះ សូមចាំថា ភាពជាដៃគូគឺជាគោលការណ៍ខាងវិញ្ញាណដ៏មានឥទ្ធិពលដែលអ្នកចង់ដឹង ហើយទាញយកប្រយោជន៍ពីពួកវា។

# ជំពូក ៦
# អាថ៌កំបាំងនៃតង្វាយមួយភាគដប់

ខ្ញុំទទួលអ៊ីមែលញឹកញាប់ពីមនុស្សដែលព្យាយាមបញ្ចុះបញ្ចូលខ្ញុំថា ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់—តង្វាយមួយភាគដប់—បានកន្លងផុតទៅ ហើយលែងមានសុពលភាពទៀតហើយ។

ទោះយ៉ាងណាក៏ដោយ ខ្ញុំយល់ថាគោលការណ៍ព្រះរាជ្យនៃព្រះជាម្ចាស់នេះសំខាន់ណាស់ ដែលខ្ញុំបានដាក់ចិត្តដាក់កាយសរសេរជំពូកទាំងមូល។

ប្រសិនបើអ្នកធ្លាប់ទៅក្រុមជំនុំ ខ្ញុំដឹងថា អ្នកធ្លាប់ឮអំពីតង្វាយមួយភាគដប់។ ប៉ុន្តែខ្ញុំក៏ដឹងដែរថា អ្វីដែលអ្នកបានឮគឺប្រហែលជាមិនត្រឹមត្រូវទាំងស្រុងនោះទេ ហើយវាជារឿងសំខាន់ដែលយើងត្រូវកែតម្រូវផ្នត់គំនិតសាសនាចាស់មួយចំនួនអំពីតង្វាយមួយភាគដប់ មុនពេលយើងបន្ត។

ជាដំបូង ប្រសិនបើអ្នកមិនដឹងទេ ពាក្យថា តង្វាយមួយភាគដប់ (Tithe) មានន័យថា «មួយក្នុងចំណោមដប់»។ ពាក្យនេះត្រូវបានគេប្រើដើម្បីពណ៌នាដល់រាស្ត្ររបស់ព្រះជាម្ចាស់អំពីចំនួនប្រាក់ចំណូលរបស់ពួកគេដែលត្រូវថ្វាយដល់កិច្ចការរបស់ទ្រង់ ដែលហៅថា តង្វាយមួយភាគដប់។

ឥលូវនេះ ការពន្យល់អំពីតង្វាយមួយភាគដប់គឺសាមញ្ញ ងាយស្រួលយល់ ហើយខ្ញុំចង់ឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅចំពោះប្រធានបទនេះនៅក្នុងជំពូកនេះ។

ប៉ុន្តែឥលូវនេះ ប្រសិនបើគំនិតនេះថ្មីសម្រាប់អ្នក នេះជាអត្ថន័យគោលនៃពាក្យ « តង្វាយមួយភាគដប់» មានន័យថាថ្វាយតង្វាយមួយភាគដប់ដល់ព្រះជាម្ចាស់។

ទីពីរ នៅពេលមនុស្សភាគច្រើនគិតពីតង្វាយមួយភាគដប់ ពួកគេក៏គិតពីព្រះគម្ពីរសម្ពន្ធមេត្រីចាស់ និងក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលតម្រូវឱ្យប្រជាជនអ៊ីស្រាអែលទាំងអស់ថ្វាយតង្វាយមួយភាគដប់។

សព្វថ្ងៃនេះ មានការភាន់ច្រឡំជាច្រើននៅក្នុងក្រុមជំនុំរបស់ព្រះគ្រិស្តអំពីអត្ថន័យនៃតង្វាយមួយភាគដប់ និងថាតើវានៅតែមានប្រសិទ្ធភាពអនុវត្ត ឬកន្លងផុតទៅជាមួយនឹងការយាងមករបស់ព្រះយេស៊ូដែរឬទេ។

អ្នកប្រហែលជាធ្លាប់បានឮខ្ញុំនិយាយរួចហើយ នៅពេលដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំឱ្យរៀនអស់ពីសមត្ថភាពរបស់ខ្ញុំអំពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ នោះខ្ញុំពិតជាបានក្លាយជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ។ ខ្ញុំចង់ដឹងថាតើអ្វីៗដំណើរការយ៉ាងដូចម្តេច ហើយតង្វាយមួយភាគដប់គឺជាសំណួរធំមួយដែលខ្ញុំត្រូវឆ្លើយ។

ដូច្នេះ សូមយើងមើលអំពីតង្វាយមួយភាគដប់ តើវាមានប្រភពមកពីណា? តើវាមានមុខងារអ្វី? តើហេតុអ្វីបានជាគេអនុវត្តថ្វាយតង្វាយមួយភាគដប់សព្វថ្ងៃនេះ?

ទោះបីជាយើងចាត់ទុកថាតង្វាយមួយភាគដប់សំខាន់ណាស់នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេក៏ដោយ ក៏តង្វាយមួយភាគដប់មិនបានចាប់ផ្តើមជាមួយនឹងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ។ ដើម្បីស្វែងរកប្រភពដើមរបស់តង្វាយមួយភាគដប់ យើងត្រូវត្រលប់ទៅមើលអំពីការចាប់ផ្តើម និងការរស់នៅរបស់អដាំ និងអេវ៉ាវិញ។

ទោះបីជាយើងពិតជាឃើញតង្វាយមួយភាគដប់យ៉ាងលេចធ្លោនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ជាលក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរក៏ដោយ ក៏តង្វាយមួយភាគដប់មិនបានចាប់ផ្តើមជាមួយនឹងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ។ ដើម្បី

ស្វែងរកប្រភពដើមរបស់វា យើងត្រូវត្រលប់ទៅមើលអំពីការចាប់ផ្តើម និងជីវិតរបស់អដាំ និងអេវ៉ាវិញ។

ដូចដែលបានរៀបរាប់ពីមុន <u>អដាំត្រូវបានបង្កើត និងតាំងនៅលើផែនដីជាអ្នកគ្រប់គ្រងលើផែនដីតាងនាមឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់</u>។

*«ព្រះអង្គបានធ្វើឱ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ*

*ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឱ្យនៅក្រោមជើងរបស់គេ»។*

*ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឥតទុកឱ្យមានអ្វីមួយនៅសល់ ដែលពុំបានចុះចូលនោះឡើយ។ ក៏ប៉ុន្តែ នៅពេលនេះ យើងពុំឃើញថា អ្វីៗសព្វសារពើសុទ្ធតែបានចុះចូលនឹងអំណាចរបស់មនុស្សហើយនោះទេ។*

—ហេប្រឺ ២:៧-៨ក

អដាំបានគ្រងមកុដដោយសិរីល្អ និងកិត្តិយស ហើយគ្មានអ្វីនៅលើផែនដីនេះដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ឡើយ។ ពាក្យថា *បានគ្រងមកុដ* បង្ហាញយើងនូវរូបភាពដ៏អស្ចារ្យមួយអំពីរបៀបដែលកិច្ចការនេះដំណើរការ។

ប្រសិនបើអ្នកក្រឡេកទៅមើលស្តេចនៅលើផែនដីនេះ ទ្រង់ពាក់មកុដ ហើយទោះបីជាទ្រង់គ្រាន់តែជាមនុស្សក៏ដោយ មកុដបង្ហាញថារដ្ឋាភិបាលទាំងមូលគាំទ្រពាក្យសម្តីរបស់ទ្រង់។ ដូច្នេះ អដាំក៏បែបនោះដែរ។ គាត់បានគ្រប់គ្រងផែនដីដោយមានអំណាចពេញលេញ ដោយនគរស្ថានសួគ៌គាំទ្រនូវអ្វីៗទាំងអស់ដែលគាត់បានធ្វើ។ យើងត្រូវចងចាំថា អដាំគ្រាន់តែជាមនុស្ស ហើយគ្រប់គ្រងតែតាមរយៈសិទ្ធិអំណាចដែលបានផ្តល់ឱ្យគាត់ប៉ុណ្ណោះ។ គាត់មានសិរីរុងរឿង (អំណាច) និងកិត្តិយស (ឋានៈ និងសិទ្ធិអំណាច) ដោយព្រះរាជ្យរបស់ព្រះជាម្ចាស់គាំទ្រគាត់។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

អ្វីដែលគួរឱ្យចាប់អារម្មណ៍ នោះគឺយើងឃើញសាតាំងនៅលើផែនដីរួចទៅហើយ នៅពេលដែលអដាំត្រូវបានបង្កើត នៅពេលដែលវាត្រូវបានទម្លាក់មកផែនដីមុនពេលព្រះជាម្ចាស់បង្កើតមនុស្ស។ សាតាំងបានមើលងាយមនុស្សលោកដ៏តូចទាបនេះ (តាមធម្មជាតិ) ដែលគ្រប់គ្រងលើវាតាងនាមឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។ សាតាំងចង់រកវិធីដើម្បីយកសិទ្ធិអំណាចនោះពីអដាំ ជាពិសេសដើម្បីលុបចោលសិទ្ធិអំណាចរបស់អដាំក្នុងការគ្រប់គ្រង។

ប្រាកដណាស់ សាតាំងគ្មានអំណាចក្នុងការធ្វើឱ្យចុះខ្សោយ ឬផ្តួលរំលំតំណែងរបស់អដាំឡើយ ដូច្នេះវាត្រូវតែរៀបចំផែនការដើម្បីបញ្ឆោតអេវ៉ាឱ្យជឿថានាងមិនអាចទុកចិត្តព្រះជាម្ចាស់បានឡើយ ហើយថានាង និងអដាំគួរតែបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយធ្វើតាមវា។

ផែនការរបស់សាតាំងបានជោគជ័យ។ អដាំ និងអេវ៉ាបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ហើយបានបាត់បង់សិទ្ធិអំណាចរបស់ពួកគេ។ នៅពេលនោះ ដោយសារអាណាចក្រផែនដីទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អដាំ នោះអដាំបានបណ្តេញព្រះជាម្ចាស់ចេញពីផែនដី រហូតទាល់តែមានសិទ្ធិអំណាចខាងវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយមនុស្សត្រូវបានបំបែកចេញពីព្រះជាម្ចាស់។

មានរឿងជាច្រើនបានកើតឡើងទាក់ទងនឹងខាងព្រលឹងវិញ្ញាណនៅពេលនោះ ប៉ុន្តែខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីនិយាយអំពីនោះនៅក្នុងជំពូកនេះទេ ដោយសារខ្ញុំចង់ផ្តោតលើប្រធានបទរបស់យើងអំពីតង្វាយមួយភាគដប់។ ដូច្នេះ យើងនឹងត្រលប់ទៅមើលនៅពេលដែលអដាំ និងអេវ៉ាបានធ្លាក់ចុះ ហើយយើងស្វែងរកថានឹងមានអ្វីកើតឡើង។

*ព្រះអង្គមានព្រះបន្ទូលមកលោកអដាំថា៖ «ដោយអ្នកបានស្តាប់តាមពាក្យប្រពន្ធ ហើយបរិភោគផ្លែឈើដែលយើងហាមប្រាមនោះដីនឹងត្រូវបណ្តាសា*

*ព្រោះតែអ្នក។ ដូច្នេះ អ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃអស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញ ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើសរហូតដល់ថ្ងៃដែលអ្នកត្រលប់ទៅជាដីវិញដ្បិតអ្នកមានកំណើតមកពីដី។ អ្នកកើតពីធូលីដី អ្នកត្រូវតែត្រលប់ទៅជាធូលីដីវិញ»។*

—លោកុប្បត្តិ ៣:១៧-១៩

ដោយក្រឡេកមើលមួយភ្លែត យើងឃើញថាមនុស្សបាត់បង់ការផ្គត់ផ្គង់ពីព្រះជាម្ចាស់ (ត្រូវបានបណ្តេញចេញពីសួនច្បារ) បន្ទាប់មកគោលបំណងរបស់គាត់គឺធ្វើយ៉ាងណាដើម្បីឱ្យបានរស់ ហើយគាត់រស់ដោយត្រូវរកស៊ីចិញ្ចឹមជីវិតដោយនឿយហត់ និងបែកញើស។ ព្រះជាម្ចាស់ក៏បានប្រាប់គាត់ថា គាត់នឹងត្រលប់ទៅជាធូលីវិញ ហើយថា គាត់នឹងត្រូវ*ស្លាប់* នៅថ្ងៃណាមួយ។ គំនិតនៃការស្លាប់ និងការរស់នៅដោយនឿយហត់ពិតជាចម្លែកណាស់សម្រាប់អដាំ ហើយសេចក្តីភ័យខ្លាច និងភាពអស់សង្ឃឹមបានចូលមកក្នុងលោកិយ។

ដូចដែលអ្នកអាចឃើញ ហើយដូចដែលអដាំបានរកឃើញ លោកិយបានផ្លាស់ប្តូរយ៉ាងខ្លាំង។

ឥលូវនេះ ខ្ញុំចង់ទៅមើលលូកាជំពូក៤ ដែលយើងនឹងរកឃើញមានការផ្លាស់ប្តូរដ៏សំខាន់។

*មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញ នគរទាំងប៉ុន្មាននៅលើផែនដីឱ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឱ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឱ្យអ្នកណាក៏បានស្រេចតែ*

*នឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*

—លូកា ៤:៥-៧

នៅក្នុងអត្ថបទគម្ពីរនេះ សាតាំងបានអះអាងថា ប្រាក់ទាំងអស់ដែលទាក់ទងនឹងនគរផែនដី (ប្រជាជាតិនានា) គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់វា ហើយបញ្ជាក់ថា សិទ្ធិអំណាចនេះត្រូវប្រគល់ឱ្យវា។ ហើយនៅក្នុងពាក្យសម្ដីទាំងនោះរបស់សាតាំង គឺត្រឹមត្រូវហើយ ដោយអដាំជាអ្នកផ្ដល់សិទ្ធិអំណាចនេះដល់វាក្នុងការបះបោររបស់គាត់។

សូមកត់សម្គាល់ខគម្ពីរនេះចែងថា សិរីរុងរឿងទាំងអស់នៃប្រជាជាតិ ឬនគរលោកិយ ទាំងអស់ឥលូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។ តើអ្វីជាសិរីរុងរឿងរបស់ប្រជាជាតិមួយ? គឺ*ទ្រព្យសម្បត្តិ*របស់ប្រជាជាតិនោះ។

ប្រាក់ទាំងអស់នៅក្នុងអាណាចក្រផែនដីមាននគរ និងប្រជាជាតិនៅក្នុងនោះ ដូច្នេះប្រាក់ទាំងអស់គឺជាផ្នែកមួយនៃ ឬស្ថិតក្រោមការគ្រប់គ្រងនៃនគរនៅលើផែនដី។ ឥលូវនេះ សាតាំងអះអាងថា ប្រាក់ ឬទ្រព្យសម្បត្តិនៃប្រជាជាតិនានាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វា ហើយវាអះអាងថាវាអាចផ្ដល់ឱ្យអ្នកណាដែលចង់បានប្រាក់ ឬទ្រព្យសម្បត្តិទាំងនោះ។ និយាយឱ្យសាមញ្ញ សាតាំងទាមទារការគ្រប់គ្រងលើទ្រព្យសម្បត្តិ និងវិបុលភាពនៃប្រជាជាតិនានា។ នេះមានសារៈសំខាន់ខ្លាំងណាស់ នៅពេលដែលយើងនឹងរកឃើញថា តង្វាយមួយភាគដប់មានគោលបំណងជាក់លាក់មួយភ្ជាប់ទៅនឹងតថភាពនោះ។

*លោកអដាំរួមរស់ជាមួយនាងអេវ៉ាជាភរិយា នាងមានផ្ទៃពោះសម្រាលបានកូនមួយ ឈ្មោះកាអ៊ីន នាងពោលថា៖ «ខ្ញុំបានបង្កើតមនុស្សម្នាក់ ព្រោះព្រះអម្ចាស់ប្រទានឱ្យ»។ នាងសម្រាលបានកូនមួយទៀត គឺអេបិល ជាកូនប្អូន។*

*ក្រោយមក លោកអេបិលបានប្រកបរបរជាគង្វាលចៀម រីឯលោកកាអ៊ីនជាអ្នកធ្វើស្រែចម្ការ។ លុះដល់ពេលប្រមូលផលហើយ លោកកាអ៊ីនក៏យកភោគផលពីស្រែចម្ការរបស់គាត់ (មួយចំនួន) មកថ្វាយព្រះអម្ចាស់។ លោកអេបិលក៏បាននាំយកកូនសត្វ ដែលកើតមុនគេបង្អស់ក្នុងហ្វូងសត្វរបស់គាត់ ព្រមទាំងខ្លាញ់របស់វាមកថ្វាយដែរ។ ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងលោកអេបិល ព្រមទាំងតង្វាយរបស់គាត់ តែព្រះអង្គមិនគាប់ព្រះហឫទ័យនឹងលោកកាអ៊ីន ព្រមទាំងតង្វាយរបស់គាត់ទេ។ លោកកាអ៊ីនក្តៅក្រហាយយ៉ាងខ្លាំង ហើយក្រពុលមុខទៀតផង។*

*ព្រះអម្ចាស់មានព្រះបន្ទូលមកលោកកាអ៊ីនថា៖ «ហេតុអ្វីបានជាអ្នកក្តៅក្រហាយ? ហេតុអ្វីបានជាអ្នកក្រពុលមុខដូច្នេះ? ប្រសិនបើអ្នកប្រព្រឹត្តល្អ អ្នកនឹងបានរីករាយឡើងវិញជាមិនខាន ផ្ទុយទៅវិញ បើអ្នកមិនប្រព្រឹត្តល្អទេ បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឱ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ»។*

—លោកុប្បត្តិ ៤:១-៧

មែនហើយ តើនឹងមានអ្វីកើតឡើងនៅទីនោះ? នេះគឺជាជំនាន់ដំបូងនៃកុមារ។ ហេតុអ្វីបានជាគេថ្វាយតង្វាយ? នៅពេលនោះ មិនមានក្រឹត្យវិន័យជាលាយលក្ខណ៍អក្សរចែងថាឱ្យធ្វើដូច្នេះទេ ហេតុអ្វីបានជាគេធ្វើ?

យើងអាចសន្មតថា អដាំ និងអេវ៉ា ឪពុកម្ដាយរបស់ពួកគេ *បានបង្រៀន*ពួកគេឱ្យថ្វាយតង្វាយ។ យើងក៏អាចសន្មតថា ព្រះជាម្ចាស់មិនធ្វើអ្វីៗដើម្បីតែធ្វើពិធីសាសនានោះទេ ហើយត្រូវតែមានហេតុផល*ដោយស្របច្បាប់*ថាហេតុអ្វីបានជាអដាំ និងអេវ៉ាត្រូវបានបង្រៀនឱ្យថ្វាយតង្វាយ។

ប្រសិនបើអ្នកមើលអត្ថបទគម្ពីរខាងលើ អ្នកនឹងឃើញថាមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងអំពីអ្វីដែលកុមារាទាំងពីរបានយកមកថ្វាយព្រះជាម្ចាស់។ ឥលូវនេះ កុំខ្វល់អំពីអ្វីដែលពួកគេត្រូវថ្វាយ គឺម្នាក់ថ្វាយសត្វ និងម្នាក់ទៀតថ្វាយផលដំណាំ ព្រោះនោះមិនមែនជាបញ្ហាទេ។ បញ្ហាគឺ*របៀប*ដែលពួកគេថ្វាយតង្វាយពីអ្វីដែលពួកគេមាន និងមូលហេតុដែលពួកគេថ្វាយតង្វាយនៅទីកន្លែងដំបូង។

សូមកត់សម្គាល់ថា កាអ៊ីនបានថ្វាយផលកើតពីដីនូវ «ចំណែកខ្លះ»។ ប៉ុន្តែ អេបិលបាន «យកកូនជាដំបូង១ពីហ្វូងសត្វមកថ្វាយ ព្រមទាំងខ្លាញ់វាផង»។ តើអ្នកឃើញភាពខុសគ្នាទេ? ក្នុងករណីមួយ គឺ «ចំណែកខ្លះ» បើប្រៀបធៀបទៅនឹង «ចំណែកដ៏ល្អបំផុត» ដែលជាចំណែកខ្លាញ់ពីកូនដំបូងនៃហ្វូងសត្វ។

ហេតុអ្វីអេបិលយកចំណែកខ្លាញ់មកថ្វាយព្រះជាម្ចាស់ ហើយហេតុអ្វីបានជាគាត់យកកូនដំបូង?

ព្រះជាម្ចាស់ច្បាស់ជាបានប្រាប់អដាំអំពីលក្ខខណ្ឌតម្រូវសម្រាប់តង្វាយនេះ។

តើអ្នកឃើញទេ? នេះជាលើកដំបូងដែលមានតង្វាយមួយភាគដប់។

ប្រសិនបើអ្នកសិក្សាអំពីតង្វាយមួយភាគដប់នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ មានន័យថា១០%**ដំបូង**ដែលបានថ្វាយដល់ព្រះជាម្ចាស់ពី**ចំណែកដ៏ល្អបំផុត**។ ក្នុងរឿងនេះ យើងអាចឃើញយ៉ាងច្បាស់ថា អេបិលបានថ្វាយតង្វាយមួយភាគដប់ *ជាដំបូង* និងជា*ចំណែកល្អបំផុត* ។ ទោះជាយ៉ាងណាក៏ដោយ កាអ៊ីនមិនសប្បាយចិត្តដែលបានលះបង់ផលដំណាំ *ខ្លះ* របស់គាត់ ហើយត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ និងសម្រេចចិត្តនាំយក «ចំណែកខ្លះ» នៃផលដំណាំរបស់គាត់ មិនមែនជាចំណែកដំបូងឬចំណែកល្អបំផុតនោះទេ។

ជាក់ស្តែង កាអ៊ីនដឹងពីអ្វីដែលត្រូវថ្វាយ និងរបៀបថ្វាយតង្វាយមួយភាគដប់ដល់ព្រះជាម្ចាស់ដូចដែលព្រះអង្គមានបន្ទូលទៅកាន់គាត់ថា *«ប្រសិនបើអ្នកប្រព្រឹត្តល្អ អ្នកនឹងបានរីករាយឡើងវិញជាមិនខាន ផ្ទុយទៅវិញ បើអ្នកមិនប្រព្រឹត្តល្អទេ បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកឱ្យធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ។»*

ប៉ុន្តែកាអ៊ីនបានបដិសេធការលើកទឹកចិត្តរបស់ព្រះជាម្ចាស់ បែរជាធ្វើអ្វីដែលគាត់បានរៀនពីគេ និងបានសម្លាប់អេបិលជាប្អូន។ ប្រហែលជាគាត់ធ្លាប់គិតកម្ចាត់អេបិលចោល ដើម្បីឱ្យគាត់អាចគ្រប់គ្រងទាំងចម្ការ និងហ្វូងសត្វ ឬភាពលោភលន់របស់គាត់បានល្បួងគាត់ឱ្យយកតែផលដំណាំខ្លះប៉ុណ្ណោះ ដោយចិត្តរបស់គាត់នៅឆ្ងាយពីព្រះជាម្ចាស់។ ខ្ញុំគ្រាន់តែស្មានប៉ុណ្ណោះ។ រឿងមួយដែលយើងដឹងគឺថា កាអ៊ីនមិនចង់ថ្វាយតង្វាយមួយភាគដប់ដូចដែលគាត់បានរៀននោះទេ។

ត្រង់ចំណុចនេះ អ្នកប្រហែលជាកំពុងសួរថា «ហេតុអ្វីបានជាមានតង្វាយមួយភាគដប់ នៅកន្លែងដំបូង? ហេតុអ្វីបានជាព្រះជាម្ចាស់តម្រូវឱ្យពួកគេថ្វាយតង្វាយមួយភាគដប់?» ខ្ញុំនឹងឆ្លើយសំណួរទាំងនោះ ប៉ុន្តែជាដំបូង សូមមើលអ្វីទៀតដែលយើងអាចរៀនអំពីតង្វាយមួយភាគដប់ មុននឹងយើងឆ្លើយសំណួរទាំងនោះ។

ពេលយើងឃើញតង្វាយមួយភាគដប់លើកក្រោយ គឺជាលើកដំបូងដែលពាក្យថា *តង្វាយមួយភាគដប់*ត្រូវបានប្រើ។

> *ក្រោយពេលដែលលោកអាប់រ៉ាមត្រលប់មកពីធ្វើសឹកឈ្នះស្តេចកេដូឡោមើរ និងស្តេចទាំងប៉ុន្មានដែលនៅជាមួយ ស្តេចក្រុងសូដុមក៏ចេញមកទទួលលោកនៅជ្រលងភ្នំសាវេ គឺជ្រលងភ្នំហ្លួង។ ព្រះបាទម៉ិលគីស្សាដែកជាមហាក្សត្រនៅក្រុងសាឡឹម បានឱ្យគេយកនំបុ័ង និងស្រាទំពាំងបាយជូរមកជូនលោកអាប់រ៉ាម។ ស្តេចជាបូជាចារ្យរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត។ស្តេចបានឱ្យពរលោកអាប់រ៉ាមថា៖ «សូមព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលបានបង្កើតផ្ទៃមេឃ និង*

*ផែនដីប្រទានពរដល់លោកអាប់រ៉ាម សូមលើកតម្កើងព្រះដ៏ខ្ពង់ខ្ពស់បំផុត ដែលបានប្រគល់ខ្មាំងសត្រូវទាំងឡាយមកក្នុងកណ្ដាប់ដៃរបស់លោក!»។ លោកអាប់រ៉ាមបានយកអ្វីៗទាំងអស់ដែលលោករឹបអូសបាន មកថ្វាយព្រះបាទម៉ិលគីស្សាដែកមួយភាគដប់។*

—លោកុប្បត្តិ ១៤:១៧-២០

សំណួរដែលយើងត្រូវសួរនៅទីនេះគឺ៖ តើលោកអប្រាហាំដឹងអំពីការថ្វាយតង្វាយមួយភាគដប់ដោយរបៀបណា? និងហេតុអ្វីបានជាគាត់ថ្វាយតង្វាយមួយភាគដប់?

ប្រាកដណាស់ តង្វាយមួយភាគដប់ត្រូវបានដឹងតាំងពីជំនាន់របស់អដាំ។ ហើយយើងដឹងថា តង្វាយមួយភាគដប់ត្រូវបានបង្រៀនដល់អដាំដោយព្រះជាម្ចាស់ផ្ទាល់បន្ទាប់ពីការបះបោរ។ នៅទីនេះយើងឃើញពាក្យពិតប្រាកដមួយ គឺពាក្យមួយភាគដប់ ត្រូវបានប្រើដើម្បីបង្ហាញពីតង្វាយមួយភាគដប់ដែលបានថ្វាយ។

មនុស្សជាច្រើននឹងនិយាយថាតង្វាយមួយភាគដប់គឺជាផ្នែកមួយនៃក្រឹត្យវិន័យរបស់លោកម៉ូសេ មានន័យថាអ្នកជឿព្រះគម្ពីរសម្ពន្ធមេត្រីថ្មីមិនចាំបាច់ថ្វាយតង្វាយមួយភាគដប់ទេ។ ព្រឹត្តិការណ៍ចំនួនពីរដែលខ្ញុំបានលើកឡើងគឺកាអ៊ីន និងអេបិល និងបន្ទាប់មក លោកអប្រាហាំ បង្ហាញថា តង្វាយមួយភាគដប់ត្រូវបានថ្វាយ*មុនពេល*ក្រឹត្យវិន័យរបស់លោកម៉ូសេត្រូវបានសរសេរ។ អូហ៎! ខ្ញុំយល់ស្រប តង្វាយមួយភាគដប់មានចែងនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ហើយប្រជាជាតិអ៊ីស្រាអែលត្រូវបានតម្រូវឱ្យថ្វាយតង្វាយមួយភាគដប់។ ប៉ុន្តែតង្វាយមួយភាគដប់គឺជាអ្វីដែលប្រជាជាតិនេះកំពុងធ្វើរួចទៅហើយ មុនពេលមានលោកម៉ូសេ។

ដូច្នេះ ហេតុអ្វីបានជាតង្វាយមួយភាគដប់មានចែងនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ? នៅពេលដែលក្រឹត្យវិន័យរបស់លោកម៉ូសេត្រូវបានសរសេរ នោះគឺដើម្បី

គ្រប់គ្រងជីវិតទាំងមូលនៃប្រជាជាតិអ៊ីស្រាអែលថ្មីដែលទើបតែចេញពីប្រទេសអេស៊ីប ។ លក្ខខណ្ឌតម្រូវផ្លូវច្បាប់ និងលក្ខខណ្ឌតម្រូវអំពីការគ្រប់គ្រងទាំងអស់មានចែងនៅក្នុងក្រមប្រតិបត្តិជាលាយលក្ខណ៍អក្សរ អំពីរបៀបដែលមនុស្សរស់នៅ។ ដូច្នេះ តង្វាយមួយភាគដប់ត្រូវបានចែងនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ដើម្បីធានាថា ប្រជាជនអ៊ីស្រាអែលអនុវត្តតាមក្រឹត្យវិន័យនេះនៅក្នុងជីវិតរស់នៅរបស់ពួកគេ។ តង្វាយមួយភាគដប់មានសារៈសំខាន់ណាស់ ដល់ម្លេះបានជាព្រះជាម្ចាស់ឱ្យចែងនៅក្នុងក្រឹត្យវិន័យរបស់ប្រជាជាតិអ៊ីស្រាអែល។ យើងនឹងរកឃើញមូលហេតុដែលព្រះជាម្ចាស់ចង់ឱ្យក្រឹត្យវិន័យនេះត្រូវបានសម្រេចភ្លាមៗ ប៉ុន្តែសូមមើលឧទាហរណ៍មួយចំនួនទៀតនៃតង្វាយមួយភាគដប់។

*ឥលូវនេះ ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «ចូររិះគិតអំពីសភាពការណ៍របស់អ្នករាល់គ្នា!។ អ្នករាល់គ្នាសាបព្រោះច្រើនតែច្រូតបានផលតិច។ អ្នករាល់គ្នាបរិភោគ តែមិនចេះឆ្អែត អ្នករាល់គ្នាផឹកស្រា តែមិនចេះស្កប់។ អ្នករាល់គ្នាស្លៀកពាក់ តែមិនកក់ក្ដៅ។ អ្នកធ្វើការទទួលប្រាក់ឈ្នួលតែដូចជាទុកនៅក្នុងថង់កណ្ដាច»។*

*ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «ចូររិះគិតអំពីសភាពការណ៍របស់អ្នករាល់គ្នា។ ចូរនាំគ្នាឡើងទៅលើភ្នំយកឈើមកសង់ដំណាក់របស់យើង។ យើងពេញចិត្តនឹងដំណាក់នេះ ហើយយើងនឹងបង្ហាញសិរីរុងរឿងរបស់យើង»។ នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ «អ្នករាល់គ្នាប្រាថ្នាចង់បានផលច្រើន តែអ្នករាល់គ្នាទទួលបានតិច។ អ្នករាល់គ្នាយកផលនោះមកដាក់ក្នុងផ្ទះ តែយើងបានផ្លុំបំបាត់អស់ទៅ។ ហេតុអ្វីបានជាដូច្នេះ?» គឺមកពីដំណាក់របស់យើងបាក់បែកនៅឡើយ ហើយអ្នករាល់គ្នាគិតតែខ្វះខ្វែងពីរឿងផ្ទះសំបែងរបស់ខ្លួន។ ហេតុនេះហើយបានជាមេឃទប់មិនឱ្យមានភ្លៀងធ្លាក់ ដីក៏មិនផ្ដល់ភោគផលឱ្យអ្នករាល់គ្នាដែរ។យើងនឹងធ្វើឱ្យកើតរាំងស្ងួតគ្មាន*

*ភ្លៀងធ្លាក់នៅក្នុងស្រុក តាមភ្នំ លើស្រែ លើចម្ការទំពាំងបាយជូរ លើចម្ការអូលីវ លើដំណាំងទៀតៗ លើមនុស្ស លើសត្វ។ ដូច្នេះ កិច្ចការទាំងអស់ដែលមនុស្សធ្វើ ឥតបង្កើតបានផលអ្វីឡើយ»។*

—ហាកាយ ១:៥-១១

នៅក្នុងអត្ថបទគម្ពីរនេះ ព្យាការីហាកាយកំពុងស្តីបន្ទោសប្រជាជាតិអ៊ីស្រាអែលចំពោះការមិនបានសង់ព្រះវិហារឡើងវិញ នៅពេលដែលពួកគេត្រលប់មកពីការនិរទេសពីបាប៊ីឡូនវិញ។ គេមិនមានការរីកចម្រើន ខ្វះខាត ដំណាំមិនទទួលបានផលល្អ ប្រជាជាតិទាំងមូលរងទុក្ខ។ ព្រះជាម្ចាស់ប្រាប់ប្រជាជនអ៊ីស្រាអែលឱ្យរិះគិតដោយយកចិត្តទុកដាក់**<u>ចំពោះជីវិតរស់នៅរបស់ពួកគេ</u>** ដោយបញ្ជាក់ថាមានអ្វីមួយដែលពួកគេកំពុងធ្វើ ឬមិនបានធ្វើ ដែលនាំឱ្យមានការខ្វះខាត។

ព្រះជាម្ចាស់មានបន្ទូលថា៖ *«**<u>ហេតុនេះហើយ</u>**បានជាមេឃទប់មិនឱ្យមានភ្លៀងធ្លាក់»។* ទ្រង់មានបន្ទូលថា ទ្រង់នឹងធ្វើឱ្យមានគ្រោះរាំងស្ងួតដោយសារតែអ្វីដែល**<u>ពួកគេ</u>**កំពុងធ្វើ។ ពួកគេបានសង់ផ្ទះរៀងខ្លួន តែទុកឱ្យព្រះវិហារនៅខូចខាត។ នេះបញ្ជាក់ថាពួកគេមិនបានតង្វាយមួយភាគក្នុងដប់ទេ។

ឃើញទេ! តង្វាយមួយភាគដប់ត្រូវយកទៅឱ្យពួកលេវី—បូជាចារ្យ—និងប្រើសម្រាប់ព័ន្ធកិច្ចរបស់ក្រុមជំនុំ។ ដោយសារតង្វាយមួយភាគដប់មិនត្រូវបានគេយកទៅឱ្យពួកលេវី ហើយព្រះវិហារមិនត្រូវបានសាងសង់ នោះព្រះជាម្ចាស់ត្រូវដកព្រះពរចេញដោយសារតែអ្វីដែលពួកគេកំពុងធ្វើ។

អ្នកត្រូវយល់ថា ព្រះជាម្ចាស់មិនមានព្រះហឫទ័យដកព្រះពរចេញពីប្រជាជាតិអ៊ីស្រាអែលទេ។ ទ្រង់មិនមានជម្រើសទេ ព្រោះវាជាបញ្ហាអំពីក្រឹត្យវិន័យទាក់ទងនឹងតង្វាយមួយភាគដប់។

## អាថ៌កំបាំងនៃតង្វាយមួយភាគដប់

នៅពេលយើងបន្តអានក្នុងជំពូកទី២ យើងឃើញថា មនុស្សបានចាប់ផ្ដើមស្ដាប់តាមពាក្យរបស់ព្យាការី។

*«ឥលូវនេះ ចូរសង្កេតមើលអំពីហេតុការណ៍ដែលកើតមានចាប់ពីពេលនេះតទៅខាងមុខ។ មុនពេលអ្នករាល់គ្នាយកថ្មមកដាក់ត្រួតលើគ្នាដើម្បីសង់ព្រះវិហាររបស់ព្រះជាម្ចាស់។ អ្នករាល់គ្នាទៅជង្រុកបម្រុងនឹងកើបស្រូវម្ភៃថាំង នោះឃើញមានតែដប់ថាំងទេ។ អ្នករាល់គ្នាទៅកន្លែងបញ្ជាន់ផ្លែទំពាំងបាយជូរដើម្បីដួសយកស្រាហាសិបធុង នោះឃើញមានតែម្ភៃធុងប៉ុណ្ណោះ។ យើងបានធ្វើឱ្យដំណាំរបស់អ្នករាល់គ្នាខូចខាត ស្រូវអ្នករាល់គ្នាស្កកមានក្រាស៊ី និងមានព្រឹលធ្លាក់មកបំផ្លាញអស់ ទោះបីយ៉ាងនេះក្ដី ក៏អ្នករាល់គ្នាមិនវិលមករកយើងវិញដែរ»*

*នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ «ហេតុនេះចូរសង្កេតមើលហេតុការណ៍ដែលកើតមានចាប់ពីឥលូវនេះតទៅខាងមុខ។ ចាប់តាំងពីថ្ងៃទីម្ភៃបួនក្នុងខែទីប្រាំបួន គឺចាប់ពីថ្ងៃដែលគេចាក់គ្រឹះសង់*

*ព្រះវិហាររបស់ព្រះជាម្ចាស់។ ចូរសង្កេតមើលចុះ! នៅក្នុងជង្រុក គ្មាននៅសល់គ្រាប់ពូជទេ សូម្បីតែចម្ការទំពាំងបាយជូរ ដើមឧទុម្ពរ ដើមទទឹម និងដើមអូលីវក៏មិនផ្ដល់ភោគផលអ្វីដែរ។ ប៉ុន្តែ ចាប់ពីថ្ងៃនេះទៅ យើងនឹងឱ្យពរអ្នករាល់គ្នាបានចម្រុងចម្រើន»។*

—ហាកាយ ២:១៥-១៩

ចាប់តាំងពីពួកគេបានសាងសង់ព្រះវិហារជាលើកដំបូងម្ដងទៀត ព្រះជាម្ចាស់បានប្រាប់ពួកគេឱ្យសម្គាល់ថ្ងៃ និងម៉ោង ព្រោះពួកគេនឹងឃើញមានភាពភាពចម្រុងចម្រើនចំពោះពួកគេកាន់តែច្រើនឡើង។ ទ្រង់ចង់ឱ្យពួកគេសម្គាល់កន្លែងដើម្បីលើកទឹកចិត្ត និងជំរុញពួកគេឱ្យចងចាំពីការផ្លាស់ប្ដូរ ដូច្នេះពួកគេនឹងមិនឈប់ថ្វាយតង្វាយ

មួយភាគក្នុងដប់ម្តងទៀតទេ មិនមែនដើម្បីប្រយោជន៍របស់ទ្រង់ ប៉ុន្តែសម្រាប់ប្រយោជន៍របស់ពួកគេផ្ទាល់។

មានគន្លឹះជាក់ស្តែងចំនួននៅទីនេះដែលនឹងធ្វើឱ្យយើងយល់ភ្លាមៗ ប៉ុន្តែរឿងដំបូងដែលខ្ញុំចង់ឱ្យអ្នកដឹងនោះគឺថា តង្វាយមួយភាគដប់គឺជាបញ្ហា *ទាក់ទងនឹងក្រឹត្យវិន័យ*។ ព្រះជាម្ចាស់ត្រូវ*តែ*ដកព្រះហស្តរបស់ទ្រង់ចេញ នៅពេលដែលពួកគេមិនបានថ្វាយតង្វាយមួយភាគក្នុងដប់ មិនមែនដោយសារទ្រង់*ចង់ធ្វើ*ទ ប៉ុន្តែដោយសារទ្រង់*ត្រូវតែ*ធ្វើ។

*«យើងជាព្រះជាម្ចាស់ យើងមិនប្រែប្រួលទេ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នានៅតែជាកូនចៅយ៉ាកុបដដែល»។ ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «អ្នករាល់គ្នាក៏ដូចដូនតារបស់អ្នករាល់គ្នាដែរ អ្នករាល់គ្នាងាកចេញពីច្បាប់របស់យើង គឺអ្នករាល់គ្នាមិនព្រមកាន់តាមទេ។*

*ចូរនាំគ្នាវិលមករកយើង នោះយើងក៏វិលមករកអ្នករាល់គ្នាវិញដែរ។*

*អ្នករាល់គ្នាពោលថាៈ «យើងខ្ញុំត្រូវវិលមកវិញយ៉ាងដូចម្តេច?»*

*«តើមនុស្សកេងប្រវ័ញ្ចព្រះជាម្ចាស់ដូចម្តេចបាន? អ្នករាល់គ្នាកេងប្រវ័ញ្ចយើង ហើយពោលថា «យើងខ្ញុំកេងប្រវ័ញ្ចព្រះអង្គដូចម្តេចខ្លះ?»*

*គឺអ្នករាល់គ្នាកេងប្រវ័ញ្ចតង្វាយមួយភាគដប់ និងតង្វាយ ដែលអ្នករាល់គ្នាត្រូវញែកទុកសម្រាប់យើង! អ្នករាល់គ្នាត្រូវបណ្តាសាហើយ! ព្រោះប្រជាជាតិទាំងមូលបានកេងប្រវ័ញ្ចយើង»។ ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះជាម្ចាស់បន្ទូលថា៖ «ចូរនាំយកតង្វាយមួយភាគដប់ទាំងប៉ុន្មានមកដាក់នៅក្នុងឃ្លាំងដើម្បីឱ្យមានស្បៀងអាហារក្នុងដំណាក់របស់យើង។ ចូរធ្វើយ៉ាងនេះ ដើម្បីល្បងលយើងទៅ នោះអ្នករាល់គ្នានឹងឃើញថា យើងនឹងបើកផ្ទៃមេឃបង្ហូរ*

*ព្រះពរដ៏លើសលប់មកលើអ្នករាល់គ្នា»។ ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «យើងនឹងរារាំងសត្វល្អិតមិនឱ្យបំផ្លាញដំណាំរបស់អ្នករាល់គ្នា ហើយចម្ការទំពាំងបាយជូររបស់អ្នករាល់គ្នានឹងផ្ដល់គោគផលបរិបូណ៌»។ ព្រះជាម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «ប្រជាជាតិទាំងអស់នឹងពោលថា អ្នករាល់គ្នាពិតជាមានសុភមង្គលមែន ដ្បិតស្រុករបស់អ្នករាល់គ្នានឹងទៅជាស្រុកមួយដ៏សម្បូណ៌សប្បាយ»។*

—ម៉ាឡាគី ៣:៦-១២

ក្នុងជំពូកនេះ យើងឃើញព្យាការីម្នាក់ផ្សេងស្ដីបន្ទោសប្រជាជនអ៊ីស្រាអែលដោយបញ្ជាក់ថា ពួកគេកេងប្រវ័ញ្ចព្រះពរដែលទ្រង់ប្រទានពរដល់រាស្ត្ររបស់ទ្រង់។ ទ្រង់មានបន្ទូលថា ពួកគេ—ប្រជាជាតិទាំងមូល—ត្រូវបណ្ដាសា ដោយសារអ្វីដែលពួកគេ*មិន*បានធ្វើ។ ពួកគេត្រូវបានបង្គាប់ឱ្យយកតង្វាយមួយភាគដប់ទាំងអស់ដាក់ក្នុងឃ្លាំង ដើម្បីឱ្យមានអាហារនៅក្នុងដំណាក់របស់ព្រះជាម្ចាស់។

ម្ដងទៀត តង្វាយមួយភាគដប់ត្រូវយកទៅឱ្យពួកលេវី បូជាចារ្យ។ ប្រជាជនបានយកតង្វាយមួយភាគដប់តែមួយផ្នែកប៉ុណ្ណោះ មិនមែនទាំងអស់ឡើយ (សូមចងចាំពីអំពើបាបរបស់កាអ៊ីន)។ ព្រះជាម្ចាស់កំពុងមានបន្ទូលទៅរាស្ត្ររបស់ទ្រង់ថា ប្រសិនបើពួកគេយកតង្វាយមួយភាគដប់ទាំងអស់មកថ្វាយទ្រង់ នោះពួកគេនឹងទទួលបានព្រះពរពីស្ថានសួគ៌ម្ដងទៀត។ ស្ថានសួគ៌នឹងមានការគ្រប់គ្រង់ដោយស្របច្បាប់លើពួកគេ។ ព្រះជាម្ចាស់មានបន្ទូលប្រាប់ពួកគេថា ប្រសិនបើពួកគេត្រលប់មកឯទ្រង់វិញដោយថ្វាយតង្វាយមួយភាគដប់ នោះគេនឹងទទួលបានព្រះពរដ៏លើសលប់។

ខ្ញុំសូមនិយាយពីចំណុចនេះបន្តិច មុនពេលខ្ញុំបន្តទៅចំណុចផ្សេងទៀត។

រហូតមកដល់ពេលនេះ យើងបានឃើញថា តង្វាយមួយភាគដប់ត្រូវបាននិយាយយ៉ាងច្បាស់លាស់តាំងពីដំបូង ហើយឥលូវនេះយើងអាចដឹងអំពីមូលហេតុ។

នៅក្នុងចំណុចនេះយើងឃើញថា តង្វាយមួយភាគដប់ផ្ដល់ឱ្យព្រះជាម្ចាស់នូវការគ្រប់គ្រង់ដោយស្របច្បាប់លើសត្វល្មិត វាស្ត្ររបស់ទ្រង់ និងបន្ទោសសាតាំង។

ព្រះជាម្ចាស់មានបន្ទូលថា៖ «សាតាំង! ចូរដកដៃរបស់ឯងចេញ! ឯងមិនអាចប៉ះរបស់របររបស់ពួកគេឡើយ!»

ឃើញទេ! នៅពេលដែលអដាំបានជំពប់ដួល នោះសាតាំងចង់បង្អត់អាហារគាត់ឱ្យស្លាប់។ ប៉ុន្តែ ភ្លាមៗនោះ ព្រះជាម្ចាស់បានដាក់តង្វាយមួយភាគដប់ដើម្បីការពារអដាំ និងអេវ៉ា។ ពេលអដាំ និងអេវ៉ាជ្រើសរើសតង្វាយមួយភាគដប់ នោះពួកគេបានដាក់ព្រះជាម្ចាស់ជាមុនបង្អស់។ ពួកគេជ្រើសរើសយកព្រះជាម្ចាស់។

សូមចាំថា សាតាំងបានចូលទៅក្នុងអាណាចក្រផែនដីក្នុងលក្ខណៈដូចគ្នា។ តាមរយៈការបញ្ចុះបញ្ចូលអដាំ និងអេវ៉ាឱ្យជឿលើវា មិនឱ្យជឿព្រះជាម្ចាស់ វាបានចូលមកផែនដីដោយស្របច្បាប់។

**នៅពេលនោះ តង្វាយមួយភាគដប់ត្រូវបានផ្ដល់ដើម្បីធ្វើជាខែលការពារដោយស្របច្បាប់ចំពោះអដាំ និនអេវ៉ា ហើយសព្វថ្ងៃនេះ តង្វាយមួយភាគដប់នៅតែជាខែលការពារដោយស្របច្បាប់ចំពោះយើងរាល់គ្នាដែរ។**

ដូច្នេះ តាមរយៈការថ្វាយតង្វាយមួយភាគដប់ គឺការថ្វាយព្រះជាម្ចាស់១០% នៃអ្វីដែលពួកគេមាន ផ្ដល់ឱ្យព្រះជាម្ចាស់នូវសិទ្ធិស្របច្បាប់ក្នុងការការពារការផ្គត់ផ្គង់ដល់អដាំ និងអេវ៉ា។

យើងត្រូវចាំថាតង្វាយមួយភាគដប់គឺជាក្រឹត្យវិន័យដែលទាក់ទងនឹងការផ្គត់ផ្គង់មនុស្សនៅលើផែនដីក្នុងដែនដីរបស់សាតាំងប៉ុណ្ណោះ។ តង្វាយមួយភាគដប់មិនបានផ្លាស់ប្ដូរស្ថានភាពរបស់ពួកគេទាក់ទងនឹងការស្អាងផ្នែកព្រលឹងវិញ្ញាណឡើងវិញនោះទេ។ ទេ ការថ្វាយយញ្ញបូជាលោះបាបនឹងត្រូវធ្វើឡើងជាមុនសិន មុនពេលការណ៍នោះ

អាចកើតឡើង។ ប៉ុន្តែតង្វាយមួយភាគដប់បានអនុញ្ញាតឱ្យព្រះជាម្ចាស់បញ្ឈប់សាតាំងពីការលួចយកការផ្គត់ផ្គង់ពីពួកគេ ហើយនោះនឹងធ្វើឱ្យគេមានជីវិតរស់នៅលើផែនដី។

មនុស្សជាច្រើននិយាយថា តង្វាយមួយភាគដប់គឺជាក្រឹត្យវិន័យនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ហើយតលូវនេះបានកន្លងផុតទៅហើយ ដោយត្រូវបានបំពេញដោយការសុគតរបស់ព្រះយេស៊ូ។ ប៉ុន្តែយើងបានឃើញថា ក្រឹត្យវិន័យអំពីតង្វាយមួយភាគដប់ត្រូវបានបង្កើតឡើងនៅពេលមនុស្សជំពប់ដួល មុននឹងក្រឹត្យវិន័យរបស់លោកម៉ូសេត្រូវបានសរសេរ។

**នៅពេលនោះ តង្វាយមួយភាគដប់ត្រូវបានផ្តល់ដើម្បីធ្វើជាខែលការពារដោយស្របច្បាប់ចំពោះអដាំ និងអេវ៉ា ហើយសព្វថ្ងៃនេះ តង្វាយមួយភាគដប់នៅតែជាខែលការពារដោយស្របច្បាប់ចំពោះយើងរាល់គ្នាផងដែរ។**

តង្វាយមួយភាគដប់គឺជាក្រឹត្យវិន័យនៃអាណាចក្រផែនដី ហើយនៅតែអនុវត្តដរាបណាសាតាំងបាត់បង់ពីផែនដី ដោយសារតែតលូវនេះវាកំពុងនៅលើផែនដី។ ដរាបណាសាតាំងនៅតែមាន ក្រឹត្យវិន័យនៃតង្វាយមួយភាគដប់នៅតែអនុវត្ត។

រឿងមួយទៀតដែលអ្នកប្រហែលជាឃើញនៅក្នុងក្រុមជំនុំ គឺជាមនុស្សដែលថ្វាយតង្វាយមួយភាគដប់ តែគេមិនទាន់ចម្រុងចម្រើននៅឡើយ។ នេះគឺដោយសារតែការបង្រៀនខុសឆ្គងមួយចំនួនទាក់ទងនឹងតង្វាយមួយភាគដប់។ មនុស្សគិតថា បើពួកគេគ្រាន់តែថ្វាយតង្វាយមួយភាគដប់ នោះព្រះពរពីព្រះជាម្ចាស់នឹងធ្វើឱ្យគេមានភាពចម្រុងចម្រើនដ៏លើសលប់។ នៅពេលគេចាប់ផ្តើមថ្វាយតង្វាយមួយភាគដប់ ហើយមិនឃើញភាពចម្រុងចម្រើនដ៏លើសលប់ នោះគេសន្និដ្ឋានថា តង្វាយមួយភាគដប់មិនមានប្រសិទ្ធភាពឡើយ។ ប៉ុន្តែការសន្មតរបស់ពួកគេមិនត្រឹមត្រូវទេ ហើយយើងត្រូវពិនិត្យមើលឱ្យបានស៊ីជម្រៅលើអត្ថបទនេះ ដើម្បីរកឱ្យឃើញពីមូលហេតុ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ព្រះជាម្ចាស់បានមានបន្ទូលប្រាប់ប្រជាជនថា ប្រសិនបើពួកគេថ្វាយតង្វាយមួយភាគដប់ *«យើងនឹងរារាំងសត្វល្អិតមិនឱ្យបំផ្លាញ**ដំណាំរបស់អ្នករាល់គ្នា** ហើយ**ចម្ការទំពាំងបាយជូររបស់អ្នករាល់គ្នា**នឹងផ្តល់ភោគផលបរិបូណ៌»។*

តើអ្នកឃើញទេ? ខគម្ពីរនេះនិយាយថា ព្រះជាម្ចាស់នឹងបើកផ្ទៃមេឃ ហើយទ្រង់នឹងប្រទានពរដល់ដំណាំ*របស់ពួកគេ*។ ចំណុចដែលខ្ញុំកំពុងធ្វើគឺថា *អ្នក*នៅតែត្រូវដាំអ្វីមួយនៅក្នុងរបងតង្វាយមួយភាគដប់។

តង្វាយមួយភាគដប់មិនធ្វើឱ្យអ្នកចម្រុងចម្រើនឡើយ គឺគ្រាន់តែការពារអ្វីដែលអ្នកធ្វើនៅក្នុងរបងប៉ុណ្ណោះ ដែលជាតង្វាយមួយភាគដប់។

ដូច្នេះ ប្រសិនបើអ្នកមានដើមប៉េងប៉ោះបីដើម នោះវានឹងរីកលូតលាស់។ ប៉ុន្តែប្រសិនបើអ្នកមានតែប៉េងប៉ោះបីដើមនេះ អ្នកនឹងមានរុក្ខជាតិដ៏ល្អចំនួនបីដើម ប៉ុន្តែអ្នកនឹងមិនចម្រុងចម្រើនច្រើនឡើយ។

វាជាអ្វីដែល*អ្នក*សង់ ឬដាំនៅក្នុងរបងដែលធ្វើឱ្យអ្នកទទួលផលដ៏ហូរហៀរ។

អ្វីដែលគួរឱ្យក្រៀមក្រំនោះគឺការបង្រៀនខុសឆ្គង។ រាស្ត្ររបស់ព្រះជាម្ចាស់ជាច្រើនថ្វាយតង្វាយមួយភាគដប់ រួចអង្គុយចាំព្រះពរដ៏ហូរហៀរ។ ព្រះពរដ៏ហូរហៀរនឹងចាប់ផ្តើមនៅពេលដែលយើងយល់ពីដំណើរការនោះ។

ដូច្នេះ ជាថ្មីម្តងទៀត តោះយើងទៅពិនិត្យមើលទាំងអស់គ្នា។

១. តង្វាយមួយភាគដប់បានចូលមកផែនដីជាលើកដំបូងនៅពេលមនុស្សធ្លាក់ចុះ។

២. តង្វាយមួយភាគដប់មានចែងនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ដោយសារក្រឹត្យវិន័យរបស់លោកម៉ូសេបានកំណត់ពីរបៀបដែលប្រជាជនអ៊ីស្រាអែលរស់នៅ។ ព្រះជាម្ចាស់សព្វព្រះទ័យប្រទានពរដល់ពួកគេ ហើយទ្រង់សព្វព្រះហឫទ័យឱ្យចែងអំពីតង្វាយមួយភាគដប់នេះទៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ដើម្បីប្រាកដថា វានៅ

តែត្រូវបានអនុវត្តតាម។ ក្រឹត្យវិន័យអំពីតង្វាយមួយភាគដប់មិនបានកន្លងផុតទៅទេ។ ប៉ុន្តែ មានលក្ខខណ្ឌតម្រូវតាមក្រឹត្យវិន័យក្នុងការថ្វាយតង្វាយមួយភាគដប់។ ឥលូវនេះ យើងមាន*ជម្រើស*ក្នុងការថ្វាយតង្វាយមួយភាគដប់ ហើយទាញយកប្រយោជន៍ពីវា។

៣. ក្រឹត្យវិន័យអំពីតង្វាយមួយភាគដប់គឺជាក្រឹត្យវិន័យនៃអាណាចក្រផែនដី ហើយនឹងនៅត្រូវបានអនុវត្តដរាបណាសាតាំងមិនទាន់បាត់បង់ពីផែនដីនេះ។

៤. តង្វាយមួយភាគដប់មិនធ្វើឱ្យអ្នកចម្រុងចម្រើនដោយស្វ័យប្រវត្តិឡើយ ប៉ុន្តែវាអនុញ្ញាតឱ្យព្រះជាម្ចាស់បញ្ឈប់សាតាំងមិនឱ្យជ្រៀតជ្រែកជាមួយនឹងអ្វីដែលអ្នកកំពុងពង្រីក ឬសាងសង់នៅខាងក្នុងរបងនៃតង្វាយមួយភាគដប់។

៥. តង្វាយមួយភាគដប់មិនធ្វើឱ្យអ្នកទៅស្ថានសួគ៌ ឬមិនបានទៅនោះទេ។ អ្នកនឹងទៅស្ថានសួគ៌ ប្រសិនបើអ្នកអំពាវនាវដល់ព្រះនាមព្រះយេស៊ូ។ ប៉ុន្តែតង្វាយមួយភាគដប់នឹងប៉ះពាល់ភាពចម្រុងចម្រើនរបស់អ្នកនៅលើផែនដីនេះ។

៦. តង្វាយមួយភាគដប់ជាឃ្លាំងរបស់ព្រះជាម្ចាស់។ នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ តង្វាយមួយភាគដប់បានផ្គត់ផ្គង់ និងទំនុកបម្រុងបូជាចារ្យដែលធ្វើការនៅក្នុងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ តង្វាយមួយភាគដប់មិនខុសពីសម័យមុនឡើយ។ តង្វាយមួយភាគដប់គួរតែត្រូវបានថ្វាយទៅឱ្យក្រុមជំនុំរបស់អ្នក។ ព្រះជាម្ចាស់បានកំណត់ឱ្យមានតង្វាយមួយភាគដប់ ដើម្បីផ្គត់ផ្គង់ដល់ព័ន្ធកិច្ចរបស់ទ្រង់។

មានមនុស្សប្រាប់ខ្ញុំថាពួកគេមិនចូលចិត្តក្រុមជំនុំរបស់ពួកគេទេ ហើយសួរថាតើពួកគេត្រូវថ្វាយតង្វាយមួយភាគដប់នៅក្រុមជំនុំនោះឬ? តើអ្នកដឹងទេថាខ្ញុំឆ្លើយដូចម្តេច? ខ្ញុំបានឆ្លើយថា ស្វែងរកក្រុមជំនុំថ្មី ដែលបង្រៀនពីជំនឿ និងព្រះរាជ្យនៃព្រះជាម្ចាស់។

ប្រសិនបើអ្នកទៅក្រុមជំនុំផ្សេងៗគ្នា អ្នកអាចថ្វាយតង្វាយមួយភាគដប់ដល់ព័ន្ធកិច្ចណាមួយដែលកំពុងផ្គត់ផ្គង់អ្នក ប៉ុន្តែប្រសិនបើអ្នកថ្វាយតង្វាយមួយភាគដប់ដល់ក្រុមជំនុំណាមួយដែលអ្នកជាប់នៅ នោះគឺព្រះជាម្ចាស់សព្វព្រះហឫទ័យណាស់។ ជាថ្មីម្តងទៀត ប្រសិនបើមិនមានក្រុមជំនុំល្អណាមួយក្នុងតំបន់នោះទេ អ្នកអាចថ្វាយតង្វាយមួយភាគដប់ទៅក្រុមជំនុំដែលកំពុងផ្គត់ផ្គង់អ្នក។

៧. អ្នកមិនអាចដាក់ឈ្មោះតង្វាយមួយភាគដប់របស់អ្នកបានទេ។ ឧទាហរណ៍ នៅពេលអ្នកថ្វាយតង្វាយមួយភាគដប់របស់អ្នក អ្នកមិនអាចនិយាយថា «ខ្ញុំថ្វាយតង្វាយមួយភាគដប់ជាគ្រាប់ពូជសម្រាប់_______________»។ តង្វាយមួយភាគដប់មានកិច្ចការរបស់វារួចហើយ។ អ្នកអាចដាក់ឈ្មោះចំពោះតង្វាយណាមួយ ប៉ុន្តែមិនមែនតង្វាយមួយភាគដប់ទេ។

៨. តង្វាយមួយភាគដប់គឺ១០% នៃប្រាក់ចំណូលរបស់អ្នក។ នេះគឺ*មុនពេល*បង់ពន្ធ។ តើអ្នកចាំទេថា ព្រះជាម្ចាស់មានបន្ទូលតាមរយៈព្យាការីម៉ាឡាគីថា «ចូរនាំយកតង្វាយមួយភាគដប់*ទាំងប៉ុន្មាន*មកដាក់នៅក្នុងឃ្លាំង។» ប្រាំបួនភាគរយមិនមែនជាតង្វាយមួយភាគដប់ទេ។ ប្រាំមួយភាគរយមិនមែនជាតង្វាយមួយភាគដប់ទេ។ តង្វាយមួយភាគដប់គឺ១០%។ ប្រសិនបើអ្នកនិយាយថា «ខ្ញុំមិនមានលទ្ធភាពថ្វាយ ១០%នោះទេ» ចូរធ្វើអ្វីដែលព្រះជាម្ចាស់បានប្រាប់អ៊ីស្រាអែលឱ្យធ្វើ នៅពេលពួកគេមិនបានយកតង្វាយមួយភាគដប់ទាំងអស់មក៖ ទ្រង់បានមានបន្ទូលថា «ចូរធ្វើយ៉ាងនេះ ដើម្បីល្បងលយើងទៅ»។ ចូរថ្វាយតង្វាយមួយភាគដប់របស់អ្នកដោយជំនឿ ដោយដឹងថាព្រះជាម្ចាស់នឹងសព្វព្រះហឫទ័យនឹងតង្វាយនោះ។

៩. តើខ្ញុំដឹងថាត្រូវថ្វាយតង្វាយមួយភាគដប់សម្រាប់អ្វីដោយរបៀបណា? តាមបទពិសោធរបស់ខ្ញុំគឺថា៖ តើវាជាចំណូលជាប់ពន្ធដែរឬទេ?

១០.បើវាជាចំណូលជាប់ពន្ធ នោះខ្ញុំត្រូវថ្វាយតង្វាយមួយភាគដប់លើប្រាក់ចំណូលនោះ។ តើអាជីវកម្មរបស់ខ្ញុំត្រូវថ្វាយតង្វាយមួយភាគដប់ដែរឬទេ? ជាថ្មីម្តងទៀត តើវាជាប់ពន្ធឬទេ? ខ្ញុំមិនថ្វាយតង្វាយមួយភាគដប់លើប្រាក់ចំណូលដុលនៃអាជីវកម្មរបស់ខ្ញុំទេ។ ខ្ញុំសាបព្រោះពីអាជីវកម្មរបស់ខ្ញុំតាមដែលខ្ញុំចង់ថ្វាយ ប៉ុន្តែនោះមិនមែនជាតង្វាយមួយភាគដប់ទេ។ ប្រសិនបើខ្ញុំដកប្រាក់ចេញពីអាជីវកម្មរបស់ខ្ញុំ នោះខ្ញុំថ្វាយតង្វាយមួយភាគដប់លើប្រាក់ដែលខ្ញុំបានដកចេញពីអាជីវកម្ម។

១២. ចុះបើខ្ញុំមិនមានក្រុមជំនុំនៅពេលនេះ? អ្នកអាចថ្វាយតង្វាយមួយភាគដប់ដល់អ្នកណាដែលផ្គត់ផ្គង់អ្នកខាងព្រលឹងវិញ្ញាណរហូតដល់អ្នករកឃើញក្រុមជំនុំណាមួយ។ មែនហើយ មនុស្សជាច្រើនចាត់ទុកក្រុមជំនុំមួយដែលនៅឆ្ងាយថាជាក្រុមជំនុំចម្បងរបស់ពួកគេតាមរយៈការផ្សាយផ្ទាល់បែបទំនើប និងការផ្សាយបន្តផ្ទាល់តាមហ្វេសប៊ុក។ ប្រសិនបើមិនមានក្រុមជំនុំល្អមួយដែលជឿតាមព្រះគម្ពីរនៅក្នុងទីក្រុងរបស់អ្នក អ្នកអាចថ្វាយតង្វាយមួយភាគដប់ទៅក្រុមជំនុំដែលនៅឆ្ងាយ។ មនុស្សជាច្រើននៅតាមតំបន់ជនបទបានយកក្រុមជំនុំ Faithlifechurch.org ធ្វើជាក្រុមជំនុំរបស់ពួកគេដោយសារអ្វីដែលបានរៀបរាប់ខាងលើ។

តោះ! យើងបន្តទៀត

ព្រះជាម្ចាស់បានបង្ហាញខ្ញុំថា គ្រិស្តបរិស័ទភាគច្រើនថ្វាយតង្វាយមួយភាគដប់របស់ពួកគេដោយជំពាក់ជាវិក្កយបត្រ (សូម្បីតែពួកគេថ្វាយតង្វាយមួយភាគដប់ ហើយភាគច្រើនមិន ថ្វាយក៏ដោយ)។ នេះមានន័យថា ពួកគេមិនមានជំនឿលើអ្វីដែលពួកគេកំពុងធ្វើនោះទេ ប៉ុន្តែគ្រាន់តែដឹងថា ពួកគេជំពាក់តង្វាយមួយភាគដប់ ហើយថ្វាយតង្វាយជាវិក្កយបត្រ។

ខណៈពេលដែលវាជាការល្អក្នុងការថ្វាយតង្វាយមួយភាគដប់របស់អ្នក អ្នកគួរថ្វាយតង្វាយមួយភាគដប់ដោយជំនឿ។ បើមិនដូច្នេះទេ ការថ្វាយតង្វាយរបស់អ្នកកំពុងត្រូវបានជំរុញពីទស្សនៈតាមក្រឹត្យវិន័យ ជំនួសឱ្យទស្សនៈផ្អែកលើជំនឿ។

សូមឱ្យគ្រប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្ហាញដល់អ្នកអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះអ្នក។ តង្វាយមួយភាគដប់មិនមែនជាបន្ទុកដ៏ធ្ងន់ទេ ហើយមិនគួរមានការសោកស្ដាយក្នុងការថ្វាយនោះទេ។ ព្រះជាម្ចាស់មិនព្យាយាម*យក*អ្វីមួយពីអ្នកទេ ប៉ុន្តែទ្រង់កំពុងព្យាយាម*ផ្តល់*អ្វីមួយមកឱ្យអ្នក។ យើងត្រូវតែជឿ និងយល់ពីអត្ថប្រយោជន៍នៃតង្វាយមួយភាគដប់ ហើយអរសប្បាយចំពោះតង្វាយនោះចុះ។ តង្វាយមួយភាគដប់គឺជាសកម្មភាពនៃការថ្វាយបង្គំដែលប្រកាសថាព្រះជាម្ចាស់ជាប្រភពរបស់យើង។ នៅពេលដែលយើងថ្វាយតង្វាយមួយភាគដប់ វាមានអត្ថប្រយោជន៍ដែលបានកំណត់យ៉ាងច្បាស់ថា យើងគួរមានជំនឿក្នុងការទទួលបានអត្ថប្រយោជន៍នោះ។

ខ្ញុំតែងតែស្នើឱ្យគ្រួសារនីមួយៗត្រៀមតង្វាយមួយភាគដប់របស់ពួកគេ នៅពេលពួកគេមកក្រុមជំនុំ។ មុនពេលពួកគេមកក្រុមជំនុំ ខ្ញុំក៏បានស្នើផងដែរថា ពួកគេគួរតែដាក់ដៃលើតង្វាយមួយភាគដប់នោះ ប្រកាសពីអត្ថប្រយោជន៍របស់វា ហើយប្រកាសថាព្រះជាម្ចាស់នឹងបើកផ្ទៃមេឃ ហើយថាសាតាំងត្រូវបានរារាំងមិនឱ្យបំផ្លាញដំណាំរបស់ពួកគេ។ ពួកគេក៏គួរប្រកាសថា សាតាំងមិនអាចលួចពីពួកគេ ហើយអ្វីដែលពួកគេដាក់ដៃទៅលើនឹងចម្រុងចម្រើនក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។

ឥលូវនេះ ជាចុងក្រោយ ខ្ញុំសូមបញ្ចប់ការពិភាក្សារបស់យើងអំពីតង្វាយមួយភាគដប់ ដោយមើលទៅលើតង្វាយមួយភាគដប់ដូចដែលបានកត់ត្រានៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី។ អូហ៎! មែនហើយ តង្វាយមួយភាគដប់ត្រូវបានលើកឡើងនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី! អត្ថបទគម្ពីរខាងក្រោមគឺជាកន្លែងដែលយើងអានពីមុន។

*ក្រោយពេលដែលលោកអាប់រ៉ាមត្រលប់មកពីធ្វើសឹកឈ្នះស្តេចកេដូឡោមើរ និងស្តេចទាំងប៉ុន្មានដែលនៅជាមួយ ស្តេចក្រុងសូដុមក៏ចេញមកទទួលលោកនៅជ្រលងភ្នំសាវេ គឺជ្រលងភ្នំហ្លួង។ ព្រះបាទម៉ិលគីស្សាដែកជាមហាក្សត្រនៅក្រុងសាឡឹម បានឱ្យគេយកនំប៉័ង និងស្រាទំពាំងបាយជូរមកជូនលោកអាប់រ៉ាម។ ស្តេចជាបូជាចារ្យរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត។ស្តេចបានឱ្យពរលោកអាប់រ៉ាមថា៖ «សូមព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលបានបង្កើតផ្ទៃមេឃ និងផែនដីប្រទានពរដល់លោកអាប់រ៉ាម។ សូមលើកតម្កើងព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលបានប្រគល់ខ្មាំងសត្រូវទាំងឡាយមកក្នុងកណ្តាប់ដៃរបស់លោក!»។ <u>លោកអាប់រ៉ាមបានយកអ្វីៗទាំងអស់ដែលលោករឹបអូសបាន មកថ្វាយព្រះបាទម៉ិលគីស្សាដែកមួយភាគដប់</u>។*

—លោកុប្បត្តិ ១៤:១៧-២០

ឥលូវនេះ សូមមើលអ្វីដែលអ្នកសរសេរគម្ពីរហេព្រើនិយាយអំពីតង្វាយមួយភាគដប់។

*ព្រះបាទម៉ិលគីស្សាដែកនេះ ជាព្រះមហាក្សត្រនៅក្រុងសាឡឹម និងជាបូជាចារ្យរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ទ្រង់បានទៅជួបលោកអប្រាហាំ ដែលវិលមកពីវាយឈ្នះស្តេចនានា ហើយទ្រង់ជូនពរលោក។ លោកអប្រាហាំបានយកអ្វីៗទាំងអស់ដែលលោកមានចំនួនមួយភាគដប់ មកថ្វាយព្រះបាទម៉ិលគីស្សាដែក។ ព្រះនាមរបស់ស្តេចអង្គនេះមានន័យថា«ស្តេចប្រកបដោយសេចក្តីសុចរិត» ហើយទ្រង់ជាស្តេចក្រុងសាឡឹមថែមទៀត ដែលមានន័យថា «ស្តេចនៃសេចក្តីសុខសាន្ត»។ ទ្រង់គ្មានមាតាបិតា និងគ្មានវង្សត្រកូលទេ ហើយជីវិតរបស់ស្តេច ក៏គ្មានដើមកំណើត និងចុងបញ្ចប់ដែរ។ ទ្រង់ដូចព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយស្ថិតនៅជាបូជាចារ្យរហូតតរៀងទៅ។*

> *សូមបងប្អូនពិចារណាមើលចុះ ព្រះបាទម៉ិលគីស្សាដែកនេះមានឋានៈធំប៉ុនណា បានជាលោកអប្រាហាំបុព្វបុរសរបស់យើង យកអ្វីៗដែលលោករឹបអូសបានពីចំបាំងចំនួនមួយភាគដប់មកថ្វាយដូច្នេះ! អស់អ្នកក្នុងពូជពង្សរបស់លោកលេវីដែលបានទទួលមុខងារជាបូជាចារ្យនោះ ក៏បានទទួលបញ្ជាឱ្យហូតយកតង្វាយមួយភាគដប់ពីប្រជាជន ស្របតាមក្រឹត្យវិន័យ គឺហូតយកពីអស់អ្នកជាសាច់ឈាមរបស់ខ្លួន ដែលជាពូជពង្សរបស់លោកអប្រាហាំដូចគ្នា។ ចំណែកឯព្រះបាទម៉ិលគីស្សាដែកវិញ លោកគ្មានជាប់សាច់ញាតិអ្វីនឹងកូនចៅលោកលេវីទេ តែលោកបានយកទ្រព្យចំនួនមួយភាគដប់ពីលោកអប្រាហាំ! ទ្រង់ក៏ជូនពរដល់លោកអប្រាហាំដែលបានទទួលព្រះបន្ទូលសន្យា! ធម្មតាអ្នកទទួលពរមានឋានៈតូចជាងអ្នកឱ្យពរ ត្រង់ចំណុចនេះ យើងពុំអាចប្រកែកបានឡើយ។ លោកលេវីដែលទទួលតង្វាយមួយភាគនោះ ជាមនុស្សតែងតែស្លាប់។ រីឯព្រះបាទម៉ិលគីស្សាដែកវិញ ទ្រង់មានព្រះជន្មរស់ដូចគម្ពីរបានបញ្ជាក់ស្រាប់។*
>
> —ហេប្រឺ ៧:១-៨

សូមកត់សម្គាល់ថាអត្ថបទនេះនិយាយថា *«លោកលេវីដែលទទួលតង្វាយមួយភាគនោះ ជាមនុស្សដែលរមែងតែងតែស្លាប់»* ដែលសំដៅទៅលើពួកលេវីនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់។ ខគម្ពីរនេះក៏និយាយបន្ថែមថា៖ «រីឯព្រះបាទម៉ិលគីស្សាដែកវិញ ***ទ្រង់មានព្រះជន្មរស់ដូចគម្ពីរបានបញ្ជាក់ស្រាប់***»។

ម៉ិលគីស្សាដែកជាស្ដេចនៃសេចក្ដីសុចរិត ជាស្ដេចនៃសេចក្ដីសុខសាន្ត ទ្រង់គ្មានមាតាបិតា និងគ្មានវង្សត្រកូលទេ ហើយជីវិតរបស់ស្ដេច ក៏គ្មានដើមកំណើត និងចុងបញ្ចប់ដែរ ទ្រង់មានលក្ខណៈដូចជាព្រះរាជបុត្រានៃព្រះជាម្ចាស់ ជាបូជាចារ្យជារៀង

រហូត។ ម៉ិលគីស្សាដែកគឺជាព្រះយេស៊ូគ្រិស្ត ឈរនៅមុខអប្រាហាំនៅថ្ងៃនោះ។ ទោះជាយ៉ាងណា គេមិនស្គាល់ទ្រង់ថាជាព្រះយេស៊ូនៅពេលនោះទេ នៅពេលនោះ។

តើអ្នកចាំទេថា មានទេវតាទៅប្រាប់យ៉ូសែបឱ្យដាក់ឈ្មោះទារកនោះថា យេស៊ូ នៅពេលដែលទ្រង់ប្រសូតមក។ ព្រះនាមព្រះយេស៊ូ មានន័យថាព្រះអង្គសង្គ្រោះ ដូច្នេះហើយ បង្ហាញតាមរយៈព្រះនាមទ្រង់ថាទ្រង់ជានរណាសម្រាប់យើង។ ព្រះគ្រិស្តមិនមែនជានាមត្រកូលរបស់ព្រះយេស៊ូទេ។ នៅពេលយើងនិយាយថាព្រះយេស៊ូគ្រិស្ត យើងនិយាយតាមន័យត្រង់ថាព្រះអង្គសង្គ្រោះដែលបានចាក់ប្រេងតាំង។ ព្រះយេស៊ូមិនត្រូវបានគេស្គាល់ដោយព្រះនាមថា ព្រះយេស៊ូឡើយ នៅពេលទ្រង់ឈរនៅចំពោះមុខអប្រាហាំ ព្រោះផែនការនោះនៅតែត្រូវបានលាក់កំបាំងពីសាតាំងនៅពេលនោះ។

ដូច្នេះ ឈ្មោះម៉ិលគីស្សាដែក គឺជាឈ្មោះដែលឆ្លុះបញ្ចាំងយ៉ាងសាមញ្ញថាទ្រង់ជានរណា ស្តេចនៃសេចក្តីសុចរិត និងជាព្រះអង្គម្ចាស់នៃសេចក្តីសុខសាន្ត។ ទោះយ៉ាងណាក៏ដោយ តាមបទទំនាយ ស្តេចម៉ិលគីស្សាដែកបានប្រកាសអំពីអនាគតរបស់អប្រាហាំ ដោយផ្តត់ផ្គង់នំប៉័ង និងស្រាទំពាំងបាយជូរដល់គាត់ ដែលនិយាយអំពីសម្ពន្ធមេត្រីថ្មី (នំប៉័ង រូបកាយរបស់ទ្រង់បានបំបែកសម្រាប់យើងរាល់គ្នា និងស្រាទំពាំងបាយជូរ លោហិតរបស់ទ្រង់បានហូរសម្រាប់យើងរាល់គ្នា) ដែលនឹងធ្វើឡើងដោយទាយាទរបស់លោកអប្រាហាំនៅពេលក្រោយ ហើយនឹងបំពេញតាមការសន្យាដែលព្រះជាម្ចាស់បានប្រទានដល់អប្រាហាំទាក់ទងនឹងទាយាទរបស់គាត់នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទី១២។

ទាក់ទងនឹងតង្វាយមួយភាគដប់ ព្រះគម្ពីរហេព្រើចែងថា ឥលូវនេះតង្វាយមួយភាគដប់ត្រូវបានប្រមូលដោយ «ទ្រង់មានព្រះជន្មរស់ដូចគម្ពីរបានបញ្ជាក់ស្រាប់»។ ឥលូវនេះ គឺព្រះយេស៊ូដែលជាអ្នកប្រមូលតង្វាយមួយភាគដប់ ជាអ្នកដែលត្រូវប្រកាស

ថាមានព្រជន្មរស់! ទ្រង់ជាស្តេចលើសអស់ទាំងស្តេច និងជាព្រះអម្ចាស់លើសអស់ទាំងអម្ចាស់។

**តង្វាយមួយភាគដប់គឺជារបងការពារជីវិតរបស់អ្នកដោយស្របច្បាប់ ដែលបញ្ឈប់អារក្សសាតាំងមិនឱ្យលួចយកការផ្គត់ផ្គង់ចេញពីអ្នក។**

ដូច្នេះចូរចាំថា ក្រឹត្យវិន័យអំពីតង្វាយមួយភាគដប់គឺនៅតែមានប្រសិទ្ធភាពអនុវត្តសព្វថ្ងៃនេះ។ រឿងតែមួយគត់ដែលបានផ្លាស់ប្តូរគឺមុខងារជាបូជាចារ្យ។ នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ កុលសម្ពន្ធលេវីបានប្រមូលតង្វាយមួយភាគដប់សម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។ សព្វថ្ងៃនេះ ព្រះយេស៊ូ (ដែលមកពីកុលសម្ពន្ធយូដាមិនមែនលេវី ដែលបង្ហាញថា បទបញ្ញត្តិថ្មីមួយអំពីមុខងារជាបូជាចារ្យត្រូវបានបង្កើតឡើង) ប្រមូលតង្វាយមួយភាគដប់ពីក្រុមជំនុំរបស់ទ្រង់សម្រាប់ការងារព័ន្ធកិច្ចរបស់ទ្រង់។ ប្រាកដណាស់ ខ្ញុំដឹងថាព្រះយេស៊ូមិននៅទីនេះដោយផ្ទាល់ ដើម្បីប្រមូលតង្វាយមួយភាគដប់នោះទេ។ ប៉ុន្តែសូមចាំថា ព្រះគម្ពីរចែងថា ក្រុមជំនុំគឺជារូបកាយរបស់ព្រះគ្រិស្ត មានន័យថា ការសម្តែងតាមក្រឹត្យវិន័យរបស់ទ្រង់នៅទីនេះ ដូចជារូបកាយរបស់យើង ផ្តល់ឱ្យយើងនូវការសម្តែងចេញតាមក្រឹត្យវិន័យនៅទីនេះដែរ។ នៅពេលដែលយើងថ្វាយដល់ក្រុមជំនុំរបស់ទ្រង់ រូបកាយរបស់ទ្រង់ យើងពិតជាថ្វាយដល់ព្រះយេស៊ូ។ ក្រោមសម្ពន្ធមេត្រីចាស់ ពួកលេវីបានប្រមូលតង្វាយមួយភាគដប់ក្នុងនាមព័ន្ធកិច្ចរបស់ព្រះជាម្ចាស់នៅពេលនោះ ហើយក្រុមជំនុំប្រមូលតង្វាយមួយភាគដប់ក្នុងនាមព័ន្ធកិច្ចរបស់ព្រះជាម្ចាស់នាពេលបច្ចុប្បន្ននេះ។

សរុបសេចក្តីមក តង្វាយមួយភាគដប់គឺជារបងការពារជីវិតរបស់អ្នកដោយស្របច្បាប់ ដែលបញ្ឈប់អារក្សសាតាំងមិនឱ្យលួចយកការផ្គត់ផ្គង់ចេញពីអ្នក។ សូមចាំថា តង្វាយមួយភាគដប់មិនធ្វើឱ្យអ្នកចម្រុងចម្រើនឡើយ! ភាពចម្រុងចម្រើនរបស់អ្នកត្រូវបានកំណត់ដោយអ្វីដែលអ្នកធ្វើនៅ*ខាងក្នុង*របងនោះ!

## អាថ៌កំបាំងនៃតង្វាយមួយភាគដប់

តង្វាយមួយភាគដប់គឺជាច្បាប់ដែលមានសារៈសំខាន់សម្រាប់ជីវិតផ្នែកហិរញ្ញវត្ថុរបស់អ្នក។ នេះជាមូលហេតុដែលខ្ញុំចំណាយពេលច្រើនដើម្បីនិយាយអំពីក្រឹត្យវិន័យដ៏សំខាន់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។

ដូច្នេះ លើកក្រោយ នៅពេលដែលអ្នកនៅក្រុមជំនុំហើយគ្រូគង្វាលនិយាយថា ដល់ពេលទទួលតង្វាយមួយភាគដប់ហើយ អ្នកគួរតែស្រែកដោយអំណរ ព្រោះឥលូវនេះអ្នកដឹងពីអត្ថប្រយោជន៍នៃតង្វាយមួយភាគដប់ហើយ។

# ជំពូក ៧

# អ្នកត្រូវការកាបូបមួយ - ផ្នែកទីមួយ

មិត្តសម្លាញ់របស់ខ្ញុំម្នាក់ឈ្មោះ ភីធើរ ម៉តលុក គឺជាគ្រូគង្វាលនៅក្រុមជំនុំ City Impact Church នៅក្នុងទីក្រុងអូកឡេន ប្រទេសនូវែលសេឡង់។ គាត់បានបង្កើតព័ន្ធកិច្ចដ៏អស្ចារ្យ និងក្រុមជំនុំធំជាងគេមួយក្នុងចំណោមក្រុមជំនុំធំៗនៅប្រទេសនូវែលសេឡង់។

តាមរយៈមិត្តភាពរបស់យើងជាច្រើនឆ្នាំ យើងបានធ្វើដំណើរកម្សាន្តតាមម៉ូតូប្រហែលជា២០ដងនៅទូទាំងប្រទេសអាមេរិកខាងជើង និងប្រទេសនូវែលសេឡង់។ គាត់គឺជាអ្នកចុងក្រោយដែលបានណែនាំខ្ញុំឱ្យទិញម៉ូតូម៉ាកហាលី។ ខ្ញុំធ្លាប់ជិះម៉ូតូហុងដា អស់ជាច្រើនឆ្នាំ ប៉ុន្តែនៅពេលដែលយើងធ្វើដំណើរ គាត់តែងតែទទូចឱ្យខ្ញុំជួលម៉ូតូម៉ាកហាលីជិះទៅ។ ពីដំបូងខ្ញុំមិនចូលចិត្តម៉ាកហាលី ដូចម៉ាកហុងដារបស់ខ្ញុំទេ ប៉ុន្តែបើអ្នកស្គាល់ម៉ូតូម៉ាកហាលីឱ្យបានច្រើននោះ អ្នកនឹងដឹងថាម៉ូតូនេះបានផ្លាស់ប្តូរផ្នែកសំខាន់ៗមួយចំនួនដែលបានរចនាឡើងកាលពីប៉ុន្មានឆ្នាំមុននេះ ដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាខ្លាំង។ ដូច្នេះកាលពីឆ្នាំមុន ឌ្រិនដាបានទិញម៉ូតូហាលីស៊េរីថ្មីមួយឱ្យខ្ញុំ ដែលយើងពិតជាចូលចិត្តជិះវាខ្លាំងណាស់។

ក្នុងអំឡុងពេលយើងជិះម៉ូតូនេះ ខ្ញុំបានកត់សម្គាល់ឃើញថាគ្រូគង្វាលភីធើរ តែងតែមានកាបូបស្បែកជាប់នឹងខ្លួន ខ្ញុំហៅវាថាជាកាបូបបុរស ដែលស្ពាយនៅនឹងស្មារបស់គាត់។ បន្ទាប់ពីមានការចុកស្រេពន់ដោយសារការជិះម៉ូតូពេញមួយថ្ងៃរួចមក ខ្ញុំបានសួរនាំអំពីការបូបរបស់គាត់។ ពិតណាស់ ការពិភាក្សានោះនាំឱ្យគាត់ទិញកាបូប

មួយសម្រាប់ខួបកំណើតរបស់ខ្ញុំ។ កាបូបនោះមិនពេញនិយមទេមិនថានៅអឺរ៉ុប ឬនៅប្រទេសនូវែលសេឡង់ ប៉ុន្តែខ្ញុំស្រលាញ់វា។

ជាធម្មតា ខ្ញុំតែងតែបាត់វ៉ែនតារបស់ខ្ញុំ ដោយមិនដឹងថាច្រឡំដៃទុកវានៅកន្លែងណា ហើយភ្លេចកន្លែងដែលខ្ញុំទុកវាទៀត។ ប៉ុន្តែចាប់តាំងពីខ្ញុំប្រើកាបូបស្ពាយរបស់បុរស ឬកាបូបបុរសនោះមក របស់អ្វីដែលខ្ញុំចង់រកនោះមិនដែលថារកមិនឃើញនោះទេ។ វាបានធ្វើឱ្យខ្ញុំដឹងយ៉ាងច្បាស់ថា ហេតុអ្វីបានជាស្ត្រីចូលចិត្តស្ពាយកាបូបយួរដៃម្ល៉េះ។ គ្រប់យ៉ាងគឺសមហេតុសមផលនៅទីនេះ ព្រោះវាសំខាន់។ ឥលូវនេះ ខ្ញុំមិនមែនកំពុងតែបញ្ចុះបញ្ចូលអ្នកឱ្យទិញកាបូបបុរសនោះទេ។ ប៉ុន្តែខ្ញុំចង់ឱ្យអ្នកគិតអំពីផលល្អនៃការមានកាបូបបុរសនោះ។

តើអ្នកបានដឹងដែរឬទេថាព្រះយេស៊ូបានប្រាប់អ្នកឱ្យស្ពាយកាបូបមួយ?

*ដូច្នេះ ចូរអ្នករាល់គ្នាកុំគិតតែពីស្វែងរកគ្រឿងបរិភោគនោះឡើយ ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់អ្នករាល់គ្នាទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ចូរខំស្វែងរកព្រះរាជ្យ*របស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»។*

*«កុំខ្លាចអី ក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់គ្នាសព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឱ្យអ្នករាល់គ្នាហើយ។ ចូរលក់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា យកប្រាក់ចែកជាទានដល់ជនក្រីក្រចុះ។ ចូរប្រមូលទ្រព្យដែលមិនចេះពុក ជាសម្បត្តិដែលមិនចេះរលាយ ទុកសម្រាប់ខ្លួននៅស្ថានបរមសុខ* ជាស្ថានដែលគ្មានចោរប្លន់ ឬកណ្តៀរស៊ីឡើយ។ ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណាចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ»។*

—លូកា ១២៖២៩-៣៤

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំមិនគិតថាព្រះយេស៊ូកំពុងជំរុញអ្នកឱ្យធ្វើតាមសេចក្ដីថ្លែងដ៏ពេញនិយម នេះទេ ប៉ុន្តែផ្ទុយទៅវិញ វាជាដំណើរការដែលអ្នកត្រូវយល់។ (ហើយយើងអាចជំនួស ពាក្យកាបូបឃ្ជរដៃ ទៅជាកាបូបដាក់លុយ ប្រសិនបើអ្នកចង់ប្រើពាក្យនេះវិញ។)

នៅក្នុងចំណុចដែលព្រះយេស៊ូកំពុងព្យាយាមបង្ហាញនៅទីនេះ ទ្រង់ចង់ បង្ហាញថាអ្នកត្រូវមានសិទ្ធិទទួលបានទ្រព្យសម្បត្តិរបស់អ្នក។

ឧទាហរណ៍ ខ្ញុំមានប្រាក់មួយលានដុល្លារក្នុងធនាគារ ប៉ុន្តែវាគ្មានប្រយោជន៍អ្វី ចំពោះខ្ញុំទេ ប្រសិនបើខ្ញុំមិនមានសិទ្ធិទទួល និងប្រើប្រាស់លុយទាំងអស់នោះ? តើត្រឹម ត្រូវដែរឬទេ? នេះជាហេតុផលដែលអ្នកត្រូវការកាបូបមួយនៅជាមួយអ្នក វាជាសិទ្ធិ មួយក្នុងការគ្រប់គ្រងទព្យរបស់អ្នក។

ការបាត់បង់កាបូបលុយរបស់អ្នក គឺជារឿងមួយដែលស្មុគស្មាញបំផុតដែល អាចកើតឡើង។ ខ្ញុំតែងតែព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីមិនឱ្យបាត់កាបូបលុយ របស់ខ្ញុំទេ កាបូបលុយដែលជាកាបូបបុរសរបស់ខ្ញុំនេះ គឺតែងតែនៅជាមួយខ្ញុំជានិច្ច។

មានពាក្យពេចន៍មួយចំនួននេះហើយដែលខ្ញុំបានដកស្រង់មកពីព្រះយេស៊ូ ជាពាក្យដែលមានប្រាជ្ញា និងគោលការណ៍សំខាន់ៗនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែល ទាក់ទងជាមួយប្រាក់របស់អ្នកនៅក្នុងព្រះរាជ្យរបស់ទ្រង់។ ជាដំបូង ឃ្លាដែលនិយាយ ថា «កុំឱ្យខ្វល់ខ្វាយឡើយ» ត្រូវបានប្រើប្រាស់ច្រើនជាងមួយដង។ ព្រះយេស៊ូបានមាន បន្ទូលប្រាប់យើងថា ព្រះជាម្ចាស់ជ្រាបដឹងអ្វីៗទាំងអស់ដែលយើងត្រូវការ ហើយទ្រង់ បង្ហាញយើងអំពីទិសដៅយ៉ាងច្បាស់លាស់អំពីរបៀបដែលយើងអាចទទួលបានវាតាម រយៈការផ្គត់ផ្គង់របស់ទ្រង់។

*ដូច្នេះ ចូរអ្នករាល់គ្នាកុំគិតតែពីស្វែងរកគ្រឿងបរិភោគនោះឡើយ ដ្បិតមានតែ សាសន៍ដទៃប៉ុណ្ណោះ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់អ្នករាល់គ្នាទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ <u>ចូរខំស្វែង</u>*

*<u>រកព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ</u> ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»។*

ព្រះយេស៊ូមានបន្ទូលថា កុំខ្វល់ខ្វាយអ្វីឡើយ ព្រោះទ្រង់មានការផ្គត់ផ្គង់ទាំងអស់នេះហើយ។ ព្រះជាម្ចាស់ជ្រាបដឹងអំពីអ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការ ប៉ុន្តែព្រះយេស៊ូបានដាក់ការណែនាំមួយចំនួនដែលយើងត្រូវធ្វើតាម ដើម្បីទទួលបានវា។

*<u>ចូរខំស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ</u> ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»។*

ព្រះយេស៊ូមានបន្ទូលថា ព្រះជាម្ចាស់មានចម្លើយនោះហើយ ប៉ុន្តែត្រូវមានដំណើរការមួយដើម្បីឱ្យអ្នកអាចមានភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់។ ព្រះជាម្ចាស់មានចម្លើយ **ប៉ុន្តែ**អ្នកត្រូវដឹងអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការជាមុនសិន មុនពេលអ្នកអាចក្លាយជាម្ចាស់កម្មសិទ្ធិលើវា។

សូមកត់សម្គាល់ថា ព្រះយេស៊ូមិនបានមានបន្ទូលថា ចូរស្វែងរកព្រះជាម្ចាស់ជាមុននោះទេ តែទ្រង់បានមានបន្ទូលថា ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុនសិន។ ខ្ញុំគិតថា យើងភាគច្រើនបានកាត់ស្រាយបទគម្ពីរនេះថា ចូរស្វែងរកព្រះជាម្ចាស់ជាមុន ប៉ុន្តែតាមពិត វាមិនបាននិយាយបែបនេះទេ។ ព្រះយេស៊ូបានបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើការស្វែងរកព្រះជាម្ចាស់ជាមុនជាអ្វីមួយដែលត្រឹមត្រូវ នោះទ្រង់នឹងមានបន្ទូលថា *«ដូច្នេះ ចូរស្វែងរកព្រះជាម្ចាស់ជាមុន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»។* ព្រះជាម្ចាស់ជ្រាបអំពីអ្វីដែលអ្នកត្រូវការ ប៉ុន្តែត្រូវមានដំណើរការស្របច្បាប់មួយកើតឡើង មុនពេលស្ថានសួគ៌អាចផ្ទេររបស់ទាំងនោះឱ្យអ្នកយ៉ាងស្របច្បាប់នៅលើផែនដីនេះ។

ខ្ញុំសូមរំឭកអ្នកថា ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាការគ្រប់គ្រងមួយ ដែលមានស្ដេចមួយអង្គ។ សិទ្ធិអំណាច និងឆន្ទៈរបស់ស្ដេចត្រូវបានអនុវត្តចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងព្រះរាជ្យរបស់ទ្រង់តាមរយៈច្បាប់គ្រប់គ្រងនៃព្រះរាជ្យព្រះជាម្ចាស់។

តាមរយៈសៀវភៅបួនក្បាលដំបូងរបស់ខ្ញុំដែលនិយាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំបានចំណាយពេលពិនិត្យមើលទិដ្ឋភាពនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ស្ដីអំពីជីវិត ជំនឿ និងយុត្តាធិការ (ឬការគ្រប់គ្រង)។ ហេតុអ្វីបានជាខ្ញុំធ្វើដូច្នេះ? ព្រោះថាគោលការណ៍ទាំងនេះពិតជាមានសារៈសំខាន់សម្រាប់ភាពជោគជ័យ និងការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតយើង។ ខ្ញុំបានបង្ហាញចំណុចសំខាន់ៗនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងសៀវភៅរបស់ខ្ញុំទាំងអស់ ដោយដឹងថាអ្នកអាចឃើញវាពីសៀវភៅណាមួយរបស់ខ្ញុំ ហើយអ្នកក៏ត្រូវដឹងអំពីចំណេះដឹងមូលដ្ឋានគ្រឹះដែលពិតជាបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំផងដែរ។

អ្នកត្រូវរៀនអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការ!

ព័ត៌មាននៅក្នុងជំពូកនេះ ត្រូវបានយកចេញពីសៀវភៅផ្សេងទៀតរបស់ខ្ញុំ គឺសៀវភៅដែលមានចំណងជើងថា បដិវត្តហិរញ្ញវត្ថុរបស់អ្នក ជាសេរី។ ប្រសិនបើអ្នកបានអានវារួចហើយ អ្នកអាចរំលងទៅជំពូកទីប្រាំបីបាន។ ប្រសិនបើអ្នកមិនទាន់បានអានវាទេ ឬចង់ពិនិត្យមើលឡើងវិញនូវមូលដ្ឋានគ្រឹះ និងគោលការណ៍សំខាន់ៗនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងជំពូកនេះ សូមបន្តអានជំពូកទីប្រាំពីរនេះបន្តទៅមុខទៀតជាមួយខ្ញុំ។

## បញ្ហាអំពីការគ្រប់គ្រង

ដូចខ្ញុំបាននិយាយកាលពីដើមអ៊ីចឹង ខ្ញុំបានរស់នៅកន្លែងជនបទដោយមានផ្ទៃដីចំនួន២៤ហិចតា ដែលជាកន្លែងដ៏ស្រស់ស្អាតបំផុតនៅក្នុងរដ្ឋអូហៃយ៉ូ។ កាលពី

ដំបូង ខ្ញុំមានដីតែ២២ហិចតាទេ ប៉ុន្តែអ្នកជិតខាងខ្ញុំបានលក់ដីមួយកន្លែងដែលជាប់នឹងដីរបស់ខ្ញុំ ធ្វើឱ្យដីខ្ញុំកើនដល់២៤ហិចតា។ នៅក្នុងរយៈពេល២២ឆ្នាំចុងក្រោយនេះ យើងបានរស់នៅលើដីរបស់យើងដោយមានចិត្តសប្បាយរីករាយខ្លាំងណាស់។ មានព្រៃឈើសម្រាប់បរបាញ់សត្វក្ងាន់ វាលតក់សម្រាប់បរបាញ់ប្រវឹក និងវាលសម្រាប់បរបាញ់ទន្សាយ និងសត្វពាហនៈ ក៏ដូចជាមានទីកន្លែងសម្រាប់ជិះម៉ូតូកង់បួនរបស់យើងផងដែរ និយាយរួមទៅ ទីនេះគឺជាកន្លែងដ៏មានព្រះពរសម្រាប់ខ្ញុំ។

ប្រសិនបើអ្នកក្រឡេកមើលដីរបស់ខ្ញុំឱ្យច្បាស់ទៅ អ្នកនឹងឃើញមានសញ្ញា **ហាមចូល**នៅក្នុងបរិវេណដីនេះ។ សញ្ញាដែលមាននៅទីនោះ ប្រាប់មនុស្សឱ្យដឹងថាដីរបស់ខ្ញុំមានព្រំដែនចាប់ពីត្រឹមណាមក។ ច្បាប់នៅក្នុងរដ្ឋអូហៃយ៉ូចែងថា អ្នកណាដែលចង់ដើរលើដីរបស់ខ្ញុំ ត្រូវតែមានកិច្ចយល់ព្រមជាលាយលក្ខណ៍អក្សរនៅជាមួយពួកគេគ្រប់ពេលដែលពួកគេស្ថិតនៅលើដីនោះ។ ប្រសិនបើមិនមានទេ គេចាត់ទុកថាពួកគេបានបំពានចូលដីខ្ញុំហើយ ហើយពួកគេអាចត្រូវបានបណ្តេញចេញដោយស្របច្បាប់ ហើយអាចប្រឈមនឹងការផាកពិន័យ ព្រមទាំងពិន័យជាប្រាក់នៅក្នុងដំណើរការនេះផងដែរ។

ដូច្នេះ បើនិយាយឱ្យខ្លីទៅ...

## អ្នកមិនអាចកាន់កាប់អ្វីមួយដែលអ្នកមិនមានសិទ្ធិគ្រប់គ្រងលើវានោះទេ

ដូចដែលខ្ញុំបាននិយាយរួចហើយថា ការមានទម្រង់បែបបទយល់ព្រមជាលាយលក្ខណ៍អក្សរដែលចុះហត្ថលេខាដោយខ្ញុំ នឹងផ្តល់ឱ្យអ្នកមានសិទ្ធិស្របច្បាប់លើដីរបស់ខ្ញុំ។ ប្រសិនបើមាននរណាម្នាក់បញ្ឈប់អ្នកនៅលើដីរបស់ខ្ញុំ ហើយគេសួរអ្នកថា ហេតុអ្វីបានជាអ្នកនៅទីនេះ ហើយអ្នកអាចឆ្លើយតាមអ្វីដែលខ្ញុំបានប្រាប់អ្នក ថាអ្នកអាចបរបាញ់នៅទីនេះបាន បើឆ្លើយត្រឹមតែប៉ុណ្ណឹងវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ច្បាប់បានចែងថាអ្នកត្រូវតែមានទម្រង់ចុះហត្ថលេខាដើម្បីចូលមកបាន។

ដំណើរការនេះគឺសំខាន់ដូចគ្នា ប្រសិនបើអ្នកទៅធនាគារ ដើម្បីដកប្រាក់របស់អ្នក នោះពួកគេនឹងសុំមើលអត្តសញ្ញាណបណ្ណរបស់អ្នក។ អ្នកលក់ទំនិញមានសិទ្ធិដូចគ្នាក្នុងការសួររកអត្តសញ្ញាណបណ្ណរបស់អ្នក នៅពេលអ្នកប្រើកាតក្រេឌីត ដើម្បីបង់ថ្លៃទំនិញ។ ការប្រាប់អំពីអត្តសញ្ញាណមិនមែនមានន័យថាជាការបង្អាក់គណនីរបស់អ្នកនោះទេ តែវាជាការការពារអ្នកពីអ្នកដទៃ ដែលអាចលួចប្រើប្រាស់កាតក្រេឌីតរបស់អ្នក។

**ចូរស្វែងយល់អំពីអ្វីដែលជាកម្មសិទ្ធិរបស់អ្នក និងរបៀបយកវាមកប្រើប្រាស់។ បន្ទាប់មក អ្វីៗទាំងអស់ដែលអ្នកត្រូវការនឹងត្រូវបានបំពេញបន្ថែមដល់អ្នក។**

ពេលដែលព្រះយេស៊ូមានបន្ទូលថា ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុន នោះទ្រង់ចង់មានន័យថា *«ត្រូវសិក្សាច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដើម្បីឱ្យដឹងពីរបៀបមានដំណើរការស្របច្បាប់ និងប្រកបដោយប្រសិទ្ធភាពក្នុងនាមជារាស្ត្រម្នាក់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់»*។ ចូរស្វែងយល់អំពីអ្វីដែលជាកម្មសិទ្ធិរបស់អ្នក និងរបៀបយកវាមកប្រើប្រាស់។ បន្ទាប់មក អ្វីទាំងអស់ដែលអ្នកត្រូវការនឹងត្រូវបានបំពេញបន្ថែមដល់អ្នក។

ឧទាហរណ៍មួយទៀត ប្រសិនបើខ្ញុំបើកគណនីសន្សំមួយសម្រាប់កូនប្រុសរបស់ខ្ញុំ។ ពេលដែលគាត់គ្រប់អាយុហើយ នោះវាជាការស្របច្បាប់ក្នុងការផ្ទេរគណនីនេះទៅឱ្យគាត់។ ខ្ញុំត្រូវប្រាប់គាត់ថានៅក្នុងគណនីនេះមានអ្វីខ្លះ និងបង្ហាញគាត់ពីរបៀបដកប្រាក់ពីគណនីនេះ និងរបៀបដាក់ប្រាក់ចូលវិញ។ ទោះបីជាវាជាគណនីរបស់គាត់ស្របច្បាប់ក៏ដោយ ក៏គាត់នៅតែត្រូវទទួលខុសត្រូវចំពោះដំណើរការស្របច្បាប់ ដើម្បីមានសិទ្ធិប្រើប្រាស់វាបាន។

ខ្ញុំសូមសង្ខេបពីអ្វីដែលខ្ញុំបាននិយាយនៅទីនេះ។ ពេលដែលព្រះយេស៊ូមានបន្ទូលថា ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុន ទ្រង់គឺកំពុងតែមានបន្ទូលអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ គឺចង់សំដៅលើច្បាប់ និងដំណើរការក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលអ្នកត្រូវតែរៀនដើម្បីកាន់កាប់ដោយស្របច្បាប់នូវអ្វីដែលជាកម្មសិទ្ធិរបស់អ្នក។ ដូចដែលអ្នកបានឃើញនៅក្នុងឧទាហរណ៍ខាងលើ ដែលនិយាយអំពីគណនីធនាគាររបស់ខ្ញុំអ៊ីចឹងដែរ អ្នកអាចមានសិទ្ធិគ្រប់គ្រងស្របច្បាប់លើគណនីទ្រព្យសម្បត្តិមួយ ប៉ុន្តែប្រហែលជាមិនអាចកាន់កាប់វាបានទេ ដោយសារតែអ្នកមិនបានធ្វើតាមដំណើរការស្របច្បាប់ដើម្បីកាន់កាប់វា។ ឧទាហរណ៍៖ ប្រសិនបើអ្នកទុកអត្តសញ្ញាណបណ្ណនៅផ្ទះពេលអ្នកទៅធនាគារ គេនឹងមិនអនុញ្ញាតឱ្យអ្នកដកលុយចេញពីគណនីនោះទេ ទោះបីវាជាលុយរបស់អ្នកក៏ដោយ។

ការយល់ដឹងអំពីការគ្រប់គ្រងនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺតម្រូវឱ្យយើងដឹងលក្ខខណ្ឌជាមុនសិន ដើម្បីមានប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។

ខ្ញុំប្រាកដថាអ្នកប្រហែលជាធ្លាប់បានឮអំពីរឿងនេះរួចហើយ៖ មានបុគ្គលដ៏ល្បីល្បាញម្នាក់បានឈឺ ហើយគេបានអធិស្ឋានឱ្យគាត់។ មានមនុស្សរាប់លាននាក់ចូលរួមក្នុងការអធិស្ឋាន ដើម្បីឱ្យបុគ្គលម្នាក់នោះទទួលបានការប្រោសលោះពីជំងឺ ប៉ុន្តែទីបំផុត គាត់នៅតែស្លាប់ដដែល តើហេតុអ្វីទៅ?

តើធ្លាប់មាននរណាម្នាក់បានប្រាប់អ្នកអំពីជីដូនរបស់ពួកគេ ដែលបានស្លាប់ទោះបីជាពួកគេបានអធិស្ឋានឱ្យដែរឬទេ? ហើយពួកគេចង់ដឹងអំពីមូលហេតុ។ ឬមាននរណាម្នាក់ប្រាប់អ្នកថា ពួកគេបានសាបព្រោះប្រាក់សម្រាប់តម្រូវការហិរញ្ញវត្ថុ ហើយពួកគេនៅតែបរាជ័យដដែល។ តើមានចម្លើយសម្រាប់សំណួរប្រភេទនេះដែរឬទេ?

មុននឹងខ្ញុំឆ្លើយសំណួរទាំងនេះ សូមទទួលស្គាល់ថា យើងមិនអាចដឹងអំពីអ្វីៗគ្រប់យ៉ាងដែលកើតឡើងនៅក្នុងពិភពខាងវិញ្ញាណបានទេ ហើយខ្ញុំក៏មិនបានធ្វើពុតជាអ្នកដឹងរឿងទាំងនោះដែរ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងដឹងថា ប្រសិនបើមាននរណាម្នាក់ឈឺ ព្រះយេស៊ូបានបង់ថ្លៃសម្រាប់ការជាសះស្បើយរបស់ពួកគេរួចហើយ។ យើងក៏ដឹងថា ប្រសិនបើយើងមានចិត្តសប្បុរសហើយចេះឱ្យ នោះព្រះគម្ពីរចែងថា យើងគួរតែទទួលបានជោគជ័យយ៉ាងពិតប្រាកដ។ ប៉ុន្តែជារៀងរាល់ថ្ងៃ យើងឃើញអ្វីដែលមើលទៅហាក់ដូចជាការបរាជ័យនៅក្នុងព្រះបន្ទូលព្រះជាម្ចាស់ ដែលបានសរសេរក្នុងជីវិតមនុស្សជាច្រើន។ តើព្រះជាម្ចាស់ជាអ្នកដែលគួរត្រូវបានគេបន្ទោសឬ?

ពេលខ្ញុំពិភាក្សាអំពីប្រធានបទនេះនៅក្នុងជំពូកនេះ អ្នកនឹងឃើញចម្លើយ ឬការឆ្លើយតបរបស់ខ្ញុំ គឺវាមិនមែនដូច្នេះទេ។ បើមិនមែនទេ តើមានបញ្ហាអ្វីទៅ? យ៉ាងណាមិញ មនុស្សភាគច្រើនបន្ទោសព្រះជាម្ចាស់ចំពោះសោកនាដកម្មទាំងនេះ។ ពួកគេបានដឹងថាព្រះជាម្ចាស់មានអំណាចក្នុងការបញ្ឈប់ការអាក្រក់មិនឱ្យកើតឡើង ហើយព្រះជាម្ចាស់មិនបានធ្វើវាទេ ដូច្នេះពួកគេសន្មតថាទ្រង់*ជ្រើសរើស*មិនជួយពួកគេ។ នេះគឺជាកន្លែងមួយដែលគោលលទ្ធិខុសឆ្គងនិយាយថា «ព្រះជាម្ចាស់អនុញ្ញាតឱ្យរឿងអាក្រក់កើតឡើងចំពោះមនុស្សល្អ»។ មនុស្សជឿថា ប្រសិនបើទ្រង់មិនបានបញ្ឈប់ ឬធ្វើអន្តរាគមន៍ទេ នោះមានន័យថាទ្រង់ច្បាស់ជាបានអនុញ្ញាតឱ្យរឿងនោះកើតឡើងហើយ។ ប៉ុន្តែប្រសិនបើអ្នកមានការយល់ដឹងថា ព្រះជាម្ចាស់តែងតែល្អជានិច្ច ហើយទ្រង់មិនចេះកុហកទេ នោះអ្នកនឹងដឹងថាបញ្ហាមិនមែនមកពីទ្រង់កុហកទេ ហើយរឿងរ៉ាវទាំងអស់នោះបានកើតឡើង តែមិនមែនមកពីទ្រង់ទេ ហើយអ្នកក៏ចាប់ផ្ដើមសួរបន្តទៀត ដើម្បីស្វែងរកចម្លើយ។

វាដូចជាពេលដែលអ្នកដើរចូលទៅក្នុងបន្ទប់អ្នក ហើយវាងងឹត អ្នកមិនអាចនិយាយថាក្រុមហ៊ុនអគ្គិសនីបានផ្ដាច់ភ្លើងអ្នកនោះទេ។ អត់ទេ អ្នកត្រូវស្វែងរកកុងតា

ក់ភ្លើង ហើយប្រសិនបើអ្នកបានចុចវាហើយ វានៅតែមិនភ្លឺទៀត អ្នកត្រូវពិនិត្យមើលអំពូលភ្លើងវិញម្តង។ អ្នកត្រូវដឹងថាបញ្ហាភាគច្រើនគឺអាចបណ្តាលមកពី*អ្នក*។

ប្រសិនបើអ្នកមានការយល់ដឹងថា បញ្ហានេះ*មិនអាច*ជាកំហុសរបស់ព្រះជាម្ចាស់បានទេ ដោយសារទ្រង់បានប្រទានឱ្យយើងនូវព្រះបន្ទូលរបស់ទ្រង់ និងការសន្យាដែលបង្ហាញអំពីព្រះហឫទ័យរបស់ទ្រង់ចំពោះយើងរួចរាល់ហើយ។ បន្ទាប់មក អ្នកនឹងចាប់ផ្តើមប្រឹងប្រែងស្វែងរកកន្លែងដែលបានកាត់ផ្តាច់ចម្លើយរបស់ព្រះជាម្ចាស់សម្រាប់បញ្ហារបស់អ្នក។

ពួកសិស្សបានបង្ហាញពីផ្នត់គំនិតនេះ នៅដែលពេលពួកគេមិនអាចដេញអារក្សចេញពីក្មេងប្រុសម្នាក់នៅក្នុង ម៉ាថាយ ១៧:១៤-២៣។ ជំនួសដោយការសួរថា « ហេតុអ្វីបានជាព្រះជាម្ចាស់ជ្រើសរើសទុកឱ្យអារក្សនៅក្នុងក្មេងនោះ?» ពួកគេបានសួរព្រះយេស៊ូថា៖ «ហេតុអ្វីបានជាយើងមិនអាចដេញអារក្សចេញបាន?» នេះគួរតែជាសំណួរបន្ទាន់របស់យើង ពេលដែលស្ថានភាពរបស់យើងហាក់បីដូចជាផ្ទុយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ជាថ្មីម្តងទៀត វាជាការសំខាន់ដែលយើងត្រូវដឹងជាមុនថា ព្រះជាម្ចាស់ទ្រង់ល្អ។ ហើយទីពីរ ទ្រង់មិនចេះកុហកទេ។ អ្នកត្រូវតែអានព្រះគម្ពីរ ហើយសួរសំណួរប្រសិនបើអ្នកចង់រៀនពីរបៀបដែលព្រះរាជ្យរបស់ជាម្ចាស់ធ្វើការ។ សូមនឹកចាំអំពីរឿងដ៏អស្ចារ្យទាំងនេះនៅក្នុងព្រះគម្ពីរ ព្រោះព្រះយេស៊ូអាចកំពុងព្យាយាមបង្ហាញអ្វីមួយដល់អ្នក។

ជាថ្មីម្តងទៀត ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាព្រះរាជ្យមួយ ដែលមានដំណើរការតាមផ្លូវច្បាប់ និងគោលការណ៍ដែលមិនផ្លាស់ប្តូរ។ ដូចដែលខ្ញុំបាននិយាយរួចហើយ អ្នកអាចរៀនគោលការណ៍ទាំងនោះបាន ហើយអាចយកវាមកប្រើ ដូចដែលកសិករបានយល់អំពីច្បាប់នៃគ្រាប់ពូជ និងច្បាប់នៃការច្រូតផលនៅលើផែនដីនេះ ព្រម

ទាំងប្រើច្បាប់ទាំងនោះដើម្បីទទួលបានភាពចម្រុងចម្រើន។ ដោយសារព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការតាមផ្លូវច្បាប់ ដែលបានផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូបដើម្បីឱ្យពួកគេបានយល់ដឹង និងប្រើប្រាស់ក្នុងព្រះរាជ្យរបស់ទ្រង់ ដូច្នេះ*អ្នកណា*ក៏អាចរៀនអំពីច្បាប់នោះបានដែរ។ ជួនកាល ការស្គាល់អំពីរបៀបដែលច្បាប់ទាំងនេះមានដំណើរការគឺជារឿងដ៏សំខាន់បំផុត។

ម៉ាក និងហាណា បានមកក្រុមជំនុំរបស់យើង ហើយមានបំណងចង់មានកូន។ រហូតមកដល់ពេលនោះ ហាណាត្រូវបានគ្រូពេទ្យប្រាប់ថា ដោយសារបញ្ហាផ្សេងៗនៅក្នុងខ្លួនរបស់នាង វាស្ទើរតែធ្វើឱ្យនាងមិនអាចមានផ្ទៃពោះ ឬពពោះបាន។ ប៉ុន្តែ ខណៈពេលដែលនាងបានឮអំពីសេចក្តីល្អរបស់ព្រះជាម្ចាស់ ហើយនាងបានរៀនអំពីច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងក្រុមជំនុំ Faith Life Church នាងបានដឹងថានាងអាចមានផ្ទៃពោះបាន។ នាងរំភើបរកអ្វីមកថ្លែងពុំបាន។ ប៉ុន្តែមិនយូរប៉ុន្មាន នាងចាប់ផ្តើមឈឺចុកចាប់ក្នុងពោះរបស់នាងពីរបីដងយ៉ាងខ្លាំង រហូតដល់នាងសន្លប់។

បន្ទាប់ពីបញ្ហានេះបានកន្លងផុតទៅ ហាណាបានទៅពិនិត្យនៅមន្ទីរពេទ្យ នាងបានទៅការិយាល័យគ្រូពេទ្យប្រចាំខ្លួនរបស់នាង។ គ្រូពេទ្យរបស់នាងមិនបាននៅទេ។ ប៉ុន្តែមានគ្រូពេទ្យដែលប្រចាំការនៅទីនោះ ជួយឆ្លុះមើលទារកនៅក្នុងពោះនាងដើម្បីដឹងថាវាកំពុងលូតលាស់ដល់កម្រិតណាហើយ។

គ្រូពេទ្យបានឃើញកំណកឈាមដ៏ធំមួយ ហើយបានប្រាប់នាងថា នាងបានរលូតកូនហើយ ព្រោះទារកនោះមិនមានចង្វាក់បេះដូងលោតទេ។

គ្រូពេទ្យបានស្នើឱ្យនាងមកមន្ទីរពេទ្យវិញនៅថ្ងៃបន្ទាប់ ដូច្នេះនាងអាចយកទារកដែលស្លាប់នោះចេញពីផ្ទៃពោះរបស់នាង ប៉ុន្តែហាណាបានបដិសេធ។ ផ្ទុយទៅវិញ ស្វាមីរបស់នាងឈ្មោះ ម៉ាក បានលើកទឹកចិត្តនាងជាមួយនឹងព្រះបន្ទូលរបស់ព្រះ

ជាម្ចាស់ និងសេចក្ដីសន្យារបស់ទ្រង់ ហើយបានលើកទឹកចិត្តនាងកុំឱ្យបាត់បង់ទំនុកចិត្តលើព្រះបន្ទូលទាក់ទងនឹងទារកនេះ។

នៅចុងសប្ដាហ៍នោះ ហាណាបានទទួលការអធិស្ឋានឱ្យនៅព្រះវិហារ ហើយជឿជាក់ថានាងនឹងមានទារកដែលមានសុខភាពល្អ ទោះបីជាគ្រូពេទ្យបានប្រាប់នាងយ៉ាងណាក៏ដោយ។

នៅថ្ងៃចន្ទនោះ នាងបានចូលទៅជួបគ្រូពេទ្យផ្ទាល់ខ្លួនរបស់នាងម្ដងទៀត តែគ្រូពេទ្យរបស់នាងមិននៅទេ ពេលនាងបានផ្លៀតពេលទៅជួបគាត់នៅការិយាល័យរបស់គាត់។ គ្រូពេទ្យម្នាក់ទៀតនោះបានស្នើឱ្យនាងឆ្លុះអេកូម្ដងទៀត។ គាត់ហាក់ដូចជាភ្ញាក់ផ្អើល ពេលគាត់បានសម្លឹងមើលអេក្រង់ឆ្លុះអេកូ ហើយបន្ទាប់មកបានមើលឯកសារស្កេន ដែលបានឆ្លុះអេកូកាលពីពីរបីថ្ងៃមុននេះ។ បន្ទាប់មកគាត់បាននិយាយទៅហាណាថា «ខ្ញុំបានធ្វើការងារផ្នែកនេះអស់រយៈពេល៣០ឆ្នាំហើយ ហើយខ្ញុំមិនដែលឃើញរឿងនេះកើតឡើងពីមុនមកទេ។ ខ្ញុំបានឃើញកំណកឈាមដ៏ធំមួយកាលពីសប្ដាហ៍មុន ហើយបានឃើញថាទារកមិនមានចង្វាក់បេះដូងលោតសោះ។ តែពេលខ្ញុំពិនិត្យនៅថ្ងៃនេះ ខ្ញុំឃើញកំណកឈាមទាំងមូលបានរលាយបាត់ទៅអស់ មានតែទារកដែលមានសុខភាពល្អ នៅមានជីវិតរស់ជាមួយចង្វាក់បេះដូងដ៏ល្អប្រសើរ។»

ប៉ុន្មានខែក្រោយមក ហាណាសម្រាលបានកូនស្រីដ៏ស្រស់ស្អាតម្នាក់។ ដែលនាងដាក់ឈ្មោះថា អេវ៉ាលីន។ ថ្ងៃមួយយើងចង់ដឹងអំពីអត្ថន័យឈ្មោះអេវ៉ាលីននេះ នាងក៏បានស្រាវជ្រាវរកអត្ថន័យរបស់វា ហើយមានការភ្ញាក់ផ្អើលពេលដឹងថាឈ្មោះនោះមានន័យថា*ជីវិត!* ដូចដែលខ្ញុំសរសេរនៅថ្ងៃនេះអ៊ីចឹង កូនទីពីររបស់ហាណា គឺជិតសម្រាលហើយ។

រឿងដ៏អស្ចារ្យនេះ ច្បាស់ជាកិច្ចការរបស់ព្រះជាម្ចាស់ហើយ។ ប៉ុន្តែ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ អ្នកគួរតែគិតអំពីសំណួរមួយចំនួនទៀត ដូចជា៖ «ហេតុអ្វី

បានជាវាកើតឡើង? តើហាណាជាមនុស្សជាទីពេញចិត្តរបស់ព្រះជាម្ចាស់មែនដែរឬទេ? តើព្រះជាម្ចាស់គ្រាន់តែជ្រើសរើសដោយចៃដន្យ ដើម្បីប្រោសកូនរបស់នាងឱ្យបានជាឬ?» ទាំងនោះគឺជាសំណួរដែលយើងត្រូវតែឆ្លើយ។

ជាថ្មីម្តងទៀត គ្រិស្តបរិស័ទជាមធ្យមទទួលបានការអស្ចារ្យមួយ ប៉ុន្តែខ្ញុំលើកទឹកចិត្តមនុស្សឱ្យគិតឡើងវិញនូវពាក្យថា «ការអស្ចារ្យ» ព្រោះវាហាក់ដូចជាមានន័យអ្វីមួយខុសប្លែកពីធម្មតា។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ វាគ្រាន់តែជាមុខងារមួយនៃច្បាប់របស់ព្រះរាជ្យរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។

ប្រសិនបើខ្ញុំទម្លាក់ដុំថ្មមួយដុំ ហើយវាបានធ្លាក់ទៅលើដី អ្នកនឹងគិតថាខ្ញុំឆ្កួតហើយ បើខ្ញុំស្រែកថា «អស្ចារ្យណាស់! តើអ្នកឃើញទេ? ដុំថ្មទើបតែធ្លាក់ទៅលើដី! នេះជាការអស្ចារ្យ!» អ្នកនឹងមិនយល់ស្របថាវាជាការអស្ចារ្យទេ ព្រោះអ្នកដឹងថាសកម្មភាពនេះគ្រាន់តែជាដំណើរការរបស់ច្បាប់ទំនាញផែនដីតែប៉ុណ្ណោះ ហើយវាមានដំណើរការដូច្នេះ*គ្រប់ពេល* ចំពោះ*មនុស្សគ្រប់ៗគ្នា។* ជាធម្មតា ដុំថ្ម*តែងតែ*ធ្លាក់មកលើដីហើយ។

ដូច្នេះ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងត្រូវតែមើលអំពីតម្រុយអ្វីដែលបណ្តាលឱ្យការទាំងនេះបានកើតឡើង។ តម្រុយខាងវិញ្ញាណនឹងបង្ហាញអំពីច្បាប់ ឬច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលបានបង្ហាញនៅក្នុងសាច់រឿងនេះ។

រឿងមួយដ៏អស្ចារ្យបំផុតនៅក្នុងព្រះគម្ពីរ នឹងជួយយើងឱ្យស្វែងរកចម្លើយទាក់ទងនឹងជំនឿ និងការគ្រប់គ្រងដែលមាននៅក្នុងសៀវភៅលូកាជំពូក៨។

> *កាលព្រះយេស៊ូយាងទៅ នៅតាមផ្លូវមានមហាជនប្រជ្រៀតគ្នាជុំវិញព្រះអង្គ។ ពេលនោះមានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយនាងបានចំណាយទ្រព្យសម្បត្តិដែលនាងមានទាំងប៉ុន្មានដើម្បីឱ្យគ្រូពេទ្យព្យាបាល តែគ្មានគ្រូពេទ្យណាអាចមើលនាងជាបានឡើយ។ នាងមកពីក្រោយព្រះយេស៊ូហើយពាល់ជាយព្រះពស្ត្រព្រះអង្គស្រាប់តែឈាមឈប់ធ្លាក់មួយរំពេច។*

*ព្រះយេស៊ូមានព្រះបន្ទូលសួរថា៖«នរណាពាល់ខ្ញុំ?»។ គេប្រកែកគ្រប់គ្នាថាគេមិនបានពាល់ព្រះអង្គទេ។ លោកពេត្រុសទូលថា៖ «ព្រះគ្រូអើយបណ្ដាជនប្រជ្រៀតគ្នានៅជុំវិញព្រះគ្រូ ហើយគេប៉ះព្រះគ្រូទាំងអស់គ្នា»។*

*ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានម្នាក់ពិតជាបានពាល់ខ្ញុំ ព្រោះខ្ញុំដឹងថាមានឫទ្ធានុភាពមួយចេញពីខ្លួនខ្ញុំទៅ»។*

*ស្ត្រីនោះមកក្រាបទៀបព្រះបាទាព្រះយេស៊ូ ទាំងញ័ររន្ធត់ព្រោះដឹងថាខ្លួនលាក់រឿងនេះមិនជិត។ នាងទូលព្រះអង្គនៅចំពោះមុខប្រជាជនទាំងមូលអំពីហេតុដែលនាំឱ្យនាងពាល់ព្រះអង្គ ហើយនាងបានជាពីជំងឺភ្លាម។ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «<u>កូនស្រីអើយ!ជំនឿរបស់នាងបានសង្គ្រោះនាងហើយ</u> សូមអញ្ជើញទៅដោយសុខសាន្តចុះ»។*

— លូកា ៨:៤២-៤៨

នៅក្នុងរឿងនេះ យើងឃើញមានស្ត្រីម្នាក់ដែលមានជំងឺធ្ងន់ធ្ងរជាច្រើនឆ្នាំមកហើយ ហើយមិនបានជាសះស្បើយសោះ។ គាត់បានមកពីក្រោយព្រះយេស៊ូ ហើយបានពាល់ជាយព្រះពស្ត្រព្រះអង្គ ស្រាប់តែឈាមក៏ឈប់ធ្លាក់មួយរំពេច។ ឥលូវនេះមានតម្រុយយ៉ាងច្បាស់មួយចំនួននៅក្នុងដំណើរការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងរឿងនេះ ដែលយើងអាចរៀនបាន ហើយវាបានបំភ្លឺនូវចម្លើយមួយចំនួនដែលយើងកំពុងស្វែងរក។

ជាដំបូង មានហ្វូងមនុស្សនៅជុំវិញព្រះយេស៊ូ ហើយពួកគេសុទ្ធតែបានពាល់ទ្រង់ ដូចនៅក្នុងសាច់រឿងនេះដែលបាននិយាយថា ទ្រង់ស្ទើរតែដួលដោយសារហ្វូងមនុស្សដែលប្រជ្រៀតមករកទ្រង់។ ពេលព្រះយេស៊ូមានព្រះបន្ទូលសួរថា៖ «អ្នកណាពាល់ខ្ញុំ?» នោះពេត្រុសភ្ញាក់ផ្អើលចំពោះសំណួរនេះ ព្រោះមនុស្ស*គ្រប់គ្នា*បានពាល់ទ្រង់។ ប៉ុន្តែព្រះយេស៊ូបានមានបន្ទូលថា មនុស្សម្នាក់នេះបានពាល់ទ្រង់តាមរបៀបមួយ

ខុសប្លែកពីអ្នកដទៃ ទ្រង់បានទទួលអារម្មណ៍ដឹងថា មានឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធបានចេញពីទ្រង់ទៅ។

បន្ទាប់ពីអានរឿងនេះហើយ ផ្នែកនៃរឿងដ៏គួរឱ្យចាប់អារម្មណ៍បានលេចឡើងនៅក្នុងវិញ្ញាណអ្នក ជំរុញអ្នកឱ្យឈប់បន្តិច ហើយពិចារណាអំពីអ្វីដែលទើបតែបានកើតឡើង។ ចិត្តរបស់អ្នកគួរតែចាប់ផ្តើមធ្វើការស៊ើបអង្កេតភ្លាមៗ ជាមួយនឹងសំណួរជាច្រើន។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងត្រូវដឹងថាហេតុអ្វីបានជាស្ត្រីម្នាក់*នេះ*បានជាសះស្បើយ ហើយអ្នកដទៃផ្សេងទៀតមិនបានជាសះស្បើយ? ខ្ញុំអាចសន្មតថា មានមនុស្សផ្សេងទៀតជាច្រើនដែលនៅទីនោះដែលបានពាល់រាងកាយទ្រង់ ហើយក៏ជាអ្នកដែលមានជំងឺផងដែរ ប៉ុន្តែមិនបានជាសះស្បើយទេ។ ដូច្នេះ យើងត្រូវសួរសំណួរមួយនេះ «ហេតុអ្វីបានជាការចាក់ប្រេងតាំងហូរមកតែចំពោះស្ត្រីម្នាក់នេះ ហើយមិនហូរដល់មនុស្សគ្រប់គ្នាដែលបានពាល់ព្រះយេស៊ូនៅពេលនោះទៅ?»

សាសនាតាមបែបបុរាណឆ្លើយថា នាងត្រូវបានប្រោសឱ្យជាដោយសារតែព្រះយេស៊ូបានប្រោសនាងឱ្យបានជា។ ប៉ុន្តែតើទ្រង់បានប្រោសនាងឱ្យបានជាដែរឬទេ? តើព្រះយេស៊ូកំពុងតែធ្វើព័ន្ធកិច្ចទៅកាន់នាងដោយចេតនា ឬបានធ្វើឱ្យនាងជាសះស្បើយដែរឬទេ? តើទ្រង់បានដាក់ដៃលើនាងដែរឬទេ? តើទ្រង់បានបង្គាប់ឱ្យជំងឺនោះចាកចេញពីខ្លួននាងដែរឬទេ? ចម្លើយគឺមិនដូច្នេះទេ។ តាមពិតទៅ ព្រះយេស៊ូមិនបានដឹងថានាងនៅទីនោះទេ។ ទ្រង់បានសួរថា អ្នកណាពាល់ខ្ញុំ។

ដូច្នេះ តើព្រះយេស៊ូបានជ្រើសរើសប្រោសនាងឱ្យជានៅពេលនោះឬ? ខ្ញុំនិយាយម្តងទៀត ទ្រង់មិនបានដឹងថានាងនៅទីនោះទេ។ ដូច្នេះ តើនាងទទួលបានការជាសះស្បើយដោយរបៀបណា? ហេតុអ្វីបានជានាងបានជាសះស្បើយ? ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងអាចបដិសេធគំនិតនេះ ដែលនិយាយថានាងជាកូនដ៏

ពិសេសរបស់ព្រះជាម្ចាស់ ឬនាងមានទំនាក់ទំនងពិសេសជាមួយព្រះយេស៊ូ ព្រោះនៅកិច្ចការ ១០:៣៤ ចែងថា ព្រះជាម្ចាស់រាប់រកមនុស្សទូទៅឥតរើសមុខឡើយ។

យើងអាចសន្មតបានថា ដោយសារព្រះយេស៊ូមិនបានដឹងថានាងមាននៅទីនោះ នោះទ្រង់មិនមានចំណែកក្នុងការសម្រេចចិត្តឱ្យនាងបានជាសះស្បើយថ្ងៃនោះទេ។ យើងក៏អាចយល់ស្របថា ទ្រង់គឺជាប្រភពនៃការចាក់ប្រេងតាំង ប៉ុន្តែទ្រង់មិនមែនជាផ្នែកមួយនៃការសម្រេចចិត្ត ដែលបានធ្វើឱ្យ*នាង*បានជាសះស្បើយនៅពេលនោះទេ។

ព្រះយេស៊ូប្រាប់យើងយ៉ាងច្បាស់ អំពីរបៀបដែលនាងបានចូលទៅក្នុងសិទ្ធិអំណាច និងឫទ្ធានុភាពនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់បានមានបន្ទូលថា «*កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅដោយសុខសាន្តចុះ*»។ ប្រយោគនេះបានប្រាប់យើងនូវអ្វីគ្រប់យ៉ាងដែលយើងត្រូវដឹង ហើយឆ្លើយសំណួររបស់យើងអំពីមូលហេតុ និងរបៀបដែលនាងបានជាសះស្បើយនៅថ្ងៃនោះ។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ យើងត្រូវពិនិត្យមើលរឿងនេះឱ្យកាន់តែច្បាស់ជាងនេះ ដើម្បីមើលថាតើយើងអាចស្វែងរកតម្រុយណាមួយអំពីមូលហេតុដែលនាងបានជាសះស្បើយដែរឬទេ។

ជាដំបូង ព្រះយេស៊ូបានហៅនាងថា *កូនស្រី* ការនេះមានន័យថានាងជាផ្នែកមួយនៅក្នុងប្រជាជាតិអ៊ីស្រាអែល ជាពូជពង្សលោកអប្រាហាំ ជាកូនរបស់លោកអប្រាហាំ នាងបានទទួលព្រះពរដែលព្រះជាម្ចាស់បានផ្តល់ឱ្យទៅលោកអប្រាហាំ និងអត្ថប្រយោជន៍នៃសម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានធ្វើជាមួយលោកអប្រាហាំ។

> *ព្រះអង្គមានព្រះបន្ទូលថា ៖ «ប្រសិនបើអ្នករាល់គ្នាយកចិត្តទុកដាក់ស្តាប់បង្គាប់យើង* ***ព្រះអម្ចាស់*** *ជាព្រះរបស់អ្នករាល់គ្នា ហើយប្រព្រឹត្តតាមអ្វីៗដែលយើងយល់ថាត្រឹមត្រូវប្រសិនបើអ្នករាល់គ្នាត្រងត្រាប់ស្តាប់បទបញ្ជា និងកាន់តាមច្បាប់ទាំងប៉ុន្មានរបស់យើង នោះយើងនឹងមិនធ្វើឱ្យអ្នករាល់គ្នាកើតជំងឺ*

*អ្វីមួយ ដូចយើងបានធ្វើចំពោះជនជាតិអេស៊ីបឡើយ ដ្បិតយើងជា**ព្រះអម្ចាស់**ដែលប្រោសឱ្យអ្នករាល់គ្នាជា»។*

—និក្ខមនំ ១៥:២៦

ដូច្នេះ ពេលដែលព្រះយេស៊ូហៅនាងថាកូនស្រី នោះមានន័យថានាងមានសិទ្ធិស្របច្បាប់សម្រាប់អ្វីៗទាំងអស់ ដែលមានរួមបញ្ចូលក្នុងសម្ពន្ធមេត្រីរបស់លោកអប្រាហាំ ដែលគាត់បានធ្វើជាមួយព្រះជាម្ចាស់។ ប៉ុន្តែ បើគ្រាន់តែរឿងមួយនេះ នោះមិនអាចជាហេតុផលតែមួយគត់ ដែលនាងបានជាសះស្បើយនោះឡើយ។ ដូចជាមនុស្សគ្រប់គ្នានៅទីនោះបានប្រជ្រៀតជុំវិញព្រះយេស៊ូ ពួកគេក៏មានសិទ្ធិដូចជានាងដែរ។ ប្រាកដជាមានអ្វីផ្សេងទៀត ដែលបណ្តាលឱ្យឫទ្ធានុភាពនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ហូរមកលើនាងហើយ។ បន្ទាប់មក ព្រះយេស៊ូបានប្រាប់យើងអំពីមូលហេតុមួយទៀតដែលនាងបានជាសះស្បើយ។ តាមពិតទៅអ្វីដែលព្រះយេស៊ូបានមានបន្ទូលគឺជាមូលហេតុ*ពិតប្រាកដ*ដែលធ្វើឱ្យនាងទទួលបានការជាសះស្បើយ។

ទ្រង់បានមានបន្ទូលថា ជំនឿរបស់នាងបានសង្គ្រោះនាងហើយ។

ដូច្នេះ ឥលូវនេះ យើងដឹងពីមូលហេតុដែលនាងបានជាសះស្បើយហើយ វាគឺជាសិទ្ធិស្របច្បាប់ក្នុងការទទួលបាន ដោយសារនាងជាកូនស្រីរបស់លោកអប្រាហាំ ព្រមទាំងជំនឿរបស់នាងបានអនុញ្ញាតឱ្យឫទ្ធានុភាពនោះហូរចូលក្នុងរូបកាយរបស់នាងដោយផ្ទាល់ ក្នុងពេលដ៏ជាក់លាក់មួយនោះ។

ការពិតដែលថានាងជាកូនស្រីរបស់លោកអប្រាហាំ វាប្រៀបដូចជាក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីមួយ ដែលមានភ្លើង និងខ្សែភ្លើងចូលក្នុងផ្ទះរបស់អ្នករួចហើយ។ អគ្គិសនីគឺមានហើយ ប៉ុន្តែការនេះមិនមានន័យថាភ្លើងក្នុងផ្ទះរបស់អ្នកនឹងភ្លឺដោយឯកឯងនោះទេ។ អ្នកត្រូវបើកកុងតាក់ភ្លើងជាមុនសិន ទើបភ្លើងអាចភ្លឺបាន។

ដូច្នេះតាមរយៈពូជពង្សដ៏ស្របច្បាប់របស់លោកអប្រាហាំ ស្រ្តីម្នាក់នេះមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានការជាសះស្បើយ។ ទោះជាយ៉ាងនេះក៏ដោយ នាងបានគ្រប់គ្រងលើផែនដី និងជីវិតរបស់នាង ហើយនាងបានបើកកុងតាក់ខ្លួនឯង ដើម្បីទទួលបានឫទ្ធានុភាពនៃការប្រោសឱ្យជានេះ។

ប៉ុន្តែ តើកុងតាក់នេះនៅឯណា? តើយើងបើកកុងតាក់យ៉ាងដូចម្តេចទៅ?

ដើម្បីយល់កាន់ច្បាស់ យើងត្រូវកំណត់និយមន័យនៃពាក្យរបស់យើងសិន។

## តើជំនឿគឺជាអ្វី?

ជំនឿ ជាពាក្យមួយដែលគ្រិស្តបរិស័ទមិនសូវយកចិត្តទុកដាក់ប៉ុន្មានទេ ហើយខ្ញុំជឿជាក់ថាមានមនុស្សជាច្រើន មិនមែនភាគច្រើនទេ ដែលមិនដឹងអំពីអត្ថន័យដ៏ពិតប្រាកដនៃពាក្យថាជំនឿនេះ។ ហេតុអ្វីបានជាវាមានសារៈសំខាន់? តើយើងអាចដឹងថាពួកគេមានជំនឿដោយរបៀបណា? ហើយត្រូវធ្វើយ៉ាងដូចម្តេចដើម្បីទទួលបានជំនឿ? ប្រសិនបើជំនឿ គឺជាកុងតាក់ដែលអនុញ្ញាតឱ្យមានការចាក់ប្រេងតាំងបង្ហូរមក ដើម្បីសង្គ្រោះស្រ្តីនេះ នោះយើងត្រូវតែមើលឱ្យបានម៉ត់ចត់ទៅលើពាក្យជំនឿនេះ!

យើងរកឃើញនិយមន័យនៃពាក្យជំនឿនៅក្នុងគម្ពីររ៉ូមជំពូក៤។

*ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏លោកអប្រាហាំនៅតែមានសង្ឃឹម និងមានជំនឿ ហើយលោកក៏បានទៅជាឪពុករបស់ជាតិសាសន៍ជាច្រើន ស្របតាមព្រះបន្ទូលដែលមានថ្លែងទុកមកថា «ពូជពង្សរបស់អ្នកនឹងមានច្រើនយ៉ាងនេះ»។ កាលណោះ លោកមានអាយុជិតមួយរយឆ្នាំហើយ ទោះបីលោកមើលមករូបកាយរបស់លោក ឃើញថាជិតស្លាប់ និងមើលទៅលោកយាយសារ៉ាឃើញថា ពុំអាចបង្កើតកូនបានសោះនោះក៏ដោយ ក៏ជំនឿរបស់លោកមិនអន់ថយដែរ។ លោកមិនបាត់ជំនឿ ហើយមិនសង្ស័យនឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទេ ផ្ទុយទៅវិញ ជំនឿរបស់លោកធ្វើឱ្យលោកមាន*

*កម្លាំងចិត្តនឹងលើកតម្កើងសិរីរុងរឿងរបស់ព្រះជម្ចាស់ ព្រោះលោកជឿប្រាកដក្នុងចិត្តថា បើព្រះជាម្ចាស់សន្យាធ្វើអ្វី ព្រះអង្គពិតជាមានឫទ្ធានុភាពនឹងសម្រេចតាមបានមិនខាន។*

—រ៉ូម ៤:១៨-២១

យើងត្រូវយល់ពីស្ថានភាពនៃរឿងនេះ។ លោកអប្រាហាំ និងលោកស្រីសារ៉ា មិនអាចមានកូនបានទេ។ ខ្ញុំមិនចង់មានន័យថាពួកគេមានបញ្ហាក្នុងការមានផ្ទៃពោះ ហើយគួរតែបន្តព្យាយាមឱ្យមានកូននោះទេ។ ខ្ញុំចង់មានន័យថាពួកគេមានអាយុជិត ១០០ឆ្នាំហើយ វាគឺហួសពេលហើយ។ រាងកាយរបស់ពួកគេមិនអាចមានកូនបានទេ វាមិនអាចទៅរួចទាល់តែសោះ! ប៉ុន្តែព្រះជាម្ចាស់បានសន្យាជាមួយលោកអប្រាហាំថា នឹងមានកូនចេញពីសាច់ឈាមគាត់។ ស្តាប់ទៅ វាហាក់ដូចជាមិនអាចទៅរួចទេ។

ព្រះគម្ពីរចែងថា លោកអប្រាហាំបានជឿប្រាកដក្នុងចិត្តថា ព្រះជាម្ចាស់មានអំណាចក្នុងការធ្វើតាមពាក្យសន្យារបស់ទ្រង់ ទោះបីជាអាយុរបស់គាត់បានបញ្ជាក់ថាវាជារឿងដែលមិនអាចទៅរួចក៏ដោយ។ នេះជានិយមន័យនៃជំនឿរបស់យើង៖ យើងជឿប្រាកដក្នុងចិត្ត ដោយដឹងថាព្រះមានអំណាចក្នុងការធ្វើតាមអ្វីដែលទ្រង់បានសន្យា។

ខ្ញុំនិយាយយ៉ាងដូច្នេះថា៖ «ចិត្តរបស់អ្នកយល់ព្រមជាមួយនឹងស្ថានសួគ៌» មិនគ្រាន់តែយល់ស្របតាមផ្លូវអារម្មណ៍ជាមួយអ្វីដែលព្រះមានបន្ទូលតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវជឿប្រាកដនៅក្នុងចិត្ត។

## និយមន័យរបស់យើង៖ អ្វីទៅជាជំនឿ?

សូមនិយាយឮៗជាមួយខ្ញុំ ដើម្បីប្រាកដថាអ្នកយល់៖ ជំនឿត្រូវតែជឿប្រាកដក្នុងចិត្តថា អ្វីៗដែលព្រះជាម្ចាស់មានបន្ទូល វានឹងកើតឡើង។ វាគឺជាចិត្ត និងគំនិតរបស់យើង ដែលយល់ព្រមជាមួយស្ថានសួគ៌ វាជាការជឿប្រាកដនៅក្នុងចិត្ត។

## ហេតុអ្វីបានជាត្រូវការជំនឿ?

ហេតុអ្វីបានជាព្រះជាម្ចាស់មិនអាចប្រោសមនុស្សគ្រប់រូបនៅក្នុងមន្ទីរពេទ្យឱ្យបានជា ពេលដែលទ្រង់ចង់ប្រោសពួកគេឱ្យជា? ហេតុអ្វីបានជាទ្រង់មិនអាចបញ្ឈប់សង្គ្រាម? ហេតុអ្វីបានជាទ្រង់មិនអាចចាត់ទេវតាឱ្យមកផ្សាយដំណឹងល្អដល់យើង? ខ្ញុំដឹងច្បាស់ថា អ្នកធ្លាប់បានឮសំណួរទាំងអស់នេះពីមុនមកហើយ។ ចម្លើយគឺថា ទ្រង់មិនអាចធ្វើដូច្នេះបានទេ។

វាមិនមែនមានន័យថា ព្រះម្ចាស់មិនមាន*អំណាច*ក្នុងការធ្វើដូច្នេះទេ។ ទ្រង់មិនមែនគ្រប់គ្រង ដើម្បីធ្វើការទាំងអស់នោះទេ។

ដើម្បីយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ ចូរយើងមើលគម្ពីរហេប្រឺទាំងអស់គ្នា។

*ផ្ទុយទៅវិញ មានម្នាក់បានផ្តល់សក្ខីភាពនៅក្នុងវគ្គមួយដែលថែងថា៖*

*«តើមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកដល់គេដូច្នេះតើបុត្រមនុស្សជាអ្វីដែរបានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ»? «ព្រះអង្គបានធ្វើ ឱ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឱ្យនៅក្រោមជើងរបស់គេ»។*

*ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឥតទុកឱ្យមានអ្វីមួយ<u>នៅសល់</u>ដែលពុំបានចុះចូលនោះឡើយ។ ក៏ប៉ុន្តែ នៅពេលនេះយើងពុំឃើញថាអ្វីៗសព្វសារពើសុទ្ធតែបានចុះចូលនឹងអំណាចរបស់មនុស្សហើយនោះទេ។*

—ហេប្រឺ ២:៦-៨

ព្រះជាម្ចាស់បានផ្ដល់សិទ្ធិឱ្យមនុស្សគ្រប់គ្រងស្របច្បាប់លើអាណាចក្រផែនដីនេះទាំងស្រុង ពេលដែលទ្រង់ផ្ដល់សិទ្ធិនេះឱ្យទៅមនុស្ស។ មិនមានអ្វីដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ទេ។ ទ្រង់បានសោយរាជ្យលើអាណាចក្រនេះដោយមានការគ្រប់គ្រង និងមានសិទ្ធិអំណាចយ៉ាងពេញលេញ។ សមត្ថភាពរបស់ទ្រង់ក្នុងការសោយរាជ្យដោយមានសិទ្ធិអំណាច ដែលបានទទួលការគាំទ្រពីការគ្រប់គ្រងនេះ គឺបានតាំងទ្រង់នៅទីនេះ។ ការដែលសំខាន់នោះ ទ្រង់បានគ្រប់គ្រងដោយតំណាងឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់ពាក់មកុដរបស់អ្នកគ្រប់គ្រង ដែលតំណាងឱ្យសិរីរុងរឿងនៃព្រះជាម្ចាស់ ការចាក់ប្រេងតាំង និងឋានៈនៃកិត្តិយស ឬសិទ្ធិអំណាចដែលទ្រង់មាន។

ពិតណាស់ ឥលូវនេះទ្រង់មិនបានពាក់មកុដដែកនោះទេ ប៉ុន្តែទ្រង់ពាក់មកុដមួយក្នុងន័យចង់បញ្ជាក់ថា មកុដនោះតំណាងឱ្យអ្វី។ ដើម្បីទទួលបានរូបភាពកាន់តែច្បាស់ថាវាមានលក្ខណៈបែបណា សូមគិតអំពីស្ដេចធម្មតាមួយអង្គ ទោះបីទ្រង់ជាមនុស្សធម្មតា ហើយមិនមានអំណាចពិតប្រាកដពីធម្មជាតិរបស់ទ្រង់ក៏ដោយ ពេលទ្រង់ពាក់មកុដដែលជានិមិត្តរូប ទ្រង់ឈរជាតំណាងមិនត្រឹមតែខ្លួនទ្រង់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាតំណាងនៃអាណាចក្រ និងការគ្រប់គ្រងទាំងមូលរបស់ព្រះអង្គផងដែរ។ ពាក្យសម្ដីរបស់ទ្រង់មានអំណាចដោយសារវាបានទទួលការគាំទ្រដោយអំណាច និងប្រភពនៃការគ្រប់គ្រង ព្រមទាំងអាណាចក្រដែលទ្រង់តំណាងឱ្យ។

**ស្ថានសួគ៌មិនមានសិទ្ធិគ្រប់គ្រងលើផែនដីទេ លុះត្រាតែមានបុរស ឬស្ត្រីដែលបានជឿប្រាកដក្នុងចិត្តអំពីអ្វីដែលស្ថានសួគ៌បានសម្ដែងប្រាប់ ហើយការនេះហៅថាជំនឿ។**

ប្រសិនបើអ្នកគិតអំពីប៉ូលីសចរាចរណ៍ម្នាក់ គាត់អាចបញ្ឈប់រថយន្តកុងតឺន័រសណ្ដោងដ៏ធំមួយបាន ដោយគ្រាន់តែប្រើពាក្យ «ឈប់សិន ត្រូវគោរពច្បាប់!»

ពិតមែនហើយ រថយន្តកុងតឺន័រនោះធំជាងប៉ូលីសនោះទៅទៀត។ បើយកប៉ូលីសនោះដាក់ក្នុងរថយន្តកុងតឺន័រនោះក៏មិនទាន់ពេញផង តែរថយន្តនោះត្រូវឈប់ដោយសារតែឯកសណ្ឋានដែលប៉ូលីសនោះពាក់ ដែលតំណាងឱ្យរដ្ឋាភិបាលដែលគាំទ្រគាត់។ ក្នុងករណីនេះ រដ្ឋាភិបាលគឺធំជាងប៉ូលីសដែលពាក់ឯកសណ្ឋាននោះទៅទៀត។ ចំណែកអ្នកបើករថយន្តកុងតឺន័រនោះវិញ គាត់មិនខ្លាចប៉ូលីសនោះទេ ប៉ុន្តែគាត់ខ្លាចរដ្ឋាភិបាលដែលប៉ូលីសនោះជាតំណាងឱ្យ ដូច្នេះគាត់ត្រូវឈប់រថយន្ត។ ដូចគ្នាដែរ អដាំបានគ្រប់គ្រងលើអ្វីៗទាំងអស់ដែលត្រូវបានបង្កើតឡើងនៅក្នុងផែនដីនេះ។ អំណាចនិងការគ្រប់គ្រងរបស់ព្រះជាម្ចាស់តំណាងដោយមកុដនៃសិរីល្អ និងកិត្តិយសបានផ្តល់ទៅឱ្យមនុស្ស ដោយធានាថាពាក្យសម្តីរបស់គាត់តំណាងឱ្យព្រះរាជ្យព្រះជាម្ចាស់។

> *ផ្ទៃមេឃជាកម្មសិទ្ធិ**របស់ព្រះអម្ចាស់** តែព្រះអង្គប្រទានផែនដីមក**ឱ្យមនុស្ស**លោក។*
>
> —ទំនុកតម្កើង ១១៥:១៦

នេះគឺជាគោលការណ៍នៃការគ្រប់គ្រងរបស់មនុស្សនៅលើផែនដី។ វាមានសារៈសំខាន់ក្នុងការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាពិសេសមូលហេតុដែលតម្រូវឱ្យមានជំនឿសម្រាប់ព្រះជាម្ចាស់ ដើម្បីទទួលបានការគ្រប់គ្រងដ៏ស្របច្បាប់ក្នុងស្ថានភាពមួយនោះ។

> *ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតាគេមើលងាយព្យាការី*តែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ»។ នៅទីនោះ ព្រះអង្គពុំអាចធ្វើការអស្ចារ្យអ្វីបានឡើយ បានត្រឹមតែដាក់ព្រះហស្តលើអ្នកជំងឺខ្លះដើម្បីប្រោសគេឱ្យបានជាប៉ុណ្ណោះ។ ព្រះអង្គនឹកឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។*
>
> —ម៉ាកុស ៦:៤-៦

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ប្រសិនបើខ្ញុំសួរទៅកាន់មនុស្សនៅតាមផ្លូវថាតើព្រះយេស៊ូអាចធ្វើការអស្ចារ្យដែរឬទេ? ពួកគេប្រហែលជានិយាយថា ទ្រង់អាចធ្វើបាន។ ហើយបើខ្ញុំសួរទៀតថា តើមានកន្លែងណានៅក្នុងព្រះគម្ពីរដែលព្រះយេស៊ូបានព្យាយាមធ្វើការអស្ចារ្យ ប៉ុន្តែមិនអាចធ្វើបានដែរឬទេ? តើពួកគេនឹងឆ្លើយយ៉ាងដូចម្ដេចវិញ?

ខ្ញុំធានាថាពួកគេនឹងប្រាប់ខ្ញុំថា ដូចជាគ្មានកន្លែងណានៅក្នុងព្រះគម្ពីរ ដែលព្រះអង្គមិនអាចធ្វើការអស្ចារ្យបានទេ ប៉ុន្តែអ្នកទើបតែអានជួបអម្បាញ់មិញនេះ។ ព្រះយេស៊ូមិនអាចប្រោសពួកគេឱ្យជាបានទេ។ ជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ខ្ញុំចង់ដឹងពីមូលហេតុនោះ។

ចម្លើយគឺសាមញ្ញទេ ទ្រង់មិនអាចធ្វើការអស្ចារ្យនោះបានទេ ហើយតលូវនេះអ្នកដឹងថា វាគឺដោយសារតែពួកគេគ្មានជំនឿ គ្មានការយល់ព្រមជាមួយស្ថានសួគ៌ ដូច្នេះហើយស្ថានសួគ៌មិនអាចគ្រប់គ្រងស្របច្បាប់ក្នុងស្ថានភាពបែបនេះបានទេ។

សូមឱ្យប្រាកដថាអ្នកយល់ច្បាស់អំពីអ្វីដែលយើងទើបបានរកឃើញ
អម្បាញ់មិញនេះ។

**ស្ថានសួគ៌មិនមានសិទ្ធិគ្រប់គ្រងលើផែនដីទេ លុះត្រាតែមានបុរស ឬស្ត្រីដែលបានជឿប្រាកដក្នុងចិត្តអំពីអ្វីដែលស្ថានសួគ៌បានសម្ដែងប្រាប់ ហើយការនេះហៅថាជំនឿ។**

ដូចនៅក្នុងឧទាហរណ៍ខាងដើមរបស់យើងអ៊ីចឹង ឧទាហរណ៍ថា អ្នកបានស្គាល់នរណាម្នាក់ដែលឈឺ ហើយគាត់ជាបុគ្គលល្បីនៅទូទាំងពិភពលោក។ មានការស្នើសុំឱ្យអធិស្ឋានសម្រាប់បុគ្គលម្នាក់នោះ ហើយមានមនុស្សជាច្រើនបានអធិស្ឋានឱ្យគាត់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បុគ្គលនោះនៅតែស្លាប់ដដែល។

តើព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបរាជ័យហើយ មែនទេ? អត់ទេ! វាមិនអាចទៅរួចទេ។ ដូច្នេះ យើងត្រូវស្វែងរកចម្លើយនៅកន្លែងផ្សេងទៀត។

*ពេលទូលទៅព្រះបិតា កុំពោលពាក្យច្រំដែលៗឥតប្រយោជន៍ ដូចសាសន៍ដទៃនោះឡើយ។ គេនឹកស្មានថា បើពោលពាក្យយ៉ាងច្រើនដូច្នេះ ព្រះរបស់គេនឹងស្តាប់គេ។ កុំធ្វើដូចគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត។*

—ម៉ាថាយ ៦:៧-៨

មានមនុស្សជាច្រើនជឿថា កាលណាមានមនុស្សអធិស្ឋានឱ្យកាន់តែច្រើន នោះឱកាសដែលព្រះជាម្ចាស់ទ្រង់ស្តាប់ឮក៏មានកាន់តែច្រើនផងដែរ ហើយទ្រង់នឹងបែរព្រះភក្ត្រមកជួយយើង។ ខ្ញុំសង្ឃឹមថា ខ្ញុំបាននិយាយក្តោបន័យគ្រប់គ្រាន់ហើយ ហើយពេលនេះអ្នកបានដឹងថា នេះគឺជាគំនិតខុសឆ្គងទាំងស្រុង។ ពេលដែលខ្ញុំនិយាយថា «គ្មានជំនឿ» ជាចម្បង ខ្ញុំកំពុងនិយាយអំពីជំនឿដែលមកពីព្រះជាម្ចាស់។ អ្នកត្រូវតែយល់ស្របថាព្រះយេស៊ូជាប្រភពនៃជំនឿយ៉ាងពេញលេញនៅក្នុងជីវិតយើង។ ក៏ប៉ុន្តែយោងតាមម៉ាកុសជំពូក៦ ទ្រង់មិនអាចប្រោសពួកគេឱ្យជាបានទេ។

ដូច្នេះ ប្រសិនបើអ្នក និងខ្ញុំកំពុងនិយាយអំពីមិត្តភក្តិម្នាក់ដែលមានជំងឺនោះ ហើយមានការអធិស្ឋានឥតឈប់ឈរសម្រាប់គាត់ នោះខ្ញុំចង់សួរអ្នកថា «តើគាត់នឹងនិយាយអ្វី? (មិត្តដែលមានជំងឺនោះ)»

អាចមានមនុស្ស២០ពាន់លាននាក់អធិស្ឋានសម្រាប់នរណាម្នាក់ ប៉ុន្តែប្រសិនបើអ្នកជំងឺនោះនិយាយថា គាត់នឹងត្រូវស្លាប់ហើយ អ៊ីចឹង គាត់ពិតជាត្រូវស្លាប់មែនហើយ។

ជាថ្មីម្តងទៀត សូមពិចារណាអំពីឧទាហរណ៍របស់យើង ដែលយើងទើបតែមើលនៅក្នុងសៀវភៅម៉ាកុសជំពូក៦។ យើងដឹងថាព្រះយេស៊ូមានជំនឿក្នុងការព្យាបាល ប៉ុន្តែទ្រង់មិនអាចធ្វើអ្វីបានឡើយ បើគ្មានជំនឿរបស់ពួកគេចូលរួមទេនោះ។

មានមនុស្សជាច្រើនមករកខ្ញុំ ដោយនិយាយថាជីដូន ឬជីតា ឬសាច់ញាតិរបស់ពួកគេណាម្នាក់កំពុងឈឺ ហើយនិយាយថាពួកគេបានអធិស្ឋានឱ្យរួចហើយ ប៉ុន្តែមិនបានជាសះស្បើយសោះ។ ខ្ញុំតែងតែសួរពួកគេវិញថា «តើជីដូនរបស់អ្នកនិយាយអ្វី? តើជីតារបស់អ្នកនិយាយអ្វី? តើពួកគេមានជំនឿដែរឬទេ?»

អ្នកឃើញទេ អ្នកមិនមានសិទ្ធិអំណាចខាងវិញ្ញាណ ដើម្បីគ្រប់គ្រងលើអ្នកណាផ្សេងទៀតទេ។ អ្នកអាចបម្រើពួកគេបាន ប៉ុន្តែពួកគេត្រូវតែចូលរួមជាមួយការប្រោសឱ្យជានោះ។ រឿងមួយដែលខ្ញុំប្រាប់ពួកគេឱ្យធ្វើ នៅពេលខ្ញុំអធិស្ឋានឱ្យពួកគេ គឺការផ្លាស់ប្តូររូបភាព។ ខ្ញុំកំពុងតែនិយាយអំពីរូបភាពដែលគេឃើញផ្ទាល់ខ្លួន អំពីស្ថានភាពរបស់ពួកគេនៅក្នុងចិត្ត។ ខ្ញុំចង់ផ្លាស់ប្តូររូបភាពនោះ ពីការស្លាប់ទៅជាជីវិតវិញ។

> *សិស្សរបស់លោកយ៉ូហាន បានរៀបរាប់ជូនលោកនូវហេតុការណ៍ទាំងអស់នោះ។ លោកយ៉ូហានក៏ហៅសិស្សពីរនាក់មក រួចចាត់ឱ្យទៅទូលសួរព្រះយេស៊ូជាអម្ចាស់ថា៖ «តើលោកជាព្រះគ្រិស្តដែលត្រូវយាងមក ឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។*
>
> *អ្នកទាំងពីរទៅដល់ទូលសួរព្រះយេស៊ូថា៖ «លោកយ៉ូហានបាទីស្តចាត់ឱ្យយើងខ្ញុំមកសួរលោកថា តើលោកជាព្រះគ្រិស្តដែលត្រូវយាងមក ឬមួយក៏យើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។ នៅគ្រានោះព្រះយេស៊ូកំពុងប្រោសអ្នកជំងឺ មនុស្សពិការ និងមនុស្សដែលមានវិញ្ញាណអាក្រក់នៅក្នុងខ្លួនឱ្យបានជា។ ព្រះអង្គក៏បានប្រោសមនុស្សខ្វាក់ជាច្រើនឱ្យមើលឃើញដែរ។*

*ព្រះអង្គមានព្រះបន្ទូលទៅសិស្សទាំងពីរនាក់នោះថា៖ «ចូរអ្នកទៅជំរាបលោកយ៉ូហាននូវហេតុការណ៍ ដែលអ្នករាល់គ្នាបានឃើញ និងបានឮ គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ មនុស្សថ្លង់ស្ដាប់ឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយគេនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ»។*

—លូកា ៧:១៨-២២

សូមកត់សម្គាល់ផងដែរថា ព្រះយេស៊ូមិនបានសំដៅលើបទគម្ពីរណាមួយឡើយ។ តាមពិតទៅទ្រង់អាចមានបន្ទូលថា «អ្នកត្រលប់ទៅប្រាប់លោកយ៉ូហាន ឱ្យបើកមើលបទគម្ពីរនេះ ឬបទគម្ពីរនោះទៅ»។ ប៉ុន្តែទ្រង់មិនបាននិយាយដូច្នេះទេ ទ្រង់បានប្រាប់គេឱ្យទៅប្រាប់យ៉ូហានអំពីរឿងល្អៗគ្រប់យ៉ាងដែលបានកើតឡើងដោយសារឫទ្ធានុភាព និងសិទ្ធិអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ។

ដើម្បីជួយមិត្តភក្ដិ ឬសមាជិកគ្រួសារអ្នក អ្នកត្រូវតែធ្វើដូច្នេះដែរ។ ប្រាប់មិត្តភក្ដិរបស់អ្នកដែលឈឺនោះនូវរឿងមួយ ដែលទាក់ទងជាមួយរបៀបដែលព្រះយេស៊ូបានប្រោសនរណាម្នាក់ឱ្យជា។ ប្រសិនបើអាច ចូរប្រាប់ពួកគេនូវរឿងរ៉ាវអំពីនរណាម្នាក់ដែលបានជាសះស្បើយពីជំងឺដូចគ្នានឹងជំងឺដែលកំពុងធ្វើទុក្ខដល់រាងកាយពួកគេ។ ការផ្ដល់រូបភាពបែបនេះ ធ្វើឱ្យមានការជំរុញចិត្តដល់ពួកគេ ហើយនាំមកនូវសេចក្ដីសង្ឃឹម។ សេចក្ដីសង្ឃឹមតែងតែមានរូបភាពវិជ្ជមានមកជាមួយវា ហើយនេះហើយគឺជារូបភាពដែលអ្នកចង់ឱ្យមិត្តភក្ដិ ឬសមាជិកក្រុមគ្រួសាររបស់អ្នកមើលឃើញ ថានៅទីនេះមានការប្រោសឱ្យជាពីជំងឺពិតប្រាកដមែន។

នៅពេលមិត្តភក្ដិ ឬសមាជិកគ្រួសាររបស់អ្នកឃើញថាវាអាចទៅរួចក្នុងការប្រោសឱ្យជា បន្ទាប់មកពួកគេនឹងសួរអ្នកអំពីរបៀបដែលអាចទទួលបានការប្រោសឱ្យជាបែបនោះដែរ។ នេះគឺជាពេលដែលអ្នកទន្ទឹងរង់ចាំ តលូវនេះ ពួកគេបើកចំហចិត្តដើម្បីទទួលការណែនាំពីព្រះបន្ទូលព្រះជាម្ចាស់ ព្រមទាំងគោលការណ៍នៃព្រះរាជ្យរបស់

ព្រះជាម្ចាស់ហើយ។ ទីមួយ អ្នកនឹងចង់នាំពួកគេឱ្យចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ប្រសិនបើពួកគេមិនទាន់បានកើតជាថ្មីទេ។ ទីពីរ សូមចំណាយពេលខ្លះជាមួយពួកគេ ដោយពន្យល់អំពីបទគម្ពីរដែលទាក់ទងជាមួយការប្រោសឱ្យជា។ បើអាចធ្វើបាន សូមទុកសម្ភារៈមួយចំនួនឱ្យពួកគេ ដើម្បីពង្រឹងអ្វីដែលអ្នកបានប្រាប់ពួកគេ។ យើងបានឃើញពីការពហុគុណនៃការប្រោសមនុស្សរាប់រយនាក់ឱ្យបានជាសះស្បើយពីជំងឺគ្រប់ប្រភេទ ព្រមទាំងទទួលសេរីភាពពីជំងឺផ្សេងៗដោយធ្វើតាមវិធីនេះ។ រឿងមួយទៀតដែលខ្ញុំធ្វើមុនពេលអធិស្ឋានសម្រាប់ពួកគេ ខ្ញុំសួរពួកគេជាមុនសិនអំពីមូលហេតុដែលពួកគេគិតថាពួកគេនឹងទទួលបានការប្រោសឱ្យជា។ ខ្ញុំចង់ឱ្យជំនឿរបស់ពួកគេត្រូវបានចងភ្ជាប់ជាមួយបទគម្ពីរមួយ ដោយមិនមែនគ្រាន់តែជាសកម្មភាពនៃសេចក្ដីអធិស្ឋានដ៏សាមញ្ញមួយនោះទេ។

ឥលូវនេះ យើងដឹងហើយថា អ្វីទៅគឺជាជំនឿ។ វាជាការយល់ស្របជាមួយស្ថានសួគ៌ ហើយចិត្តរបស់អ្នកបានជឿប្រាកដក្នុងចិត្តថា អ្វីដែលព្រះជាម្ចាស់មានបន្ទូលនឹងកើតជារូបរាងឡើង។ ហើយឥលូវនេះ យើងក៏ដឹងបន្ថែមទៀតថា ត្រូវទាមទារឱ្យមានជំនឿ ដើម្បីទទួលបានការគ្រប់គ្រងស្របច្បាប់នៅលើផែនដីនេះ តាមរយៈបុគ្គលដែលយល់ស្របជាមួយស្ថានសួគ៌។

## តើយើងទទួលបានជំនឿដោយរបៀបណា?

*ដូច្នេះ ជំនឿកើតមកពីសេចក្ដីដែលយើងបានស្ដាប់ រីឯសេចក្ដីដែលយើងបានស្ដាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ដ។*

—រ៉ូម ១០:១៧

តើជំនឿកើតឡើងពីការបានស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេចទៅ? តើវាមានដំណើរការអ្វីខ្លះ? តើការគ្រាន់តែបានស្តាប់ឮព្រះបន្ទូលនោះ នាំឱ្យមានជំនឿកើតឡើងនៅក្នុងព្រលឹងវិញ្ញាណមនុស្សឬ?

ដើម្បីយល់អំពីរបៀបដែលជំនឿកើតឡើង ហើយយល់ពីអ្វីដែលរ៉ូម ១០៖១៧ កំពុងនិយាយ យើងអាចមើលទៅម៉ាកុសជំពូក៤។ ខ្ញុំតែងតែនិយាយថា ទោះបើអ្នកបើកព្រះគម្ពីរអានដល់ណាក៏ដោយ ក៏អ្នកនៅតែមិនអាចគេចផុតពីម៉ាកុសជំពូក៤ដដែល ព្រោះបទគម្ពីរនេះសំខាន់ខ្លាំងណាស់!

ព្រះយេស៊ូមានបន្ទូលនៅក្នុងម៉ាកុស ៤:១៣ ថា៖ ប្រសិនបើអ្នកមិនយល់អំពីអ្វីដែលទ្រង់បានបង្រៀននៅក្នុងរឿងប្រៀបប្រដូចនេះទេ នោះអ្នកក៏មិនអាចយល់រឿងប្រៀបប្រដូច*ផ្សេងទៀត* នៅក្នុងព្រះគម្ពីរបានដែរ។ ខ្ញុំចង់និយាយថា វាពិតជាសំខាន់ខ្លាំងណាស់! ហេតុអ្វីបានជំពូកនេះមានសារៈសំខាន់ខ្លាំងដល់ម្ល៉េះ? ព្រោះវាប្រាប់យើងអំពីរបៀបដែលស្ថានសួគ៌ធ្វើការជាមួយអាណាចក្រផែនដីនេះ របៀបដែលស្ថានសួគ៌ទទួលបានការគ្រប់គ្រង និងកន្លែងដែលការគ្រប់គ្រងនេះកើតឡើង។ នៅក្នុងជីវិតអ្នកគ្មានអ្វីដែលសំខាន់ជាងការយល់អំពីអ្វីដែលជំពូកទាំងមូលកំពុងតែនិយាយទេ។

នៅក្នុងជំពូកនេះ ព្រះយេស៊ូបានប្រាប់យើងអំពីរឿងប្រៀបប្រដូចបីយ៉ាងទាក់ទងជាមួយរបៀបដែលជំនឿត្រូវបានកើតឡើងនៅក្នុងព្រលឹងវិញ្ញាណមនុស្ស។ ដូចដែលអ្នកបានដឹងហើយថា វាជាតម្រូវការរបស់ស្ថានសួគ៌ ដើម្បីឱ្យស្ថានសួគ៌អាចគ្រប់គ្រងផែនដីយ៉ាងស្របច្បាប់។ រឿងទាំងបីនៅក្នុងជំពូកនេះ គឺជារឿងប្រៀបប្រដូចអំពីអ្នកព្រោះពូជ រឿងប្រៀបប្រដូចរបស់បុរសព្រោះពូជម្នាក់ និងរឿងប្រៀបប្រដូចអំពីគ្រាប់ពូជល្អិត ។

*ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាបុរសម្នាក់ព្រោះស្រូវនៅក្នុងស្រែរបស់ខ្លួន។ ទោះបីគាត់ដេកក្តី ក្រោកក្តី យប់ក្តី*

*ថ្ងៃក្តី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ ដ្បិតដីធ្វើឱ្យពូជបង្កើតផលដោយខ្លួនឯង ដំបូងមានពន្លកលេចឡើង បន្ទាប់មក ក៏បែកជាកួរហើយចេញជាគ្រាប់ស្រូវ។ លុះស្រូវទុំគេយកកណ្តៀវមកច្រូត ដ្បិតដល់រដូវចំរូតហើយ»។*

—ម៉ាកុស ៤:២៦-២៩

រឿងដំបូងដែលយើងត្រូវធ្វើ គឺត្រូវពន្យល់ពាក្យរបស់យើងជាមុនសិន។ គ្រាប់ពូជដែលព្រះយេស៊ូកំពុងមានបន្ទូលគឺជាអ្វី? ហើយតើដីនោះតំណាងឱ្យអ្វីដែរ? តាមពិតទៅព្រះយេស៊ូបានពន្យល់ពាក្យទាំងពីរនេះកាលពីពេលមុន នៅក្នុងរឿងប្រៀបប្រដូចអ្នកព្រោះពូជនៅក្នុងជំពូកនេះរួចហើយ។

គ្រាប់ពូជ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយដីគឺជាចិត្តរបស់មនុស្ស ឬវិញ្ញាណរបស់មនុស្ស។ ដូច្នេះ ក្នុងរឿងប្រៀបប្រដូចនេះ ព្រះយេស៊ូមានបន្ទូលថាមានបុរសម្នាក់សាបព្រោះព្រះបន្ទូលរបស់ព្រះនៅក្នុងចិត្តរបស់គាត់ បន្ទាប់មកវា*បង្កើតផលដោយខ្លួនឯង។* ដី ឬចិត្តរបស់មនុស្សចាប់ផ្តើមបង្កើតជំនឿ ឬការព្រមព្រៀងជាមួយស្ថានសួគ៌។ នេះគឺជាដំណើរការធម្មជាតិ និងមុខងារនៃវិញ្ញាណរបស់អ្នក វានឹងបង្កើតផលផ្លែតាមអ្វីដែលអ្នកបានដាក់នៅទីនោះ។

មុននឹងខ្ញុំបន្តទៅមុខទៀត វាជារឿងសំខាន់ដែលអ្នកត្រូវចាំអំពីអ្វីជានិយមន័យនៃជំនឿរបស់យើង *បុរស ឬស្ត្រីបានជឿប្រាកដក្នុងចិត្តអំពីអ្វីដែលស្ថានសួគ៌បានសម្តែងប្រាប់។*

រឿងដែលត្រូវចងចាំនៅទីនេះគឺ ការព្រមព្រៀងជាមួយស្ថានសួគ៌ វាមិនដូចគ្នាជាមួយការព្រមព្រៀងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ។ នៅក្នុងព្រះគម្ពីរបានប្រាប់យើងថា លោកអប្រាហាំបានជឿប្រាកដក្នុងចិត្ត។ ដើម្បីជួយអ្នកឱ្យយល់ច្បាស់នូវរូបភាពអំពីឃ្លាដែលនិយាយថា បានជឿប្រាកដក្នុងចិត្តមានន័យយ៉ាងណា ខ្ញុំសូម

លើកឧទាហរណ៍មួយមកបង្ហាញ។ ឧទាហរណ៍ថា ខ្ញុំបានប្រាប់អ្នកឱ្យលោតពីលើកំពូលអគារ Empire State ក្នុងទីក្រុងញូវយ៉ក។ ដើម្បីបញ្ចុះបញ្ចូលអ្នកឱ្យសាកល្បងលោត ខ្ញុំបានប្រាប់អ្នកថា ប្រសិនបើអ្នកទទះដៃរបស់អ្នកឱ្យញាប់ អ្នកអាចហោះហើរចុះមកដល់ដីដោយសុវត្ថិភាព។ អ្នកនឹងសើចដាក់ខ្ញុំ ព្រោះអ្នក**ដឹង**អំពីអ្វីដែលនឹងកើតឡើងចំពោះអ្នកហើយ បើអ្នកព្រមលោតពីលើកំពូលអគារនោះ។ អ្នកបានជឿប្រាកដក្នុងចិត្តអំពីលទ្ធផលវាហើយ។ នេះគឺជាលក្ខណៈនៃការជឿប្រាកដក្នុងចិត្ត។ អ្នក**បានដឹង**អំពីវា អ្នកបានប្រាកដក្នុងចិត្តថា វាគ្មានហេតុផលណាផ្សេងទៀតដែលអាចទៅរួចបានទេ អ្នកនឹងស្លាប់ជាមិនខាន ប្រសិនសិនអ្នកលោតចុះមែននោះ។

ដូច្នេះ សូមគិតអំពីស្ថានភាពមួយផ្សេងទៀត ហើយចាំមើលអ្នកដោះស្រាយវាដោយរបៀបណា។ ឧទាហរណ៍ថា អ្នកបានឃើញដុំពកមួយយ៉ាងធំនៅក្នុងរាងកាយអ្នក ហើយគ្រូពេទ្យបាននិយាយថាអ្នកសល់ពេលតែមួយខែប៉ុណ្ណោះ។ អ្នកមានជំងឺមហារីក។ តាមពិតទៅ គ្រូពេទ្យនិយាយថាជំងឺមហារីករបស់អ្នក គឺជាប្រភេទជំងឺដ៏កម្រមួយ បើពិនិត្យឃើញវាហើយ នោះគ្មាននរណាម្នាក់អាចមានជីវិតរស់នៅបានទេ។

ឥលូវនេះ ឧទាហរណ៍ថាអ្នកបានដឹងពី ១ពេត្រុស ២:២៤ ដែលចែងថា៖

> *«ព្រះគ្រិស្តបានផ្ទុកបាបរបស់យើង» ក្នុងព្រះកាយរបស់ព្រះអង្គដែលជាប់លើឈើឆ្កាង ដើម្បីឱ្យយើងលែងជំពាក់ជំពិននឹងបាបតទៅមុខទៀត ហើយឱ្យយើងមានជីវិតដោយប្រព្រឹត្តតែអំពើសុចរិត។ «បងប្អូនបានជាសះស្បើយដោយសារស្នាមរបួសរបស់ព្រះអង្គ»។*

—១ពេត្រុស ២:២៤

បទគម្ពីរនេះប្រាប់យើងនូវចម្លើយរួចហើយ ប៉ុន្តែអ្នក និងខ្ញុំមានបញ្ហាធំមួយ៖ យើងធំធាត់ឡើងនៅក្នុងលោកិយនៃសេចក្តីងងឹត ដែលមានការខូចខាត និងការស្លាប់នៅជុំវិញយើង។ យើងបានធំធាត់ឡើងនៅក្នុងលោកិយនៃភាពភ័យខ្លាច ហើយជឿ

ប្រាកដក្នុងចិត្តអំពីអ្វីដែលការភ័យខ្លាចនោះបានប្រាប់យើង។ ដូច្នេះ នៅក្នុងការបកស្រាយខាងលើ យើងបានទទួលការបណ្ដុះគំនិតថា ជំងឺមហារីកអាចសម្លាប់មនុស្សបាន។ យើងមានភស្ដុតាងនៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយដែលនិយាយថា នេះគឺជារឿងពិត។ ដូច្នេះ តើយើងនឹងផ្លាស់ប្ដូរការព្រមព្រៀងរបស់យើងដោយរបៀបណា? តើយើងអាចជឿប្រាកដក្នុងចិត្តនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូលដោយរបៀបណា? ពិតមែនហើយតាមពិតទៅ យើងមិនអាចធ្វើអ្វីដោយខ្លួនឯងបានទេ។ ប៉ុន្តែព្រះបន្ទូលព្រះជាម្ចាស់មានជីវិត ហើយពោរពេញដោយអំណាច។ ពេលអ្នកដាំវានៅក្នុងព្រលឹងវិញ្ញាណអ្នក វានឹងបង្កើតផលផ្លែដោយខ្លួនឯង។ ពេលនោះព្រលឹងវិញ្ញាណរបស់អ្នក និងព្រះបន្ទូលចាប់ផ្ដើមបង្កើតការព្រមព្រៀងជាមួយអ្វីដែលស្ថានសួគ៌បានសម្ដែងប្រាប់យើង។

> *ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាបុរសម្នាក់ព្រោះស្រូវ នៅក្នុងស្រែរបស់ខ្លួន។ ទោះបីគាត់ដេកក្ដី ក្រោកក្ដី យប់ក្ដី ថ្ងៃក្ដី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ ដ្បិតដីធ្វើឱ្យពូជបង្កើតផលដោយខ្លួនឯង ដំបូងមានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ។ លុះស្រូវទុំ គេយកកណ្ដៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ»។*

—ម៉ាកុស ៤:២៦-២៩

ចំណែក ដី (ចិត្តរបស់អ្នក) វាបង្កើតផលដោយខ្លួនឯង ដោយឱ្យមានការព្រមព្រៀងនេះកើតឡើង។ សូមកត់សម្គាល់ថា អ្នកមិនអាចអធិស្ឋានឱ្យមានជំនឿបានទេ។ វាជាតួនាទីមួយនៃចិត្តរបស់អ្នក និងព្រះបន្ទូល។ ពេលយើងក្រឡេកមើលអត្ថបទនេះ យើងអាចឃើញថា ការព្រមព្រៀងរវាងចិត្តរបស់យើងជាមួយស្ថានសួគ៌គឺជាដំណើរការមួយ។ វាមិនអាចកើតឡើងភ្លាមៗបានទេ។ ការបង្ហាញនេះបានប្រាប់យើងថា ដំបូងឡើយ នៅពេលចិត្តរបស់យើងទទួលបានព្រះបន្ទូល នោះជំនឿក៏ចាប់ផ្ដើមលូតលាស់

ប៉ិចឡើង ឬលូតលាស់ជាពន្លកនៃគ្រាប់ពូជដែលទើបតែបានដាំនៅទីនោះ។ បន្ទាប់មក វាបន្តលូតលាស់រហូតក្លាយជាដើម ហើយបង្កើតជាសំបក។ សំបកគឺជាកន្លែងដែលគ្រាប់ពូជ ឬផ្លែឈើចាប់ផ្តើមលេចចេញជារូបរាងឡើង។ នៅក្នុងដំណាក់កាលនៃជីវិតរុក្ខជាតិនេះ អ្នកមិនទាន់អាចបរិភោគវាបានភ្លាមៗទេ។ រុក្ខជាតិនេះមិនទាន់មានការបង្កើតជាផ្លែចាស់ ឬទុំនៅឡើយទេ ប៉ុន្តែវាកំពុងតែលូតលាស់ឡើងហើយ។

ដូច្នេះ វាគឺស្រដៀងគ្នាជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ មិនទាន់ឃើញមានការផ្លាស់ប្តូរលក្ខណៈខាងក្រៅនៅឡើយទេ នៅពេលដែលជំនឿកំពុងលូតលាស់។ មិនទាន់មានការព្រមព្រៀងនៅឡើយទេ ប៉ុន្តែអ្នកត្រូវប្រាកដក្នុងចិត្តថារុក្ខជាតិនោះ*កំពុង*លូតលាស់ ជំនឿ*កំពុង*បង្កើតផល ហើយការព្រមព្រៀង*កំពុង*កើតមានឡើង។ ព្រះយេស៊ូបន្តពន្យល់ថា កាលណាគ្រាប់នៅក្នុងសំបកចាស់ ឬទុំ រដូវច្រូតបានមកដល់ហើយ ការព្រមព្រៀងមាននៅទីនោះរួចហើយ ហើយឥលូវនេះ ជំនឿក៏នៅទីនោះដែរ។

ពេលអ្នកដាំគ្រាប់ពូជនៅក្នុងដី តាមដំណើរការនៃដំណុះរុក្ខជាតិ រុក្ខជាតិនោះចាប់ផ្តើមលូតលាស់ ប៉ុន្តែមិនទាន់មានផ្លែនៅឡើយទេ។ រុក្ខជាតិនោះបន្តលូតលាស់រហូត ដរាបណាវាស្ថិតនៅក្នុងបរិយាកាសត្រឹមត្រូវ។ ពេលណាវាដល់អាយុវាហើយ នោះវានឹងបញ្ចេញផ្លែរបស់វាមក។

អាចនិយាយតាមបែបនេះវិញ ឧទាហរណ៍ថា អ្នកកំពុងតែដាំពោត។ ដើមពោតបានដុះស្នៀតចេញមកក្រៅ ប៉ុន្តែដំបូងវាគ្រាន់តែជាស្នៀតពោតតូចប៉ុណ្ណោះ វាមិនទាន់មានផ្លែពោតចាស់ដែលអ្នកអាចយកទៅបរិភោគបានទេ។ ប៉ុន្តែបន្ទាប់ពីមួយរដូវកាលក្រោយមក ទើបផ្លែពោតដែលនៅជាប់នឹងស្នៀតនោះវាចាស់ ឬទុំ។ សូមយកចិត្តទុកដាក់នៅត្រង់នេះ! ពេលនេះគ្រាប់ពោតដែលនៅលើស្នៀត មានលក្ខណៈដូចជាគ្រាប់ពោតដែលបានសាបព្រោះក្នុងដីពីដំបូងអ៊ីចឹង ហើយនេះហើយជាការព្រមព្រៀងគ្នា។

## ពេលដែលគ្រាប់ពូជនៅក្នុងសំបករុក្ខជាតិមានផ្លែចាស់ទៅ វាមើលទៅ — មានលក្ខណៈដូចគ្នានឹងគ្រាប់ពូជដែលបានសាបព្រោះកាលពីមុន។

ទាក់ទងនឹងការដាំដំណាំពោត គ្រាប់ពោតដែលចាស់នៅនឹងស្នៀត មានលក្ខណៈដូចគ្នានឹងគ្រាប់ពោតដែលអ្នកបានដាំដែរ។ ពួកវាគឺដូចគ្នា។ វាមើលទៅដូចគ្នា ហើយមានរសជាតិដូចគ្នា និយាយរួមវាគឺដូចគ្នាបេះបិទតែម្តង។

ដូច្នេះ ខ្ញុំសូមបកស្រាយអ្វីដែលព្រះយេស៊ូកំពុងមានព្រះបន្ទូល។ ពេលដែលយើងឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ (រ៉ូម ១០:១៧) នោះយើងប្រាកដជាកំពុងតែសាបព្រោះព្រះបន្ទូលនោះចូលទៅក្នុងព្រលឹងវិញ្ញាណរបស់យើង ឬចិត្តរបស់យើង។ បើយើងរក្សាទុកព្រះបន្ទូលនោះនៅក្នុងចិត្តរបស់យើង នោះវានឹងលូតលាស់ឡើង ហើយក្លាយទៅជាចាស់ទុំ។ ពេលដែលវាចាស់ទុំហើយ ចិត្តរបស់យើងនឹងជឿប្រាកដក្នុងចិត្តអំពីអ្វីដែលស្ថានសួគ៌បានសម្តែងប្រាប់យើង។ ស្ថានសួគ៌ និងផែនដីដើរស្របគ្នា ហើយឥលូវនេះ ស្ថានសួគ៌ទទួលបានការគ្រប់គ្រងស្របច្បាប់នៅលើអាណាចក្រផែនដី តាមរយៈបុគ្គលដែលបានជឿប្រាកដក្នុងចិត្ត។ គំនិត និងជំនឿរបស់យើងត្រូវតែត្រូវគ្នាជាមួយអ្វីដែលស្ថានសួគ៌បានសម្តែងប្រាប់យើង ដោយមានទំនុកចិត្តខ្លាំងបំផុត។ ការនេះមិនទាក់ទងជាមួយផ្លូវចិត្តទេ។ ឥលូវនេះ វាបានក្លាយជាអ្វីដែលយើងជឿជាក់យ៉ាងពិតប្រាកដ ដូចដែលយើងជឿជាក់ថា ដុំថ្មនឹងធ្លាក់ចុះក្រោម បើយើងទម្លាក់វាចុះមក។ ស្ថានសួគ៌សាបព្រោះព្រះបន្ទូលពីស្ថានសួគ៌មកក្នុងអាណាចក្រផែនដីនេះ ដែលជាកន្លែងដែលនឹងនាំមកនូវការព្រមព្រៀង និងព្រះហឫទ័យព្រះជាម្ចាស់។ បើស្ថានសួគ៌បានសម្តែងថាអ្នកបានប្រោសឱ្យជាហើយ នោះពេលដែលព្រះបន្ទូលនោះបានរីកដុះដាលនៅក្នុងចិត្តរបស់អ្នក អ្នកនឹងឃើញការប្រោសឱ្យជាបានកើតឡើង ដូចដែលស្ថានសួគ៌បានសម្តែងប្រាប់។ សូមកុំភ័យខ្លាចឡើយ។ ពេលអ្នកបិទភ្នែក អ្នកនឹងឃើញខ្លួនឯងបានជាសះស្បើយ! នេះជាមូលហេតុដែលហេប្រឺ ១១:១ ចែងថា៖

*ជំនឿធ្វើឱ្យយើងមានអ្វីៗដែលយើងសង្ឃឹមថានឹងបាន និងធ្វើឱ្យស្គាល់ជាក់ច្បាស់នូវអ្វីៗដែលយើងមើលពុំឃើញ។*

អ្នកប្រហែលជាមិនទាន់ឃើញវានៅក្នុងលក្ខណៈខាងក្រៅ ប៉ុន្តែអ្នកបានឃើញវានៅក្នុងព្រលឹងវិញ្ញាណរបស់អ្នករួចហើយ។ ហើយវាដូចជារបស់ពិតដែលអ្នកអាចកាន់ក្នុងដៃបាន។ ការព្រមព្រៀងនោះត្រូវបានគេហៅថាជំនឿ ហើយជំនឿនោះនឹងនាំរូបភាពនោះឱ្យឆ្លងកាត់នៅក្នុងអាណាចក្រផែនដីនេះចូលទៅក្នុងជីវិតរបស់អ្នក!

ប៉ុន្តែនេះមិនមែនជាកន្លែងដែលម៉ាកុសជំពូក ៤ ចប់ត្រឹមនេះទេ។ បន្ទាប់ពីជំពូកនេះមក វាបានបង្រៀនយើងអំពីរបៀបដែលចិត្តរបស់យើងព្រមព្រៀងគ្នាជាមួយស្ថានសួគ៌ ហើយក៏មានជំនឿកើតឡើងនៅកន្លែងនោះដែរ។ ជំពូកនេះបានផ្តល់ការណែនាំដល់យើងអំពីរបៀបប្រមូលផលចម្រូត។

*លុះស្រូវទុំ* ***គេយកកណ្តៀវមកច្រូត*** *ដ្បិតដល់រដូវចម្រូតហើយ។*

—ម៉ាកុស ៤:២៩

សូមកត់សម្គាល់ថា ទោះបីចិត្តអ្នកស្ថិតនៅក្នុងការព្រមព្រៀងជាមួយស្ថានសួគ៌ហើយ ហើយមានជំនឿហើយក៏ដោយ ក៏មិនទាន់មានផលផ្លែកើតឡើងភ្លាមៗដែរ។ ហេតុអ្វីទៅ? ដូចដែលខ្ញុំបាននិយាយរួចមកហើយ អ្នកទទួលបានការគ្រប់គ្រងស្របច្បាប់នៅលើអាណាចក្រផែនដីនេះហើយ។

តើអ្នកនៅចាំការពិភាក្សារបស់យើងអំពីលូកាជំពូក៨ ដែលនិយាយអំពីស្ត្រីធ្លាក់ឈាមដែរឬទេ? ចូរនឹកចាំអំពីពាក្យដែលព្រះយេស៊ូបានមានបន្ទូល *«កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ»* ។ ខ្ញុំសូមបញ្ជាក់ប្រាប់អ្នកថា ពេលព្រះយេស៊ូបានប្រើពាក្យថា «កូនស្រី» នោះទ្រង់ចង់បង្ហាញអំពីការសម្រេចនៃការស្របច្បាប់នៅឯស្ថានសួគ៌។ នាងជាកូនស្រីរបស់ពូជពង្សអប្រាហាំ។ នាងមានសិទ្ធិស្របច្បាប់។ ខ្ញុំបាន

ប្រៀបធៀបវាជាមួយការមានខ្សែភ្លើងចេញពីរោងចក្រអគ្គិសនីតភ្ជាប់ទៅផ្ទះរបស់អ្នក។ នៅទីនោះគឺមានភ្លើងអគ្គិសនីរួចហើយ ហើយអាចប្រើប្រាស់បាន ប៉ុន្តែអ្នកត្រូវតែចុចបើកកុងតាក់ភ្លើងនោះជាមុនសិន ទើបភ្លើងអាចភ្លឺបាន។ ដូចគ្នាដែរ ពេលនោះជំនឿបានកើតឡើងហើយ ហើយក៏មានភ្លើងអគ្គិសនីអាចប្រើប្រាស់បានដែរ ប៉ុន្តែភ្លើងនឹងមិនភ្លឺទេ ទាល់តែអ្នកទៅបើកកុងតាក់សិន។

អ្នកត្រូវតែស្រាយអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅក្នុងអាណាចក្រផែនដីនេះ ព្រោះមានតែបុរស ឬស្ត្រីនៅលើផែនដីនេះទេ ទើបអាចដោះស្រាយដោយស្របច្បាប់បាន។ គោលការណ៍នេះបានប្រាប់យើងយ៉ាងច្បាស់អំពីរបៀបដែលអ្នកបានទទួលការសង្គ្រោះ ដូចដែលបានរៀបរាប់នៅក្នុងរ៉ូម ១០:១០។

> *ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿ នោះយើងនឹងទទួលការសង្គ្រោះ។*
>
> —រ៉ូម ១០:១០

ដោយមនុស្សមានចិត្តជឿលើព្រះបន្ទូលព្រះជាម្ចាស់ នោះពួកគេទទួលបានការប្រោសឱ្យបានសុចរិត។ ការប្រោសឱ្យបានសុចរិត គឺជាពាក្យទាក់ទងនឹងច្បាប់ដែលជាច្បាប់ស្តីពីការគ្រប់គ្រង។ ដូច្នេះពេលដែលចិត្តបុរស និងស្ត្រីស្ថិតក្នុងការព្រមព្រៀងគ្នាជាមួយស្ថានសួគ៌ នៅពេលពួកគេជឿលើអ្វីដែលស្ថានសួគ៌បានសម្តែងប្រាប់ពួកគេ នោះពួកគេទទួលបានការប្រោសឱ្យបានសុចរិតនៅចំពោះស្ថានសួគ៌ និងផែនដីផងដែរ។ ឥលូវនេះ វាស្របច្បាប់ក្នុងការដែលស្ថានសួគ៌បង្ហូរភាពសុចរិតចូល*ទៅក្នុង*ជីវិតពួកគេ និង*តាមរយៈ*ជីវិតពួកគេ ហើយជះឥទ្ធិពលលើផែនដីនេះ ដោយតំណាងឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។ ប៉ុន្តែគួរឱ្យចម្លែក ទោះបីជាឥលូវនេះមានច្បាប់ ហើយមានជំនឿហើយក៏ដោយ នៅតែគ្មានអ្វីកើតឡើងដដែល។ «ប៉ុន្តែ ហ្គារី ខ្ញុំគិតថាលោកគ្រូបាននិយាយថា បើខ្ញុំមានជំនឿ នោះនឹងផ្តល់សិទ្ធិឱ្យស្ថានសួគ៌គ្រប់គ្រងស្របច្បាប់នៅលើ

ផែនដីនេះ»។ ត្រឹមត្រូវហើយ ប៉ុន្តែត្រូវតែមាននរណាម្នាក់ស្រាយសិទ្ធិអំណាចរបស់ស្ថានសួគ៌នៅទីនេះជាមុនសិន ពេលដែលមានជំនឿហើយ។ សូមពិនិត្យមើលបទគម្ពីររបស់យើងបន្ថែមទៀត។

> *ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿ នោះយើងនឹងទទួលការសង្គ្រោះ។*
>
> —រ៉ូម ១០:១០

ពេលដែលអ្នកមានជំនឿ ឬបានប្រោសឱ្យបានសុចរិតហើយ នោះគឺដល់ពេលស្របច្បាប់សម្រាប់ស្ថានសួគ៌គ្រប់គ្រងផែនដីហើយ។ ប៉ុន្តែសូមកត់សម្គាល់ថា បើអ្នក*បើកមាត់របស់អ្នក* ហើយប្រកាសពីជំនឿរបស់អ្នក នោះអ្នកទទួលបានការសង្គ្រោះ។ តើអ្នកឃើញផ្នែកទាំងពីរនេះដែរឬទេ? ផ្នែកនៃស្ថានសួគ៌កំពុងនាំយកព្រះបន្ទូលទៅក្នុងចិត្តរបស់អ្នក ដែលជាកន្លែងដែលបង្កើតការព្រមព្រៀងនៅទីនោះ នៅក្នុងអាណាចក្រផែនដី។ បន្ទាប់មក ពេលដែលមានការព្រមព្រៀងគ្នា ឬសេចក្តីជំនឿនៅទីនោះហើយ នោះអ្នកត្រូវតែធ្វើតាមការព្រមព្រៀងនេះ ហើយស្រាយសិទ្ធិអំណាចនៃស្ថានសួគ៌ទៅក្នុងស្ថានភាពរបស់អ្នក ដើម្បីទទួលបាននូវអ្វីដែលស្ថានសួគ៌បានសម្តែងប្រាប់អ្នក។

**ពេលដែលអ្នកមានជំនឿ ឬបានប្រោសឱ្យបានសុចរិតហើយ នោះគឺដល់ពេលស្របច្បាប់សម្រាប់ស្ថានសួគ៌គ្រប់គ្រងផែនដីហើយ។**

នៅក្នុងបទគម្ពីររបស់យើង នៅក្នុងម៉ាកុសជំពូក៤ចែងថា នៅពេលដែលរដូវច្រូតបានមកដល់ មនុស្ស (នៅលើផែនដី) យកកណ្តៀវមកច្រូត។ គាត់គឺជាអ្នកដែលប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ពេលដែលមានជំនឿនៅទីនោះហើយ។ ហើយគាត់នឹងទទួលបានចម្រូតនោះយ៉ាងពិតប្រាកដ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំសូមត្រលប់ទៅនិយាយអំពីកណ្តៀរ ដែលបានបង្ហាញនៅក្នុងម៉ាកុសជំពូក ៤ បន្តិចសិន។ ខ្ញុំជឿថាក្រុមជំនុំសកលភាគច្រើន មិនធ្លាប់បានបង្រៀនពីរបៀបប្រើកណ្តៀរទេ មានន័យថាពួកគេមិនធ្លាប់បានបង្រៀនអំពីរបៀបច្រូតកាត់នូវអ្វីដែលពួកគេត្រូវការនោះទេ។ ខ្ញុំក៏មិនដឹងអំពីរបៀបច្រូតកាត់នេះដែរ រហូតទាល់តែព្រះជាម្ចាស់ចាប់ផ្តើមបង្រៀនខ្ញុំ ពីរបៀបដែលព្រះរាជ្យរបស់ជាម្ចាស់មានដំណើរការ។ ការបើកសម្តែងដំបូងរបស់ខ្ញុំ អំពីដំណើរការដ៏សំខាន់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់នេះ បានកើតឡើងជាច្រើនឆ្នាំមកហើយ នៅពេលដែលខ្ញុំត្រូវបានអញ្ជើញឱ្យទៅលើកទឹកចិត្តនៅវេនថ្វាយបង្គំពេលយប់ថ្ងៃពុធ នៅឯក្រុមជំនុំមួយនៅក្នុងរដ្ឋអាត្លង់តា។

ក្រុមជំនុំនោះមិនធំប៉ុន្មានទេ ប៉ុន្តែវាមិនបញ្ហាអ្វីទេសម្រាប់ខ្ញុំ។ ខ្ញុំគ្រាន់តែចូលចិត្តបង្រៀនមនុស្សអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ពេលខ្ញុំទៅដល់ក្រុមជំនុំនោះ ខ្ញុំបានឃើញថាវាចម្លែក ព្រោះទ្វារជាប់សោ ហើយគ្មានអ្នកណានៅទីនោះសោះ។ វាសល់ពេលតែដប់នាទីទៀតប៉ុណ្ណោះ កម្មវិធីនឹងត្រូវចាប់ផ្តើមហើយ។

បន្ទាប់មក ខ្ញុំបានឮសំឡេងរថយន្តខ្លាំងៗពីក្រោយខ្ញុំ ខ្ញុំក៏ងាកមើលទៅ ក៏ឃើញរថយន្ត Pickup ចាស់មួយគ្រឿងបើកមកពីក្រោយផ្លូវចូលក្រុមជំនុំ។ ខ្ញុំមិនបានគិតអ្វីពីការនោះទេ។ ទោះជាយ៉ាងណា ខ្ញុំបានមកដល់ជាយក្រុងរដ្ឋអាត្លង់តាហើយ។

នៅពេលខ្ញុំកំពុងរង់ចាំនៅទីនោះ មានបុរសម្នាក់ដើរមកពីក្រោយអគារ ហើយណែនាំខ្លួនថាជាគ្រូគង្វាល។ គាត់បាននិយាយថា ឱ្យគាត់សុំទោសផងដែលគាត់មកយឺត ប៉ុន្តែរថយន្ត Pickup ចាស់របស់គាត់មិនមានដំណើរការល្អទេ។ គាត់បានប្រាប់ខ្ញុំថា គាត់បានបញ្ឆេះរថយន្តនោះដោយរុញវាចុះពីលើភ្នំ ពេលដែលម៉ាស៊ីនវារលត់ម្តងៗ។ គាត់បានបន្តនិយាយទៀតថា ពេលខ្លះវាមិនឆេះទាល់តែសោះ ហើយគាត់ត្រូវបង្ខំចិត្តដើរចម្ងាយ ៨ គីឡូម៉ែត្រទៅក្រុមជំនុំ។

ខ្ញុំទទួលស្គាល់ថា ខ្ញុំមានការភ្ញាក់ផ្អើលបន្តិចចំពោះការសន្ទនាមួយនេះ។ គាត់បានបន្តពន្យល់ថា ព័ន្ធកិច្ចរបស់គាត់គឺជាព័ន្ធកិច្ចឈោងចាប់ដ៏សំខាន់មួយ ហើយគាត់បានផ្តល់អាហារដល់មនុស្សរាប់ពាន់នាក់ជារៀងរាល់ខែ ជាញឹកញាប់បានផ្តល់អាហារជាង១០.០០០នាក់ ក្នុងមួយខែៗនៅទីតាំងមួយកន្លែងៗ។

ពេលដែលគ្រូគង្វាលនិយាយបែបនេះ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ពិបាកចិត្ត។ នេះគឺជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដែលបានចម្អែតមនុស្ស១០.០០០នាក់ក្នុងមួយខែ តែសម្រាប់ខ្លួនគាត់វិញ សូម្បីតែរថយន្តដ៏សមរម្យមួយគ្រឿងក៏គ្មានដែរ? ខ្ញុំត្រូវធ្វើអ្វីម្យ៉ាងហើយ។ ខ្ញុំមានរថយន្តថ្មីមួយដែលទើបតែជិះបានចម្ងាយ ២០.០០០ ម៉ែល៍ទុកនៅផ្ទះ ហើយខ្ញុំបានសម្រេចចិត្តឱ្យរថយន្តនោះទៅគាត់។

ខ្ញុំបានប្រាប់គាត់អំពីផែនការរបស់ខ្ញុំ ហើយថាខ្ញុំនឹងបញ្ជូនបុគ្គលិករបស់ខ្ញុំម្នាក់ទៅរដ្ឋអាត្លង់តា ដោយយករថយន្តមួយគ្រឿងនោះទៅឱ្យគាត់។ ពិតមែនហើយគាត់រំភើបចិត្តណាស់។ ខ្ញុំបានចំណាយពេលវេលានៅយប់នោះដើម្បីបង្រៀនគាត់ និងក្រុមជំនុំតូចរបស់គាត់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលវាមានដំណើរការទាក់ទងជាមួយប្រាក់។ ខ្ញុំដឹងថាវាសំខាន់ខ្លាំងណាស់។ ខ្ញុំបានចាប់ផ្តើមបង្ហាញពីលក្ខណៈនៃព្រះរាជ្យរបស់ជាម្ចាស់ទៅកាន់អស់អ្នកដែលត្រូវការវាយ៉ាងខ្លាំង។

ពេលខ្ញុំទៅដល់ផ្ទះវិញ ខ្ញុំបានរៀបចំរថយន្តមួយគ្រឿងដែលត្រូវយកទៅរដ្ឋអាត្លង់តា។ ពេលបុគ្គលិករបស់ខ្ញុំមកយករថយន្តនោះ ខ្ញុំបានដឹងថាខ្ញុំកំពុងធ្វើការព្រមព្រៀងខាងវិញ្ញាណនៅឯស្ថានសួគ៌។ ខ្ញុំបានដឹងថា ពេលខ្ញុំផ្តល់រថយន្តនោះឱ្យទៅព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំជឿទុកចិត្តលើព្រះជាម្ចាស់ថា ខ្ញុំនឹងទទួលបានរថយន្តមួយគ្រឿងដែលខ្ញុំត្រូវការវិញ។

ខ្ញុំមិនមែនជាមនុស្សរថយន្តនិយមទេ មានន័យថាខ្ញុំមិនមែនជាអ្នកងប់ងុលនឹងរថយន្តទេ។ មនុស្សខ្លះងប់ងុលខ្លាំងមែនទែន ប៉ុន្តែខ្ញុំមិនអីចឹងទេ។ ដូច្នេះ ខ្ញុំបាន

យកដៃដាក់លើរថយន្តនោះ ពេលដែលបុគ្គលិករបស់ខ្ញុំមកយកវា ហើយខ្ញុំនិយាយយ៉ាងច្បាស់ថា «ព្រះវរបិតា ខ្ញុំបានប្រគល់រថយន្តនេះទៅក្នុងកិច្ចការរបស់ទ្រង់នៅរដ្ឋអាត្លង់តាហើយ។ ពេលខ្ញុំថ្វាយរថយន្តនេះទៅក្នុងកិច្ចការនេះ វាប្រៀបដូចជាខ្ញុំបានសាបព្រោះគ្រាប់ពូជមួយ ហើយខ្ញុំជឿថាខ្ញុំនឹងទទួលបាន...»។ ខ្ញុំមិនដឹងថារថយន្តប្រភេទណាដែលខ្ញុំចង់បានទេ ដូច្នេះខ្ញុំបាននិយាយថា «ខ្ញុំនឹងទូលទៅកាន់ព្រះអង្គ ពេលណាដែលខ្ញុំរកនឹកឃើញ!»

ជាការពិតណាស់ រយៈពេលពីរបីខែបានកន្លងផុតទៅ ខ្ញុំពិតជាមិនបានយកចិត្តទុកដាក់អំពីរថយន្តនោះទេ ប៉ុន្តែនៅព្រឹកមួយខ្ញុំបានសួរឌ្រិនដាថា តើនាងចង់មានរថយន្តប្រភេទអីដែរ។ បន្ទាប់ពីនាងបានគិតមួយភ្លែតមក នាងបាននិយាយថា នាងចង់បានរថយន្តដែលមិនមានដំបូល។ ខ្ញុំបានសួរនាងថា តើរថយន្តមិនមានដំបូលប្រភេទណាដែលនាងចង់បាន ហើយយើងទាំងពីរនាក់មិនបានរកឃើញម៉ូតរថយន្តណានៅពេលនោះទេ។ ដោយសារខ្ញុំជាអ្នកទិញរថយន្តឱ្យឌ្រិនដា ខ្ញុំចង់ប្រាកដថានាងទទួលបានរថយន្តដែលនាងពេញចិត្ត ដូច្នេះខ្ញុំប្រាប់នាងឱ្យឆែកមើលតាមអ៊ីនធឺណិត ឬមើលក្បែរៗកន្លែងយើង ហើយបន្ទាប់មកប្រាប់ខ្ញុំវិញ ប្រសិនបើនាងរកឃើញរថយន្តមិនមានដំបូលដែលនាងចង់បានហើយ។ ទន្ទឹមនឹងនេះ យើងមិនបានប្រាប់អ្នកណាម្នាក់អំពីបំណងប្រាថ្នារបស់យើងទាក់ទងជាមួយរថយន្តថ្មីនេះទេ ប៉ុន្តែយើងសម្លឹងមើលយ៉ាងយកចិត្តទុកដាក់ជានិច្ច ពេលដែលយើងបើករថយន្ត យើងព្យាយាមមើលរថយន្តណាដែលគួរឱ្យចាប់អារម្មណ៍។

ថ្ងៃមួយ ពេលដែលយើងបានទៅបរិភោគអាហារថ្ងៃត្រង់ នៅក្នុងភោជនីយដ្ឋានមួយក្នុងតំបន់មួយកន្លែង រំពេចនោះឌ្រិនដាស្រែកថា «គឺវានោះហើយ!»

ខ្ញុំបានសួរនាងថា «តើវាជាអ្វីទៅ?»

«រថយន្តដែលខ្ញុំស្រលាញ់» នាងបានចង្អុលទៅកាន់ចំណតជាច្រើន។ ខ្ញុំក៏បានបើកក្រឡឹងចំណតជាច្រើន ហើយតាមពីក្រោយរថយន្តមួយគ្រឿងម៉ាក BMW 6 series Ci មិនមានដំបូល វាជារថយន្តដ៏ស្រស់ស្អាតពិតមែន។ ហើយខ្ញុំបន្ថែមថា វាអាចជារថយន្តថ្លៃផងដែរ។ ខ្ញុំបានសរសើរភ្នែកដ៏មុតរបស់នាង ហើយប្រាប់នាងថា វាជារថយន្តដ៏ស្រស់ស្អាតពិតមែន។

ឥលូវអ្នកត្រូវដឹងថា គ្រិនដា និងខ្ញុំមិនចេញទៅក្រៅ ហើយចំណាយប្រាក់ច្រើនសម្រាប់រថយន្តទេ។ ដូចខ្ញុំបាននិយាយរួចហើយអ៊ីចឹង ខ្ញុំមិនមែនជាអ្នកលេងរថយន្តអីនោះទេ។ ចំពោះផ្នែកហិរញ្ញវត្ថុ ខ្ញុំក៏ដឹងថាការទិញរថយន្តថ្មី វានឹងធ្លាក់ថ្លៃលឿនប៉ុណ្ណា ហើយអ្វីដែលល្អបំផុតក្នុងការទិញរថយន្ត គឺរករថយន្តណាដែលគេជិះពី១ឆ្នាំទៅ២ឆ្នាំហើយ។ ដូច្នេះ នេះជាផែនការរបស់ខ្ញុំក្នុងការស្វែងរករថយន្តល្អមួយគ្រឿង គឺរករថយន្តដែលគេបានប្រើរួចហើយ។

មួយសប្តាហ៍ក្រោយមក មានបុរសម្នាក់នៅក្នុងក្រុមជំនុំបានហៅខ្ញុំ ហើយគាត់បាននិយាយថា «ខ្ញុំបានដឹងអំពីរថយន្តដែលគ្រិនដាស្រលាញ់ហើយ!» ខ្ញុំមានការងឿងឆ្ងល់ជាខ្លាំង ដែលពួកយើងមិនបានប្រាប់នរណាម្នាក់អំពីរថយន្ត BMW ដែលយើងបានឃើញនៅថ្ងៃបរិភោគអាហារថ្ងៃត្រង់នោះទេ។

ខ្ញុំបានសួរគាត់ថាជារថយន្តប្រភេទអ្វី ហើយគាត់ឆ្លើយថាគឺជារថយន្ត BMW 6 Series Ci មិនមានដំបូល។ គាត់បាននិយាយថា ពេលគាត់កំពុងបើកបរ គាត់បានឃើញរថយន្តនោះ ហើយព្រះអម្ចាស់បានប្រាប់គាត់ថា វាជារថយន្តរបស់គ្រិនដា។

«មិនអីទេ ខ្ញុំបានប្រាប់គាត់ ឥលូវនេះ អ្នកបានដឹងពីបំណងរបស់ខ្ញុំហើយ» រថយន្តនេះទើបតែដាក់លក់លើទីផ្សារបាន១ឆ្នាំប៉ុណ្ណោះ ហើយវានៅថ្មីស្អាតនៅឡើយទេ។ ខ្ញុំបានទិញវាផ្តាច់ជាសាច់ប្រាក់សុទ្ធ។ គ្រិនដាទទួលបានរថយន្តរបស់នាង។ តើវាអាច

កើតឡើងដោយរបៀបណា? សូមយើងប្រៀបធៀបរឿងនេះជាមួយអ្វីដែលយើងបាន រៀនទាក់ទងជាមួយការមានជំនឿ និងការយកកណ្ដៀវមកច្រូត។

ពេលដែលខ្ញុំថ្វាយរថយន្តរបស់ខ្ញុំ ខ្ញុំមានជំនឿ។ ប៉ុន្តែ ពេលដែលឌ្រិនដាបាន និយាយខ្លាំងៗថា «គឺវានោះហើយ!» នាងកំពុងតែយកកណ្ដៀវមកច្រូត ហើយប៉ុន្មាន ថ្ងៃក្រោយមក ខ្ញុំក៏ទទួលបានរថយន្តនោះមែន។

ទោះបីជាខ្ញុំបានឮនាងស្រែកខ្លាំងៗថា «គឺវានោះហើយ!» ខ្ញុំមិនដែលគិតទៅ ដល់ការប្រកាសរបស់នាងនៅក្នុងម៉ាកុសជំពូក៤ និងកណ្ដៀវនោះទេ។ ប៉ុន្តែ រឿងបន្ទាប់ នេះ បានធ្វើឱ្យខ្ញុំមានការយល់ដឹងកាន់តែច្បាស់។

ខ្ញុំបាននិយាយពីរបីដងរួចហើយ ថាខ្ញុំមានដី២៥ហិចតា។ ក្នុងនោះផ្ទៃដី ប្រហែល៥ហិចតាជាវាលភក់។ ខ្ញុំចូលចិត្តការបរបាញ់សត្វនៅរដូវស្លឹកឈើជ្រុះ ប៉ុន្តែ ទោះបីជាខ្ញុំធ្លាប់បានបរបាញ់ប្រវឹកកាលពីនៅវិទ្យាល័យក៏ដោយ ប៉ុន្តែខ្ញុំពិតជាមិនធ្លាប់ ធ្វើការបរបាញ់ប្រវឹកនៅទីនេះ ក្នុងរដ្ឋអូហៃយ៉ូទេ។ មួយឆ្នាំៗ វាលភក់បានពេញទៅ ដោយទឹក ហើយប្រវឹកបានហើរចូលទៅក្នុងហ្វូងធំរបស់វា។ ពេលដ៏ល្អបានចូលមក ដល់ ជាពេលសម្រាប់ការដើរស្វែងរកកន្លែងដែលសត្វដេកនៅពេលយប់។ ដូច្នេះ ខ្ញុំកាន់ កាំភ្លើងខ្ញុំពេញមួយយប់ ហើយចេញទៅក្រៅ វាជាពេលដ៏សប្បាយរីករាយខ្លាំងណាស់ ដែលខ្ញុំបានបាញ់សត្វប្រវឹកបានពីរបីក្បាល សម្រាប់អាហារពេលល្ងាច។

នៅរដូវស្លឹកឈើជ្រុះនោះ កូនប្រុសទាំងពីររបស់ខ្ញុំ និងខ្ញុំ បានរីករាយក្នុងការ បរបាញ់ប្រវឹកផងដែរ។

ទោះជាយ៉ាងណាក៏ដោយ រឿងមួយដែលខ្ញុំបានកត់សម្គាល់គឺថា មានពេលជា ច្រើនដង ដែលប្រវឹកនៅឆ្ងាយជាងចម្ងាយដែលកាំភ្លើងយើងអាចបាញ់ដល់។ ពេល ដែលបរបាញ់ប្រវឹក តាមច្បាប់អ្នកត្រូវបានអនុញ្ញាតឱ្យប្រើតែគ្រាប់កាំភ្លើងដែកតែ ប៉ុណ្ណោះ ផ្ទុយពីការបរបាញ់បែបប្រពៃណីដោយប្រើកាំភ្លើងគ្រាប់សំណ។ កាំភ្លើងគ្រាប់

សំណាគឺធ្ងន់ជាង ហើយមានកម្លាំងបាញ់បានឆ្ងាយជាងកាំភ្លើងគ្រាប់ដែក ដូច្នេះនេះជាបញ្ហារបស់ខ្ញុំទាក់ទងជាមួយការបាញ់ចម្ងាយឆ្ងាយពេលដែលខ្ញុំបរបាញ់ប្រវឹក។ ប៉ុន្តែក្នុងអំឡុងពេលរដូវស្លឹកឈើជ្រុះនោះ នៅពេលដែលខ្ញុំកំពុងនិយាយជាមួយអ្នកប្រមាញ់ប្រវឹកពីរបីនាក់ដែលដើរជាមួយគ្នា ពួកគេបានប្រាប់ខ្ញុំអំពីកាំភ្លើងថ្មីមួយចំនួន ពួកវាត្រូវបានរចនាឡើងសម្រាប់តែការបរបាញ់ប្រវឹកតែប៉ុណ្ណោះ។ កាំភ្លើងនោះអាចបាញ់គ្រាប់ដែលធ្ងន់ជាងមុន និងមានពណ៌ប៉ារ៉ាអាចបន្លំខ្លួនដែរ។ ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញកាំភ្លើងប្រភេទនោះ ដោយសារវាជាខែធ្នូ ហើយរដូវបរបាញ់ប្រវឹកក៏ជិតហួសដែរហើយ ដូច្នេះ ខ្ញុំក៏មិនបានគិតថែមទៀតអំពីការរកទិញកាំភ្លើងនោះ។

ខ្ញុំបានឈប់នៅមុខហាងលក់សម្ភារៈកីឡាក្នុងតំបន់របស់យើងមួយកន្លែងដែលមានឈ្មោះ ការបេឡា ប្រហែលនៅដើមខែមករា ហើយខ្ញុំក៏នឹកឃើញអំពីកាំភ្លើងបាញ់ប្រវឹកទាំងនោះ ខ្ញុំក៏ចង់ឃើញរូបរាងរបស់វា។ ដូច្នេះ ខ្ញុំបានដើរកាត់ហាងលក់កាំភ្លើងនៅច្រកចេញ ហើយខ្ញុំបានឃើញកាំភ្លើងជាច្រើនសម្រាប់ការបរបាញ់សត្វស្លាបទឹក។ ភ្លាមៗនោះ ដោយមិនបានគិតអំពីវាច្រើនពេកទេ ខ្ញុំក៏ចង្អុលម្រាមដៃរបស់ខ្ញុំចំកាំភ្លើងមួយដើម ហើយខ្ញុំបានគិតក្នុងចិត្តថាមើលទៅវាស្អាតខ្លាំងណាស់ ហើយក៏បាននិយាយឮៗថា៖ «ព្រះអម្ចាស់អើយ ខ្ញុំនឹងទទួលបានកាំភ្លើងមួយដើមនេះ» ខ្ញុំមិនបានគិតច្រើនអំពីពាក្យដែលខ្ញុំបាននិយាយទេ វាគ្រាន់តែបានផ្លោយចេញពីមាត់របស់ខ្ញុំមក។ រដូវកាលប្រមាញ់ប្រវឹកមិនទាន់បើកម្តងទៀតនៅឡើយទេ រហូតទាល់តែដល់រដូវស្លឹកឈើជ្រុះ ដូច្នេះខ្ញុំមិនមានគម្រោងទិញកាំភ្លើងតលូវនេះទេ រហូតទាល់តែរដូវប្រមាញ់នោះជិតមកដល់។

ពីរសប្តាហ៍ក្រោយមក ខ្ញុំត្រូវបានអញ្ជើញឱ្យទៅអធិប្បាយនៅក្នុងសន្និបាតជំនួញមួយ។ នៅពេលអធិប្បាយចប់ នាយកប្រតិបត្តិក៏ចេញមកអរគុណខ្ញុំ ហើយពួកគេនិយាយថា មានកាដូឱ្យខ្ញុំ។ ពិតជាគួរឱ្យភ្ញាក់ផ្អើលខ្លាំងណាស់ គាត់បានឱ្យខ្ញុំកាំភ្លើងមួយដើមហ្នឹង ដូច*ម៉ូត* ដែលខ្ញុំបានចង្អុលកាលពីពីរសប្តាហ៍មុននៅក្នុងហាងកាបេឡា

ដែរ។ ជាការពិតណាស់ ខ្ញុំពិតភ្ញាក់ផ្អើលខ្លាំងណាស់ចំពោះអំណោយដ៏សប្បុរសបែបនេះ ប៉ុន្តែខ្ញុំក៏បានដឹងថា វាមិនមែនជារឿងចៃដន្យទេ។ ខ្ញុំបាននឹកចាំនូវអ្វីដែលខ្ញុំបាននិយាយនៅក្នុងហាងកាបេឡា ហើយបានដឹងពីអ្វីដែលខ្ញុំបានធ្វើ។ គឺខ្ញុំបានយកកណ្តៀវមកច្រូត!

ការយល់ដឹងអំពីអ្វីដែលអ្នកទើបតែបានអាននៅក្នុងជំពូកនេះ ដូចដែលខ្ញុំបាននិយាយកាលពីដើមអីចឹង វាពិតជាសំខាន់ខ្លាំងណាស់សម្រាប់អ្នក ដើម្បីឱ្យអ្នកអាចទទួលបានអ្វីៗ និងអ្វីៗគ្រប់យ៉ាងមកពីព្រះជាម្ចាស់។ អ្វីៗគ្រប់យ៉ាងដែលអ្នកទទួលបានពីព្រះជាម្ចាស់នឹងឆ្លងកាត់ដំណើរការដូចគ្នានេះ ដូច្នេះសូមអ្នកប្រាកដថាអ្នកយល់អំពីអ្វីដែលអ្នកទើបតែបានអានមុននេះ។ សូមអានវាឡើងវិញ ប្រសិនបើអ្នកត្រូវការ! វាពិតជាសំខាន់ខ្លាំងណាស់!

# ជំពូក ៨

# អ្នកត្រូវការកាបូបមួយ - ផ្នែកទី២

យើងត្រូវនិយាយឱ្យច្រើនបន្តិច ព្រោះខ្ញុំដឹងថាជាការចាំបាច់ណាស់សម្រាប់អ្នកក្នុងការយល់ច្បាស់អំពីអ្វីទៅជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ជាថ្មីម្តងទៀត គ្រិស្តបរិស័ទភាគច្រើនមិនមានការយល់ដឹងអំពីប្រតិបត្តិការតាមច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ក្នុងអាណាចក្រផែនដីទេ ហើយពួកគេក៏មិនយល់អំពីស្ថានភាពក្រឹត្យវិន័យដែលពួកគេកំពុងអនុវត្តនៅក្នុងព្រះរាជ្យដែរ។ ឥលូវអ្នកដឹងហើយថាហេតុអ្វីបានជាខ្ញុំត្រូវនិយាយលម្អិតក្នុងប្រធានបទនៃជំនឿ និងការគ្រប់គ្រង។ ដោយសារតែគ្មានការយល់ដឹងជាមូលដ្ឋាននោះ អ្នកនឹងមិនដឹងថាតើបទគម្ពីររបស់យើងនៅក្នុងលូកាកំពុងនិយាយអំពីអ្វីនៅពេលដែលនិយាយថា ចូរខំស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង។

ឥលូវនេះដែលអ្នកដឹងអំពីអត្ថន័យនោះហើយ តោះ! សូមត្រលប់ទៅមើលអត្ថបទរបស់យើងវិញ។

*ដូច្នេះ ចូរអ្នករាល់គ្នាកុំគិតតែពីស្វែងរកគ្រឿងបរិភោគនោះឡើយ ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់អ្នករាល់គ្នាទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ <u>ចូរខំស្វែងរកព្រះរាជ្យ*របស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»</u>។*

> *«កុំខ្លាចអី ក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់គ្នា សព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឱ្យអ្នករាល់គ្នាហើយ។ ចូរលក់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា យកប្រាក់ចែកជាទានដល់ជនក្រីក្រចុះ។ <u>ចូរប្រមូលទ្រព្យដែលមិនចេះពុក ជាសម្បត្តិ</u>ដែលមិនចេះរលាយ ទុកសម្រាប់ខ្លួននៅស្ថានបរមសុខ ជាស្ថានដែលគ្មានចោរប្លន់ ឬកណ្ដៀរស៊ីឡើយ។ ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ»* ។
>
> —លូកា ១២:២៩-៣៤

ជាថ្មីម្ដងទៀត ព្រះបិតាជ្រាបរួចទៅហើយអំពីអ្វីដែលអ្នកត្រូវការ ហើយអ្វីគ្រប់យ៉ាងដែលអ្នកត្រូវការត្រូវបានផ្ដល់ឱ្យដោយព្រះបិតា ហើយវាជារបស់អ្នករួចទៅហើយ ប៉ុន្តែអ្នកត្រូវតែដឹង និងយល់ពីដំណើរការស្របច្បាប់នៃការទទួលពីស្ថានសួគ៌ដើម្បីរីករាយនឹងអ្វីដែលទ្រង់មាន។

ខ៣២ ចែងអំពីមត៌កដែលមិនគួរឱ្យជឿដែលអ្នកបានទទួលក្នុងនាមជាកូនរបស់ព្រះជាម្ចាស់។ ទ្រង់មានបន្ទូលថា ***«ព្រះបិតារបស់អ្នករាល់គ្នា សព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឱ្យអ្នករាល់គ្នាហើយ។»***

> *គឺព្រះវិញ្ញាណផ្ទាល់ដែលផ្ដល់សក្ខីភាពឱ្យវិញ្ញាណរបស់យើងដឹងថា យើងពិតជាបុត្ររបស់ព្រះជាម្ចាស់មែន។ ប្រសិនបើយើងពិតជាបុត្រមែន នោះយើងមុខជាទទួលមត៌កពុំខាន។ យើងនឹងទទួលមត៌កពីព្រះជាម្ចាស់ គឺទទួលមត៌ករួមជាមួយព្រះគ្រិស្ត។ ដោយយើងរងទុក្ខលំបាករួមជាមួយព្រះអង្គដូច្នេះ យើងក៏នឹងទទួលសិរីរុងរឿងរួមជាមួយព្រះអង្គដែរ។*
>
> —រ៉ូម ៨:១៦-១៧

លោកប៉ូលនិយាយថា យើងជាអ្នកគ្រងមតិករួមនឹងព្រះគ្រិស្ត។ ក្នុងនាមជាកូនរបស់ព្រះជាម្ចាស់ អ្នកមានមតិក គឺព្រះរាជ្យនៃព្រះជាម្ចាស់។

សូមគិតអំពីការណ៍នោះមួយភ្លែត។ អ្នកមានសិទ្ធិស្របច្បាប់រួចទៅហើយចំពោះអ្វីៗទាំងអស់ដែលព្រះរាជ្យនៃព្រះជាម្ចាស់មាន។ អ្នកមិនចាំបាច់អង្វរកទេ។ អ្វីៗទាំងនោះជាកម្មសិទ្ធិរបស់អ្នកស្រាប់ទៅហើយ។

អូហ៎! ខ្ញុំសង្ឃឹមថាអ្នកពិតជាយល់អំពីឃ្លានោះ។ នេះជាមូលហេតុដែលព្រះគម្ពីរ ២ កូរិនថូស ១:២០ ចែងដូចខាងក្រោមៈ

> *ព្រះគ្រិស្តបានធ្វើឱ្យព្រះបន្ទូលសន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់បានសម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយបានជាយើងពោលពាក្យ «អាម៉ែន» ទៅកាន់ព្រះជាម្ចាស់ តាមរយៈព្រះគ្រិស្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។*
>
> —២ កូរិនថូស ១:២០

នេះជាមូលហេតុដែលនៅក្នុងសៀវភៅចុងក្រោយរបស់ខ្ញុំដែលមានចំណងជើងថា *បដិវត្តហិរញ្ញវត្ថុរបស់អ្នកៈ អំណាចនៃព្រះរាជទាន* ខ្ញុំបានប្រាប់អ្នកថា ការអធិស្ឋានរបស់ព្រះជាម្ចាស់គឺនៅក្នុងទម្រង់នៃការស្នើសុំ ឬការទូលអង្វរដោយស្របច្បាប់។ វាមិនមែនជាការអង្វរទេនៅពេលដែលនិយាយថា *«សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ»*។នេះមិនមែនជាការអង្វរទេ វាគឺជាការស្នើសុំ។

ដូចជាកូនរបស់ខ្ញុំ គាត់មិនចាំបាច់អង្វរសុំអាហារពេលព្រឹកពីខ្ញុំទេ (ពួកគេធ្វើដូចជាពួកគេជាម្ចាស់លើអាហារពេលព្រឹកនោះ ដោយនិនាយថា «ប៉ា សូមហុចចានស៊ុតឱ្យខ្ញុំតិច»។) ដូច្នេះ នៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់ អ្នកមានសិទ្ធិស្របច្បាប់រួចទៅហើយក្នុងការទទួលបានមតិកណាមួយ និងទាំងអស់តាមរយៈព្រះយេស៊ូគ្រិស្ត។

ក្រៅពីមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានអ្វីដែលព្រះរាជ្យនៃព្រះជាម្ចាស់មាន អ្នកក៏ជាពលរដ្ឋនៅក្នុងព្រះរាជ្យដែរ ដែលបញ្ជាក់ថាអ្នកមានអត្ថប្រយោជន៍ជាច្រើនទៀត ប្រៀបដូចជាអ្នកជាពលរដ្ឋអាមេរិកមានអត្ថប្រយោជន៍ច្រើន ដែលអ្នកនឹងមិនអាចទាញយកប្រយោជន៍ពីវាបាន។

> *ហេតុនេះ បងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជន្មរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។*

—អេភេសូ ២:១៩

ចុងក្រោយ តោះ! យើងទៅនិយាយពីទ្រព្យសម្បត្តិនោះ! ចាំទេ ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកត្រូវការទ្រព្យសម្បត្តិ។

> *ចូរលក់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា យកប្រាក់ចែកជាទានដល់ជនក្រីក្រចុះ។ <u>ចូរប្រមូលទ្រព្យដែល</u>មិនចេះពុក ជាសម្បត្តិដែលមិនចេះរលាយ ទុកសម្រាប់ខ្លួននៅស្ថានបរមសុខ ជាស្ថានដែលគ្មានចោរប្លន់ ឬកណ្ដៀរស៊ីឡើយ។ ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ»។*

—លូកា ១២:៣៣-៣៤

ចូរប្រមូលទ្រព្យ ជាសម្បត្តិដែលមិនចេះរលាយ ទុកសម្រាប់ខ្លួននៅស្ថានបរមសុខ ជាស្ថានដែលគ្មានចោរប្លន់ ឬកណ្ដៀរស៊ីឡើយ។ ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះឱ្យច្បាស់៖ ព្រះយេស៊ូមិនបានមានបន្ទូលថាអ្នកត្រូវតែលក់អ្វីគ្រប់យ៉ាងដែលអ្នកមានហើយនៅក្រខ្សត់រហូតដល់អ្នកទៅស្ថានសួគ៌នោះទេ។ សូមចាំថា លោកប៉ូលគឺជាមនុស្សតែម្នាក់ដែលបានសរសេរព្រះគម្ពីរ ២ កូរិនថូស ជំពូក ៩ ដែលគាត់បាននិយាយថា យើងនឹងក្លាយជាអ្នកមានតាមគ្រប់មធ្យោបាយ ដើម្បីយើងអាចមានចិត្តសប្បុរស

គ្រប់កាលៈទេសៈ។ ដូច្នេះចូរដឹងថា លោកប៉ូលមិនបានបញ្ជាក់ថា ការមានប្រាក់ ឬមានអ្វីៗទាំងឡាយជាអំពើបាប ហើយខុសនោះទេ។ ព្រះយេស៊ូមានបន្ទូលថា បើប្រាក់ និងរបស់របរដែលអ្នកមាន នោះជាការប្រសើរក្នុងការលក់របស់ទាំងនោះ ហើយផ្ទង់ចិត្តរបស់អ្នកចំពោះទ្រព្យដែលអ្នកមិនចេះបាត់បង់ ជាទ្រព្យសម្បត្តិដ៏អស់កល្បជានិច្ច។

យើងធំធាត់ដោយយកប្រាក់ជាសំខាន់។ ប្រាក់ជួយផ្តល់អ្វីដែលយើងត្រូវការក្នុងជីវិត។ ទោះយ៉ាងណាក៏ដោយ មានមនុស្សជាច្រើនថ្វាយបង្គំប្រាក់។ នេះជាមូលហេតុដែលលោកប៉ូលបានប្រាប់ធីម៉ូថេឱ្យដាស់តឿនមនុស្សដែលមានទ្រព្យស្តុកស្តម្ភឱ្យមានចិត្តសប្បុរស ដើម្បីឱ្យពួកគេមានសុខភាពល្អខាងព្រលឹងវិញ្ញាណ។ ជាការងាយស្រួលណាស់សម្រាប់ឱ្យចិត្តរបស់យើងយកប្រាក់ជាសំខាន់។ ភាពសប្បុរសជាឱសថកម្ចាត់ភាពលោភលន់។ ចូរមានភាពសប្បុរសឱ្យបានញឹកញាប់។

> *ចូរដាស់តឿនពួកអ្នកមាន នៅលោកីយ៍នេះ កុំឱ្យអួតខ្លួន និងយកទ្រព្យសម្បត្តិដែលមិនទៀងធ្វើជាទីសង្ឃឹមឡើយ គឺត្រូវសង្ឃឹមលើព្រះជាម្ចាស់ដែលប្រទានឱ្យយើងមានអ្វីៗទាំងអស់យ៉ាងបរិបូណ៌ សម្រាប់ឱ្យយើងប្រើប្រាស់នោះវិញ។ ត្រូវឱ្យគេប្រព្រឹត្តអំពើល្អ ឱ្យគេធ្វើជាអ្នកមានផ្នែកខាងបុណ្យទាន ឱ្យគេមានចិត្តទូលាយ ចេះចែករំលែកដល់អ្នកឯទៀតៗ ធ្វើដូច្នេះ គេនឹងសន្សំសម្បត្តិដ៏ល្អគង់វង្សសម្រាប់លោកខាងមុខ ដើម្បីទទួលជីវិតដ៏ពិតប្រាកដ។*
>
> —១ ធីម៉ូថេ ៦:១៧-១៩

សូមកត់សម្គាល់ថា លោកប៉ូលប្រាប់ធីម៉ូថេឱ្យ*ដាស់តឿន* មិនមែន*ស្នើសុំ*ពួកអ្នកមានឱ្យមានចិត្តសប្បុរស និងចេះចែករំលែកទេ។ ត្រូវចាំថា ប្រាក់គឺចាំបាច់ណាស់ ប៉ុន្តែវាមិនមែនជាជីវិតទេ។

## ដូច្នេះ តើទ្រព្យសម្បត្តិរបស់អ្នកនៅឯណា?

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ មិនត្រឹមតែធ្វើឱ្យអ្នកមានចិត្តទន់ចំពោះព្រះជាម្ចាស់ និងមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឱ្យចិត្តរបស់អ្នកចង់ព្រលែងប្រាក់ដែលអ្នកកំពុងតែក្ដាប់ជាប់នឹងដៃ។ ចិត្តដែលចេះតែច្រណែន និងថ្វាយបង្គំអ្វីៗទាំងអស់តាមចិត្តរបស់អ្នក ដូច្នេះយើងមិនអាចឱ្យចិត្តយើងវង្វេងដោយគ្មានគោលដៅឡើយ។ យើងត្រូវរៀនរក្សាចិត្តរបស់យើងចំពោះព្រះជាម្ចាស់ ដែលទ្រង់ជាប្រភពរបស់យើង។ ការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់អាចកម្ចាត់ភាពលោភលន់ ដែលងាយទាញចិត្តយើង។

ដូច្នេះ ហេតុអ្វីបានជាយើងត្រូវធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់នូវអ្វីដែលយើងមាន? ហេតុអ្វីបានជាព្រះជាម្ចាស់មិនអាចជួយយើងផ្នែកហិរញ្ញវត្ថុ ដោយយើងមិនចាំបាច់ធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់? នោះជាសំណួរដ៏ល្អមួយ ហើយយើងរកឃើញចម្លើយនៅក្នុងលូកាជំពូកទី៤។

ទីមួយ ព្រះជាម្ចាស់គ្មានប្រាក់ទេ ដូចដែលខ្ញុំបានបញ្ជាក់ពីមុនដំបូង។ ទីពីរ ទ្រង់បានឱ្យអដាំគ្រប់គ្រងទាំងស្រុងលើផែនដី ដូចមានចែងនៅក្នុង ហេប្រឺ ២:៧-៨។

*មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញ នគរទាំងប៉ុន្មាននៅលើផែនដីឱ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់<u>អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះ</u>ឱ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឱ្យអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*

*ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុងគម្ពីរមានចែងថា "អ្នកត្រូវតែថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់អ្នក និងគោរពបំរើតែព្រះអង្គមួយប៉ុណ្ណោះ"»។*

—លូកា ៤:៥-៨

អត្ថបទគម្ពីរនេះកើតឡើងនៅពេលដែលសាតាំងកំពុងល្បួងព្រះយេស៊ូនៅទីរហោស្ថាន។ សាតាំងប្រាប់ព្រះយេស៊ូថា អំណាច និងសិរីរុងរឿងរបស់ប្រជាជាតិទាំងអស់ក្នុងលោកត្រូវបានប្រគល់ឱ្យវា។ នេះគឺជាការពិត។ អដាំជាម្ចាស់លើសិរីរុងរឿងទាំងនោះ ប៉ុន្តែគាត់បានប្រគល់ទៅឱ្យសាតាំង ពេលដែលគាត់បានក្បត់នឹងព្រះរាជ្យរបស់ព្រះជាម្ចាស់។

សិរីរុងរឿងរបស់ប្រជាជាតិមួយគឺជាទ្រព្យសម្បត្តិរបស់ប្រជាជាតិនោះ ហើយសមត្ថភាពគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ប្រជាជាតិនានា ឥលូវនេះត្រូវបានគ្រប់គ្រងដោយសាតាំង។ កុំយល់ច្រឡំ—អត្ថបទគម្ពីរនេះមិនបាននិយាយថា សាតាំងបានទទួល*សិទ្ធិអំណាច*លើសិរីរុងរឿងនៃផែនដីនោះទេ។

ព្រះជាម្ចាស់គ្រប់គ្រងផែនដី និងអ្វីៗទាំងអស់នៅលើផែនដីនេះ។ ប៉ុន្តែ អត្ថបទគម្ពីរនេះនិយាយថា សាតាំងមាន*ការទាមទារដោយស្របច្បាប់*លើទ្រព្យសម្បត្តិរបស់ប្រជាជាតិនានា។

ប្រសិនបើអ្នកក្រឡេកមើលប្រាក់មួយដុំ ជារឿយៗ វាត្រូវបានផលិត ឬបោះពុម្ពដោយប្រទេសដែលមានសិទ្ធិអំណាចពេញលេញលើរូបិយបណ្ណរបស់ខ្លួន។ ដោយសារអ្វីដែលអដាំបានធ្វើ ព្រះជាម្ចាស់មិនអាចទាមទារដោយស្របច្បាប់លើរូបិយបណ្ណរបស់ប្រទេសណាមួយ ឬក្លែងបន្លំបានទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើព្រះជាម្ចាស់អាចស្វែងរកនរណាម្នាក់នៅក្នុងអាណាចក្រផែនដីដែលជឿលើទ្រង់ ហើយមានឆន្ទៈក្នុងការថ្វាយប្រាក់ទៅក្នុងការគ្រប់គ្រង និងសិទ្ធិអំណាចរបស់ទ្រង់ នោះព្រះអង្គនឹងទទួលបានសិទ្ធិស្របច្បាប់ ហើយទ្រង់អាចចូលរួមនៅក្នុងស្ថានភាពនោះ។

ជាថ្មីម្តងទៀត ទោះជាយ៉ាងណាក៏ដោយ ព្រះជាម្ចាស់មិនមានប្រាក់នោះទេ ដូច្នេះ តើខ្ញុំចង់មានន័យយ៉ាងដូចម្តេចពេលដែលខ្ញុំនិយាយថា ទ្រង់អាចចូលរួមក្នុងបញ្ហាហិរញ្ញវត្ថុរបស់យើង? ទោះបីជាព្រះជាម្ចាស់មិនអាចប្រើមន្តអាគមបង្កើតប្រាក់ (នោះនឹងខុសច្បាប់ដោយសារការទាមទារដោយស្របច្បាប់របស់សាតាំង) ទ្រង់អាចជួយអ្នកឱ្យរកបាន ឬបង្កើតទ្រព្យសម្បត្តិ។ ដូចរឿងដែលខ្ញុំបានលើកឡើងពីដំបូងក្នុងសៀវភៅនេះ ភាពសប្បុរសផ្តល់ឱ្យស្ថានសួគ៌នូវការគ្រប់គ្រងដោយស្របច្បាប់ដើម្បីទាញយកការណែនាំ និងការបង្ហាញផ្លូវដល់នរណាម្នាក់នៅក្នុងផ្នែកហិរញ្ញវត្ថុនៅពេលដែលពួកគេធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់។ តើអ្នកនៅចាំរឿងត្រីក្នុងលូកាជំពូក៥ទេ? បំណងរបស់លោកពេត្រុសក្នុងការឱ្យព្រះយេស៊ូខ្ចីទូកនេសាទរបស់គាត់ដើម្បីប្រកាសអំពីដំណឹងល្អ បានបើកទ្វារស្របច្បាប់សម្រាប់ឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញអំពីត្រីដែលមាននៅក្នុងទឹកជ្រៅ។

**ការថ្វាយដល់ព្រះជាម្ចាស់ ទ្រង់បើកទ្វារនៃការឱ្យទៅវិញទៅមក ដែលជាច្បាប់ដ៏សំខាន់មួយនៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់។ យើងច្រូតកាត់នូវអ្វីដែលយើងសាបព្រោះ។**

ការថ្វាយតង្វាយរបស់យើងដល់ព្រះជាម្ចាស់ គឺបើកទ្វារនៃការឱ្យទៅវិញទៅមក ដែលជាក្រឹត្យវិន័យដ៏សំខាន់បំផុតនៅក្នុងព្រះរាជ្យនៃព្រះជាម្ចាស់។ យើងច្រូតកាត់អ្វីដែលយើងសាបព្រោះ។

ដូច្នេះ និយាយឱ្យខ្លីទៅ យើងផ្តល់ទ្រព្យសម្បត្តិសម្រាប់ខ្លួនយើងតាមរយៈការថ្វាយដល់ព្រះរាជ្យនៃព្រះជាម្ចាស់ និងកិច្ចការរបស់ទ្រង់។ ការថ្វាយតង្វាយរបស់យើងធ្វើឱ្យយើងទទួលបានទ្រព្យសម្បត្តិពីស្ថានសួគ៌ ដែលជាមូលហេតុដែលប៉ូលហៅថា « ធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់» ពីទ្រព្យសម្បត្តិរបស់យើង។ នេះផ្លាស់ប្តូរអ្វីគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើង។ យើងលែងកម្រិតដោយការយល់ដឹង

របស់យើងទៀតហើយ។ ឥលូវនេះ ព្រះជាម្ចាស់កំពុងជួយយើងឱ្យរីកចម្រើន ដោយអង្គទ្រង់ផ្ទាល់។

> *ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ចំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ ដោយយើងជួយគេ។*
>
> —២ កូរិនថូស ៩:១១

ចូរកត់សម្គាល់ថា ព្រះគម្ពីរចែងថា អ្នក*នឹងក្លាយជាអ្នកមាន* មិនមែននិយាយថាអ្នកត្រូវតែ*ខំដើម្បីឱ្យក្លាយជាអ្នកមាន*ដោយកម្លាំង និងប្រាជ្ញារបស់អ្នកទេ។ ទេ អ្នកមានដៃគូថ្មី គឺព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់ជ្រាបពីអ្វីៗច្រើនជាងអ្នកទៅទៀត។

ខ្ញុំអាចចងចាំនៅពេលដែលយើងក្រខ្សត់អស់រយៈពេលប្រាំបួនឆ្នាំដែលពោរពេញដោយភាពតានតឹង។ ចិត្តគំនិតរបស់ខ្ញុំគិតតែអំពីប្រាក់ប៉ុណ្ណោះ ឬខ្ញុំគួរនិយាយថាខ្ញុំភ័យខ្លាចដោយសារតែមិនមានប្រាក់គ្រប់គ្រាន់។ ទោះបីជាខ្ញុំជាគ្រិស្តបរិស័ទម្នាក់ក៏ដោយ ក៏ខ្ញុំមិនមានជំនឿគ្រប់គ្រាន់លើព្រះជាម្ចាស់ ដើម្បីឱ្យចិត្តរបស់ខ្ញុំលែងមានភក្តីភាពចំពោះប្រព័ន្ធបណ្តាសាលើផែនដីដែលបែកបាក់នោះទេ។ ខ្ញុំជឿលើទ្រព្យសម្បត្តិដែលខុសឆ្គង! ក្នុងចំណុចនេះ ខ្ញុំមានទំនុកចិត្តចំពោះ*ខ្លួនឯង* ហើយខ្ញុំដឹងប្រាកដថានោះមិនមែនជាជម្រើសដ៏ល្អនោះទេ។

ព្រះជាម្ចាស់ត្រូវបង្រៀនខ្ញុំពីរបៀបផ្តល់ទ្រព្យសម្បត្តិសម្រាប់ខ្លួនខ្ញុំដើម្បីទទួលបានព្រះគុណ និងសមត្ថភាពរបស់ទ្រង់។ ហើយទោះបីជាខ្ញុំគិតថាអ្នកគ្រប់គ្នាដែលស្គាល់ខ្ញុំ ដឹងពីរបៀបដែលព្រះជាម្ចាស់បានធ្វើរឿងនោះ ខ្ញុំចង់និយាយអំពីរឿងនេះម្តងទៀតនៅទីនេះ ក្នុងករណីដែលអ្នកមិនដឹងថាតើព្រះជាម្ចាស់បានធ្វើកិច្ចការនោះដោយរបៀបណា។ អ្នកដឹងទេ ព្រះជាម្ចាស់មានយុទ្ធសាស្រ្តច្បាស់លាស់។ ទ្រង់ដឹងច្បាស់ពីរបៀបដើម្បីមករកយើងម្នាក់ៗ។

**បង្វិលត្ថន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំចូលចិត្តបរបាញ់សត្វក្តាន់ ប៉ុន្តែបរបាញ់មិនបានជោគជ័យអស់ជាច្រើនឆ្នាំ។ ខ្ញុំបានចេញទៅអង្គុយនៅក្នុងព្រៃល ហើយទៅបរបាញ់ពីមួយថ្ងៃទៅមួយថ្ងៃដោយគ្មានសំណាង។ វាមិនមែនជារឿងដែលខ្ញុំគ្រាន់តែចូលចិត្តបរបាញ់នោះទេ។ ខ្ញុំមានកូនដែលត្រូវចិញ្ចឹម ហើយប្រាកដណាស់ថា ខ្ញុំអាចយកវាមកធ្វើជាសាច់អាំង។ ថ្វីត្បិតតែខ្ញុំធ្លាប់ជោគជ័យខ្លះកាលពីមុនក៏ដោយ វាបានកន្លងទៅអស់ជាច្រើនឆ្នាំហើយចាប់តាំងពីខ្ញុំមានរដូវកាលបរបាញ់សត្វដោយជោគជ័យ ហើយយកសាច់មកផ្ទះវិញ។

នៅថ្ងៃមួយ ពេលខ្ញុំកំពុងគិតអំពីរដូវកាលបរបាញ់សត្វក្តាន់ដែលនឹងមកដល់នាពេលខាងមុខ ខ្ញុំបានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់។ ទ្រង់បានមានបន្ទូលថា « ហេតុអ្វីបានជាអ្នកមិនអនុញ្ញាតឱ្យយើងបង្ហាញអ្នកពីរបៀបបាញ់សត្វក្តាន់ឱ្យបាននៅឆ្នាំនេះ?»

ការណ៍នោះធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល។ តើការ *«បង្ហាញខ្ញុំពីរបៀបដើម្បីបាញ់សត្វក្តាន់ឱ្យបាននៅឆ្នាំនោះ?»* មានន័យដូចម្តេច? ដោយអធិស្ឋានអំពីព្រះបន្ទូលទាំងនោះ ខ្ញុំចាប់អារម្មណ៍ក្នុងការសាបព្រោះគ្រាប់ពូជហិរញ្ញវត្ថុ ឬអំណោយសម្រាប់គោលបំណងពិតប្រាកដនៃការទទួលបានសត្វក្តាន់នោះ។ ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់មានបន្ទូលមកខ្ញុំថា នៅពេលដែលខ្ញុំបានសាបព្រោះសម្រាប់សត្វក្តាន់របស់ខ្ញុំ ខ្ញុំត្រូវជឿថាខ្ញុំបានទទួលវារួចទៅហើយ មុនពេលដែលខ្ញុំទទួលបានវាពិតប្រាកដ យោងទៅតាមព្រះគម្ពីរម៉ាកុស ១១:២៤។

> *ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឱ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។*
>
> —ម៉ាកុស ១១:២៤

ទោះបីជាក្នុងនាមជាគ្រិស្តបរិស័ទ ខ្ញុំតែងតែថ្វាយតង្វាយ និងគាំទ្រក្រុមជំនុំរបស់ខ្ញុំ ដោយផ្ទង់ចិត្ត និងជឿថាខ្ញុំទទួលនឹងទទួលបាននៅពេលខ្ញុំអធិស្ឋានក៏ដោយ ការសាបព្រោះបែបនេះគឺជារឿងថ្មី។

ខ្ញុំបានយកមូលប្បទានបត្រមួយ ហើយសរសេរក្នុងផ្នែកកំណត់ហេតុថា « សម្រាប់សត្វក្តាន់ឆ្នាំ ១៩៨៧ របស់ខ្ញុំ»។ ខ្ញុំបានដាក់ដៃលើមូលប្បទានបត្រ ហើយប្រកាសថាខ្ញុំទើបតែបានទទួលសត្វក្តាន់របស់ខ្ញុំ ខណៈខ្ញុំបានផ្ញើមូលប្បទានបត្រនោះទៅព័ន្ធកិច្ចមួយដែលខ្ញុំទុកចិត្ត។

ដោយរស់នៅក្នុងទីក្រុងធុលសា រដ្ឋអូក្លាហូម៉ា ខ្ញុំពិតជាមិនមានកន្លែងសម្រាប់បរបាញ់ទេ ប៉ុន្តែមិត្តរបស់ខ្ញុំម្នាក់នៅក្រុមជំនុំបានអញ្ជើញខ្ញុំឱ្យទៅលេងផ្ទះជីដូនរបស់គាត់នៅក្នុងប្រទេសដើម្បីចូលរួមក្នុងពិធីបុណ្យដឹងគុណ ហើយគាត់បាននិយាយថាមានសត្វក្តាន់ពីរបីក្បាលនៅជុំវិញកសិដ្ឋាន។ ដូច្នេះ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅចូលរួមពិធីបុណ្យអរព្រះគុណនៅពេលព្រឹក ដើម្បីប្រកបគ្នា និងញ៉ាំអាហារជាមួយគ្នាដ៏រីករាយ និងដើម្បីបរបាញសត្វក្តាន់។

មិត្តភក្តិរបស់ខ្ញុំពិតជាមិនដឹងថាត្រូវប្រាប់ខ្ញុំឱ្យទៅទីណានោះទេ ប៉ុន្តែមានវាលស្មៅមួយដែលជាប់នឹងព្រៃឈើ ហើយគាត់បានប្រាប់ខ្ញុំឱ្យចេញទៅវាលស្មៅ ហើយអង្គុយក្បែរដើមឈើធំមួយនៅទីនោះ។

ឥលូវនេះខ្ញុំចង់ឱ្យអ្នកស្រមៃអំពីរូបភាពនេះ។ ខ្ញុំកំពុងអង្គុយនៅក្នុងវាលស្មៅដែលបានកាត់រួច ដែលមានដើមឈើធំមួយនៅកណ្តាល។ ចូរក្រឡេកមើលទៅក្រោយវិញ ខ្ញុំគ្រាន់តែអង្គុយនៅទីវាលក្បែរដើមឈើមួយដើមប៉ុណ្ណោះ។ នៅពេលដែលមានពន្លឺ ខ្ញុំគិតថា *មិនកើតនោះទេដោយអង្គុយនៅទីវាលបែបនេះ។ ខ្ញុំត្រូវរកកន្លែងអង្គុយដែលប្រសើរជាងនេះ។*

នៅពេលដែលខ្ញុំកំពុងគិតថានឹងក្រោកដើរទៅកាន់ព្រៃនោះ ខ្ញុំមិនបានដឹងថាមានអ្វីកើតឡើងនៅពីក្រោយខ្ញុំ នៅម្ខាងទៀតនៃដើមឈើនោះ។ ដោយខ្ញុំមិនបានដឹងសត្វក្ដាន់មួយក្បាលកំពុងរត់កាត់ទីវាលពីក្រោយខ្ញុំ។ ដើមឈើគឺនៅចន្លោះសត្វក្ដាន់នឹងខ្ញុំ ដូច្នេះ សត្វក្ដាន់មិនឃើញខ្ញុំ ហើយខ្ញុំក៏មិនឃើញវាដែរ។ ក្ដាន់នោះបានរត់ទៅរកដើមឈើ វាធំក្លិនខ្ញុំ ហើយវាក៏ឈប់ភ្លាម ខណៈវាព្យាយាមរកមើលថាមានអ្វីកើតឡើង។

នៅពេលដែលសត្វក្ដាន់នោះឈប់ ហើយមើលជុំវិញដើមឈើ ខ្ញុំ និងសត្វក្ដាន់នោះបានមើលមុខគ្នា។ ក្ដាន់នោះស្ថិតនៅចម្ងាយតែ៩ម៉ែត្រជាងប៉ុណ្ណោះពីខ្ញុំ! ដោយមិនបង្អង់យូរ វាបានរត់គេចយ៉ាងលឿនចេញទៅបាត់។

ឥលូវនេះ ខ្ញុំនឹងត្រូវទទួលស្គាល់ថា ខ្ញុំមិនមែនជាអ្នកបរបាញ់ដ៏អស្ចារ្យនោះទេ។ ខ្ញុំមិនអាចតម្រង់បាញ់សត្វក្ដាន់កន្ទុយសដែលកំពុងរត់ក្នុងល្បឿនយ៉ាងលឿនចេញពីខ្ញុំបានល្អឡើយ។ ទីពីរ ការបាញ់ដែលមិនបានត្រៀមទុកជាមុនក្នុងកម្រិត៣០-០៦ មិនមែនជាការបាញ់ដែលងាយស្រួលនោះទេ។ ប៉ុន្តែ នៅពេលដែលខ្ញុំកេះកៃកាំភ្លើង សត្វក្ដាន់នោះដួល ហើយវាមិនកម្រើកសោះ។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង! ពេលឮសូរកាំភ្លើង មិត្តភក្តិរបស់ខ្ញុំបានចេញមកអបអរសាទរខ្ញុំ ពេលដែលគាត់ឃើញក្ដាន់ដេកនៅទីនោះ។ ខ្ញុំមិនបានប្រាប់មិត្តរបស់ខ្ញុំអំពីអ្វីដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំទេ ប៉ុន្តែខ្ញុំមើលទៅគាត់ហើយនិយាយថា «ខ្ញុំគិតថាសត្វក្ដាន់នេះបានមក មិនមែនដោយសារសមត្ថភាពបរបាញ់ដ៏ល្អរបស់ខ្ញុំទេ»។

ខ្ញុំទាញក្រដាសដែលខ្ញុំបានសរសេរនៅថ្ងៃដែលខ្ញុំផ្ញើមូលប្បទានបត្រនោះចេញពីអាវសម្រាប់បរបាញ់របស់ខ្ញុំ។ ក្នុងក្រដាសនោះសរសេរថា «ខ្ញុំជឿថាខ្ញុំទទួលបានសត្វក្ដាន់ឆ្នាំ ១៩៨៧ របស់ខ្ញុំ ក្នុងព្រះនាមព្រះយេស៊ូ»។ ខ្ញុំក៏បានចុះកាលបរិច្ឆេទ និងពេលវេលាដែលខ្ញុំបានអធិស្ឋាននៅក្នុងក្រដាសនោះផងដែរ។ ខ្ញុំលើកក្រដាសឱ្យមិត្តខ្ញុំមើល រួចចាប់ផ្តើមប្រាប់គាត់អំពីអ្វីដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំឱ្យធ្វើ។

ព្រឹត្តិការណ៍នេះបានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។ ដោយគ្មានការសង្ស័យ ខ្ញុំដឹងថា ការទទួលបានសត្វក្ដាន់នោះ គឺព្រះជាម្ចាស់ធ្វើការអស្ចារ្យ។ ជាការពិតណាស់ នៅពេលដែលអ្នកឃើញអ្វីមួយបែបនោះ អ្នកនឹងគិតថា វាគ្រាន់តែជាការចៃដន្យប៉ុណ្ណោះ។ ប៉ុន្តែសម្រាប់រយៈពេល៣៩ឆ្នាំចុងក្រោយនេះ ខ្ញុំបានបរបាញ់សត្វក្ដាន់ដោយប្រើវិធីសាស្ត្រដូចគ្នានឹងវិធីសាស្ត្រដែលខ្ញុំបាញ់សត្វក្ដាន់ឆ្នាំ ១៩៨៧ នេះដែរ មិនដែលបរាជ័យឡើយ ជាធម្មតាចំណាយពេលត្រឹមតែមួយម៉ោងប៉ុណ្ណោះនៅក្នុងព្រៃ។

ព្រះជាម្ចាស់បានប្រើវិធីសាស្ត្រដូចគ្នានេះដើម្បីទៅរកលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហាននៅថ្ងៃនោះនៅបឹងគេនេសារ៉ែត។ ព្រះគម្ពីរចែងថាពួកគេភ្ញាក់ផ្អើលនឹងអ្វីដែលពួកគេបានឃើញ។

> *លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ រីឯលោកយ៉ាកុប និងលោកយ៉ូហានជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។*
>
> *ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។ ពេលទូកទៅដល់មាត់ច្រាំងវិញ គេបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។*
>
> —លូកា ៥:៩-១១

ពួកគេភ័យស្ញប់ស្ញែងជាខ្លាំង ដែលបានបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូ។ ពួកគេបានមើលឃើញវិធីដ៏ល្អប្រសើរមួយនៃការធ្វើកិច្ចការទាំងឡាយ ដែលជាវិធីកាន់តែប្រសើរជាងមុន។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នៅពេលដែលព្រះជាម្ចាស់បានបង្ហាញខ្ញុំអំពីព្រះរាជ្យរបស់ទ្រង់ និងរបៀបដែលយើងធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះអង្គជាទ្រព្យសម្បត្តិ (របៀបដែលខ្ញុំអាចទទួលបានទ្រព្យសម្បត្តិរបស់ខ្ញុំនៅស្ថានសួគ៌) ដែលខ្ញុំត្រូវការ ខ្ញុំកាន់តែមានទំនុកចិត្តលើធនធានរបស់ខ្ញុំនៅស្ថានសួគ៌របស់ខ្ញុំជាងអ្វីដែលខ្ញុំកាន់នៅក្នុងដៃ។

ព្រះជាម្ចាស់បានបង្រៀនខ្ញុំថា ខ្ញុំអាចសាបព្រោះសម្រាប់អ្វីដែលខ្ញុំត្រូវការ ហើយទ្រង់នឹងប្រទានឱ្យខ្ញុំនូវផែនការមួយដើម្បីបង្កើតប្រាក់ ឬផែនការដើម្បីទទួលបានប្រាក់។

ខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីចែករំលែករឿងរ៉ាវដ៏អស្ចារ្យទាំងអស់ដែលខ្ញុំបានឃើញ ជាលទ្ធផលនៃព្រះរាជ្យនៃព្រះជាម្ចាស់នោះទេ ប៉ុន្តែខ្ញុំអាចនិយាយបានថា ខ្រិនដា និងខ្ញុំបានឃើញរឿងមិនគួរឱ្យជឿមួយចំនួនដែលកើតឡើងក្នុងផ្នែកហិរញ្ញវត្ថុ។ ចាប់ពីការក្រខ្សត់ខ្លាំងទៅជាមានសេរីភាពខាងហិរញ្ញវត្ថុ និងអាចផ្គត់ផ្គង់ព័ន្ធកិច្ចរាប់លានក្នុងរយៈពេលជាច្រើនឆ្នាំគឺជារឿងដ៏អស្ចារ្យមួយ។

ការសាបព្រោះដោយជំនឿសម្រាប់ការប្រមូលផលជាក់លាក់ គឺជារឿងដំបូងដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំ នៅពេលខ្ញុំចាប់ផ្តើមរៀនអំពីព្រះរាជ្យនៃព្រះជាម្ចាស់។ ទោះបីជាខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់នៅក្នុងសៀវភៅនេះ ដើម្បីនិយាយអំពីអ្វីគ្រប់យ៉ាងក៏ដោយ នៅក្នុងសៀវភៅផ្សេងទៀតរបស់ខ្ញុំ អ្នកនឹងឃើញរឿងរ៉ាវអំពីថាតើព្រះរាជ្យនៃព្រះជាម្ចាស់មានភាពជាក់លាក់កម្រិតណា? ហើយគ្រាប់ពូជរបស់អ្នកត្រូវមានភាពជាក់លាក់កម្រិតណា? សៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា៖ *បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃព្រះរាជទាន* និយាយអំពីជំហានដើម្បីបញ្ចេញជំនឿរបស់អ្នក និងរបៀបសាបព្រោះគ្រាប់ពូជរបស់អ្នកជាពិសេសច្រើនជាងសៀវភៅនេះ។ ខ្ញុំលើកទឹកចិត្តឱ្យអ្នកស្វែងរកសៀវភៅនោះ និងឈ្វេងយល់បន្ថែមអំពីប្រធានបទនេះ។

សៀវភៅនេះរៀបរាប់អំពីគោលការណ៍សំខាន់ៗនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានបង្រៀនខ្ញុំអំពីចិត្តសប្បុរស និងការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់។ ខ្ញុំសង្ឃឹមថាសៀវភៅទាំងនេះលើកទឹកចិត្តអ្នក និងជំរុញអ្នកឱ្យចង់ឈ្វេងយល់បន្ថែមទៀត និងទទួលបានអ្វីៗទាំងអស់ដែលព្រះអង្គមានសម្រាប់អ្នក។

# ជំពូក ៩

# ច្បាប់អំពីរង្វាល់

ប៉ុន្មានខែមុន ឌ្រិនដា និងខ្ញុំបានសាបព្រោះប្រាក់ចំនួន ១៥.០០០ដុល្លារ ទៅក្នុងព័ន្ធកិច្ចមួយផ្សេងទៀត។ នៅពេលខ្ញុំហៀបនឹងស្រាយជំនឿរបស់ខ្ញុំ ព្រះវិញ្ញាណដ៏វិសុទ្ធបានរំឮកខ្ញុំអំពីព្រះគម្ពីរ ២ កូរិនថូស ៩:១០-១១ ហើយខ្ញុំនៅតែចាំអំពីបទគម្ពីរនោះប៉ុន្មានថ្ងៃបន្ទាប់ពីនោះមក។

*ព្រះអង្គដែល «ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារឱ្យគេផងនោះ» ទ្រង់ក៏ផ្គត់ផ្គង់គ្រាប់ពូជឱ្យបងប្អូន និងឱ្យគ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះអង្គនឹងធ្វើឱ្យសេចក្ដីសុចរិតរបស់បងប្អូន បង្កើតផលបានច្រើនឡើងថែមទៀត។ ព្រះអង្គនឹងធ្វើឱ្យបងប្អូនទៅជាអ្នកមានគ្រប់វិស័យទាំងអស់ ដើម្បីឱ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់ចំពូក និងឱ្យអ្នកឯទៀតៗអរព្រះគុណព្រះជាម្ចាស់ដោយយើងជួយគេ*

—២ កូរិនថូស ៩:១០-១១

**គោលគំនិតចំណែកទ្វេដង ការមានច្រើនបរិបូណ៌ហូរហៀរ អាចមើលទៅហាក់ដូចជាមិនអាចនឹងស្រមើស្រមៃទៅរួចបានក្នុងពេលតលូវនេះទេបើធៀបនឹងកន្លែងដែលអ្នកមើលឃើញខ្លួនអ្នក ក្នុងជីវិតរបស់អ្នកនៅពេលនេះឡើយ។ ក៏ប៉ុន្តែទីនេះគឺជាកន្លែងដែលអ្នកត្រូវតែចាប់ផ្ដើមដំណើរទៅរកសេរីភាពរបស់អ្នក - នៅក្នុងការគិតរបស់អ្នក។**

ខ្ញុំបានជញ្ជឹងគិតអំពីផ្នែកដែលនិយាយថា ព្រះអង្គប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ និងប្រទានចំណីអាហារ ហើយខ្ញុំចាប់អារម្មណ៍លើពាក្យថា «ចំណីអាហារ» ជាខ្លាំង។ ខ្ញុំបានដឹងថាមនុស្សជាច្រើនភ័យខ្លាចនៅពេលដែលពួកគេចង់ធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ ដោយសារតែពួកគេមិនយល់អំពីឃ្លានោះ។ មនុស្សភាគច្រើនគិតថា នៅពេលដែលគេធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ ពួកគេនឹងលះបង់អ្វីមួយ វានឹងធ្វើឱ្យពួកគេ *ខាតបង់*។ ប៉ុន្តែអ្វីដែលព្រះជាម្ចាស់បានរំឭកខ្ញុំគឺថា ទ្រង់មិនត្រឹមតែផ្តល់គ្រាប់ពូជសម្រាប់សាបព្រោះប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ប្រទានអាហារសម្រាប់បរិភោគ ឬអ្វីដែលមនុស្សម្នាក់ត្រូវការផ្ទាល់ខ្លួនដែរ។ ជាការពិតណាស់ ខ្ញុំបានដឹងរឿងនោះរួចហើយ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ទ្រង់សព្វព្រះហឫទ័យធ្វើឱ្យប្រាកដថា ខ្ញុំបានប្រាប់មនុស្សថា ទ្រង់ផ្តល់របស់ទាំងពីរនេះដល់យើង ហើយយើងមិនចាំបាច់ខ្លាចក្នុងការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់នោះទេ។

នៅយប់យប់មួយ ពីរបីសប្តាហ៍បន្ទាប់ពីយើងបានសាបព្រោះទឹកប្រាក់ចំនួន ១៥.០០០ដុល្លារ ខ្ញុំហៀបនឹងបិទភ្លើង ហើយចូលគេងទៅហើយ ស្រាប់តែខ្ញុំនឹកឃើញចង់ពិនិត្យមើលភាគហ៊ុនមួយចំនួនដែលខ្ញុំកាន់កាប់ ដើម្បីមើលថាវាដំណើរការដល់ណាហើយនៅលើទីផ្សារ។ នៅពេលខ្ញុំពិនិត្យមើលគណនីរបស់ខ្ញុំ ខ្ញុំឃើញថា ភាគហ៊ុនទាំងនោះមានការកើនឡើងមួយចំនួន។

ខ្ញុំហៀបនឹងដាក់ទូរសព្ទចុះ នៅពេលដែលភ្នែករបស់ខ្ញុំកំពុងតែផ្តោតទៅកាន់ភាគហ៊ុនមួយចំនួនដែលខ្ញុំមិនបានកាន់កាប់។ ខ្ញុំធ្លាប់ឃើញភាគហ៊ុននេះពីមុនមក ហើយខ្ញុំធ្លាប់បានមើលវាម្តងរួចមកហើយដើម្បីពិចារណាទិញភាគហ៊ុននោះ។ នៅពេលខ្ញុំស៊ើបអង្កេតលើដំណើរការរបស់ភាគហ៊ុននោះកន្លងមក ខ្ញុំបានដឹងថាវានៅថេរអស់រយៈពេល១២ខែចុងក្រោយ ដូច្នេះ ខ្ញុំបានបោះបង់ចោល។

ប៉ុន្តែមិនដឹងហេតុផលអី នៅយប់នោះ ខ្ញុំហាក់ដូចជាចាប់អារម្មណ៍នឹងភាគហ៊ុននេះខ្លាំងណាស់។ ចម្លែកណាស់ ខ្ញុំមានអារម្មណ៍ថាខ្ញុំគួរតែទិញភាគហ៊ុននោះខ្លះដែលវាខុសពីចរិតរបស់ខ្ញុំទាំងស្រុង។ ដូច្នេះ ខ្ញុំបានទិញភាគហ៊ុននោះក្នុងតម្លៃ ១.៥០០ ដុល្លារ ហើយដាក់ទូរសព្ទចុះ។

ឌ្រិនដា និងខ្ញុំបាននិយាយគ្នាបន្តិចបន្តួច ហើយខ្ញុំបានប្រាប់នាងអំពីការទិញភាគហ៊ុននោះ។ ពេលនោះ ខ្ញុំបានបង្ហាញដល់នាង។ នៅពេលខ្ញុំបើកគណនី ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង។ វាបានកើនឡើងជាង ១០០ ភាគរយក្នុងរយៈពេលតែមួយម៉ោងប៉ុណ្ណោះ! យើងនៅតែភ្ញាក់ផ្អើលអំពីការណ៍នោះ ហើយបាននិយាយគ្នានៅពេលដែលយើងមើលចំនួនភាគហ៊ុនបន្តកើនឡើងស្រីតៗ។

ក្នុងរយៈពេលបីម៉ោងបន្ទាប់ ភាគហ៊ុនបានឡើងដល់តម្លៃជាង ១៧.០០០ ដុល្លារ ដែលជាតម្លៃថេរ។ ខ្ញុំបានប្រាប់ឌ្រិនដា ថា «នោះជាភាគហ៊ុនរបស់យើងដែលមានតម្លៃ ១៥.០០០ដុល្លារ!»

ខ្ញុំបានលក់ភាគហ៊ុននោះភ្លាមៗ ហើយទទួលបានទឹកប្រាក់ដែលកើនឡើង។ ភាគហ៊ុនបានធ្លាក់ចុះវិញនៅព្រឹកបន្ទាប់ ហើយមិនដែលមានការកើនឡើងទៀតនោះទេឥលូវនេះ និងជាច្រើនខែបន្ទាប់ពីព្រឹត្តិការណ៍នោះបានកើតឡើង។ វាជារឿងចម្លែកបំផុតដែលខ្ញុំមិនធ្លាប់ឃើញ។ ខ្ញុំដឹងថាគឺជាព្រះវិញ្ញាណដ៏វិសុទ្ធដែលបានបង្ហាញភាគហ៊ុននោះមកខ្ញុំ ហើយខ្ញុំបានប្រាប់ឌ្រិនដាថាគឺជាព្រះជាម្ចាស់ដែលទ្រង់ប្រទានពរមកឱ្យយើងវិញតាមរយៈគ្រាប់ពូជរបស់យើង។ ព្រះជាម្ចាស់ប្រទានគ្រាប់ពូជដល់អ្នកសាបព្រោះ ហើយទ្រង់ប្រទានអាហារសម្រាប់បរិភោគ! អ្នកដឹងទេ ខ្ញុំមិនខ្វល់ពីរបៀបដែលទ្រង់ធ្វើកិច្ចការនោះទេ ប៉ុន្តែទ្រង់តែងតែធ្វើកិច្ចការនោះ!

ប៉ុន្តែ វាគួរឱ្យចាប់អារម្មណ៍។ បន្ទាប់ពីខ្ញុំលក់ភាគហ៊ុននោះ ហើយទទួលបានប្រាក់មកវិញក្នុងគណនីរបស់ខ្ញុំ ខ្ញុំគិតថា *ប្រសិនបើខ្ញុំដឹងថាភាគហ៊ុននឹងមានតម្លៃកើន*

*ឡើងបែបនេះ ខ្ញុំនឹងដាក់ប្រាក់ច្រើនជាង១.៥០០ដុល្លារ។* ការក្រឡេកមើលទៅក្រោយគឺតែងតែជានិមិត្ត២០/២០។ មែនហើយ ខ្ញុំអាចដាក់ប្រាក់ ១០.០០០ដុល្លារ ឬចិត្តរបស់ខ្ញុំរសាត់អណ្តែត ហើយគិតថា *ចុះបើខ្ញុំដាក់ប្រាក់ចំនួន ១០០.០០០ដុល្លារវិញ តើវានឹងយ៉ាងម៉េចដែរ? គិតពីចំនួនទឹកប្រាក់ដែលខ្ញុំនឹងរកបានពីការវិនិយោគនោះ។* ប៉ុន្តែ ខ្ញុំមិនបានដាក់ប្រាក់ចំនួន១០០.០០០ដុល្លារ ខ្ញុំមិនបានដាក់ប្រាក់ចំនួន១០.០០០ដុល្លារ ហើយខ្ញុំក៏មិនបានដាក់ប្រាក់ចំនួន៥.០០០ដុល្លារដែរ ខ្ញុំដាក់ប្រាក់ត្រឹមតែ១.៥០០ដុល្លារប៉ុណ្ណោះ។ ប្រាក់ចំណេញរបស់ខ្ញុំត្រូវបានកម្រិត។ ខ្ញុំដាក់ប្រាក់ចំនួន ១.៥០០ដុល្លារ ហើយទោះបីជាខ្ញុំចង់បានប្រាក់ចំណូលច្រើនជាងនេះក៏ដោយ ក៏វាមិនកើតឡើងដែរ ព្រោះខ្ញុំដាក់ត្រឹមតែ១.៥០០ដុល្លារប៉ុណ្ណោះ។

ព្រះគម្ពីរប្រាប់យើងនៅក្នុងលូកា ៦:៣៨ ពីអ្វីដែលបានកើតឡើង ហេតុអ្វីបានជាខ្ញុំមិនទទួលបានប្រាក់ចំណេញបន្ថែមទៀតនៅយប់នោះ។

> *ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ។ <u>ព្រះជាម្ចាស់នឹងវាល់ឱ្យអ្នក តាមរង្វាល់ដែលអ្នកវាល់ឱ្យអ្នកដទៃ»</u>។*
>
> —លូកា ៦:៣៨

ឃើញទេ ខ្ញុំបានកំណត់រង្វាល់ ហើយខ្ញុំបានទទួលរង្វាល់មកវិញតាមអ្វីដែលខ្ញុំវាល់—សក្តានុពលដែលខ្ញុំមាននៅយប់នោះ គឺសមាមាត្រដោយផ្ទាល់ទៅនឹងភាគហ៊ុនដែលខ្ញុំបានដាក់។ ខ្ញុំបានកំណត់រង្វាល់ ហើយខ្ញុំច្រូតកាត់មកវិញតាមរង្វាល់នោះ។ ព្រះយេស៊ូមានបន្ទូលថាគោលការណ៍ដូចគ្នានេះក៏អនុវត្តចំពោះការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់របស់អ្នកដែរ។

មានរឿងមួយនៅក្នុងព្រះគម្ពីរ ដែលខ្ញុំចង់បង្ហាញអ្នកពីកន្លែងដែលរឿងនេះបានកើតឡើង។ យើងអាចរៀនបានច្រើនអំពីច្បាប់អំពីរង្វាល់។

*មានស្ត្រីមេម៉ាយម្នាក់ ជាភរិយារបស់បុរសមួយរូប ដែលជាសមាជិករបស់ក្រុមព្យាការី បានមកជួបលោកអេលីសេ ហើយអង្វរលោកថា៖ «ប្ដីរបស់នាងខ្ញុំ ជាអ្នកបំរើរបស់លោកស្លាប់ផុតហើយ។ លោកក៏ជ្រាបដែរថា អ្នកបំរើរបស់លោកគោរពកោតខ្លាចព្រះអម្ចាស់ណាស់។ ឥលូវនេះ ម្ចាស់បំណុលបានមកទាមទារយកកូនប្រុសទាំងពីរនាក់របស់នាងខ្ញុំ ទៅធ្វើជាបាវបំរើរបស់គេ»។*

*លោកអេលីសេមានប្រសាសន៍ថា៖ «តើនាងចង់ឱ្យខ្ញុំធ្វើដូចម្ដេចចំពោះនាង? ចូរប្រាប់ខ្ញុំមកមើល នៅក្នុងផ្ទះនាងមានអ្វីខ្លះ?»។*

*នាងឆ្លើយតបថា៖ «នៅក្នុងផ្ទះនាងខ្ញុំ គ្មានអ្វីក្រៅពីប្រេងមួយកូនដបប៉ុណ្ណោះ» ។ លោកអេលីសេមានប្រសាសន៍ថា៖ «ចូរទៅខ្ចីដបទំនេរ ពីអ្នកជិតខាងឱ្យបានច្រើន*

*គឺកុំខ្ចីតិចពេក។ ពេលមកដល់វិញ ត្រូវនាំគ្នាទាំងម្ដាយ ទាំងកូនចូលទៅក្នុងផ្ទះ បិទទ្វារឱ្យជិត ហើយយកប្រេងចាក់ក្នុងដបទាំងនោះ។ ដបណាពេញត្រូវទុកដោយឡែក»។*

*នាងក៏ចាកចេញពីលោកទៅ ហើយនាំកូនចូលក្នុងផ្ទះបិទទ្វារជិត។ កូនទាំងពីរហុចដបមកឱ្យម្ដាយ រួចម្ដាយយកប្រេងមកចាក់ក្នុងដប។*

*លុះដបទាំងអស់ពេញហើយ នាងប្រាប់កូនថា៖ «ហុចដបមួយទៀតមក!»។*

*កូនឆ្លើយថា៖ «អស់ដបហើយម៉ែ!»។ ពេលនោះ ប្រេងក៏ឈប់ហូរ។*

*នាងនាំដំណឹងនេះទៅជំរាបអ្នកជំនិតរបស់ព្រះជាម្ចាស់ លោកមានប្រសាសន៍មកកាន់នាងថា៖ «ចូរយកប្រេងនេះទៅលក់សងបំណុលគេ រីឯប្រាក់ដែលនៅសល់ចូរទុកចិញ្ចឹមជីវិតម្ដាយ និងកូនចុះ»។*

—២ ពង្សាវតារក្សត្រ ៤:១-៧

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

នេះជារឿងដ៏អស្ចារ្យមួយដែលមានការបើកសម្ដែងជាច្រើនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។

ស្ត្រីនេះទៅរកព្យាការីដើម្បីសុំជំនួយ។ នាងជំពាក់បំណុលគេ ហើយហៀបនឹងបាត់បង់កូនប្រុសរបស់នាង។ ប៉ុន្តែ គួរឱ្យចាប់អារម្មណ៍ណាស់ ព្យាការីមិនដកប្រាក់ពីរតនាគាររបស់គាត់ទេ។ ផ្ទុយទៅវិញ គាត់សួរនាងនូវសំណួរដ៏ចម្លែកមួយក្នុងកាលៈទេសៈនេះ៖ «នៅក្នុងផ្ទះនាងមានអ្វីខ្លះ?»

ខ្ញុំគិតថាសំណួរនេះបានធ្វើឱ្យស្ត្រីភ្ញាក់ផ្អើល ព្រោះអ្នកស្ទើរតែអាចឮនាងឆ្លើយសំណួរដោយភ្ញាក់ផ្អើលថា «ខ្ញុំគ្មានអ្វីសោះ!»។ នាងបញ្ជាក់បន្ថែមដោយប្រើពាក្យថា «ទាល់តែសោះ»។ ប៉ុន្តែ នាងនិយាយអំពីអ្វីដែលនាងមាន។ នាងមានប្រេងបន្តិចបន្តួចប៉ុណ្ណោះ។ នោះគឺជាអ្វីដែលព្យាការីចង់ឮ។ នោះគឺជាចម្លើយ។ មើលដោយយកចិត្តទុកដាក់អំពីការណែនាំរបស់គាត់។

*លោកអេលីសេមានប្រសាសន៍ថា៖ «ចូរទៅខ្ចីដបទំនេរ ពីអ្នកជិតខាងឱ្យបានច្រើន គឺកុំខ្ចីតិចពេក»។*

កុំខ្ចីតិចពេក។ តើត្រូវខ្ចីប៉ុន្មាន? ខ្ញុំគិតថា អ្នកនឹងយល់ស្របថា ចំនួនដបដែលនាងបានប្រមូលគឺមានភាពទូលំទូលាយសម្រាប់ការជជែកដេញដោល ព្រោះមានតែនាងប៉ុណ្ណោះដែលអាចដឹងថាតើនោះមានន័យយ៉ាងដូចម្ដេច? នាងហៀបនឹងដឹងថានាងពិតជាប្រមូលដបមិនបានគ្រប់គ្រាន់!

*នាងក៏ចាកចេញពីលោកទៅ ហើយនាំកូនចូលក្នុងផ្ទះបិទទ្វារជិត។ កូនទាំងពីរហុចដបមកឱ្យម្ដាយ រួចម្ដាយយកប្រេងមកចាក់ក្នុងដប។ លុះដបទាំងអស់ពេញហើយ នាងប្រាប់កូនថា៖ «ហុចដបមួយទៀតមក!»។*

*កូនឆ្លើយថា៖ «អស់ដបហើយម៉ែ!»។ ពេលនោះ ប្រេងក៏ឈប់ហូរ។*

សូមកត់សម្គាល់ថានៅពេលដែលប្រេងឈប់ហូរ—មិនមែនតាមចំនួនដបដែលបានបញ្ជាក់នោះទេ ប៉ុន្តែនៅពេលដែលនាងអស់ដប។ នៅពេលដែលដបទាំងអស់ពេញហើយ នាងប្រាប់កូនប្រុសរបស់នាងឱ្យយកដបមួយទៀតមកឱ្យនាង ប៉ុន្តែគាត់ឆ្លើយថា «អស់ដបហើយម៉ែ»។ ខ្ញុំប្រាកដថានាងចង់បានប្រេងបន្ថែមទៀត ប៉ុន្តែនាងអស់ដបហើយ។ ព្រះជាម្ចាស់មិនបានបិទប្រេងមិនឱ្យឈប់ហូរទេ ប៉ុន្តែគឺដោយការគិតរបស់នាងផ្ទាល់។

ខ្ញុំប្រាកដថានាងប្រហែលជាចង់បានដបច្រើនជាងនេះទៀត។ ហើយប្រសិនបើនាងពិតជាយល់ពីអ្វីដែលហៀបនឹងកើតឡើង ខ្ញុំប្រាកដថានាងនឹងទៅគោះទ្វារគ្រប់ទីកន្លែងក្នុងទីក្រុងដើម្បីស្វែងរកដប។ នាងប្រហែលជានឹងផ្ញើលិខិតស្នើសុំទៅទីក្រុងផ្សេងទៀតដើម្បីប្រមូលដប។

រឿងនេះមានលទ្ធផលល្អ៖ នាងសងបំណុលរបស់នាងរួច ហើយប្រាក់ដែលនៅសេសសល់ពីការលក់ប្រេង នាងយកមកផ្គត់ផ្គង់គ្រួសារ។

ប៉ុន្តែ តើលទ្ធផលអាចជាអ្វី? នាងអាចសងបំណុលគេ*គ្រប់គ្នា*ដែលនាងស្គាល់ សង់ទីប្រជុំជនថ្មី និងបានជួយមនុស្សជាច្រើន។

ដូច្នេះ ហេតុអ្វីបានជានាងប្រមូលតែចំនួនដបដែលនាងបានប្រមូល? ចម្លើយគឺ នាងគ្រាន់តែចង់ដោះស្រាយបញ្ហាដែលនាងកំពុងជួបប៉ុណ្ណោះ។ នាងផ្តោតលើសម្ពាធដែលនាងកំពុងជួប ដូចជាទឹកប្រាក់ដែលនាងជំពាក់បំណុលគេ និងអ្វីដែលនាងត្រូវការដើម្បីបន្តចិញ្ចឹមកូនប្រុសរបស់នាង។ ជំនួសឱ្យការគិតលើសពីសម្ពាធទាំងនោះ នាងផ្តោតលើការលុបបំបាត់សម្ពាធទាំងនោះ។ ខ្ញុំជឿថាប្រសិនបើនាងប្រមូលបានមួយពាន់ដប ដបទាំងអស់នឹងមានប្រេងពេញ។ នាងបានកំណត់រង្វាល់ដោយខ្លួនឯង!

ព្រះជាម្ចាស់ប្រទានឱ្យយើងទាំងអស់គ្នានូវឱកាសដូចគ្នានឹងស្ត្រីនោះដែរ។ យើងទាំងអស់គ្នាត្រូវតែជ្រើសរើសពីរបៀបដែលយើងចង់កំណត់រង្វាល់។

អនុញ្ញាតឱ្យខ្ញុំពន្យល់នៅពេលយើងពិនិត្យមើលបទគម្ពីរសំខាន់របស់យើងសម្រាប់ជំពូកនេះ។

*ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ។ ព្រះជាម្ចាស់នឹងវាល់ឱ្យអ្នកតាមរង្វាល់ដែលអ្នកវាល់ឱ្យអ្នកដទៃ»* ។

—លូកា ៦:៣៨

យើងទាំងអស់គ្នាចូលចិត្តដកស្រង់ផ្នែកដំបូងនៃបទគម្ពីរនេះ ដែលថាប្រសិនបើយើងធ្វើអំណោយ នោះយើងនឹងទទួលបានព្រះពរយ៉ាងបរិបូណ៌ហូរហៀរ។ ប៉ុន្តែជាច្រើនដង យើងមិនបានអានផ្នែកចុងក្រោយ ដែលនិយាយថា យើងនឹង*ច្រូតកាត់តាមរង្វាល់ដែលយើងវាល់ឱ្យអ្នកដទៃតែប៉ុណ្ណោះ*។

ហេតុអ្វីបានជាគោលការណ៍នេះមានសារៈសំខាន់ខ្លាំងចំពោះអ្នក និងខ្ញុំ? ខ្ញុំសូមលើកឧទាហរណ៍មួយ។

ឧបមាថាអ្នកគឺជាកសិករដែលទើបនឹងចាប់ផ្តើមម្នាក់ ហើយខ្ញុំបានប្រាប់អ្នកថាខ្ញុំចង់ទិញស្រូវសាលីចំនួន ៥.០០០តៅ។ អ្នក និងខ្ញុំព្រមព្រៀងគ្នាចំពោះតម្លៃក្នុងមួយតៅ ហើយអ្នករៀបចំដាំស្រូវសាលីលើផ្ទៃដី១០ហិចតាសម្រាប់ការប្រមូលផល។

ខ្ញុំគិតថា អ្នកដឹងពីអ្វីដែលនឹងកើតឡើង។ អ្នកនឹងខ្វះតៅច្រើនដែលត្រូវការដើម្បីបំពេញតាមកិច្ចសន្យារបស់យើង។ ហេតុអ្វី? ដោយសារតែអ្នកមិនដឹងថាតើត្រូវការដីប៉ុន្មានហិចតាដើម្បីប្រមូលផលស្រូវសាលីចំនួន ៥.០០០តៅ។

**តើមានគ្រិស្តបរិស័ទប៉ុន្មាននាក់ដែលកំពុងតម្រង់ជួរដើម្បីប្រមូលផលរបស់ពួកគេទៅលក់នៅទីផ្សារ ប៉ុន្តែបានដាំតែប៉េងប៉ោះពីរដើមប៉ុណ្ណោះ?**

រង្វាល់នៅក្នុងឧទាហរណ៍អំពីកសិករគឺដំណាំដែលគាត់បានដាំគិតជាហិចតា។ ក្នុងករណីអំពីស្ត្រី គឺជាចំនួនដបដែលនាងប្រមូល។ ក្នុងឧទាហរណ៍របស់ព្រះយេស៊ូ វាជាចំនួនដែលយើងសាបព្រោះ។

ដូច្នេះ ប្រសិនបើចម្រូតដែលយើងរំពឹងទុកមិនអាចសម្រេចបានតាមរង្វាល់ដែលយើងបានកំណត់ដើម្បីទទួលបានលទ្ធផលនៃចម្រូត នោះយើងមានការខកចិត្ត ហើយប្រហែលជាមនុស្សដែលមានការយល់ដឹងតិចតួចអាចបន្ទោសព្រះជាម្ចាស់ចំពោះអ្វីដែលគេឃើញថាជាការបរាជ័យនៃព្រះបន្ទូលរបស់ទ្រង់។

ដូច្នេះ នេះជាសំណួរដ៏ពិបាកឆ្លើយមួយៈ ប្រសិនបើកសិករម្នាក់ត្រូវការស្រូវសាលីចំនួន ៥.០០០ តៅ ហើយមិនដឹងថាតើគាត់ត្រូវការដីប៉ុន្មានហិចតាដើម្បីដាំ តើគាត់គួរធ្វើយ៉ាងណា?

## គួរសួរកសិករដែលដឹង!

ឥលូវនេះ ចូរយើងដាក់គោលការណ៍នេះទៅក្នុងស្ថានភាពជីវិតពិតដែលខ្ញុំឃើញគ្រប់ពេលវេលា។

គ្រួសារមួយចង់សងបំណុលគេចំនួន ៣០០.០០០ដុល្លារ ហើយពួកគេដឹងថាពួកគេត្រូវសាបព្រោះ និងចុះកិច្ចព្រមព្រៀងជាប្តីប្រពន្ធ និងស្រាយជំនឿរបស់ពួកគេ។ ប៉ុន្តែតើពួកគេគួរសាបព្រោះទឹកប្រាក់ចំនួនប៉ុន្មាន? ខ្ញុំទទួលបានសំណួរនេះគ្រប់ពេល។ តើពួកគេត្រូវការប្រាក់ចំនួនប៉ុន្មានដើម្បីកំណត់រង្វាល់សម្រាប់ចម្រូតដែលមានតម្លៃ ៣០០.០០០ដុល្លារនេះ? ពួកគេមិនដឹងថាត្រូវធ្វើដូចម្តេចទេ។ ពួកគេនឹងត្រូវសួរនរណាម្នាក់ដែលដឹង ហើយនោះជាព្រះវិញ្ញាណដ៏វិសុទ្ធ។

យើងទាំងអស់គ្នាបានឮទ្រង់ខ្សឹបប្រាប់ចម្លើយចំពោះសំណួរនោះជាច្រើនដង ។ ជាធម្មតា ដោយគ្មានការបង្រៀនដែលល្អ យើងគ្រាន់តែបដិសេធសំឡេងខ្សឹបនោះថា

ជាអ្វីមួយដែលយើងមិនអាចធ្វើបាន។ ឧទាហរណ៍ នៅពេលអ្នកកំពុងសាបព្រោះសម្រាប់ XYZ អ្នកយល់ថាអ្នកគួរតែសាបព្រោះទឹកប្រាក់ចំនួន ១.០០០ដុល្លារ។ រំពេចនោះ អ្នកចាប់ផ្ដើមមានគំនិត និងនិយាយថា «ទេ ខ្ញុំមិនអាចធ្វើរឿងនោះបានទេ» ឬនិយាយថា «នែ៎ សាតាំងអើយ! ថយទៅខាងក្រោយខ្ញុំ»។

រឿងមួយដែលអ្នកអាចដឹងប្រាកដនោះគឺថា <u>សាតាំងនឹងមិនប្រាប់អ្នកឱ្យសាបព្រោះច្រើននៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ឡើយ</u>។ វាដឹងច្បាស់អំពីច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់នេះ។ ដូច្នេះក្នុងករណីនេះ ដោយសារអ្នកមិនទាន់មានទំនុកចិត្តលើគោលការណ៍កំណត់រង្វាល់ ពេលចិត្តរបស់អ្នកប្រកែក អ្នកក៏ព្រមសាបព្រោះ និងផ្ដល់ប្រាក់ចំនួន១០០ដុល្លារតាមធម្មតា។ ហើយជាការពិតណាស់ ដូចជាឧទាហរណ៍របស់ខ្ញុំអំពីស្រូវសាលី អ្នកពិតជាខ្វះខាតយ៉ាងខ្លាំងចំពោះចម្រូតដែលត្រូវការ។

ឥលូវនេះ មុននឹងខ្ញុំនិយាយបន្តទៀត ខ្ញុំត្រូវបញ្ជាក់រឿងមួយ៖

ចំនួនទឹកប្រាក់ដែលអ្នកធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ មិនមែនកំណត់ដោយចំនួនទឹកប្រាក់ដែលអ្នកកំពុងសាបព្រោះនោះទេ!

សូមមើល លូកា ២១:១-៤៖

(ម៉ាកុស ១២:៤១-៤៤)

*ព្រះយេស៊ូទតឃើញពួកអ្នកមានយកប្រាក់មកដាក់ក្នុងហិប ថ្វាយព្រះជាម្ចាស់ ។ ព្រះអង្គទតឃើញស្ត្រីមេម៉ាយក្រីក្រម្នាក់យកប្រាក់ពីរសេន មកដាក់ក្នុងហិបនោះដែរ។ ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ច្រើនជាងគេទាំងអស់ ដ្បិតអ្នកទាំងនោះបានយកប្រាក់សំណល់របស់ខ្លួនមកដាក់ក្នុងហិប។ រីឯស្ត្រីមេម៉ាយនេះវិញ ទោះបី*

*នាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងយកប្រាក់ទាំងអស់ ដែលនាងត្រូវការជាចាំបាច់សម្រាប់ចិញ្ចឹមជីវិត មកដាក់ក្នុងហិប ថ្វាយព្រះជាម្ចាស់ដែរ»។*

សូមកត់សម្គាល់ថា ព្រះយេស៊ូមានបន្ទូលថា ស្ត្រីមេម៉ាយក្រីក្របានថ្វាយប្រាក់ច្រើនជាងអ្នកមានទាំងអស់ដែលបានថ្វាយនៅថ្ងៃនោះ។ ពួកអ្នកមានបានថ្វាយប្រាក់ច្រើន ប៉ុន្តែព្រះគម្ពីរចែងថា ពួកគេបានថ្វាយដោយដកចេញពីទ្រព្យសម្បត្តិរបស់ពួកគេ ឬយើងអាចនិយាយបានថាដកចេញពីប្រាក់ដែលនៅសេសសល់របស់ពួកគេ។ ស្ត្រីមេម៉ាយក្រីក្របានថ្វាយប្រាក់ដែលនាងទុកសម្រាប់ចិញ្ចឹមជីវិត ហើយការណ៍នោះត្រូវការជំនឿយ៉ាងរឹងមាំ។

មិនចាំបាច់មានជំនឿនោះទេក្នុងការថ្វាយពីអ្វីដែលនៅសេសសល់ពីអ្នក។ ជាការពិតណាស់ ការថ្វាយដោយចិត្តសប្បុរសពីអ្វីដែលនៅសេសសល់ពីអ្នកគឺជារឿងល្អដែលគួរធ្វើ ប៉ុន្តែនៅថ្ងៃនោះ គេអាចមើលអ្វីដែលមនុស្សបានថ្វាយ ហើយជាច្រើនដងពួកអ្នកមានថ្វាយដើម្បីឱ្យមនុស្សមើលឃើញ និងដើម្បីទទួលបានឋានៈខាងសាសនាក្នុងចំណោមមិត្តភក្តិរបស់ពួកគេ។

ដូច្នេះ សមីការនៃការកំណត់រង្វាល់ដោយចំនួនទឹកប្រាក់ដែលអ្នកធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ មិនមែនជានិយមន័យត្រឹមត្រូវនៃរបៀបដែលយើងកំណត់រង្វាល់នោះទេ។ វាជាផ្នែកមួយដ៏ធំ ប៉ុន្តែមិនមែនជាផ្នែកតែមួយនោះទេ។

យើងត្រូវចាំថាអ្វីដែល «ធំ» សម្រាប់មនុស្សណាម្នាក់គឺមិនមែនមានន័យថាធំសម្រាប់អ្នកផ្សេងឡើយ។

កាលពីដើម ការធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់មួយពាន់ដុល្លារ គឺច្រើនណាស់សម្រាប់ខ្ញុំ។ តាមពិត នៅពេលដែលយើងចាប់ផ្តើម យើងនឹងត្រូវថ្វាយតង្វាយនោះក្នុងរយៈពេលពីរបីខែ។ ប៉ុន្តែយើងមានលទ្ធភាពកាន់តែច្រើនឡើង

ហើយយើងអាចធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់កាន់តែច្រើន ដោយសារតែយើងមានជំនឿ និងទំនុកចិត្តកាន់តែរឹងមាំ។

នេះជាអ្វីដែលខ្ញុំប្រាប់មនុស្ស៖ ពេលអ្នកសាបព្រោះសម្រាប់ការផ្គត់ផ្គង់ សូមចំណាយពេលមួយភ្លែត ហើយសួរព្រះវិញ្ញាណដ៏វិសុទ្ធនូវអ្វីដែលត្រូវសាបព្រោះ និងកន្លែងដែលត្រូវសាបព្រោះ។

ជាធម្មតា ការសាបព្រោះសម្រាប់តម្រូវការជាប្រចាំ មិនតម្រូវឱ្យមានជំនឿរឹងមាំដូចការសាបព្រោះសម្រាប់ការដោះស្រាយបញ្ហាដ៏សំខាន់ណាមួយនោះទេ ដូចជាដោះបំណុលថ្លៃផ្ទះរបស់អ្នក។ ពេលខ្ញុំសាបព្រោះសម្រាប់បញ្ហាសំខាន់ៗ ខ្ញុំតែងតែ*ចង់ដឹង*អំពីបញ្ហានោះ។ អ្វីដែលខ្ញុំចង់និយាយគឺថាខ្ញុំមិនគ្រាន់តែចង់ធ្វើអំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ពីប្រាក់ដែលនៅសេសសល់ពីខ្ញុំប៉ុណ្ណោះទេ។ ខ្ញុំចង់សាបព្រោះគ្រប់គ្រាន់ដែលខ្ញុំអាច*ដឹង*ថា ខ្ញុំធ្វើដោយជំនឿ។ ចំនួនទឹកប្រាក់ត្រូវតែមានចំនួនច្រើនល្មមដែលអាចជំរុញឱ្យសាច់ឈាមរបស់ខ្ញុំមានប្រតិកម្មហើយខ្ញុំឮក្នុងចិត្តថា តើ*អ្នកប្រាកដទេថានឹងថ្វាយប៉ុណ្ណឹង?*

ខ្ញុំបានដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រាប់អ្នកពីចំនួនទឹកប្រាក់ នៅពេលអ្នកសួរទ្រង់ បើអ្នកប្រាកដថា អ្នកពិតជាចង់ស្តាប់ទ្រង់មានបន្ទូល។

ខ្ញុំត្រូវការជំនួយក្នុងចំណុចនេះជាច្រើនដង។ ដោយសារតែខ្ញុំបង់វិក្កយបត្រនោះតែងតែងាយស្រួលសម្រាប់ខ្រិនដា ក្នុងការឮនូវចំនួនទឹកប្រាក់ដែលយើងគួរសាបព្រោះ និងមិនមានការស្ទាក់ស្ទើរណាមួយឡើយ។ តើអ្នកចាំរឿងដែលខ្ញុំបានប្រាប់អំពីការសាបព្រោះទឹកប្រាក់ចំនួន ២០០.០០០ដុល្លារ សម្រាប់ទិញអគារក្រុមជំនុំ Faith Life របស់យើងជាលើកដំបូងឬទេ?

ខ្ញុំមិនបានប្រាប់អ្នកនូវព័ត៌មានលម្អិតនៃរឿងនោះទេ។ នេះគឺជាការប្តេជ្ញាចិត្តរយៈពេលបីឆ្នាំ មិនមែនជាបំណុលទេ ប៉ុន្តែជាគោលដៅដែលយើងកំណត់ដើម្បីធ្វើ

អំណោយដល់អ្នកដទៃ/ថ្វាយដល់ព្រះជាម្ចាស់ក្នុងរយៈពេលនោះ។ នៅថ្ងៃដែលយើងត្រូវធ្វើឱ្យគេដឹងពីបំណងរបស់យើង ហើយសាបព្រោះពូជដំបូងរបស់យើង ខ្ញុំពិតជាគិតថា ចង់ថ្វាយតែ១៥០.០០០ដុល្លារ។ ប៉ុន្តែឌ្រិនដា បានប្រកែកជាមួយខ្ញុំថា នាងបានឮថា យើងត្រូវថ្វាយចំនួន ២០០.០០០ដុល្លារ។ ខ្ញុំបានច្រានចោលគំនិតរបស់នាង ហើយកាន់ខ្ជាប់តាមគំនិតរបស់ខ្ញុំ គឺត្រូវថ្វាយចំនួន១៥០.០០០ដុល្លារ។ នៅក្នុងកម្មវិធីម្តងទៀត នាងបានទទូចឱ្យយើងថ្វាយ២០០.០០០ដុល្លារ ប៉ុន្តែខ្ញុំបានបដិសេធទៀត។

មុនពេលដែលយើងសាបព្រោះគ្រាប់ពូជនៅថ្ងៃនោះ កសិករម្នាក់ក្នុងក្រុមជំនុំរបស់ខ្ញុំបានក្រោកឈរ ហើយសុំនិយាយ។ គាត់បានលើកទឹកចិត្តអ្នករាល់គ្នាឱ្យទុកចិត្តព្រះជាម្ចាស់ចំពោះចម្រូតរបស់ពួកគេ។ គាត់បានពន្យល់បន្តថា ក្នុងនាមជាកសិករ គាត់ពឹងផ្អែកលើច្បាប់នៃការសាបព្រោះ និងច្រូតកាត់ដើម្បីមានជីវិតរស់នៅ ហើយគាត់បានរកឃើញថាច្បាប់ទាំងនេះគួរឱ្យទុកចិត្ត។ គាត់បាននិយាយថា គាត់ចំណាយប្រាក់ចំនួន ២០០.០០០ដុល្លារក្នុងមួយឆ្នាំ ដើម្បីដាំគ្រាប់ពូជរបស់គាត់។ គាត់បានបន្តទៀតថា ដំបូងឡើយ មើលទៅដូចជាល្ងង់ ដែលបោះប្រាក់ចោលទៅក្នុងដីចំនួន២០០.០០០ដុល្លារ ព្រោះនៅពេលសាបព្រោះ នឹងគ្មានផ្លូវអាចទទួលបានផលមកវិញទេ។ ប៉ុន្តែគាត់បានសង្កត់ធ្ងន់ថា ច្បាប់អំពីការសាបព្រោះ និងច្រូតកាត់តែងតែមានអានុភាពលើចម្រូតដែលមានចំនួនច្រើនជាង២០០.០០០ដុល្លារ ដែលគាត់ចំណាយលើការសាបព្រោះស្រែចម្ការរបស់គាត់។

ឌ្រិនដា យកដៃចាក់ខ្ញុំតិចៗពីចំហៀង។ ខ្ញុំយល់ពីតម្រុយរបស់នាង យើងបានសាបព្រោះចំនួន២០០.០០០ដុល្លារ។ ហើយតើអ្នកចាំពីរបៀបដែលព្រះជាម្ចាស់បានបណ្តាលចិត្តឱ្យអនុប្រធាននោះ ផ្តល់ឱ្យយើងនូវប្រាក់រង្វាន់ប្រចាំឆ្នាំនៅឆ្នាំនោះឬទេ? គឺចំនួន ២០០.០០០ដុល្លារ។ យើងមិនបានចំណាយប្រាក់មួយសេនឡើយក្នុងការសាបព្រោះគ្រាប់ពូជនោះទេ។ ហើយដូចដែលខ្ញុំបាននិយាយនៅក្នុងជំពូកមុននេះ

ប្រាក់រង្វាន់នោះមានជាច្រើនឆ្នាំមកហើយ ហើយបានធ្វើឱ្យយើងទទួលបានប្រាក់ចំណូលជាង ២ លានដុល្លារ។

យើញទេ ចិត្តរបស់ខ្រិនដា មិនពេញទៅដោយព័ត៌មានលម្អិតនៃវិក្កយបត្រទាំងអស់នោះទេ ដោយនាងមិនទុកឱ្យសេចក្ដីភ័យខ្លាចឈ្នះមកលើនាងនោះទេ។ នាងបានឮព្រះជាម្ចាស់មានបន្ទូលមកនាង។ ហើយតាមការពិត នោះគឺជាអ្វីដែលខ្ញុំត្រូវធ្វើផងដែរ។ ប៉ុន្តែ នេះជាលើកដំបូងដែលយើងបានសាបព្រោះអ្វីមួយដែលមានចំនួនជិតស្មើនឹងចំនួននោះ។ ដូច្នេះខ្ញុំមានការភ័យខ្លាចនៅពេលដែលខ្ញុំសម្រេចចិត្តថ្វាយតែ ១៥០.០០០ដុល្លារ។ ខ្ញុំអរគុណព្រះចំពោះភរិយារបស់ខ្ញុំ ដែលបានលើកទឹកចិត្តខ្ញុំឱ្យទុកចិត្តលើព្រះជាម្ចាស់សម្រាប់ការថ្វាយក្នុងចំនួនច្រើនជាងនេះ។

ក្នុងការសាបព្រោះ *តែងតែ*ត្រូវការជំនឿ។ ដូច្នេះចូរយើងកុំអនុញ្ញាតឱ្យការភ័យខ្លាចមករារាំងយើងពីការច្រូតកាត់អ្វីដែលព្រះជាម្ចាស់កំពុងព្យាយាមផ្តល់មកយើង។

*សូមចងចាំថា អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានផលតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិបូណ៌ ក៏ច្រូតបានផលច្រើនបរិបូណ៌ដែរ។*

—២ កូរិនថូស ៩:៦

នៅក្នុងអត្ថបទនេះ លោកប៉ូលកំពុងប្រមូលតង្វាយសម្រាប់ក្រុមជំនុំមួយផ្សេងទៀត ហើយគាត់កំពុងរំឭកប្រជាជនអំពីគោលការណ៍មួយដែលគាត់បានបង្រៀនពួកគេយ៉ាងច្បាស់ពីមុនមក ថាពួកគេនឹងច្រូតនូវអ្វីដែលពួកគេបានសាបព្រោះ និងតាមរង្វាល់ដែលពួកគេសាបព្រោះ។ លោកប៉ូលកំពុងបញ្ជាក់ពីគោលការណ៍នៃការកំណត់រង្វាល់។

ពេលលោកពេត្រុសឱ្យទូកទៅព្រះយេស៊ូប្រើថ្ងៃនោះនៅឯបឹង យើងបានឃើញទូករបស់លោកយ៉ាកុប និងលោកយ៉ូហានពេញដោយចម្រូត ដោយសារជំនឿ

របស់ពេត្រុស ព្រោះពួកគេជាដៃគូ។ ប៉ុន្តែ ខ្ញុំសូមសួរអ្នកថា ប្រសិនបើលោកពេត្រុសមាន ទូកចំនួន ១.០០០ នៅថ្ងៃនោះក្នុងមុខរបរនេសាទរបស់គាត់ តើមានទូកប៉ុន្មាននឹងពេញ ដោយចម្រូត?

ប្រសិនបើអ្នកនិយាយថា ១.០០០ ទូក អ្នកនិយាយត្រូវហើយ។

ជាថ្មីម្តងទៀត យើងឃើញមានការកំណត់រង្វាល់។ រង្វាល់ដែលបានកំណត់គឺ ជាចំនួន*ទូក* ដែលព្រះជាម្ចាស់អាចបំពេញ។ ដូច្នេះខ្ញុំលើកទឹកចិត្តអ្នកឱ្យកំណត់រង្វាល់ ដោយមាននិមិត្តធំ។ សូមកុំមើលទៅក្រោយ ហើយនិយាយថា «អស្ចារ្យ! ភាគហ៊ុននោះ ពេញក្នុងរយៈពេលបីម៉ោង។ ខ្ញុំចង់ដាក់បន្ថែមទៀត»។

ដូច្នេះតើអ្វីបានជំរុញខ្ញុំឱ្យដាក់ប្រាក់តែ ១.៥០០ដុល្លារនៅយប់នោះ បន្ទាប់ពី ព្រះវិញ្ញាណដ៏វិសុទ្ធបានបណ្តាលចិត្តឱ្យទិញ? ខ្ញុំមិនបានសុំឱ្យព្រះជាម្ចាស់ប្រាប់ខ្ញុំពី ចំនួនទឹកប្រាក់ទេ។ ខ្ញុំធ្វើតាមគំនិតរបស់ខ្ញុំផ្ទាល់ ហើយខ្ញុំមិនបានឮសំឡេងរបស់ទ្រង់។

ឥឡូវ សូមកុំនាំគ្នាទិញភាគហ៊ុនជាច្រើនដោយសារតែរឿងនេះ។ ដូចខ្ញុំបាន និយាយមុននេះ ខ្ញុំមិនដាក់ប្រាក់ច្រើនក្នុងផ្សារភាគហ៊ុនទេ។ ប៉ុន្តែព្រះជាម្ចាស់បាន បង្ហាញពីបំណងព្រះហឫទ័យរបស់ទ្រង់នៅយប់នោះ ទ្រង់ប្រទានគ្រាប់ពូជសម្រាប់ សាបព្រោះ និងអាហារសម្រាប់បរិភោគ ហើយវាជាការរំឭកដ៏ល្អមួយដែលយើងគួរ កំណត់រង្វាល់។

ខ្ញុំសង្ឃឹមថាអ្នកចាំរឿងនេះ នៅពេលបន្ទាប់ដែលព្រះជាម្ចាស់ទះស្មារបស់អ្នក ឱ្យផ្តល់ថវិកាដល់កិច្ចការណាមួយ។

យើងទាំងអស់គ្នាត្រូវតែអនុញ្ញាតឱ្យព្រះជាម្ចាស់បង្ហាត់បង្រៀនយើងក្នុងរឿង នេះ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃចិត្តសប្បុរស

ខ្ញុំអាចចាំបានថា នៅពេលដែលតម្លៃអចលនទ្រព្យនៅរដ្ឋផ្លរីដាបានធ្លាក់ចុះអំឡុងពេលមានវិបត្តិឆ្នាំ ២០០៩។ យើងមានមិត្តភក្តិនៅទីនោះដែលរស់នៅតាមឆ្នេរសមុទ្រ ហើយយើងទៅលេងពួកគេជាញឹកញាប់។ ក្នុងអំឡុងពេលនោះ មានផ្ទះសម្រាប់លក់នៅទូទាំងរដ្ឋផ្លរីដា។ ពេលយើងដើរលេងតាមឆ្នេរជាមួយមិត្តភក្តិរបស់យើង ថ្ងៃមួយគាត់បាននិយាយថា «ខ្ញុំចង់បង្ហាញអ្វីមួយដល់អ្នក»។

យើងដើរទៅផ្ទះមួយដែលមានដាក់ផ្លាកសម្រាប់លក់។ តម្លៃត្រឹមតែ ៦៩៥.០០០ដុល្លារ សម្រាប់ផ្ទះចំនួនពីរនៅលើដី។ (បញ្ជាក់ម្តងទៀត ផ្ទះចំនួនពីរនៅមាត់សមុទ្រតម្លៃ ៦៩៥.០០០ដុល្លារ។ ពួកគេនឹងបំពាក់គ្រឿងសង្ហារិមផងដែរ។ ខ្ញុំគិតថាយើងទាំងពីរនឹងយល់ស្របជាមួយគ្នាថាតម្លៃនេះធូរថ្លៃខ្លាំង។ ផ្ទះមួយមានគេជួលហើយទទួលបានចំណូលច្រើន ដោយសារតែផ្ទះទាំងពីរនេះនៅលើឆ្នេរ។ ប៉ុន្តែខ្ញុំមិនអាចគិតអំពីការចំណាយច្រើនបែបនេះក្នុងពេលនោះទេ ហើយខ្ញុំបានបដិសេធមិនទិញផ្ទះទាំងពីរនោះ។ (ខ្ញុំដឹងថា នោះមិនមែនជាជម្រើសដ៏វៃឆ្លាតនោះទេ។) មិត្តរបស់ខ្ញុំមានផ្ទះច្រើនហើយ គាត់មិនចង់មានការងារគ្រប់គ្រងពីរថែមទៀតនៅពេលនោះ។ ខ្ញុំចង់និយាយថា គាត់ចង់ឱ្យយើងទិញផ្ទះនោះភ្លាមៗ។ កម្រមានមហាសេដ្ឋីណាម្នាក់ប្រឹក្សាជាមួយអ្នក ហើយនិយាយថា «នេះជាអ្វីដែលខ្ញុំនឹងធ្វើ»។ ជាការពិតណាស់ គ្រិនដាបាននិយាយថាយើងគួរតែទិញ ប៉ុន្តែខ្ញុំមិនបានផ្លាស់ប្តូរគំនិតរបស់ខ្ញុំឡើយ។

មែនហើយ អ្នកអាចទាយអំពីលទ្ធផល។ មានគេទិញផ្ទះទាំងពីរនោះ ហើយប៉ុន្មានឆ្នាំក្រោយ គេលក់បន្តក្នុងតម្លៃ ៣ លានដុល្លារ។

តើអ្នកដឹងទេថាអ្វីជារឿងគួរឱ្យក្រៀមក្រំ និងខកចិត្តបំផុត? ខ្ញុំមិនបានអធិស្ឋានអំពីការណ៍នោះនៅថ្ងៃនោះ។ ខ្ញុំទុកប្រាជ្ញានៃព្រះវិញ្ញាណដ៏វិសុទ្ធចោល។ ខ្ញុំមិនអើពើនឹងប្រាជ្ញារបស់មិត្តភក្តិ និងភរិយារបស់ខ្ញុំដែលមានប្រាជ្ញាច្រើន។ ខ្ញុំនៅតែនិយាយថាទេ ព្រោះខ្ញុំដឹងថាយើងនឹងត្រូវចំណាយប្រាក់ទាំងអស់ដែលយើងមាននៅពេលនោះ ហើយកំពុងតែមានវិបត្តិសេដ្ឋកិច្ចផង ខ្ញុំមិនមានភាពកក់ក្តៅក្នុងការទិញផ្ទះនោះទេ។ ប៉ុន្តែដូចដែលខ្ញុំបាននិយាយ ខ្ញុំមិនបានសួរព្រះជាម្ចាស់អំពីការណ៍នោះទេ ដែលជាកំហុសដ៏ធ្ងន់។

**ដូច្នេះ កុំឱ្យសេចក្តីភ័យខ្លាចនិយាយមកកាន់អ្នកនៅពេលដែលអ្នកកំពុងសាបព្រោះ និនកំណត់រង្វាល់របស់អ្នក។ ចូរមានចិត្តក្លាហានឡើង។**

ជាអកុសល ខ្ញុំខកខានមិនបានប្រមូលចម្រូតជាច្រើន (មិនមែនទាំងអស់ ប៉ុន្តែជាច្រើន) ហើយព្រះជាម្ចាស់ត្រូវតែដោះស្រាយជាមួយខ្ញុំអំពីការណ៍នោះ។

ថ្ងៃមួយ កាលពីមួយឆ្នាំមុន ឌ្រិនដា បានជួបលោក ខេននែត ខូបលែន ដោយចៃដន្យខណៈពេលដែលនាងនៅរមណីយដ្ឋានមួយ ហើយគាត់បានអញ្ជើញនាងឱ្យញ៉ាំអាហារពេលព្រឹកជាមួយគាត់ និងប្រពន្ធរបស់គាត់ឈ្មោះ ក្លូរា។

នៅតុញ៉ាំអាហារ លោកខេននែត បាននិយាយថា គាត់មានពាក្យមួយឃ្លាសម្រាប់ ឌ្រិនដានិងខ្ញុំ។ នាងបានថតពាក្យទាំងនោះទុកក្នុងទូរសព្ទសម្រាប់ឱ្យខ្ញុំស្តាប់ ព្រោះខ្ញុំមិនបានធ្វើដំណើរជាមួយនាងទេ។ ឃ្លានោះគឺ៖

«យើងបានព្យាយាមនាំយកផ្ទះ និងដីមកឱ្យអ្នក ប៉ុន្តែអ្នកមិនអនុញ្ញាតឱ្យយើងធ្វើកិច្ចការនោះទេ»។

អ៊ីយ៉ា! នោះជាការស្តីបន្ទោស។ ប៉ុន្តែនៅពេលដែលខ្ញុំគិតថយក្រោយអំពីរឿងរ៉ាវជាច្រើន ខ្ញុំបាននិយាយ ទេ មិនមែនជាការស្តីបន្ទោសនោះទេ ខ្ញុំបានឃើញពី

កំហុសរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំគិតថា ចាប់ពីថ្ងៃនោះទៅ ខ្ញុំនឹងមិនខកខានក្នុងចម្រូតរបស់ខ្ញុំទៀតទេ។ នៅពេលដែលខ្ញុំបានធ្វើការសម្រេចចិត្តនោះ វាពិតជាអស្ចារ្យណាស់ដែលព្រះជាម្ចាស់បាននាំរបស់ទាំងនោះមកឱ្យខ្ញុំយ៉ាងលឿនដែលខ្ញុំបានសាបព្រោះ។

ដូច្នេះ សូមកុំឱ្យសេចក្តីភ័យខ្លាចនិយាយទៅកាន់អ្នក នៅពេលអ្នកកំពុងសាបព្រោះ និងកំណត់រង្វាល់របស់អ្នក។ ចូរមានចិត្តក្លាហានឡើង។ អ្នកនឹងមិនដឹងថាព្រះជាម្ចាស់នឹងធ្វើឱ្យរឿងទាំងនេះកន្លងទៅដោយរបៀបណានោះទេ។ ខ្ញុំប្រាកដថា ស្ត្រីមេម៉ាយនៅក្នុងព្រះគម្ពីរ ២ ពង្សាវតារក្សត្រ ជំពូក ៤ មិនអាចនឹកស្មានដល់ថា ប្រេងនឹងហូររហូតនោះទេ។ ប្រសិនបើនាងដឹងមុន រឿងរ៉ាវអំពីស្ត្រីនោះនឹងក្លាយទៅជារឿងផ្សេងទាំងស្រុង។ យើងប្រហែលជានៅតែកំពុងអានអំពីស្ត្រីមេម៉ាយក្រីក្រដែលបានក្លាយជាមហាសេដ្ឋីក្នុងអាជីវកម្មប្រេងសព្វថ្ងៃនេះ។

ជាចុងក្រោយ សូមចងចាំថា អ្នកនឹងត្រូវសាបព្រោះទៅក្នុងចម្រូតកាន់តែច្រើនឡើងជានិច្ច។ អ្នកកំពុងរស់នៅថ្ងៃនេះពីចម្រូតកាលពីម្សិលមិញ ដូច្នេះ សូមចងចាំអំពីឃ្លានេះ នៅពេលដែលអ្នកកំពុងសាបព្រោះ។

សូមចងចាំផងដែរថា បន្ទាប់ពីអ្នកសាបព្រោះ មិនទាន់ទទួលបានផលភ្លាមៗនោះទេ។ ធុងគ្រាប់ពូជមើលទៅទទេ ហើយរុក្ខជាតិមិនទាន់ចាប់ផ្តើមចេញពន្លកនៅឡើយ។ ប៉ុន្តែអ្នកកាន់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឈរយ៉ាងរឹងមាំ ហើយអធិស្ឋានដោយព្រះវិញ្ញាណសម្រាប់ការដឹកនាំ និងព័ត៌មានលម្អិតអំពីចម្រូតដែលព្រះជាម្ចាស់កំពុងប្រទានមកអ្នក។

ខ្ញុំចង់បញ្ចប់ជំពូកនេះដោយលើកយករឿងមួយដែលខ្ញុំបានប្រាប់ជាច្រើនដងហើយ ប៉ុន្តែ វាជារឿងសំខាន់។ រឿងនេះពាក់ព័ន្ធនឹងអ្នកលក់របស់ខ្ញុំម្នាក់កាលពីប៉ុន្មានឆ្នាំមុន នៅពេលដែលខ្ញុំរៀនអំពីគោលការណ៍កំណត់រង្វាល់ដំបូង។ គាត់សាងសង់ផ្ទះថ្មី

តែគាត់ខ្វះថវិកា ដូចដែលអ្នកដឹងហើយថា ការសាងសង់ផ្ទះថ្មីត្រូវចំណាយប្រាក់ច្រើន។ អ្វីមួយតែងតែផ្លាស់ប្ដូរ ឬបន្ថែមដែលផ្លាស់ប្ដូរតម្លៃចុងក្រោយ។

ក្នុងករណីនេះ មិត្តរបស់ខ្ញុំបានប្រើប្រាស់ប្រាក់ដែលធនាគារបានឱ្យខ្ចីអស់ហើយ ហើយគាត់ខ្វះប្រាក់។ តាមថាំពីបញ្ហានេះ គាត់មិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃទូផ្ទះបាយទេ។ ខ្ញុំគិតថា គាត់ខ្វះប្រាក់ប្រហែល ២៥.០០០ដុល្លារ។

នៅយប់មួយ អ្នកតំណាងម្នាក់ទៀតរបស់ខ្ញុំបានទៅជាមួយអ្នកតំណាងដែលកំពុងសាងសង់ផ្ទះដើម្បីថ្វាយបង្គំព្រះជាម្ចាស់។ នៅពេលចប់កម្មវិធី គ្រូអធិប្បាយបានទទួលតង្វាយដោយមានហេតុផលជាក់លាក់មួយ ហើយខ្ញុំមិនបានទទួលព័ត៌មានលម្អិតអំពីរឿងទេ ប៉ុន្តែតំណាងផ្នែកលក់ដែលទៅជាមួយអ្នកតំណាងដែលកំពុងសាងសង់ផ្ទះរបស់គាត់បានមករកខ្ញុំហើយនិយាយថា តំណាងផ្នែកលក់ដែលកំពុងសាងសង់ផ្ទះរបស់គាត់ ហាក់ដូចជាកំពុងជួបបញ្ហានៅយប់នោះ។

គាត់បានពន្យល់ថា បុរសម្នាក់នេះដែលកំពុងសាងសង់ផ្ទះរបស់គាត់បានដើរទៅខាងមុខ ហើយបានថ្វាយតង្វាយ បន្ទាប់មកក៏ត្រលប់មកអង្គុយវិញ។ ប៉ុន្តែគាត់ហាក់មានការព្រួយបារម្ភ។ គាត់ប្រាប់ខ្ញុំថា គាត់ក្រោកឡើងទៅខាងមុខ ហើយថ្វាយតង្វាយថែមទៀត។ គាត់ត្រលប់មកអង្គុយវិញ តែគាត់ហាក់ដូចជាមានការព្រួយបារម្ភកាន់តែច្រើនឡើងនៅពេលនោះ។ គាត់បានអង្គុយនៅទីនោះពីរបីនាទី ហើយបន្ទាប់មកគាត់ដកដង្ហើមធំ គាត់ក៏ដើរទៅខាងមុខម្ដងទៀត ហើយថ្វាយតង្វាយបន្ថែមទៀត។ ពេលនោះ នៅពេលដែលគាត់ត្រលប់មកអង្គុយវិញ គាត់ហាក់ដូចជាមានសេចក្ដីសុខសាន្ត និងលែងមានការព្រួយបារម្ភ។

ក្រោយមកក្នុងខែនោះ អ្នកតំណាងដែលកំពុងសង់ផ្ទះរបស់គាត់បានធ្វើទីបន្ទាល់ថា គាត់បានសាបព្រោះនៅយប់នោះនៅក្រុមជំនុំ សម្រាប់ប្រាក់ដែលគាត់ត្រូវការដើម្បីទូទាត់ថ្លៃទូផ្ទះបាយទាំងនោះ។ បើខ្ញុំចាំមិនខុសទេ ជាងសាងសង់បានសម្រេចចិត្ត

បញ្ចុះតម្លៃទូ៥០%ហើយគាត់អាចបិទការលក់គ្រប់គ្រាន់ដើម្បីបានប្រាក់ទូទាត់វិក្កយបត្រចុងក្រោយបាន។

ដូច្នេះ តើយប់នោះមានរឿងអ្វីកើតឡើង? អ្នកតំណាងដែលកំពុងសង់ផ្ទះរបស់គាត់ប្រាប់ខ្ញុំថា គាត់មិនមានសេចក្តីសុខសាន្តក្នុងចិត្តទេ រហូតដល់លើកទីបី ដែលគាត់បានក្រោកឡើងទៅថ្វាយអ្វីទាំងអស់ដែលគាត់មាន។ ឃើញទេ គាត់បានអធិស្ឋានអំពីរបៀបទូទាត់ប្រាក់ចំនួន ២៥.០០០ដុល្លារនោះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានដឹកនាំគាត់ឱ្យកំណត់រង្វាល់ដែលត្រូវការដើម្បីប្រមូលផលដែលគាត់កំពុងស្វែងរក។

ដូច្នេះ ចូរចងចាំអំពីក្រឹត្យវិន័យដ៏សំខាន់នៃព្រះរាជ្យនៃព្រះជាម្ចាស់នេះ ច្បាប់អំពីរង្វាល់ នៅពេលក្រោយដែលអ្នកសាបព្រោះ។

# ជំពូក ១០
# ស្ដេចដែលមានចិត្តសប្បុរស

ខ្ញុំប្រាកដថាយើងទាំងអស់គ្នាធ្លាប់ធ្វើរឿងនេះ។ មាននរណាម្នាក់ដើរមកសរសើរយើង ហើយយើងនិយាយអ្វីមួយដូចជា «អូហ៎! ខ្ញុំបានទិញវានៅយានដ្ឋានមួយកន្លែងក្នុងតម្លៃ ៥ ដុល្លារ»។

ហេតុអ្វីបានជាយើងនិយាយបែបនេះ? ហេតុអ្វីបានជាយើងមានអារម្មណ៍ខ្មាសគេដែលមានរបស់ល្អ? វាជារឿងគួរឱ្យចាប់អារម្មណ៍ និងក្រៀមក្រំនៅពេលដែលយើងសាងសង់ផ្ទះថ្មីរបស់យើងនៅក្នុងប្រទេសកាលពីជាង ២០ ឆ្នាំមុន យើងបានអធិស្ឋានសុំព្រះជាម្ចាស់ថា ឱ្យផ្ទះនោះធំនៅខាងក្នុង ប៉ុន្តែមើលពីក្រៅទៅឃើញតូច។ យើងជាគ្រូគង្វាលថ្មី ហើយយើងមានអារម្មណ៍ថាមនុស្សនឹងអន់ចិត្តប្រសិនបើយើងសាងសង់ផ្ទះធំ។ នៅពេលនោះ យើងមិនទទួលបានប្រាក់ចំណូលពីក្រុមជំនុំទេ គឺជាប្រាក់ទទួលបានពីអាជីវកម្មរបស់យើងផ្ទាល់ ដែលយើងប្រើដើម្បីសាងសង់ ប៉ុន្តែសម្រាប់ហេតុផលមួយចំនួន យើងមានអារម្មណ៍ថា មនុស្សនឹងគិតថាយើងយកប្រាក់ពីក្រុមជំនុំ។ ដូច្នេះ យើងបានសាងសង់ផ្ទះមួយដែលមានទំហំ ៧១៥ ម៉ែត្រការ៉េ ប៉ុន្តែប្រសិនបើអ្នកមើលទៅផ្ទះវិញ វាមើលទៅដូចជាផ្ទះពីរជាន់ធម្មតាអ៊ីចឹង។

ក្រោយមក យើងដឹងថា នោះជារឿងល្ងង់ខ្លៅ។ ហេតុអ្វីបានជាយើងត្រូវខ្មាសអៀនចំពោះព្រះពរដែលព្រះជាម្ចាស់ប្រទានឱ្យ?

ខ្ញុំប្រើការប្រៀបធៀបនេះនៅក្នុងសន្និបាតរបស់ខ្ញុំ។

ឧបមាថា ខ្ញុំឡើងលើវេទិកាដោយស្លៀកសម្លៀកបំពាក់រហែក និងកខ្វក់ ហើយប្រកាសថា ថ្ងៃនេះយើងប្រារព្ធពិធីអបអរសាទរមួយ ដែលឌ្រិនដា និងខ្ញុំបានដោះបំណុលផ្ទះរបស់យើងរួចហើយ។ បន្ទាប់មកខ្ញុំបានចែករំលែកពីការលំបាកដែលយើងបានជួបប្រទះ (ជួនកាល ៨០ ម៉ោងក្នុងមួយសប្តាហ៍) ដើម្បីសម្រេចការណ៍នោះ ប៉ុន្តែយើងទទួលបានជោគជ័យ។

មនុស្សគ្រប់គ្នានឹងទះដៃ ហើយស្រែក។ ហេតុអ្វី? ដោយសារតែមាននរណាម្នាក់យកឈ្នះលើប្រព័ន្ធបណ្តាសាផែនដី។ មានវិធីដើម្បីយកឈ្នះលើប្រព័ន្ធនេះ។

ប៉ុន្តែប្រសិនបើខ្ញុំដើរឡើងទៅវេទិកា ហើយនិយាយថា «ថ្ងៃនេះមានមនុស្សចម្លែកម្នាក់បានដើរមកហុចប្រាក់ឱ្យយើង ១ លានដុល្លារ ហើយយើងបានដោះបំណុលផ្ទះរបស់យើងរួចហើយ»។

គ្រប់គ្នានឹងនិយាយថា មិនយុត្តិធម៌ទេ។ ហេតុអ្វី? ដោយសារតែយើងត្រូវបានចម្រើនឡើងនៅក្នុងប្រព័ន្ធបណ្តាសាផែនដីដែលត្រូវកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា។ នោះហើយជារបៀបដែលយើងត្រូវបានបណ្តុះបណ្តាលដើម្បីទទួលបានការផ្គត់ផ្គង់។ ជាការពិតណាស់ វាគឺជាប្រព័ន្ធនៃទាសភាព ដោយសារតែមនុស្សភាគច្រើនមិនដែលរីករាយនឹងអារម្មណ៍នៃសេរីភាពហិរញ្ញវត្ថុពិតប្រាកដនោះទេ។ ហើយដោយសារតែរឿងនេះ មនុស្សភាគច្រើនមិនដែលរកឃើញពីគោលបំណងពិតប្រាកដនៃ DNA ខាងវិញ្ញាណរបស់ពួកគេ។ ដោយសារតែយើងរស់នៅក្រោមប្រព័ន្ធរស់រានមានជីវិត ការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុភាគច្រើនត្រូវបានធ្វើឡើងអំពីប្រាក់ មិនមែនអំពី*គោលបំណង*នោះទេ។ មនុស្សស្រមៃចង់មានសេរីភាពក្នុងការបន្តក្តីសុបិន និងសេចក្តីប្រាថ្នារបស់ខ្លួន ប៉ុន្តែសម្រាប់មនុស្សភាគច្រើន ការណ៍នោះមិនដែលកើតឡើងទេ។

កាលពីប៉ុន្មានឆ្នាំមុន ព្រះជាម្ចាស់បានចាប់ផ្ដើមប្រឈមជាមួយខ្ញុំអំពីចំណែកទ្វេគុណ និងរបៀបដែលចំណែកនោះជាកម្មសិទ្ធិរបស់យើង។ ចំណែកទ្វេគុណជួយយើងឱ្យរួចផុតពីប្រព័ន្ធបណ្ដាសាផែនដីនៃការរស់រានមានជីវិត និងការពឹងផ្អែកលើការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាដើម្បីមានជីវិតរស់នៅ។

សរុបមក ចំណែកទ្វេគុណមានន័យថា *លើសពីគ្រប់គ្រាន់*។ ការមានលើសពីគ្រប់គ្រាន់ អនុញ្ញាតឱ្យយើងរស់នៅដោយគ្មានបំណុល ហើយមានភារកិច្ចជាជាងធ្វើឱ្យជីវិតរបស់យើងជាអ្នកបម្រើរបស់ប្រាក់។

ទោះបីជាខ្ញុំបាននិយាយអំពីចំណែកទ្វេគុណនៅក្នុងសន្និបាតរបស់ខ្ញុំអស់ជាច្រើនឆ្នាំក៏ដោយ ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់ចង់បង្ហាញខ្ញុំនូវអ្វីមួយអំពីចំណែកនោះដែលខ្ញុំមិនទាន់យល់។ ខ្ញុំបានដឹងថាមានអ្វីច្រើនជាងដែលខ្ញុំបានឃើញ ហើយខ្ញុំបានសុំព្រះវិញ្ញាណដ៏វិសុទ្ធឱ្យបង្ហាញខ្ញុំថាវាជាអ្វី។

ខ្ញុំបានចាប់ផ្ដើមសិក្សាអត្ថបទគម្ពីរដែលទាក់ទងនឹងចំណែកទ្វេគុណ ហើយរង់ចាំព្រះជាម្ចាស់បង្ហាញខ្ញុំពីអ្វីដែលខ្ញុំបានខកខាន។ ទ្រង់បានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំដោយបង្ហាញអ្វីមួយដ៏គួរឱ្យភ្ញាក់ផ្អើលបំផុតអំពីអ្វីដែលទ្រង់កំពុងព្យាយាមផ្ដល់មកឱ្យខ្ញុំ ដែលខ្ញុំមិនធ្លាប់ស្រមៃដល់។

ខ្ញុំបានទទួលការហៅទូរសព្ទពីបុរសម្នាក់ដែលខ្ញុំមិនដែលបានជួប គឺដៃគូព័ន្ធកិច្ចម្នាក់របស់យើង។ ក្រោយពីបានអានសៀវភៅរបស់ខ្ញុំរួច គាត់ដឹងថាខ្ញុំចូលចិត្តបរបាញ់ គាត់ក៏ទូរសព្ទមកនិយាយថា «ខ្ញុំចង់ទិញកាំភ្លើងមួយដើមឱ្យលោកគ្រូ។ តើលោកគ្រូមិនមានកាំភ្លើងប្រភេទណា»?

នៅពេលនោះ ខ្ញុំមានតែកាំភ្លើងធម្មតាដែលខ្ញុំប្រើសម្រាប់បរបាញ់សត្វជាច្រើនប្រភេទចាប់ពីសត្វក្ដាន់ រហូតដល់សត្វប្រវឹក មាន់ទោ និងទន្សាយ។ ខ្ញុំក៏មានកាំភ្លើងម៉ាក 20 gauge double side-by-side ដែលឪពុករបស់ខ្ញុំបានទិញឱ្យខ្ញុំនៅពេលខ្ញុំមានអាយុ

១៦ ឆ្នាំ។ ប៉ុន្តែ ខ្ញុំតែងតែចាប់អារម្មណ៍នឹងកាំភ្លើងស្នប់ដ៏ស្រស់ស្អាតម៉ាក over and under shotguns ដែលខ្ញុំបានឃើញជាច្រើនដងនៅក្នុងទស្សនាវដ្តីបរបាញ់។ កាំភ្លើងប្រភេទទាំងនេះតែងតែមានចម្លាក់ដ៏ស្រស់ស្អាត និងដងឈើដ៏ល្អឥតខ្ចោះ ហើយតែងតែត្រូវបានផលិតឡើងដោយមានគុណភាពល្អឥតខ្ចោះ។ ដូច្នេះ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនមានកាំភ្លើងស្នប់ម៉ាក over and under ទេ ហើយខ្ញុំពិតជាចង់បានមួយដើម។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំងនៅពេលគាត់និយាយថា គាត់នឹងផ្ញើមកឱ្យខ្ញុំមួយដើម។ នោះពិតជាមិនធម្មតា ហើយខ្ញុំពិតជារំភើបណាស់។

ប្រាកដណាស់ មួយសប្តាហ៍ក្រោយមក ប្រអប់មួយត្រូវបានផ្ញើមកដល់ការិយាល័យក្រុមជំនុំរបស់ខ្ញុំ ហើយនៅពេលដែលខ្ញុំបើកប្រអប់នោះ មិនមែនមានតែមួយដើមទេ ប៉ុន្តែ មាន*ពីរ*ដើមនៃកាំភ្លើងម៉ាក over and under ដ៏ស្រស់ស្អាតបំផុតពីរដែលខ្ញុំមិនធ្លាប់ឃើញ។

ភ្លាមនោះ ខ្ញុំបានទូរសព្ទទៅដៃគូរបស់ខ្ញុំ ហើយអរគុណគាត់សម្រាប់អំណោយដ៏អស្ចារ្យនោះ។

សប្តាហ៍បន្ទាប់ គាត់ផ្ញើឱ្យខ្ញុំពីរដើមទៀត! ឥលូវនេះ ខ្ញុំមានកាំភ្លើងល្អបំផុតចំនួនបួនដើម ដែលខ្ញុំមិនធ្លាប់មាន។ ខ្ញុំបានទូរសព្ទទៅគាត់ម្តងទៀត ហើយគាត់បាននិយាយថា ជារឿយៗ មនុស្សមិនដែលទូរសព្ទមកអរគុណគាត់សម្រាប់អំណោយដែលគាត់ឱ្យទេ ហើយដោយសារខ្ញុំបានអរគុណគាត់ គាត់គិតថាគាត់នឹងផ្ញើឱ្យខ្ញុំពីរដើមទៀត។ ជាក់ស្តែងខ្ញុំបានដឹងថា នេះជាអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ ខ្ញុំមានន័យថា កាំភ្លើងទាំងពីរដើមនោះមកដល់ដំណាលគ្នា ហើយខ្ញុំបានសួរទ្រង់អំពីចំណែកទ្វេគុណ។

និយាយឱ្យខ្លីទៅ កាំភ្លើងទាំងនោះត្រូវបានចាប់ផ្តើមផ្ញើមកម្តងមួយគូ។ មិនយូរប៉ុន្មាន ខ្ញុំប្រហែលជាមានកាំភ្លើងថ្មីចំនួន១៤ដើម ដែលមានគុណភាពខ្ពស់បំផុត។ កាំភ្លើងទាំងនោះមិនមានតម្លៃថោកនោះទេ។ វាមានតម្លៃរាប់ពាន់ដុល្លារ។

បន្ទាប់មក ខ្ញុំទទួលបានរថយន្ត Cadillac Escalade SUV ពណ៌សថ្មីសន្លាង ចំនួនពីរគ្រឿង។ នៅពេលនោះយើងជិះរថយន្តម៉ាក Honda Pilot រយៈពេលដប់ឆ្នាំហើយ ដែលយើងស្រលាញ់ (ហុងដាជារថយន្តដ៏ល្អជានិច្ច) ប៉ុន្តែមិនមែនជា Escalades នោះទេ។

ប៉ុន្មានឆ្នាំហើយដែលឌ្រិនដាចង់បានកាបូបម៉ាក Louis Vuitton ហើយខ្ញុំបាន ជូនវាជាកាដូពិសេសសម្រាប់បុណ្យណូអែលកាលពីប៉ុន្មានឆ្នាំមុន។ ប៉ុន្តែនៅថ្ងៃខួប កំណើតរបស់នាងឆ្នាំនេះ នាងបានទទួលកាបូបម៉ាក Louis Vuitton ជាកាដូ។ ទាយ មើលថានាងទទួលបានប៉ុន្មាន? គឺបានដល់ទៅពីរ ដែលមកពីមនុស្សផ្សេងគ្នា។

យើងក៏មានយន្តហោះទី២របស់យើងបង្ហាញខ្លួននៅក្នុងរដូវកាលនេះ ក៏ដូច ជាផ្ទះនៅមាត់សមុទ្រចំនួន២ផងដែរ ហើយកាន់តែពិសេសជាងនេះទៅទៀតនោះ នៅថ្ងៃ បុណ្យណូអែល យើងទទួលបានអាវធំធ្វើពីរោមសំពោចពណ៌ខ្មៅចំនួន២ដែលអាវមួយ មានតម្លៃ១០.០០០ដុល្លារ។

ខ្ញុំសូមឈប់ត្រង់នេះបន្តិច និងបញ្ជាក់ថាខ្ញុំមិនចង់អួតអំពីនេះទេ ព្រោះខ្ញុំមិន បានធ្វើអីទេ!!!! កាំភ្លើង រថយន្ត Escalades ចំនួនពីរគ្រឿង ការបូប អាវធំធ្វើពីរោមសំពោច បានមកដោយឯកឯងប៉ុណ្ណោះ។

ជាការពិតណាស់ យើងមានការពាក់ព័ន្ធជាមួយផ្ទះទាំងពីរច្រើនជាង ប៉ុន្តែ យើងបានសាបព្រោះគ្រាប់ពូជសម្រាប់ផ្ទះមួយនៅលើឆ្នេរកាលពីប៉ុន្មានឆ្នាំមុន។ ខ្ញុំមិន ដឹងទេ ហើយនាងក៏មិនបានប្រាប់ខ្ញុំដែរនៅពេលនោះ ប៉ុន្តែប៉ុន្មានឆ្នាំមុនឌ្រិនដាបានរក ឃើញផ្ទះដែលនាងស្រលាញ់នៅក្នុងទស្សនាវដ្តីអចលនទ្រព្យមួយ។ នាងចាំថា នាង បានចង្អុលទៅរូបភាពហើយនិយាយថា «ព្រះជាម្ចាស់ ខ្ញុំចង់បានផ្ទះមួយនោះ»។ នៅ ពេលនោះ យើងមានការប្តេជ្ញាចិត្ត និងគម្រោងហិរញ្ញវត្ថុផ្សេងទៀតច្រើនពេក បានជា យើងមិនមានប្រាក់ដើម្បីទិញផ្ទះនៅរដ្ឋផ្លរីដា ប៉ុន្តែយើងដឹងថា យើងនឹងទទួលបានផ្ទះ ណាមួយនៅក្នុងពេលវេលាដែលត្រឹមត្រូវ។

នៅថ្ងៃមួយ ពេលខ្ញុំកំពុងរត់ហាត់ប្រាណ ព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា «*ចូរឱ្យឌ្រិនដាទៅផ្លរីដានៅថ្ងៃស្អែកដើម្បីទិញផ្ទះ*»។ មានការបន្ទាន់ដែលត្រូវធ្វើនៅថ្ងៃស្អែក ដូច្នេះខ្ញុំបាននិយាយថា «បាទ ខ្ញុំនឹងឱ្យនាងទៅ»។

ដូច្នេះឌ្រិនដាបានទៅរដ្ឋផ្លរីដា ហើយមើលផ្ទះចំនួន២៥ផ្សេងគ្នា។ ក្នុងចំណោមផ្ទះដែលនាងបានទៅមើល នាងបានចាប់អារម្មណ៍ផ្ទះមួយ។

ខ្ញុំបានទៅមើលផ្ទះនោះជាមួយនាង ហើយយើងយល់ស្របជាមួយគ្នាថា ផ្ទះនោះល្អឥតខ្ចោះ។ (នៅពេលនេះ នាងភ្លេចថ្ងៃដែលនាងចង្អុលទៅទស្សនាវដ្ដីអចលនទ្រព្យនោះ ហើយបានប្រកាសថានាងនឹងបានផ្ទះនោះ។ រឿងនោះបានកន្លងទៅប្រហែលជាបីឆ្នាំហើយ ហើយយើងមិនដែលឃើញផ្ទះដែលនាងបានចង្អុលដោយផ្ទាល់ឡើយ។)

យើងបានចុះកិច្ចសន្យាទិញផ្ទះដែលនាងចង់បាន ហើយនៅថ្ងៃមួយ ខណៈពេលដែលយើងកំពុងអង្គុយនៅក្នុងផ្ទះរបស់យើងក្នុងរដ្ឋអូហៃយ៉ូ ធ្វើការលើកិច្ចសន្យាមួយចំនួនដែលតម្រូវឱ្យមានរបាយការណ៍អធិការកិច្ចនោះ ឌ្រិនដាស្រាប់តែស្រែកឡើងថា «នោះជាផ្ទះរបស់ខ្ញុំ!»

ខ្ញុំមានការភ្ញាក់ផ្អើល ខណៈដែលយើងចុះកិច្ចសន្យា ហើយអ្វីៗទទួលបានជោគជ័យ។ ខ្ញុំបាននិយាយថា «ពិតមែនហើយ វាជាផ្ទះរបស់អូន»។

នាងបាននិយាយថា «បងមិនយល់ទេ»។ «នោះជា*ផ្ទះពិត*ដែលខ្ញុំបានចង្អុលនៅក្នុងទស្សនាវដ្ដីអចលនទ្រព្យកាលពីប៉ុន្មានឆ្នាំមុន!»

ពេលនោះខ្ញុំនឹកឃើញថា ទស្សនាវដ្ដីអចលនទ្រព្យដែលនាងមើលកាលពីបីឆ្នាំមុនបង្ហាញអំពីផ្ទះនៅក្នុងក្រុងតែមួយ។ តើវាអាចជាផ្ទះតែមួយ? ឌ្រិនដា ប្រាកដថាវាជាផ្ទះតែមួយ ហើយនាងបានចាប់ផ្ដើមដាក់ឈ្មោះលក្ខណៈនៃផ្ទះដែលបានទាក់ទាញចំណាប់អារម្មណ៍របស់នាងកាលពីឆ្នាំមុន។ លក្ខណៈទាំងនោះត្រូវគ្នានឹងផ្ទះនេះយ៉ាងពិត

ប្រាកដ។ ដូច្នេះ ខ្ញុំបានស្រាវជ្រាវខ្លះៗ ហើយប្រាកដណាស់ ផ្ទះដែលយើងបានទិញគឺពិតជាត្រូវបានចុះបញ្ជីសម្រាប់លក់ក្នុងឆ្នាំ និងពេលវេលានៃឆ្នាំដែលគ្រីនដាបាននិយាយថានាងបានចង្អុលទៅផ្ទះនោះ ហើយបានប្រកាសថានាងនឹងបានផ្ទះនោះ។ ប៉ុន្តែសម្រាប់ហេតុផលមួយចំនួន ខ្ញុំបានឃើញថា ភ្លាមៗបន្ទាប់ពីនាងបានប្រកាសថានាងនឹងបានផ្ទះនោះ វាត្រូវបានដកចេញពីទីផ្សារ។

នៅពេលដែលខ្ញុំបានសិក្សាពីប្រវត្តិនៃផ្ទះនេះ ខ្ញុំបានដឹងថា គេដកផ្ទះនេះចេញពីទីផ្សារហើយ រហូតដល់ប៉ុន្មានថ្ងៃមុននេះនៅពេលដែលគេដាក់លក់នៅលើទីផ្សារវិញ។ ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលថាត្រូវឱ្យនាងទៅរដ្ឋផ្លរីដានៅថ្ងៃស្អែក!

ដូច្នេះ យើងបានទិញផ្ទះនៅលើឆ្នេរនោះ ហើយនៅទីបំផុត គ្រីនដាទទួលបានផ្ទះរបស់នាង ជាអ្វីដែលនាងសុបិនចង់បានពេញមួយជីវិតរបស់នាង។ បន្ទាប់មកយើងបានទទួលផ្ទះទីពីរនៅលើឆ្នេរនៅប្រទេសកាណាដាក្នុងឆ្នាំដដែលនោះ។ អស្ចារ្យណាស់!

សូមចងចាំថា អ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានប្រទានមកឱ្យយើង គឺតែងតែល្អបំផុត។ យើងមានការតក់ស្លុតបន្តិចចំពោះរឿងទាំងអស់នោះដែលបានកើតឡើង។ ប៉ុន្តែព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ *«យើងដឹងថា អ្នកមិនត្រូវការកាំភ្លើងចំនួនដប់បួនដើមនោះទេ។ យើងដឹងថាអ្នកមិនត្រូវការរថយន្ត Escalades ពណ៌សចំនួនពីរគ្រឿងទេ...»* ហើយទ្រង់បានពិនិត្យមើលបញ្ជីទាំងមូល។

បន្ទាប់មកទ្រង់មានបន្ទូលថា *«យើងមិនត្រូវការឱ្យកូនរបស់យើងខ្វល់ខ្វាយចំពោះតម្រូវការនោះទេ។ ពួកគេជាម្ចាស់លើអចលទ្រព្យទាំងមូល ហើយយើងសព្វព្រះហឫទ័យក្នុងការផ្ដល់របស់ល្អដល់កូនរបស់យើង»។*

**ទ្រង់បានរំឭកខ្ញុំថា ទ្រង់គឺជាព្រះលើសពីភាពគ្រប់គ្រាន់ គឺជាព្រះនៃចំណែកទ្វេគុណ។**

ទ្រង់បានរំឭកខ្ញុំថា ទ្រង់ជាព្រះលើសពីភាពគ្រប់គ្រាន់ ជាព្រះនៃចំណែកទ្វេគុណ។ ទ្រង់បានបន្តមានបន្ទូលទៀតថា រាស្ត្ររបស់ទ្រង់មិនបានគិតឱ្យបានទូលំទូលាយ មិនមានសុបិនធំល្មម ហើយពួកគេកំពុងកម្រិតនូវអ្វីដែលទ្រង់អាចធ្វើសម្រាប់ពួកគេ។

ឌ្រិនដា និងខ្ញុំភ្ញាក់ផ្អើលបន្តិចចំពោះអ្វីដែលព្រះជាម្ចាស់បានបង្ហាញយើង។ យើងបានដឹងថាយើងត្រូវប្រាប់មនុស្សអំពីចំណែកទ្វេគុណ។ ចំណែកទ្វេគុណមិនមានន័យត្រង់ថា ជាចំនួនពីរនៃអ្វីៗគ្រប់យ៉ាងនោះទេ—ព្រះជាម្ចាស់បានប្រើចំណែកទ្វេគុណដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។ ចំណែកទ្វេគុណមានន័យថា *លើសពីភាពគ្រប់គ្រាន់*។

ពេលនោះព្រះជាម្ចាស់បានមានបន្ទូលប្រាប់ខ្ញុំថា ខ្ញុំត្រូវបង្រៀនអំពីចំណែកទ្វេគុណនេះដល់ក្រុមជំនុំរបស់ខ្ញុំ ហើយខ្ញុំត្រូវប្រាប់ពួកគេអំពីអ្វីគ្រប់យ៉ាងដែលទ្រង់បានប្រទានមកយើង និងពីរបៀបដែលរបស់ទាំងនោះត្រូវបានប្រទានមកយើង។

ឥលូវនេះ ឌ្រិនដា និងខ្ញុំមានភាពឯកជនចំពោះអ្វីដែលយើងមាន ព្រោះអ្វីៗទាំងនោះមិនមែនជាជីវិតនោះទេ ហើយយើងពិតជាមិនដែលចង់សង្កត់ធ្ងន់លើការមានរបស់ទាំងនោះ ឬការបង្កើតរបស់ទាំងនោះដែលអ្នកស្វែងរកនោះទេ។ ប៉ុន្តែយើងមិនបានស្វែងរករបស់ទាំងនេះទេ។ ព្រះជាម្ចាស់បានប្រទានរបស់ទាំងនោះមកយើង។ ដូច្នេះយើងបានបង្រៀនអំពីចំណែកទ្វេគុណក្នុងរយៈពេល ១១ សប្តាហ៍នៅក្រុមជំនុំ ហើយខ្ញុំគិតថាវាប្រហែលជាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើហិរញ្ញវត្ថុរបស់មនុស្សជាងស៊េរីផ្សេងទៀតដែលខ្ញុំធ្លាប់បានបង្រៀន។

ប៉ុន្តែតើអ្នកដឹងទេ? មានសមាជិកលែងមកក្រុមជំនុំដោយសារពួកគេអន់ចិត្តនឹងអ្វីដែលខ្ញុំបានចែកចាយ។ ពួកគេគិតថាខ្ញុំមិនត្រូវការកាំភ្លើងទាំងអស់នោះ ឬរថ

យន្ដ Escalades ទាំងពីរគ្រឿង ឬផ្ទះទាំងពីរនៅលើឆ្នេរ ឬយន្ដហោះទាំងពីរគ្រឿង ឬអាវរោមសត្វដ៏ស្រស់ស្អាតទាំងពីរ។ គេគិតថាខ្ញុំគ្រាន់តែអួតអំពី*របស់*ទាំងនោះ។

ប៉ុន្ដែពួកគេមិនបានយល់ពីចំណុចទាំងមូលដែលថា ព្រះជាម្ចាស់កំពុងបង្ហាញយើងថា ទ្រង់លើសពីភាពគ្រប់គ្រាន់។ ព្រះរាជ្យរបស់ទ្រង់មិនស្ថិតនៅក្នុងការរស់រានមានជីវិតដូចអាណាចក្រផែនដីនោះទេ។ ព្រះរាជ្យនៃព្រះគឺជាព្រះរាជ្យដែលលើសពីភាពគ្រប់គ្រាន់ ហើយទ្រង់សព្វព្រះហឫទ័យក្នុងការមើលថែកូនរបស់ទ្រង់ឱ្យបានជិតដល់។

ខ្ញុំត្រូវតែរំឭកមនុស្សថាខ្ញុំមិនបានធ្វើរឿងនេះទេ។ ព្រះជាម្ចាស់បានធ្វើកិច្ចការនេះ មិនមែនមានន័យថាគ្រប់គ្នាគួរតែបើករថយន្ដដែលមានតម្លៃថ្លៃនោះទេ ប៉ុន្ដែដោយសារទ្រង់ចង់ឱ្យយើងឈប់កំណត់ និងដាក់កម្រិតលើទ្រង់។ ទ្រង់ចង់ឱ្យយើងឈប់និយាយថាគ្មានទម្លាប់ ដោយដាក់កម្រិតទ្រង់ពីអ្វីដែលទ្រង់សព្វព្រះទ័យធ្វើ។ ទ្រង់ចង់ឱ្យយើងដឹងថាទ្រង់ជាព្រះលើសពីភាពគ្រប់គ្រាន់។

ការយល់ដឹងនេះមានសារៈសំខាន់ណាស់ក្នុងការពិភាក្សារបស់យើងអំពីភាពសប្បុរស។ អ្នកត្រូវមានអ្វីមួយដែលត្រូវមានចិត្តសប្បុរសចំពោះវា ជាពិសេសត្រូវមានចិត្តសប្បុរស*គ្រប់*កាលៈទេសៈ។ ខ្ញុំដឹងថា ខ្ញុំបានផ្ដោតយកចិត្តទុកដាក់ចំពោះទ្រង់ ហើយខ្ញុំបានដឹងថា មិនត្រូវខ្មាសចំពោះសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ឡើយ។

រដូវស្លឹកឈើជ្រុះបន្ទាប់ គ្រូគង្វាលក្នុងតំបន់បានសួរថាតើគាត់អាចបរបាញ់នៅលើដីរបស់ខ្ញុំបានដែរឬទេ? ខ្ញុំតែងតែប្រាប់សមាជិកក្នុងក្រុមជំនុំថា ខ្ញុំមិនអនុញ្ញាតឱ្យមានការបរបាញ់ទេ រហូតទាល់តែកូនរបស់ខ្ញុំ និងខ្ញុំទាំងអស់បរបាញ់បានសត្វក្ដាន់សិន នោះខ្ញុំនឹងអនុញ្ញាតឱ្យមនុស្សពីរបីនាក់បរបាញ់មុនពេលបិទរដូវកាល។ ជាការពិតណាស់ រដូវស្លឹកឈើជ្រុះនោះ យើងមានសាច់ក្ដាន់ដាក់នៅក្នុងទូបង្កក ដូច្នេះខ្ញុំបានអញ្ជើញគ្រូគង្វាលនេះមកលេង។

ថ្ងៃដែលគាត់មកលេង ខ្ញុំបានជួបគាត់នៅខាងក្រៅ ដើម្បីប្រាប់គាត់ពីកន្លែងដែលគាត់គួរបរបាញ់។ ខ្ញុំបានឃើញថាគាត់ប្រើកាំភ្លើងបាញ់សត្វស្លាបស៊េរីចាស់ មានន័យថាជាកាំភ្លើងគ្រាប់សំណ។ កាំភ្លើងប្រភេទនេះមិនមែនផលិតឡើងដើម្បីបរបាញ់សត្វក្ដាន់នោះទេ។ អ្នកត្រូវទៅឱ្យជិតសត្វក្ដាន់ ព្រោះកាំភ្លើងបាញ់សត្វស្លាបស៊េរីចាស់មិនមែនផលិតឡើងដើម្បីបរបាញ់សត្វក្ដាន់ឡើយ។ ប៉ុន្តែអ្នកក៏អាចប្រើកាំភ្លើងប្រភេទនេះបានដែរ ព្រោះខ្ញុំបានប្រើវាពីរបីដងមកហើយ ក្នុងអាជីពបរបាញ់របស់ខ្ញុំ។

ប៉ុន្តែ ពេលខ្ញុំអង្គុយនិយាយជាមួយគាត់នៅទីនោះ ខ្ញុំចាំបានថា កាំភ្លើងមួយដើមដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ គឺជាកាំភ្លើងបាញ់សត្វក្ដាន់ដ៏ស្រស់ស្អាត។ តាមពិតទៅ វាជាកាំភ្លើងដែលមានគុណភាពល្អបំផុត។ ខ្ញុំមានអារម្មណ៍ថាព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលថា *«ហេតុអ្វីបានជាអ្នកមិនឱ្យកាំភ្លើងបរបាញ់សត្វក្ដាន់ដែលយើងបានប្រទានឱ្យអ្នកទៅគ្រូគង្វាលម្នាក់នេះ? អ្នកមានកាំភ្លើងបរបាញ់សត្វក្ដាន់ពីរបីដើមទៀត ប៉ុន្តែគាត់មិនមានកាំភ្លើងល្អសម្រាប់បរបាញ់ទេ»។*

ដូច្នេះ ខ្ញុំបានឱ្យកាំភ្លើងនោះទៅគាត់ ហើយគាត់សប្បាយចិត្តណាស់។ អំណោយនោះបានបង្ហាញដល់គាត់អំពីសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ហើយលើកទឹកចិត្តគាត់ចំពោះព្រះជាម្ចាស់។

តើអ្នកចាំនូវអ្វីដែលខ្ញុំបានប្រាប់អ្នកកាលពីប៉ុន្មានជំពូកមុនទេ ថាប្រាក់ និងរបស់របរមួយចំនួនដែលអ្នកកំពុងមានក្នុងដៃគឺមិនមែនជារបស់អ្នកទេ? ព្រះជាម្ចាស់បានប្រទានមកអ្នកដើម្បីបំពេញតម្រូវការរបស់អ្នកផ្សេង។

អ្វីដែលខ្ញុំចង់និយាយគឺថា៖ អ្នករស់នៅក្នុងព្រះរាជ្យនៃព្រះដ៏សប្បុរសដែលមានស្ដេចដ៏សប្បុរស ប៉ុន្តែអ្នកនឹងមិនរីករាយចំពោះអ្វីៗដែលព្រះរាជ្យមាននោះទេ ប្រសិនបើអ្នកមិនបំបែកស្មារតីនៃភាពក្រីក្រនោះ ដែលជំរុញអ្នកឱ្យប្រមូលទុកអ្វីៗទាំងអស់ដែលអ្នកធ្លាប់ទទួលបាន។

ខ្ញុំដឹងថាអ្នកប្រហែលជាបានមើលកម្មវិធីទូរទស្សន៍អំពីអ្នកប្រមូលទុកដែលពួកគេពិតជាធ្វើអន្តរាគមន៍។ ផ្ទះនេះតូចចង្អៀត ពេញទៅដោយសំរាមដែលអ្នកមិនអាចដើរកាត់បាន។ ក្នុងករណីជាច្រើន ផ្ទះនេះត្រូវរុះរើ ឬសាងសង់ឡើងវិញ ព្រោះវាមានសភាពទ្រុឌទ្រោម។ នេះហើយចិត្តរបស់យើង នៅពេលយើងពោរពេញដោយភាពលោភលន់ ហើយចង់ប្រមូលរបស់គ្រប់យ៉ាងទុកសម្រាប់រដូវវស្សា។ យើងមិនត្រូវមានប្រាក់ និងទ្រព្យសម្បត្តិច្រើនពេកនោះទេនៅក្នុងដៃ។

ជាការពិបាកណាស់ក្នុងការមានចិត្តសប្បុរសនៅពេលដែលអ្នកប្រឹងប្រែងសម្រាប់ជីវិតរស់នៅ។ ព្រះជាម្ចាស់ចង់ឱ្យអ្នកដឹងថាមានអ្វីៗជាច្រើននៅក្នុងដំណាក់របស់ទ្រង់ ដូច្នេះចូរមានចិត្តសប្បុរស។ ភាពសប្បុរសរបស់អ្នកនឹងនាំមនុស្សឱ្យចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយបើកចិត្តរបស់ពួកគេដើម្បីទទួលនូវសេចក្ដីល្អ និងសប្បុរសរបស់ទ្រង់។ សូមចាំថា វាគឺជាសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ដែលនាំឱ្យមនុស្សកែប្រែចិត្ត។

*«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹងម្ចាស់ចម្ការម្នាក់ ដែលចាកចេញពីផ្ទះតាំងពីព្រលឹម ដើម្បីរកជួលកម្មករមកធ្វើការនៅក្នុងចម្ការទំពាំងបាយជូររបស់គាត់។ គាត់ព្រមព្រៀងជាមួយពួកកម្មករជាស្រេចថា នឹងឱ្យប្រាក់មួយដួង*ក្នុងមួយថ្ងៃ ហើយចាត់គេឱ្យទៅធ្វើការក្នុងចម្ការ។*

*ប្រមាណជាម៉ោងប្រាំបួនព្រឹក គាត់ចេញទៅឃើញអ្នកផ្សេងទៀតកំពុងតែឈរនៅតាមទីផ្សារឥតធ្វើអ្វីសោះ។ គាត់ក៏និយាយទៅកាន់គេថា "ចូរអ្នករាល់គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ ខ្ញុំនឹងឱ្យប្រាក់ឈ្នួលត្រឹមត្រូវ"។*

*អ្នកទាំងនោះក៏នាំគ្នាទៅធ្វើការនៅចម្ការ។ ម្ចាស់ចម្ការចេញទៅសាជាថ្មីទៀតនៅម៉ោងដប់ពីរ និងម៉ោងបីរសៀល ហើយជួលអ្នកផ្សេងតាមរបៀបដដែល។ ប្រមាណជាម៉ោងប្រាំល្ងាចគាត់ចេញទៅសាជាថ្មី ឃើញអ្នកខ្លះទៀតឈរនៅ*

*តាមទីផ្សារ។ គាត់សួរគេថា "ហេតុដូចម្ដេចបានជាអ្នករាល់គ្នាឈរនៅទីនេះ មួយថ្ងៃវាល់ល្ងាច ឥតធ្វើអ្វីសោះដូច្នេះ?"*

*ពួកគេឆ្លើយថា "មកពីគ្មាននរណាជួលយើងខ្ញុំទៅធ្វើការទេ!"។*

*គាត់ក៏ពោលទៅអ្នកទាំងនោះថា "ចូរអ្នករាល់គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ"។*

*លុះដល់ល្ងាច ម្ចាស់ចម្ការប្រាប់ទៅអ្នកកាន់ប្រាក់ថា "ចូរហៅពួកកម្មករមក ហើយបើកប្រាក់ឱ្យគេ គឺចាប់ផ្ដើមពីអ្នកដែលចូលធ្វើការក្រោយគេបង្អស់ រហូតដល់អ្នកមកមុនគេបង្អស់"។*

*ពួកអ្នកដែលបានចាប់ផ្ដើមធ្វើការម៉ោងប្រាំល្ងាចមកដល់ ទទួលប្រាក់ម្នាក់មួយដួង*ៗ។ ពួកអ្នកដែលចាប់ផ្ដើមធ្វើការមុនគេក៏មកដល់ដែរ ហើយគិតថានឹងបានប្រាក់ច្រើនជាង ប៉ុន្តែ គេទទួលម្នាក់មួយដួងដូចៗគ្នា។ គេទទួលយកប្រាក់ទាំងរអ៊ូរទាំដាក់ម្ចាស់ចម្ការថា "ពួកអ្នកដែលមកដល់ក្រោយនេះ បានធ្វើការតែមួយម៉ោងប៉ុណ្ណោះ រីឯយើងខ្ញុំវិញ យើងខ្ញុំធ្វើការហាលថ្ងៃ ហាលក្ដៅ ហើយលោកបែរជាបើកប្រាក់ឱ្យគេស្មើនឹងយើងខ្ញុំដែរ!"។*

*ម្ចាស់ចម្ការនិយាយទៅកាន់ម្នាក់ក្នុងចំណោមកម្មករទាំងនោះថា "សម្លាញ់អើយ! ខ្ញុំមិនបានបោកបញ្ឆោតអ្នកទេ។ អ្នកបានយល់ព្រមធ្វើការឱ្យខ្ញុំមួយដួងក្នុងមួយថ្ងៃ មែនឬមិនមែន! ចូរយកប្រាក់ឈ្នួលរបស់អ្នកហើយចេញទៅចុះ! ខ្ញុំចង់ឱ្យអ្នកដែលមកដល់ក្រោយ ទទួលប្រាក់ស្មើនឹងអ្នកដែរ។ តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំ ទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬ? ឬមួយអ្នកច្រណែន មកពីឃើញខ្ញុំមានចិត្តសប្បុរស?"។*

*ហេតុនេះ អ្នកដែលនៅខាងក្រោយនឹងត្រលប់ទៅនៅខាងមុខ រីឯអ្នកដែលនៅខាងមុខនឹងត្រលប់ទៅនៅខាងក្រោយវិញ»។*

—ម៉ាថាយ ២០:១-១៦

ដូច្នេះ តើព្រះយេស៊ូកំពុងមានបន្ទូលអំពីអ្វីក្នុងរឿងប្រៀបប្រដូចនេះ? ជាដំបូង យើងត្រូវទទួលស្គាល់ថា ម្ចាស់ចម្ការតំណាងឱ្យព្រះវរបិតា ហើយដំណាំដែលទ្រង់មើលថែ មិនមែនជាសណ្តែកសៀង ឬពោតទេ គឺជាព្រលឹងរបស់មនុស្សវិញ។ កម្មករតំណាងឱ្យយើងរាល់គ្នា គឺជាពួកអ្នកដែលទ្រង់កំពុងចាត់ឱ្យទៅឯទីចម្រូត។ មានរឿងពីរដែលខ្ញុំជឿថាព្រះយេស៊ូចង់ឱ្យយើងឃើញ។ ជាដំបូង សូមកត់សម្គាល់ថា តើម្ចាស់ចម្ការត្រូវការជំនួយកម្រិតណា?

*ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹងម្ចាស់ចម្ការម្នាក់ ដែលចាកចេញពីផ្ទះតាំងពីព្រលឹម ដើម្បីរកជួលកម្មករមកធ្វើការនៅក្នុងចម្ការទំពាំងបាយជូររបស់គាត់។*

គាត់ក្រោកពីព្រលឹមដើម្បីស្វែងរកកម្មករ ហើយគាត់បានចេញទៅក្រៅម្តង ហើយម្តងទៀតពេញមួយថ្ងៃដើម្បីស្វែងរកនរណាម្នាក់អាចជួយការងារក្នុងចម្ការរបស់គាត់បាន។ គាត់ត្រូវការកម្មករជាបន្ទាន់។ ដល់រដូវចម្រូតហើយ ត្រូវតែច្រូត បើមិនដូច្នេះទេនឹងមានការខាតបង់។ សូមកត់សម្គាល់ថា គាត់ថែមទាំងជួលកម្មករតែមួយម៉ោងប៉ុណ្ណោះរហូតដល់ចប់ចម្រូត។

*ម្ចាស់ចម្ការចេញទៅសាជាថ្មីទៀតនៅម៉ោងដប់ពីរ និងម៉ោងបីរសៀល ហើយជួលអ្នកផ្សេងតាមរបៀបដដែល។ ប្រមាណជាម៉ោងប្រាំល្ងាចគាត់ចេញទៅសាជាថ្មី ឃើញអ្នកខ្លះទៀតឈរនៅតាមទីផ្សារ។ គាត់សួរគេថា “ហេតុដូចម្តេចបានជាអ្នករាល់គ្នាឈរនៅទីនេះ មួយថ្ងៃរាល់ល្ងាច ឥតធ្វើអ្វីសោះដូច្នេះ?”*
*ពួកគេឆ្លើយថា “មកពីគ្មាននរណាជួលយើងខ្ញុំទៅធ្វើការទេ!”។*
*គាត់ក៏ពោលទៅអ្នកទាំងនោះថា“ចូរអ្នករាល់គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ”។*

ឥលូវនេះ នេះគឺជាអាថិកំបាំងនៃរឿងប្រៀបប្រដូចះ ហេតុអ្វីបានជាគាត់បង់ប្រាក់ឱ្យកម្មករចាប់ផ្តើមពីអ្នកដែលចូលធ្វើការក្រោយគេ? ចម្លើយមាននៅក្នុង ខ១៥ ។

*ពួកអ្នកដែលបានចាប់ផ្ដើមធ្វើការម៉ោងប្រាំល្ងាចមកដល់ ទទួលប្រាក់ម្នាក់មួយដួងៗ។ ពួកអ្នកដែលចាប់ផ្ដើមធ្វើការមុនគេក៏មកដល់ដែរ ហើយគិតថានឹងបានប្រាក់ច្រើនជាង ប៉ុន្តែ គេទទួលម្នាក់មួយដួងដូចៗគ្នា។ គេទទួលយកប្រាក់ទាំងរអ៊ូរទាំដាក់ម្ចាស់ចម្ការថា "ពួកអ្នកដែលមកដល់ក្រោយនេះ បានធ្វើការតែមួយម៉ោងប៉ុណ្ណោះ រីឯយើងខ្ញុំវិញ យើងខ្ញុំធ្វើការហាលថ្ងៃ ហាលក្ដៅ ហើយលោកបែរជាបើកប្រាក់ឱ្យគេស្មើនឹងយើងខ្ញុំដែរ!"។*

*ម្ចាស់ចម្ការនិយាយទៅកាន់ម្នាក់ក្នុងចំណោមកម្មករទាំងនោះថា "សម្លាញ់អើយ! ខ្ញុំមិនបានបោកបញ្ឆោតអ្នកទេ។ អ្នកបានយល់ព្រមធ្វើការឱ្យខ្ញុំមួយដួងក្នុងមួយថ្ងៃ មែនឬមិនមែន! ចូរយកប្រាក់ឈ្នួលរបស់អ្នកហើយចេញទៅចុះ! ខ្ញុំចង់ឱ្យអ្នកដែលមកដល់ក្រោយ ទទួលប្រាក់ស្មើនឹងអ្នកដែរ។ <u>តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំ ទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬ? ឬមួយអ្នកច្រណែន មកពីឃើញខ្ញុំមានចិត្តសប្បុរស?"</u>។*

## <u>តើអ្នកច្រណែនព្រោះខ្ញុំមានចិត្តសប្បុរសឬ?</u>

ពេលយើងអានរឿងប្រៀបប្រដូចនេះ យើងអាចគិតថា *មិនយុត្តិធម៌ទេ!* អ្នកគិតត្រូវហើយ នៅពេលដែលយើងមើលទៅលើម៉ោងត្រូវបណ្ដាសាលើផែនដីសម្រាប់ចិត្តដែលស្រលាញ់តែប្រាក់។ ប៉ុន្តែដូចដែលខ្ញុំបាននិយាយពីមុនរួចហើយ នោះមិនមែនជាបំណងរបស់ព្រះជាម្ចាស់ទេ។

ម្ចាស់ចម្ការចង់ឱ្យកម្មករដែលមកធ្វើការក្រោយគេ ហើយបានទទួលប្រាក់ឈ្នួលស្មើនឹងគេដែរ ឃើញពីភាពសប្បុរសរបស់គាត់ និងមានចិត្តចង់បន្តធ្វើការឱ្យគាត់។ ប្រសើរជាងនេះទៅទៀត ម្ចាស់ចម្ការចង់ឱ្យពួកគេត្រលប់ទៅរកមិត្តភក្តិទាំងអស់របស់ពួកគេវិញ ហើយប្រាប់មិត្តភក្តិពីចំនួនប្រាក់ឈ្នួលដែលបានទទួល និងភាពសប្បុរសដែលម្ចាស់ចំការមានសម្រាប់ពួកគេ។ ដូច្នេះ តើអ្វីទៅជាការសន្និដ្ឋាននៃរឿង

ប្រៀបប្រដូចនេះ? ព្រះជាម្ចាស់ទ្រង់គង់នៅក្នុងកិច្ចការរបស់មនុស្ស ហើយប្រសិនបើអ្នកចូលរួមក្នុងកិច្ចការរបស់ទ្រង់ ទ្រង់មានភាពសប្បុរស ហើយនឹងផ្តល់រង្វាន់ដល់អ្នកយ៉ាងច្រើន។

## តើអ្នកអាចទទួលបានរង្វាន់នោះដោយឥតគិតថ្លៃពីព្រះជាម្ចាស់ឬទេ?

**ព្រះជាម្ចាស់ទ្រង់គង់នៅក្នុងកិច្ចការរបស់មនុស្ស ហើយប្រសិនបើអ្នកចូលរួមក្នុងកិច្ចការរបស់ទ្រង់ ទ្រង់មានចិត្តសប្បុរសណាស់ ហើយនឹងផ្តល់រង្វាន់ដល់អ្នកយ៉ាងច្រើន។**

ព្រះយេស៊ូប្រាប់រឿងប្រៀបប្រដូចដ៏អស្ចារ្យបំផុតមួយក្នុងព្រះគម្ពីរអំពីការបានរង្វាន់ ខ្ញុំដឹងថាអ្នកបានឮអំពីរឿងប្រៀបប្រដូចនេះ គឺជារឿងអំពីកូនពៅវង្វេង ។ ខ្ញុំចង់ឱ្យអ្នកអានរឿងប្រៀបប្រដូចនេះ បន្ទាប់មកយើងនឹងនិយាយអំពីរឿងនេះ។ សូមចាំបន្តិចទៀត។ យើងជិតចប់សៀវភៅហើយ ខ្ញុំមិនចង់ឱ្យឈប់អានត្រឹមហ្នឹងទេ រហូតដល់អ្នកឮខ្ញុំអានរឿងនេះ។ យើងនឹងអានរឿងនៅក្នុងលូកា ជំពូក ១៥។ វាជាអត្ថបទរាងវែងបន្តិច ប៉ុន្តែសូមចំណាយពេលអានរឿងនេះ។

*ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «មានបុរសមួយរូបមានកូនប្រុសពីរនាក់។ កូនពៅនិយាយទៅឪពុកថា “លោកឪពុក! សូមចែកកេរមត៌កឱ្យកូនមក”។ ឪពុកក៏ចែកមត៌កឱ្យកូន។*

*ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុកឆ្ងាយ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយបង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ។ ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ ដួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្តើមខ្វះខាត។ គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ គេប្រើគាត់ឱ្យ*

*មើលជ្រូកតាមស្រែចម្ការ។ គាត់ចង់ចំអែតក្រពះនឹងចំណីដែលគេដាក់ឱ្យជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឱ្យបរិភោគឡើយ។*

*ពេលនោះ កូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា "អ្នកបម្រើរបស់ឪពុកអញសុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ អញត្រូវតែវិលត្រលប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ សូមលោកឪពុកចាត់ទុកកូនជាអ្នកបម្រើចុះ"។*

*លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រលប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរក្រៃលែងក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។*

*កូនពៅជម្រាបឪពុកថា "លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះ ជាកូនទៀតទេ"។*

*ឪពុកប្រាប់ពួកអ្នកបម្រើថា "ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុត មកពាក់ឱ្យកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់ឱ្យផង។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឱ្យសប្បាយចុះ ដ្បិតកូនខ្ញុំនេះបានស្លាប់ទៅហើយ តែឥលូវរស់ឡើងវិញ វាវង្វេងបាត់ តែឥលូវនេះ ខ្ញុំរកឃើញវិញហើយ"។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ។*

*ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រលប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចំរៀងរបាំ គាត់ហៅអ្នកបម្រើម្នាក់មកសួរថា មានការអ្វីកើតឡើង។ អ្នកបម្រើឆ្លើយថា "ប្អូនលោកត្រលប់មកវិញហើយ។ ឪពុករបស់លោកឱ្យគេកាប់កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រលប់មកវិញដោយសុខសាន្ត"។*

*កូនច្បងខឹងណាស់មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរឱ្យចូល។ កូនច្បងនិយាយទៅឪពុកថា "ខ្ញុំបាននៅបម្រើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបទបញ្ជារបស់លោកត្រង់ណាឡើយ តែលោកមិនដែលឱ្យកូនពពែដើម្បីឱ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង។ ពេលកូនលោកត្រលប់មកវិញ លោកបានកាប់កូនគោបំប៉នទទួលវា មើល៍ វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី"។*

*ឪពុកនិយាយទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥលូវនេះ រស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥលូវនេះ យើងរកឃើញវិញហើយ"»។*

—លូកា ១៥:១១-៣២

ដំបូង យើងត្រូវយល់ថាហេតុអ្វីបានជាកូនពៅចាកចេញពីផ្ទះឪពុក។ ចម្លើយគឺដោយសារគាត់មានរូបភាពនៃកំហុសរបស់ឪពុក ដូចដែលបងប្រុសរបស់គាត់ដែរ។ ចាំទេ កូនច្បងបាននិយាយថា គាត់បានបម្រើឪពុកជាច្រើនឆ្នាំមកហើយ តែឪពុកមិនដែលឱ្យកូនពពែ ដើម្បីឱ្យគាត់កាប់ជប់លៀងជាមួយជាមួយមិត្តភក្តិគាត់ឡើយ។ ចំពោះកូនច្បង ឪពុកគឺជាមេការដ៏តឹងរ៉ឹង។ អ្នកប្រហែលជាសួរថា ហេតុអ្វីបានជាកូនច្បងមិនចាកចេញពីផ្ទះជាមួយកូនពៅ? នេះគ្រាន់តែជាការគិតរបស់ខ្ញុំប៉ុណ្ណោះ ប៉ុន្តែតាមទំនៀមទម្លាប់របស់ជនជាតិយូដា កូនច្បងនឹងទទួលមរតកទ្វេគុណនៅពេលឪពុករបស់គាត់ទទួលមរណភាព។ កូនពៅមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍នោះទេ។ ដូច្នេះ តាមគំនិតរបស់ខ្ញុំគឺថា កូនច្បងមានអ្វីមួយដែលថ្ងៃណាមួយនឹងក្លាយជារបស់គាត់ ហើយគាត់គិតថា គាត់ត្រូវទទួលមរកនោះ។

កូនពៅចង់ស្វែងរកកន្លែងដែលអំណោយផលណាមួយ ហើយចេញពីក្រោមការគ្រប់គ្រងរបស់ឪពុកគាត់ ដូច្នេះគាត់បានយកចំណែកនៃមរតករបស់គាត់ហើយ

ចាកចេញ។ ប៉ុន្តែនៅពេលដែលគាត់ចាកចេញ គាត់បានធ្លាក់ទៅក្នុងស្ថានភាពដែលគាត់នឹកស្មានមិនដល់។ ពេលគាត់អស់ប្រាក់ គាត់បានដឹងថា ប្រទេសទាំងមូលដែលគាត់រត់ទៅនោះ បានជួបគ្រោះទុរ្ភិក្សជាខ្លាំង។ មានទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុកទាំងមូល។ ដោយអស់សង្ឃឹមនឹងមានអាហារបរិភោគ គាត់បានធ្វើអ្វីមួយដែលគាត់មិនដែលធ្វើទាល់តែសោះ។ គាត់បានធ្វើជាអ្នកស៊ីឈ្នួលគេ ដើម្បីទទួលបានអាហារបរិភោគ។ នេះជាលើកទីមួយហើយដែលគាត់ធ្វើជាអ្នកស៊ីឈ្នួលគេ។ ពីមុន គាត់ត្រូវបានគេយកចិត្តទុកដាក់ដោយសារតែឋានៈរបស់គាត់ មិនមែនដោយអ្វីដែលគាត់បានធ្វើនោះទេ។ ឥលូវនេះគាត់ត្រូវបង្ខំចិត្តធ្វើការ។ ការងារតែមួយគត់ដែលគាត់អាចរកបានគឺឱ្យចំណីជ្រូក ដែលជាការងារមិនស្អាត និងគួរឱ្យស្អប់ខ្ពើមសម្រាប់ជនជាតិយូដា។ ព្រះគម្ពីរចែងថាគាត់ឃ្លានខ្លាំងដល់ម្ល៉េះ បានជាគាត់ចង់បានសំណល់ដែលសត្វជ្រូកស៊ី ប៉ុន្តែគ្មានអ្នកណាឱ្យគាត់ទេ។ ហេតុអ្វី? ព្រោះគ្រប់គ្នាកំពុងតែស្ថិតនៅក្នុងស្ថានភាពដូចគាត់ដែរ គឺជួបគ្រោះទុរ្ភិក្ស ហើយម្នាក់ៗចង់បានតែជីវិតរស់នៅ។ តើអ្នកធ្លាប់ជួបប្រទះនឹងចំណុចណាមួយឬទេ? យ៉ាងណាក៏ដោយ ថ្ងៃមួយគាត់បានភ្ញាក់ខ្លួន ហើយគាត់នឹកឃើញថាសូម្បីតែអ្នកបម្រើក្នុងផ្ទះឪពុករបស់គាត់ក៏មានអាហារបរិភោគច្រើនដែរ។

> *ពេលនោះ កូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា "អ្នកបម្រើរបស់ឪពុកអញសុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់។ អញត្រូវតែវិលត្រលប់ទៅរកឪពុកអញវិញ ហើយជម្រាបគាត់ថា លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ។ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ សូមលោកឪពុកចាត់ទុកកូនជាអ្នកបម្រើចុះ"។*
>
> *លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រលប់ទៅរកឪពុកវិញ។*

ដោយដឹងថាមានអាហារបរិភោគហូរហៀរនៅផ្ទះរបស់គាត់ គាត់ក៏ត្រលប់ទៅផ្ទះរបស់ឪពុកគាត់វិញ មិនមែនក្នុងនាមជាកូនទៀតទេ តែជាអ្នកបម្រើស៊ីឈ្នួលវិញ។ គាត់មានគម្រោងទទួលស្គាល់កំហុស និងអំពើបាបរបស់គាត់ចំពោះឪពុកគាត់ ហើយបន្ទាប់មកអង្វរឪពុកឱ្យអនុញ្ញាតឱ្យគាត់ត្រលប់មកធ្វើជាអ្នកបម្រើវិញ។ ទោះយ៉ាងណាក៏ដោយ ពេលគាត់ទៅដល់ផ្ទះ ឪពុករបស់គាត់នៅខាងក្រៅ។ ពេលឃើញគាត់ ឪពុកក៏រត់មកឱបថើប។

*លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រលប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរក្រៃលែងក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។*

ចូរយើងយល់ច្បាស់អំពីអ្វីដែលកំពុងកើតឡើង ព្រោះរឿងនេះពិតជារឿងប្រៀបប្រដូចរវាងព្រះវរបិតានៃយើង និងយើង។ កូនម្នាក់នេះបានចេញមកពីទ្រុងជ្រូក។ តាមច្បាប់របស់សាសន៍យូដា ពេលនោះគាត់ត្រូវបានគេចាត់ទុកថាមិនស្អាត។ នៅពេលដែលឪពុកឱបគាត់ ឪពុកក៏ក្លាយទៅជាមនុស្សមិនស្អាតដែរ ប៉ុន្តែគាត់ធ្វើដូច្នេះដោយសារគាត់មានក្តីស្រលាញ់ចំពោះកូន។ ជំនួសឱ្យការស្តីបន្ទោស និងដាក់ទណ្ឌកម្មកូនពីភាពល្ងង់ខ្លៅរបស់ខ្លួន ឪពុកបានយកអាវដ៏ល្អបំផុតមកពាក់ឱ្យគាត់។ បន្ទាប់មកឪពុកបានពាក់ចិញ្ចៀននៅលើម្រាមដៃរបស់គាត់ ដែលបញ្ជាក់ថា ទទួលបានសិទ្ធិជាកូនរបស់ឪពុកវិញហើយ។ បន្ទាប់មកទៀត ឪពុកបានយកស្បែកជើងមកពាក់ឱ្យគាត់ដែលបញ្ជាក់ថា គាត់មានសិទ្ធិចូលទៅក្នុងផ្ទះ។ អ្នកនឹងឃើញទំនៀមទម្លាប់នេះនៅក្នុងព្រះគម្ពីរ នាងរស់ ៤:៧។

*(កាលពីដើមនៅស្រុកអ៊ីស្រាអែល ពេលអ្នកស្រុកទិញទ្រព្យសម្បត្តិ ឬផ្ទេរកម្មសិទ្ធិអ្វីមួយ ពួកគេមានទម្លាប់ដោះស្បែកជើង ហុចទៅឱ្យម្នាក់ទៀត ទុកជាសញ្ញាបញ្ជាក់ថា គេបានព្រមព្រៀងគ្នាហើយ។)*

ហើយចុងក្រោយ គេជប់លៀងឱ្យគាត់ ដោយកាប់កូនគោដែលបានបំប៉ន។

កូនម្នាក់នេះត្រលប់មកវិញដោយសង្ឃឹមថានឹងធ្វើជាអ្នកបម្រើ ប៉ុន្តែឪពុកបានរាប់គាត់ជាកូនវិញ។

*កូនពៅជម្រាបឪពុកថា "លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឱ្យលោកឪពុករាប់ខ្ញុំនេះ ជាកូនទៀតទេ"។*

*ឪពុកប្រាប់ពួកអ្នកបម្រើថា "ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុត មកពាក់ឱ្យកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់ឱ្យផង។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឱ្យសប្បាយចុះ ដ្បិតកូនខ្ញុំនេះបានស្លាប់ទៅហើយ តែឥលូវរស់ឡើងវិញ វាវង្វេងបាត់ តែឥលូវនេះ ខ្ញុំរកឃើញវិញហើយ"។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ។*

ប៉ុន្តែ ផ្នែកបន្ទាប់នៃរឿងគឺជាអ្វីដែលខ្ញុំចង់ឱ្យអ្នកឃើញ។

*ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រលប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចំរៀងរបាំ គាត់ហៅអ្នកបម្រើម្នាក់មកសួរថា មានការអ្វីកើតឡើង។ អ្នកបម្រើឆ្លើយថា "ប្អូនលោកត្រលប់មកវិញហើយ។ ឪពុករបស់លោកឱ្យគេកាប់កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រលប់មកវិញដោយសុខសាន្ត"។*

*កូនច្បងខឹងណាស់មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរឱ្យចូល។ កូនច្បងនិយាយទៅឪពុកថា "ខ្ញុំបាននៅបម្រើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបទបញ្ជារបស់លោកត្រង់ណាឡើយ តែលោកមិនដែលឱ្យកូនពពែដើម្បីឱ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង។ ពេលកូនលោកត្រលប់មកវិញ លោកបានកាប់កូនគោបំប៉នទទួលវា មើល៍ វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី"។*

*ឪពុកនិយាយទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥលូវនេះ រស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥលូវនេះ យើងរកឃើញវិញហើយ"*»។

ពេលកូនប្រុសច្បងមកដល់ផ្ទះ គាត់មិនព្រមចូលទេ នៅពេលគាត់ដឹងថាមានរឿងអ្វីកើតឡើង។ សូមកត់សម្គាល់អ្វីដែលកូនប្រុសច្បងបាននិយាយ៖ *«ខ្ញុំបាន__នៅបម្រើ__លោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបទបញ្ជារបស់លោកត្រង់ណាឡើយ តែលោកមិនដែលឱ្យកូនពពែ ដើម្បីឱ្យខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង»*។គាត់បាននិយាយថា ឪពុកគាត់ជាមេការដ៏តឹងរ៉ឹង ហើយគាត់ហៅខ្លួនឯងថាយ៉ាងដូចម្តេច? គឺគាត់ហៅខ្លួនឯងថាជាអ្នកបម្រើ! ប៉ុន្តែតើឪពុកហៅគាត់យ៉ាងដូចម្តេចនៅក្នុង ខ៣១? គឺគាត់ហៅថាកូនរបស់ខ្ញុំ! នេះជាអ្វីដែលខ្ញុំចង់និយាយ។

អ្នកធំឡើងដោយមានផ្នត់គំនិតដូចគ្នាចំពោះព្រះជាម្ចាស់ដែលកូនទាំងពីរនាក់នេះទទួលបានពីឪពុករបស់ពួកគេ ដែលគាត់ជាមេការដ៏តឹងរ៉ឹង មានន័យថាការបម្រើគាត់មិនទទួលបានរង្វាន់ឡើយ។ សាសនាបានបង្រៀនអ្នកថា អ្នកត្រូវធ្វើការបម្រើព្រះជាម្ចាស់ ដើម្បីឱ្យទ្រង់ទទួលយកអ្នកជាកូនទ្រង់។ ទោះជាយ៉ាងណាក៏ដោយរូបភាពរបស់កូនពៅអំពីឪពុកគាត់បានផ្លាស់ប្តូរ នៅពេលដែលឪពុករបស់គាត់ទទួលយកគាត់មកវិញដោយមិនមានការស្តីបន្ទោស និងបានទទួលកូនពៅជាកូនរបស់គាត់មិនមែនជាអ្នកបម្រើទេ។ ទំនាក់ទំនងរបស់កូនប្រុសច្បងជាមួយឪពុករបស់គាត់គឺផ្អែកលើអ្វីដែលគាត់បានធ្វើ ដូច្នេះគាត់បានបម្រើឪពុករបស់គាត់ ហើយតែងតែព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ។ នៅពេលអ្នកមើលអត្តសញ្ញាណរបស់អ្នកតាមរយៈការឆ្លុះបញ្ចាំងពីអ្វីដែលអ្នកធ្វើ អ្នកនឹងតែងតែមានចំណុចខ្វះខាត ហើយអ្នកនឹងវិនិច្ឆ័យដោយខុសឆ្គងចំពោះមនុស្សជុំវិញអ្នកថាជាមនុស្សមិនដែលសប្បាយចិត្តជាមួយអ្នក។ ប៉ុន្តែការពិត

ត្រូវបានលាតត្រដាងដែលថា កូនច្បងគឺជាមេការដ៏តឹងរ៉ឹងចំពោះខ្លួនគាត់ រហូតដល់គាត់មិនអាចទទួលសេចក្តីសប្បុរសពីឪពុក។ នៅពេលដែលគាត់ចោទឪពុកថាអយុត្តិធម៌ និងនិយាយថា ឪពុកមិនដែលឱ្យកូនពពែដល់គាត់ដើម្បីកាប់ជប់លៀងជាមួយមិត្តភក្តិរបស់គាត់ ឪពុកក៏បាននិយាយដូចខាងក្រោម៖

*«ឪពុកនិយាយទៅកូនថា "កូនអើយ ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។"»*

គាត់មិនបាននិយាយថា «អ្នកបម្រើរបស់ខ្ញុំអើយ»។ ឪពុកហៅគាត់ថាកូន! កូនគឺមានសិទ្ធិទទួលបានចំណែកមរតកក្នុងគ្រួសារ។ ចំណែកឯអ្នកបម្រើគ្មានសិទ្ធិទទួលបានមរតកទេ។ អ្នកឃើញទេ កូនច្បងមានសិទ្ធិទទួលបានអ្វីៗគ្រប់យ៉ាងក្នុងគ្រួសារ។ ប៉ុន្តែទស្សនៈខុសឆ្គងរបស់គាត់ចំពោះឪពុក និងគំនិតមិនត្រឹមត្រូវរបស់គាត់ចំពោះខ្លួនឯង មិនបានអនុញ្ញាតឱ្យគាត់សម្រាក និងរីករាយជាមួយអ្វីដែលជារបស់គាត់នោះទេ ព្រោះគាត់ចាត់ទុកខ្លួនគាត់ជាអ្នកបម្រើ។

ហេតុអ្វីបានជាខ្ញុំចំណាយពេលដើម្បីរៀបរាប់អំពីរឿងនេះប្រាប់អ្នក? ដោយសារតែអ្នកបម្រើមានការលំបាកក្នុងការទទួលពីព្រះជាម្ចាស់! ពួកគេតែងតែមានអារម្មណ៍ថាពួកគេត្រូវតែធ្វើឱ្យទ្រង់សព្វព្រះហឫទ័យជាមុនសិន និងដោយសារតែពួកគេខ្វះមិនដល់សិរីល្អ នោះពួកគេមានអារម្មណ៍អៀនខ្មាស ភ័យខ្លាច ហើយមិនសក្តិសមក្នុងការទទួលបានព្រះពរពីព្រះវរបិតា។ លុះត្រាតែអ្នកកែប្រែទស្សនៈចំពោះខ្លួនឯង បើពុំនោះសោត អ្នកនឹងមិនអាចទទួលបានព្រះពរដោយសេរីពីព្រះបិតាឡើយ។ ហើយត្រូវចាំថាយើងអាចទទួលបានដោយសេរី បើយើងមានចិត្តសប្បុរសដូចជាព្រះបិតានៃយើង។

អ្នកមិនអាចទទួលបានតួនាទីត្រឹមត្រូវរបស់អ្នកជាមួយព្រះជាម្ចាស់នោះទេ។ វាជាអំណោយនៃសេចក្តីស្រឡាញ់ដែលព្រះអង្គប្រទានមកអ្នក។ ខ្ញុំចូលចិត្តព្រះគម្ពីរម៉ាថាយ ៣:១៦-១៧ ដែលចែងថា៖

*ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹករួចហើយ ទ្រង់យាងឡើងពីទឹក ស្រាប់តែផ្ទៃមេឃបើកចំហ ព្រះអង្គទតឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចុះដូចសត្វព្រាប មកសណ្ឋិតលើព្រះអង្គ។ ពេលនោះ មានព្រះសូរសៀងពីលើមេឃមកថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់!»។*

នេះគឺនៅពេលដែលព្រះយេស៊ូកំពុងចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់។ ទ្រង់មិនទាន់បានធ្វើអ្វីមួយដើម្បីទទួលបានការសរសើរពីព្រះជាម្ចាស់នៅឡើយទេ ប៉ុន្តែសូមកត់សម្គាល់នូវអ្វីដែលព្រះជាម្ចាស់មានបន្ទូល។ ព្រះវរបិតាមានបន្ទូលថា «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់!»។

តើអ្នកនៅចាំចោរពីរនាក់ដែលនៅលើឈើឆ្កាងនៅពេលដែលព្រះយេស៊ូត្រូវបានឆ្កាងដែរឬទេ? ចោរម្នាក់និយាយថា៖ «ឱព្រះយេស៊ូអើយ! ពេលព្រះអង្គយាងមកគ្រងរាជ្យ សូមកុំភ្លេចទូលបង្គំ»។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំសុំប្រាប់ឱ្យអ្នកដឹងច្បាស់ថា ថ្ងៃនេះអ្នកបានទៅនៅស្ថានបរមសុខជាមួយខ្ញុំ»។ តើចោរនោះបានធ្វើអ្វីដើម្បីទទួលបានសេចក្តីសប្បុរសនោះ? មិនបានធ្វើអ្វីទេ!

នៅពេលដែលយើងអំពាវនាវរកព្រះនាមព្រះយេស៊ូ ព្រះគម្ពីរចែងថា យើងបានកើតជាថ្មី ហើយបានរួចចេញពីអាណាចក្រនៃសេចក្តីងងឹតចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ តើយើងបានធ្វើអ្វីដើម្បីទទួលបានសេចក្តីសប្បុរសនោះ? មិនបានធ្វើអ្វីទេ។

ដូច្នេះ នៅពេលខ្ញុំបិទបញ្ចប់ជំពូកនេះ សូមចងចាំថា ខ្ញុំមិនសមនឹងទទួលបានអ្វីទាំងអស់ដែលព្រះជាម្ចាស់បានប្រទានឱ្យខ្ញុំនៅឆ្នាំនោះទេ។ ទ្រង់បានព្យាយាមជួយខ្ញុំឱ្យយល់ថាខ្ញុំបានទទួលព្រះរាជ្យទាំងមូលរបស់ព្រះជាម្ចាស់ នៅពេលដែលខ្ញុំអំពាវនាវដល់ព្រះនាមរបស់ព្រះយេស៊ូ។ ខ្ញុំមិនចាំបាច់ស្វែងរកនោះទេ។ ខ្ញុំគ្រាន់តែត្រូវ

ទទួលសេចក្តីល្អ និងចិត្តសប្បុរសរបស់ទ្រង់។ ពេលដែលអ្នកអាចទទួលបានសេចក្តីសប្បុរសរបស់ទ្រង់ អ្នកអាចមានចិត្តសប្បុរសតាមរយៈសេចក្តីសប្បុរសរបស់ទ្រង់។

# ជំពូក ១១
# សេចក្តីសន្យាដល់អស់អ្នកដែលមានចិត្តសប្បុរស

លោកបៀល និងប្រពន្ធរបស់គាត់ឈ្មោះ អេប្រិល បានកាន់កាប់អាជីវកម្មគ្រួសារខ្នាតតូចមួយ ផ្នែកជួសជុលទុយោដែលមានរយៈពេល១៨ឆ្នាំមកហើយ។ ក្នុងនាមជាសមាជិកនៃក្រុមជុំនុំ Faith Life Church ពួកគេបានឃើញការរីកចម្រើនកើតឡើងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ព្រមទាំងរឿងរ៉ាវដែលទទួលបានជោគជ័យជាច្រើនទៀតដែរ។ ដូច្នេះ ពេលដែលពួកគេបានឮថា យើងនឹងពង្រីកក្រុមជំនុំ Faith Life Church ដើម្បីមានឥទ្ធិពលកាន់តែខ្លាំងនៅក្នុងសហគមន៍ ពួកគេបានសហការយ៉ាងពេញលេញជាមួយយើង។

អេប្រិលបាននិយាយថា នាងបានរៀបចំរួចជាស្រេចក្នុងការផ្តល់ប្រាក់ចំនួន ១០.០០០ដុល្លារ សម្រាប់គម្រោងនេះ ប៉ុន្តែនាងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបៀលចេញពីហាងលក់គ្រឿងទេសត្រលប់មកផ្ទះវិញ ហើយបានប្រាប់នាងថា ព្រះអម្ចាស់បានប្រាប់គាត់ឱ្យផ្តល់ប្រាក់ ៧៥.០០០ ដុល្លារ មិនមែន ១០.០០០ដុល្លារ ទេ។

ពួកគេមិនបានដឹងថា តើវាអាចទៅរួចបានយ៉ាងដូចម្តេចទេ ប៉ុន្តែអេប្រិលបានយល់ព្រមផ្តល់ប្រាក់ចំនួន ៧៥.០០០ ដុល្លារ សម្រាប់ការពង្រីកក្រុមជំនុំនេះ។ ប៉ុន្តែជាថ្មីម្តងទៀត ពួកគេមិនមានលុយ ឬមិនដឹងថាទៅរកប្រាក់ទាំងនេះមកពីណាទេ។

ប៉ុន្មានសប្តាហ៍ក្រោយមក នាយកដ្ឋានផ្គត់ផ្គង់ទឹកសាលាក្រុងបានទូរសព្ទមកប្រាប់ពួកគេថា ពួកគេកំពុងធ្វើគម្រោងជួសជុលដ៏ធំមួយ ហើយបានសួរថាតើពួកគេចាប់អារម្មណ៍ក្នុងការដេញថ្លៃដែរឬទេ។ ពួកគេបាននិយាយថា បាទ/ចាស៎ យើងចាប់អារម្មណ៍ ហើយក៏បានចាប់ផ្តើមរៀបចំឯកសារតាមផ្លូវច្បាប់ និងឯកសារតម្រូវឱ្យបំពេញតាមសាលាក្រុង។ អេប្រិលបាននិយាយថាកិច្ចសន្យានោះមានច្រើនជាង១០០ទំព័រ ហើយពួកគេក៏ចង់បានក្រដាសកុងត្រានៅនឹងកន្លែងតែម្តង។ វាជាដំណើរការមួយដែលត្រូវបំពេញក្រដាសឯកសារជាច្រើន ហើយពួកគេក៏ទទួលបានការដេញថ្លៃនោះ។ ពួកគេបានរកឃើញថា មានតែក្រុមហ៊ុនពួកគេទេដែលបានដាក់សំណើរដេញថ្លៃគម្រោងនេះ ហើយពួកគេក៏មិនបានដឹងថាវាកើតឡើងដោយរបៀបណា ឬមិនបានដឹងពីមូលហេតុដែលសាលាក្រុងបានទាក់ទងមកពួកគេ ដើម្បីឱ្យពួកគេដាក់ពាក្យនោះទេ។

ពេលដែលពួកគេបានដាក់បញ្ជូនកិច្ចសន្យានោះរួចហើយ សាលាក្រុងបានទូរសព្ទមក ហើយបានប្រាប់ពួកគេថា ពួកគេមានអារម្មណ៍ថាក្រុមហ៊ុននោះដូចជាតូចពេក ក្នុងការធ្វើកិច្ចការងារនេះ ដែលពួកគេត្រូវធ្វើផ្ទះចំនួន២០០ផ្ទះ នៅក្នុងរយៈពេលតែ៧៥ថ្ងៃ។ ប៉ុន្តែបន្ទាប់ពីមានការពិភាក្សាមួយចំនួនរួចមក ពួកគេបានបញ្ចុះបញ្ចូលសាលាក្រុងថា ពួកគេអាចដោះស្រាយវាបាន។

លោកបៀលបាននិយាយថា វាគឺជាគម្រោងដែលត្រូវការសហការគ្នាជាក្រុម ត្រូវការធ្វើការបន្ថែមម៉ោង មិនថាថ្ងៃសៅរ៍ក៏ដោយ។ ប៉ុន្តែតើអ្នកដឹងថាវាទៅយ៉ាងណាទេ ? ពួកគេបានបញ្ចប់វាទាន់ពេល ហើយអាចផ្តល់ប្រាក់ចំនួន៧៥.០០០ដុល្លារ សម្រាប់គម្រោងរបស់ក្រុមជំនុំ ព្រមទាំងសងបំណុលអតិថិជនទាំងអស់របស់ពួកគេនៅក្នុងដំណើរការធ្វើគម្រោងមួយនេះផងដែរ។ ពួកគេរំភើបរីករាយជាខ្លាំង!

ឃើញដែរឬទេ ព្រះជាម្ចាស់មានផែនការសម្រាប់បៀល និងអេប្រិល ធំជាងផែនការដែលពួកគេមានសម្រាប់ខ្លួនឯងទៅទៀត។ ទ្រង់ជ្រាបដឹងពីចិត្តរបស់ពួកគេដែលមានចំពោះព្រះអង្គ ប៉ុន្តែទ្រង់ចង់ពង្រីកសមត្ថភាពរបស់ពួកគេ។

ការងារនោះត្រូវបានអនុម័តដោយរដ្ឋាភិបាល ហើយពួកគេបានបញ្ចប់កិច្ចសន្យាដោយជោគជ័យសម្រាប់សាលាក្រុង នេះគឺជាឱកាសដ៏ល្អមួយ ដែលពួកគេអាចធ្វើកិច្ចការនេះបាន ថែមទាំងអាចមានកិច្ចសន្យាធំជាងនេះនាពេលអនាគតផងដែរ។

ព្រះជាម្ចាស់សព្វព្រះហឫទ័យពង្រីកសមត្ថភាពមនុស្ស។ ទ្រង់ជ្រាបពីសក្តានុពលរបស់យើង ប៉ុន្តែជារឿយៗយើងមិនដឹងពីសក្តានុពលរបស់យើងទេ ហើយជាធម្មតាយើងត្រូវការការដាស់តឿនឱ្យភ្ញាក់ខ្លួនបន្តិច។ នេះជាគំរូមួយដែលអ្នកត្រូវតែមានទម្លាប់ជាមួយវា។

*«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹងបុរសម្នាក់ ដែលហៀបចេញដំណើរទៅស្រុកឆ្ងាយ។ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឱ្យ។ គាត់ប្រគល់ប្រាក់ឱ្យអ្នកបម្រើម្នាក់ៗតាមសមត្ថភាពរៀងៗខ្លួន គឺឱ្យប្រាំណែន ទៅអ្នកទីមួយ ពីរណែនទៅអ្នកទីពីរ និងមួយណែនទៅអ្នកទីបី រួចគាត់ចេញដំណើរទៅ។ អ្នកបម្រើដែលបានទទួលប្រាក់ប្រាំណែន យកប្រាក់ចេញទៅរកស៊ីភ្លាម ហើយចំណេញបានប្រាំណែនទៀត។ អ្នកទីពីរក៏ដូច្នោះដែរ គាត់យកប្រាក់ពីរណែននោះទៅរកស៊ី ចំណេញបានពីរណែនទៀត។ រីឯអ្នកដែលទទួលប្រាក់មួយណែនបានចេញទៅជីកដីកប់ប្រាក់ម្ចាស់របស់ខ្លួនទុក។*

—ម៉ាថាយ ២៥:១៤-១៨

យើងបានអានរឿងប្រៀបប្រដូចនេះពីមុនរួចហើយ ប៉ុន្តែខ្ញុំចង់ចង្អុលបង្ហាញនូវអ្វីមួយដែលយើងមិនបានមើលវា។

សូមកត់សម្គាល់ថា ពេលដែលថៅហ្វាយបានប្រគល់ភារកិច្ចដល់អ្នកបម្រើរបស់គាត់ គាត់បាននិយាយថាកិច្ចការត្រូវបានប្រគល់ឱ្យ «ម្នាក់ៗតាមសមត្ថភាពរៀងៗខ្លួន»។ ម្នាក់ដែលបានទទួលមាសប្រាំណែននោះ ត្រូវបានទុកចិត្តថាគាត់អាចប្រើប្រាស់មាសប្រាំណែននោះ មានន័យថាពេលបច្ចុប្បន្នគាត់មានសមត្ថភាពគ្រប់គ្រងមាសប្រាំណែន។ ប្រសិនបើគាត់មានសមត្ថភាព ឬលទ្ធភាពខ្លាំងជាងនេះ ថៅហ្វាយនឹងផ្តល់ឱ្យគាត់កាន់តែច្រើនជាងនេះទៅទៀត។ វាដូចគ្នាចំពោះអ្នកបម្រើពីរនាក់ផ្សេងទៀតដែរ។

ប៉ុន្តែ សូមពិនិត្យមើលថាមានអ្វីបានកើតឡើង។ អ្នកបម្រើដែលមានមាសប្រាំណែនបានបង្កើនដល់ដប់ណែន។ នៅក្នុងដំណើរការនេះ តើមានអ្វីកើតឡើង? និយាយឱ្យចំទៅ សមត្ថភាព ឬលទ្ធភាពរបស់គាត់បានកើនឡើងពីកម្រិតប្រាំទៅកម្រិតដប់។ លទ្ធភាពរបស់គាត់មានការកើនឡើងទាំងនៅក្នុងទំនួលខុសត្រូវ និងការគ្រប់គ្រង។ គាត់កាន់តែមានតម្លៃចំពោះថៅហ្វាយ ហើយបានបង្ហាញអំពីលក្ខណៈរបស់គាត់សម្រាប់ការដំឡើងតួនាទីបន្ថែមទៀត។

ឥលូវនេះ នេះគឺជាប្រាជ្ញារបស់ថៅហ្វាយ។ គាត់ស្គាល់ចរិតលក្ខណៈអ្នកបម្រើដែលមានប្រាក់ប្រាំណែន។ គាត់បានដឹងថា គាត់មានសក្តានុពលក្នុងការឡើងដល់កម្រិតថ្មីថែមទៀត។ ទោះបីជាថៅហ្វាយបានឱ្យប្រាក់ប្រាំណែនទៅអ្នកបម្រើ ដែលនេះជាកម្រិតលទ្ធភាពពេលបច្ចុប្បន្នរបស់គាត់ក៏ដោយ ក៏កិច្ចការដែលគាត់បានផ្តល់ឱ្យទៅអ្នកបម្រើជាមួយនឹងប្រាក់ប្រាំណែននោះ នឹងប្រមូលផលច្រើនជាងអ្វីដែលអ្នកបម្រើមាននៅក្នុងដៃ ហើយជំរុញឱ្យគាត់ឈានដល់កម្រិតថ្មីមួយទៀត ក្នុងលទ្ធភាពនៃការគ្រប់គ្រងរបស់គាត់ផងដែរ។

ថៅហ្វាយបានដឹងថា មធ្យោបាយតែមួយគត់ដើម្បីធ្វើឱ្យអ្នកបម្រើរបស់គាត់មានតម្លៃកាន់តែខ្លាំង គឺត្រូវពង្រីកសមត្ថភាពរបស់គាត់ ហើយអនុញ្ញាតឱ្យគាត់ស្វែងរកសមត្ថភាពរបស់គាត់ដោយខ្លួនឯង។ ការនេះមានដំណើរការដូចគ្នា ពេលដែលព្រះ

ជាម្ចាស់ប្រើជីវិតរបស់យើងដើម្បីធ្វើឱ្យយើងកាន់តែមានតម្លៃ និងបង្ហាត់បង្រៀនយើង នៅក្នុងទិសដៅរបស់យើង។

> *អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ។ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។*
>
> —លូកា ១៦:១០

ដូចដែលខ្ញុំបាននិយាយនៅក្នុងជំពូកមុនអ៊ីចឹង មិនមានកិច្ចការណាដែលតូចតាចនោះទេ។ អ្នកនឹងរីកចម្រើនពីផ្នែកមួយទៅផ្នែកមួយទៀត ហើយវានឹងបង្កើនលទ្ធភាពរបស់អ្នកសម្រាប់ជំហានបន្ទាប់។

ខ្ញុំបានឆ្លងកាត់ដំណើរការនេះច្រើនដងហើយ។ រាល់ពេលដែលខ្ញុំព្យាយាមគិតអំពីការទាំងអស់នោះ ខ្ញុំធ្លាប់គិតថា *អត់ទេ ខ្ញុំមិនអាចធ្វើរឿងនេះបានទេ។ ខ្ញុំមិនដឹងពីរបៀបធ្វើ ឬខ្ញុំគ្មានពេលធ្វើវាទេ។* ប៉ុន្តែរាល់ពេលដែលខ្ញុំនិយាយថា «បាទ ខ្ញុំអាចធ្វើបាន ខ្ញុំក៏ទទួលបានការពង្រីកសមត្ថភាព» ហើយកាន់តែមានលទ្ធភាពសម្រេចសក្តានុពលរបស់ខ្ញុំជាងមុនបន្ថែមទៀត។

មនុស្សអាចមើលមកកាន់ជីវិតខ្ញុំ ហើយគិតថា *អូហ៍ វាពិតជាងាយស្រួលណាស់ ក្នុងការរួចផុតពីបំណុល មានវត្តមាននៅក្នុងកញ្ចក់ទូរទស្សន៍ ហើយមានយន្តហោះឯកជន។* អ៊ៅ ជីវិតពិតជាមានន័យអ្វីម្ល៉េះទេ។ ពិតណាស់ ខ្ញុំយល់ស្រប ថាជីវិតពិតជាមានន័យ ជាជីវិតដ៏ល្អ និងប្រសើរថ្លៃថ្លា! ប៉ុន្តែ អ្នកមិនបានដឹងថាតើជីវិតរបស់ខ្ញុំបានជួបរឿងរ៉ាវអ្វីខ្លះនោះទេ ទម្រាំមកដល់ដំណាក់កាលសព្វថ្ងៃនេះ។ អ្នកមិនដឹងថាខ្ញុំត្រូវមានការព្យាយាមប៉ុនណា ហើយមានពេលជាច្រើនដែលខ្ញុំស្ថិតនៅក្រោមសម្ពាធដ៏លំបាក ដើម្បីឈានដល់កម្រិតនៃលទ្ធភាពពេលបច្ចុប្បន្ននេះ។

ខ្ញុំនៅបន្តលូតលាស់ជានិច្ច ហើយព្រះជាម្ចាស់ក៏នៅតែបន្តផ្តល់កិច្ចការធំៗឱ្យខ្ញុំធ្វើ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងត្រូវបានពង្រីកសមត្ថភាពតតឈប់ឈរជាមួយគម្រោងធំៗ ហើយក៏បានពង្រីកសមត្ថភាពដោយសារការត្រូវការប្រាក់បន្ថែមដើម្បីសម្រេចវាផងដែរ។ ប៉ុន្តែខ្ញុំនឹងមិនផ្ទេរសម្ពាធ (ហើយពេលខ្លះក៏មានភាពរីករាយ) សម្រាប់ពិភពលោកនេះទេ ព្រោះវាជាប្រព័ន្ធបណ្តុះបណ្តាលរបស់ព្រះជាម្ចាស់ដែលជួយខ្ញុំឱ្យទទួលបានជោគជ័យតាមអ្វីដែលខ្ញុំត្រូវបានត្រាស់ហៅឱ្យសម្រេចវា។

ប្រសិនបើខ្ញុំអាចផ្តល់ដំបូន្មានមួយចំនួនដល់អ្នក នោះខ្ញុំនឹងប្រាប់អ្នកថា កុំបោះបង់ឡើយ! សូមអនុញ្ញាតឱ្យព្រះជាម្ចាស់ពង្រីកសមត្ថភាពអ្នកឱ្យក្លាយជាមនុស្សម្នាក់ដែលទ្រង់សព្វព្រះហឫទ័យឱ្យអ្នកក្លាយជា។

ព្រះជាម្ចាស់តែងតែមានជោគជ័យជានិច្ច ទ្រង់មិនដែលបរាជ័យទេ។ អនាគតរបស់អ្នកគឺនៅចំពោះមុខអ្នកហើយ ហើយអ្នកត្រូវតែបន្តដំណើរទៅមុខទៀត។

## តើអ្នកព្រមអនុញ្ញាតឱ្យព្រះជាម្ចាស់ពង្រីកសមត្ថភាពអ្នកដែរឬទេ?

ខ្ញុំបានចូលរួមការប្រជុំអធិស្ឋាននៅយប់ថ្ងៃពុធមួយ។ កូនស្រីរបស់ខ្ញុំកំពុងតែនាំមុខការអធិស្ឋាន ភ្លាមៗនោះនាងបានឈប់ ក្រឡេកមើលមកខ្ញុំ ហើយចាប់ផ្តើមថ្លែងព្រះបន្ទូល។ នេះជាអ្វីដែលនាងបាននិយាយ៖

> ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចម្រូតធំពេកហើយសម្រាប់អ្នក។ យើងកំពុងតែពង្រីកសមត្ថភាពអ្នក។ មានតែដោយសារព្រះវិញ្ញាណរបស់យើងតែប៉ុណ្ណោះទេ ទើបអ្នកអាចយល់ពីអ្វីដែលនឹងកើតឡើងបាន។ តើអ្នកនឹងឈានជើងចេញ ហើយអនុញ្ញាតឱ្យយើងនាំអ្នកទៅរករឿងរ៉ាវលំបាកៗដែលហួសពីការយល់ដឹងរបស់អ្នក ដែលអ្នកគិតថាមិនអាចទៅរួច ដែរឬទេ?

ខ្ញុំបានគិតថា *អូហ៎ អត់ទេ ខ្ញុំដឹងថាវាមានន័យយ៉ាងណាហើយ។* វាមិនមែនជាលើកទីមួយរបស់ខ្ញុំទេ។

ខ្ញុំអរគុណដែលព្រះជាម្ចាស់កំពុងតែសួរខ្ញុំថា ប្រសិនបើខ្ញុំអនុញ្ញាតឱ្យទ្រង់ដឹកនាំខ្ញុំចូលទៅក្នុងរឿងរ៉ាវលំបាកៗ និងរឿងរ៉ាវដែលមិនអាចទៅរួច ខ្ញុំដឹងថាកិច្ចការទាំងនោះនឹងនាំឱ្យមានការអស្ចារ្យកើតឡើង ព្រោះពេលដែលអ្នកព្រមអនុញ្ញាតឱ្យព្រះជាម្ចាស់ដឹកនាំអ្នក នោះទ្រង់នឹងតែងតែបង្ហាញអ្នកឱ្យឃើញវាយ៉ាងច្បាស់។

ប៉ុន្តែខ្ញុំដឹងពីការឈឺចាប់នៃការពង្រីកសមត្ថភាពនេះ និងដឹងពីតម្លៃដែលត្រូវលះបង់ដើម្បីទៅកាន់កន្លែងមួយដែលអ្នកមិនធ្លាប់ទៅពីមុនមក។ ប៉ុន្តែ **គឺប៉ុន្តែ** ខ្ញុំក៏ដឹងអំពីភាពល្អរបស់ព្រះជាម្ចាស់ និងប្រព័ន្ធលើកកម្ពស់សមត្ថភាពរបស់ទ្រង់ ដូច្នេះខ្ញុំក៏បាននិយាយភ្លាមៗថា «បាទ!»

ព្រះជាម្ចាស់ចង់នាំយកសក្ដានុពលដែលទ្រង់បានដាក់នៅក្នុងអ្នកចេញមកក្រៅ។ នេះគឺជាវិធីតែមួយគត់ដែលអ្នកនឹងទៅដល់ទិសដៅរបស់អ្នក។ ទ្រង់ត្រូវតែពង្រីកសមត្ថភាពរបស់អ្នក! តើព្រះជាម្ចាស់ពង្រីកសមត្ថភាពរបស់យើងដោយរបៀបណា? ដោយ*ការដាក់សម្ពាធ។*

បើអ្នកផ្លុំប៉េងប៉ោងមួយ ហើយបន្ទាប់មកបន្ធូរខ្យល់វាចេញ នោះប៉េងប៉ោងរីកមាឌធំជាងមុន។ រឿងនេះគឺដូចគ្នាជាមួយអ្នក និងខ្ញុំដែរ។ ពេលដែលយើងរងសម្ពាធ ហើយមិនបោះបង់ចោល នោះលទ្ធភាពរបស់យើងនឹងកើនឡើង។ លទ្ធភាពនោះ មានន័យថា អ្នកអាចធ្វើគម្រោងកាន់តែធំជាងមុន និងត្រូវការការត្រួតពិនិត្យកាន់តែច្រើនជាងមុនផងដែរ។ អ្នកដឹងទេ វាជារឿងដ៏រីករាយមួយ ពេលនិយាយអំពីចិត្តសប្បុរស ពេលដែលព្រះជាម្ចាស់ប្រាប់អ្នកឱ្យថ្វាយប្រាក់១០០.០០០ដុល្លារ ឬថ្វាយរថយន្តដែលអ្នកចូលចិត្តនោះឱ្យទៅអ្នកដទៃ ឬព័ន្ធកិច្ចណាមួយ។ ទំនុកចិត្តរបស់អ្នកចំពោះព្រះជាម្ចាស់ ត្រូវតែលូតលាស់ ហើយលទ្ធភាពរបស់អ្នកក៏កើនឡើងតាមនោះដែរ។

ពីរបីសប្តាហ៍ក្រោយមក បន្ទាប់ពីខ្ញុំបាននិយាយថាយល់ព្រមជាមួយព្រះជាម្ចាស់នៅក្នុងការប្រជុំនោះមក ខ្ញុំបានដឹងថា វាជារឿងអ្វីហើយ។ វាគឺជាការចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍របស់យើង ដែលយើងបានចាក់ផ្សាយមួយថ្ងៃក្នុងមួយសប្តាហ៍ *ពួកគេបានទាក់ទងមកយើង ហើយសួរយើងថាចង់ចាក់ផ្សាយរាល់ថ្ងៃដែរឬទេ*។ វាអាចស្តាប់ទៅអស្ចារ្យណាស់ ប៉ុន្តែមានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយជាមួយការផ្លាស់ប្តូរប្រភេទនេះ។ ទីមួយ តម្លៃម៉ោងផ្សាយរបស់យើងនឹងឡើង៥០០%ភ្លាមៗ ហើយយើងបានត្រឹមតែអាចបង់ថ្លៃមួយថ្ងៃក្នុងមួយសប្តាហ៍តែប៉ុណ្ណោះទេពេលនោះ។ ទីពីរ យើងនឹងត្រូវផលិត និងកែសម្រួលកម្មវិធីចំនួនប្រាំក្នុងមួយសប្តាហ៍ ហើយយើងមិនទាន់មាននាយកដ្ឋានផ្នែកស្ថានីយទូរទស្សន៍នៅឡើយទេ។ នៅពេលនោះ យើងបានជួលកម្មវិធីទូរទស្សន៍របស់ក្រុមហ៊ុនមួយដែលនឹងចូលមក ហើយជួយថតកម្មវិធីចំនួនបួនក្នុងមួយសប្តាហ៍សម្រាប់ខែនោះ។ ពួកគេនឹងកាត់ត ហើយកែសម្រួលកម្មវិធី បញ្ជូនកម្មវិធីទៅក្នុងបណ្តាញ និងធ្វើការងារដទៃទៀតដែលទាក់ទងនឹងការងារនេះ។ ប៉ុន្តែបន្ទាប់មក ខ្ញុំបានដឹងថាយើងត្រូវមានសម្ភារៈទាំងអស់នោះដោយខ្លួនឯងដើម្បីរៀបចំវា។ ហើយបញ្ហាធំជាងគេនោះគឺថាឌ្រែនដា និងខ្ញុំ មិនដឹងពីរបៀបបង្កើតនាយកដ្ឋានផ្នែកស្ថានីយទូរទស្សន៍ទេ។ ប៉ុន្តែយើងបានព្យាយាមដោះស្រាយបញ្ហានោះ។

ដើម្បីបំពេញតាមខ្ទង់ថវិការបស់យើង ដោយយើងកំពុងតែបញ្ចប់ការសាងសង់បរិវេណក្រុមជំនុំ Now Center របស់យើង យើងមិនមានប្រាក់បន្ថែមសម្រាប់ការសាងសង់នាយកដ្ឋានផ្នែកស្ថានីយទូរទស្សន៍នៅឡើយទេ។ ខាងផ្នែកផលិតកម្ម យើងត្រូវទិញឧបករណ៍កាមេរ៉ា ហើយជួលបុគ្គលិកឱ្យកាន់កាមេរ៉ានោះ។ មានថ្ងៃខ្លះដែលមើលទៅហាក់ដូចជាមិនអាចទៅរួចសោះ។ ប៉ុន្តែព្រះជាម្ចាស់ស្មោះត្រង់ ហើយបានបន្តលើកទឹកចិត្តឌ្រែនដា និងខ្ញុំ ហើយយើងបានឆ្លងកាត់ការលំបាកទាំងអស់នោះ។

ឧបសគ្គដ៏ធំបំផុតរបស់យើងបានកើតឡើងប្រហែលបួនខែ នៅពេលដែលយើងដឹងថា យើងត្រូវចំណាយប្រាក់កន្លះលានដុល្លារសម្រាប់ម៉ោងផ្សាយរបស់យើង។

ការនោះពិតជាស្ថានភាពដ៏លំបាកខ្លាំងណាស់សម្រាប់យើង ព្រោះកម្មវិធីទូរទស្សន៍របស់យើងឈ្មោះ *ការដោះស្រាយរឿងរ៉ាវពាក់ព័ន្ធនឹងលុយកាក់*។

ខ្ញុំបានជញ្ជឹងគិត ថាតើយើងនឹងអាចធ្វើដំណើរការទូរទស្សន៍បានឬអត់។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចបន្តដោយសេចក្ដីសុចរិតបានទេ ប្រសិនបើខ្ញុំមិនអាចបង់ថ្លៃម៉ោងចេញផ្សាយទេនោះ។ ខ្ញុំបានតយុទ្ធជាមួយនឹងការសង្ស័យជាច្រើននៅពេលនោះ។ ប៉ុន្តែជាថ្មីម្តងទៀត ព្រះជាម្ចាស់ស្មោះត្រង់ ហើយឌ្រិនដាក៏បានលើកទឹកចិត្តខ្ញុំនៅពេលនោះដែរ។

ខ្ញុំបានយល់សប្តិមួយក្នុងសប្តាហ៍នោះ ព្រះជាម្ចាស់បានបង្ហាញខ្ញុំថា វិក្កយបត្រទាំងអស់នោះនឹងត្រូវបានបង់សរុបរួមតែមួយដងប៉ុណ្ណោះ។ ខ្ញុំបាននិយាយថា ជាធម្មតាវាមិនអាចទៅរួចទេ។ ប៉ុន្តែនៅចុងសប្តាហ៍នោះនៅឯក្រុមជំនុំ មានប្រាក់ចំនួន៥០០.០០០ដុល្លារបានចូលមក សម្រាប់ការចំណាយលើម៉ោងផ្សាយរហូតមកដល់ពេលបច្ចុប្បន្ននេះ ហើយបានមានដំណើរការតាំងពីពេលនោះមករហូតមកដល់ពេលនេះ។

វ៉ៅ វាគឺជាដំណើរការមួយដែលមិនគួរឱ្យជឿ!!!!

យើងទទួលបានការផ្លាស់ប្តូរតាមរយៈដំណើរការនោះ។ ឥលូវនេះ យើងធ្វើកម្មវិធីប្រចាំថ្ងៃ *ចំនួនពីរ* ហើយចំណាយប្រាក់រាប់លាន ដើម្បីផ្សាយដំណឹងល្អចេញទៅខាងក្រៅ។ ពេលយើងមើលត្រលប់ទៅក្រោយវិញអំពីអ្វីដែលយើងបានជួបនៅពេលនោះ យើងឃើញថាវាដូចជាមិនមែនជារឿងអ្វីធំដុំទេ។ អ្នកត្រូវចាំជានិច្ចនូវអ្វីដែលយើងបានរៀននៅក្នុងជំពូកទីមួយ៖ ព្រះគុណរបស់ព្រះជាម្ចាស់កំពុងធ្វើការជាមួយអ្នក! ការដើរជាមួយព្រះជាម្ចាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំពិតជាយល់ច្បាស់ថាហេតុអ្វីបានជាសំបុត្ររបស់លោកប៉ូលភាគច្រើនបានចាប់ផ្តើមឡើងដោយប្រើពាក្យថា៖

**«សូមព្រះគុណ និងសេចក្តីសុខសាន្តកើតមានដល់អ្នករាល់គ្នា មកពីព្រះព្រះវរបិតានៃយើង និងព្រះអម្ចាស់យេស៊ូគ្រិស្ត»។**

យើងត្រូវចាំថាយើងមិនឯកាទេ។ ព្រះគុណរបស់ទ្រង់ដែលបានផ្តល់អំណាចអធិធម្មជាតិ គឺកំពុងតែមានដំណើរការនៅក្នុងជីវិតរបស់យើង។ វាត្រូវការភាពក្លាហានក្នុងការនិយាយថា បាទ/ចាស៎ ហើយឈានជើងចូលទៅក្នុងអ្វីដែលយើងមិនធ្លាប់ស្គាល់ ប៉ុន្តែវាសក្តិសមនឹងឱ្យយើងធ្វើដូច្នេះ។ ខ្ញុំអាចថ្លែងទីបន្ទាល់អំពីរឿងនេះបាន។

គ្រីនដា និងខ្ញុំបានធ្វើដំណើរជុំវិញពិភពលោកដើម្បីផ្សព្វផ្សាយដំណឹងល្អ។ យើងបានឃើញការអស្ចារ្យទាំងឡាយដែលបានកត់ត្រានៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីកើតឡើងនៅចំពោះមុខយើងផ្ទាល់។ យើងបានឃើញជីវិតរបស់មនុស្សរាប់ពាន់នាក់បានផ្លាស់ប្តូរ ហើយបានបរិភោគផលពីដីដ៏ល្អបំផុត។ គ្មានកន្លែងណាដែលកក់ក្តៅជាងផ្ទះខ្លួនឯងនោះទេ!

ការអធិស្ឋានរបស់ខ្ញុំសម្រាប់អ្នក គឺសូមឱ្យអ្នកបានបរិបូណ៌នៅក្នុងគ្រប់កិច្ចការល្អដែលព្រះប្រទានឱ្យអ្នកធ្វើ ហើយអ្នកនឹងចងចាំថាការមានចិត្តសប្បុរសមានសារៈសំខាន់ប៉ុណ្ណា។

> សរុបសេចក្តីមក មានបទគម្ពីរមួយនៅក្នុងទំនុកតម្កើងដែលខ្ញុំចូលចិត្ត៖ *ចូរសរសើរតម្កើងព្រះអម្ចាស់! អ្នកណាគោរពកោតខ្លាចព្រះអម្ចាស់ហើយពេញចិត្តនឹងគោរពតាមព្រះបញ្ញត្តរបស់ព្រះអង្គ អ្នកនោះមានសុភមង្គលហើយ! ពូជពង្សរបស់គេនឹងមានអំណាចនៅក្នុងស្រុក ដ្បិតព្រះជាម្ចាស់នឹងប្រទានពរដល់មនុស្សទៀងត្រង់។ នៅក្នុងផ្ទះរបស់អ្នកនោះនឹងមានទ្រព្យសម្បត្តិស្តុកស្តម្ភ សេចក្តីសុចរិតរបស់គាត់នៅស្ថិតស្ថេររហូតតទៅ។ ក្នុងទីងងឹត មានពន្លឺលេចឡើង បំភ្លឺមនុស្សទៀងត្រង់ដែលមានចិត្តប្រណីសន្តោស អាណិតមេត្តា និងសុចរិត។ អ្នកណាមានចិត្តទូលាយ ហើយយករបស់ខ្លួនឱ្យគេខ្ចី ព្រមទាំង*

*រកស៊ីដោយទៀងត្រង់ អ្នកនោះប្រព្រឹត្តយ៉ាងល្អប្រពៃហើយ។ មនុស្សល្អនឹងបានសុខជានិច្ច គេនឹងរំឭកកេរ្តិ៍ឈ្មោះគាត់រហូតតទៅ។ គាត់នឹងមិនខ្លាចនរណានិយាយអាក្រក់ ពីគាត់សោះឡើយ គាត់មានចិត្តរឹងប៉ឹង ហើយផ្ញើជីវិតលើព្រះអម្ចាស់ទាំងស្រុង។ គាត់មានចិត្តនឹងន ឥតភ័យខ្លាចអ្វីទាំងអស់ រហូតទាល់តែបានឃើញខ្មាំងសត្រូវបរាជ័យ។ គាត់តែងចែកទានឱ្យអ្នកក្រដោយចិត្តទូលាយ សេចក្ដីសុចរិតរបស់គាត់នៅស្ថិតស្ថេររហូតតទៅ ហើយគាត់ចម្រើនកម្លាំងកាន់តែរុងរឿងឡើងៗ។ ពេលមនុស្សអាក្រក់ឃើញដូច្នេះ ក៏មានចិត្តទោមនស្ស គេសង្កៀតធ្មេញ ហើយរលាយសូន្យទៅ មនុស្សអាក្រក់ ពុំដែលបានសម្រេចដូចបំណងឡើយ។*

—ទំនុកតម្កើង ១១២:១-១០

ខ្ញុំស្រឡាញ់ផ្នែកដែលនិយាយថា*ពេលមនុស្សអាក្រក់ឃើញដូច្នេះ ក៏មានចិត្តទោមនស្ស។* ចុងក្រោយព្រះជាម្ចាស់តែងតែមានជ័យជម្នះ។ ជោគជ័យតែងតែជាការសងសឹកដ៏ល្អបំផុតមួយ។

ប្រសិនបើអ្នកដឹងរឿងរបស់ខ្ញុំ អ្នកនឹងដឹងថាខ្ញុំរៀននៅវិទ្យាល័យដោយមានពិន្ទុមធ្យមភាគ១.៣។ ពេលដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំឱ្យទៅមហាវិទ្យាល័យវិញ បន្ទាប់ពីទ្រង់បានហៅខ្ញុំឱ្យទៅផ្សាយដំណឹងល្អនោះ ខ្ញុំមិនបានរារែកទេ។

នៅក្នុងថ្នាក់ភាសាអង់គ្លេសឆ្នាំដំបូងរបស់ខ្ញុំ ខ្ញុំត្រូវសរសេរក្រដាសកិច្ចការមួយ។ សាស្ត្រាចារ្យរបស់ខ្ញុំបានប្រគល់វាមកឱ្យខ្ញុំវិញជាមួយនឹងអក្សរ «F» យ៉ាងធំនៅលើទំព័រមុខ ហើយបានមូលវិចារដោយនិយាយថា «តើវាអាចទៅរួចទេ ដែលអ្នកបានរៀននៅវិទ្យាល័យ?» ខ្ញុំចាំបាច់ត្រូវមានគ្រូបង្រៀនបំប៉នម្នាក់ជួយខ្ញុំឱ្យរៀនអ្វីដែលខ្ញុំមិនបានរៀននៅវិទ្យាល័យ។

ពេលដែលសៀវភៅដំបូងរបស់ខ្ញុំបានចេញផ្សាយ ខ្ញុំបានទទួលអ៊ីមែលពីសាស្ត្រាចារ្យភាសាអង់គ្លេសម្នាក់នោះ។ គាត់បាននិយាយថា «តើវាអាចទៅរួចទេ ដែលនេះជាហ្គារី ឃីស៊ី ដែលធ្លាប់នៅក្នុងថ្នាក់ខ្ញុំ?» គាត់ភ្ញាក់ផ្អើលជាខ្លាំងពេលដែលគាត់បានឃើញខ្ញុំសរសេរសៀវភៅមួយក្បាលនោះ។

**ត្រូវរៀនអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការ នោះអ្នកនឹងរីករាយជាមួយជីវិតដ៏ល្អដែលព្រះជាម្ចាស់បានសន្យា!**

ហេ៎ សូមអនុញ្ញាតឱព្រះជាម្ចាស់ និងអ្នកធ្វើឱ្យមានការភ្ញាក់ផ្អើលចំពោះមិត្តភក្តិទាំងអស់របស់អ្នក!

មានថ្ងៃមួយ មានមិត្តម្នាក់ដែលខ្ញុំធ្លាប់រៀនវិទ្យាល័យជាមួយ បានឈាងចូលលេងការិយាល័យក្រុមហ៊ុនហិរញ្ញវត្ថុរបស់ខ្ញុំ ហើយគាត់បាននិយាយថា «ខ្ញុំមិនយល់សោះ» ហ្គារីបានបោះបង់ការសិក្សាតាំងពីនៅវិទ្យាល័យមកម្ល៉េះ ហើយឥលូវនេះ ហេតុអ្វីបានជាគាត់កំពុងតែនៅលើកញ្ចក់ទូរទស្សន៍ជុំវិញពិភពលោកទៅវិញ?

ខ្ញុំពេញចិត្តរឿងបែបនេះណាស់ ហើយព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យរឿងបែបនេះដែរ! ដូច្នេះសូមចាំថា រឿងរបស់អ្នកមិនទាន់ចប់ទេ។ ចូរព្យាយាមធ្វើខ្លួនឱ្យមានចិត្តសប្បុរស ពេលអ្នកធ្វើជាតំណាងព្រះហឫទ័យសប្បុរសរបស់ទ្រង់នៅគ្រប់ទីកន្លែងដែលអ្នកទៅ។ ត្រូវរៀនអំពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ នោះអ្នកនឹងរីករាយជាមួយជីវិតដ៏ល្អដែលព្រះជាម្ចាស់បានសន្យា!

—ហ្គារី ឃីស៊ី

*ដ្បិតមុខងារប្រមូលប្រាក់នេះមិនត្រឹមតែជួយផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែមទាំងជួយគេឱ្យអរព្រះគុណព្រះជាម្ចាស់កាន់តែច្រើន*

*ឡើងទៀតផង។ ពេលគេយល់តម្លៃនៃកិច្ចការដែលបងប្អូនធ្វើនេះ គេនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះបងប្អូនសម្តែងឱ្យគេឃើញថា បងប្អូនពិតជាប្រតិបត្តិតាមដំណឹងល្អរបស់ព្រះគ្រិស្តដែលបងប្អូនប្រកាស ហើយបងប្អូនមានចិត្តទូលាយ ដោយយករបស់របរមកចែកជាមួយពួកគេ និងជាមួយមនុស្សទាំងអស់។ <u>គេទូលអង្វរព្រះជាម្ចាស់ឱ្យបងប្អូនដោយចិត្តស្រឡាញ់ ព្រោះតែព្រះគុណដ៏ច្រើនលើសលុបដែលព្រះជាម្ចាស់ប្រទានមកបងប្អូន។ សូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គ រកថ្លែងពុំបាន។</u>*

—២ កូរិនថូស ៩:១២-១៥

ប្រសិនសិនបើលោកអ្នកចង់ស្វែងយល់បន្ថែមអំពីក្រុមហ៊ុនហិរញ្ញវត្ថុឆ្ពោះទៅមុខ ( Forward Financial Group) ឬយុទ្ធសាស្ត្រក្នុងការវិនិយោគប្រាក់ដោយមានសុវត្ថិភាព សូមចូលទៅមើលគេហទំព័រ forwardfinancialgroup.com ឬទូរសព្ទមកយើងខ្ញុំតាមរយៈលេខ ១-(៨៨៨)-៣៩៧ ៣៣២៨។

ប្រសិនបើលោកអ្នកចង់ស្វែងយល់បន្ថែមអំពីសន្និបាតបដិវត្តន៍ហិរញ្ញវត្ថុ ឬចង់ទទួលរៀបចំសន្និបាតនេះ សូមទូរសព្ទមកយើងខ្ញុំតាមរយៈលេខ (៧៤០) ៩៦៥៨-៧៤០០ ហើយសួរផ្នែកការិយាល័យប្រតិបត្តិរបស់យើង។

## ព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យអ្នកទទួលបានព្រះពរ និងចម្រុងចម្រើន ដើម្បីឱ្យអ្នកអាចមានចិត្តសប្បុរសនៅគ្រប់ឱកាស!

អ្នកនឹងមិនមានសេរីភាពទេ រហូតដល់អ្នកមានសេរីភាពផ្នែកហិរញ្ញវត្ថុ។ ហើយដូចដែលខ្រិនដា និងខ្ញុំបាននិយាយនៅក្នុងពេលជាង ៣០ ឆ្នាំកន្លងមកនេះថា អ្នកនឹងមិនដែលរកឃើញថាអ្នកពិតជានរណា និងរស់នៅក្នុងគោលបំណងខាងវិញ្ញាណសម្រាប់ជីវិតរបស់អ្នកទេ លុះត្រាតែអ្នកដោះស្រាយរឿងលុយកាក់សិន។

**អ្នកអាចមានសេរីភាពបាន!**

ខ្ញុំបានបញ្ជាក់ពីការណ៍នោះ ហើយមនុស្សរាប់ពាន់នាក់ផ្សេងទៀតក៏បានបញ្ជាក់ដូច្នេះដែរ។ ព្រះគុណរបស់ព្រះជាម្ចាស់នៅដើម្បីចាំជួយអ្នកហើយ។ មានកិច្ចការដែលទ្រង់ត្រាស់ហៅឱ្យអ្នកធ្វើ ដែលអ្នកនឹងមិនដែលអាចសម្រេចបានទេ បើគ្មានហិរញ្ញវត្ថុ។ អ្នកត្រូវតែមានសេរីភាពផ្នែកហិរញ្ញវត្ថុ មិនត្រឹមតែសម្រាប់ខ្លួនឯង និងក្រុមគ្រួសារ ប៉ុន្តែដើម្បីឱ្យមនុស្សអាចមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការនៅក្នុងជីវិតរបស់អ្នក។

**មនុស្សកំពុងស្វែងរកចម្លើយ។ ពួកគេកំពុងស្វែងរកចម្លើយពិតប្រាកដ។ ពួកគេត្រូវការមើលឃើញព្រះរាជ្យជាខ្លាំង មិនមែនមើលឃើញសាសនាទេ។**

ព្រះជាម្ចាស់ទ្រង់ល្អ ហើយទ្រង់មានព្រះហឫទ័យសប្បុរស! នៅពេលដែលយើងមានចិត្តសប្បុរស យើងចែករំលែកព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់មនុស្ស។ ដូចជាការក្រេបទឹកដ៏ត្រជាក់នៅក្នុងថ្ងៃដ៏ក្ដៅមួយ ការមានចិត្តសប្បុរសនាំភាពធូរស្រាល និងក្ដីសង្ឃឹមទៅកាន់លោកិយមួយដែលស្ថិតនៅក្នុងវាលរហោស្ថាននៃភាពក្រីក្រ។

នៅក្នុងសៀវភៅទី៥ និងជាសៀវភៅចុងក្រោយនៃស៊េរីសៀវភៅ បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក ដែលនិពន្ធដោយលោកគ្រូហ្គារី ឃីស៊ី សូមរកឱ្យឃើញរបៀបដែលអ្នកអាចធ្វើជាដៃគូជាមួយព្រះជាម្ចាស់នៅក្នុង*កិច្ចការរបស់ទ្រង់* និងទទួលបទពិសោធនូវជោគជ័យក្នុងកម្រិតដ៏ថ្មីអស្ចារ្យ។

សូមទទួលបានការយល់ដឹងកាន់តែច្បាស់អំពីគោលការណ៍នៃព្រះរាជ្យដែលប្រកបដោយឫទ្ធានុភាពនៃចិត្តសប្បុរស និងរបៀបដែលវាដំណើរការនៅក្នុងសៀវភៅដ៏អស្ចារ្យនេ ដែលពោរពេញដោយការបើកសម្ដែងថ្មីស្រស់ស្រាយ ឧទាហរណ៍ដ៏មានអានុភាពពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងរឿងរ៉ាវជំរុញទឹកចិត្តផ្ទាល់ខ្លួនអំពីលោកគ្រូហ្គារី និងអ្នកផ្សេងទៀតដែលបានអនុវត្តនូវអំណាចនៃចិត្តសប្បុរសនៅក្នុងជីវិតរបស់គេផ្ទាល់ ហើយទទួលបានលទ្ធផលជាការផ្លាស់ប្រែដ៏អស្ចារ្យ។

**ចិត្តសប្បុរសបង្ហាញមនុស្សពីដួងចិត្តរបស់អ្នក និងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ។**



លោកគ្រូ ហ្គារី ឃីស៊ីជាអ្នកនិពន្ធ វាគ្មិន សហគ្រិន អ្នកជំនាញហិរញ្ញវត្ថុ និងគ្រូគង្វាលដែលមានចិត្តឆេះឆួលជួយមនុស្សឱ្យយកឈ្នះនៅក្នុងជីវិត ជាពិសេសនៅលើផ្នែកជំនឿ ក្រុមគ្រួសារ និងហិរញ្ញវត្ថុ។ លោកគ្រូហ្គារី និងភរិយា គឺអ្នកគ្រូខ្រិនដា បានបង្កើតអាជីវកម្មដ៏ជោគជ័យមួយចំនួន និងជាស្ថាបនិកនៃ Faith Life Now ដែលបង្កើតកម្មវិធីទូរទស្សន៍ពីរគឺ *ការដោះស្រាយរឿងលុយកាក់* និង *ខ្រិនដា* សន្និបាតទូទាំងពិភពលោក និងធនធានអនុវត្តជាច្រើន។ លោកទាំងពីរក៏ជាគ្រូគង្វាលនៃក្រុមជំនុំ Faith Life Church ក្បែរទីក្រុងកូឡុំប៊ីស រដ្ឋអូហៃយ៉ូ។

ប្រអប់សំបុត្រលេខ 779, New ALBANY, OH 43054
1.888.391.LIFE | garykeesee.com